មង្គលកថា

មង្គលទី ១៥

រៀបរៀងដោយ

ភិក្ខុសីលប្បញ្ញោ ឆែ សុផល្លី

ព.ស.២៥៥៧

មង្គលកថា

មង្គលទី ១៥

រៀបរៀងដោយ

ភិក្ខុសីលប្បញ្ញោ ឆែ សុផល្លី

ព.ស.២៥៥៧

ពុទ្ធប្បវត្តិសង្ខេប

ព្រះពុទ្ធមានព្រះនាមថាព្រះសទ្ធត្ថជាបុគ្គលប្រសើរបំផុតក្នុងលោក។ បិតាព្រះនាម សុទ្ធោទន:, មាតាព្រះនាម សិរិមហាមយា, ព្រះនគរឈ្មោះ កបិលពស្តុ, សព្វថ្ងៃជាប្រទេសនេប៉ាល បែកចេញពីឥណ្ឌា, ប្រសូតនៅថ្ងៃ សុក្រ ១៥ កើត ខែវិសាខ ឆ្នាំ ច, ត្រកូលជាក្សត្រ សក្យវង្ស តំណពីព្រះបាទ ឱក្កាកវាជ ប្អូនរួមបិតាព្រះនាម ព្រះនន្ទ មាតាផ្សេងគ្នាព្រះជន្ម ១៦ព្រះវស្សា មានអគ្គមហេសី ព្រះនាមពិម្ពាយសោធរា ព្រះជន្ម ២៩ ព្រះវស្សា រាហុលជាបុត្រប្រសូត និងទ្រង់ចេញសាងផ្នួសព្រះជន្ម ២៩ ព្រះវស្សា ត្រាស់ជា ព្រះពុទ្ធព្រះជន្ម ៣៥ ព្រះវស្សា ព្រះនាមថា សមណ:គោតម ។

ស្ថានទីគង់ចាំព្រះវស្សា

១-ឥសិបតនមិគទាយវ័ន, ២-៤ វត្តវេឡុវ័ន, ៥-កូដាគារសាលាមហាវ័ន ៦-មកុដបព៌តដែនមគធ:, ៧-ឋានតាវត្តិង្ស, ៨-កេសកទ្ធាវ័ន កគ្គរាជ-ជនបទ, ៩-ឃោសិតារាម, ១០-ព្រៃបាលិលេយ្យ ១១-ដងព្រៃជិតស្រុក សាលា លេយ្យក:,១២-ក្រោមដើមស្តៅជិតស្រុកវេរញ្ជា,១៣-ចាលិកប-ពត៌, ១៤-វត្តជេតពន ១៥- វត្តនិគ្រោធារាម, ១៦-ស្រុកអាឡវី, ១៧-វត្ត វេឡុវ័ន ១៨-១៩-ចាលិកបពត៌ ២០- វេឡុវ័ន, ២១-៤៤ វត្តជេតពន, ៤៥- ស្រុកវេឡុវគ្រាម ។

ព្រះជន្ម ៨០ ព្រះវស្សា ដាក់ព្រះជន្មាយុ និងបរិញ្ញានក្នុងនគរ កុសិនារា នៅថ្ងៃអង្គារ ១៥ កើត ខែវិសាខ ឆ្នាំម្សាញ់ ក្នុងវេលាជិតភ្លឺ ។ ទ្រង់ប្រតិស្ឋានព្រះពុទ្ធសាសនា ៥.០០០ ព្រះវស្សា រហូតរៀងមក ។

ទេវតាមួយម៉ឺនចក្រវាឡ ចុះមកអារាធនាសូមឱ្យព្រះអង្គសម្តែងមង្គល

រឿងមង្គលនេះទេវតាមួយម៉ឺនចក្រវាឡប្រើពេលអស់១២ឆ្នាំរកមង្គលតែរកមិនឃើញលុះដល់ព្រះអង្គបានត្រាស់ដឹងក៏នាំគ្នាចុះមកទូលសួរព្រះអង្គ ។ ព្រះអង្គបានសម្តែងមង្គលទាំង៣៨ប្រការមានកិរិយាមិនសេពគប់បុគ្គលពាលជាដើមរហូតដល់មានចិត្តក្សេមក្សាន្ត កាលចប់**ទេវតាសម្រេចជាព្រះអរហន្តរាប់សែនកោដិ ។ សម្រេចជាសោតាបត្តិផលសកទាគាមិផលអនាគាមិផលរាប់ប្រមាណមិនបាន ។**

មង្គលកថា

មង្គលទី ១៥

រៀបរៀងដោយ

ភិក្ខុសីលប្បញ្ញោ ឆែ សុផល្លី

វត្តនិគ្រោធវ័ន គល់ទទឹង

ព.ស.២៥៥៧

_ឈ្មោះសៀវភៅ មង្គលកថា មង្គលទី ១៥

_រៀបរៀងដោយ តិក្ខសីលប្បញ្ញោ ឆែ សុផល្លី

_អនុញ្ញាតឱ្យប្រើប្រាស់កុំព្យូទ័រដោយ **អគ្គចីវរ គង់ សុមិត្ត**

_ចេញផ្សាយ លើកទី ១

_កាលបរិច្ឆេទ ព.ស. ២៥៥៧

_ ទីកន្លែងធ្វើ វត្តនិគ្រោធវ័ន"គល់ទទឹង" ភូមិកោះក្របី

សង្កាត់ព្រែកថ្មី ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ

អារម្ភកថា

មនុស្សនៅលើសកលលោកយើងនេះ សុទ្ធតែជាអ្នកប្រាថ្នានូវសេចក្តីសុខចម្រើន សិរីសួស្តី សុភមង្គល ភាពសុខដុមរមនាគ្រប់គ្នា ៗទាំងអស់មិនចំពោះថា ជាតិសាសន៍ណាឡើយ មានអ្នកខ្លះព្រោះតែចង់បានសេចក្តីសុខ ចម្រើន សិរីសួស្តី សុភមង្គលដល់ជីវិតខ្លាំងពេកទៅ រហូតដល់ថ្នាក់ បន់ស្រន់បួងសួង អារក្សអ្នកតាទេវតា ព្រៃភ្នំ មន្តអាគមអូមអាមផ្សេង ៗនិងមានអ្នកខ្លះទៀតយល់ថា ទាល់តែមានទ្រព្យ សម្បត្តិស្តុកស្តម្ភ មានយសសក្តិខ្ពង់ខ្ពស់ មានគេគោរពលើកតម្កើង បរិវារ បៃហាម ចោមរោម ការពារគ្រប់ជំហានជាដើម ទើបជីវិតមាននៅសិរី សួស្តីសុភមង្គល ។ ទង្វើទាំងអស់នេះ វាផ្ទុយស្រឡះអំពីគន្លងនៃព្រះពុទ្ធសាសនាទាំងស្រុង ។

នៅក្នុងព្រះធម៌របស់ព្រះអង្គទាំង ៨៤,០០០ ព្រះធម្មខន្ធ ដែលមាននៅក្នុងគម្ពីរព្រះត្រៃបិដកទាំង ១១០ ក្បាល ដោយព្រះអង្គសម្តែងអស់រយៈពេល ៤៥ ព្រះវស្សានោះ ទាំងសម្តែងឋានទេវតា ឋានមនុស្សគ្រប់ស្រុកតំបន់ផ្សេង ៗនោះ មានព្រះសូត្រមួយឈ្មោះថា **មង្គលសូត្រ** ដែលជាព្រះសូត្រសម្តែងអំពីវិធីបដិបត្តិនាំឱ្យកើតនូវសិរីសួស្តី សុភមង្គលដ៏ខ្ពង់ខ្ពស់ត្រឹមត្រូវនៃជីវិត ។ និងជាព្រះសូត្រដែលព្រះអង្គសម្តែងបើកបង្ហាញដល់មនុស្សនិង

ទៅតានាសម័យនោះ ។ ព្រះសូត្រនេះសំខាន់ខ្លាំងណាស់ សម្រាប់អ្នកដែលប្រាថ្នានូវសិរីសួស្តីដល់ខ្លួនឯង ក្រុមគ្រួសារ ញាតិមិត្ត បងប្អូន និងសង្គមជាតិទាំងមូល ។ ព្រោះព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សម្តែងចំតែម្តង អំពីវិធីបដិបត្តិនាំឱ្យកើតនូវសិរីសួស្តី សុភមង្គលដ៏ឧត្តមនៃជីវិត ។

នៅក្នុងអដ្ឋកថា **មង្គលជាតក** បានពោលអំពីព្រាហ្មណ៍ម្នាក់អ្នកនៅក្នុងក្រុងនគរវាជគ្រឹះ ជាអ្នកប្រកាន់មង្គលភ្ជាក់ផ្អើលមិនជ្រះថ្លាក្នុងព្រះរតនត្រ័យ ជាបុគ្គលមិច្ឆាទិដ្ឋិ មានភោគសម្បត្តិច្រើន ។

ក្នុងកាលនោះកណ្តុរបានកាត់នូវសម្ពត់សាជកមួយគូរបស់គាត់ ។ ដល់ពេលគាត់ត្រូវការឱ្យគេយកសំពត់នោះមក ទើបដឹងថាត្រូវកណ្តុរកាត់ដាច់ជាអន្លើ ៗទៅហើយ ។ ព្រាហ្មណ៍គិតថា សំពត់នេះជាអពមង្គល បើទុកនៅនឹងផ្ទះនាំឱ្យមានការវិនាសយ៉ាងក្រៃលែង គឺវាដូចជាកាឡកណ្ណីមួយអ៊ីចឹង ទាំងមិនអាចឱ្យដល់បុត្រធីតាឬទាសកម្មករផង ព្រោះសេចក្តីវិនាសនឹងកើតដល់អ្នកទទួលសំពត់នោះទៅគ្រប់គ្នា ត្រូវយកទៅចោលក្នុងព្រៃខ្មោចទើបបាន ។

ព្រាហ្មណ៍មិច្ឆាទិដ្ឋិ មិនឱ្យពួកទាសកម្មករយកទៅចោលទេ ដោយខ្លាចពួកទាសកម្មករ នាំយកនូវសំពត់នោះទៅប្រើប្រាស់បណ្តាលឱ្យវិនាសត ៗគ្នា ។ ទើបព្រាហ្មណ៍ប្រាប់ឱ្យកូនប្រុសរបស់គាត់យកឈើឆ្កឹះទាក់នូវសំពត់នោះ នាំទៅចោលនៅព្រៃខ្មោច ហើយត្រូវងូតទឹកមុជឱ្យលិចក្បាលសឹមត្រឡប់មកផ្ទះវិញ ។

ព្រះបរមសាស្តាសម្មាសម្ពុទ្ធគង់ប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ជ្រាបឧបនិស្ស័យនៃព្រាហ្មណ៍ពីរនាក់ឪពុកនិងកូន ព្រះអង្គបានយាងទៅកាន់ព្រៃខ្មោចនោះ ហើយទ្រង់កាន់យកនូវសំពត់សាជកដែលកូនប្រុសរបស់ព្រាហ្មណ៍បានចោលហើយ ទាំងដែលកូនប្រុសនោះឃាត់ព្រះអង្គមិនឱ្យចាប់ ដោយអាងថា ជារបស់ចម្រៃ ។ ព្រះបរមសាស្តាទ្រង់កាន់យកនូវសំពត់មួយគូរនោះ រួលត្រឡប់មកកាន់វត្តវេឡុវ័នវិញ ។

កាលដែលកូនប្រុសត្រឡប់មកជម្រាបរឿងរ៉ាវ ដល់ឪពុកហើយ ឪពុកនិងកូនក៏ប្រញាប់នាំគ្នាទៅវត្តវេឡុវ័ន ដើម្បីសូមឱ្យព្រះសម្មាសម្ពុទ្ធចោលនូវសំពត់នោះទៅវិញ ។ ព្រាហ្មណ៍គិតថា បើព្រះសមណគោតម ប្រើសំពត់នេះទៅ វាត្រូវធ្វើឱ្យលំបាកដល់ព្រះអង្គផង ត្រូវវិនាសវត្តវេឡុវ័នផង ម្ល៉ោះហើយគេនិងនិន្ទាស្តីថា

មកដល់យើងជាពិតប្រាជក ដូច្នេះ យើងត្រូវយកសំពត់សាជក ថ្មី ៗទៅថ្វាយដល់ព្រះសមណគោតម ដើម្បីសូមឱ្យព្រះសមណ គោតម ចោលនូវសំពត់ចង្រៃនោះ ។

នៅពេលដែលព្រាហ្មណ៍ឪពុកនិងកូនប្រុសបានទៅដល់វត្ត ហើយ ព្រាហ្មណ៍ជាឪពុកបានក្រាបទូលព្រះសម្មាសម្ពុទ្ធដោយ សព្វគ្រប់ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពួក យើងមានឈ្មោះថាជាបព្វជិតដូច្នេះសំពត់ចាស់ ៗដែលគេចោល នៅព្រៃខ្មោច ឬគំនរសម្រាមជាដើម រមែងសមគួរដល់ពួកយើង ឯចំណែកព្រាហ្មណ៍ឯង មិនមែនទើបតែឥឡូវនេះទេ ពីជាតិមុន មក ក៏ធ្លាប់ប្រកាន់នូវលទ្ធិដូច្នេះដែរ ។

កាលដែលព្រាហ្មណ៍អារាធនាហើយ ព្រះអង្គទ្រង់ត្រាស់ សម្តែងនូវរឿងរ៉ាវអតីតជាតិ មានសេចក្តីប្រហែលគ្នានឹងបច្ចុប្បន្ន ដែរគ្រាន់តែកាលណោះ ព្រះបរមពោធិសត្វជាតាបសបានឈាន ហើយប្រោសព្រាហ្មណ៍ឯព្រាហ្មណ៍ក៏បានយកព្រះបរមពោធិសត្វ ជាសរណៈ ។

នៅក្នុងបិដកលេខ ៥៨ ទំព័រ ៣៨ **មង្គលជាតក** ព្រះ បរមសាស្តាទ្រង់ត្រាស់ថា ៖

មង្គលទាំង៦ប្បាយក្តី ឧត្បាតទាំង៦ប្បាយក្តី សុបិនទាំង៦ប្បាយក្តី លក្ខណៈទាំង៦ប្បាយក្តី ដែលបុគ្គលណាបានផ្តាច់បង់ហើយ បុគ្គលនោះឈ្មោះថា អ្នកកន្ថង់ផុតនូវទោសនៃមង្គល(ភ្ជាក់ផ្អើល) ។ ជាអ្នកគ្របសង្កត់នូវយុគក្លិសៈ(ក្រោធ ១ ការចងគំនុំ ១ ការមិលគុណ ១ និងការវាយឫកស្មើ ១ ទាំង ៤ នេះ ហៅថា យុគក្លិសៈ)និងយោគក្លិសៈ(កាមយោគ ១ ភវយោគ ១ ទិដ្ឋិយោគ១អវិជ្ជាយោគ ១)រមែងមិនមកកើតទៀតឡើយ ។

ដោយសេចក្តីថា បុគ្គលណាមិនប្រកាន់មង្គលភ្ជាក់ផ្អើល មិនប្រកាន់ឧត្បាត មិនប្រកាន់ការយល់សប្តិ មិនប្រកាន់លក្ខណៈជោគល្អ ឬជោគអាក្រក់ បុគ្គលនោះឈ្មោះថា ជាអ្នកកន្ថង់ផុតនូវទោសនៃការប្រកាន់មង្គលភ្ជាក់ផ្អើល ។

ព្រះបរមសាស្តា ទ្រង់សម្តែងធម៌ឱ្យព្រាហ្មណ៍ឪពុក និងកូនបានសម្រេចសោតាបត្តិផល ។

នៅក្នុងអដ្ឋកថា**នក្ខត្តជាតក** បានពោលអំពីត្រកូលមួយនៅក្រៅក្រុងសាវត្ថី បានទៅស្តីដណ្តឹងកុលធីតាម្នាក់នៅក្នុងក្រុងសាវត្ថី ដើម្បីជាប្រយោជន៍ដល់កូនប្រុសរបស់ខ្លួន ។ គេបានសន្យាថ្ងៃកំណត់មកទទួលយកកូនកូនស្រីទៅកាន់ត្រកូលខាងប្រុសប៉ុន្តែ

លុះដល់ថ្ងៃកំណត់ ត្រកូលខាងប្រុសគេបានសួរអាជីវកម្នាក់ដែលបានចូលទៅកាន់ត្រកូលរបស់ខ្លួនថា លោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះពួកខ្ញុំនឹងធ្វើនូវមង្គលមួយ តើនក្ខត្តឫក្សល្អដែរទេ ?

អាជីវកមានការខឹងក្រោធជាខ្លាំង ព្រោះគិតថាពួកអស់នេះមិនសួរយើងពីដំបូង ឥឡូវដល់ថ្ងៃទៅហើយទើបតែសួរ យើងនឹងផ្តល់មេរៀនឱ្យគេម្តង ដូច្នេះហើយក៏ពោលថា ថ្ងៃនេះមិនល្អទេ អ្នកទាំងអស់គ្នាកុំធ្វើមង្គលឡើយ បើចេះតែធ្វើនឹងមានការវិនាសធំ ។ ពួកមនុស្សក្នុងត្រកូលក៏ជឿអាជីវកនោះ ហើយក៏មិនបានទៅទទួលយកកូនស្រីក្នុងថ្ងៃហ្នឹងឡើយ ។

ចំណែកត្រកូលខាងស្រី បានចាត់ការមង្គលរៀបចំទទួលភ្ញៀវខាងប្រុស លុះមិនឃើញពួកគេមកតាមសន្យា ក៏លើកធីតាឱ្យទៅត្រកូលដទៃសម្រេចស្រេចបាច់ក្នុងថ្ងៃនោះដែរទៅ ។

ថ្ងៃស្អែកឡើង ត្រកូលក្រៅក្រុងក៏បាននាំគ្នាមកដល់សូមយកកូនស្រីពួកអ្នកក្នុងក្រុងក៏ពោលតិះដៀលថា ពួកអ្នកឯងសមនឹងឈ្នោះ អ្នកក្រៅក្រុងមែនហើយ ជាមនុស្សខ្វះសម្បត្តិរបស់មនុស្សល្អ ជាមនុស្សអាក្រក់ សន្យាគ្នាហើយ មើលងាយពាក្យសន្យា មិនមកតាមកំណត់ អញ្ជើញទៅតាមផ្លូវដែលអ្នករាល់គ្នា

មកនោះវិញទៅ ពួកយើងលើកកូនស្រីយើងឱ្យអ្នកផ្សេង ៗទៅ
ហើយ ។

ពួកអ្នកក្រៅក្រុង ខំប្រឹងឈ្លោះនឹងអ្នកក្រុងអស់មួយសន្ទុះ
ធំ លុះដឹងប្រាកដថា មិនបានកូនក្រមុំពិតហើយ ក៏នាំគ្នាត្រឡប់
ទៅវិញតាមផ្លូវដែលមកនោះឯង ។

រឿងទាំងអស់នេះបានជ្រាបដល់ព្រះមានព្រះភាគ ព្រះអង្គ
ទ្រង់ត្រាស់ព្រះជាតក ពីអាជីវកនោះធ្លាប់បំផ្លាញមង្គលរបស់គេ
តាំងពីជាតិមុនមកហើយ ។

ក្នុងជាតិមុននោះ អ្នកក្រុងពារាណសី ទៅស្តីដណ្តឹងកូនស្រី
អ្នកជនបទហើយមិនទៅតាមសន្យា ព្រោះថាជឿតាមពាក្យកុហក
របស់អាជីវក ។ រឿងរ៉ាងមានទំនងដូចគ្នា ខុសត្រង់ថាអ្នកជនបទ
បានតិះដៀលអ្នកក្រុងពារាណសីថា ពួកអ្នករាល់គ្នាឈ្មោះថាជា
អ្នកក្រុង ប៉ុន្តែខ្វះនូវសម្បត្តិរបស់មនុស្សល្អ ព្រោះមិនគោរពាក្យ
សន្យា ។ ក្នុងកាលណោះ ព្រះបរមពោធិសត្វជាបណ្ឌិត បាន
ពោលថា ផ្កាយទាំងឡាយនិងមានប្រយោជន៍អ្វី ព្រោះការបាន
កូនស្រីក្រមុំជាឫក្សស្អាតស្រេចទៅហើយ មិនមែនទេ ? រួចហើយ
ទើបព្រះបរមពោធិសត្វពោលនូវគាថា ៖

នៅក្នុងបិដកលេខ៥៨ទំព័រ ២២ **នក្ខត្តជាតក** បណ្ឌិតបុរសពោធិសត្វពោលថា ៖

នក្ខត្តំ បដិមានេន្តំ អត្ថោ ពាលំ ឧបច្ចគា

អត្ថោ អត្តស្ស នក្ខត្តំ កឹ ករិស្សន្តិ តារកាតិ ។

ប្រែថា៖ ប្រយោជន៍រមែងកន្ធងបង់នូវមនុស្សល្ងង់ដែលរាប់អាននូវនក្ខត្តឫក្ស ប្រយោជន៍ជានក្ខត្តឫក្សរបស់ប្រយោជន៍ ឯផ្កាយទាំងឡាយនឹងធ្វើអ្វីបាន ។

បណ្តាបទទាំងនោះ បទថា **បដិមានេ្តន** ដោយសេចក្តីថា អ្នករង់ចាំមើលអធិប្បាយថា រង់តែរង់ចាំមើល នក្ខត្តឫក្សនឹងមានក្នុងពេលនេះ នឹងមានក្នុងកាលឥឡូវនេះ ។

បទថា **អត្ថោពាលំឧបច្ចគា** ដោយសេចក្តីថា ប្រយោជន៍ពោលគឺការបាននូវកូនក្រមុំ កន្ធងផុតនូវមនុស្សល្ងង់ដែលជាអ្នកក្រងពាពណាសីនោះ ។

បទថា **អត្ថោអត្តស្ស នក្ខត្តំ** ដោយសេចក្តីថា បុគ្គលស្វែងរកនូវប្រយោជន៍ណា ប្រយោជន៍ដែលគេបានហើយនោះឯង ឈ្មោះថាជានក្ខត្តឫក្សរបស់ប្រយោជន៍ ។

បទថា **កឹ ករិស្សន្តិ តារកា** ដោយសេចក្តីថា តើដួងផ្កាយ

ទាំងឡាយក្នុងអាកាសក្រៅអំពីនេះ នឹងញុំាងប្រយោជន៍ដូចម្តេច ឱ្យសម្រេចបាន ។

ម្យ៉ាងទៀត នៅក្នុងបិដកលេខ ៤១, ទំព័រ ៤៧៥ ត្រង់ **មគ្គលវគ្គ** ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្ត ក្នុងវេលាបុព្វណ្ហសម័យ(ពេលព្រឹក) សត្វទាំងនោះ ឈ្មោះថា **មានបុព្វណ្ហសម័យដ៏ល្អ** ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចា ប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាមជ្ឈន្តិកសម័យ(ពេលថ្ងៃ) សត្វទាំងនោះឈ្មោះថា **មានមជ្ឈន្តិកសម័យដ៏ល្អ** ។ ម្នាលភិក្ខុទាំងឡាយ សត្វទាំងឡាយប្រព្រឹត្តសុចរិតដោយកាយ ប្រព្រឹត្តសុចរិតដោយវាចាប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាសាយណ្ហសម័យ(ពេលល្ងាច) សត្វទាំងនោះឈ្មោះថា សាយណ្ហសម័យដ៏ល្អ ។

សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ ។

ពេលណាដែលសត្វទាំងឡាយ ប្រព្រឹត្តល្អដោយកាយ វាចា ចិត្ត ពេលនោះឈ្មោះថា នក្ខត្តឫក្សល្អ មង្គលល្អ ពេលភ្លឺស្វាងល្អ ពេលនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ (ទានដែលបុគ្គលបូជា) ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះ) ឈ្មោះថា ជាគ្រឿងបូជាល្អ ។

បឋក្ខិណំ កាយកម្មំ វាចាកម្មំ បឋក្ខិណំ

បឋក្ខិណំ មនោកម្មំ បណិធី តេ បឋក្ខិណា ។

(ក្នុងថ្ងៃនោះ) កាយកម្មឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន វចីកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន មនោកម្មក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន សេចក្តីប្រាថ្នារបស់អ្នកទាំងនោះ ក៏ឈ្មោះថា នាំឱ្យមានសេចក្តីចម្រើន ។

បឋក្ខិណានិ កត្វាន លភន្តត្ថេ បឋក្ខិណេ ។

បុគ្គលដែលបានធ្វើនូវកាយកម្ម វចីកម្ម មនោកម្មគួរដល់សេចក្តីចម្រើនហើយ រមែងបាននូវប្រយោជន៍ដ៏ចម្រើនទាំងឡាយ ។

នៅក្នុង**មង្គល**សូត្រនេះ ព្រះអង្គបានសម្តែងមានទាំងអស់ ១០ ព្រះគាថា ។ ក្នុងមួយគាថា មាន ៣ ក៏មាន ៤ ក៏មាន ៥ ក៏មាន ។ ព្រោកជាមាតិកា មានទាំងអស់ ៣៨ ប្រការ ដែលខាង

ដើម ព្រះអង្គទ្រង់ត្រាស់សម្តែងថា **អាសេវនា ច ពាលានំ** មិនឱ្យសេពគប់បុគ្គលពាល រហូតដល់ខាងចុងថា **ខេមំ** ធ្វើចិត្តឱ្យឃ្លាតចាកអំពីកិលេស ដែលហៅថា **ចិត្តក្បែរមក្សាន្ត** ។

សរុបមក បើបុគ្គលណាប្រាថ្នានូវសិរីសួស្តី សុភមង្គល ភាពសុខដុមរមនាដល់ខ្លួនដល់ក្រមគ្រួសារជាដើមនោះត្រូវព្យាយាមបដិបត្តិទៅតាមមង្គលទាំង ៣៨ ប្រការនេះចុះ, ឬថា ត្រូវប្រព្រឹត្តឱ្យល្អទៅតាមផ្លូវកាយ វាចា ចិត្ត ឱ្យបានជានិច្ចចុះ នុ៎ះសិរីសួស្តី សុភមង្គល សេចក្តីសុខចម្រើន នឹងកើតមានដល់បុគ្គលនោះឯង ។

សៀវភៅ **មង្គលកថា** ដែលនិយាយអំពីមង្គលទាំង ៣៨ ប្រការនេះ ខ្ញុំព្រះករុណាសម្បីមថា នឹងបានជួយតម្រែតម្រង់មាគ៌ាជីវិតនៃពុទ្ធបរិស័ទគ្រប់វ័យ គ្រប់ស្រទាប់វណ្ណៈទាំងអស់ ឱ្យដើរឈានទៅរកសេចក្តីសុខ និងការកែចម្រើននៃជីវិតទាំងនៅក្នុងបច្ចុប្បន្ន ទាំងក្នុងបរលោកនាយ រហូតដល់អស់នូវអាសវៈកិលេស ។

ម្យ៉ាងទៀត សៀវភៅនេះ បើសិនជាមានខុសត្រង់អក្ខរៈព្យញ្ជនៈកាសាបាលីសេចក្តីអធិប្បាយត្រង់ចំណុចណាមួយនោះ

សូមមេត្តាខន្តី អភ័ព្វទោសផង ។

ដោយអំណាចមហាកុសលចេតនា ដែលខ្ញុំមានចិត្តជ្រះថ្លា ក្នុងព្រះសទ្ធម្មរបស់ព្រះអង្គ ទិតទំាកសាងសន្សំព្យាយាមធ្វើសៀវ-ភៅនេះ សូមបានជាឧបនិស្ស័យដ៏ល្អបានពាល់ត្រូវនូវព្រះនិព្វានក្នុងពេលដ៏ខ្លីខាងមុខនេះផងចុះ តែបើមិនទាន់បានសម្រេចទេ សូមកើតជាតិណា ៗក៏ដោយ សូមកុំឱ្យស្គាល់ពាក្យថាអត់ ពាក្យថាគ្មាន ពាក្យថាក្រ ពាក្យថាលំបាក និងសូមឱ្យមានតែសិរីសួស្តី មិនមានសេចក្តីប្រមាទក្នុងជីវិត និងសូមឱ្យខ្ញុំមានបញ្ញាមោះមុតឆាប់ចាក់ធ្លុះនូវអរិយសច្ចធម៌ បានដល់នូវអមតដ្ឋាន **ក្នុងសាសនានៃព្រះសិរីអារ្យមេត្រីយ៍** កុំបីអាក់ខានឡើយ,ម្យ៉ាងទៀតសូមឧទ្ទិសបុណ្យកុសលនេះ ជូនដល់បុព្វការីជនទាំងឡាយ ដែលបានបែកធ្លាយរាងកាយទៅ និងពួកសត្វទាំងឡាយផង សូមបាននូវសេចក្តីសុខ ចូរជាអ្នកបានសោយរសនៃព្រះសទ្ធម្មរបស់ព្រះមានព្រះភាគចុះ មួយអន្ទើយដោយព្រះកុរុណាគុណម្ចាស់គ្រប់ព្រះអង្គ និងញាតិញោមពុទ្ធបរិស័ទ ។

សូមអនុមោទនា !!!

ថ្ងៃ៧កើត ខែពិសាខ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស. ២៥៥៧

ភិក្ខុសីលប្បញ្ញោ ឆៃ សុផល្លី

បញ្ជីមាតិកា

មាតិកា	មជ្ឈឈកថា	ទំព័រ
អារម្ភកថា	... ...	ក
មជ្ឈឈនី ១៥ បំពេញ្ញទាន	... ...	១
ទានគឺជាអ្វី	... ...	១
ប្រភេទរបស់ទាន	... .	៥
គោលបំណងនៃការធ្វើទាន	... ...	៦
គតិជាសត្វតើនចិត្ត	... ...	៨
ទានដែលឱ្យហើយមិនបានបុណ្យ	... ...	៩
វិធីធ្វើទានឱ្យបានបុណ្យច្រើន	... ...	១០
ស្រែមានលក្ខណៈ៨ ប្រការ	... ...	១២
អាហុណេយ្យសូត្រ	... ...	១៦
ទេវហិតសូត្រ	... ...	១៨
ឥស្សត្តសូត្រ	... ...	២៧
ហេតុនាំឱ្យធ្វើទាន	... ...	៤២
បឋមទានសូត្រ	... ...	៤៣
ទានូបបត្តិសូត្រ	... ...	៤៧
ទានវត្ថុសូត្រ	... ...	៥១
អសប្បុរិសទានសូត្រ	... ...	៥៣

មាតិកា **ទំព័រ**

ព្រាហ្មណសូត្រ ៥៦
ហេតុនាំឱ្យធ្វើទានមាន ៨ យ៉ាង ៥៨
ហេតុនាំឱ្យធ្វើទាន ៨ យ៉ាងទៀត ៥៩
ហេតុនាំឱ្យធ្វើទាន ៨ យ៉ាងទៀត.... .... ៦០
សប្បុរិសទានសូត្រ ៦១
រឿងពាពណសីសេដ្ឋីបុត្រ ៦៤
ហេតុឱ្យទានមិនបាននិងទោសនៃសេចក្តីកំណាញ់ ៦៦
អាទិត្តវគ្គមច្ឆរិសូត្រ ៦៩
សតុល្លប្បកាយិកាវគ្គ មច្ឆរិសូត្រ ៧៧
បឋមាបុត្តកសូត្រ ៩៥
ទុតិយាបុត្តកសូត្រ ១០៣
រឿងសេដ្ឋីអ្នកមិនមានបុត្រ ១១២
ពាក្យរបស់នាងរេវតីនៅក្នុងនរក ១១៩
គិតមើលទៅ ១២១
មច្ឆរិយសូត្រ ១២២
ភោគសូត្រ ១២៥
ទានដែលមានផលច្រើន ១២៧
ទក្ខិណាសូត្រ ១២៨

មាតិកា **ទំព័រ**

សេចក្ដីបន្ថែមនៃទក្ខិណាទាន ១៣២
បុណ្យទក្ខិណានុប្បទាន ១៣៤
កាលទានសូត្រ ១៣៨
រឿងអង្កុរទេវបុត្រ ១៤១
សេក្ខបរិហានិយវគ្គទានសូត្រ ១៤៥
ដីកាពន្យល់ ១៥១
មង្គលត្ថទីបនី ១៥២
វនរោបសូត្រ ១៥៣
បឋមសប្បុរិសទានសូត្រ ១៥៧
សម្មុខីសូត្រ ១៦០
វេលាមសូត្រ ១៦២
សង្ឃទាន ១៨៩
ទារុកម្មិកសូត្រ ១៩០
ទក្ខិណាវិភង្គសូត្រ ១៩៤
ការសរុបសេចក្ដីរឿងទានក្នុងសូត្រនេះ ២៤០
បាដិបុគ្គលិកទានមាន ១៤ ... ... ២៤០
សង្ឃគតាទក្ខិណាទានមាន ៧ ... ... ២៤២

មាតិកា ទំព័រ

អធិប្បាយបាដិបុគ្គលិកទាន ២៤៤
អធិប្បាយសង្ឃគតាទក្ខិណាទាន ២៥៣
ដីកាទក្ខិណាវិភង្គសូត្រនោះថា ២៥៧
អានិសង្សនៃការធ្វើទាន ២៦០
សីហសូត្រ ២៦១
ប្រវត្តិសង្ខេបរបស់សីហសេនាបតី ២៦៨
ទានានិសង្សសូត្រ ២៨៨
បុត្តសូត្រ ២៩០
ឧគ្គហសូត្រ ២៩៥
ចុន្ទីសូត្រ ៣០២
បុញ្ញាភិសន្ទសូត្រ ៣០៧
សាធុសូត្រ ៣០៨
តតិយវគ្គ ទានសូត្រ ៣២២
ភោជនទានសូត្រ ៣២៩
អាទិត្តសូត្រ ៣៣១
សុទត្តសូត្រ ៣៣៥

មាតិកា **ទំព័រ**

កិន្ទទសូត្រ ៣៣៨
ឱទយសូត្រ ៣៤៤
រឿយ ៗ ១៦យ៉ាង ៣៥២
អន្ធសូត្រ ៣៥៣
សុមនសូត្រ ៣៥៥
រឿងទេពធីតា ២៥ រូប ៣៧៣
វណិជ្ជសូត្រ ៣៧៦
រឿងសេដ្ឋីឈ្មោះពិឡាលបទកៈ ៣៨២
បណ្ឌិតធ្វើទានដោយខ្លួនឯង រមែងបានទ្រព្យយ៉ាងនេះ.... ៣៨៩
បណ្ឌិតបបួលអ្នកដទៃឱ្យធ្វើទាន ៣៩០
រឿងអបុត្តកសេដ្ឋីធ្វើទានស្តាយក្រោយ ៣៩០
លក្ខណសូត្រ ៣៩១
សាលសូត្រ ៣៩៧
មហាសាលសូត្រនិងអដ្ឋកថា ៤០០
សេរីសូត្រ ៤១៤
មនាបទាយីសូត្រ ៤១៥

មាតិកា **ទំព័រ**

ប្រវត្តិសង្ខេបរបស់ឧគ្គគហបតី ៤២២
ប្រភេទនៃការធ្វើទានផ្សេង ៗ ៤២៨
មានទានពួកដទៃទៀត ៤៣១
មានទានពួកដទៃទៀត ៤៣៣
សរុបទាន ៤៣៥
ព្រះគាថាសម្ដែងអំពីទាន ៤៣៦
អនុមោទនាវិសាខាគាថា ៤៤០
អានិសង្សរបស់ទាន ១៨ យ៉ាងគឺ ៤៤១
អានិសង្សរបស់ទានមួយទៀត ៤៤៤
អានិសង្សថ្វាយបាយជាទាន ៤៤៥
អានិសង្សថ្វាយបាយដ៏ប្រសើរ ៤៤៦
អានិសង្សថ្វាយបាយមួយវែក ៤៤៦
អានិសង្សថ្វាយទឹកដោះគោជាទានមាន ៥ ប្រការ ... ៤៤៧
អានិសង្សថ្វាយទឹកជាទាន ៤៤៧
អានិសង្សថ្វាយភេសជ្ជៈជាទាន ៤៤៨
អានិសង្សថ្វាយទឹកឃ្មុំជាទាន ៤៤៩
អានិសង្សថ្វាយសប្បិជាទាន ៤៤៩

មាតិកា **ទំព័រ**

រឿងព្រះបាទនន្ទរាជ … … … … … … … … … … … … ៤៥០
រឿងព្រះទេវីព្រះនាមគោបាលមាតា … … … … … … … ៤៥៤
អានិសង្សបុណ្យទាន … … … … … … … … … … … … ៤៥៧
គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ ៤៦៣

មង្គលទី ១៥ បំពេញទាន

ដើមឈើដែលមានផ្លែនិងមួយដ៏ត្រជាក់ក្រៅអំពីបានឈ្មោះថា ជាដើមឈើមានសារៈប្រយោជន៍ហើយ រមែងបានទទួលការមើលថែរក្សាដោយការដាក់ជីជ្រួយដ៏ខ្លាំង ។ឡើយយ៉ាងណា អ្នកដែលដឹងអំពីផលនៃការឱ្យទាន ក្រៅអំពីបានឈ្មោះថា ជាមនុស្សមានប្រយោជន៍ហើយ រមែងបានទទួល ការលើកសរសើរ គាំទ្រពីមនុស្សទាំងឡាយទៀតផង ។

ទានគឺជាអ្វី?

ឈ្មោះថា **ទាន** ព្រោះគេឱ្យដោយវត្ថុនេះ លោកអធិប្បាយថា គេប្រគល់ទ្រព្យដែលមាននៅរបស់ខ្លួនឱ្យដល់អ្នកដទៃ ។

ចំណែកការពណ៌នាសេចក្តីគប្បីជ្រាបដូច្នេះ ។ ចេតនាជាហេតុបរិច្ចាគទានវត្ថុ ១០ មានបាយជាដើម ដែលមានការជឹងច្បាស់ជាប្រធានចំពោះអ្នកដទៃ ឬ សេចក្តីមិនលោភ ដែលប្រកបដោយចេតនានោះឈ្មោះថា **ទាន** ។ មែនពិតបុគ្គលរមែងប្រគល់ឱ្យនូវវត្ថុនោះដល់អ្នកដទៃដោយសេចក្តីមិនលោភ ។ ព្រោះហេតុនោះខ្ញុំទើបពោលថា ឈ្មោះថា **ទាន** ព្រោះគេឱ្យទានដោយវត្ថុនេះ

ត្រាស់ថា **ជាមង្គល** ព្រោះជាហេតុសម្រេចនូវផលវិសេសដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងប្រព្រឹត្តទៅពេលខាងមុខ មានភាពជាអ្នកដែលជនជាច្រើនស្រឡាញ់និងពេញចិត្តជាច្រើន ។ ក្នុងរឿងទាននេះគប្បីរលឹកដល់សូត្រទាំងឡាយ ជាដើមយ៉ាងនេះថា ៖

"ម្នាលសីហៈ ទាយកជាម្ចាស់ទាន ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន" ។

ន័យម្យ៉ាងទៀត ឈ្មោះថា**ទាន**មាន ២ គឺអាមិសទាននិងធម្មទាន,បណ្តាទានទាំងពីរនោះអាមិសទាន បានពោលមកហើយទាំងអស់ ។ ចំណែកការសម្តែងធម៌ដែលព្រះសម្មាសម្ពុទ្ធ ជាម្ចាស់ ទ្រង់ប្រកាសហើយ ដែលនាំមកនូវការអស់ទៅនៃទុក្ខនិងសុខក្នុងលោកនេះ និង លោកខាងមុខ ព្រោះបំណងនឹងឱ្យជាប្រយោជន៍ដល់ជនដទៃ ។ឈ្មោះថា**ធម្មទាន** ។

ម្យ៉ាងទៀត បណ្តាទានទាំងពីរនេះ ធម្មទាននេះជាកំពូលដូចដែលព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកថា ៖

សព្វទានំ ធម្មទានំ ជិនាតិ

សព្វរសំ ធម្មរសោ ជិនាតិ

សព្វរតី ធម្មរតិ ជិនាតិ

តណ្ហក្ខយោ សព្វទុក្ខំ ជិនាតិ

ធម្មទានឈ្នះអាមិសទានទាំងពួង ធម្មរសឈ្នះរសទាំងពួង សេចក្តីត្រេកអរក្នុងធម៌ឈ្នះត្រេកអរទាំងពួង ការអស់តណ្ហាឈ្នះទុក្ខទាំងពួង ។

ក្នុងព្រះសូត្រនិងគាថានោះ ក៏ទ្រង់ត្រាស់តាមសេចក្តីដែលអាមិសទានជាមង្គលប៉ុណ្ណោះ ចំណែកធម្មទានទ្រង់ត្រាស់ថា ជាមង្គល ព្រោះជាបទដ្ឋាននៃគុណទាំងឡាយ មានភាពជាអ្នកយល់ជ្រួតជ្រាបអត្ថជាដើម សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកដូច្នេះថា ៖

"ម្នាលភិក្ខុទាំងឡាយ ព្រះសាស្តា ឬភិក្ខុជាសព្រហ្មចារីណាមួយក្នុងសាសនានេះ ជាគរុដ្ឋានីយបុគ្គល(បុគ្គលគួរគោរព) សម្តែងធម៌ដល់ភិក្ខុនោះយ៉ាងណា ។ ភិក្ខុនោះរមែងដឹងច្បាស់នូវអដ្ឋកថាផង ដឹងច្បាស់នូវបាលីផង ក្នុងធម៌នោះយ៉ាងនោះ ។ យ៉ាងនេះជាដើម" ។

មួយទៀត ***ទាន*** *ប្រែថា* ***ការឱ្យ*** *សំដៅដល់* ***ការឱ្យលះ***

បង់នូវទេយ្យធម៌របស់ខ្លួន ដើម្បីជាប្រយោជន៍ដល់បុគ្គលដទៃ ដោយសេចក្តីពេញចិត្ត ។

ការឱ្យទាន មានប្រយោជន៍យ៉ាងធំធេងដល់ប្រទេសជាតិ បើជាច់ឬមិនមានការឱ្យទាននេះហើយ នៅក្នុងសង្គមលោកទាំងមូល ក៏មិនមានទូវសេចក្តីសុខដែរ ដូចជា ៖

- **មាតាបិតា** បើមិនបានឱ្យទាន គឺមិនចិញ្ចឹមយើងមកទេ យើងប្រាកដជាត្រូវស្លាប់តាំងពីកើតមកម៉្លេះ ។

- **ស្វាមីភរិយា** រកទ្រព្យសម្បត្តិបានមក បើមិនប្រើប្រាស់ដោយការចាយវាយឬចិញ្ចឹមគ្រួសារទេ គ្រួសារនោះវានិងបែកបាក់គ្នាជាមិនខាន ។

- **គ្រូអាចារ្យ** បើមិនឱ្យទាន គឺមិនលះបង់នូវមន្តវិជ្ជាដល់កូនសិស្សទេ កូនសិស្សនិងល្ងិតល្ងង់រកទីពឹងគ្មាន ។

- **មនុស្សយើង** បើមានសេចក្តីខឹងក្រោធហើយ គឺមិនមាន**អភយទាន**ទេ កាលបើជាយ៉ាងនេះ នៅក្នុងលោកនិង**ច្របូកច្របល់** ។

ជីវិតមនុស្សគ្រប់គ្នា ដែលអាចរស់នៅបានដោយអាស្រ័យ

ការឱ្យទាន យើងមានរាងកាយធំធាត់ទៅបាន ក៏ដោយសារទាន យើងមានទូវចំណេះចេះដឹងក្នុងផ្នែកផ្សេង ៗទៅបានក៏ ព្រោះទាន លោកនេះមានទូវសេចក្តីសុខ សប្បាយទៅបានក៏ព្រោះទាន ការឱ្យទានទើបជាចាំបាច់ជាទីបំផុតនិងមានគុណប្រយោជន៍យ៉ាងធំធេងសម្រាប់មនុស្សទូទៅ ។

ប្រភេទរបស់ទាន

១- អាមិសទាន គឺ ការឱ្យវត្ថុរបស់ជាទាន ដូចជាឱ្យអាហារបរិភោគ គ្រឿងប្រើប្រាស់ជាដើម ។

២- ធម្មទាន ឬ **វិទ្យាទាន** គឺការឱ្យសេចក្តីចេះដឹងជាទាន ។ បើជាចំណេះដឹងផ្លូវលោក ឱ្យទូវសិល្បៈវិជ្ជាផ្សេង ៗហៅថា**វិទ្យាទាន** បើជាចំណេះចេះដឹងខាងផ្លូវធម៌ ដូចជាទូន្មានប្រៀនប្រដៅឱ្យលះបង់អំពើអាក្រក់ ប្រព្រឹត្តធ្វើតែសេចក្តីល្អ មានសីល-ធម៌ នេះហៅថា **ធម្មទាន** ។

៣- អភយទាន គឺការឱ្យនូវការមិនបៀតបៀនដល់សត្វដទៃ ដោយការលះបង់នូវសេចក្តីក្រេវក្រោធឱ្យជាទាន ឱ្យអភ័យមិនចងពៀរវេរា លះបង់នូវការព្យាបាលឱ្យដាច់ចេញអំពីចិត្ត មាន

ការរក្សាសីល ៥ ជាដើម ។

ការឱ្យធម៌ជាទាន ចាត់ជាទានដែលបានបុណ្យខ្ពស់បំផុត មានគុណប្រយោជន៍ច្រើនជាងការឱ្យទាំងពួង ព្រោះធ្វើឱ្យអ្នកទទួលមានទុវបញ្ញាស្មារតី សម្រាប់ដោះស្រាយទុវបញ្ហានៅក្នុងជីវិតបានគ្រប់ពេល ហើយអាចនាំយកទៅប្រើបានមិនចេះអស់ទាំងជាតិនេះនិងជាតិខាងមុខ ។ ចំណែកទានប្រភេទដទៃអ្នកទទួលបានទទួលហើយ មិនយូរប៉ុន្មានវារមែងអស់ទៅ ។

គោលបំណងនៃការធ្វើទាន

១- ធ្វើទានដើម្បីធ្វើគុណ គឺការឱ្យដើម្បីយកចិត្ត យកថ្លើមអ្នកដទៃ ឱ្យដើម្បីឱ្យអ្នកដែលទទួលនោះ មានការស្រឡាញ់រាប់អានខ្លួន មិនប្រាថ្នាជាបុណ្យជាកុសលអ្វីទេ ដូចជាបុគ្គលដែលឱ្យទានចិត្តមិនស្មោះ ។ គឺដល់ពេលវេលាដែលត្រូវរកសម្លេងគាំទ្រអំពីប្រជាជន ក៏ដង្ហែសម្ពត់កឋិនទៅរហូត ១០ វត្តខ្លះ ២០ វត្តខ្លះ ទៅកសាងស្ពានខ្លះ សាងផ្លូវថ្នល់ខ្លះ ដើម្បីឱ្យប្រជាជនបានឃើញថា ខ្លួនជាមនុស្សចិត្តបុណ្យ ដើម្បីឱ្យប្រជាជនបោះឆ្នោតឱ្យខ្លួន ឬ បុគ្គលខ្លះ ស្រឡាញ់បងក្រមុំរបស់គេក៏យកនំទៅឱ្យប្អូន

របស់គេ ការឱ្យបែបនេះ បំណងទិសដៅដើម្បីផលប្រយោជន៍ដើម្បីឱ្យអ្នកទទួលទាន នោះស្រឡាញ់ខ្លួនការឱ្យដូច្នេះសួរថា តើបានបុណ្យដែរឬទេ ?ឆ្លើយថាបានបុណ្យដែរ តែបានតិចបានមិនពេញបរិបូណ៌ ។ **ការឱ្យដែលបានបុណ្យច្រើននោះ ត្រូវដើម្បីឱ្យបានបុណ្យខ្ពស់ជាងនោះទៅទៀតនោះ គឺឱ្យដើម្បីបូជាគុណ ។**

២- ឱ្យដើម្បីអនុគ្រោះ គឺឱ្យដោយការជួយទំនុកបម្រុងអើពើចំពោះគ្នានិងគ្នា ឱ្យដោយចិត្តមេត្តាករុណាដូចជាមាតាបិតាឱ្យអាហារដល់កូនគ្រូអាចារ្យឱ្យចំណេះដឹងដល់កូនសិស្ស អ្នកមានទ្រព្យសម្បត្តិ បរិច្ចាគដើម្បីជួយដល់និស្សិតដែលមានការខ្វះខាតឬជនក្រីក្រជាដើម ។

៣- ធ្វើដើម្បីបូជាគុណ គឺកាលបើមានអ្នកប្រាថ្នាសេចក្តីល្អចំពោះយើង មានចិត្តប្រកបដោយមេត្តាករុណា និងមានទូវគុណូបការៈលើយើងដូចជាមាតាបិតា គ្រូអាចារ្យ បុគ្គលទាំងអស់នេះ យើងគួរតែសម្តែងសេចក្តីគោរព ឱនលំទោនចំពោះលោកទៅដោយកាយ វាចា ចិត្ត បូជាគុណលោកដោយទ្រព្យសម្បត្តិ តាមកម្លាំងដែលខ្លួនមាននៅពេកលោកឈឺ ក៏ជួយព្យា-

បាលមិនលះបង់លោកចោលទាំងនៅក្នុងពេលលោកមានសេចក្តីសុខ និងសេចក្តីទុក្ខក្រៅពីនេះ បុគ្គលដែលគួរបូជាគុណ គឺភិក្ខុសាមណេរ អ្នកទ្រទ្រង់ធម៌ ជាអ្នកបង្ហាញផ្លូវទៅរកសេចក្តីសុខ ប្រដៅណែនាំឱ្យបានដឹងអំពីបាប បុណ្យ គុណ ទោស ជួយប្រៀនប្រដៅអប់រំពុទ្ធបរិស័ទឱ្យបានរួចចាកសេចក្តីទុក្ខ ព្រោះដូច្នេះ ទើបគួរបូជាលោកដោយបច្ច័យ ៤ ដើម្បីឱ្យលោកមានកម្លាំងបំពេញសមណធម៌និងបំពេញនូវប្រយោជន៍ដល់មនុស្សទាំងឡាយតាមសមណវិស័យ ។

គតិជាស់តឿនចិត្ត

មនុស្សយើងកាលស្លាប់ទៅហើយ ទ្រព្យសម្បត្តិសូម្បីតែមួលមួយដើម ក៏មិនអាចនាំយកទៅជាប់តាមខ្លួនបានឡើយ វិធីតែមួយគត់ដែលអាចនាំយកទ្រព្យជាប់តាមខ្លួនបាននោះ គឺការយកទ្រព្យទាំងអស់នោះទៅធ្វើទាន ។

បុគ្គលដែលត្រូវភ្លើងឆេះផ្ទះ ទ្រព្យណាដែលគេជញ្ជូនចេញមកបាន ទ្រព្យនោះមានប្រយោជន៍ដល់គេជាម្ចាស់ផ្ទះ ទ្រព្យណាដែលគេមិនបានជញ្ជូនចេញទ្រព្យនោះត្រូវភ្លើង ឆេះនៅក្នុងផ្ទះនោះ

ឯង មិនមានប្រយោជន៍ដល់គេតិចតួចឡើយ យ៉ាងណាមិញ បុគ្គលដែលត្រូវភ្លើងជរាព្យាធិមរណៈឆាបឆេះហើយ បើបានជញ្ជូនទ្រព្យចេញដោយការឱ្យទានទ្រព្យនោះ រមែងមានប្រយោជន៍ដល់គេជាម្ចាស់ទ្រព្យក៏យ៉ាងនោះដែរ ។

ទានដែលឱ្យហើយមិនបានបុណ្យ

១~ ឱ្យគ្រឿងស្រវឹងនិងគ្រឿងញៀន ដូចជា សុរាកញ្ឆា និងថ្នាំញៀន

២~ ឱ្យអាវុធ ដូចជាគេកំពុងឈ្លោះគ្នាក៏ហុចជាវកាំបិតឱ្យ

៣~ ឱ្យមហោស្រព ដូចជា នាំទៅមើលល្ខោន ស្តាប់តន្ត្រី ដែលជាហេតុធ្វើឱ្យកាមកំរើក

៤~ ឱ្យសត្វមានភេទផ្ទុយគ្នា ដូចជានាំសុនខញីទៅឱ្យសុនខឈ្មោល រកស្រីក្រមុំទៅឱ្យចៅហ្វាយនាយជាដើម

៥~ ឱ្យរូបភាពលាមក ដូចជា ឱ្យសៀវភៅឬកាសែត មានរូបអាស់អាកាស ដែលជាហេតុឱ្យកាមចម្រើន ។

វិធីធ្វើទានឱ្យបានបុណ្យច្រើន

ការធ្វើទានឱ្យបានបុណ្យច្រើន ត្រូវប្រកបដោយអង្គ ៣ យ៉ាងគឺ ៖

១. វត្ថុបរិសុទ្ធិ គឺទេយ្យធម៌ដែលត្រូវឱ្យ ជារបស់ដែលខ្លួនបានមកដោយសុចរិតត្រឹមត្រូវតាមធម៌ មិនបានមកដោយការកុហក ឆបោកអ្នកណា ឬបៀតបៀនគេឡើយ ។

ការឱ្យទានដោយទេយ្យធម៌ដែលសៅហ្មង ដែលបានមកដោយអំពើសុចរិត បានបុណ្យច្រើនជាងការឱ្យទេយ្យធម៌ដែលប្រណិត មានតម្លៃច្រើនរាប់ពាន់ម៉ឺនសែនដោយមាសប្រាក់ ដែលបានមកដោយអំពើទុច្ចរិតមិនបរិសុទ្ធ ។ ដូច្នេះ អ្នកឱ្យទានត្រូវតែមានសីលបរិសុទ្ធិ ទើបធ្វើទៅបានបុណ្យច្រើន ព្រោះហេតុនោះ យើងតែងឃើញគ្រប់គ្រា មុនពេលដែលយើងថ្វាយទានចំពោះសង្ឃ ព្រះសង្ឃដែលមានការឱ្យនូវសីល សូម្បីថាយ៉ាងហោចណាស់ នៅពេលនោះគង់យើងមានសីល៥ ធ្វើយ៉ាងនេះ បុណ្យនឹងកើតឡើងពេញបរិបូណ៌ ។

២. ចេតនាបរិសុទ្ធិ គឺមានចេតនាដើម្បីកម្ចាត់សេចក្តីកំណាញ់របស់ខ្លួន ធ្វើដើម្បីយកបុណ្យមិនធ្វើយកមុខ យកឈ្មោះ

សម្លេងនោះទេ ត្រូវមានចេតនាបរិសុទ្ធទាំង ៣ ខណៈគឺ ៖

- **មុនពេលឱ្យទានក៏មានចិត្តជ្រះថ្លាជាទាងដើម ពេញចិត្តនិងធ្វើបុណ្យនោះ (បុព្វចេតនា) ។**

- **ខណៈឱ្យទានក៏តាំងចិត្តឱ្យដោយសេចក្តីសប្បាយ រីករាយ (មុញ្ចនចេតនា) ។**

- **ក្រោយពីឱ្យទានរួចហើយ ក៏មានចិត្តសប្បាយរីករាយត្រេកអរ និង មិននឹកស្តាយទេយ្យធម៌ដែលឱ្យហើយ (អបរាបរចេតនា) ។**

៣.បុគ្គលបរិសុទ្ធិ គឺជ្រើសរើសឱ្យដល់បុគ្គលដែលមានសីលបរិសុទ្ធិមានចិត្តស្ងប់តាំងចិត្តបដិបត្តិធម៌យ៉ាងខ្ជាប់ខ្ជួនដោយព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែងសំដៅយកព្រះសង្ឃថាជាស្រែបុណ្យដ៏ប្រសើរបស់សត្វលោក តែបើឱ្យដោយចោះចំពោះបុគ្គល ក៏ទ្រង់ត្រាស់ណែនាំឱ្យជ្រើរើសនិមន្តភិក្ខុសាមណេរណាដែលប្រព្រឹត្តម៉ត់ចត់នៅក្នុងសីល សិក្ខាដែលគួរជាទីជ្រះថ្លា បើឱ្យដោយមិនចោះចំពោះទេ ត្រូវឱ្យដោយតាំងចិត្តចំពោះសង្ឃទូទៅ ក៏ត្រូវឱ្យភិក្ខុដែលមានទាទីជាភត្តុទ្ទេសកចាត់ឱ្យ ។

ស្រែមានលក្ខណៈ ៨ ប្រការ

នៅក្នុងខេត្តសូត្រ បិដកលេខ ៤៨ ទំព័រ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពូជដែលបុគ្គលសាបព្រោះក្នុងស្រែប្រកបដោយអង្គ ៨ ទើបជាពូជមានផលច្រើន មានសេចក្តីត្រេកអរច្រើន មានសេចក្តីចម្រើនច្រើន ។

ស្រែប្រកបដោយអង្គ ៨ នោះគឺ ៖

១- ស្រែនោះមិនមានទីទួល

២- មិនមានថ្មនិងគ្រួស

៣- មិនមានទឹកប្រៃ

៤- មានគន្ធងនង្គ័លជ្រៅ

៥- បរិបូណ៌ដោយផ្លូវទឹកសម្រាប់បញ្ចូល

៦- បរិបូណ៌ដោយផ្លូវទឹកសម្រាប់បញ្ចេញ

៧- បរិបូណ៌ដោយប្រឡាយទឹក

៨- បរិបូណ៌ដោយភ្លឺ ។

សេចក្តីនេះយ៉ាងណា ៖

នៅក្នុងខេត្តសូត្រហ្នឹងដដែល ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ទានដែលបុគ្គលឱ្យចំពោះសមណព្រាហ្មណ៍ ដែលប្រកបដោយអង្គ ៨ ជាទានមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ក៏យ៉ាងនោះដែរ ។

សមណព្រាហ្មណ៍ប្រកបដោយអង្គ ៨ នោះគឺ ÷

១- *សម្មាទិដ្ឋិ* មានសេចក្តីយល់ឃើញត្រូវ គឺឃើញនូវអរិយសច្ច ៤ គឺទុក្ខសច្ចៈ (ទីតាំងនៃទុក្ខមានជាតិ ជរា ព្យាធិ មរណៈជាដើម) សមុទ្យសច្ចៈ(ហេតុនាំឱ្យកើតទុក្ខ មានកាមតណ្ហា ភវតណ្ហា វិភវតណ្ហា) និរោធសច្ចៈ(សភាពពិត គឺការរំលត់ទុក្ខ បានដល់ព្រះនិព្វាន) មគ្គសច្ចៈ (សភាពពិតគឺផ្លូវប្រតិបត្តិឱ្យរួចចាកទុក្ខ ។

២- *សម្មាសង្កប្បោ* ត្រិះរិះត្រូវ គឺត្រិះរិះនឹងចេញចាកកាម ១ ត្រិះរិះក្នុងការមិនជាហេតុឱ្យកើតព្យាបាទ ១ ត្រិះរិះក្នុងការមិនជាហេតុបៀតបៀន ១, ។

៣- *សម្មាវាចា* និយាយត្រូវ គឺវៀរចាកវចីទុច្ចរិត ៤ មាន

មិននិយាយកុហក ១, មិននិយាយញុះញង់គេ ១, មិននិយាយចាក់ជោគគេ ១, មិននិយាយពាក្យឥតប្រយោជន៍ ១ ។

៤- សម្មាកម្មន្តោ ធ្វើការងារត្រូវ គឺវៀរចាកកាយទុច្ចរិត ៣ មានមិនសម្លាប់សត្វ ១, មិនលួចទ្រព្យគេ ១, មិនប្រព្រឹត្តខុសក្នុងកាម ១ ។

៥- សម្មាអាជីវោ ចិញ្ចឹមជីវិតត្រូវ គឺវៀរចាកការចិញ្ចឹមជោយផ្លូវខុស បានដល់ជំនួញខុស ៥ យ៉ាង មានមិនជួញមនុស្ស ១, មិនជួញថ្នាំពិស ១, មិនជួញគ្រឿងសាស្ត្រាវុធ ១, មិនជួញគ្រឿងញៀន ១, មិនសត្វមានជីវិត ១ ។

៦- សម្មាវាយាមោ ព្យាយាមត្រូវ គឺព្យាយាមក្នុងទីស្ថាន ៤ ស្ថាន មានព្យាយាមមិនឱ្យបាបកើតឡើងក្នុងសន្តាន ១, ព្យាយាមលះបាបដែលកើតឡើងហើយ ១, ព្យាយាមញុំាងកុសលឱ្យកើតក្នុងសន្តាន ១, ព្យាយាមញុំាងកុសលដែលកើតឡើងហើយមិនឱ្យសាបសូន្យទៅវិញ ១ ។

៧- សម្មាសតិ នឹករលឹកត្រូវ គឺរលឹកក្នុងសតិប្បដ្ឋាន ៤ មានសតិរលឹកពិចារណាកាយ ជាអារម្មណ៍ថា កាយនេះគ្រាន់តែ

ជាកាយប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គលជាខ្លួនប្រាណជាយើង ជាគេឡើយ ១, សតិរលឹកពិចារណាវេទនា គឺសេចក្តីដឹងសុខ ទុក្ខ ឧបេក្ខា ជាអារម្មណ៍ថា ចិត្តនេះគ្រាន់តែជាវេទនាប៉ុណ្ណោះ មិនមែនជាសត្វជាបុគ្គលជាខ្លួនប្រាណជាយើងជាគេឡើយ ១,សតិរលឹកពិចារណាចិត្តដែលសៅហ្មង និងផូរផង់ជាអារម្មណ៍ថា ចិត្តនេះគ្រាន់តែជាចិត្តប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គល ជាខ្លួនប្រាណជាយើង ជាគេឡើយ ១ សតិរលឹកពិចារណាធម៌កុសល ឬអកុសលដែលកើតឡើងជាមួយចិត្តជាអារម្មណ៍ថា ធម៌នេះគ្រាន់តែជាធម៌ប៉ុណ្ណោះ មិនមែនជាសត្វ ជាបុគ្គលជាខ្លួនប្រាណជាយើងជាគេឡើយ១ ។

៨- សម្មាសមាធិ តាំងចិត្តត្រូវ ។

ពូជដីបរិបូរណ៍ ដែលគេសាបព្រោះក្នុងស្រែដ៏ល្អ កាលបើមានភ្លៀងស្រួល **ការបរិបូណ៌ដោយគ្រាប់ស្រូវ ក៏រមែងមាន គឺ បរិបូណ៌ដោយការមិនអន្តរាយ ១ ការចម្រើនឡើងបរិបូរណ៌ ១ ការលូតលាស់បរិបូរណ៌ ១ ផ្លែហ្នឹងឯងបរិបូរណ៌ ១ មានឧបមាយ៉ាងណាមិញ ។**

ក្នុងអង្គមគ្គទាំង ៨ នេះ សម្មាទិដ្ឋិ, សម្មាសង្កប្បៈ សង្គ្រោះចូលបញ្ញាសិក្ខា, សម្មាវាចា, សម្មាកម្មន្ត, សម្មាអាជីវៈ សង្គ្រោះចូលសីលសិក្ខា,សម្មាវាយាម,សម្មាសតិ,សម្មាសមាធិ សង្គ្រោះចូលក្នុងចិត្តសិក្ខា ។

ភោជនដ៏បរិបូរណ៌ ដែលបុគ្គលឱ្យហើយចំពោះពួកបុគ្គលមានសីលបរិបូណ៌ រមែងញុំាងចំណែកកុសលឱ្យកើតឡើង កុសលកម្មដែលបុគ្គលនោះឱ្យហើយ ឈ្មោះថា កម្មដ៏បរិបូណ៌ មានឧបមេយ្យយ៉ាងនោះដែរ ព្រោះហេតុនោះ បុគ្គលក្នុងលោកនេះជាអ្នកបរិបូណ៌ មានសេចក្តីជ្រាបច្បាស់ជាអ្នកបរិបូណ៌ គួរសេពគប់នូវបុគ្គលដែលមាននូវបញ្ញាដ៏បរិបូណ៌ ការបរិបូណ៌រមែងសម្រេចយ៉ាងនោះឯង ។

អាហុណេយ្យសូត្រ

នៅក្នុងបិដកលេខ ៤៩ ទំព័រ ៤២ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់អំពី **[បុគ្គលដែលជាស្រែបុណ្យ ៩ ជំពូក]** មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ បុគ្គល ៩ ពួកនេះ ជាអ្នកគួរទទួល

នូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទានដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេតដ៏ប្រសើរបស់សត្វលោក ។

បុគ្គល ៩ ពួក តើដូចម្តេច ?

១- អរហា គឺព្រះអរហន្ត

២-អរហត្តាយបដិបន្នោ បុគ្គលប្រតិបត្តិដើម្បីព្រះអរហន្ត

៣- អនាគាមី អនាគាមីបុគ្គល

៤- អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ បុគ្គលប្រតិបត្តិធ្វើឱ្យជាក់ច្បាស់នូវអនាគាមិផល

៥- សកទាគាមី សកទាគាមីបុគ្គល

៦-សកទាគាមិផលសច្ឆិកិរិយា បដិបន្នោ បុគ្គលប្រតិបត្តិធ្វើឱ្យជាក់ច្បាស់នូវសកទាគាមីផល

៧- សោតាបន្នោ សោតបន្នបុគ្គល

៨-សោតាបត្តិផលសច្ឆិកិរិយា បដិបន្នោ បុគ្គលប្រតិបត្តិធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល

៩- គោត្រភូ គោត្រភូបុគ្គល ។

ម្នាលភិក្ខុទាំងឡាយ បុគ្គល ៩ ពួកនេះឯង ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវអាគន្តុកទានដែលគេនាំមកដើម្បីភ្ញៀវ គួរទទួលទក្ខិណាទាន គួរដល់អញ្ជលិកម្ម ជាបុញ្ញក្ខេតដ៏ប្រសើរបស់សត្វលោក ។

អដ្ឋកថា

បទថា គោត្រភូ បានដល់ ជាអ្នកប្រកបដោយវិបស្សនាចិត្ត ដែលមានកម្លាំងដល់ទីបំផុត ដោយអនន្តរប្បច្ច័យនៃសោតាបត្តិមគ្គ ។

ទេវហិតសូត្រ

នៅក្នុងបិដកលេខ ៣០ ទំព័រ ១២១ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់អំពី [ការឱ្យទេយ្យធម៌] ជាមួយនឹងទេវហិតព្រាហ្មណ៍ មានសេចក្តីថា ៖

ព្រះសាស្តា ទ្រង់គង់នៅក្នុងវត្តជេតពន ជាអារាមរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។

សម័យនោះឯង ព្រះមានព្រះភាគទ្រង់មានព្រះអាពាធដោយខ្យល់ក្នុងព្រះឧទរ ។

ព្រះឧបវាណៈមានអាយុ ជាអ្នកបម្រើព្រះមានព្រះភាគ ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅព្រះឧបវាណៈមានអាយុមកថា ម្នាលឧបវាណៈ អ្នកចូរដើរទីកក្តៅដល់តថាគតចុះ ។ ព្រះឧបវាណៈមានអាយុទទួលព្រះពុទ្ធដីកានៃព្រះមានព្រះភាគថា ព្រះករុណា ព្រះអង្គ ហើយស្លៀកស្បង់ប្រដាប់បាត្រ និងចីវរ ចូលទៅកាន់លំនៅរបស់ទេវហិតព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏ឈរស្ងៀមក្នុងទីសមគួរ ។

ទេវហិតព្រាហ្មណ៍ បានឃើញព្រះឧបវាណៈមានអាយុឈរស្ងៀមក្នុងទីសមគួរ លុះឃើញហើយបានពោលនឹងឧបវាណៈមានអាយុដោយគាថា ៖

តុណ្ហីភូតោ ភវំ តិដ្ឋ មុណ្ហោ សច្ឆាដិបារុតោ
កឹ បត្តយានោ កឹ ឯសំ កឹ នុ យាចិតុមាគតោតិ ។

អ្នកត្រដោលដ៏ចម្រើន ឃ្លុំសង្ឃាដី ឈរនៅស្ងៀមប្រាថ្នាអ្វី ស្វែងរកអ្វី មកដើម្បីសូមនូវអ្វីហ្ន៎ ។

ព្រះឧបវាណៈតបថា ៖

អហំ សុគតោ លោកេ វាតេហាពាធិតោ មុនិ
សចេ ឧណ្ហោទកំ អត្ថិ មុនិនោ ទេហិ ព្រាហ្មណ
បូជិតោ បូជនេយ្យានំ សក្ការេយ្យាន សក្ខតា
អបចិតោ អបចិនេយ្យានំ តស្ស ឥច្ចាមិ ហាតវេតិ ។

ព្រះសុគតជាអរហន្ត ជាអ្នកប្រាជ្ញក្នុងលោក ទ្រង់មានអាពាធដោយខ្យល់ក្នុងព្រះឧទរ ម្នាលព្រាហ្មណ៍ បើអ្នកមានទឹកក្តៅអ្នកចូរថ្វាយដល់ព្រះពុទ្ធ ជាអ្នកប្រាជ្ញ(ព្រោះថា)ព្រះមានព្រះភាគ គឺបូជនេយ្យបុគ្គលទាំងឡាយបានបូជាហើយ សក្ការេយ្យបុគ្គលទាំងឡាយ បានធ្វើសក្ការៈហើយ អបចិនេយ្យបុគ្គលទាំងឡាយបានកោតក្រែងហើយអាត្មាប្រាថ្នាដើម្បីនាំទឹកទៅថ្វាយព្រះអង្គ ។

លំដាប់នោះ ទេវហិតព្រាហ្មណ៍ឱ្យបុរសវែកអម្បែកទឹកក្តៅនិងដុំស្ករអំពៅ ទៅប្រគេនព្រះឧបវាណៈមានអាយុ ។

លំដាប់នោះឯង ព្រះឧបវាណៈមានអាយុ ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏បានស្រង់ព្រះមានព្រះភាគដោយទឹកក្តៅ ហើយលាយស្ករអំពៅដោយទឹកក្តៅ ថ្វាយព្រះមានព្រះភាគ ។

លំដាប់នោះ អាពាធព្រះមានព្រះភាគក៏សះស្បើយទៅ ។

គ្រានោះ ទេវហិតព្រាហ្មណ៍ ចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួរនឹងរីករាយ និងពាក្យដែលគួរនឹងរឭកហើយ ក៏អង្គុយក្នុងទីសមគួរ ។

លុះទេវហិតព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏បានក្រាបទូលព្រះមានព្រះភាគដោយគាថាថា ៖

តត្ថ ទជ្ជា ទេយ្យធម្មំ កត្ថ ទិន្នំ មហប្ផលំ
កថំ ហិ យជមានស្ស កត្ថ ឥជ្ឈតិ ទក្ខិណាតិ ។

បុគ្គលគួរឱ្យទេយ្យធម៌ចំពោះបុគ្គលណា ទានដែលបុគ្គលឱ្យចំពោះបុគ្គលណា ទើបមានផលច្រើន កាលបុគ្គលបូជាដូចម្តេច ទក្ខិណាទានសម្រេចដូចម្តេច ។

ព្រះមានព្រះភាគត្រាស់ថា ៖

បុព្វេនិវាសំ យោ វេទិ សគ្គាបាយញ្ច បស្សតិ
អថោ ជាតិក្ខយំ បត្តោ អភិញ្ញា ភោសិតោ មុនិ
ឯត្ថ ទជ្ជ ទេយ្យធម្មំ ឯត្ថ ទិន្នំ មហប្ផលំ

ឯវំ ហិ យជមានស្ស ឯវំ ឥជ្ឈតិ ទក្ខិណាតិ ។

បុគ្គលណាជីងនូវបុព្វេនិវាសផង ឃើញនូវសួគ៌និងអបាយផង មួយទៀត ដល់នូវការអស់ទៅនៃជាតិ ជាអ្នកប្រាជ្ញ សម្រេចហើយ ព្រោះត្រាស់ដឹង បុគ្គលគួរឱ្យទេយ្យធម៌ចំពោះបុគ្គលនុ៎ះ ទានដែលបូគ្គលឱ្យចំពោះបុគ្គលនុ៎ះ ទើបមានផលច្រើន កាលបុគ្គលបូជាយ៉ាងនេះ ទក្ខិណាទាន តែងសម្រេច គឺមានផលច្រើនយ៉ាងនេះ ។

កាលព្រះមានព្រះភាគ ត្រាស់យ៉ាងនេះហើយ ទេវហិតព្រាហ្មណ៍ ក៏បានពោលនូវពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។បេ ។ សូមព្រះគោតមដ៏ចម្រើនជ្រាបនូវខ្ញុំព្រះអង្គថា ជាឧបាសកដល់នូវព្រះរតនត្រ័យ ជាទីពឹងស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ។

អដ្ឋកថា

បទថា វាតេហិ បានដល់ ដោយខ្យល់ក្នុងផ្ទៃ ។ បានឮថា កាលព្រះមានព្រះភាគទ្រង់ធ្វើទុក្ករកិរិយាអស់ ៦ វស្សា ទ្រង់នាំយកសណ្តែកបាយនិងសណ្តែកជ្រុងជាដើម មួយប្រភេទមួយទូកដៃ

មកសោយ ខ្យល់ក្នុងព្រះឧទរកម្រើកព្រោះសោយមិនល្អ និងផ្ទុំលំបាក ។ សម័យតមក ទ្រង់សម្រេចព្រះសម្ពោធិញ្ញាណហើយ សូម្បីសោយកោជនដ៏ប្រណីត អាពាធនោះក៏នៅប្រាកដជាចន្លោះ ។ ពាក្យនេះលោកពោលសំដៅយកអាពាធនោះ ។

បទថា **ឧបដ្ឋាកោ ហោតិ** សេចក្តីថា ជាឧបដ្ឋាកក្នុងគ្រាមិនទាន់មានឧបដ្ឋាកប្រចាំផ្នែកបឋមពោធិកាល ។ បានឮថា ក្នុងវេលានោះ បណ្តាព្រះអសីតិមហាថេរៈ អ្នកដែលមិនធ្លាប់ជាឧបដ្ឋាករបស់ព្រះសាស្តាមិនមាន ។ ក៏ព្រះថេរៈទាំងនេះគឺព្រះនាគសុមនៈ ព្រះឧបវាណៈ ព្រះសុនក្ខត្តៈ ព្រះចុន្ទៈ ព្រះសមណុទ្ទេសៈ ព្រះសាគតៈព្រះមេឃិយៈ ជាឧបដ្ឋានដែលមានឈ្មោះមកក្នុងបាលី តែក្នុងវេលានេះ ព្រះឧបវាណត្ថេរក្រោកឡើងពីព្រលឹមបានឧបដ្ឋាកព្រះមានព្រះភាគគ្រប់យ៉ាង ដូចបោសបរិវេណថ្វាយឈើជម្រះព្រះទន្ត ចាត់ថ្វាយទឹកស្រង់ កាន់បាត្រចីវរតាមស្តេច ។

បទថា **ឧបសង្កមិ** សេចក្តីថា បានឮថា អស់វេលា ២០ ឆ្នាំ ក្នុងបឋមពោធិកាល ព្រៃប្រាសចាកផ្សែងភ្លើង សូម្បីព្រះមានព្រះភាគក៏មិនទាន់បានទ្រង់អនុញ្ញាតការដាំទឹកដល់ភិក្ខុទាំងឡាយ ក៏

ព្រាហ្មណ៍នោះឱ្យធ្វើចង្រ្កានជាជួរលើកភាជនៈធំ ៗ ឡើងតាំងលើចង្រ្កាន ឱ្យធ្វើទឹកក្តៅហើយលក់ទឹកក្តៅ ព្រមទាំងកម្ទេចផង់សម្រាប់ងូតទឹកជាដើមចិញ្ចឹមជីវិត ។ អ្នកប្រាថ្នាងូតទឹកទៅក្នុងទីនោះហើយឱ្យតម្លៃ (ទិញ) ងូតទឹកលាបស្រឡាបដោយរបស់ក្រអូបប្រជាប់ផ្កាឈើហើយជៀសទៅ ។ ព្រោះដូច្នោះព្រះថេរៈទើបចូលទៅក្នុងទីនោះ ។

បទថា កិំ បត្ថយានោ បានដល់ ប្រាថ្នាអ្វី ។

បទថា កិំ ឯសំ បានដល់ ស្វែងរកអ្វី ។

បទថា បូជិតោ បូជនេយ្យានំ សេចក្តីថា ព្រះថេរៈផ្តើមពោលការសរសើរព្រះទសពលនេះ ។ លោកពោលពាក្យនេះទុកថា បានឮថា ព្រះថេរៈទៅដើម្បីគិលានភេសជ្ជៈ ពោលសរសើរភិក្ខុឈឺ ដូច្នេះ ។ ពិតមែន ពួកមនុស្សបានស្តាប់ពាក្យសរសើរហើយ រមែងសម្គាល់ភេសជ្ជៈដែលគួរថ្វាយដោយគោរព ។ ភិក្ខុឈឺបានភេសជ្ជៈដែលជាសប្បាយហើយ រមែងបាត់ឈឺឆាប់រហ័សតែម្តង ។ សេចក្តីពិតកាលនឹងពោល មិនគួរពោលដល់ឈាន វិមោក្ខ សមាបត្តិ និងមគ្គផល ។ តែគួរពោលអាគមនីយបដិបទា

យ៉ាងនេះ គឺ អ្នកមានសីល មានសេចក្តីភ្លាស ច្រើនរង្គៀស ពហុស្សុតទ្រង់ទុកនូវនិកាយជាទីមក អ្នកតាមរក្សាអរិយវង្ស ។

បទថា បូជនេយ្យានំ សេចក្តីថា ព្រះអសីតិមហាថេរៈ ឈ្មោះថា បូជនេយ្យ ព្រោះលោកព្រមទាំងទេវលោកគួរបូជា ។ លោកទាំងនោះឯង ឈ្មោះថា សក្ការេយ្យ ព្រោះសេចក្តីសក្ការៈ ឈ្មោះថា អបចិនេយ្យ ព្រោះគួរធ្វើសេចក្តីនមស្សការរដល់លោកទាំងនោះតែម្តង ។ ព្រះថេរៈកាលប្រកាសគុណរបស់ព្រះមានព្រះភាគនោះថា ព្រះមានព្រះភាគជាអ្នកដែលទេវតានិងមនុស្សទាំងនោះបូជាសក្ការៈនមស្សការ ដូច្នេះ ទើបពោលយ៉ាងនេះ ។

បទថា ហាតវេ ប្រែថា ដើម្បីនាំទៅ ។

បទថា ជាណិតស្ស ច បុដំ បានដល់ ជុំស្ករអំពៅធំ ដែលប្រាសចាកកម្ទេចផេះបានឮថា ព្រាហ្មណ៍នោះ សួរថា ព្រះសមណគោតមទ្រង់មិនស្រួលអ្វី បានជ្រាបថា ខ្យល់ក្នុងផ្ទៃ ទើបពោលថា បើដូច្នោះ ពួកយើងស្គាល់ថ្នាំក្នុងរឿងនេះ តពីនេះ សូមលោកម្ចាស់ យកទឹកបន្តិច លាយស្ករអំពៅនេះ ថ្វាយឱ្យទ្រង់ផឹកក្នុងវេលាស្រេចសម្រេច ព្រះសោតនឹងហូរចេញខាងក្រៅព្រះសរីរៈ

ដោយទឹកក្តៅខ្សល់ក្នុងផ្ទៃនឹងបាត់ដោយថ្នាំនេះដោយប្រការដូច្នេះ ព្រះសមណគោតមនឹងទ្រង់សប្បាយ ដោយអាការដូចពោលមកនេះ ដូច្នេះហើយ ទើបបានថ្វាយដាក់ចុះក្នុងបាត្រព្រះថេរៈ ។

បទថា **ឧបសង្កមិ** សេចក្តីថា បានឮថា កាលអាពាធនោះស្ងប់ហើយបានកើតរឿងពិស្តារថា ទេវហិតព្រាហ្មណ៍ថ្វាយភេសជ្ជចំពោះព្រះតថាគតរោគស្ងប់ព្រោះភេសជ្ជៈនោះឯង គួរអស្ចារ្យទានរបស់ព្រាហ្មណ៍ជាបរមទាន ។ ព្រាហ្មណ៍អ្នកប្រាថ្នាឈ្នោះសំឡេង បានស្តាប់ដូច្នោះហើយ កើតសោមនស្សថា កិត្តិសព្ទរបស់យើងនេះខ្ចរខ្ចាយទៅ សូម្បីព្រោះហេតុត្រឹមតែប៉ុណ្ណេះឯង ប្រាថ្នានឹងឱ្យគេដឹងរឿងដែលខ្លួនធ្វើហើយ ក្នុងខណៈនោះឯង ចូលទៅគាល់ធ្វើសេចក្តីជិតជិតក្នុងព្រះទសពល ។

បទថា **ឧជ្ឈា** ប្រែថា គប្បីឱ្យ ។

បទថា **កថំ ហិ យជមានស្ស** បានដល់ បូជាព្រោះហេតុអ្វី ។

បទថា **ឥជ្ឈតិ** បានដល់ មានផលច្រើន ។

បទថា **យោ** វេទិ សេចក្តីថា បានធ្វើអ្នកដែលដឹងឱ្យប្រាកដ

ច្បាស់ ។ បាឋៈថា យោ វេតិ ដូច្នេះក៏មាន ។ អធិប្បាយថា អ្នកណា រមែងដឹង គឺដឹងច្បាស់ ។

បទថា បស្សតិ បានដល់ រមែងឃើញដោយទិព្វចក្ខុ ។

បទថា ជាតិក្ខយំ បានដល់ ព្រះអរហត្ត ។

បទថា អភិញ្ញា វោសិតោ សេចក្តីថា នៅចប់ព្រហ្មចរិយ គឺដល់ទីបំផុតព្រហ្មចរិយៈ គឺ ភាពជាអ្នកធ្វើកិច្ចសម្រេចហើយ ព្រោះដឹង ។

បទថា ឯវំ ហិ យជមានស្ស សេចក្តីថា បូជាដោយអាការៈយ៉ាងនេះ គឺ អាការបូជាព្រះខីណាស្រព ។

ឥសិត្តសូត្រ

នៅក្នុងបិដកលេខ ២៥, ទំព័រ ២៦៧ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្តែងអំពី **[ទានត្រូវឱ្យជាមួយអ្នកលះអង្គ ៥]** មានសេចក្តីថា ៖

ទៀបក្រុងសាវត្ថី... លុះព្រះបាទបសេនទិកោសល គង់នៅក្នុងទីសមគួរហើយ ក៏ក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន **ទាន** តើបុគ្គលត្រូវឱ្យដល់បុគ្គលណា ។

ព្រះអង្គត្រាស់ថា បពិត្រមហារាជ ចិត្តជ្រះថ្លាចំពោះបុគ្គលណា (ត្រូវឱ្យដល់បុគ្គលនោះ) ។

បពិត្រព្រះអង្គដ៏ចម្រើន **ទាន** ដែលបុគ្គលឱ្យហើយដល់បុគ្គលណា ទើបមានផលច្រើន ។

ព្រះអង្គត្រាស់ថា បពិត្រមហារាជ ពាក្យថា **ទាន** បុគ្គលត្រូវឱ្យដល់បុគ្គលណា នេះជាពាក្យដទៃពាក្យថា **ទាន** ដែលបុគ្គលឱ្យហើយ ដល់បុគ្គលណា ទើបមានផលច្រើន នេះក៏ជាពាក្យដទៃដែរ បពិត្រមហារាជ **ទាន** ដែលបុគ្គលត្រូវឱ្យហើយដល់បុគ្គលមានសីល ទើបមានផលច្រើន **ទាន** ដែលបុគ្គលឱ្យដល់បុគ្គលទ្រុស្តសីល មិនមានផលច្រើនទេ ។

បពិត្រមហារាជ បើដូច្នោះ តថាគតនឹងសួរព្រះអង្គ ក្នុងប្រស្នានេះ ប្រស្នានេះគាប់ចិត្តព្រះអង្គយ៉ាងណា ត្រូវព្រះអង្គព្យាករនូវប្រស្នានោះយ៉ាងនោះ ។

បពិត្រមហារាជ ព្រះអង្គសំគាល់ហេតុនោះដូចម្តេច ក្នុងជនបទនេះ មានចម្បាំងមកប្រាកដដល់ព្រះអង្គហើយ ប្រសិនបើសង្គ្រាមលើកគ្នាជាពួកមកដល់ហើយ តែខត្តិយកុមារមិនបានសិក្សា មិនមានថ្វីដៃ មិនទាន់កន្ទាយ មិនថ្លែងសរ មានសេចក្តីខ្លាច រន្ធត់

តក់ស្លុតរត់ទៅជាប្រក្រតីតើព្រះអង្គគួរចិញ្ចឹមបុរសនោះដែរឬព្រះអង្គត្រូវការដោយបុរសបែបនោះដែរឬ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនគួរចិញ្ចឹមបុរសនោះ ខ្ញុំព្រះអង្គមិនត្រូវការដោយបុរសបែបនោះឡើយ ។

ប្រសិនបើសង្គ្រាមលើកគ្នាជាពួកមកដល់ហើយ តែថាព្រាហ្មណត្រកូលកុមារ មិនបានសិក្សា (មិនមានថ្វីដៃ មិនទាន់កន្ទាយ មិនថ្លែងសរ មានសេចក្តីខ្លាច រន្ធត់តក់ស្លុត រត់ទៅជាប្រក្រតី តើព្រះអង្គគួរចិញ្ចឹមបុរសនោះដែរឬ ព្រះអង្គត្រូវការដោយបុរសបែបនោះដែរឬ ។

ប្រសិនបើសង្គ្រាមលើកគ្នាជាពួកមកដល់ហើយ តែថាកុមាររបស់វេស្សត្រកូល មិនបានសិក្សា(មិនមានថ្វីដៃ មិនទាន់កន្ទាយ មិនថ្លែងសរ មានសេចក្តីខ្លាច រន្ធត់តក់ស្លុត រត់ទៅជាប្រក្រតី តើព្រះអង្គគួរចិញ្ចឹមបុរសនោះដែរឬ ព្រះអង្គត្រូវការដោយបុរសបែបនោះដែរឬ) ។

ប្រសិនបើសង្គ្រាមលើកគ្នាជាពួកមកដល់ហើយ តែថាកុមាររបស់សុទ្ទត្រកូល មិនបានសិក្សា (មិនមានថ្វីដៃ មិនទាន់កន្ទាយ មិនថ្លែងសរ មានសេចក្តីខ្លាច រន្ធត់តក់ស្លុត រត់ទៅជា

ប្រក្រតី តើព្រះអង្គគួរចិញ្ចឹមបុរសនោះដែរឬ ព្រះអង្គត្រូវការដោយបុរសបែបនោះដែរឬ) ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គក៏មិនត្រូវការដោយបុរសបែបដូច្នោះឡើយ ។

បពិត្រមហារាជ ព្រះអង្គសំគាល់ហេតុនោះដូចម្តេច ក្នុងជនបទនេះ មានចម្បាំងមកប្រាកដដល់ព្រះអង្គហើយ ប្រសិនបើសង្គ្រាមលើកគ្នាជាពួកមកដល់ហើយ ជួនជាខត្តិយកុមារបានសិក្សាល្អ មានថ្វីដៃ បានទាំងកន្ទាយ ចេះថ្លែងសរ ឥតមានសេចក្តីខ្លាចរន្ធត់តក់ស្លុត មិនរត់ទៅជាប្រក្រតី តើព្រះអង្គគួរចិញ្ចឹមបុរសនោះដែរឬ ព្រះអង្គត្រូវការដោយបុរសបែបនោះដែរឬ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរចិញ្ចឹមបុរសនោះ ខ្ញុំព្រះអង្គត្រូវការដោយបុរសបែបនោះដែរ ។

ប្រសិនបើសង្គ្រាមលើកគ្នា ជាពួកមកដល់ហើយ កុមារបស់ព្រាហ្មណត្រកូល ។ បេ ។ ប្រសិនបើសង្គ្រាម លើកគ្នាជាពួកមកដល់ហើយ កុមារបស់វេស្សត្រកូល ។ បេ ។ ប្រសិនបើសង្គ្រាមលើកគ្នាជាពួកមកដល់ហើយ កុមារបស់សុទ្ទត្រកូលបានសិក្សាល្អ មានថ្វីដៃ បានទាំងកន្ទាយ ចេះថ្លែងសរ ឥតមាន

សេចក្តីខ្ជាចរន្ធត់តក់ស្លុត មិនរត់ទៅឡើយ តើព្រះអង្គគួរចិញ្ចឹមបុរសនោះដែរឬ ព្រះអង្គត្រូវការដោយបុរសបែបនោះដែរឬ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគួរចិញ្ចឹមបុរសបែបនោះ ខ្ញុំត្រូវការដោយបុរសបែបនោះដែរ ។

បពិត្រមហារាជ បើបុគ្គលចេញចាកត្រកូល ចេញចាកផ្ទះ ហើយចូលមកកាន់ផ្នួស បុគ្គលនេះឯង បានលះបង់អង្គ ៥ ប្រកបដោយអង្គ ៥ **ទាន** ដែលបុគ្គលឱ្យដល់បុគ្គលនោះ ទើបមានផលច្រើន ក៏យ៉ាងនោះឯង ។ អង្គ ៥ ដែលបុគ្គលនោះបានលះបង់ដូចម្តេច ។

១- កាមច្ឆន្ទោ បហីនោ ហោតិ គឺ **កាមច្ឆន្ទៈ** បុគ្គលនោះបានលះបង់ហើយ

២- ព្យាបាទោ បហីនោ ហោតិ **ព្យាបាទៈ** បុគ្គលនោះ បានលះបង់ហើយ

៣- ថីនមិទ្ធំ បហីនោ ហោតិ **ថីនមិទ្ធៈ** បុគ្គលនោះបានលះបង់ហើយ

៤- ឧទ្ធច្ចកុក្កុច្ចំ បហីនោ ហោតិ **ឧទ្ធច្ចកុក្កុច្ចៈ** បុគ្គល

នោះបានលះបង់ហើយ

៥- **វិចិកិច្ឆា បហីនោ ហោតិ** **វិចិកិច្ឆា** បុគ្គលនោះបានលះបង់ហើយ ។

អង្គទាំង ៥ នេះ បុគ្គលនោះបានលះបង់ហើយ ។

បុគ្គលប្រកបដោយអង្គ ៥ ដូចម្តេច ។

១-អសេក្ខេន សីលក្ខន្ធេន សមន្នាគតោ ហោតិ ប្រកបដោយសីលក្ខន្ធជារបស់អសេក្ខៈ

២-អសេក្ខេន សមាធិក្ខន្ធេន សមន្នាគតោ ហោតិ ប្រកបដោយសមាធិក្ខន្ធជារបស់អសេក្ខៈ

៣-អសេក្ខេន បញ្ញាក្ខន្ធេន សមន្នាគតោ ហោតិ ប្រកបដោយបញ្ញាក្ខន្ធជារបស់អសេក្ខៈ

៤-អសេក្ខេន វិមុត្តិក្ខន្ធេន សមន្នាគតោ ហោតិ ប្រកបដោយវិមុត្តិក្ខន្ធជារបស់អសេក្ខៈ

៥-អសេក្ខេន វិមុត្តិញ្ញាណទស្សនក្ខន្ធេន សមន្នាគតោ ហោតិ ប្រកបដោយវិមុត្តិញ្ញាណទស្សនក្ខន្ធ ជារបស់អសេក្ខៈ ។

ទាន ដែលបុគ្គលឱ្យដល់បុគ្គល ដែលបានលះបង់អង្គ ៥

ប្រកបដោយអង្គ ៥ ហើយ ទើបមានផលច្រើន ដូច្នេះឯង ។

ព្រះមានព្រះភាគ បានត្រាស់នូវពាក្យនេះចប់ហើយ ទើប បានត្រាស់ព្រះគាថានេះតទៅទៀតថា ៖

ឥស្សត្តំ ពលវីរិយញ្ច យស្មិ វិជ្ជេ មាណវេ
តំ យុទ្ធគោ ភរេ រាជា ជានសូរំ ជាតិបច្ចយា
តថេវ ខត្តិសោរច្ចំ ធម្មា យស្មិ បតិដ្ឋិតា
តមរិយវុត្តិ មេធាវី ហីនជច្ចម្ហិ បូជយេ
ការយេ អស្សមេ រម្មេ វាសយេត្ត ពហុស្សុតេ
បបញ្ច វិវនេ កយិរា ខុត្តេ សព្ភមនានិ ច
អន្នំ បានំ ខាទនីយំ វត្ថសេនាសនានិ ច
ទទេយ្យ ឧជុភូតេសុ វិប្បសន្នេន ចេតសា ។
យថាបិ មេឃោ ថនយំ វិជ្ជុមាលី សតក្កុកុ
ថលំ និន្នញ្ច បូរេតិ អភិវស្សំ វសុន្ធរំ ។
តថេវ សទ្ធោ សុតវា អភិសទ្ធញ្ច កោដនំ
វណិព្វកេ តប្បយតិ អន្នបានេន បណ្ឌិត

អនុមោទមានោ បកិរេតិ ទេវ ទេវាតិ ភាសតិ ។

តញ្ចិស្ស តជ្ជិតំ ហោតិ ទេវេស្សរ បវស្សតោ

សា បុញ្ញធារា វិបុលា ធាតារំ អភិវស្សតីតិ ។

សិល្បសាស្ត្រខាន់ធ្នូវក្តី កម្ចាំងនិងសេចក្តីព្យាយាមក្តី មាន ក្នុងមាណពណា ព្រះរាជាដែលត្រូវការដោយចម្បាំង គួរចិញ្ចឹម មាណពនោះ មិនគួរចិញ្ចមមាណពដែលឥតក្លៀវក្លា ដោយហេតុ គឺជាតិឡើយ ធម៌ទាំងឡាយគឺសេចក្តីអត់ធន់ និងសេចក្តីស្ងួត (ព្រះអរហត្ត)តាំងនៅក្នុងបុគ្គលណាហើយ បុគ្គលត្រូវតែបូជា បុគ្គលនោះ សូម្បីមានជាតិដ៏ថោកទាប តែជាអ្នកប្រាជ្ញ ចិញ្ចឹម ជីវិតដ៏ប្រសើរ បុគ្គលគប្បីឱ្យគេធ្វើអាស្រមជាទីត្រេកអរ ហើយ ញុំាងពហុស្សូតឱ្យនៅទីនោះ បុគ្គលគប្បីជីកអណ្តូងឬស្រះក្នុង ព្រៃធ្វើស្ពានក្នុងទីដែលលំបាកឆ្លងបុគ្គលមានចិត្តជ្រះថ្លា គប្បីឱ្យ បាយ ទឹក ខាទនីយៈ សម្ភត់និងទីសេនាសនៈទាំងឡាយ ដល់ពួក បុគ្គលដែលមានកាយនិងចិត្តត្រង់ មហាមេឃគ្រហឹម របៀបនៃ ផ្លេកបន្ទោរ មានកំពូលរាប់រយ ភ្លៀងបង្អុរចុះលើផែនដី ញុំាងទី ទួលនិងទីទាបឱ្យពេញបានយ៉ាងណាមិញ បុគ្គលជាបណ្ឌិត មាន

សទ្ធា ស្តាប់ធម៌បានចេះដឹង ហើយតាក់តែងនូវភោជនឱ្យដល់ពួកវណិព្វក[1]បានឆ្អែតដោយបាយនិងទឹក ក៏យ៉ាងនោះដែរ បុគ្គលមានចិត្តត្រេកអរ បាចសាចទ្រព្យធ្វើជាទាន ពោលថា អ្នកទាំងឡាយចូរឱ្យ អ្នកទាំងឡាយចូរឱ្យ ដូច្នេះឯង ។

ពាក្យនោះ បុគ្គលនោះ បានបញ្ចេញឱ្យលាន់ឮហើយ ដូចផ្គរលាន់ពេលភ្លៀង ធារទឹក គឺបុណ្យដ៏ធំទូលាយនោះ នឹងបង្អុរចុះលើបុគ្គលអ្នកឱ្យដូចជាមហាមេឃដែលបង្អុរចុះភ្លៀងមកលើផែនដីដែរ ។

អដ្ឋកថា

ការតាំងឡើងនៃឥស្សត្តសូត្រ មានអត្ថុប្បត្តិហេតុកើតរឿងដូច្នេះ ៖

បានឮថា ក្នុងបឋមពោធិកាល ព្រះមានព្រះភាគនិងភិក្ខុសង្ឃមានលាភសក្ការៈកើតឡើងជាច្រើន ។ ពួកតិរ្ថិយសាបសូន្យលាភសក្ការៈក៏គ្រាច់និយាយទៅក្នុងត្រកូលទាំងឡាយយ៉ាងនេះថា ព្រះសមណគោតមពោលយ៉ាងនេះថា គប្បីឱ្យទានដល់តថាគត

---

១. ស្ងួម សូមបានហើយពោលសរសើរ ឱ្យពរដល់ម្ចាស់ទាន ។

ប៉ុណ្ណោះ មិនគប្បីឱ្យទានដល់ពួកជនៃ គប្បីឱ្យទានដល់សាវ័ករបស់តថាគតប៉ុណ្ណោះ មិនគប្បីឱ្យទានដល់ពួកសាវ័ករបស់ពួកជនៃទានដែលឱ្យដល់តថាគតប៉ុណ្ណោះមានផលច្រើន ទានដែលឱ្យដល់ពួកជនៃ មិនមានផលច្រើន ទានដែលឱ្យដល់សាវ័ករបស់តថាគតប៉ុណ្ណោះមានផលច្រើន ទានដែលឱ្យដល់ពួកសាវ័ករបស់ពួកជនៃមិនមានផលច្រើន ។ សូម្បីទាំងដែលខ្ញុំឯងក៏នៅអាស្រ័យភិក្ខាចារគួរដែរឬដែលមកធ្វើអន្តរាយដល់បច្ច័យ៤របស់ពួកជនៃដែលខ្ញុំនក៏អាស្រ័យភិក្ខាចារដូចគ្នា ព្រះសមណគោតមធ្វើមិនត្រូវមិនសមគួរឡើយ ពាក្យនោះក៏ផ្សាយខ្ទរខ្ទាយទៅដល់រាជត្រកូល ។ ព្រះរាជាទ្រង់ស្តាប់ហើយ ទ្រង់ព្រះត្រិះរិះថា មិនមែនហាន:ឡើយ (ប្រព្រឹត្តទៅមិនបាន) ដែលព្រះតថាគតនឹងគប្បីទ្រង់ធ្វើអន្តរាយដល់សាវ័ករបស់អ្នកពួកជនៃ មានតែអ្នកជនៃទាំងនោះ ត្រជាបត្រជួស ដើម្បីមិនឱ្យមានលាភ ដើម្បីមិនឱ្យមានយសដល់ព្រះតថាគត បើយើងនៅក្នុងទីនេះឯង ក៏នឹងគប្បីនិយាយថា ពួកលោកកុំនិយាយយ៉ាងនេះ ព្រះសាស្តា រមែងមិនត្រាស់យ៉ាងនោះ ពាក្យនោះ មិនគប្បីដល់សេចក្តីមិនមានមន្ទិលទោស យើងនឹងធ្វើពាក្យនោះឱ្យអស់មន្ទិល ក្នុងវេលាដែលមហាជននេះជុំគ្នា ទើបទ្រង់

ស្បៀមរង់ចាំថ្ងៃមហោស្រពមួយថ្ងៃ ។ សម័យតមកកាលមហា-
ជនប្រជុំគ្នា ព្រះរាជាទ្រង់ព្រះត្រិះរិះថា "វេលានេះជាកាលនៃមហោ-
ស្រពនេះ" ហើយត្រាស់ឱ្យវាយស្គរប្រកាសទៅក្នុងព្រះនគរថា អ្នក
ទាំងឡាយមិនថា មានសទ្ធា ឬ មិនមានសទ្ធា ជាសម្មាទិដ្ឋិ ឬ
មិច្ឆាទិដ្ឋិ វៀរលែងតែក្មេងឬស្ត្រីចាំផ្ទះ ត្រូវទៅកាន់ព្រះវិហារ អ្នក
ណាមិនទៅ ទឹងត្រូវពិន័យប្រាក់ ៥០ កហាបណៈ សូម្បីព្រះអគ្គ
ឯង ក៏ទ្រង់ស្រង់ពីព្រឹកព្រលឹម សោយព្រះក្រយាហារព្រឹកហើយ
ទ្រង់ប្រដាប់ព្រះអង្គដោយគ្រឿងប្រដាប់គ្រប់យ៉ាងហើយ បានស្តេច
ទៅកាន់ព្រះវិហារ ព្រមដោយទាហានពួកធំ កាលកំពុងយាង ទ្រង់
ព្រះត្រិះរិះថា យើងនឹងទូលសួរបញ្ហាដែលមិនគួរនឹងសួរយ៉ាងនេះ
ថា បពិត្រព្រះមានព្រះភាគ គេថា ព្រះអង្គត្រាស់ថា គប្បីឱ្យទាន
ដល់តថាគតប៉ុណ្ណោះ ។ល ។ ទានដែលឱ្យដល់ពួកសាវ័ករបស់
អ្នកពួកជទៃ មិនមានផលច្រើន ដូច្នេះ ក៏ព្រះមានព្រះភាគត្រាស់
តបបញ្ហារបស់យើង ក៏ទឹងទ្រង់ទម្លាយវាទៈរបស់ពួកតិរ្ថិយបាន
ក្នុងទីបំផុត ព្រះរាជាកាលទ្រង់ទូលសួរបញ្ហាទើបត្រាស់ថា បពិត្រ
ព្រះអង្គដ៏ចម្រើន បុគ្គលគួរឱ្យទានក្នុងទីណាហ្ន៎ ។

បទថា យត្ថ សេចក្តីថា ចិត្តជ្រះថ្លាក្នុងបុគ្គលណា គប្បីឱ្យ

ទានក្នុងបុគ្គលនោះ ឬគប្បីឱ្យដល់បុគ្គលនោះ ។

កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះ ព្រះរាជាក៏ទតមើលពួកអ្នកដែលច្រាប់ពោលពាក្យរបស់ពួកតិរ្ថិយ ។ អ្នកទាំងនោះលុះជួបព្រះរាជាក៏អៀនខ្មាស ឱនមុខឈរយកមេជើងឆ្កឹះដី ។ ព្រះរាជាកាលនឹងទ្រង់ប្រកាសដល់មហាជន ក៏បានត្រាស់ដោយព្រះសូរសៀងដែលខ្ចាំងតែមួយបទប៉ុណ្ណោះថា ពួកតិរ្ថិយត្រូវកម្ចាត់ហើយ គ្រាត្រាស់ព្រះតម្រាស់យ៉ាងនេះហើយ ទើបទូលសួរថា បពិត្រព្រះមានព្រះភាគ ដែលឈ្មោះថា ចិត្តរមែងជ្រះថ្លាក្នុងពួកនិគ្រន្ថអចេលនិងបរិព្វាជកជាដើមពួកណាមួយក៏ទានដែលឱ្យហើយក្នុងអ្នកពួកណាហ្ន៎ មានផលច្រើន ។

បទថា **អញ្ញំ** ឯតំ សេចក្តីថា ព្រះមានព្រះភាគត្រាស់ថា ថ្វាយព្រះពរ មហាបពិត្រត្រាស់សួរគ្រាដំបូង មួយយ៉ាង គ្រាក្រោយក៏ទ្រង់កំណត់ម្យ៉ាងទៀត សូម្បីការតបបញ្ហានេះ ក៏ជាភារៈនាទីរបស់តថាគត ទើបត្រាស់ថា **សីលវតោ** ឥ ជាដើម ។

បណ្តាបទទាំងនោះ បទថា **ឥធ** ត្យស្សរ ចែកជា **ឥធ** តេ អស្ស ការយុទ្ធគប្បីប្រាកដចំពោះមហាបពិត្រក្នុងទីនេះ ។

បទថា សមុបព្យុឡ្ហោ ប្រែថា ផ្តុំគ្នាជាក្រុម ៗ បទថា អសិ-
ក្ខិតោ បានដល់ មិនសិក្សាក្នុងធ្នូសិល្ប៍ ។

បទថា អកតហត្ថោ បានដល់ មានដៃមិនទាន់ព្រមដោយ
ការពាន់ដៃជាដើម ។

បទថា អកតយោគ្គោ បានដល់ ទូន្មានមិនទាន់ជំនាញ
ក្នុងការជូតស្មៅជូតជីស្អិតជាដើម ។

បទថា អកតុបាសនោ បានដល់ មិនទាន់បាន សម្តែងថ្វី
ដៃបាញ់ធ្នូចំពោះព្រះរាជា និងមហាអាមាត្យរបស់ព្រះរាជា ។

បទថា ឆម្ភី បានដល់ មានកាយញ័រវន្ធត់ ។

ក្នុងបទថា កាមឆន្ទោ បហីនោ ជាដើម កាមឆន្ទៈជាការ
លះបានដោយព្រះអរហត្តមគ្គ ។ ព្យាបាទៈលះបានដោយអនាគា-
មិមគ្គ ។ ថីនមិទ្ធៈ និងឧទ្ធច្ចៈ ក៏លះបានដោយអរហត្តមគ្គដូចគ្នា
កុក្កុច្ចៈលះបានដោយមគ្គទី ៣ ដូចគ្នា វិចិកិច្ឆា ជាការលះបាន
ដោយមគ្គដំបូង ។

បទថា អសេក្ខេន សីលក្ខន្ធេន សេចក្តីថា សីលក្ខន្ធ
របស់ព្រះអសេក្ខៈ ឈ្មោះថា សីលក្ខន្ធ ចំណែកអសេក្ខៈ ។

ក្នុងបទទាំងពួងក៏នយនេះ ។ ក៏បណ្តាបទទាំងនោះ សីលសមាធិបញ្ញា និងវិមុត្តិទាំងលោកិយៈនិងលោកុត្តរៈលោកពោលដោយ ៤ បទដើម វិមុត្តិញ្ញាណទស្សនៈរមែងជាបច្ចវេក្ខណញ្ញាណ បច្ចវេក្ខណញ្ញាណនោះ ជាលោកិយៈប៉ុណ្ណោះ ។

បទថា ឥស្សត្តំបានដល់ធ្នូសិល្ប៍ ។ ក្នុងបទថា ពលវីរិយំ នេះ វាយោធាតុ ឈ្មោះថា ពលៈ វីរិយៈក៏គឺសេចក្តីព្យាយាមផ្លូវកាយផ្លូវចិត្ត ។

បទថា ភវេប្រែថា គប្បីចំពោះ ។

បទថា នាសូរំ ជាតិបច្ចយា សេចក្តីថា មិនគប្បីចំពោះអ្នកមិនក្លាហាន ព្រោះប្រកាន់ជាតិជាហេតុ យ៉ាងនេះថា អ្នកនេះសម្បូរណ៌ដោយជាតិ ។ អធិវាសនខន្តិ ឈ្មោះថា ខន្តិ ក្នុងពាក្យថា ខន្តិសោរច្ចំ នេះ ។

បទថា សោរច្ចំ បានដល់ ព្រះអរហត្ត ។

បទថា ធម្មា បានដល់ ធម៌ទាំងពីរនេះ ។

បទថា អស្សមេ ប្រែថា ទីនៅ ។

បទថា វិវនេ ប្រែថា ដែលជាព្រៃ អធិប្បាយថា គប្បីសាង

ស្រះបោក្ខរណី ៤ ជ្រុងជាដើមក្នុងព្រៃដែលមិនមានទឹក ។

បទថា ទុគ្គេ បានដល់ ក្នុងទីរដិបរដុប ។

បទថា សង្កមនានិ សេចក្តីថា គប្បីធ្វើផ្លូវដើរ មានទ្រុង ស្នាតចាក់រោយរាបស្មើ ៥០-៦០ ហត្ថ ។

ឥឡូវនេះ កាលនឹងទ្រង់ត្រាស់ប្រាប់ទំនៀមភិក្ខាចារ របស់ពួកភិក្ខុដែលនៅក្នុងសេនាសនៈព្រៃទាំងនោះ ទើបត្រាស់ថា អន្តរាមំ ជាដើម ។ បណ្តាបទទាំងនោះ បទថា សេនាសនានិ បានដល់ គ្រែនិងតាំងជាដើម ។

បទថា វិប្បសន្នេន សេចក្តីថា សូម្បីកាលនឹងថ្វាយដល់ព្រះខីណាស្រពមិនថ្វាយដោយចិត្តមានសេចក្តីសង្វេគមានមន្ទិលគឺកិលេស គប្បីថ្វាយដោយចិត្តដែលថ្លាផូរផង់ប៉ុណ្ណោះ ។

បទថា ឋនយំ បានដល់ គំរាម ។

បទថា សតក្ខត្តុំ បានដល់ មានចុងរយមួយ អធិប្បាយថា មានកំពូលជាច្រើន ។

បទថា អភិសង្ខរិត្វា បានដល់ តាក់តែង គឺ រួបរួមធ្វើជាអាហារ ។

បទថា **អនុមោទមានោ** *បានដល់ ជាអ្នកមានចិត្តត្រេកអរ ។*

បទថា **បកិរេតិ** *បានដល់ ត្រាច់ក្នុងវោងទាន ឬដូចជាវោយឱ្យទាន ។*

បទថា **បុញ្ញឆរា** *បានដល់ធារនៃបុណ្យដែលសម្រេចមកពីទានចេតនាមិនមែនតិច ។*

បទថា **ធាតារំ អភិវស្សតិ** *សេចក្តីថា ខ្សែទឹកដែលបង្ហូរចេញចាកពពក ដែលតាំងឡើងក្នុងអាកាស រមែងធ្លាក់ស្រោចផែនដីឱ្យសើមជោក យ៉ាងណា ធារនៃបុណ្យដែលកើតក្នុងខាងក្នុងទាយកសូម្បីនេះ ក៏បង្ហូរស្រោចខាងក្នុងទាយកនោះឱ្យជោកពេញប្រៀប ដូច្នោះដែរ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា* **ធាតារំ អភិវស្សតិ** ។

ហេតុនាំឱ្យធ្វើទាន

បុគ្គលដែលបានលះបង់នូវទ្រព្យសម្បត្តិ ពោលគឺសេចក្តីកំណាញ់ចេញអំពីសន្តានចិត្ត ធ្វើទាន ឬសេចក្តីល្អផ្សេង ៗនោះក៏ព្រោះបានសម្លឹងឃើញនូវប្រយោជន៍ អំពីការលះបង់នោះឯង ។ ដូចជាព្រះអង្គទ្រង់ត្រាស់ជាមួយនឹងភិក្ខុទាំងឡាយ នៅក្នុងទាន-

សូត្របិដកលេខ ៥៣ ថា ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយដឹងនូវផលនៃការ**ឱ្យទានដូចជាតថាគតដឹងដែរនោះ ម៉្លោះបើអ្នកទាំងឡាយមិនទាន់បានឱ្យទានទេ នឹងមិនហ៊ានបរិភោគឡើយ** ម្យ៉ាងទៀត មន្ទិលគឺសេចក្តីកំណាញ់ ក៏មិនអាចគ្រប់សង្កត់ចិត្តនៃអ្នកទាំងឡាយបានដែរ ។ មួយទៀត ព្រះអង្គត្រាស់ថា **បុព្វេ ទានា ធិកំ ទត្វា ឥទានិ លភតិ សុខី មូលេវ សញ្ជិកំ ហោតិ អគ្គេ ច ផលទាយិកំ** បុគ្គលបាននូវសេចក្តីសុខក្នុងកាលឥឡូវនេះ ក៏ព្រោះបានឱ្យទានជាដើមក្នុងកាលមុន ដូចជារុក្ខជាតិដែលគេស្រោចទឹកត្រង់គល់ តែងឱ្យផលត្រង់ចុងវិញ ដូច្នោះ ។ រឿងឱ្យទានការឱ្យទាននេះមានហេតុច្រើនណាស់ ដូចជាបុគ្គលខ្លះឱ្យទាន ព្រោះចង់ឱ្យគេសរសើរ, ឱ្យទានព្រោះចង់បានកេរ្តិ៍ឈ្មោះកិត្តិយស, ឱ្យទានព្រោះមកអំពីមានសេចក្តីស្រឡាញ់ជាដើម ដូចជាមានព្រះសូត្រសម្តែងនៅខាងក្រោមនេះ ៖

បឋមទានសូត្រ

នៅក្នុងបិដកលេខ ៤៨, ទំព័រ ១៦០ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្តែងអំពី **[ហេតុនាំឱ្យធ្វើទាន ៨ យ៉ាង]**

មានសេចក្តីថា ៖

អដ្ឋិមានិ ភិក្ខវេ ទានានិ ម្នាលភិក្ខុទាំងឡាយ ទាននេះមាន ៨ យ៉ាង ។ កតមានិ អដ្ឋ, **ទាន ៨ យ៉ាង តើដូចម្តេចខ្លះ គឺ**

១- អាសជ្ជ ទានំ ទេតិ ***បុគ្គលឱ្យទាន ព្រោះបានចាត់ចែងទុកស្រេច ។ អដ្ឋកថា:*** ដោយសេចក្តីថា បុគ្គលខ្លះឱ្យទានព្រោះបានជួបប្រទះ គឺស្រាប់តែបានឃើញបដិគ្គាហកមកដល់និមន្តឱ្យលោកគង់មួយភ្លែតធ្វើសក្ការៈហើយ ទើបប្រគេនទូវទេយ្យធម៌រមែងមិនលំបាកចិត្តថានឹងឱ្យ ។

២- ភយា ទានំ ទេតិ ***ឱ្យទានព្រោះភ័យ ។ អដ្ឋកថា:*** គឺព្រោះខ្លាចគេតិះដៀលថា បុគ្គលនេះជាអ្នកមិនឱ្យទាន ឬព្រោះខ្លាចអបាយភូមិ ។

៣- អទាសិ មេតិ ទានំ ទេតិ ***ឱ្យទានដោយគិតថាគេបានឱ្យដល់អាត្មាអញ ។ អដ្ឋកថា:*** ដោយសេចក្តីថា ឱ្យទានដោយគិតថាបុគ្គលនេះធ្លាប់បានឱ្យវត្ថុនេះ ដល់អាត្មាអញក្នុងកាលមុន ។

៤- ឧស្សតិ មេតិ ទានំ ទេតិ **ឱ្យទានដោយគិតថា គេនឹងឱ្យដល់អាត្មាអញវិញ ។** ***អដ្ឋកថា:*** ដោយសេចក្តីថា ឱ្យទានដោយគិតថា បុគ្គលនេះនឹងឱ្យវត្ថុនេះដល់អាត្មាអញក្នុងអនាគត ។

៥- សាហុ ទានន្តិ ទានំ ទេតិ **ឱ្យទានដោយគិតថា ទានជាការប្រពៃ ។** ***អដ្ឋកថា:*** ដោយសេចក្តីថា ឱ្យទានដោយគិតថា ដែលឈ្មោះថា **ទាន** រមែងញុំាងប្រយោជន៍ឱ្យសម្រេច គឺថាជាការល្អប្រពៃដែលបណ្ឌិតទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើមសរសើរហើយ ។

៦- អហំ បថាមិ ឥមេន បថន្តិ នារហាមិ បថន្តោ អបថន្តានំ ទានំ ន ទាតុន្តិ ទានំ ទេតិ **ឱ្យទាន ដោយគិតថា យើងចម្អិន បុគ្គលទាំងឡាយនេះចម្អិនមិនបាន អាត្មាអញកាលចម្អិនបាន មិនគួរថា មិនឱ្យទានដល់បុគ្គលដែលមិនអាចចម្អិនបាននោះឡើយ ។**

៧- ឥមំ មេ ទានំ ទទតោ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតីតិ ទានំ ទេតិ **ឱ្យទានដោយគិតថា កាលបើអាត្មាអញឱ្យនូវទាននេះ កិត្តិសព្ទជ័ពីរោះ រមែងខ្ចរខ្ចាយទៅ ។**

៨- ចិត្តាលម្ពារចិត្តបរិក្ខារត្ថំ ទានំ ទេតិ ឱ្យាន ជើម្បីជាគ្រឿងប្រដាប់នៃចិត្ត និង ជើម្បីជាបរិក្ខារនៃចិត្ត ។

អដ្ឋកថា: ដោយសេចក្តីថា ឱ្យានជើម្បីប្រដាប់តាក់តែងចិត្តក្នុងសមថៈ និងក្នុងវិបស្សនា ព្រោះថា ទានរមែងធ្វើចិត្តឱ្យទន់ភ្លន់ទាំងអ្នកឱ្យទាំងអ្នកទទួល ។ អ្នកដែលទទួលទាន រមែងមានចិត្តទន់ភ្លន់ល្អថា ម្ចាស់ទានបានឱ្យហើយ ចំណែកបុគ្គលអ្នកឱ្យទានវិញ ក៏រមែងមានចិត្តទន់ភ្លន់ថា យើងបានឱ្យទានហើយ ព្រោះហេតុនោះឯង ទើបលោកពោលថា ការហ្វឹកហាត់ចិត្តដែលនៅមិនទាន់ហ្វឹកហាត់ដោយការឱ្យទាន ។ សមដូចព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ៖

អទន្តទមនំ ទានំ អទានំ ទន្តទូសកំ

អនេន បិយវាចេន ឱណមន្តិ នមន្តិ ច ។

ការឱ្យទាន ជាគ្រឿងហ្វឹកហាត់ទូន្មានចិត្តដែលនៅមិនទាន់បានទូន្មាន ការមិនឱ្យទានជាគ្រឿងប្រទូសរ៉ាយចិត្តដែលបានទូន្មានហើយ ជនទាំងឡាយដែលមានចិត្តទន់ភ្លន់ និងមានចិត្តបង្អោនដោយបិយវាចានេះឯង ។

ក្នុងបណ្តាការឱ្យទានទាំង ៨ ប្រការនេះ ការឱ្យជើម្បីប្រដាប់

តាក់តែងចិត្ត បានដល់ ការឱ្យទានទី ៨ តែប៉ុណ្ណោះ ជាការឱ្យដ៏ខ្ពង់ខ្ពស់បំផុត ។

ក្នុងអដ្ឋកថា **ទានសូត្រ** អង្គុត្តរនិកាយ សត្តកនិបាតបានសម្តែងថា ទានដែលជាគ្រឿងប្រដាប់តាក់តែងចិត្តនេះឯង គឺជាទានដែលប្រកបដោយសមថៈនិងវិបស្សនាដូច្នោះ ទើបញុំាងឈាននិងអរិយមគ្គឱ្យកើតឡើង បដិសន្ធិក្នុងព្រហ្មលោកជាព្រះអនាគាមី នេះជាទានមានផលច្រើន មានអានិសង្សច្រើន ។

ទានូបបត្តិសូត្រ

នៅក្នុងបិដកលេខ ៤៨, ទំព័រ ១៦៤ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្តែងអំពី **[ការធ្វើទានប្រាថ្នាអធិដ្ឋានទៅកើតក្នុងសុគតិ]** មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃទាននេះ មាន ៨ យ៉ាង ។

ការកើតឡើងនៃទាន ៨ យ៉ាង តើដូចម្តេចខ្លះ?

១-ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ឱ្យទានគឺបាយ ទឹក សំពត់ យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប

ទីដេក ទីអាស្រ័យ គ្រឿងប្រដាប់ប្រទីប ជាទានដល់សមណៈ ឬ
ព្រាហ្មណ៍ បុគ្គលនោះឱ្យនូវវត្ថុណាក៏ប្រាថ្នានូវវត្ថុនោះ បុគ្គលនោះ
ឃើញពួកខត្តិយមហាសាលក្តី ព្រាហ្មណមហាសាលក្តី គហបតិ-
មហាសាលក្តី ដែលកំពុងឆ្អែតស្កប់ស្កល់ មូលមិត្ត បម្រើដោយ
កាមគុណទាំង ៥ ។ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា
ឱហ្ន៎ អញលុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជា
មួយនឹងខត្តិយមហាសាលក្តី ព្រាហ្មណមហាសាលក្តី គហបតិ-
មហាសាលក្តី បុគ្គលនោះក៏ជម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចំរើន
ចិត្តនោះ ចិត្តរបស់បុគ្គលនោះក៏សិប់ក្នុងកាមគុណដ៏ថោកទាប មិន
បានចំរើនគុណធម៌ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយរាង
កាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកខត្តិយមហាសាល
ខ្លះ ព្រាហ្មណមហាសាលខ្លះ គហបតិមហាសាលខ្លះ ម្នាលភិក្ខុ
ទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯងចំពោះបុគ្គល
មានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ សេចក្តីប្រាថ្នាដោយ
ចិត្តរបស់បុគ្គលមានសីល រមែងសម្រេចព្រោះចិត្តដ៏បរិសុទ្ធ ។

២-ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ឱ្យទាន
គឺបាយ ទឹក សំពត់ យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប

ទីដេក ទីអាស្រ័យ គ្រឿងប្រដាប់ប្រទីប ជាទានដល់សមណៈ ឬ ព្រាហ្មណ៍ បុគ្គលនោះបានឮថា ពួកទេវតាចាតុម្មហារាជិកា មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើនបុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អញលុះបែកធ្លាយរាងកាយស្លាប់ទៅ សូមឱ្យទៅកើតជាមួយនឹងពួកទេវតាចាតុម្មហារាជិកា បុគ្គលនោះដម្កល់ចិត្តនោះអធិដ្ឋានចិត្តនោះចំរើនចិត្តនោះចិត្តរបស់បុគ្គលនោះ ក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនបានចំរើនគុណធម៌ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាចាតុម្មហារាជិក ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីលមិនចំពោះបុគ្គលទ្រុស្តសីលឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេចព្រោះចិត្តដ៏បរិសុទ្ធ ។

៣-ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ឱ្យទានគឺបាយ ទឹក សំពត់ យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យ គ្រឿងប្រដាប់ប្រទីប ជាទានដល់សមណៈ ឬ ព្រាហ្មណ៍ បុគ្គលនោះបាន ឮថាពួកទេវតាតាវត្តឹង្ស ។បេ។ ពួក

ទេវតាយាមា... ពួកទេវតាតុសិត... ពួកទេវតានិម្មានរតី...ពួកទេវតាបរនិម្មិតវសវតីមានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អញលុះបែកធ្លាយរាងកាយស្លាប់ទៅ សូមឱ្យទៅកើតជាមួយនឹងពួកទេវតាបរនិម្មិតវសវតីបុគ្គលនោះជម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចំរើនចិត្តនោះ ចិត្តរបស់បុគ្គលនោះក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាបមិនបានចំរើនគុណធម៌ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាបរនិម្មិតវសវតី ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីលរមែងសម្រេច ព្រោះចិត្តដ៏បរិសុទ្ធ ។

៣-ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ឱ្យទានគឺបាយ ទឹក សំពត់ យានជំនិះ ផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យ គ្រឿងប្រដាប់ប្រទីប ជាទានដល់សមណៈ ឬព្រាហ្មណ៍បុគ្គលនោះបានឮថា ពួកទេវតាព្រហ្មកាយិកៈមានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អញលុះបែកធ្លាយរាងកាយស្លាប់ទៅសូម

ឱ្យទៅកើតជាមួយនឹងពួកទេវតាព្រហ្មកាយិកៈ បុគ្គលនោះដម្កល់ចិត្តនោះ តាំងចិត្តនោះ ចំរើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ចុះសិប់ក្នុងកាមគុណដ៏ថោកទាប មិនបានចំរើនគុណធម៌ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅក៏រមែងទៅកើតជាមួយនឹងពួកទេវតាព្រហ្មកាយិក ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីលរមែងសម្រេច ព្រោះប្រាសចាករាគៈ ។

ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃទានមាន ៨ ប្រការនេះឯង ។

ទានវត្ថុសូត្រ

នៅក្នុងបិដកលេខ ៤៨, ទំព័រ ១៦៤ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្តែងអំពី **(ការធ្វើទានប្រាថ្នាអធិដ្ឋានទៅកើតក្នុងសុគតិ)** មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ទានវត្ថុនេះមាន ៨ យ៉ាង ។ ទានវត្ថុ ៨ យ៉ាងតើដូចម្តេច ។

១- ឆន្ទា ទានំ ទេតិ ឱ្យទានព្រោះសេចក្តីស្រឡាញ់ ។

២- ទោសា ទានំ ទេតិ ឱ្យទានព្រោះសេចក្តីខឹង ។

៣- មោហា ធានំ ទេតិ ឱ្យទានព្រោះសេចក្តីល្ងង់ ។

៤- ភយា ធានំ ទេតិ ឱ្យទានព្រោះសេចក្តីភ័យ ។

៥- ឯន្ទបុព្វំ កតបុព្វំ បិតុបិតាមហេហិ នាហាសឹ ទោរាណាំ កុលវំសំ ហាបេតុន្តិ ធានំ ទេតិ ឱ្យទានព្រោះគិតថា ជីដូចជីតាទាំងឡាយ(របស់អាត្មាអញ)ធ្លាប់ឱ្យ ធ្លាប់ធ្វើមក អញមិន គួរញ៉ាំងវង្សត្រកូលពីបូរាណនុ៎ះឱ្យវិនាស ។

៦-ឥមាហាំ ធានំ ឧត្វា កាយស្ស ភេទា បរម្មរណា សុគតិ សគ្គំ លោកំ ឧបបជ្ជិស្សាមីតិ ធានំ ទេតិ ឱ្យទានព្រោះគិតថា អញបានឱ្យទាននេះ លុះបែកធ្លាយរាងកាយស្លាប់ទៅនឹងទៅកើតក្នុងសុគតិសួគ៌ ទេវលោក ។

៧-ឥមំ មេ ធានំ ឧឧតោ ចិត្តំ បសីទតិ អត្តមនតា សោមនស្សំ ឧបជាយតីតិ ធានំ ទេតិ ឱ្យទានព្រោះគិតថា កាលអញឱ្យទាននេះចិត្តរមែងជ្រះថ្លា ទាំងសេចក្តីពេញចិត្តនឹងសោមនស្សក៏រមែងកើតឡើង ។

៨- ចិត្តាលង្ការចិត្តបរិក្ខារត្ថំ ធានំ ទេតិ ឱ្យទានដើម្បីជាគ្រឿងប្រដាប់នៃចិត្ត នឹងជាបរិក្ខារនៃចិត្ត ។

អដ្ឋកថា

បទថា ទានវត្ថូនិ បានដល់ ហេតុនៃការឱ្យទាន ។

បទថា ឆន្ទា ទានំ ទេតិ សេចក្តីថា បុគ្គលឱ្យទាន ព្រោះសេចក្តីស្រឡាញ់ ។

បទថា ទោសា សេចក្តីថា ជាអ្នកក្រោធហើយ វត្តុណាមាន ប្រញាប់ចាប់យកវត្តុនោះឱ្យទៅ ព្រោះទោសៈ ។

បទថា មោហេន សេចក្តីថា ជាអ្នកល្ងង់ ឱ្យទៅ ព្រោះមោហៈ ។

បទថា ភយា សេចក្តីថា ព្រោះខ្លាចពាក្យរិះគន់ ឬព្រោះខ្លាចអបាយភូមិ ឬព្រោះភ័យខ្លាចពាក្យរិះគន់ និងអបាយភូមិនោះឯងពិត ៗទើបឱ្យទៅ ។

បទថា កុលវំសំ បានដល់ ជាប្រវេណីរបស់ត្រកូល ។

អសប្បុរិសទានសូត្រ

នៅក្នុងបិកដលេខ ៤៥ ទំព័រ ៨៧ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ម្តែងអំពី [**ទានរបស់អសប្បុរសនឹងសប្បុរស**] ជាមួយនឹងភិក្ខុទាំងឡាយ មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ អសប្បុរិសទាននេះមាន ៥ យ៉ាង

អសប្បុរិសទាន ៥ យ៉ាងដូចម្តេចខ្លះ ។

១-អសក្កច្ចំ ទេតិ ឱ្យទានដោយមិនគោរព (ក្នុងទេយ្យ-ធម៌ បានដល់ មិនគោរព គឺធ្វើចិត្តឱ្យស្អាតឱ្យទានទេ)

២- អចិតិ កត្វា ទេតិ ឱ្យទានដោយមិនធ្វើនូវសេចក្តីគោរព (ក្នុងបដិគ្គាហកៈ បានដល់ ឱ្យដោយអាការៈមិនកោតក្រែង ដោយសេចក្តីមិនគោរព)

៣- អសហត្ថា ទេតិ មិនឱ្យដោយដៃខ្លួនឯង

៤- អបវិដ្ឋំ ទេតិ ឱ្យទានដូចជាបោះចោល

៥- អនាគមនទិដ្ឋិកោ ទេតិ ឱ្យទានដោយឃើញថា មិនឱ្យផល (បានដល់មិនធ្វើសេចក្តីឃើញផលកម្មនឹងមកយ៉ាងនេះថា ផលនៃកម្មដែលធ្វើ នឹងមកដល់ដូច្នេះឱ្យកើតឡើងទេ) ។

๖. ម្នាលភិក្ខុទាំងឡាយសប្បុរិសទាននេះមាន៥យ៉ាង ។

សប្បុរិសទាន ៥ យ៉ាងដូចម្តេចខ្លះ ។

១-សក្កច្ចំ ទេតិ ឱ្យទានដោយមិនគោរព (ក្នុងទេយ្យ-

ធម៌ បានដល់ មិនគោរព គឺធ្វើចិត្តឱ្យស្អាតឱ្យទានទេ)

២-ចិត្តី កត្វា ទេតិ ឱ្យទានដោយធ្វើនូវសេចក្តីគោរព (ក្នុងបដិគ្គាហក:បានដល់ឱ្យដោយអាការ:មិនកោតក្រែងដោយសេចក្តីមិនគោរព)

៣- សហត្ថា ទេតិ ឱ្យដោយដៃខ្លួនឯង

៤- អនបវិដ្ឋំ ទេតិ ឱ្យទានមិនដូចជាបោះចោល

៥-អាគមនទិដ្ឋិកោ ទេតិ ឱ្យទានដោយឃើញថាឱ្យផលបានដល់ មិនធ្វើសេចក្តីឃើញផលកម្ម នឹងមកយ៉ាងនេះថា ផលនៃកម្មដែលធ្វើ នឹងមកដល់ដូច្នេះឱ្យកើតឡើងទេ) ។

ម្នាលភិក្ខុទាំងឡាយ សប្បុរិសទានមាន ៥យ៉ាងនេះឯង ។

អដ្ឋកថាមនោរថបូរណី ពន្យល់ថា :

បទថា **ចិត្តី កត្វា ទេតិ** បានដល់ ចូលទៅតាំងសេចក្តីកោតក្រែងក្នុងទេយ្យធម៌ និងទក្ខិណេយ្យបុគ្គលហើយឱ្យ ។ ក្នុងពីរយ៉ាងនោះបុគ្គលធ្វើទេយ្យធម៌ឱ្យប្រណីតមានរសឆ្ងាញ់ហើយឱ្យ ឈ្មោះថាចូលទៅតាំងសេចក្តីកោតក្រែងក្នុងទេយ្យធម៌ ។ បុគ្គល

ជ្រើសរើសបុគ្គលហើយឱ្យឈ្មោះថា តាំងសេចក្តីកោតក្រែងក្នុងទក្ខិណេយ្យបុគ្គល ។

បទថា **សហត្ថា ន** តិ សេចក្តីថា មិនប្រើដៃរបស់អ្នកដទៃឱ្យដោយពាក្យបញ្ជា គឺឱ្យដោយដៃខ្លួនឯងប៉ុណ្ណោះ ដោយគិតថា ឈ្មោះថាកាលដែលយើងត្រាច់រង្គាត់ទៅក្នុងសង្សារវដ្តដែលមិនមានខាងដើម និងខាងចុងហើយ បានប្រើដៃនិងជើងនោះ មិនមានប្រមាណឡើយ យើងនឹងធ្វើសេចក្តីរួចផុតទៅអំពីវដ្តៈ ការចេញចាក ភពដូច្នោះ ។

បទថា **អាគមនធិដ្ឋិកោ** បានដល់ ជឿកម្មនិងវិបាកថានឹងជាបច្ចុប្បន្នៃភពក្នុងអនាគតហើយឱ្យ ដូច្នេះ ។

ព្រាហ្មណសូត្រ

នៅក្នុងបិដកលេខ ៥៣ ទំព័រ ១៣៣ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្តែងអំពី (**ការឱ្យទានពីរយ៉ាង**) ជាមួយនឹងភិក្ខុទាំងឡាយ ដោយមានសេចក្តីថា ៖

ខ្ញុំបានស្តាប់មកថា ពាក្យនុ៎ះព្រះមានព្រះភាគ ទ្រង់ត្រាស់

ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ តថាគតជាព្រាហ្មណ៍ គួរគេសូមបាន មានដៃលាងស្អាតគ្រប់កាល ទ្រទ្រង់នូវអត្តភាពជាទីបំផុត ជាពេទ្យវះកាត់យ៉ាងប្រសើរ អ្នកទាំងជាបុត្រជាឱរសកើតអំពីមាត់តថាគត កើតអំពីធម៌ មានធម៌តាក់តែងហើយ មានធម៌ជាមត៌ក មិនមានអាមិសជាមត៌កឡើយ ។ ម្នាលភិក្ខុទាំងឡាយ **ទាននេះមាន ២** គឺ អាមិសទាន ១ ធម្មទាន ១ ម្នាលភិក្ខុទាំងឡាយ បណ្តាទានទាំង ២ នេះ ធម្មទានប្រសើរជាង, ម្នាលភិក្ខុទាំងឡាយ ការចែកទាននេះមាន ២ គឺការចែកអាមិសទាន ១ ការចែកធម៌ ១, ម្នាលភិក្ខុទាំងឡាយ បណ្តាការចែក ២ យ៉ាងនេះ ការចែកធម៌ប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ ការអនុគ្រោះនេះមាន ២ គឺ ការអនុគ្រោះដោយអាមិស ១ ការអនុគ្រោះដោយធម៌ ១ ម្នាលភិក្ខុទាំងឡាយ បណ្តាការអនុគ្រោះទាំង ២ នេះ ការអនុគ្រោះដោយធម៌ប្រសើរជាង ។ ម្នាលភិក្ខុទាំងឡាយ ការបូជានេះមាន ២ គឺការបូជាដោយអាមិស ១ ការបូជាដោយធម៌ ១,ម្នាលភិក្ខុទាំងឡាយ បណ្តាការបូជាទាំង ២ នេះ ការបូជាដោយធម៌ប្រសើរជាង ។

លុះព្រះមានព្រះភាគសម្តែងសេចក្តីនេះហើយ ។ ទ្រង់ត្រាស់គាថាព័ន្ធនេះក្នុងព្រះសូត្រនោះថា ៖

យោ ធម្មយោគំ អយដិ អមច្ចរី
តថាគតោ សព្ពសត្តានុកម្បី
តំ តាទិសំ ទេវមនុស្សសេដ្ឋំ
សត្តា នមស្សន្តិ ភវស្ស បារគុន្តិ ។

ព្រះតថាគតអង្គណា មិនមានព្រះទ័យកំណាញ់ មានការអនុគ្រោះដល់សព្វសត្វ បានប្រោសប្រទានធម៌ សត្វទាំងឡាយតែងនមស្សការព្រះតថាគតនោះ ប្រាកដដូច្នោះ ព្រះអង្គប្រសើរជាងទេវតានិងមនុស្ស ទ្រង់ដល់នូវត្រើយនៃភព ។

ខ្ញុំបានស្តាប់មកហើយថា សេចក្តីនេះឯងព្រះមានព្រះភាគទ្រង់ត្រាស់ទុកហើយ ។

ហេតុឲ្យធ្វើទានមាន ៨ យ៉ាង

១- ព្រោះមានអ្នកនិមន្តមកទទួលដល់ទីកន្លែង
២- ព្រោះខ្លាចអន្តរាយខ្លាចគេតិះដៀលខ្លាចមិនទៅសួគ៌

៣- ព្រោះគិតថា គេឱ្យដល់អញ ត្រូវឱ្យទៅវិញ

៤- ព្រោះគិតថា គេនឹងឱ្យដល់អញវិញគួរឱ្យគេមុន

៥- ព្រោះគិតថា ការឱ្យទានជាការប្រសើរ

៦- ព្រោះគិតថា គេមិនទាន់ចំអិន អញចំអិនរួចមុន

៧- ព្រោះគិតថា កាលអញឱ្យទាននេះកិត្តិសព្ទរបស់អញ រមែងខ្ចរខ្ចាយទៅ

៨-ព្រោះដើម្បីញុំាងឱ្យចិត្តស្អាតផូរផង់ប្រាសចាកកិលេស ។

ហេតុនាំឱ្យធ្វើទាន ៨ យ៉ាងទៀត

១- ព្រោះសេចក្តីស្រឡាញ់

២- ព្រោះសេចក្តីក្រោធ

៣- ព្រោះសេចក្តីវង្វេង

៤- ព្រោះសេចក្តីភ័យខ្លាច

៥-ព្រោះគិតថា ជីដូនជីតាទាំងឡាយរបស់អញធ្លាប់ ឱ្យធ្លាប់ធ្វើមក អញមិនគួរញុំាងវង្សត្រកូលពីបុរាណនុ៎ះ ឱ្យវិនាស

៦- ព្រោះគិតថា អញឱ្យទាននេះ ចិត្តរមែងជ្រះថ្លា ទាំងសេចក្តីពេញចិត្ត និងសោមនស្សក៏រមែងកើតឡើង

៧- ព្រោះគិតថា អញឱ្យនេះលុះបែកធ្លាយរាងកាយស្លាប់ទៅ និងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក

៨- ព្រោះត្រូវការធ្វើចិត្តឱ្យផូរផង់ ។

ហេតុនាំឱ្យធ្វើទាន ៨ យ៉ាងទៀត ព្រោះត្រូវការទៅកើតជា ៖

១- ក្សត្រិយ៍ ព្រាហ្មណ៍មហាសាល គហបតី

២- ទេវតាជាន់ចាតុម្មហារាជិកា

៣- ទេវតាជាន់តាវត្តឹង្ស

៤- ទេវតាជាន់យាមា

៥- ទេវតាជាន់តុសិត

៦- ទេវតាជាន់និម្មានរតី

៧- ទេវតាជាន់បរនិម្មិតវសវតី

៨- ទេវតាជាន់ព្រហ្ម ។

(ចាក.គម្ពីរឃ្លាំងបរិយត្តិភាគ ២,ទំព័រ ៥៨)

សប្បុរិសទានសូត្រ

នៅក្នុងបិដកលេខ ៤៥, ទំព័រ ៨៨ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់អំពី **[ទានរបស់សប្បុរស ៥យ៉ាង]** ជាមួយនឹងភិក្ខុទាំងឡាយ ដោយមានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ**សប្បុរិសទាននេះមាន ៥ យ៉ាង ។**

សប្បុរិសទាន ៥ យ៉ាង ដូចម្តេចខ្លះ?

១- សទ្ធាយ ទានំ ទេតិ គឺឱ្យទានដោយសទ្ធា

២- សក្កច្ចំ ទានំ ទេតិ ឱ្យទានដោយគោរព

៣- កាលេន ទានំ ទេតិ ឱ្យទានតាមកាលគួរ

៤- អនុគ្គហិតចិត្តោ ទានំ ទេតិ ឱ្យទានដោយចិត្តអនុគ្រោះ

៥- អត្តានញ្ច បរញ្ច អនុបហាញ្ច ទានំ ទេតិ ឱ្យទានដោយមិនបានបៀតបៀនខ្លួនឯងនិងអ្នកដទៃ ។

ម្នាលភិក្ខុទាំងឡាយ **បុគ្គលឱ្យទានដោយសទ្ធា, ដោយផលទាននោះ កើតក្នុងទីណា ។ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន**

មានភោគៈច្រើនផង ជាបុគ្គលមានរូបល្អ គួរមិលមើល ជាទីជ្រះថ្លា ប្រកបដោយភាពជាអ្នកមានសម្បុរល្អដ៏ក្រៃលែងផង ។

ម្នាលភិក្ខុទាំងឡាយ **បុគ្គលឱ្យទានដោយគោរព,** *ដោយផលទាននោះ កើតក្នុងទីណា ៗជាបុគ្គលស្អុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង ពួកជនណាទោះកូនក្តី ប្រពន្ធក្តី ខ្ញុំក្តី អ្នកបម្រើក្តី អ្នកធ្វើការងារក្តី របស់បុគ្គលនោះ ជនទាំងនោះតែងស្តាប់ដោយល្អ ផ្អៀងសោតតាំងចិត្តដើម្បីដឹងផង ។*

ម្នាលភិក្ខុទាំងឡាយ **បុគ្គលឱ្យទានតាមកាលដ៏គួរ,** *ដោយផលទាននោះ កើតក្នុងទីណា ៗ ជាបុគ្គលស្អុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង ប្រយោជន៍គឺភោគៈដ៏ពោរពេញ រមែងមកតាមកាលដ៏គួរដល់បុគ្គលនោះឯង ។*

ម្នាលភិក្ខុទាំងឡាយ **បុគ្គលឱ្យទានដោយចិត្តអនុគ្រោះ,** *ដោយផលទាននោះ កើតក្នុងទីណា ៗ ជាបុគ្គលស្អុកស្តម្ភ មានទ្រព្យច្រើនមានភោគៈច្រើនផង រមែងបង្អោនចិត្តទៅដើម្បីបរិភោគក្នុងកាមគុណ ៥ ដ៏លើសលុបផង ។*

ម្នាលភិក្ខុទាំងឡាយ **បុគ្គលឱ្យទានដោយមិនបាន** បៀត

ប្បឹនខ្លួនឯងនិងអ្នកដទៃ, ដោយផលទាននោះកើតក្នុងទីណា ៗ ជាបុគ្គលស្តុកស្តម្ភ មានទ្រព្យច្រើន មានភោគៈច្រើនផង សេចក្តីអន្តរាយនៃភោគៈទាំងឡាយមិនមានមកអំពីណាមួយ គឺអំពីភ្លើង អំពីទឹកអំពីស្តេច អំពីចោរ អំពីហេតុមិនជាទីស្រឡាញ់ នឹងអំពីមនុស្សជាទាយាទ ។

ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាន មាន ៥យ៉ាងនេះឯង ។

អដ្ឋកថា

បទថា សទ្ធាយ បានដល់ ជឿទាន និងផលរបស់ការធ្វើទាន ។

បទថា សក្កច្ចំ បានដល់ ធ្វើចិត្តឱ្យស្អាតក្នុងការឱ្យទាន គោរពកោតក្រែងក្នុងទេយ្យធម៌ និងក្នុងទក្ខិណេយ្យបុគ្គល ។ ទានទាំងពីរយ៉ាងនេះ បុគ្គលរៀបចំទេយ្យធម៌ឱ្យប្រណីតឈ្មោះ ថាចូលទៅតាំងសេចក្តីគោរពកោតក្រែងក្នុងទេយ្យធម៌ ឯការជ្រើសរើសបុគ្គលហើយឱ្យឈ្មោះថា ចូលទៅតាំងសេចក្តីគោរពកោតក្រែងក្នុងទក្ខិណេយ្យបុគ្គល ។

បទថា កាលេន បានដល់តាមកាលដែលសមគួរឱ្យ ។

បទថា **អនុគ្គហចិត្តោ** បានដល់ មានចិត្តមិនស្តាយ គឺ មានចិត្តលះជាច់តែម្តង ។

បទថា **អនុបហញ្ញ** បានដល់ មិនប៉ះទង្គិច គឺមិនលុបបំបាត់គុណទាំងឡាយ ។

បទថា **កាលាគតា ចស្ស អត្តា បរិបូរា ហោន្តិ** សេចក្តីថា ប្រយោជន៍ កាលដែលនឹងមកដល់មិនមែនមកក្នុងវ័យតាល់តែចាស់ហើយនោះទេ គឺ រមែងមកក្នុងពេលដ៏សមគួរក្នុងបឋមវ័យនោះឯងទាំងដែលមកដោយច្រើនផង ។

រឿងពារាណសីសេដ្ឋីបុត្រ

កាលកន្លងទៅហើយ ព្រះពោធិសត្វទ្រង់សោយព្រះជាតិជាកូនសេដ្ឋីនៅក្នុងនគរពារាណសីលុះឥតអំពីបិតាធ្វើមរណកាលទៅព្រះបាទព្រាហ្មទត្តបានតែងតាំងព្រះពោធិសត្វ ជាសេដ្ឋីនៅក្នុងនគរពារាណសីគ្រប់គ្រងសម្បត្តិជំនួញបិតា ។ ព្រះពោធិសត្វជាបុគ្គលមានសទ្ធាមុតមាំជឿកម្មផលច្បាស់លាស់ បានចំណាយទ្រព្យធ្វើមរណសាលាទាន ៦ កន្លែង ហើយតែងបរិច្ចាគទាន រក្សាទានឧបោសថសីលជានិច្ចពុំដែលខាន ។ វេលាថ្ងៃមួយនេះព្រះ

ពោធិសត្វរៀបបរិច្ចាគអាហារពេលព្រឹក ស្រាប់តែមានព្រះបច្ចេក
មួយព្រះអង្គ ទើបនិងចេញចាកនិរោធសមាបត្តិ ហោះមកឈរទៀប
ទ្វារផ្ទះ ។ ព្រះពោធិសត្វក្រេឡេកទៅឃើញទើបប្រើបុរសម្នាក់ឱ្យ
ទៅយកបាត្រពីលោកមកជាក់ចង្ហាន់, គ្រានោះមារាធិរាជមកនិម្មិត
ធ្វើជារណ្តៅរងើកភ្លើងក្រហមរន្ទាលច្រាលឆ្អៅ ដូចជាអវិចីមហា-
នរក ។ បុរសម្នាក់ទៅយកបាត្រឃើញភ្លើងនោះហើយ ភិតភ័យ
ណាស់ត្រឡប់មកជំរាបព្រះពោធិសត្វវិញ ព្រះពោធិសត្វបានយល់
ច្បាស់ថា មារនៅឯហានបរនិម្មិតវសវត្តីមកធ្វើអន្តរាយទានផង ឱ្យ
អន្តរាយព្រះជន្មព្រះបច្ចេកពុទ្ធផង ទើបយកភាជន៍ដាក់ចង្ហាន់ពេញ
ចេញអំពីផ្ទះទៅឈរក្បែររណ្តៅភ្លើងហើយទូលព្រះបច្ចេកពុទ្ធថា

កាមំ បតាមិ និរយំ ឧទ្ធំបាទោ អវំសិរោ

ទានរិយំ ករិស្សាមិ ហន្ទ បិណ្ឌំ បដិគ្គហ ។

ប្រែជាសេចក្តីថា បពិត្រលោកម្ចាស់ដ៏ចម្រើន បើទុកណា
ជាខ្ញុំធ្លាក់ដាំក្បាលចុះក្នុងរណ្តៅភ្លើងដូចជានរកនោះ ក៏ខ្ញុំមិនថយ
ក្រោយវិញដែរ សូមព្រះករុណាម្ចាស់ទទួលយកនូវចង្ហាន់នេះចុះ ។

ព្រះពោធិសត្វនិយាយទូលព្រះបច្ចេកពុទ្ធដូច្នេះហើយ ក៏

លោកចុះទៅរណ្តៅភ្លើង ស្រាប់មានផ្កាឈូកផុះទ្រជើងយ៉ាងអស្ចារ្យ ព្រះពោធិសត្វបានយកចង្ក្រានទៅដាក់ក្នុងបាត្រប្រគេនព្រះបច្ចេកពុទ្ធដោយសួស្តី ។

ឯមារឃើញហេតុអស្ចារ្យដូច្នោះហើយ ភ័យតក់ស្លុតវិនាសបាត់អំពីទីនោះទៅ ។

ហេតុឱ្យទានមិនបាននិងទោសនៃសេចក្តីកំណាញ់

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់សម្តែងថា ការឱ្យទាននេះមានផលានិសង្សច្រើនប្រការណាស់ ប៉ុន្តែក៏នៅមានបុគ្គលមួយចំនួនមួយទៀតដែលមិនអាចនិងឱ្យទានបាន ។ នៅក្នុងបិដក លេខ ៥៩ ទំព័រ ៩១៦ មានជាតកមួយឈ្មោះពិលារកោសិយ ដែលនិយាយអំពីបុគ្គលឱ្យទានមិនបានដោយហេតុ ២ យ៉ាងគឺ **មច្ឆេរ ច** ដោយសេចក្តីកំណាញ់ ១, **បមាទ ច** សេចក្តីប្រមាទ ១ ។ មានបុគ្គលពួកខ្លះនៅក្នុងលោកនេះ មានទ្រព្យសម្បត្តិច្រើនតែមានទូវសេចក្តីកំណាញ់ស្ងិតស្ងាញ មិនដែលបានបរិច្ចាគទ្រព្យសូម្បីតែមួយកាក មួយសេន មួយរយ មួយរៀលក៏អត់មានដែរ ព្រោះគេគិតថា កាលបើគេបរិច្ចាគទ្រព្យធ្វើទានទៅ នោះទ្រព្យរបស់និងអស់ទៅជាមិនខាន ដូច្នេះហើយក៏មានទូវសេចក្តីកំណាញ់ ។

សេចក្តីកំណាញ់នេះមានទោសច្រើនណាស់ ដូចជាក្នុងព្រះគាថា-ធម្មបទ បិដកលេខ **៥២**, ទំព័រ **៥៩** ព្រះអង្គប្រារព្ធ **អសទិសទាន** របស់ព្រះបាទបសេនទិកោសល ដោយមានអ្នកតិះដៀល មានអ្នកសរសើរនូវទានទោះ ព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ត្រាស់ថា ៖

ន វេ កទរិយា ទេវលោកំ វជន្តិ
ពាលា ហវេ នប្បសំសន្តិ ទានំ
ធីរោ ច ទានំ អនុមោទមានោ
តេនេវ សោ ហោតិ សុខី បរត្ថ ។

បុគ្គលកំណាញ់ស្វិតស្វាញមិនបានទៅកាន់ទេវលោកឡើយ បុគ្គលពាលតាំងឡាយ មិនសរសើរនូវការឱ្យទានទេ ចំណែកអ្នកប្រាជ្ញ តែងអនុមោទនានូវទាន ព្រោះហេតុនោះ ធីរជន អ្នកអនុមោទនានូវទាននោះឯង រមែងបានសុខក្នុងលោកខាងមុខ (ពោលគឺ បានសោយទិព្វសម្បត្តិក្នុងទេវលោក) ។ ពេលចប់ព្រះធម៌-ទេសនា អាមាត្យឈ្មោះ ជុណ្ហៈ តាំងនៅក្នុងសោតាបត្តិផល ។

ម្យ៉ាងទៀត សេចក្តីកំណាញ់នេះមានទោសច្រើនប្រការ ។ នៅក្នុងអដ្ឋកថាលេខ ២៣ លោកមានការសម្តែងរឿងតោទេយ្យ-

ព្រាហ្មណ៍ដែលគាត់គឺជាបុរោហិតរបស់ព្រះបាទបសេនទិកោសល គាត់មានទ្រព្យសម្បត្តិ ៨៧ កោដិ តែគាត់គឺជាមនុស្សមានទុវសេចក្តីកំណាញ់ ពេលគាត់ស្លាប់ទៅក៏បានទៅកើតជាសុនខនៅក្នុងផ្ទះរបស់ខ្លួនតែម្តង ។ ក្នុងអដ្ឋកថាលេខ ៤៣ លោកមានការសម្តែងរឿងអានន្ទសេដ្ឋីមានសេចក្តីកំណាញ់ គាត់ស្លាប់ទៅក៏បានទៅកើតនៅក្នុងផ្ទៃនៃត្រកូលចណ្ឌាល មនុស្សមិនសមជាមនុស្ស គ្រាន់តែចាប់បដិសន្ធិនៅក្នុងផ្ទៃនៃត្រកូលចណ្ឌាលភ្លាមធ្វើមនុស្សចណ្ឌាលទាំងអស់នោះ ដើរសុំទានគេមិនបាន នេះជាទោសនៃសេចក្តីកំណាញ់ ។ នៅក្នុងបិដកលេខ ២៩ លោកក៏បានសម្តែងរឿងអបុត្តកសេដ្ឋីមានសេចក្តីកំណាញ់ ធ្វើទានស្តាយក្រោយហើយថែមទាំងបានសម្លាប់កូនប្រុសរបស់បងខ្លួនទៀត ព្រោះតែទ្រព្យស្លាប់ទៅក៏បានទៅកើតនៅក្នុងអវុវនរក ។ នេះជាទោសរបស់បុគ្គលដែលមានទុវសេចក្តីកំណាញ់ និងនៅមានរឿងច្រើនទៀតដែលព្រះអង្គសម្តែងទាក់ទងទៅនឹងរឿងនេះ ។

ឯចំណែកបុគ្គលឱ្យទានមិនបាន ព្រោះសេចក្តីប្រមាទវិញនោះ គឺបានដល់ អ្នកដែលមិនមានសេចក្តីកំណាញ់ទេ តែមានការធ្វេសប្រហែសក្នុងការសាងល្អ ដោយគេមានគំនិតគិតថា ខ្លួនទៅ

ក្មេង មានសក់ខ្មៅស្រិល មានសុខភាពល្អ មានកម្លាំងពលំមាំមួន មានកិច្ចការងារធ្វើច្រើន ដូច្នេះចំពោះរឿងធ្វើទាន រក្សាសីល ចម្រើនភាវនាស្តាប់ធម៌រៀនធម៌ ចូលវត្តជាដើមវាគឺជារឿងរបស់មនុស្សចាស់ ៗ ដូច្នេះហើយមិនបានធ្វើនូវសេចក្តីល្អទៅ ។ ការមាននូវសេចក្តីប្រមាទ គឺជាការបាត់បង់នូវសតិ ។ ការបាត់បង់នូវសតិនោះធ្វើឱ្យមនុស្សយើងធ្វើខុស ៗជានិច្ច, បុគ្គលមានសេចក្តីប្រមាទ ព្រះអង្គទ្រង់ត្រាស់ថា ស្លាប់បាត់ទៅហើយ **បមាទោ មច្ចុនោ បទំ** គឺស្លាប់នូវគំនិតដែលនឹងគិតឡើងថា អញនឹងធ្វើទានរក្សាសីលជាដើម ។ **ជីវិតរបស់មនុស្សយើងនេះ មិនទៀតទាត់ទេ អាចស្លាប់បានគ្រប់ពេលទាំងអស់** ព្រោះហេតុនោះបានជាព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ថា **កុំឱ្យមានសេចក្តីប្រមាទ ។**

អាឝិត្តវគ្គ **មច្ឆរិសុត្រ**

នៅក្នុងបិដកលេខ ២៩, ទំព័រ ៨៧ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់អំពី [**ផលវិបាករបស់មនុស្សកំណាញ់**] មានសេចក្តីថា ៖

ទេវតាទូលសួរថា ៖

យេធ មច្ចរិនោ លោកេ កទរិយា បរិភាសកា
អញ្ញេសំ ទទមានានំ អន្តរាយករា នរា
តីធិសោ តេសំ វិបាកោ សម្បរាយោ ច តីធិសោ
ភគវន្តំ បុដ្ឋមាគម្ម កថំ ជានេមុ តំ មយន្តិ ។

ក្នុងលោកនេះ ជនទាំងឡាយណា ជាអ្នកកំណាញ់ស្វិតស្វាញ ជាអ្នកពោលពាក្យទ្រគោះ ជាអ្នកធ្វើសេចក្តីអន្តរាយដល់ជនដទៃ ដែលកំពុងឱ្យទាន ផលវិបាករបស់ជន ទាំងឡាយនោះដូចម្តេច សម្បរាយភពរបស់ជនទាំងឡាយនោះ ដូចម្តេច យើងខ្ញុំមកដើម្បីក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូចម្តេចហ្ន៎ នឹងដឹងនូវសេចក្តីនោះបាន ។

ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់តបថា ៖

យេធ មច្ចរិនោ លោកេ កទរិយា បរិភាសកា
អញ្ញេសំ ទទមានានំ អន្តរាយករា នរា
និរយំ តិរច្ឆានយោនិ យមលោកូបបជ្ជរេ
សចេ ឯន្តិ មនុស្សត្តំ ទឡ្ឍិទ្ធេ ជាយរេ កុលេ

ចោឡំ បិណ្ឌោ រតឺ ឱិទ្ធា យត្ថ កិច្ចេន លព្ភតិ
បរតោ អាសីសរេ ពាលា តំបិ តេសំ ន លព្ភតិ
ឥដ្ឋេ ធម្មេស វិបាកោ សម្បរាយោ ច ទុគ្គតីតិ ។

ក្នុងលោកនេះ ជនទាំងឡាយណាជាអ្នកកំណាញ់ស្វិតស្វាញ ជាអ្នកពោលពាក្យទ្រគោះ ជាអ្នកធ្វើសេចក្តីអន្តរាយដល់ជនដទៃ ដែលកំពុងឱ្យទាន ជនទាំងឡាយនោះ តែងទៅកើតក្នុងនរក ក្នុងកំណើតសត្វតិរច្ឆាននិងក្នុងយមលោក ប្រសិនបើដល់នូវភាពមនុស្សវិញមែងកើតក្នុងត្រកូលកំសត់ស្វែងរកតែសំពត់និងអាហារនិងសេចក្តីត្រេកអរក្នុងបញ្ចកាមគុណ និងល្បែង ក៏បានដោយកម្រ ពួកពាលតែង នឹកប៉ង់នូវទ្រព្យណាអំពីទីដទៃ ទ្រព្យនោះ មិនដែលបានដល់ពួកពាលនោះឡើយ នេះជាផលវិបាកក្នុងទិដ្ឋធម៌គឺក្នុងទីដែលកើត ចំណែកសម្បរាយភព វិញមែងមានទុគ្គតិជាផល ។

ទេវតាទូលសួរថា ៖

ឥតិ ហេតំ វិជានាម អញ្ញំ បុច្ឆាម គោតមំ
យេធ លទ្ធា មនុស្សត្តំ វធញ្ញូ វីតិមច្ចរា
ពុទ្ធេ បសន្នា ធម្មេ ច សង្ឃេ ច តិព្ពគារវា

កីទិសោ តេសំ វិចារកោ សម្បរាយោ ច កីទិសោ ភគវន្តំ បុដ្ឋមាគម្ម កថំ ជនេមុ តំ មយន្តិ ។

យើងខ្ញុំដឹងសេចក្តីនេះជាក់ច្បាស់ដូច្នេះហើយ យើងខ្ញុំសូមក្រាបបង្គំទូលសួរនូវសេចក្តីដទៃនឹងព្រះគោតមជាម្ចាស់ តទៅទៀត ក្នុងលោកនេះ ជនទាំងឡាយណាបាននូវអត្តភាពមនុស្សហើយ ជាអ្នកជ្រះថ្លាទាំងមានសេចក្តីគោរព យ៉ាងខ្លាំង ក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ផលវិបាករបស់ជនទាំងនោះ ដូចម្តេច សម្បរាយភព របស់ជនទាំងនោះ ដូចម្តេច យើងខ្ញុំមកដើម្បីក្រាបបង្គំទូលសួរព្រះមានព្រះភាគ ដូចម្តេចហ្ន៎ នឹងដឹងនូវសេចក្តីនោះបាន ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់តបថា ៖

យេធ លទ្ធា មនុស្សត្តំ វធញ្ញូ វីតិមច្ចរា
ពុទ្ធេ បសន្នា ធម្មេ ច សង្ឃេ ច តិព្ពគារវា
ឯតេ សគ្គេ បកាសេន្តិ យត្ថ តេ ឧបបជ្ជរេ
សចេ ឯត្ថិ មនុស្សត្តំ អឌ្ឍេ អាជាយរេ កុលេ
ចោឡេ បិណ្ឌោ រតី ខិឌ្ឌា យត្ថាកិច្ចេន លព្ភតិ
បរសម្ភតេសុ ភោគេសុ វសវត្តីវ មោទរេ

ឥដ្ឋេ ធម្មេ សរិទ្ធាកោ សម្បរាយោ ច សុគតីតិ ។

ក្នុងលោកនេះ ជនទាំងឡាយណា បានអត្តភាពជាមនុស្ស
ហើយ ជាអ្នកជឿនូវពាក្យពោល ជាអ្នកប្រាសចាកសេចក្តីកំណាញ់
ជាអ្នកជ្រះថ្លា ទាំងមានសេចក្តីគោរពយ៉ាងខ្លាំង ក្នុងព្រះពុទ្ធ ព្រះ
ធម៌ ព្រះសង្ឃ ជនទាំងឡាយនោះ រមែងរុងរឿងក្នុងឋានសួគ៌ ជន
ទាំងឡាយនោះ ទោះទៅកើតក្នុងទីណា បើដល់នូវអត្តភាពជាមនុស្ស
រមែងកើតក្នុងត្រកូលដ៏ស្តុកស្តម្ភ ស្វែងរកសំពត់ និងអាហារ និង
សេចក្តីត្រេកអរក្នុងបញ្ចកាមគុណ និងល្បែងបានដោយងាយទាំង
មានអំណាចផ្សាយទៅក្នុងភោគៈទាំងឡាយ ដែលអ្នកដទៃសន្សំ
បានមក សប្បាយរីករាយក្នុងចិត្ត នេះជាផលវិបាកក្នុងទិដ្ឋធម៌គឺ
ក្នុងទីដែលកើតចំណែកសម្បរាយភពរមែងមានសុគតិជាផល ។

អដ្ឋកថា

បទថា **មច្ឆរិនោ** ប្រែថា អ្នកប្រកបដោយសេចក្តីកំណា-
ញ់ ។ ពិតមែន អ្នកខ្វះមិនព្រមលូកដៃចេញសំពះសូម្បីភិក្ខុទាំង
ឡាយក្នុងទីជាទីនៅរបស់ខ្លួន គឺថា ឧបាសកម្នាក់ទៅក្នុងទីដទៃចូល
ទៅកាន់វិហារសំពះដោយគោរពហើយ ធ្វើការរាក់ទាក់ប្រាស្រ័យ

ន៏ឯភិក្ខុ ដោយពាក្យដ៏ពីរោះថា បពិត្រលោកដ៏ចម្រើន លោកទាំងឡាយ រមែងមិនមកកាន់ទីជាទីនៅរបស់ពួកខ្ញុំ ពេលនោះជាប្រទេសដែលសម្បុរណ៍ ពួកខ្ញុំអាចដើម្បីនឹងធ្វើការទំនុកបម្រុងលោកម្ចាស់ទាំងឡាយដោយយាគូនិងភត្តជាដើម ។ ភិក្ខុគិតថា ឧបាសកនេះមានសទ្ធានឹងសង្គ្រោះពួកយើងដោយបាយយាគូជាដើម ។ លំដាប់នោះ ព្រះថេរៈមួយរូបចូលទៅស្រុកនោះ ដើម្បីត្រាច់ទៅបិណ្ឌបាត ។ ចំណែកឧបាសកនោះឃើញព្រះថេរៈនោះ ហើយរមែងជៀសទៅផ្លូវដទៃ ឬចូលទៅកាន់ផ្ទះ គិតថា"បើព្រះថេរៈមកនៅចំពោះមុខយើងក៏ត្រូវលើកដៃសំពះ ហើយក៏ត្រូវថ្វាយភិក្ខាដល់លោកម្ចាស់ កុំដូច្នោះឡើយ យើងនឹងទៅដោយការងារអ្វីមួយ" ដូច្នេះហើយគេចជៀសចេញទៅ ព្រះថេរៈត្រាច់ទៅកាន់ស្រុកទាំងអស់ជាអ្នកមានបាត្រទទេចេញមកហើយ ។ ប្រការនេះ ឈ្មោះថា សេចក្តីកំណាញ់យ៉ាងខ្លាំង (មុទ្ទមច្ឆរិយៈ) ។

បុគ្គលសូម្បីមិនមែនជាទាយក រមែងធ្វើហាក់បីដូចជាទាយក គឺជាអ្នកប្រកបព្រោះហេតុយ៉ាងណានោះ ក្នុងទីនេះលោកប្រាថ្នាយកបុគ្គលដែលមានសេចក្តីកំណាញ់ខ្លាំង (ថទ្ធមច្ឆរិយៈ)គឺថា

ឧបាសកនោះ ប្រកបដោយមច្ឆរិយៈយ៉ាងណា កាលមានអ្នកពោលថា ភិក្ខុទាំងឡាយចូលទៅដើម្បីបិណ្ឌបាត ព្រះថេរៈទាំងឡាយឈរហើយដូច្នេះ ក៏និងនិយាយថា"ជើងរបស់យើងឈឺមិនមែនឬ" និងជាអ្នកវង្វែង ឈរជូចសសរឬ ឬដូចជង្គត់ឈើ រមែងមិនធ្វើសូម្បីសាមីចិកម្ម ។

បទថា កទរិយោ សេចក្តីសង្ខេបនេះទុកជាវចនៈរបស់សេចក្តីកំណាញ់នោះឯង ព្រោះថា សេចក្តីកំណាញ់យ៉ាងខ្សោយ លោកហៅថា មច្ឆរិយៈ ចំណែកសេចក្តីកំណាញ់ លោកហៅថា កមរិយៈ ។ ពាក្យថា បរិភាសតោ ពោលពាក្យទ្រគោះគឺថាឃើញភិក្ខុទាំងឡាយ ឈរត្រង់ទ្វារស្រុក ក៏និងគំរាមដោយពាក្យថា "ពួកលោកមកភ្លាវស្រែឬ ឬមកសាបព្រោះស្រូវ ទើបមករហ័សណាស់ សូម្បីពួកយើងក៏មិនទាន់បានដើម្បីខ្លួន នឹងបានអាហារដើម្បីលោកអំពីណា" ដូច្នេះជាដើម ។ ពាក្យថា អន្តរាយករា ប្រែថា ធ្វើការជំទាស់រារាំង គឺជាអ្នកធ្វើអន្តរាយទាំងឡាយរបស់ជនទាំងនេះ គឺធ្វើអន្តរាយសួគ៌របស់ទាយក ធ្វើអន្តរាយលាភរបស់បដិគ្គាហក និងបំផ្លាញខ្លួនឯង ។ ពាក្យថា សម្បរាយោ បានដល់បរលោក ។

ពាក្យថា រតិ បានដល់ សេចក្តីរីករាយក្នុងកាមគុណ ៥ ។

ពាក្យថា **ខិឌ្ឌា** បានដល់ សេចក្តីសប្បាយរីករាយ ៣ យ៉ាង មានសេចក្តីសប្បាយរីករាយផ្លូវកាយជាដើម ។

ពាក្យថា **ឯដ្ឋេ ធម្មេ សវិចារកោ** បានដល់ នោះជាវិបាកក្នុងភពបច្ចុប្បន្ន ដែលជាទី ៗខ្លួនកើតហើយ ៗ ។

ពាក្យថា **សម្បរាយោ ច ទុគ្គតិ** បានដល់ បុគ្គលទាំងនោះ រមែងចូលដល់យមលោក ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ភពមុខក៏ជាទុគ្គតិ ។

ពាក្យថា **វនញ្ញូ** ដ៏ងពាក្យ សេចក្តីថា ភិក្ខុទាំងឡាយឈរត្រង់ទ្វារស្រុក នឹងជាអ្នកស្ងៀមសូម្បីក៏ពិត តែក៏ឈ្មោះថា រមែងពោលថា សូមពួកលោកចូរឱ្យភិក្ខាដើម្បីប្រយោជន៍ ដូច្នេះ គឺថា ជនពួកណារមែងបែងចែកទេយ្យធម៌ដោយពោលថា ពួកយើងនឹងដាំបាយជនទាំងនេះរមែងមិនដាំ កាលយើងមិនដាំពួកភិក្ខុនឹងបានបាយអំពីណាដូច្នេះ ព្រោះហេតុនោះ ជនទាំងនោះទើបឈ្មោះថា **វនញ្ញូ** ប្រែថា ដ៏ងពាក្យ ។

ពាក្យថា **បគាសេន្តិ** រមែងប្រាកដ គឺថា រមែងរុងរឿង

ដោយវស្មីនៃវិមាន ។ ពាក្យថា **បរសម្ពតេសុ** ប្រែថា ភោគទ្រព្យ ដែលអ្នកដទៃកសន្សំទុក បានដល់ ដែលអ្នកដទៃបរបួរមទុក ។ ពាក្យថា ទាំងភពមុខក៏ជាសុគតិ សេចក្តីថា សម្បរាយភពដែលព្រះមានព្រះភាគត្រាស់ហើយយ៉ាងនេះថា **ឯតេមង្គា** ដូច្នេះ ឈ្មោះថា សុគតិ ។

ម្យ៉ាងទៀត អធិប្បាយថា កាលជនទាំងនោះ សូម្បីទាំងពីរពួកឃ្លាតហើយអំពីទីនោះភពមុខទៀត រមែងជាទុគ្គតិនិងសុគតិដូច្នេះឯង ។

សតុល្លបកាយិកាវគ្គ មច្ឆរិសុត្រ

នៅក្នុងបិដកលេខ ២៥, ទំព័រ ៤៧ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី [**ហេតុឱ្យទានមិនបាន**]មានសេចក្តីថា ៖

សម័យមួយ ព្រះមានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ គ្រានោះឯង កាលរាត្រីបឋមយាមកន្លងហើយ មានពួកសតុល្លបកាយិកាទេវតាជាច្រើនមានវស្មីរុងរឿង ញុំាងវត្តជេតជនទាំងមូលឱ្យភ្លឺស្វាង ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះមាន

ព្រះភាគហើយ ឈរក្នុងទីដ៏សមគួរ ។

លុះទេវតាមួយអង្គ ឈរក្នុងទីដ៏សមគួរហើយ ក៏ពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

មច្ឆរា ច បមាទា ច ឯវំ ទានំ ន ទីយតិ
បុញ្ញមាកង្ខមានេន ទេយ្យំ ហោតិ វិជានតាតិ ។

ព្រោះសេចក្តីកំណាញ់ និងសេចក្តីប្រមាទ បានជានរជនឱ្យទានមិនកើតយ៉ាងនេះ **ទាន** កាលបើបុគ្គលដឹងច្បាស់ ជាអ្នកប្រាថ្នានូវបុណ្យគួរតែឱ្យ ។

លំដាប់នោះឯង ទេវតាមួយអង្គទៀត បានពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

យស្សេវ កីតោ ន ទទាតិ មច្ឆរី
តទេវ អទទតោ ភយំ ជិឃច្ឆា ច បិបាសា ច
យស្ស ភាយតិ មច្ឆរី តមេវ ពាលំ ផុសតិ
អស្មឹ លោកេ បរម្ហិ ច តស្មា វិនេយ្យ មច្ឆរំ
ទជ្ជា ទានំ មលាភិភូ បុញ្ញានិ បរលោកស្មឹ
បតិដ្ឋា ហោន្តិ បាណិនន្តិ ។

មនុស្សកំណាញ់ ភ័យចំពោះហេតុណា ហើយមិនឱ្យទាន ហេតុនោះឯង ជាភ័យរបស់អ្នកមិនឱ្យ បុគ្គលកំណាញ់ខ្លាចចំពោះហេតុណា ព្រោះសេចក្តីឃ្លានឥតស្រេក ហេតុនោះឯង តែងពាល់ត្រូវបុគ្គលពាលក្នុងលោកនេះ និងលោកខាងមុខ ព្រោះហេតុនោះ សាធុជន គួរតែកំចាត់បង់នូវសេចក្តីកំណាញ់ ជាអ្នកគ្រប់សង្កត់នូវមន្ទិល ហើយត្រូវឱ្យទាន ព្រោះថា បុណ្យទាំងឡាយ ជាទីពឹងរបស់ពួកសត្វ ក្នុងលោកខាងមុខ ។

លំដាប់នោះឯង ទេវតាមួយអង្គទៀត បានពោលគាថានេះក្នុងសំណាក់នៃព្រះមានៃព្រះភាគថា ៖

តេ បតេសុ ន មិយ្យន្តិ អន្ធានំវ សហាវជំ
អប្បស្មឹ យេ បវេច្ឆន្តិ ឯស ធម្មោ សនន្តនោ
អប្បស្មេកេ បវេច្ឆន្តិ ពហុនេកេ ន ទិច្ឆរេ
អប្បស្មា ទក្ខិណា ទិន្នា សហស្សេន សមំ មិតាតិ ។

ពួកជនណាកាលទ្រព្យមានតិច ក៏នៅតែឱ្យទានបាន ដូចជាអ្នកដើរផ្លូវឆ្ងាយ ចែកស្បៀងដែលមានតិចតួចដល់គ្នាបាន កាលបើគេស្លាប់រាល់គ្នា ជននោះឈ្មោះថា មិនស្លាប់ ធម៌នេះជាធម៌

របស់បូរាណាចារ្យ ជនពួកខ្លះ កាលទ្រព្យមានតិចក៏នៅតែឱ្យទានបាន ជនពួកខ្លះសូម្បីសម្បូរណ៌ទ្រព្យច្រើន ក៏ឱ្យទានមិនកើតទុក្ខិណាទានដែលគេបែងអំពីទ្រព្យតិចហើយឱ្យរមែងមានផលស្មើគ្នានឹងទានរាប់ពាន់ ។

លំដាប់នោះឯង ទេវតាមួយអង្គទៀត បានពោលគាថានេះក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

ទុទ្ទទំ ទទមានានំ ទុក្ករំ កម្មកុព្វតំ
អសន្តោ នានុកុព្វន្តិ សតំ ធម្មោ ទុរន្នយោ
តស្មា សតញ្ច អសតញ្ច នានា ហោតិ ឥតោ គតិ
អសន្តោ និរយំ យន្តិ សន្តោ សគ្គបរាយនោន្តិ ។

កាលបើពួកសប្បុរស កំពុងឱ្យរបស់ដែលឱ្យបានដោយកម្រកំពុងធ្វើអំពើដែលធ្វើបានដោយកម្រពួកអសប្បុរសធ្វើតាមមិនបាន ព្រោះធម៌របស់ពួកសប្បុរស គឺពួកអសប្បុរសប្រព្រឹត្តតាមបានដោយកម្រ ព្រោះហេតុនោះ គតិរបស់ពួកសប្បុរសនិងអសប្បុរស រមែងផ្សេងគ្នាអំពីលោកនេះទៅ គឺ ពួកអសប្បុរសទៅកាន់នរក ពួកសប្បុរសទៅកាន់ឋានសួគ៌ ។

លំដាប់នោះឯង ទេវតាមួយអង្គទៀត បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ភាសិតរបស់អ្នកណាហ្ន៎ ជាសុភាសិត ។

ភាសិតរបស់អ្នកទាំងឡាយគ្នាជាសុភាសិតដោយបរិយាយដែរហើយ តែអ្នកទាំងឡាយ ចូរស្តាប់ភាសិតរបស់តថាគតវិញថា ៖

ធម្មំ ចរេ យោបិ សមុញ្ជកំ ចរេ ធារំ ច
ផោសំ ឧទំ អប្បកស្មឹ
សតំ សហស្សាន សហស្សយាគិនំ
កលំបិ នាគ្ឃន្តិ តថាវិធស្ស តេតិ ។

បុគ្គលណាចិញ្ចឹមភរិយាផង ប្រព្រឹត្តធម៌ គឺកុសលកម្មបថ ១០ បានផង ប្រព្រឹត្តស្អាតក្នុងការងារបានផង កាលបើទ្រព្យមានតិចនៅតែឱ្យទានបានផង (ទាននៃបុគ្គលអ្នកប្រព្រឹត្តធម៌នេះប្រសើរក្រៃលែងណាស់) សូម្បីបុរសមួយសែននាក់ បូជាចំពោះភិក្ខុមួយពាន់អង្គ ឬបរិច្ចាគទ្រព្យម្នាក់មួយពាន់កហាបណៈ រួមគ្នាទៅបានដប់កោដិកហាបណៈ(ប្រាក់ច្រើនដល់ម្ល៉ឺង) នៅតែមិនដល់

មួយភាគរយនៃទានរបស់បុគ្គលអ្នកប្រព្រឹត្តធម៌ដែលបានឱ្យ សូម្បីទ្រព្យតិចតួច ។

លំដាប់នោះ ទេវតាមួយអង្គទៀត បានពោលគាថានេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

កេនេស យញ្ញោ វិបុលោ មហគ្គតោ
សមេន ចិត្តេន ន អគ្ឃមេតិ
កថំ សហស្សាន សហស្សយោគិនំ
កលំបិ នាគ្ឃន្តិ តថាវិធស្ស តេតិ ។

យ័ញ្ញនុ៎ះ មានផលដ៏ទូលាយច្រើនដែរ នៅតែមិនដល់ទានដែលបុគ្គលឱ្យហើយ ដោយធម៌ដ៏ស្មើ តើដោយហេតុដូចម្តេច បុគ្គលមានការបូជារាប់ពាន់ដល់បុគ្គលមួយពាន់នាក់នោះ នៅតែមិនដល់មួយចំណិតរបស់បុគ្គលយ៉ាងនោះ តើដូចម្តេច ។

លំដាប់នោះឯង ព្រះមានព្រះភាគបានត្រាស់ដឹងទេវតានោះ ដោយគាថាថា ៖

ឧទន្តិ ហេកេវិស បេនិវិដ្ឋា ឃត្វាវធិត្វា អថ សោចយិត្វា
សា ទក្ខិណា អស្សុមុខា សទណ្ឌា

សមេន ចិន្នស្ស ន អគ្ឃមេតិ
ឯវំ សហស្សាន សហស្សយាគិនំ
កលំបិ ន៑ាគ្ឃន្តិ តថាវិធស្ស តេតិ ។

បុគ្គលពួកមួយបានបឋមជ្ឈានដែលមិនស្មើ ហើយបៀតបៀន សម្លាប់ ពុំនោះសោត ធ្វើបុគ្គលដទៃឱ្យសោកសៅ ទើបឱ្យទាន ទក្ខិណានោះ ឈ្មោះថា មានមុខទទឹកដោយទឹកភ្នែក ប្រកបដោយអាជ្ញា មិនដល់នូវតម្លៃនៃទានដែលបុគ្គលឱ្យហើយ ដោយធម៌ដ៏ស្មើទេ បុគ្គលមានការបូជារាប់ពាន់ដល់បុគ្គលមួយពាន់នាក់នោះ នៅតែមិនដល់មួយចំណិតរបស់បុគ្គលយ៉ាងនោះដូច្នេះឯង ។

អដ្ឋកថា

បទថា មច្ចរា ច បមាទា ច ប្រែថា ព្រោះសេចក្តីកំណាញ់និងសេចក្តីប្រមាទ បានដល់ ព្រោះសេចក្តីកំណាញ់ដែលមានការបិទបាំងនូវសម្បត្តិរបស់ខ្លួនទុកជាលក្ខណៈ និង ព្រោះសេចក្តីប្រមាទ ដែលមានការនៅច្រាសចាកសតិជាលក្ខណៈតែម្តង អ្នកខ្លះគិតថា កាលយើងឱ្យវត្ថុនេះ វត្ថុនេះក៏នឹងអស់ទៅ វត្ថុរបស់យើង ឬ វត្ថុដែលជារបស់មាននៅក្នុងស្រុកក៏នឹងមិនមាន

ដូច្នេះ ឈ្មោះថា មិនឱ្យទានព្រោះសេចក្តីកំណាញ់ ។ អ្នកខ្លះសូម្បីនឹងត្រឹមតែញុំាងចិត្ត ឱ្យកើតឡើងថា យើងគួរឱ្យទាន ដូច្នេះ ក៏មិនមាន ព្រោះខ្លួនជាអ្នកឰ្យល់ឰ្យក្នុងការលេងជាដើម នេះឈ្មោះថា មិនឱ្យទាន ព្រោះសេចក្តីប្រមាទ ។

ពាក្យថា **ឯវំ ទានំ ន ទីយតិ** ប្រែថា យ៉ាងនេះបុគ្គលទើបឱ្យទានមិនបាន អធិប្បាយថា ធម្មតាថា ទាននេះ ដែលជាហេតុនាំមកឱ្យទូវយស ឱ្យទូវសិរី ឱ្យទូវសម្បត្តិបែបនេះ បុគ្គលក៏នៅតែឱ្យមិនបាន ព្រោះដូច្នោះ ទើបលោកពោលដល់ហេតុនៃការមិនឱ្យ ព្រោះសេចក្តីកំណាញ់ជាដើម ។

បទថា **បុញ្ញំ អាកង្ខមានេន** ប្រែថា បុគ្គលដែលប្រាថ្នាបុណ្យ គឺអ្នកប្រាថ្នាបុណ្យដែលផ្សែងដោយចេតនា មានបុព្វចេតនាជាដើម ។ ក្នុងពាក្យថា **ទេយ្យំ ហោតិ វិជ្ជានតា** ប្រែថា ដឹងច្បាស់ហើយ ទើបឱ្យទាននោះ ទេវតាពោលថា បុគ្គលដឹងច្បាស់ថា ផលរបស់ទានមាន ដូច្នេះ ទើបឱ្យទាន ។

លំដាប់នោះ ទេវតាដទៃទៀត បានពោលគាថាទាំងឡាយក្នុងសំណាក់ព្រះមានព្រះភាគថា ៖

អ្នកកំណាញ់ ខ្លាចភ័យណា រមែងមិនឱ្យទាន ភ័យនោះឯង រមែងមានដល់អ្នកកំណាញ់អ្នកមិនឱ្យទាន អ្នកកំណាញ់ខ្លាចសេចក្តីឃ្លាន និងសេចក្តីក្តៅក្រហាយណា សេចក្តីឃ្លាននិងសេចក្តីក្តៅក្រហាយនោះ រមែងពាល់ត្រូវ អ្នកកំណាញ់នោះឯង អ្នកជាពាលទាំងក្នុងលោកនេះ និងលោកមុខ ដូច្នោះ បុគ្គលគួរកម្ចាត់នូវសេចក្តីកំណាញ់ដែលជាស្នើមក្នុងចិត្ត (មន្ទិល)ឱ្យទានចុះ ព្រោះបុណ្យទាំងឡាយ រមែងជាទីពឹងរបស់សត្វទាំងឡាយក្នុងលោកមុខ ។

បទថា តមេវមលំ ជុសតិ អធិប្បាយថា សេចក្តីឃ្លាន និងសេចក្តីស្រេក រមែងពាល់ត្រូវ គឺរមែងជាប់តាម រមែងមិនលះបុគ្គលដែលជាពាលនោះឯង ទាំងក្នុងលោកនេះ និងលោកខាងមុខ ។

បទថា តស្មា បានដល់ ក៏ព្រោះសេចក្តីឃ្លាននិងសេចក្តីស្រេករមែងពាល់ត្រូវបុគ្គលដែលជាពាលនេះឯង ។

បទថា វិនេយ្យ មច្ឆេរំ ប្រែថា បុគ្គលគួរកម្ចាត់សេចក្តីកំណាញ់ បានដល់ នាំសេចក្តីកំណាញ់ដែលជាមន្ទិលចេញ ។

បទថា ទជ្ជា ទានំ មលាភិភូ អធិប្បាយថា បុគ្គលដែល

កម្មាត់នូវមន្ទិល គ្រាកម្មាត់មន្ទិល គឺសេចក្តីកំណាញ់នោះហើយ ទើបឱ្យទានបាន ។

ក្នុងលំដាប់នោះឯង ទេវតាដទៃទៀតបានពោលគាថាទាំងឡាយ ក្នុងសំណាក់ព្រះមានព្រះភាគថា ជនពួកណា កាលរបស់មានតិច ក៏បែងចែកឱ្យបាន ដូចពួកដើរផ្លូវឆ្ងាយ បែងចែករបស់ឱ្យដល់ពួកដែលធ្វើដំណើរមួយគ្នា ជនទាំងនោះកាលបុគ្គលពួកដទៃស្លាប់ហើយ ឈ្មោះថា រមែងមិនស្លាប់ ធម៌នេះជារបស់បណ្ឌិតពីកាលមុន ជនមួយពួក កាលរបស់មានតិចក៏បែងចែកឱ្យបាន ជនមួយពួកសូម្បីរបស់មាន ច្រើនក៏មិនឱ្យ ទក្ខិណា(របស់អ្នកធ្វើបុណ្យ)ដែលឱ្យតែរបស់តិចរាប់ស្មើដោយផុត ។

បទថា **តេ មតេសុ ន មិយ្យន្តិ** សេចក្តីថា បុគ្គលទាំងនោះ កាលបុគ្គលដទៃស្លាប់ហើយ ឈ្មោះថា រមែងមិនស្លាប់ ព្រោះសេចក្តីស្លាប់គឺ ភាពជាអ្នកមានប្រក្រតីមិនឱ្យទានដូចយ៉ាងថាបុគ្គលដែលស្លាប់ហើយ កាលបុគ្គលដទៃនាំវត្ថុទាំងឡាយ មានបាយនិងទឹកជាដើម សូម្បីច្រើនមកជាក់ហៅហាមហើយប្រាប់ថា វត្ថុនេះចូរជារបស់អ្នកនេះ វត្ថុនេះចូរជារបស់អ្នកនេះ ដូច្នេះ បុគ្គលដែល

ស្លាប់ហើយទាំងនោះ ក៏មិនអាចក្រោកឡើងមកទទួលការចែកចាយបានយ៉ាងណា សូម្បីបុគ្គលដែលមិនឱ្យទានក៏ដូចគ្នា ព្រោះដូច្នោះ ភោគៈទាំងឡាយរបស់អ្នកស្លាប់ហើយ និងរបស់អ្នកមានប្រក្រតីមិនឱ្យទានទើបឈ្មោះថា ស្មើ ៗគ្នា ព្រោះហេតុនោះឯង បុគ្គលដែលមានប្រក្រតីឱ្យទាន កាលជនទាំងឡាយបែបនេះស្លាប់ហើយ ឈ្មោះថា រមែងមិនស្លាប់ ។

បទថា **អទ្ធានំ សហាវដ្ដំ អប្បស្មិ យេ បវេច្ឆន្តិ** អធិប្បាយថា អ្នកទាំងឡាយដែលដើរផ្លូវឆ្ងាយកន្លារួមគ្នា កាលស្បៀងមានតិច បុគ្គលដែលធ្វើដំណើរួមគ្នាក៏បែងចែកគឺរមែងឱ្យទានទុំៈឯងដល់បុគ្គលដែលធ្វើដំណើរួមគ្នាយ៉ាងណា សេចក្តីនេះក៏យ៉ាងនោះឯង ពួកអ្នកណាធ្វើដំណើរួមគ្នាទៅកាន់ផ្លូវកន្លារ គឺសង្សារដែលមានខាងដើមនិងទីបំផុត ដែលបុគ្គលដឹងមិនបាន កាលវត្ថុដែលគប្បីឱ្យសូម្បីមានតិច ក៏បែងចែករបស់ឱ្យបាន ជនទាំងនោះ គ្រាកាលជនដទៃ ស្លាប់ហើយ ទើបឈ្មោះថា រមែងមិនស្លាប់ ។

បទថា **ឯស ធម្មោ សនន្តនោ** អធិប្បាយថា ធម៌នេះជារបស់បូរាណ ម្យ៉ាងទៀត ធម៌នេះជារបស់បណ្ឌិតពីកាលមុន ។

បទថា អប្បស្មេកេ ប្រែថា ជនមួយពួកកាលរបស់មានតិច ។

បទថា បវេច្ឆន្តិ កែជា ទទន្តិ ប្រែថា រមែងឱ្យ ។

បទថា ពហុនេកេ ន ទិច្ឆរេ ប្រែថា ជនមួយពួកមានរបស់ច្រើនក៏មិនឱ្យ គឺថា ជនពួកខ្លះសូម្បីមានភោគៈច្រើនណាស់ ក៏រមែងមិនឱ្យ ។

បទថា សហស្សេន សមំ មិតា ប្រែថា រាប់ស្មើដោយពាន់ គឺ រមែងដូចទានមួយពាន់ ។

ក្នុងលំដាប់នោះឯង ទេវតាដទៃទៀត បានពោលគាថាទាំងឡាយ ក្នុងសំណាក់ព្រះមានព្រះភាគថា ៖

ទាន ពួកពាលជនកាលឱ្យ ឱ្យបានលំបាក កុសលធម៌ ពួកពាលជនកាលធ្វើ ធ្វើបានលំបាក ពួកអសប្បុរស រមែងមិនធ្វើតាមធម៌របស់សប្បុរស ដែលពួកអសប្បុរសធ្វើតាមបានលំបាក ព្រោះដូច្នោះ ការទៅអំពីលោកនេះ របស់ពួកសប្បុរស និងពួកអសប្បុរស ទើបផ្សេងគ្នា ពួកអសប្បុរស រមែងទៅកាន់នរក ពួកសប្បុរសរមែងជាអ្នកដំណើរទៅកាន់សួគ៌ ។

បទថា ឧរន្ធយោ ប្រែថា ដំណើរតាមបានលំបាកគឺ ចូលដល់បានលំបាក អធិប្បាយថា ឱ្យពេញបានលំបាក ។ ក្នុងលំដាប់នោះឯង ទេវតាដទៃទៀត បានក្រាបទូលចំពោះព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ ពាក្យរបស់អ្នកណាហ្ន៎ ជាសុភាសិតដូច្នេះ ។ ព្រះមានព្រះភាគត្រាស់ថា ពាក្យរបស់ពួកលោកទាំងអស់ជាសុភាសិតដោយបរិយាយក៏ប៉ុន្តែពួកលោកចូរស្តាប់ពាក្យរបស់តថាគតវិញថា ៖

បុគ្គលសូម្បីណារមែងប្រព្រឹត្តធម៌ ប្រព្រឹត្តស្អាត ជាអ្នកចិញ្ចឹមភរិយា និងកាលរបស់មានតិចក៏ឱ្យបាន កាលបុរសមួយសែនបូជាភិក្ខុមួយពាន់ ឬបរិច្ចាគទ្រព្យពាន់កហាបណៈ ការបូជារបស់បុគ្គលទាំងនោះ រមែងមិនដល់ចំណែកវេរបស់បុគ្គលយ៉ាងនោះ ។

បទថា ធម្មំ ចរេ បានដល់ រមែងប្រព្រឹត្តធម៌ គឺកុសលកម្មបថ ១០ ។

បទថា យោបិ សមុញ្ញកំ ចរេ ប្រែថា បុគ្គលសូម្បីណារមែងប្រព្រឹត្តស្អាត បានដល់ ប្រព្រឹត្តឱ្យស្អាតដោយអំណាចនៃ

ការជម្រះលាងសេចក្តីអាក្រក់គ្រប់ ៗ ទៅតាំងពីដើម និងដោយអំណាចនៃការញាំញ៉ី ដូចការច្របាច់ចំបើងជាដើម ។

បទថា ធារំ ច ធោសំ តែជា ធារំ ច ធោសេន្តោ ប្រែថា ចិញ្ចឹមរក្សាភរិយា ។

បទថា ឧធំអប្បកេស្មឹ ប្រែថាកាលរបស់មានតិចក៏ឱ្យបានបានដល់ បុគ្គលណាមានសូម្បីត្រឹមតែស្លឹកឈើនិងបន្លែជាដើមមានតិច ក៏ធ្វើការបែងចែកឱ្យបាននុ៎ះឯង បុគ្គលនោះឈ្មោះថារមែងប្រព្រឹត្តធម៌ ។

បទថា សតំ សហស្សាន ប្រែថា កាលបុរសមួយសែនគឺបុរសដែលលោកបែងចែកចេញជាពួកមួយពាន់ ៗ រាប់បានជាមួយរយ ទើបឈ្មោះថា បុរសមួយសែន ។

បទថា សហស្សយោគិនំ ប្រែថា បូជាភិក្ខុមួយពាន់ មានវិគ្រោះថា ឈ្មោះថា ការបូជាមួយពាន់ ព្រោះអត្ថថា ការបូជាភិក្ខុមួយពាន់ ឬថា ការបូជាការកើតពីការបរិច្ចាគទ្រព្យមួយពាន់កហាបណៈ ។ ការបូជាមួយពាន់នោះ មានដល់ភិក្ខុនោះ ហេតុនោះ ភិក្ខុនោះ ទើបឈ្មោះថា មានការបូជាមួយពាន់ ។ ដោយបទថា បុរស

មួយសែនបូជាភិក្ខុមួយពាន់នោះ រមែងជាការសម្តែងដល់បិណ្ឌបាត ១០ កោដិ (ពាក្យថា ១០ កោដិនេះសំដៅយកចំណែកដែលឱ្យផល ជាពាន់ចំណែក ហើយគុណដោយបុរសមួយសែន ។) ឬថា ១០ កោដិនៃកហាបណៈ គ្រាស់ថា បុគ្គលពួកណារមែងឱ្យរបស់មានប្រមាណប៉ុណ្ណេះ បុគ្គលទាំងនោះ រមែងមិនដល់តម្លៃសូម្បីចំណែករយ របស់បុគ្គលយ៉ាងនោះ ។ បុគ្គលនេះណាសូម្បីកាលប្រព្រឹត្តធម៌ រមែងប្រព្រឹត្តស្អាត ចិញ្ចឹមរក្សាភរិយា សូម្បីរបស់មានតិចក៏នៅតែឱ្យបានការបូជាភិក្ខុមួយពាន់នោះរមែងមិនដល់តម្លៃសូម្បីចំណែករយរបស់បុគ្គលដែលប្រព្រឹត្តធម៌នោះ ។

ម្យ៉ាងទៀត ទានយ៉ាងណា ត្រឹមតែរបស់អ្នកជិតជិតគ្នាតែម្នាក់ក្តី ត្រឹមតែជាស្លាកភត្តក្តី ដែលបុគ្គលក្រលំបាកឱ្យហើយ ទានទាំងឡាយរបស់បុគ្គលសូម្បីទាំងអស់នោះ រមែងមិនដល់តម្លៃចំណែកមួយរយរបស់ទាន ដែលអ្នកក្រលំបាកឱ្យហើយ ។

ឈ្មោះថា កលំ ប្រែថា ចំណែកមួយនោះបែងចែកចេញជា ១៦ ចំណែកខ្លះ ជា ១០០ ចំណែកខ្លះ ជា ១,០០០ ចំណែកខ្លះ ក្នុងទីនេះ ព្រះមានព្រះភាគទ្រង់កាន់យកចំណែកនៃមួយរយគ្រាស់ថា ទានយ៉ាងណា ដែលអ្នកក្រលំបាកនោះឱ្យហើយ ឱ្យព្រោះ

ទាននោះ លោកចែកហើយមួយរយចំណែក ការឱ្យបិណ្ឌបាត ដោយរួមតាំង ១០ កោដិរបស់បុគ្គលនេះ ក៏មិនដល់តម្លៃសូម្បី មួយចំណែកនៃទាន ដែលអ្នកក្រលំបាកនោះឱ្យហើយ ។

កាលព្រះតថាគតទ្រង់ធ្វើនូវទាន ដែលកាត់ថ្លៃមិនបានយ៉ាងនេះហើយ ទេវតាដែលឈរក្នុងទីជិត ទើបគិតថា ព្រះមានព្រះភាគញុំាងមហាទានយ៉ាងនេះ ឱ្យប្រព្រឹត្តទៅដោយគាថាមួយបាទ ដូចយកវត្ថុដែលប្រកបទៅដោយរតន:ទាំងរយ ដាក់ចូលទៅក្នុងជ្រោះ ចោះទៅនូវទានច្រើនយ៉ាង នេះថា មានប្រមាណបន្តិចបន្តួចយ៉ាងនេះ ដូចប្រហារនូវមណ្ឌលនៃព្រះចន្ទ ទើបពោលគាថាថា ៖

ការបូជា ការបរិបូណ៌ិនេះ ដែលធំសម្បើមនេះ រមែងមិនប៉ុនដល់ចំណែកនៃទាន ដែលបុគ្គលឱ្យដោយការប្រព្រឹត្តធម៌ ព្រោះហេតុអ្វីកាលបុរសមួយសែនបូជាភិក្ខុមួយពាន់ ឬ បរិច្ចាគទ្រព្យពាន់កហាបណៈ ការបូជារបស់បុរសទាំងនោះ រមែងមិនដល់ចំណែករយរបស់បុគ្គលយ៉ាងនោះ ។

បណ្តាបទទាំងនោះ បទថា តេនប្រែថា ព្រោះហេតុអ្វី ។

បទថា **មហគ្គតោ** ប្រែថា ធំសម្បើម នេះជាពាក្យវេវចន:របស់ពាក្យថា បរិបូណ៌ ។

ពីរបទថា សមេន ឯន្តសុ្ស ប្រែថា នៃទានដែលបុគ្គលឱ្យដោយការប្រព្រឹត្ត ។

លំដាប់នោះព្រះមានព្រះភាគ កាលនឹងទ្រង់ចែកទានសម្តែងដល់ទេវតានោះ ទើបត្រាស់ថា ៖

ទទន្តិ ហោកេវិសមេនិវិដ្ឋាឃត្វា វធិត្វាអថ សោចយិត្វា

សា ទក្ខិណា អស្សុមុខា សទណ្ឌា សមេន ឯន្តសុ្ស ន អគ្ឃតេ ។

បុគ្គលមួយពួកតាំងនៅក្នុងកម្មប្រាសចាកសេចក្តីស្ងប់ វាយគេ សម្លាប់គេ ធ្វើឱ្យគេសោកសៅហើយឱ្យទាន ទាននោះចាត់ថាទានមានមុខដែលជោកដោយទឹកភ្នែកចាត់ថា ជាទានប្រព្រឹត្តទៅនឹងដោយអាជ្ញា ទើបមិនប៉ុនដល់ចំណែកនៃទានដែលឱ្យដោយសេចក្តីស្ងប់ ។

បណ្តាបទទាំងនោះ បទថា វិសមេ និវិដ្ឋា ប្រែថា តាំងមាំក្នុងកម្មដែលប្រាសចាកសេចក្តីស្ងប់ បានដល់ តាំងមាំក្នុងកាយកម្ម វចីកម្ម និងមនោកម្មដែលគ្មានសេចក្តីស្ងប់ ។

បទថា ឃត្វា កែជា ឆោដេត្វា ប្រែថា វាយហើយ ។

បទថា វធិត្វា ប្រែថា សម្លាប់ហើយ គឺធ្វើឱ្យស្លាប់ ។

បទថា អស្សមុខា ប្រែថា មានមុខជោកដោយទឹកភ្នែក ពិតមែន ទានដែលធ្វើឱ្យអ្នកដទៃស្រែកយំហើយឱ្យ ព្រះមានព្រះភាគត្រាស់ថា ទានមានមុខជោកដោយទឹកភ្នែក ។

បទថា សឌណ្ឌា ប្រែថា ប្រព្រឹត្តទៅនឹងដោយអាជ្ញា ។

ព្រះមានព្រះភាគត្រាស់ថា ទក្ខិណាដែលបុគ្គលគំរាមអ្នកដទៃហើយឱ្យ ហៅថា ទក្ខិណាប្រព្រឹត្តទៅនឹងដោយអាជ្ញា ។

ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងសេចក្តីនេះយ៉ាងនេះថា យើងមិនអាចដើម្បីកាន់យកមហាទានហើយធ្វើឱ្យឈ្មោះថា មានផលតិច ឬទានដែលតិចធ្វើឱ្យមានឈ្មោះថា មានផលច្រើន ព្រោះភាពជាព្រះសម្មាសម្ពុទ្ធ ក៏ប៉ុន្តែមហាទាននេះ ឈ្មោះថា មានផលតិចយ៉ាងនេះ ព្រោះសេចក្តីមិនបរិសុទ្ធិកើតឡើងដល់ខ្លួន ទានតិចនេះ ឈ្មោះថា មានផលច្រើនយ៉ាងនេះ ព្រោះសេចក្តីបរិសុទ្ធិកើតឡើងដល់ខ្លួន ដូច្នេះ ទើបត្រាស់ពាក្យថា ដោយន័យយ៉ាងនេះ កាលបុរសមួយសែនបូជាភិក្ខុមួយពាន់ ឬបរិច្ចាគទ្រព្យពាន់កហាបណៈ ការបូជារបស់បុគ្គលទាំងនោះ រមែងមិនដល់ចំណែករយៈរបស់បុគ្គលយ៉ាងនោះដូច្នេះ ។

បឋមមាបុត្តកសូត្រ

នៅក្នុងបិដកលេខ ២៩ ទំព័រ ២៤២ ព្រះដ៏មានព្រះភាគ ជាម្ចាស់ ទ្រង់ត្រាស់សម្តែងអំពីរឿងរបស់អសប្បុរស កាលបើបានភោគសម្បត្តិដ៏លើសលុបហើយក៏មិនចេះប្រើប្រាស់ឡើយ តែងធ្វើខ្លួនឱ្យក្តៅក្រហាយជានិច្ច ជាមួយនឹងព្រះបាទបសេនទិកោសល មានសេចក្តីថា ៖

ទៀបក្រុងសាវត្ថី ។ គ្រានោះ ព្រះបាទបសេនទិកោសល ចូលទៅគាល់ព្រះមានព្រះភាគទាំងថ្ងៃត្រង់ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគ ហើយគង់នៅក្នុងទីសមគួរ ។

លុះព្រះបាទបសេនទិកោសល គង់នៅក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា បពិត្រមហារាជ ចុះព្រះអង្គទើបនឹងស្តេចមកពីណា ទាំងថ្ងៃត្រង់ ។

ព្រះបាទបសេនទិកោសលក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សេដ្ឋីគហបតីក្នុងក្រុងសាវត្ថីនេះ ធ្វើមរណកាលទៅហើយ ខ្ញុំព្រះអង្គមកនាំយកទ្រព្យសេដ្ឋី គ្មានកូននោះទៅកាន់ខាងក្នុងព្រះរាជវាំង បពិត្រព្រះអង្គដ៏ចម្រើន គ្រាន់តែប្រាក់មានចំនួនមួយរយ-

សែនទៅហើយ ទើបបាច់ពោលទៅថ្វីដល់រូបិយៈ បពិត្រព្រះអង្គដ៏ចម្រើន **សេដ្ឋីគហបតីនោះមានការបរិភោគភត្តបែបនេះ គឺគាត់បរិភោគបាយចុងអង្ករ** មានជ្រក់ជាគម្រប់ពីរ មានការប្រើប្រាស់សម្ពត់បែបនេះ **គឺគាត់ប្រើប្រាស់សម្ពត់សំបក់ឆ្មៃ ប៉ះជា ៣ ផ្ទាំង** មានការប្រើប្រាស់យានបែបនេះ **គឺគាត់ជិះរថតូចកញ្ជាស់ ជាំង ឆត្រស្វឹកយ៉ាងតូច** ។

ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ ពាក្យនេះយ៉ាងនេះហើយ បពិត្រមហារាជ ពាក្យនេះយ៉ាងនេះហើយ បពិត្រមហារាជ ធម្មតាអសប្បុរស **បើបានភោគៈច្រើនលើសលុបហើយ មិនធ្វើខ្លួនឱ្យបានសុខ មិនបំពេញខ្លួន មិនធ្វើមាតាបិតាឱ្យសុខ មិនបំពេញមាតាបិតា មិនធ្វើបុត្តភរិយាឱ្យបានសុខ មិនបំពេញបុត្តភរិយា មិនធ្វើពួកបុរសជាទាសកម្មករឱ្យបានសុខ មិនបំពេញពួកបុរសជាទាសកម្មករ មិនធ្វើពួកមិត្តនិងអាមាត្យឱ្យបានសុខ មិនបំពេញពួកមិត្តនិងអាមាត្យ ទាំងមិនតម្កល់ទុកនូវទក្ខិណាទាន ក្នុងសមណព្រាហ្មណ៍ទាំងឡាយ ដែលជាទានមានផលខ្ពង់ខ្ពស់ ជាទានឱ្យនូវឱ្យនូវអារម្មណ៍មានរូបជាដើមដ៏ប្រសើរ ដោយប្រពៃ**

មានវិបាកជាសុខ ប្រព្រឹត្តទៅដើម្បីសួគ៌ឡើយ ។ កាលបើអសប្បុរសនោះ មិនប្រើប្រាស់ភោគៈសម្បត្តិទាំងនោះដោយស្រួលយ៉ាងនេះហើយ **ព្រះរាជាទាំងឡាយនាំយកទៅខ្លះ, ពួកចោរនាំយក ទៅខ្លះ, ភ្លើងឆេះខ្លួចទៅខ្លះ, ទឹកបន្សាត់ទៅខ្លះ, ពួកញាតិដែលមិនជាទីស្រឡាញ់នាំយកទៅខ្លះ ។**

បពិត្រមហារាជ កាលបើភោគៈទាំងនោះ ដែលអសប្បុរសនោះមិនប្រើប្រាស់ដោយប្រពៃយ៉ាងនេះហើយ រមែងដល់នូវការអស់ទៅ មិនដល់នូវការប្រើប្រាស់បានឡើយ ។

បពិត្រមហារាជ ស្រះបោក្ខរណីក្នុងទីគ្មានមនុស្ស មានទឹកថ្លា មានទឹកត្រជាក់ មានទឹកឆ្ងាញ់ មានទឹកស (ដោយអន្លើ) មានកំពង់ល្អ គួរជាទីត្រេកអរ អ្នកផងមិនជងទឹកនោះ មិនផឹកទឹកនោះ មិនងូតទឹកនោះ មិនយកទឹកនោះទៅប្រើប្រាស់តាមសមគួរដល់សេចក្តីត្រូវការឡើយ បពិត្រមហារាជ ឯទឹកនោះកាលគេមិនប្រើប្រាស់ដោយប្រពៃយ៉ាងនេះហើយ គប្បីដល់នូវការអស់ទៅ មិនដល់នូវការប្រើប្រាស់បានយ៉ាងណា បពិត្រមហារាជ អសប្បុរស**បើបានភោគៈច្រើនលើសលុបហើយ មិនធ្វើខ្លួនឱ្យបានសុខ មិន**

បំពេញខ្លួន ។បេ។ បពិត្រមហាជ កាលបើភោគៈទាំងឡាយដែលអសប្បុរសនោះ មិនប្រើប្រាស់ដោយប្រពៃយ៉ាងនេះហើយ តែងដល់នូវការអស់ទៅ មិនដល់នូវការប្រើប្រាស់យ៉ាងនោះឯង ។

បពិត្រមហាវាជ ចំណែកសប្បុរស **បានភោគៈច្រើនលើសលុបហើយ តែងធ្វើខ្លួនឱ្យបានសុខ បំពេញខ្លួន ធ្វើមាតាបិតាឱ្យសុខ បំពេញមាតាបិតា ធ្វើបុត្តភរិយាឱ្យបានសុខ បំពេញបុត្តភរិយា ធ្វើពួកបុរសជាទាសកម្មករឱ្យបានសុខ បំពេញពួកបុរសជាទាសកម្មករ ធ្វើពួកមិត្តនិងអាមាត្យឱ្យបានសុខ បំពេញពួកមិត្តនិងអាមាត្យ ទាំងបានតម្កល់ទុកនូវទក្ខិណាទាន ក្នុងសមណព្រាហ្មណ៍ទាំងឡាយ ដែលជាទានមានផលខ្ពង់ខ្ពស់ ជាទានឱ្យនូវឱ្យនូវអារម្មណ៍មានរូបជាដើមដ៏ប្រសើរដោយប្រពៃ មានវិបាកជាសុខប្រព្រឹត្តទៅដើម្បីសួគ៌ ។** កាលបើសប្បុរសនោះ ប្រើប្រាស់ភោគៈសម្បត្តិទាំងនោះដោយស្រួលយ៉ាងនេះហើយ **ពួកព្រះរាជាក៏មិននាំទៅ, ពួកចោរក៏មិនលួចទៅ, ភ្លើងមិនឆេះ, ទឹកក៏មិនបន្សាត់ទៅ ពួកញាតិដែលមិនជាទីស្រឡាញ់ក៏មិនបាននាំយកទៅ ។**

បពិត្រមហាវាជ ភោគៈទាំងនោះដែលសប្បុរសនោះ ប្រើ

ប្រាស់ដោយប្រពៃយ៉ាងនេះហើយ រមែងដល់នូវការប្រើប្រាស់បាន មិនដល់នូវការអស់ទៅឡើយ ។

បពិត្រមហារាជ ស្រះបោក្ខរណីដែលនៅជិតស្រុក ឬនិគម មានទឹកថ្លា មានទឹកត្រជាក់ មានទឹកឆ្ងាញ់ មានទឹកស (ដោយអន្លើ) មានកំពង់ល្អ គួរជាទីត្រេកអរ អ្នកផងទៅជងទឹកនោះមកខ្លះ ផឹកខ្លះ ងូតខ្លះ ប្រើប្រាស់តាមសមគួរដល់សេចក្តីត្រូវការខ្លះ បពិត្រមហារាជ ឯទឹកនោះ ដែលអ្នកបរិភោគដោយប្រពៃយ៉ាងនេះហើយ គប្បីដល់នូវការប្រើប្រាស់បាន មិនដល់នូវការអស់ទៅឡើយ យ៉ាងណាមិញ បពិត្រមហារាជ សប្បុរស **បានភោគៈច្រើនលើសលុបហើយ តែងធ្វើខ្លួនឱ្យបានសុខបំពេញខ្លួន ។បេ ។** បពិត្រមហាជ កាលបើភោគសម្បត្តិទាំងនោះ ដែលសប្បុរសនោះ ប្រើប្រាស់ដោយប្រពៃយ៉ាងនេះហើយ តែងដល់នូវការប្រើប្រាស់បាន មិនដល់នូវការអស់ទៅឡើយ យ៉ាងនោះឯង ។

ព្រះមានព្រះភាគ ទ្រង់បានត្រាស់នូវពាក្យនេះហើយ ទើបបានត្រាស់នូវគាថានេះតទៅទៀតថា ៖

អមនុស្សដ្ឋានេ ឧទកំ វសិកំ

តឧបេយ្យមានំ បុរិសេ សមេតិ
ឯវំ ធនំ កាបុរិសោ លភិត្វា
នេវត្តនា បរិភុញ្ជតិ នោ ទទាតិ
ធីរោ ច វិញ្ញូ អធិគម្ម កោវេ
សោ បរិភុញ្ជតិ កិច្ចការោ ច ហោតិ
សោ ញាតិសច្ឆំ និសភោ ភវិត្វា
អនិន្ទិតោ សគ្គមុបេតិ ឋានន្តិ ។

បុរសបានជួបប្រទះនឹងទឹក ដែលជក់នៅក្នុងទីគ្មានមនុស្ស ជាទឹកផឹកមិនបាន យ៉ាងណាមិញ បុរសអាក្រក់ បាននូវទ្រព្យ ហើយ មិនប្រើប្រាស់ខ្លួនឯង មិនឱ្យទានយ៉ាងនោះឯង ឯអ្នកប្រាជ្ញ ជាអ្នកចេះដឹងនោះ បើបានភោគសម្បត្តិហើយ តែងប្រើប្រាស់ខ្លួន ឯងខ្លះ ធ្វើកិច្ចឯទៀតខ្លះ អ្នកប្រាជ្ញនោះ ជាបុគ្គលប្រសើរ ចំណាយ ចិញ្ចឹមពួកញាតិខ្លះឥតមានគេតិះដៀល (លុះស្លាប់ទៅ) ក៏ទៅកាន់ស្ថានសួគ៌ ។

អដ្ឋកថា

បទថា ឯវាឯវស្ស ប្រែថា ថ្ងៃនៃថ្ងៃ អធិប្បាយថា វេលាថ្ងៃ(ថ្ងៃត្រង់) ។

បទថា សាមតេយ្យំ ប្រែថា ទ្រព្យ ។

បទថា កោ បន វាទោរូបិយស្ស សេចក្តីថា ក៏ទីធ៌បាច់ពោលទៅថ្វីដល់វត្ថុ ទាំងដែលធ្វើជាដុំ មានប្រាក់ មាសក្រហមដែក សំរឹទ្ធិជាដើម ទាំងដែលជារូបិយភ័ណ្ឌ មានភាជនៈប្រើប្រាស់ជាដើម គឺទីធ៌និយាយកំណត់អ្វីគ្នាថា ឈ្មោះមានប៉ុណ្ណេះ ។

បទថា កណាជកំ បានចុងអង្ករ បានដល់ បាយមានកណ្តក ។

បទថា ឯលច្ចុតិយំ ប្រែថា មានទឹកក្រូចផ្សមជាទីពីរ ។

បទថា សាណំ បានដល់សំពត់ដែលធ្វើដោយសំបកឆ្មៃ ។

បទថា តិបក្ខវសនំ បានដល់ សំពត់ដែលកាត់ជា ៣ ផ្ទាំងដេរជាយទាំងពីរជាប់គ្នា ។

បទថា អសប្បុរិសោ ប្រែថា បុរសអាក្រក់ ។ ទក្ខិណា

ឈ្មោះថា ឧទុគ្គិកា ក្នុងពាក្យថា ឧទុគ្គិកំ ជាដើម ព្រោះមានផលក្នុងខាងលើ (ខ្ពស់) ដោយឱ្យផលក្នុងភូមិខ្ពស់ ៗ ឡើងទៅ ។ ឈ្មោះថា សោវគ្គិកា ព្រោះជាប្រយោជន៍ដល់សួគ៌ ហេតុឱ្យឧប្បត្តិក្នុងសួគ៌នោះ ។ ឈ្មោះថា សុខវិបាកា ព្រោះទក្ខិណានោះមានសុខជាវិបាកក្នុងទីកើតហើយហ្ន៎ ។ ឈ្មោះថា សគ្គសំវត្តនិកា ព្រោះជាទីកើតរបស់វិសេសមានវណ្ណៈទិព្វជាដើមដ៏ប្រសើរល្អ ។ អធិប្បាយថា ទក្ខិណាទាននេះ រមែងប្រតិស្ឋាននៅ ។

បទថា សាតោឧកា បានដល់ មានទឹករសឆ្ងាញ់ ។

បទថា សេតកា បានដល់ ទឹកដែលស ព្រោះទឹកក្នុងទីរលកបែកខ្ចាយ ពណ៌ស ។

បទថា សុបតិត្ថា ប្រែថា មានកំពង់ដែលល្អ ។

បទថា តញ្ញេវ សេចក្តីថា ទឹកដែលសាបធម្មតាដោយទឹកប្រភេទណា ជនមិនគប្បីចាក់ទឹកប្រភេទនោះដាក់ភាជនៈនាំទៅបានទេ ។

បទថា នយថាបច្ចយំ ករេយ្យ សេចក្តីថា ។ កិច្ចដោយទឹកណា ៗ បុគ្គលគប្បីធ្វើដោយទឹក គេមិនគួរធ្វើកិច្ចដោយទឹក

នោះ ៗបានទេ ។

បទថា តទុបេយ្យមានំ ប្រែថា ទឹកនោះគេផឹកមិនបាន ។

បទថា កិច្ចករោ ច ហោតិ សេចក្តីថា អ្នកធ្វើកិច្ចគឺ ការងារ និងអ្នកធ្វើកិច្ចគឺ កុសលរបស់ខ្លួន រមែងបរិភោគ រមែងប្រកបការងារនិងការឱ្យទាន ។

ទុតិយាបុត្តកសូត្រ

នៅក្នុងបិដកលេខ ២៩ ទំព័រ ២៤៨ ព្រះដ៏មានព្រះភាគ ជាម្ចាស់ ទ្រង់ត្រាស់សម្តែងអំពីរឿងសេដ្ឋីគហបតីម្នាក់ ដែលមានសេចក្តីកំណាញ់ជាមួយនឹងព្រះបាទបសេនទិកោសល ដោយមានសេចក្តីថា ៖

គ្រានោះ ព្រះបាទបសេនទិកោសល ចូលទៅគាល់ព្រះមានព្រះភាគទាំងថ្ងៃត្រង់ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគហើយ គង់នៅក្នុងទីសមគួរ ។

លុះព្រះបាទបសេនទិកោសល គង់នៅក្នុងទីសមគួរហើយ ព្រះមានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា បពិត្រមហារាជ ចុះព្រះអង្គទើបនឹងស្តេចមកពីណា ទាំងថ្ងៃត្រង់ ។

ព្រះបាទបសេនទិកោសលក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សេដ្ឋីគហបតីក្នុងក្រុងសាវត្ថីនេះ ធ្វើមរណកាលទៅហើយ ខ្ញុំព្រះអង្គមកនាំយកទ្រព្យសេដ្ឋីគ្មានកូននោះ ទៅកាន់ខាងក្នុងព្រះរាជវាំង បពិត្រព្រះអង្គដ៏ចម្រើន គ្រាន់តែប្រាក់មានចំនួនមួយរយ-សែនទៅហើយ ទើបបាច់ពោលទៅថ្វីដល់រូបិយៈ បពិត្រព្រះអង្គដ៏ចម្រើន **សេដ្ឋីគហបតីនោះមានការបរិភោគភត្តបែបនេះ គឺគាត់បរិភោគបាយចុងអង្ករ** មានជ្រក់ជាគម្រប់ពីរ មានការប្រើប្រាស់សម្ពត់បែបនេះ **គឺគាត់ប្រើប្រាស់សម្ពត់សំបក់ផ្ទៃ ប៉ះជា ៣ ផ្ទាំង មានការប្រើប្រាស់យានបែបនេះ គឺគាត់ជិះរថតូចកញ្ជាស់ ជាំងឆត្រស្លឹកយ៉ាងតូច ។**

បពិត្រមហារាជ ពាក្យនេះយ៉ាងនេះហើយ បពិត្រមហារាជ ពាក្យនេះយ៉ាងនេះហើយ បពិត្រមហារាជ កាលពីព្រេងនាយមក សេដ្ឋីគហបតីនោះ បានឱ្យគេប្រតិបត្តិព្រះតគរសិខីបច្ចេកពុទ្ធដោយបិណ្ឌបាត្រថា អ្នកទាំងឡាយចូរឱ្យដុំបាយដល់សមណៈដូច្នេះ លុះពោលរួចហើយ ក៏ក្រោកអំពីអាសនៈចៀសចេញទៅ លុះសេដ្ឋី-គហបតីនោះឱ្យរួចហើយជាអ្នកមានសេចក្តីក្តៅក្រហាយក្នុងពេល

ជាខាងក្រោយថា ទាសៈទាំងឡាយក្តី កម្មករទាំងឡាយក្តី គប្បីបរិភោគនូវបិណ្ឌបាត្រនេះប្រសើរជាង មិនតែប៉ុណ្ណោះ សេដ្ឋីគហបតីនោះបានទាំងផ្តាច់កូនម្នាក់របស់បង ព្រោះហេតុនៃទ្រព្យ ។ បពិត្រមហារាជ សេដ្ឋីគហបតីនោះ បានឱ្យគេប្រគល់ព្រះតគរសិខីបច្ចេកសម្ពុទ្ធដោយបិណ្ឌបាត្រហើយ បានទៅកាន់សុគតិ សួគ៌ទេវលោកអស់វារៈ ៧ ដង ដោយវិបាកនៃកម្មនោះឯង បានតំណែងជាសេដ្ឋីក្នុងក្រុងសាវត្ថីនេះឯងអស់វារៈ ៧ ដង ដោយសេសសល់ផលកម្មនោះឯង ។

បពិត្រមហារាជ លុះសេដ្ឋីគហបតីនោះឱ្យរួចហើយ ជាអ្នកមានសេចក្តីក្តៅក្រហាយ ក្នុងពេលជាខាងក្រោយថា ទាសៈទាំងឡាយក្តី កម្មករទាំងឡាយក្តី គប្បីបរិភោគនូវបិណ្ឌបាត្រនេះប្រសើរជាង ដោយវិបាកនៃកម្មនោះ បានជាសេដ្ឋីគហបតីនេះ មិនបង្អោនចិត្តទៅដើម្បីបរិភោគនូវភត្តឆ្ងាញ់ពិសា មិនបង្អោនចិត្តទៅដើម្បីប្រើប្រាស់សម្ពត់ល្អថ្លៃថ្លា មិនបង្អោនចិត្តទៅដើម្បីប្រើប្រាស់យានល្អ មិនបង្អោនចិត្តទៅដើម្បីបរិភោគបញ្ចកាមគុណដ៏ថ្លៃថ្លា ។

បពិត្រមហារាជ សេដ្ឋីគហបតីនោះផ្តាច់ជីវិតកូនប្រុសម្នាក់

របស់បង ព្រោះហេតុនៃទ្រព្យ បានជាឆេះនៅក្នុងនរកអស់ឆ្នាំជាច្រើន អស់ពាន់នៃឆ្នាំជាច្រើន អស់សែននៃឆ្នាំជាច្រើន ដោយវិបាកនៃកម្មនោះ ជនទាំងឡាយតែងទៅនាំទ្រព្យសេដ្ឋីគ្មានកូននេះមកជាក់ព្រះឃ្លាំងអស់វារៈជាគម្រប់ ៧ ដងនេះហើយ ដោយសេសសល់នៃផលកម្មនោះឯង អស់រយនៃឆ្នាំជាច្រើន ។

បពិត្រមហារាជ បុណ្យចាស់របស់សេដ្ឋីគហបតីនោះអស់រលីងទៅ ទាំងបុណ្យថ្មី គាត់ក៏មិនសន្សំឡើយ ។

បពិត្រមហារាជ ក៏ក្នុងថ្ងៃនេះ សេដ្ឋីគហបតីនោះឆេះនៅក្នុងមហាភេរុវនរក ។

បពិត្រព្រះអង្គដ៏ចម្រើន សេដ្ឋីគហបតីចូលទៅកាន់មហាភេរុវនរក មែនឬ ។

បពិត្រមហារាជ សេដ្ឋីគហបតីចូលទៅកាន់មហាភេរុវនរក មែន ។

ព្រះមានព្រះភាគ ទ្រង់បានត្រាស់នូវពាក្យនេះហើយ ទើបបានត្រាស់នូវគាថានេះតទៅទៀតថា ៖

ធញ្ញំ ធនំ រជតំ ជាតរូបំ បរិគ្គហំ វាបិ យធត្ថិ កិញ្ចិ

ទាសា កម្មករា បេស្សា យេ ចស្ស អនុជីវិនោ
សព្វញ្ញាទាយ គន្តព្វំ សព្វំ និក្ខិបតាមិនំ
យញ្ហេ កភោតិ កាយេន វាចាយ ឧទ ចេតសា
តំ ហិ តស្ស សកំ ហោតិ តញ្ហេ អាទាយ គច្ឆតិ
តញ្ហេស្ស អនុកំ ហោតិ ឆាយាវ អនុបាយិនី
តស្មា កយេរ្យ កល្យាណំ និចយំ សម្បរាយិកំ
បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ ។

របស់ណាមួយគឺស្រេវទ្រព្យ ប្រាក់ មាស ដែលខ្ជនហួង ហែងក្តីជនទាំងឡាយណាគឺទាស: កម្មករ អ្នកបម្រើ និងអ្នកស៊ីឈ្នួនៃខ្ជនោះក្តី បុគ្គលមិនគប្បីកាន់យករបស់ទាំងអស់នោះទៅបានទេត្រូវតែលះបង់របស់ទាំងអស់នោះហើយទៅលុះតែបុគ្គលធ្វើកម្មណាដោយកាយ ដោយវាចា ឬដោយចិត្ត កម្មនោះឯង ជារបស់ខ្ជននៃបុគ្គលនោះ បុគ្គលតែងកាន់យកនូវកម្មនោះទៅ កម្មនោះតែងទៅតាមនូវបុគ្គលនោះ ដូចជាស្រមោលអនុលតាមប្រាណព្រោះហេតុនោះ សាធុជនគួរធ្វើកម្មជាកុសលដែលប្រព្រឹត្តទៅក្នុងបរលោកឱ្យច្រើន(ព្រោះថា)បុណ្យទាំងឡាយក្នុងបរលោក ។

អដ្ឋកថា

បទថា **បិណ្ឌបាតេន បដិបាទេសិ** បានដល់ ប្រកបទុកនឹងបិណ្ឌបាតអធិប្បាយថា បានថ្វាយបិណ្ឌបាត ។

បទថា **បក្កាមិ** បានដល់ ទៅដោយកិច្ចយ៉ាងណាមួយគឺ ដោយកិច្ចមានចូលគាល់ព្រះរាជាជាដើម ។

បទថា **បច្ចា វប្បដិសារី អហោសិ** សេចក្តីថា បានឮថា សេដ្ឋីនោះជួបព្រះបច្ចេកសម្ពុទ្ធអង្គនោះ សូម្បីក្នុងថ្ងៃដទៃ ៗតែគេមិនបានកើតចិត្តគិតនឹងថ្វាយទាន ។ ក្នុងថ្ងៃនោះ ព្រះបច្ចេកសម្ពុទ្ធនាមថា **តគរសិខី** បុត្រទី ៣ របស់នាងបទុមវតីទេវី អង្គនេះបញ្ឈប់នៅដោយសុខកើតពីផលសមាបត្តិក្នុងភ្នំគន្ធមាទន៍ ក្រោកឡើងក្នុងវេលាព្រឹក ខ្ពុរព្រះឱស្ឋ ក្នុងស្រះអនោត្តៈ ស្លៀកស្បង់ពណ៌ក្រហមដូចទឹកជាត ក្រវាត់វត្តពួនចង្កេះ កាន់បាត្រចីវរ ចូលចតុត្ថជ្ឈានដែលជាបាទនៃអភិញ្ញា ហោះទៅដោយឫទ្ធិចុះក្បែរទ្វារនគរ ដណ្តប់ចីវរហើយកាន់បាត្រដល់ទ្វារផ្ទះរបស់សេដ្ឋីតាមលំដាប់ ដោយអាកប្បៈអាការ មានឈានទៅជាដើមដែលគួរជ្រះថ្លា ដូចជាដាក់របស់មានតម្លៃមួយពាន់ ក្បែរទ្វារនគរសម្រាប់អ្នកនគរទាំង

ឡាយ ថ្ងៃនោះ សេដ្ឋីភ្ញាក់ពីព្រឹកព្រលឹម បរិភោគអាហារដ៏ប្រណីត ក្រាលអាសនៈក្នុងភ្លោងទ្វារផ្ទះ នៅអង្គុយសំអាតធ្មេញ សេដ្ឋីនោះ ឃើញព្រះបច្ចេកសម្ពុទ្ធហើយ កើតចិត្តគិតនឹងថ្វាយទាន ព្រោះថ្ងៃនោះ សេដ្ឋីបរិភោគអាហារព្រឹកហើយអង្គុយ ទើបហៅភរិយាមកបង្គាប់ថា អ្នកឯងចូរថ្វាយបិណ្ឌបាតដល់សមណៈនេះ ហើយក៏ជៀសទៅ ។ ភរិយាសេដ្ឋីគិតថា ដោយវេលាដល់ត្រឹមប៉ុណ្ណេះ យើងមិនធ្លាប់បានឮពាក្យថា អ្នកឯងចូរថ្វាយទានដល់អ្នកនេះ តែថ្ងៃនេះ សេដ្ឋី សូម្បីកាលបង្គាប់ឱ្យថ្វាយទាន ក៏មិនបានបង្គាប់ឱ្យថ្វាយដល់អ្នកនោះ អ្នកនេះ តែឱ្យថ្វាយទានដល់ព្រះបច្ចេកសម្ពុទ្ធអ្នកប្រាសចាករាគទោសនិងមោហៈ អ្នកបន្ទោរបង់កិលេស អ្នកដាក់ភារៈហើយ យើងមិនចាំបាច់ថ្វាយទានវត្ថុនោះវត្ថុនេះ តែនឹងថ្វាយបិណ្ឌបាតដ៏ប្រណីត នាងចេញចាកផ្ទះ ហើយសំពះព្រះបច្ចេកសម្ពុទ្ធដោយបញ្ចង្គប្រតិស្ឋាន ហើយទទួលបាត្រនិមន្តឱ្យអង្គុយលើអាសនៈ ដែលចាត់ទុកក្នុងខាងក្នុងនិវេសន៍ ផ្សំអាហារដោយអង្គរស្រូវសាលីដែលបរិសុទ្ធល្អ កំណត់នឹងដែលគួរទំពា និងសម្ងួតដែលសមគួរជាក់ពេញបាត្រ ប្រជាប់របស់ក្រអូបទុកខាងក្រៅបាត្រ ផ្ដិតផ្ដង់ថ្វាយជាក់ក្នុងដៃទាំងពីរបស់ព្រះបច្ចេកពុទ្ធ ហើយ

សំពះ ។ ព្រះបច្ចេកពុទ្ធមិនទាន់ឆាន់ដោយគិតនឹងធ្វើការសង្គ្រោះ ព្រះបច្ចេកពុទ្ធអង្គដទៃ ។ ទើបធ្វើអនុមោទនាហើយជៀសទៅ ។ សេដ្ឋីសូម្បីនោះឯងកំពុងដើរមកពីខាងក្រៅ ឃើញព្រះបច្ចេកពុទ្ធសួរថា ខ្ញុំបង្គាប់ឱ្យគេថ្វាយបិណ្ឌបាតដល់លោកម្ចាស់ ហើយជៀសទៅ លោកម្ចាស់បានបិណ្ឌបាតហើយឬ ។ ព្រះបច្ចេកពុទ្ធឆ្លើយថា ត្រូវមែន សេដ្ឋី អាត្មាបានហើយ សេដ្ឋីបំណងថា នឹងមើល ទើបងើយកឡើងមើល ។ ខណៈនោះឯង ភ្លិនបិណ្ឌបាតរបស់ព្រះបច្ចេកពុទ្ធនោះក៏សាយជះឡើងប៉ះខ្ទប់ប្រហោងច្រមុះ ។ គេមិនអាចសង្រួមចិត្តបាន ខាងក្រោយក៏មានវិប្បដិសារក្តៅក្រហាយចិត្ត ។

ពាក្យថា **វរមេតំ** ជាដើម ជាការសម្តែងអាការរបស់សេចក្តីក្តៅចិត្តដែលកើតឡើង តែគេក៏សម្លាប់បុត្រមួយនាក់របស់បងប្រុសចោល ព្រោះហេតុនៃទ្រព្យសម្បត្តិ ។ បានឮថា គ្រានោះ កាលគំនរទ្រព្យមិនទាន់បានបែងចែកគ្នា មាតាបិតានិងបងប្រុសរបស់គេក៏ស្លាប់ទៅ គេទើបនៅរួមនឹងភរិយារបស់បងប្រុស ។ តែបងប្រុសរបស់គេមានបុត្រនៅម្នាក់ ។ ក្មេងនោះកំពុងលេងនៅត្រង់ថ្នល់ មនុស្សទាំងឡាយក៏និយាយគ្នាថា នេះទាស នេះទាសី នេះយាន នេះទ្រព្យជារបស់ ។ អ្នកឯង ក្មេងនោះ ក៏ចាប់ពាក្យរបស់

មនុស្សទាំងនោះ យកមកនិយាយថា ឥឡូវនេះ នេះជារបស់ ៗ យើងដូច្នេះជាដើម ។

ចំណែកពួរបស់ក្មេងនោះគិតថា "ឥឡូវនេះ ក្មេងនេះញ៉ាំងនិយាយយ៉ាងនេះ កាលយើងចាស់ ខ្លួនគេក៏នឹងគប្បីកាត់គំនរទ្រព្យចេញចន្លោះកណ្តាល ឥឡូវនេះឯង យើងចាំនឹងត្រូវធ្វើការដែលនឹងគប្បីធ្វើដល់ក្មេងនេះ" ។ ថ្ងៃមួយ គេកាន់កាំបិតបង្គាប់ថា "នែកូន មកនេះ យើងនឹងទៅព្រៃជាមួយគ្នា" ហើយនាំក្មេងនោះទៅព្រៃ សម្លាប់ក្មេងនោះដែលកំពុងស្រែកទួញយំ ចោះចុះក្នុងអណ្តូងលុបដោយធូលី ។ លោកសំដែងយកប្រការនេះទើបពោលពាក្យនេះ ។

បទថា សត្តក្ខត្តុំ ប្រែថា ៧ គ្រា ។ ក៏ក្នុងពាក្យនេះគប្បីជ្រាបសេចក្តីដោយចេតនាដើមនិងចេតនាក្រោយ ។ ពិតមែនក្នុងការថ្វាយបិណ្ឌបាតតែម្តង ចេតនាតែមួយគ្រា រមែងមិនឱ្យបដិសន្ធិពីរគ្រា ។ ក៏សេដ្ឋីនោះកើតក្នុងសួគ៌ ៧ ដង ក្នុងត្រកូលសេដ្ឋី ៧ ដង ក៏ដោយចេតនាដើមនិងចេតនាក្រោយ ។

បទថា **បុរាណំ** បានដល់ កម្មគឺ ចេតនាក្នុងបិណ្ឌបាតទានដែលថ្វាយដល់ព្រះបច្ចេកពុទ្ធ ។

បទថា **បរិគ្គហំ** បានដល់ វត្តដែលហួងហែង ។

បទថា **អនុជីវិនោ** បានដល់ ពួកត្រកូលចំនួន ៥០ ខ្នះ ៦០ ខ្នះអាស្រ័យត្រកូលធំត្រកូលមួយចិញ្ចឹមជីវិតនៅ ។ លោកសំដៅយកអ្នកទាំងនោះ ទើបពោលពាក្យនេះ ។

បទថា **សព្វង្ហាធាយ គន្តុំ** បានដល់ នាំយកទ្រព្យនោះទាំងអស់ទៅមិនបាន ។

បទថា **និក្ខីបតាមិនំ** បានដល់ ទ្រព្យទាំងអស់នោះមានការត្រូវចោលទុកជាសភាព អធិប្បាយថា មានការចាំបាច់ត្រូវលះបង់ជាសភាវៈទាំងនោះ ។

រឿងសេដ្ឋីអ្នកមិនមានបុត្រ

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះថា **អបុត្តកៈ** ត្រាស់ព្រះធម្មទេសនានេះថា "**ហានន្តិ** ភោគោ ទុម្មេធំ" ជូច្នេះជាដើម ។

(ប្រវត្តិកាលនៅមានជីវិតរបស់អបុត្តកសេដ្ឋី)

បានឮមកថា ព្រះបាទបសេនទិកោសល ទ្រង់ព្រះសណ្តាប់

ការធ្វើមរណកាលរបស់សេដ្ឋីនោះហើយ ក៏គ្រាស់សួរថា" ទ្រព្យសម្បត្តិដែលគ្មានបុត្រ នឹងទៅជារបស់អ្នកណា ?" ទ្រង់ព្រះសណ្តាប់ថា "នឹងទៅជាព្រះរាជទ្រព្យ" ក៏គ្រាស់ឱ្យនាំទ្រព្យអំពីផ្ទះរបស់សេដ្ឋីនោះ មកកាន់រាជត្រកូល(អស់ពេលវេលា) ៧ ថ្ងៃ ហើយស្តេចយាងទៅកាន់សម្នាក់ព្រះសាស្តា កាលព្រះសាស្តាត្រាស់សួរថា "បពិត្រមហារាជ ព្រះអង្គស្តេចមកអំពីទីណាទាំងកណ្តាលថ្ងៃ" ក៏ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន គហបតីជាសេដ្ឋីក្រុងសាវត្ថីនេះធ្វើកាលកិរិយាហើយ ខ្ញុំព្រះអង្គនាំទ្រព្យសម្បត្តិដែលគ្មានបុត្តនោះទៅកាន់រាជសម្នាក់ហើយទើបមក" ។

រឿងទាំងពួង គប្បីជ្រាបតាមន័យដែលមានមកហើយក្នុងព្រះសូត្រនោះចុះ ។

កាលព្រះរាជាក្រាបទូលសេចក្តីយ៉ាងនេះថា " បានឮថា សេដ្ឋីនោះ កាលអ្នកបម្រើនាំភោជនមានរសដ៏ប្រណីតផ្សេង ៗ ចូលទៅឱ្យដោយថាសមាស ក៏ពោលថា មនុស្សទាំងឡាយ តែងតែបរិភោគបែបនេះឬ, ពួកឯងមានចេតនាបញ្ឈឺយើងឬ ? កាលអ្នកបម្រើនាំភោជនចូលទៅតម្កល់ ទុកឱ្យក៏ប្រហារអ្នកបម្រើទាំង

នោះ ដោយដុំដីនិងដំបងជាដើម ឱ្យចៀសចេញទៅបរិភោគបាយ ចុងអង្គរ មានទឹកជ្រក់ជាគម្រប់ ២ ដោយពោលថា នេះទើបជាភោជនសម្រាប់មនុស្ស, សូម្បីកាលអ្នកបម្រើចាត់ចែងរៀបចំសំពត់ យានទិងឆត្រដែលជាទីពេញចិត្តជូន ក៏ប្រហារអ្នកបម្រើទាំងនោះឱ្យចៀសចេញទៅ ដោយដុំដីនិងដំបងជាដើម ស្លៀកដណ្តប់សំពត់សម្បកឈើ ប្រើប្រាស់ឆត្រស្លឹកឈើ ហើយទៅណាមកណារមែងទៅដោយរថកញ្ជាស់ ។ ទើបព្រះសាស្តាត្រាស់សម្តែងបុព្វកម្មរបស់អបុត្តសេដ្ឋីនោះថា ៖

[បុព្វកម្មរបស់អបុត្តកសេដ្ឋី]

"មហាបពិត្រ រឿងធ្លាប់មានមកហើយ គហបតីដែលជាសេដ្ឋីនោះ ទទួលព្រះបច្ចេកពុទ្ធព្រះនាមថាតគរសិខីដោយបិណ្ឌបាត ហើយពោលថា អ្នកទាំងឡាយ ចូរប្រគេនបិណ្ឌៈដល់សមណៈដូច្នេះហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។ បានឮថា កាលសេដ្ឋីនោះ អ្នកមិនមានសទ្ធា ជាអ្នកល្ងង់ខ្លៅ ពោលយ៉ាងនេះហើយចៀសចេញទៅ ភរិយារបស់គាត់ដែលជាអ្នកមានសទ្ធាជ្រះថ្លា គិតថា ឃុរណាស់មកហើយ យើងមិនដែលបានឮ

ពាក្យថា អ្នកចូរឱ្យអំពីមាត់របស់សេដ្ឋីនេះទេ ទើបតែបានឮក្នុងថ្ងៃនេះឯង, មនោរថរបស់យើងនឹងពេញក្នុងថ្ងៃនេះ, យើងនឹងថ្វាយបិណ្ឌបាត ហើយទទួលបាត្ររបស់ព្រះបច្ចេកពុទ្ធ មកជាក់ភោជនដ៏ប្រណីតហើយប្រគេនព្រះបច្ចេកពុទ្ធ ។ ចំណែកសេដ្ឋីនោះត្រឡប់មកឃើញព្រះបច្ចេកពុទ្ធនោះ ក៏សួរថា "សមណៈលោកបានអ្វី ៗ ហើយឬ" ហើយចាប់បាត្រឃើញបិណ្ឌបាតដ៏ប្រណីតក៏មានសេចក្តីក្តៅក្រហាយស្តាយក្រោយ ទើបគិតយ៉ាងនេះថា " ប្រសិនបើទុកបិណ្ឌបាតនេះ ឱ្យពួកទាសៈ ឬពួកកម្មករបរិភោគវិញប្រសើរជាង ព្រោះថា ពួកគេលុះបានបរិភោគបិណ្ឌបាតនេះហើយ នឹងធ្វើការងារឱ្យយើង, ចំណែកសមណៈឆាន់ហើយក៏នឹងទៅដេកលក់យ៉ាងស្រួល, បិណ្ឌបាតរបស់យើងវិនាសអស់ហើយ " មិនត្រឹមតែប៉ុណ្ណោះ សេដ្ឋីនោះ បានសម្លាប់កូនប្រុសរបស់បង ប្រុសខ្ចីម្នាក់ ព្រោះហេតុនៃទ្រព្យសម្បត្តិ ។ ក្មេងនោះចាប់ម្រាមដៃរបស់សេដ្ឋីនោះ ដើរទៅបណ្តើរពោលបណ្តើរថា "យាននេះរបស់បិតាខ្ញុំ គោនេះក៏ជារបស់គាត់ដែរ" ។ គ្រានោះ សេដ្ឋីគិតថា "ឥឡូវនេះ ក្មេងនេះ ចេះពោលយ៉ាងនេះទៅហើយ, ក៏ក្នុងកាលក្មេងនេះចម្រើនវ័យ

ហើយ នរណានឹងក្សាទ្រព្យសម្បត្តិក្នុងផ្ទះនេះបាន ក៏នាំក្មេងនោះទៅកាន់ព្រៃ ចាប់ច្របាច់ក.ដូចច្របាច់មើមដំឡូង ឱ្យងាប់ក្បែរគុម្ពឈើមួយហើយបោះសាកសពក្មេងនោះចោលក្នុងទីនោះឯង” ។ នេះជាបុព្វកម្មរបស់សេដ្ឋីនោះ ។

[សរុបកម្មនិងផលនៃកម្មរបស់សេដ្ឋី]

ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះថា “មហាបពិត្រ ដោយផលនៃកម្មដែលគហបតីជាសេដ្ឋីទទួលព្រះបច្ចេកពុទ្ធព្រះនាមថាតគរសិខីដោយបិណ្ឌបាតនោះឯង ទើបសេដ្ឋីនោះទៅកាន់សុគតិសួគ៌ទេវលោក ៧ ដង, ដោយផលដ៏សេសនៃកម្មនោះទើបសេដ្ឋីនោះបានជាសេដ្ឋីនៅក្នុងក្រុងសាវត្ថីនេះឯងដល់ទៅ ៧ ដង ។ មហាបពិត្រ ដោយផលនៃកម្មដែលសេដ្ឋីនោះឱ្យទានហើយ មានការស្តាយក្រោយថា ពួកទាសៈ ឬកម្មករគប្បីបរិភោគបិណ្ឌបាតនេះប្រសើរជាង, ទើបសេដ្ឋីនោះមិនបង្អោនចិត្តទៅដើម្បីបរិភោគភត្តដែលប្រណីត ៗ, មិនបង្អោនចិត្តទៅដើម្បីប្រើប្រាស់សំពត់ដែលប្រណីត ៗ,មិនបង្អោនចិត្តទៅដើម្បីប្រើប្រាស់យានដែលប្រណីត ៗ,មិនបង្អោនចិត្តទៅដើម្បីបរិភោគកាមគុណ

ទាំង ៥ ឱ្យសប្បាយចិត្ត ។ មហាបពិត្រ ដោយផលនៃកម្មដែលសេដ្ឋីនោះ ផ្តាច់ជីវិតបុត្រតូចរបស់បង់ប្រុសម្នាក់ ព្រោះហេតុនៃទ្រព្យសម្បត្តិ, ទើបសេដ្ឋីនោះឆេះក្នុងនរកអស់ឆ្នាំជាច្រើន អស់រយឆ្នាំជាច្រើន អស់ពាន់ឆ្នាំជាច្រើន អស់សែនឆ្នាំជាច្រើន ។ ជនទាំងឡាយ ញាំងទ្រព្យសម្បត្តិរបស់សេដ្ឋីដែលគ្មានបុត្រក្នុងជាតិទី ៧នេះឱ្យចូលទៅកាន់ព្រះរាជឃ្លាំង ដោយផលដ៏សេសនៃកម្មនោះឯង ។ មហាបពិត្រម្យ៉ាងទៀត បុណ្យចាស់របស់សេដ្ឋីនោះអស់ហើយហើយបុណ្យថ្មីសេដ្ឋីនោះមិនបានសន្សំ,មហាបពិត្រថ្ងៃនេះ សេដ្ឋីនោះឆេះនៅក្នុងមហាអវីចិនរក ។

[ភោគៈទាំងឡាយរមែងសម្ងាប់បុគ្គលអប្បបញ្ញា]

ព្រះរាជា ទ្រង់ព្រះសណ្តាប់នូវព្រះតម្រាស់របស់ព្រះសាស្តាហើយក៏ក្រាបទូលថា"បពិត្រព្រះអង្គដ៏ចម្រើន គួរអស្ចារ្យណាស់នេះជាកម្មដ៏ធ្ងន់,សេដ្ឋីនោះកាលភោគៈមានប្រមាណប៉ុណ្ណោះ មានមិនបរិភោគដោយខ្លួនឯង, កាលព្រះពុទ្ធដូចជាព្រះអង្គ ទ្រង់គង់នៅក្នុងវិហារជិត ។ ក៏មិនបានធ្វើបុណ្យ" ។

ព្រះសាស្តាត្រាស់ថា"យ៉ាងហ្នឹងហើយមហាបពិត្រធម្មតាបុគ្គលល្ងង់ខ្លៅអប្បបញ្ញាបានភោគៈទាំងឡាយហើយ រមែងមិន

ស្វែងរកនិព្វាន, ម្យ៉ាងទៀត តណ្ហាដែលកើតឡើង ព្រោះអាស្រ័យ
ភោគៈទាំងឡាយ រមែងសម្លាប់បុគ្គលទាំងនោះអស់កាលយូរ ”
ដូច្នេះហើយ បានត្រាស់ព្រះគាថានេះថា ៖

ហន្តិ ភោគា ទុម្មេធំ យោ ច បារគវេសិនោ
ភោគតណ្ហាយ ទុម្មេធោ ហន្តិ អញ្ញេវ អត្តនំ
តិណាទោសានិ ខេត្តានិ រាគទោសា អយំ បជា
តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ ។

ភោគៈទាំងឡាយ រមែងសម្លាប់បុគ្គលអប្បប្រាជ្ញា ប៉ុន្តែមិន
សម្លាប់បុគ្គលអ្នកស្វែងរកត្រើយគឺព្រះនិព្វានទេ ឯបុគ្គលអប្ប
ប្រាជ្ញា រមែងសម្លាប់ខ្លួនឯង ដូចជាសម្លាប់បុគ្គលដទៃ ព្រោះចំណង់
ក្នុងភោគៈ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បាទព្រះគាថាថា យោ ច បារគវេសិនោ
សេចក្តីថាប៉ុន្តែភោគៈទាំងឡាយរមែងមិនសម្លាប់បុគ្គលអ្នកស្វែង
រកត្រើយ គឺព្រះនិព្វានជាប្រក្រតី ។

បាទព្រះគាថាថា ហន្តិ អញ្ញេវ អត្តនំ សេចក្តីថា បុគ្គល

អប្បបញ្ញា រមែងសម្លាប់ខ្លួនឯង ដូចសម្លាប់អ្នកដទៃព្រោះតណ្ហា ដែលកើតឡើង ព្រោះអាស្រ័យភោគៈទាំងឡាយ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផល ទាំងឡាយមានសោតាបត្តិផលជាដើម ។

ពាក្យរបស់នាងវេឥតីនៅក្នុងនរក

នៅក្នុងបិដកលេខ ៥៥ ទំព័រ ១១១ នាងវេឥតីដែលត្រូវជាភរិយារបស់នន្ទិយឧបាសក បានត្រូវពួកនិរយបាលមកចាប់នាងទាំងនៅមានជីវិត យកទៅបោះនៅក្នុងនរក ហើយបាននិយាយពាក្យទាំងនេះថា ៖

៦. បុគ្គលណាចេញអំពីលោកនេះ (ពីនរក) ទៅកាន់មនុស្សលោកហើយ ខ្ញុំសួរគប្បីប្រាប់ខ្ញុំយ៉ាងនេះថា អ្នកទាំងឡាយចូរឱ្យសម្ពត់សម្រាប់ស្លៀកដណ្តប់ ទីដេក ទីអង្គុយ និងបាយ ទឹក ជាទាន ចំពោះពួកជនដែលមានអាជ្ញាជាក់ចុះហើយ បើពិតថាបុគ្គលមានសេចក្តីកំណាញ់ ជាអ្នកជេរប្រទេចគេ មានធម៌ដ៏លាមក រមែងមិនបានទៅកើតជាមួយនឹងពួកអ្នកដែលទៅកើតក្នុងឋានសួគ៌ ។

ឯ. ខ្ញុំនោះ**ប្រសិនបើរួចទៅអំពីនេះហើយ**បាននូវកំណើតរបស់មនុស្ស នឹងជាអ្នកដឹងក្តីបរិបូណ៌ដោយសីល ធ្វើនូវកុសលឱ្យច្រើន ដោយការឱ្យទាន ការប្រព្រឹត្តស្មើ ការសង្រួម និងការទូន្មាននូវឥន្ទ្រិយ ។

ឯ. មួយទៀត ខ្ញុំនឹងដាំឈើសួន សង់ស្ពានសម្រាប់ឆ្លងទៅមកក្នុងទីដែលលំបាក ជីកអណ្តូង ជីកស្រះដោយចិត្តជ្រះថ្លា ។

ឯ. ខ្ញុំនឹងរក្សាឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ខ្ញុំនឹងជាបុគ្គលសង្រួមក្នុងសីលទាំងគ្រប់កាល ខ្ញុំនឹងមិនប្រមាទក្នុងទាន ព្រោះខ្ញុំបានឃើញអំពើនេះជាក់ច្បាស់ដោយខ្លួនឯងហើយ ។

លំដាប់នោះ ពួកនិរយបាលបានបោះនាងវេតីដែលកំពុងយំ បម្រះនៀលយ៉ាងនោះទៅក្នុងនរកដ៏ពន្លឹក ឱ្យមានជើងឡើងលើ មានក្បាលចុះក្រោម ។

នាងវេតីបាននិយាយពាក្យចុងក្រោយទៀតថា ***ក្នុងកាលមុន ខ្ញុំជាអ្នកមានសេចក្តីកំណាញ់ ជាអ្នកជេរប្រទេចនូវពួកសមណៈនិងព្រាហ្មណ៍ បោកប្រាស់នូវស្វាមីដោយពាក្យមិនពិត ទើបខ្ញុំឆេះក្នុងនរក មានសភាពដ៏ពន្លឹក ។***

គិតមើល៍ទៅ

យាទិសំ វប្បតេ ពីជំ តាទិសំ លភតេ ផលំ
កល្យាណការីច កល្យាណំ បាបការីច បាបកំ ។

មនុស្សក្នុងលោក គេសាបព្រោះបណ្តុះពូជបែបណា តែងបានផ្លែផ្កាមកជាបែបនោះវិញ សេចក្តីនេះមានឧបមាដូចម្តេចមិញ កល្យាណជនអ្នកធ្វើអំពើល្អតែងបានល្អ បាបជនអ្នកធ្វើអាក្រក់ ក៏តែងបានអាក្រក់ មានឧបមេយ្យដូច្នេះដែរ ។

អត្តនា វ កតំ បាបំ អត្តនា សង្កិលិស្សតិ
អត្តនា អកតំ បាបំ អត្តនា វ វិសុជ្ឈតិ
សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។

អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើបាបខ្លួនឯង តែងបរិសុទ្ធខ្លួនឯង សេចក្តីបរិសុទ្ធ និងមិនបរិសុទ្ធមានចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃឱ្យបរិសុទ្ធពុំបានឡើយ ។

អត្តា ហិ អត្តនោ នាថោ កោ ហិ នាថោ បរោ សិយា
អត្តនា ហិ សុទន្តេន នាថំ លភតិ ទុល្លភំ ។

ខ្លួនជាទីពឹងរបស់ខ្លួន អ្នកដទៃជាទីពឹងដូចម្តេចបាន ព្រោះបុគ្គលអ្នកមានខ្លួនហ្វឹកហ្វឺនល្អហើយ រមែងបាននូវទីពឹងដែលគេបានដោយកម្រ ។

មច្ឆរិយសូត្រ

នៅក្នុងបិដកលេខ ៤៥ ទំព័រ ២៣ ព្រះមានព្រះភាគ ជាម្ចាស់ទ្រង់ត្រាស់សម្តែងនូវធម៌ដែលធ្វើឱ្យភិក្ខុនីដូចធ្លាក់នរក និងឡើងឋានសួគ៌ ជាមួយនឹងភិក្ខុទាំងឡាយ មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។ **ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេច ។**

១- អាវាសមច្ឆរិនី ហោតិ គឺភិក្ខុនីកំណាញ់អាវាស

២- កុលមច្ឆរិនី ហោតិ កំណាញ់ត្រកូល

៣- លាភមច្ឆរិនី ហោតិ កំណាញ់លាភ

៤- វណ្ណមច្ឆរិនី ហោតិ កំណាញ់គុណ

៥- ធម្មមច្ឆរិនី ហោតិ កំណាញ់ធម៌ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនេះឯង នឹងធ្លាក់ទៅក្នុងនរក ដូចជាគេនាំយកទៅទម្លាក់ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនឹង

ទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅទម្លាក់ ។ **ប្រកបដោយធម៌ ៥ យ៉ាង តើដូចម្តេច ។**

១- ន អាវាសមច្ឆរិនី ហោតិ គឺភិក្ខុនីមិនកំណាញ់អាវាស

២- ន កុលមច្ឆរិនី ហោតិ **មិន**កំណាញ់ត្រកូល

៣- ន លាភមច្ឆរិនី ហោតិ មិនកំណាញ់លាភ

៤- ន វណ្ណមច្ឆរិនី ហោតិ **មិន**កំណាញ់គុណ

៥- ន ធម្មមច្ឆរិនី ហោតិ **មិន**កំណាញ់ធម៌ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីប្រកបដោយធម៌ ៥ យ៉ាងនេះឯង នឹងទៅកើតក្នុងស្ថានសួគ៌ ដូចជាគេនាំយកទៅដំកល់ទុក ។

អដ្ឋកថា

បទថា អាវាសមច្ឆរិនី សេចក្តីថា រមែងកំណាញ់អាវាស គឺឃើញបុគ្គលដទៃនៅក្នុងអាវាសនោះ ទ្រាំមិនបាន ។

បទថា កុលមច្ឆរិនី សេចក្តីថា រមែងកំណាញ់ត្រកូលឧបដ្ឋាក គឺឃើញបុគ្គលដទៃចូលទៅរកត្រកូលនោះ ទ្រាំមិនបាន ។

បទថា លាភមច្ឆរិនី សេចក្តីថា រមែងកំណាញ់លាភ គឺឃើញលាភកើតឡើងដល់បុគ្គលដទៃ ទ្រាំមិនបាន ។

បទថា វណ្ណមច្ឆរិនី សេចក្តីថា កំណាញ់គុណាសេចក្តីល្អ គឺឃើញគេនិយាយសរសើរគុណរបស់បុគ្គលដទៃទ្រាំមិនបាន ។

បទថា ធម្មមច្ឆរិនី សេចក្តីថា រមែងកំណាញ់បរិយត្តិ-ធម៌ គឺប្រាថ្នានឹងឱ្យបុគ្គលដទៃ ។

សេចក្តីកំណាញ់ ៥ យ៉ាងរបស់តិក្ខុ

ម្នាលភិក្ខុទាំងឡាយ សេចក្តីកំណាញ់នេះមាន ៥ យ៉ាង ។ **សេចក្តីកំណាញ់ ៥ យ៉ាង គឺអ្វីខ្លះ ។**

១- អាវាសមច្ឆរិយំ គឺភិក្ខុកំណាញ់អាវាស

២- កុលមច្ឆរិយំ កំណាញ់ត្រកូល

៣- លាភមច្ឆរិយំ កំណាញ់លាភ

៤- វណ្ណមច្ឆរិយំ កំណាញ់គុណ

៥- ធម្មមច្ឆរិយំ កំណាញ់ធម៌ ។

ម្នាលភិក្ខុទាំងឡាយ សេចក្តីកំណាញ់ ៥ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ បណ្តាសេចក្តីកំណាញ់ ៥ យ៉ាងនេះ សេចក្តីកំណាញ់ធម៌នេះ ជាសេចក្តីកំណាញ់ដែលអ្នកប្រាជ្ញតិះដៀល ។

គោគសូត្រ

នៅក្នុងបិដកលេខ ៤៥, ទំព័រ ២៥៩ ព្រះអង្គទ្រង់ត្រាស់សម្តែង [**អំពីគុណនិងទោសរបស់ភោគទ្រព្យ**] ដោយមានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងភោគៈទាំងឡាយ ។ **ទោស ៥ យ៉ាង គឺអ្វីខ្លះ**

១-អគ្គិសាធារណាភោគា គឺភោគៈជាសាធារណៈដល់ភ្លើង

២-ឧទកសាធារណា ភោគា ភោគៈសាធារណៈដល់ទឹក

៣-រាជសាធារណាភោគា ភោគៈសាធារណៈដល់ព្រះរាជា

៤-ចោរសាធារណា ភោគា ភោគៈសាធារណៈដល់ចោរ

៥-អប្បិយេហិ ឌាយាទេហិ សាធារណា ភោគា ភោគៈសាធារណៈដល់អ្នកទទួលមត៌កដែលមិនជាទីស្រឡាញ់ ។

ម្នាលភិក្ខុទាំងឡាយ ទោស ៥ យ៉ាងនេះ រមែងមានក្នុងភោគៈ ។

ម្នាលភិក្ខុទាំងឡាយ អានិសង្សយ៉ាងនេះ រមែងមានក្នុងភោគៈទាំងឡាយ ។ អានិសង្ស ៥ យ៉ាង គឺអ្វីខ្លះ ។

១- ភោគេ និស្សាយ អត្តានំ សុខេតិ បីណេតិ សម្មា សុខំ គឺអាស្រ័យភោគៈហើយញុំាងខ្លួនឱ្យសុខ ឱ្យឆ្អែត រក្សាខ្លួនឱ្យសុខសប្បាយ

២- បរិហរតិ មាតាបិតរោ សុខេតិ បីណេតិ សម្មា សុខំ ញុំាងមាតានិងបិតាឱ្យសុខ ឱ្យឆ្អែតរក្សាមាតាបិតាឱ្យសុខសប្បាយ

៣- បរិហរតិ បុត្តទារទាសកម្មការបារិសេ សុខេតិ បីណេតិ សម្មាសុខំ ញុំាងកូនប្រពន្ធខ្ញុំ នឹងបុរសជាកម្មករឱ្យសុខឱ្យឆ្អែត រក្សាកូនប្រពន្ធ ខ្ញុំ នឹងបុរសជាកម្មករ ឱ្យសុខសប្បាយ

៤- បរិហរតិ មិត្តាមច្ចេ សុខេតិ បីណេតិ សម្មា សុខំ ញុំាងមិត្តនិងអាមាត្យឱ្យសុខ ឱ្យឆ្អែត រក្សាមិត្តអាមាត្យឱ្យសុខសប្បាយ

៥- បរិហរតិ សមណព្រាហ្មណេសុ ខន្ធគ្គិកំ ទក្ខិណំ បតិដ្ឋាបេតិ សោវគ្គិកំ សុខវិបាកំ សគ្គសំវត្តនិកំ ដំកល់ទុកនូវទាន មានផលដ៏ខ្ពស់ក្នុងពួកសមណៈព្រាហ្មណ៍ ជាទានឱ្យនូវអារម្មណ៍ដ៏ប្រសើរល្អ មានផលជាសុខ ប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ ។

ម្នាលភិក្ខុទាំងឡាយ អានិសង្ស ៥ យ៉ាងនេះ រមែងក្នុងភោគៈទាំងឡាយ ។

ទានដែលមានផលច្រើន

ការធ្វើទានដែលមានផលច្រើននោះ លុះត្រាតែប្រកបដោយអង្គ ៣ គឺ ទេយ្យធម៌ដែលបានមកដើម្បីធ្វើទាននោះ ជារបស់បានមកប្រកបដោយធម៌ ដោយកម្លាំងញើសឈាមផ្ទាល់ខ្លួនតែម្តង មិនមែនបានដោយការបៀតបៀន កាប់សម្លាប់គេនោះទេ, មានចេតនាបរិសុទ្ធិ គឺប្រកបដោយចេតនា ៣ មានបុព្វចេតនា, មុញ្ចនចេតនា, អបរចេតនា មុនធ្វើ កំពង់ធ្វើ និងធ្វើរួចហើយ ក៏មានចិត្តត្រេកអរ សប្បាយរីករាយចំពោះទង្វើរនោះ, មួយទៀតមានបដិគ្គាហកបរិសុទ្ធិ គឺបានដល់អ្នកដែលអស់នូវរាគៈ ទោសៈ មោហៈឬក៏ជាអ្នកបដិបត្តិដើម្បីកម្ចាត់បង់នូវរាគៈ ទោសៈ មោហៈឬក៏ម្យ៉ាងទៀត ជាបុគ្គលដែលទើបនិងចេញអំពីនិរោធសមាបត្តិផង ។ ហេតុទាំងអស់នេះឯង ធ្វើឱ្យទានរបស់បុគ្គលមាននូវផលានិសង្សច្រើន រាប់មិនបាន ប្រមាណមិនកើត ប្រៀបដូចជាទឹកនៅក្នុងមហាសមុទ្រ មិនអាចរាប់បានថា ប៉ុណ្ណោះ ប៉ុណ្ណោះបានឡើយ គ្រាន់តែយើងអាចដឹងថា ជាគំនរទឹកដ៏ធំតែប៉ុណ្ណោះ ។

ទក្ខិណាសុត្រ

នៅក្នុងបិដកលេខ ៤២ ទំព័រ ១៩៨ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី [***ទក្ខិណាវិសុទ្ធិ ៤ ប្រការ***] *មានសេចក្តីថា ៖*

ម្នាលភិក្ខុទាំងឡាយ ទក្ខិណាវិសុទ្ធិ (សេចក្តីបរិសុទ្ធិនៃទក្ខិណាទាន)នេះមាន ៤ ប្រការ ។

ទក្ខិណាវិសុទ្ធិ ៤ ប្រការ ដូចម្តេចខ្លះ។

១- *អត្ថិ ភិក្ខវេ ទក្ខិណា ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ម្នាលភិក្ខុទាំងឡាយ* ***ទក្ខិណាបរិសុទ្ធិអំពីទាយក មិនបរិសុទ្ធិអំពីបដិគ្គាហក:ក៏មាន ។***

២- *អត្ថិភិក្ខវេ ទក្ខិណា បដិគ្គាហកតោវិសុជ្ឈតិ នោ ទាយកតោ ម្នាលភិក្ខុទាំងឡាយ* ***ទក្ខិណាបរិសុទ្ធិអំពីបដិគ្គាហក: មិនបរិសុទ្ធិអំពីទាយកក៏មាន ។***

៣- *អត្ថិ ភិក្ខវេ ទក្ខិណា នេវ ទាយកតោ វិសុជ្ឈតិ នោ បដិគ្គាហកតោ ម្នាលភិក្ខុទាំងឡាយ* ***ទក្ខិណាមិនបរិសុទ្ធិអំពីទាយក ទាំងមិនបរិសុទ្ធិអំពីបដិគ្គាហក:ក៏មាន ។***

៤- *អត្ថិ ភិក្ខវេ ទក្ខិណា ទាយកតោ ចេវ វិសុជ្ឈតិ*

បដិគ្គាហកគោ ច ម្នាលភិក្ខុទាំងឡាយ **ទក្ខិណាបរិសុទ្ធិអំពីទាយកផង បរិសុទ្ធិអំពីបដិគ្គាហក:ផងក៏មាន** ។

សេចក្តីអធិប្បាយទក្ខិណាវិសុទ្ធិ ៤ ប្រការ

ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណា បរិសុទ្ធិអំពីទាយក មិនបរិសុទ្ធិអំពីបដិគ្គាហក:ដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ **ទាយកក្នុងសាសនានេះ មានសីល មានកល្យាណធម៌ តែបដិគ្គាហក:ជាអ្នកទ្រុស្តសីល មានបាបធម៌** ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា **ទក្ខិណាបរិសុទ្ធិអំពីទាយក មិនបរិសុទ្ធអំពីបដិគ្គាហក:** ។

ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណា បរិសុទ្ធិអំពីបដិគ្គាហក: មិនបរិសុទ្ធិអំពីទាយកដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ **ទាយកក្នុងសាសនានេះ ជាអ្នកទ្រុស្តសីល មានបាបធម៌ តែបដិគ្គាហក: ជាអ្នកមានសីល មានកល្យាណធម៌** ។ ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះ ឈ្មោះថា **ទក្ខិណាបរិសុទ្ធិអំពីបដិគ្គាហក: មិនបរិសុទ្ធិអំពីទាយក** ។

ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណា មិនបរិសុទ្ធិអំពីទាយកទាំង មិនបរិសុទ្ធិអំពីបដិគ្គាក: ដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ **ទាយកក្នុងសាសនានេះ ជាអ្នកទ្រុស្តសីល មានបាបធម៌ ទាំងបដិគ្គាហក:ក៏ជាអ្នកទ្រុស្តសីល មានបាបធម៌ដែរ ។** ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា **ទក្ខិណាមិនបរិសុទ្ធិអំពីទាយក ទាំងមិនបរិសុទ្ធិអំពីបដិគ្គាហក: ។**

ម្នាលភិក្ខុទាំងឡាយ ចុះទក្ខិណាបរិសុទ្ធិអំពីទាយកផង បរិសុទ្ធិអំពីបដិគ្គាក:ផង តើដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ **ទាយកក្នុងសាសនានេះ ជាអ្នកមានសីល មានកល្យាណធម៌ បដិគ្គាហក:ក៏ជាអ្នកមានសីល មានកល្យាណធម៌ដូចគ្នា ។**

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឈ្មោះថា ទក្ខិណាបរិសុទ្ធិអំពីទាយកផង អំពីបដិគ្គាហក:ផង ។

ម្នាលភិក្ខុទាំងឡាយ ទក្ខិណាវិសុទ្ធិមាន ៤ ប្រការប៉ុណ្ណេះឯង ។

អដ្ឋកថា

បទថា ឧក្ខិណាវិសុទ្ធិយោ បានដល់ ហេតុទាំងឡាយនៃសេចក្តីបរិសុទ្ធិរបស់ទក្ខិណា គឺទាន ។

បទថា ធាយកគោ វិសុទ្ធិំ ឈ្លតិ សេចក្តីថា រមែងបរិសុទ្ធិ ដោយសេចក្តីដែលមានផលច្រើន ។

បទថា កល្យាណធម្មោ គឺជាអ្នកមានធម៌ល្អ ។

បទថា បាបធម្មោ គឺជាអ្នកមានធម៌អាក្រក់ ។

ក្នុងបទថា ធាយកគោ វិសុទ្ធិំ ឈ្លតិ នេះគួរពោលដល់ ព្រះវេស្សន្តរមហារាជ ។ បានឮថា ព្រះវេស្សន្តរមហារាជនោះ ឱ្យកូនទាំងពីរ(គឺជាលី និងកណ្ហាជិនា) ដល់ព្រាហ្មណ៍ឈ្មោះ ជូជក ធ្វើឱ្យមហាប្រឋពីញាប់ញ័រ ។

បទថា បដិគ្គាហកគោ វិសុទ្ធិំ ឈ្លតិ នេះគួរពោលដល់អ្នកនេសាទ ដែលរស់នៅក្បែរស្ទឹងកល្យាណី ។ បានឮថា អ្នកនេសាទនោះ បានថ្វាយបិណ្ឌបាតបីដង ដល់ព្រះទីឃសុមនត្ថេរៈ (ត្រា)ដេកនៅលើត្រែមរណៈបានពោលថា បិណ្ឌបាតដែលបានថ្វាយដល់លោកម្ចាស់ ទីឃសុមនត្ថេរៈ (អាច)លើកអាត្មាអញឡើងបាន ។

ក្នុងបទថា នេវ ធាយកគោ នេះ គួរពោលដល់នាយព្រានអ្នករស់នៅក្នុងស្រុកវឌ្ឍនៈ បានឮថា នាយព្រាននោះ កាល

ធ្វើបុណ្យឧទ្ទិសដល់មិត្តមួយនាក់ដែលស្លាប់ទៅ ទើបបានថ្វាយទានដល់បដិគ្គាហក: ដែលទ្រុស្តសីលម្នាក់រហូត ៣ ដង ។ ក្នុងលើកទី ៣ អមនុស្ស(អ្នកស្លាប់ទៅកើតជាប្រេត)ស្រែកថា បដិគ្គាហក:ទ្រុស្តសីល ប្លន់យើងហើយ ដូច្នេះ ។ ទក្ខិណាដែលអាចសម្រេចដល់អ្នកស្លាប់បាននោះ គឺត្រូវតែជាទក្ខិណាដែលថ្វាយដល់ភិក្ខុអ្នកមានសីល ។

ក្នុងបទថា ទាយកោ តោ ចេវ បដិគ្គាហកោ ច វិសុទ្ធិឆ្លងនេះ បណ្ឌិតគួរពោលដល់អសទិសទាន ។

សេចក្តីបន្ថែមនៃទក្ខិណាទាន

ក្នុងបរមត្ថជោតិក ខុទ្ទកអដ្ឋកថា

បទថា លភាមសេ ប្រែថាបាន ។ ពួកប្រេតពោលអាងសម្បត្តិដែលខ្លួនបានក្នុងខណៈនោះ ។

បេតានញ្ហិ អត្តនោ អនុមោទនេន, ទាយកានំ ឧទ្ទេសេន, ទក្ខិណេយ្យសម្បទាយ ចាតិ តីហិ អង្គេហិ ទក្ខិណា សមិជ្ឈតិ, តទ្ធេ ផលនិព្ពត្តិកា ហោតិ ។ តត្ថ ទាយកា វិសេសហេតុ ។ តេនាហំសុ "យេសំ ហេតុ លភាមសេ"តិ ។ ពិតមែន ទក្ខិណា

រមែងសម្រេចផលគឺ ឱ្យកើតផលក្នុងខណៈនោះបាន ក៏ដោយអង្គ ៣ គឺដោយការអនុមោទនាដោយខ្លួនឯងរបស់ប្រេតទាំងឡាយ ១ ដោយការឧទ្ទិសរបស់ទាយកទាំងឡាយ ១ ដោយការដល់ព្រមនៃទក្ខិណេយ្យបុគ្គល ១ ។

ក្នុងអង្គទាំង ៣ នោះ ទាយកទាំងឡាយជាហេតុពិសេស ដោយហេតុនោះ ប្រេតទាំងឡាយទើបពោលថា **យេសំ ហេតុ លភាមសេ** រមែងបានព្រោះហេតុនៃញាតិ (ដែលជាទាយក) ពួកណា ។

អម្ហាកញ្ច កតា បូជាតិ "ឥទំ វោ ញាតីនំ ហោតូ"តិ ឯវំ ឥមំ ធានំ ឧទ្ទិសន្តេហិ អម្ហាកញ្ច បូជា កតា ។

បទថា អម្ហាកញ្ច កតា បូជា សេចក្តីថា និងញាតិទាំងឡាយ ដែលឧទ្ទិសទាននេះយ៉ាងនេះថា "សូមទាននេះ ចូរមានដល់ញាតិទាំងឡាយរបស់យើង"ដូច្នេះ ឈ្មោះថា ធ្វើការបូជាពួកយើងហើយ ។

វុត្តំ ឥត្ថ ខុប្បថាសិកវត្ថាសបរេតត្ថបដិវិនិជ្ឈាមឥណ្ឌិ-កាទិភេទភិន្នេ ឋានេ ឧបកប្បតីតិ វុត្តំ យថា កហាបណាំ

ទេន្តោ "កហាបណសោ ទេតី"តិ លោកេ វុច្ចតិ ។ ឥមស្មិញ្ច អត្ថវិកប្បេ ឧបកប្បតីតិ ចាតុភវតិ, និព្ពត្តតីតិ វុត្តំ ហោតិ ។

ទក្ខិណាដែលសម្រេចផលក្នុងហាន:នោះ ដែលផ្សែងដោយប្រភេទមាន ***ខុប្បជាសិកប្រេត វន្តាសប្រេត បរទត្តូបជីវិកប្រេត និវនិជ្ឈាមតណ្ហិកប្រេត*** *ជាដើម ក៏ត្រាស់ថា រមែងសម្រេចផលដោយហាន:ដូចអ្នកឱ្យកហាបណ:ក្នុងលោក គេក៏ហៅថា អ្នកនោះឱ្យកហាបណ: ដូច្នោះ ។ តែក្នុងអត្ថវិកប្បនេះ បទថា* ***ឧបកប្បតិ*** *បានដល់ ប្រាកដផល លោកអធិប្បាយថា កើតផល ។*

បុណ្យទក្ខិណានុប្បទាន

បុណ្យទក្ខិណានុប្បទាន *ជាបុណ្យមួយធ្វើឡើង ដើម្បីឧទ្ទិសកុសលជូនដល់អ្នកដែលចែកហានទៅ ។ តាមធម្មតា មនុស្សណាម្នាក់មានចំណង់ជូនវត្ថុដល់អ្នកណាម្នាក់ គេអាចជូនដោយកាយ ឬដោយវាចា, នេះជូនចំពោះអ្នកនៅរស់ ។ ប៉ុន្តែចំពោះអ្នកដែលស្លាប់ទៅពុំអាចជូនបែបនេះបានឡើយ គឺត្រូវធ្វើបុណ្យកុសលមានធ្វើទាន សមាទានសីលជាដើម ហើយតាំងចិត្តជូនទៅ ដែលហៅថា* ***បុណ្យទក្ខិណានុប្បទាន*** *នេះឯង ។ បុណ្យទក្ខិណានុប្ប-*

ទាននេះ ត្រូវធ្វើឱ្យត្រឹមត្រូវ ទើបសម្រេចផលដល់អ្នកដែលចែកឋានទៅដោយអង្គ ៣ ប្រការគឺ ៖

១-ត្រូវធ្វើបុណ្យកុសល មានការធ្វើទាន រក្សាសីល ភាវនា ជាដើមជាពិសេសត្រូវធ្វើទានចំពោះអ្នកមានសីលដែលក្នុងបាលីថា **សង្ឃម្ហិ សុបតិដ្ឋិតា** ប្រែថា **ទានបានដំកល់ល្អហើយក្នុងព្រះសង្ឃ** ។

២-ឧទ្ទិសេន ប្រែថា ដោយការតាំងចិត្តជូនកុសលទៅ ។ បានសេចក្តីថាត្រូវតាំងចិត្តឧទ្ទិសកុសលដែលបានធ្វើនោះជូនដល់អ្នកដែលចែកស្ថានទៅទើបអ្នកស្លាប់មានសិទ្ធិទទួល ។ បើពុំបានឧទ្ទិសជូនទៅទេ អ្នកស្លាប់គ្មានសិទ្ធិទទួលឡើយ ប្រៀបដូចជនណាម្នាក់ពុំហ៊ានយកវត្ថុដែលគេ ពុំបានឱ្យដោយកាយឬដោយវាចាបើយកទុកជាបទលួច ។ ការឧទ្ទិសកុសលគឺឧទ្ទិសតាមមនោទ្វារគឺផ្ទៀងចិត្តទុកជាបានការ ។ បើបញ្ចេញវាចាដូចជាធម៌វេរវែងមិនទៀតក៏រឹតតែល្អ មានអ្នកខ្លះសរសេរឈ្មោះអ្នកស្លាប់ ព្រោះខ្លាចភ្លេចនឹកពុំអស់ ។

៣-អនុមោទនេន គឺអ្នកស្លាប់ដែលបានទៅកើតជាអ្វីមួយ

នោះអាចទទួលត្រេកអរបានផង ។ ក្នុងតិរោកុឌ្ឌសូត្របញ្ជាក់ថា សត្វដែលអាចទទួលផលដែលញាតិមិត្តឧទ្ទិសទៅ ឱ្យភាគច្រើនបានដល់ប្រេត ៣ ពួក មានប្រេតឈ្មោះ **បរទត្តូបជីវិកប្រេត** ប្រែថា **ប្រេតរស់នៅដោយសារអំណោយផល ដែលញាតិមិត្តឧទ្ទិសទៅឱ្យជាដើម** នេះជាអង្គ ៣ យ៉ាង នៃការធ្វើបុណ្យទក្ខិណានុប្បទាន ។ មានទំនៀមទម្លាប់ក្រៅពុទ្ធសាសនាមួយ គឺការសែនព្រេនដោយគេរៀបចំបាយ ទឹក នំ ចំណី ហើយនិយាយអញ្ជើញអ្នកដែលចែកស្ថានទៅឱ្យមកសេពសោយ ។ តាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ការសែនបែបនេះ អ្នកដែលស្លាប់ទៅពុំអាចមកបរិភោគភោជនាហារនោះបានឡើយ ព្រោះអ្នកស្លាប់ទៅបានទៅកើតជាអ្វីមួយមានអាហារផ្សេង ៗគ្នា ប៉ុន្តែបានបុណ្យជល់អ្នកធ្វើខ្លះ ត្រង់នឹកគុណជល់អ្នកស្លាប់ ។

ចំណែកព្រះសង្ឃសូត្រធម៌ធម្មសង្វេគ ដែលពុទ្ធបរិស័ទនិយមហៅថា ធម៌បង្សុកូលនោះ គ្រាន់តែជាកិច្ចអនុមោទនាទៅលើអង្គទាំង ៣ នៃទក្ខិណានុប្បទាននោះប៉ុណ្ណោះ ។ តាមពិត ការសូត្រធម៌ធម្មសំវេគ ដែលហៅថា ធម៌បង្សុកូលនោះ មានគោល

បំណងពិសេសឱ្យអ្នកនៅរស់ដែលជាសមាជិកគ្រួសាររបស់អ្នកស្លាប់ ពិចារណាឱ្យឃើញភាពពុំទៀងនៃជីវិត ដូចព្រះសង្ឃសូត្រធម៌ថា**អនិច្ចា វត សង្ខារ** ។ល។ ប្រែថា សង្ខារទាំងឡាយពុំទៀង មែនពិត មានកិរិយាកើតឡើងហើយ វិនាសទៅវិញជាធម្មតា លុះតែរលត់នូវសង្ខារទាំងឡាយនោះហើយ ទើបបាននូវសេចក្តីសុខគ្រប់យ៉ាង ។ សង្ខារក្នុងធម៌នេះ សំដៅយកខន្ធ ៥ របស់មនុស្សសត្វ ។ អ្នកដែលបានធ្វើបុណ្យឧទ្ទិសទៅនេះរមែងមានចិត្តជ្រះថ្លា នៅពេលធ្វើបុណ្យហើយបានបុណ្យ ម្យ៉ាងទៀត គឺត្រង់នឹកដល់គុណអ្នកដែលចែកស្លាន ។ ក្នុង"ខ"ទី៥នៃធម៌ដែលបុត្តធីតាប្រុសស្ត្រីត្រូវតបគុណចំពោះមាតាបិតាថា **បន្ទាប់ពីមាតាបិតាអនិច្ចកម្មទៅបុត្រធីតាប្រុសស្រី ត្រូវធ្វើបុណ្យទក្ខិណានុប្បទានឧទ្ទិសកុសលជូនគាត់ ។** ចំណែកសមាជិកគ្រួសារដែលស្លាប់ទៅក្រៅពីមាតាបិតា ក៏ក្រុមគ្រួសារត្រូវឧទ្ទិសកុសលជូនទៅដូចគ្នា ។ ការឧទ្ទិសកុសលនេះ មិនត្រឹមតែញាតិមិត្តរបស់ខ្លួន ទើបឧទ្ទិសកុសលបាននោះទេ តែអាចផ្សាយចិត្តឱ្យទូលាយឧទ្ទិសជូនទៅគ្រប់សព្វសត្វទាំងអស់ ដូចការសូត្រធម៌ **យំ កិញ្ចិ** កុសល-

កម្មំ ។ ការឧទ្ទិសកុសលនេះក្នុងឧត្តមគតិថា ទោះបីក្រុមគ្រួសារស្លាប់ទៅហើយ ក៏នៅតែនឹកឃើញគុណពុំភ្លេច ហើយជាការជួយសង្គ្រោះក្រែងអ្នកស្លាប់ទៅនោះ ទទួលរងទុក្ខវេទនាក្នុងភពណាមួយ ជាការឧទ្ទិសជួយរំលែកទុក្ខដែលចាត់ទុកថា ជាការតបគុណចំពោះអ្នកស្លាប់ ។

ការឲទានសូត្រ

នៅក្នុងបិដកលេខ ៤៤, ទំព័រ ៨០ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី **(កាលទាន ៥ យ៉ាង)** មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ កាលទាននេះមាន ៥ យ៉ាង ។ **៥ យ៉ាង ដូចម្តេចខ្លះ**

១- អាគន្តុកស្ស ទានំ ទេតិ **គឺឲ្យទានដល់អ្នកមកថ្មី**

២- គមិកស្ស ទានំ ទេតិ **ឲ្យទានដល់អ្នកមានដំណើរ**

៣- គិលានស្ស ទានំ ទេតិ **ឲ្យទានដល់អ្នកមានជម្ងឺ**

៤- ទុព្ភិក្ខេ ទានំ ទេតិ **ឲ្យទានក្នុងពេលអត់បាយ**

៥- យានិ តានិ នវសស្សានិ នវផលានិ តានិ បឋមំ សីលវន្តេសុ បតិដ្ឋាបេតិ **បានជម្ពល់ស្រូវថ្មី ផ្លែឈើដំបូងដល់**

បុគ្គលមានសីលទាំងឆ្កាយជាដំបូង ។

ម្នាលភិក្ខុទាំងឡាយ នេះឯងជាកាលទាន ៥ យ៉ាង ។

កាលេ ទទន្តិ សប្បញ្ញា វទញ្ញូ វីតមច្ឆរា
កាលេន ទិន្នំ អរិយេសុ ឧជុភូតេសុ តាទិសុ
វិប្បសន្នមនា តស្ស វិប្បលា ហោតិ ទក្ខិណា ។

ពួកជនមានបញ្ញា ដឹងភាសិតរបស់អ្នកប្រាជ្ញ មានសេចក្តីកំណាញ់ប្រាសចេញហើយ មានចិត្តជ្រះថ្លាហើយ រមែងឱ្យទានក្នុងកាលគួរទានដែលបុគ្គលឱ្យតាមកាលគួរ ចំពោះព្រះអរិយបុគ្គលទាំងឡាយ ដែលជាបុគ្គលមានកាយនិងចិត្តប្រកបដោយតាទិគុណ[1] ទក្ខិណាទានរបស់បុគ្គលនោះ ជាទានមានផលបរិបូរណ៌ ។

យេ តត្ថ អនុមោទន្តិ វេយ្យាវច្ចំ ករោន្តិ វា
ន តេន ទក្ខិណា ខុទ្ទា តេបិ បុញ្ញស្ស ភាគិនោ ។

ពួកជនណា អនុមោទនា ឬធ្វើសេចក្តីខ្វល់ខ្វាល់ក្នុងទក្ខិណាទាននោះ ទក្ខិណាទានរបស់អ្នកទាំងនោះនិងបាន ឈ្មោះថា ជា

---

១. គុណគឺព្រះហទ័យមាំទាំ មិនញាប់ញ័រដោយលោកធម៌ ។

ទានថយថោក ព្រោះតែអនុមោនា ឬធ្វើការខ្វល់ខ្វាល់នោះក៏ទេ ពួកជនទាំងនោះ ជាអ្នកបានចំណែកបុណ្យដែរ ។

តស្មា ឧភេ អប្បដិវាណចិត្តោ យត្ត ឥច្ឆំ មហាបួលំ
បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ ផាណិនន្តិ ។

ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យហើយដល់បុគ្គលណា ជាទានមានផលច្រើន បុគ្គលមានចិត្តមិនបានរួញរា គប្បីឱ្យទានចំពោះបុគ្គលនោះ ព្រោះថា បុណ្យទាំងឡាយ រមែងជាទីពឹងនៃពួកសត្វក្នុងលោកខាងមុខ ។

អដ្ឋកថា

បទថា កាលផានានិ គឺទានដែលគួរ ទានដែលមកដល់ហើយ អធិប្បាយថា ទានដ៏សមគួរ ។

បទថា វនសណ្ឌានិ គឺស្រុកសំណាប់ល្អ ។

បទថា វនផលានិ បានដល់ ផ្លែឈើដែលល្អចេញគ្រាដំបូងអំពីសួន ។

បទថា បឋមំ សីលវន្តេសុ បតិដ្ឋាបេតិ សេចក្តីថា គេថ្វាយដល់អ្នកមានសីលមុនហើយ ខ្លួនក៏បរិភោគខាងក្រោយ ។

បទថា វេទញ្ញូ គឺជាអ្នកដឹងនូវកាសិត ។

បទថា កាលេន ទន្នំ បានដល់ ទានដែលគេឱ្យដ៏សមគួរតាមកាល ។

បទថា អនុមោទន្តិ បានដល់ ជនដែលឈរអនុមោទនាក្នុងទីមួយដ៏សមគួរ ។

បទថា វេយ្យាវច្ចំ បានដល់ ធ្វើការដែលជាការងារជួយខ្វាយខ្វល់ផ្សេងកាយ ។

បទថា យត្ត ទិន្នំ មហប្ផលំ បានដល់ គប្បីឱ្យទានក្នុងបុគ្គលណា ដែលជាទានឱ្យហើយមានផលច្រើន ។

រឿងអង្គុរទេវបុត្រ

ព្រះសាស្តា កាលទ្រង់គង់នៅលើបណ្ឌុតម្ពលសិលា ទ្រង់បានប្រារព្ធចំពោះអង្គុរទេពបុត្រ ត្រាស់ព្រះធម្មទេសនា នេះថា តិណាទោសានិ ខេត្តានិ ជាដើម ។

[ឱ្យទានដោយជ្រើសរើសព្រះសុគតទ្រង់សរសើរ]

សមពិត ដូចពាក្យដែលលោកបានប្រារព្ធចំពោះ **ឥន្ទក**-

ទេវបុត្ត ពោលទុកក្នុងរឿងនោះ ដូច្នេះថា បានឮថា ឥន្ទកទេវបុត្តនោះ ញុំាងភិក្ខាមួយវែកដែលគេនាំមកដើម្បីខ្លួន បានប្រគេនហើយដល់ព្រះអនុរុទ្ធត្ថេរៈ ដែលនិមន្តទៅបិណ្ឌបាត្រនៅក្នុងស្រុក ។ បុណ្យរបស់ឥន្ទកទេវបុត្តនោះ មានផលច្រើនជាងទានដែលអង្កុរ-ទេវបុត្ត ធ្វើរបៀបដាំដោយចង្រ្កានប្រមាណ ១២ យោជន៍ ប្រគេនហើយអស់សែនឆ្នាំ ព្រោះហេតុនោះ ឥន្ទកទេវបុត្តទើបពោលយ៉ាងនោះ ។ កាលឥន្ទកទេវបុត្តពោលយ៉ាងនេះហើយ ព្រះសាស្តាទើបត្រាស់ថា **ម្នាលអង្កុរ** ឈ្មោះថា ឱ្យទានដោយការជ្រើសរើសឱ្យរមែងគួរ,ទាន(របស់ឥន្ទកទេវបុត្ត)នោះជាទានមានផលច្រើន ដូចជាពូជដែលសាបព្រោះល្អហើយក្នុងស្រែល្អ តែលោកមិនធ្វើយ៉ាងនោះទ្បើយព្រោះហេតុនោះទានរបស់លោកទើបមិនមានផលច្រើន កាលព្រះសាស្តាទ្រង់បានសម្តែងសេចក្តីនេះហើយទើបទ្រង់ត្រាស់ថា ៖

បុគ្គលឱ្យទានគួរជ្រើសរើសឱ្យ ក្នុងខេត្តដែលខ្លួនឱ្យហើយនិងមានផលច្រើន ។ ទានដែលឱ្យក្នុងលោកអ្នកដែលជាទក្ខិណេយ្យបុគ្គលក្នុងលោកនេះជាទានមានផលច្រើន ដូចពូជដែលសាបព្រោះក្នុងស្រែដែលល្អ ដូច្នោះ ។

កាលទ្រង់សម្តែងធម៌នេះឱ្យក្រលែងទៅ ទើបទ្រង់ត្រាស់ព្រះគាថា ថា ៖

តិណាទោសានិ ខេត្តានិ រាគទោសា អយំ បជា
តស្មា ហិ វីតរាគេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះមានរាគៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យ ហើយដល់អ្នកមានរាគៈអស់ហើយ រមែងមានផលច្រើន ។

តិណាទោសានិ ខេត្តានិ ទោសទោសា អយំ បជា
តស្មា ហិ វីតទោសេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះមានទោសៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យ ហើយដល់អ្នកមានទោសៈអស់ហើយរមែងមានផលច្រើន ។

តិណាទោសានិ ខេត្តានិ មោហាទោសា អយំ បជា
តស្មា ហិ វីតមោហេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះមានមោហៈជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យ ហើយដល់

អ្នកមានមោហៈអស់ហើយ រមែងជាទានមានផលច្រើន ។

តិណាទោសានិ ខេត្តានិ ឥច្ចាទោសា អយំ បជា
តស្មា ហិ វីតឥច្ឆេសុ ទិន្នំ ហោតិ មហប្ផលំ ។

ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះមានសេចក្តីប្រាថ្នាជាទោស ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យហើយ ដល់អ្នកមានសេចក្តីប្រាថ្នាអស់ហើយ រមែងជាទានមានផលច្រើន ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា តិណាទោសានិ សេចក្តីថា សេចក្តីចម្រើនរបស់ស្មៅទាំងឡាយ មានស្រូវមីយេ (ស្រូវង៉ែ) ជាដើម កាលវាដុះឡើង រមែងប្រទុស្តភាយដល់ស្រែដែលជាបុព្វណ្ណជាតិ និងអបរណ្ណជាតិ ព្រោះហេតុនោះ ស្រែពួកនោះ ទើបមិនមានផលច្រើនបាន, រាគៈកាលកើតឡើងក្នុងចិត្តនៃសត្វលោក រមែងប្រទុស្តភាយដល់សត្វទាំងឡាយ ព្រោះហេតុនោះ ទានដែលថ្វាយហើយដល់បុគ្គលអ្នកមានរាគៈប្រទុស្តភាយពួកនោះ ទើបជាទានមិនមានផលច្រើន, ចំណែកទានដែលថ្វាយហើយ ដល់ព្រះខីណាស្រពទាំងឡាយ ជាទានមានផលច្រើន, ព្រោះហេតុនោះ

ព្រះមានព្រះភាគទើបត្រាស់ថា ស្រែទាំងឡាយមានស្មៅជាទោស ពួកសត្វលោកនេះ មានរាគៈជាទោស, ព្រោះហេតុនេះ ទាន ដែលថ្វាយហើយដល់លោកអ្នកអស់រាគៈទើបជាទានមានផលច្រើន ។

សូម្បីក្នុងគាថាជទៃក៏នយនេះ

ក្នុងកាលចប់ទេសនាអង្គុរទេវបុត្ត និងឥន្ទកទេវបុត្ត ក៏តាំងនៅក្នុងសោតាបត្តិផល ទេសនាមានប្រយោជន៍សូម្បីដល់ពួកទេវបុត្ត ដែលប្រជុំគ្នាហើយ ដូច្នេះឯង ។

សេក្ខបរិហានិយវគ្គ ទានសូត្រ

នៅក្នុងបិដកលេខ ៤៦ ទំព័រ ១១៤ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី [**អង្គនៃទក្ខិណាទាន ៦ ប្រការ**] មានសេចក្តីថា

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ឧបាសិកាជាមាតាព្រះនន្ទ អ្នកនៅក្នុងក្រុងវេឡុកណ្ឌកៈដម្កល់ទានប្រកបដោយអង្គ ៦ ចំពោះភិក្ខុសង្ឃ មានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាប្រធាន ។ ព្រះដ៏មានព្រះភាគបានទតឃើញនន្ទមាតាឧបាសិកាអ្នកនៅក្នុងក្រុងវេឡុកណ្ឌកៈ ដោយទិព្វចក្ខុដ៏បរិសុទ្ធិ

កន្ធង់ចក្ខុរបស់មនុស្សធម្មតា ដែលកំពុងជម្ពល់ទានប្រកបដោយអង្គ ៦ចំពោះភិក្ខុសង្ឃ មានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាប្រធាន លុះទតឃើញហើយ ក៏ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ នន្ទមាតាឧបាសិកា អ្នកនៅក្នុងវេឡុកណ្ឌកៈនោះ កំពុងជម្ពល់ទានប្រកបដោយអង្គ ៦ ចំពោះភិក្ខុសង្ឃ មានព្រះសារីបុត្រ និងព្រះមោគ្គល្លានជាប្រធាន ។ ម្នាលភិក្ខុទាំងឡាយ ចុះទានប្រកបដោយអង្គ ៦ តើដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ អង្គរបស់ទាយក មាន ៣,អង្គរបស់បដិគ្គាហកៈទាំងឡាយមាន ៣ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ៖

១- ទាយកោ បុព្វេវ ទានា សុមនោ ហោតិ ទាយក ជាអ្នកមានចិត្តត្រេកអរមុនអំពីកាលឱ្យ

២- ទទំ ចិត្តំ បសាទេតិ កំពុងតែឱ្យធ្វើចិត្តឱ្យជ្រះថ្លា

៣- ទត្វា អត្តមនោ ហោតិ លុះឱ្យហើយ មានចិត្តរីករាយ ។

នេះជាអង្គរបស់ទាយកមាន ៣ ។

អង្គរបស់បដិគ្គាហក:ឧរំឯឡ្យាយមាន៣តើដូចម្តេចម្ល

ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ ពួកបដិគ្គាហក ៖

១-បដិគ្គាហកាវិតរាគាវា ហោន្តិ រាគវិនយាយ វា បដិបន្នា *ជាអ្នកប្រាសចាករាគៈ ឬប្រតិបត្តិដើម្បីបន្ទោបង់រាគៈ*

២-វិតទោសាវា ហោន្តិ ទោសវិនយាយ វា បដិបន្នា *ប្រាសចាកទោសៈឬប្រតិបត្តិដើម្បីបន្ទោបង់ទោសៈ*

៣-វិតមោហា វា ហោន្តិ មោហវិនយាយវា បដិបន្នា *ប្រាសចាកមោហៈ ឬប្រតិបត្តិដើម្បីបន្ទោបង់មោហៈ ។*

នេះជាអង្គរបស់បដិគ្គាហក:មាន ៣ ដូច្នេះ ។

ម្នាលភិក្ខុទាំងឡាយ យ៉ាងនេះឯង ជាទានប្រកបដោយអង្គ ៦ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយកំណត់នូវប្រមាណនៃបុណ្យរបស់ទាន ដែលប្រកបដោយអង្គ ៦ យ៉ាងនេះថា ***គំនរបុណ្យ គំនរកុសល ជាគ្រឿងនាំមកនូវសេចក្តីសុខ ឱ្យនូវអារម្មណ៍ដ៏ល្អមានសុខជាវិបាកប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នា ត្រេកអរគាប់ចិត្ត ជាប្រយោជន៍ជាសុខបានឡើយ ។*** ដោយពិតនោះថា

រាប់មិនបានប្រមាណ មិនកើត គ្រាន់តែរាប់ថា ជាគំនរបុណ្យច្រើនប៉ុណ្ណោះបាន ។

ម្នាលភិក្ខុទាំងឡាយ **ដូចបុគ្គលដែលមិនងាយកំណត់**ប្រមាណនូវទឹកក្នុងមហាសមុទ្រថា ទឹកប៉ុណ្ណោះអាឡ្ហកក្តី ទឹកប៉ុណ្ណោះរយអាឡ្ហកក្តី ទឹកប៉ុណ្ណោះពាន់អាឡ្ហកក្តី ទឹកប៉ុណ្ណោះសែនអាឡ្ហកក្តី បានឡើយ ។ ដោយពិតនោះថា រាប់មិនបាន ប្រមាណមិនកើត គ្រាន់តែរាប់ថា គំនរទឹកដ៏ច្រើនប៉ុណ្ណោះបានយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលមិនងាយកំណត់នូវបុណ្យនៃទាន ប្រកបដោយអង្គ ៦ យ៉ាង យ៉ាងនេះថា គំនរបុណ្យ គំនរកុសល ជាគ្រឿងនាំមកនូវសុខ ឱនូវអារម្មណ៍ដ៏ល្អមានសុខជាវិបាកប្រព្រឹត្តទៅដើម្បីស្ថានសួគ៌ប៉ុណ្ណោះ ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាត្រេកអរគាប់ចិត្ត ជាប្រយោជន៍ ជាសុខបានឡើយ ។ ដោយពិតនោះថា រាប់មិនបានប្រមាណមិនកើត គ្រាន់តែរាប់ថា ជាគំនរបុណ្យដ៏ច្រើនប៉ុណ្ណោះបាន ក៏យ៉ាងនោះដែរ ។

បុព្វេ ទានា សុមនោ ទធំ ចិត្តំ បសាទយេ

ទត្វា អត្តមនោ ហោតិ ឯសា យញ្ញស្ស សម្បទា ។

ទាយកមានចិត្តរីករាយ ក្នុងវេលាមុនអំពីកាលឱ្យកំពុងឱ្យធ្វើចិត្តឱ្យជ្រះថ្លា លុះឱ្យហើយក៏មានចិត្តត្រេកអរ (តាមក្រោយ) នេះជាសេចក្តីបរិបូណ៌រៀបរាប់ទាន ។

វីតរាគោ វីតទោសោ វីតមោហោ អនាសវោ
ខេត្តំ យញ្ញស្ស សម្បន្នំ សញ្ញតា ព្រហ្មចារិនោ ។

បុគ្គលអ្នកប្រាសចាករាគៈ ប្រាសចាកទោសៈ ប្រាសចាកមោហៈ មិនមានអាសវៈ ជាព្រហ្មចារី មានសេចក្តីសង្រួមឈ្មោះថា ជាខេត្តនៃទានដ៏បរិបូណ៌ (ដោយគុណ) ។

សយំ អាចរយិត្វាន ទត្វា សកេហិ បាណិភិ
អត្តនោបរតោចេសោយញ្ញោ ហោតិ មហប្ផលោកេ ។

បុគ្គលទ្រុស្តទ្រាយដោយខ្លួនឯង ឱ្យទានដោយដៃរបស់ខ្លួន ។ ទានទុំៈជាទានមានផលច្រើនព្រោះខ្លួនឯង ព្រោះបុគ្គលជទៃផង ។

ឯវំ យជិត្វា មេធាវី សទ្ធោ មុត្តេន ចេតសា
អព្យាបជ្ឈំ សុខំ លោកំ បណ្ឌិតោ ឧបបជ្ជតិ ។

អ្នកប្រាជ្ញ ជាបណ្ឌិត អ្នកមានសទ្ធា មានចិត្តផុតស្រឡះ (ចាកសេចក្តីកំណាញ់) លុះឱ្យទានយ៉ាងនេះហើយ ក៏រមែងទៅកើតក្នុងទេវលោកជាសុខ ឥតមានទុក្ខ ។

អដ្ឋកថា

បទថា ឆឡង្គសមន្នាគតំ សេចក្តីថា ប្រកបទៅដោយអង្គនៃគុណ ៦ ប្រការ ។

បទថា បុព្វេ ទានា សុមនោ សេចក្តីថា ជាអ្នកដល់ព្រមហើយដោយសោមនស្សតាំងអំពីមួយខែថា អាត្មាអញនឹងឱ្យទាន ។ អធិប្បាយថា បុព្វចេតនា ក្នុងពាក្យថា បុព្វេ ទានា សុមនោ នេះ រមែងមានដល់ទាយកចាប់ដើម តាំងអំពីធ្វើស្រែដោយគិតថា អាត្មាអញនឹងឱ្យទាន ។

ចំណែក **មុញ្ចនចេតនា** (សេចក្តីតាំងចិត្តលះ)ដែលព្រះដ៏មានព្រះភាគត្រាស់ទុកយ៉ាងនេះថា ទាយកកំពុងរមែងញុំាងចិត្តឱ្យជ្រះថ្លា រមែងបានក្នុងពេលខ្លួនឱ្យទាននុ៎ះឯង ។ ចំណែកអបរាបរចេតនានេះថា លុះឱ្យទានរួចហើយ ក៏រមែងមានចិត្តត្រេកអរដូច្នេះរមែងបានដល់ទាយកអ្នកនឹករលឹកតាមជាបន្តបន្ទាប់មក ។

បទថា វិតរាគា បានដល់ ព្រះខីណាស្រពតាំងឡាយដែលមានរាគៈទៅប្រាសហើយ ។

បទថា រាគវិនយាយ វា បដិបន្នា មានសេចក្តីថា ប្រតិប-

ត្តិនូវបដិបទាដែលជាគ្រឿងកម្ចាត់បង់នូវរាគៈ (ឱ្យចេញអំពីសន្តានចិត្ត) ។

ក៏ទេសនានេះ សំដែងសំដៅយកបដិគ្គាហកៈយ៉ាងខ្ពង់ខ្ពស់ ។ ក៏ទក្ខិណាដែលឱ្យដល់ព្រះខីណាស្រពន់ឆ្ងាយ តែឱ្យសូម្បីដល់ព្រះអនាគាមី ព្រះសកទាគាមី នឹងព្រះសោតាបន្នទាំងឆ្ងាយដោយហោចទៅសូម្បីដល់សាមណេរអ្នកកាន់កណ្ឌៈ ដែលបួសនៅក្នុងថ្ងៃនោះទក្ខិណាទានដែលឱ្យហើយក៏រមែងឈ្មោះថាប្រកបដោយអង្គ ៦ ដូចគ្នា ដែរ ។ ព្រោះថា សូម្បីសាមណេរនោះក៏បួសដើម្បីសោតាបត្តិមគ្គដូចគ្នា ។

ដីកាពន្យល់

បទថា បុព្វេ ទានា មានសេចក្តីថា ក្នុងពេលមុនអំពីមុញ្ចនចេតនា គឺចាប់ផ្តើមអំពីការចាត់ចែងឧបករណ៍នៃទាន ។

បទថា សុមនោ មានសេចក្តីថា គប្បីជាអ្នកដល់នូវសោមនស្សថា អាត្មាអញនឹងកប់នូវកំណប់ទ្រព្យដែលជាហេតុនៃសម្បត្តិមានប្រក្រតីជាប់តាមខ្លួនទៅបាន ។

បាទគាថាថា ទទំ ចិត្តំ បសាទយេ មានសេចក្តីថា ទាយក

កំពុងឱ្យ ដាក់នូវទេយ្យធម៌ក្នុងដៃនៃទក្ខិណេយ្យបុគ្គលគប្បីធ្វើចិត្ត របស់ខ្លួនឱ្យជ្រះថ្លាថា អាត្មាអញកំពុងតែធ្វើនូវការកាន់យកខ្លឹម សារអំពីទ្រព្យដែលមិនមានខ្លឹមសារដូច្នេះ ។

បាទគាថាថា **ទត្វា អត្តមនោ ហោតិ** *មានសេចក្តីថា ទាយកបរិច្ចាគទេយ្យធ៌ដល់ទក្ខិណេយ្យបុគ្គលទាំងឡាយ ហើយ ជាអ្នកមានចិត្តត្រេកអរព្រឹកឯសប្បាយគ្មើតបីតិ សោមនស្ស ថា* **ទាន** *ដែលឈ្មោះថា បណ្ឌិតបញ្ញត្តិទុកហើយ អាត្មាអញក៏បាន ដម្កល់ទុកហើយ ឱហ្ន៎! ទានរបស់អញសម្រេចប្រយោជន៍ដោយ ល្អហើយហ្ន៎ ។*

បទថា **ឯសា** *មានសេចក្តីថា សេចក្តីបរិបូណ៌នៃចេតនាទាំង ៣ យ៉ាង ដែលទៅតាមនូវការជឿកម្ម នឹងផលដែលសោមនស្ស កាន់កាប់នោះ គឺ បុព្វចេតនា មុញ្ចនចេតនា អបរាបរចេតនានេះ ឯណា សេចក្តីបរិបូណ៌នៃចេតនានេះ ។*

មង្គលត្ថទីបនី

បទវិគ្គហៈថា ទទំ ចិត្តំ បសាទយេតិ ទទន្តោ ទេយ្យធម្មំ ទក្ខិណេយ្យស្ស ហត្ថេ បដិដ្ឋាបេន្តោ អសារតោ ធនតោ សារាធានំ ករោមិ ។

បុគ្គលមានចេតនាកាលញុំាងទេយ្យធម៌ ឱ្យតម្កល់នៅក្នុងដៃខាងស្តាំថា អញនឹងធ្វើនូវទ្រព្យដែលមិនមានខ្លឹមឱ្យទៅជាទ្រព្យមានខ្លឹម ឈ្មោះថា ឧទំ ចិត្តំ បសាទយេ គឺញុំាងចិត្តឱ្យជ្រះថ្លា ។

ឧត្វា អត្តមនោ ហោតីតិ ឧក្ខិណោយ្យានំ ទេយ្យធម្មំ បរិច្ចជិត្វា បណ្ឌិតប្បញ្ញត្តំ នាម មយា អនុវដ្ដិតំ អហោ សាធុ សុដ្ឋិតិ អត្តមនោ បមុទិតោ បីតិសោមនស្សជាតោ ហោតិ ។

បុគ្គលលះបង់នូវទេយ្យធម៌ ដល់បដិគ្គាហក:បុគ្គលជាអ្នកមានចិត្តត្រេកអរផង មានចិត្តរីករាយផង ជាអ្នកមានបីតិនឹងសោមនស្សកើតឡើងដោយគិតថា ទាននេះគឺអញបាន តម្កល់ល្អហើយ ឈ្មោះថា គឺបណ្ឌិតលោកបញ្ញត្តិហើយថា ជាទានញុំាងប្រយោជន៍ឱ្យសម្រេចដោយប្រពៃ ឈ្មោះថា ឧត្វា អត្តមនោ ហោតិ គឺឱ្យរួចហើយ មានចិត្តជ្រះថ្លាថែមទាងក្រោយទៀត ។

ទនវោបសូត្រ

នៅក្នុងបិដកលេខ ២៥ ទំព័រ ៨៤ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី [**ចំរើនបុណ្យបានគ្រប់កាល**] មានសេចក្តីថា

ទៅតាទូលសួរថា ៖

កេសំ ទិវា ច រត្តោ ច

សទា បុញ្ញំ បវឌ្ឍតិ

ធម្មដ្ឋា សីលសម្បន្នា

កេ ជាន សគ្គគាមិនោតិ ។

បុណ្យរមែងចំរើនមិនជាប់ ទាំងថ្ងៃទាំងយប់គ្រប់វេលា ដល់ជនណា ជនពួកណាឈ្មោះថា តាំងនៅក្នុងធម៌ ឈ្មោះថា បរិបូណ៌ដោយសីល គួរទៅកាន់ឋានសួគ៌បាន ។

ព្រះមានព្រះមានត្រាស់តបថា ៖

អារាមរោបា វនរោបកា

យេ ជាន សេតុការកា

បបញ្ច ឧទបានញ្ច

យេ ទទន្តិ ឧបស្សយំ

តេសំ ទិវា ច រត្តោ ច

សទា បុញ្ញំ បវឌ្ឍតិ

ធម្មដ្ឋា សីលសម្បន្នា

តេ ជាន សគ្គគាមិនោតិ ។

ជនណាដាំច្បារឈើមានផ្កាផ្លែដាំច្បារឈើមានម្លប់ សាងស្ពាន សាងភេង ឱ្យទានទឹក ទាំងជីកស្រះ ជនទាំងឡាយណាឱ្យនូវទីសំណាក់អាស្រ័យបុណ្យ រមែងចម្រើន មិនដាច់ទាំងថ្ងៃទាំងយប់ គ្រប់វេលាដល់ជនទាំងនោះ ជនទាំងនោះឈ្មោះថា ជាអ្នកតាំងនៅក្នុងធម៌ ឈ្មោះថា បរិបូណ៌ដោយសីល គួរទៅកាន់ឋានសួគ៌បាន ។

អដ្ឋកថា

បទថា ធម្មដ្ឋា សីលសម្បន្នា **តាំងនៅក្នុងធម៌បរិបូណ៌ដោយសីល** សេចក្តីថា ទេវតារមែងទូលសួរថា ជនពួកណាតាំងនៅក្នុងធម៌ ជនពួកណាសម្បូរណ៌ដោយសីល ដូច្នេះ ។

ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងបញ្ហានេះដោយវត្ថុមុនទើបត្រាស់ថា **អារាមភេចា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **អារាមភេចា ដាំច្បារជាទីរីករាយ** បានដល់ ដាំច្បារឈើមានផ្កា និងច្បារឈើមានផ្លែ ។

បទថា វនរោបា **ដាំព្រៃ** អធិប្បាយថា ធ្វើការលោមព័ទ្ធព្រំប្រទល់ក្នុងព្រៃ ធម្មជាតិដែលកើតឡើងឯង ហើយធ្វើចេតិយដាំដើមពោធិព្រឹក្ស ធ្វើទីចង្រ្កម ធ្វើមណ្ឌប កុដិ ទីពួនសម្ងំ និងទីសម្រាកក្នុងវេលាថ្ងៃនិងវេលាយប់ ។ កាលបុគ្គលដាំដើមឈើអាស្រ័យម្ចប់ ឱ្យអាស្រ័យនៅ ក៏ឈ្មោះថា ការដាំពួកឈើ ។

បទថា សេតុការកោ បានដល់ ជនទាំងឡាយសាងស្ពានក្នុងទីដែលមិនស្មើគ្នា ឬរមែងប្រគល់ទូកឱ្យទៅ ។

បទថា **បបំ សាធវោ** បានដល់ ពោធដែលឱ្យទឹកផឹក ។

បទថា ឧទបានំ **ទានទីក** បានដល់ ទីណាមួយមានស្រះបោក្ខរណី និងអណ្តូងដែលមានទឹកជាដើម ។

បទថា អបស្សយំ **ទីសំណាក់** បានដល់ ផ្ទះនៅសម្រាកអាស្រ័យព្រះបាលីថា ឧបាសយំ **ឱ្យចូលទៅអាស្រ័យ** ក៏មាន ។

បទថា សទា បុញ្ញំ បវឌ្ឍន្តិ **បុណ្យរមែងចម្រើនគ្រប់វេលា** សេចក្តីថា កាលត្រិះរិះដល់អកុសលវិតក្កក្តី កាលដេកលក់ក្តី បុណ្យរមែងមិនចម្រើន ។ តែកាលនឹកដល់(កុសលនោះ)វេលាណាបុណ្យក៏ចម្រើនវេលានោះ ដូច្នោះ ព្រះមានព្រះភាគ

ទ្រង់សំដៅយកសេចក្តីដូចពោលមកនេះទើបត្រាស់ថា បុណ្យរមែងចម្រើនគ្រប់វេលា ។

បទថា ធម្មដ្ឋា សីលសម្បន្នា **តាំងនៅក្នុងធម៌ បរិបូណ៌ដោយសីល** អធិប្បាយថា ឈ្មោះថា តាំងនៅហើយក្នុងធម៌ ព្រោះបុគ្គលនោះតាំងនៅក្នុងធម៌ឈ្មោះថា សម្បូរណ៌ហើយដោយសីល ព្រោះបុគ្គលនោះ ដល់ព្រមហើយដោយសីលសូម្បីនោះ ។

ម្យ៉ាងទៀត កាលបុគ្គលទាំងឡាយធ្វើបុណ្យបែបនេះ ឈ្មោះថារមែងបំពេញកុសលធម៌ ១០ ។ ឈ្មោះថា តាំងនៅក្នុងធម៌ ព្រោះតាំងនៅក្នុងកុសលធម៌ ១០ ទាំងនោះ និងឈ្មោះថា បរិបូណ៌ដោយសីល ព្រោះដល់ព្រមហើយដោយសីលនោះឯងដូច្នេះ ។

បឋមសប្បុរិសទានសូត្រ

នៅក្នុងបិដកលេខ ៤៨ ទំព័រ ១៧៣ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី[**ទានរបស់សប្បុរិស**]មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាននេះ មាន ៨ យ៉ាង ។

សប្បុរិសទាន ៨ យ៉ាង តើដូចម្តេចខ្លះ?

១- សុចឹ ខេតិ **គឺបុគ្គលជ្បាវត្ថុស្អាត**

២- បណីតំ ទេតិ ឱ្យវត្ថុថ្លៃថ្លា

៣- កាលេន ទេតិ ឱ្យតាមកាល

៤- កប្បិយំ ទេតិ ឱ្យវត្ថុគួរ

៥- វិចេយ្យ ទេតិ ជ្រើសរើសហើយទើបឱ្យ

៦- អភិណ្ហំ ទេតិ ឱ្យទានរឿយ ៗ

៧- ទទំ ចិត្តំ បសាទេតិ កំពុងឱ្យញុំាងចិត្តឱ្យជ្រះថ្លា

៨- ទត្វា អត្តនោ ហោតិ លុះឱ្យហើយ រមែងមានសេចក្តីពេញចិត្ត ។

ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាននេះមាន ៨ យ៉ាងនេះឯង ។

សុចិ បណីតំ កាលេន កប្បយំ បានភោជនំ

អភិណ្ហំ ទទាតិ ទានាតិ សុខេត្តេសុ ព្រហ្មចារីសុ ។

បុគ្គលរមែងឱ្យទានទាំងឡាយ គឺ ទឹក និងភោជនដ៏ស្អាត ថ្លៃថ្លា តាមកាល វត្ថុដ៏គួររឿយ ៗចំពោះព្រហ្មចារីបុគ្គលទាំងឡាយ ដូចជាស្រែដ៏ល្អ ។

នេវ វិប្បដិសារិយំ ចជិត្វា អាមិសំ ពហុំ

ឯវំ ទិន្នានិ ទានានិ វណ្ណយន្តិ វិប្បសដ្ឋិនោ ។

ពួកអ្នកប្រាជ្ញ រមែងសរសើរនូវទានទាំងឡាយដែលបុគ្គលលះបង់នូវអាមិសៈជាច្រើន ដែលមិនគួរឱ្យកើតសេចក្តីក្តៅក្រហាយ ហើយឱ្យយ៉ាងនេះ ។

ឯវំ យជិត្វា មេធាវី សទ្ធោ មុត្តេន ចេតសា

អព្យាបជ្ឈំ សុខំ លោកំ បណ្ឌិតោ ឧបបជ្ជតិ ។

អ្នកប្រាជ្ញមានបញ្ញា ជាអ្នកមានសទ្ធា បានបូជាយ៉ាងនេះ ហើយ មានចិត្តរួចស្រឡះ រមែងចូលទៅកាន់ទេវលោក ដែលមិនមានសេចក្តីទុក្ខមានតែសេចក្តីសុខ ។

អដ្ឋកថា

បទថា សុចី បានដល់ ឱ្យបស់ដែលស្អាតគឺបរិសុទ្ធិថ្លៃថ្លា ។

បទថា បណីតំ បានដល់ ឧត្តមសម្បុរណ៌ ល្អប្រណីត ។

បទថា កាលេន បានដល់ សមគួរដល់ការប្រកបខ្ជាប់ខ្ជួយ ។

បទថា **កប្បិយំ** *បានដល់ឱ្យរបស់ដែលជាកប្បិយ(គឺរបស់ដែលគួរដល់អ្នកទទួល) ។*

បទថា **វិចេយ្យ ទេតិ** *ដោយសេចក្តីថា ជ្រើសរើសបដិគ្គាហក ឬឱ្យទានដោយតាំងចិត្តយ៉ាងនេះថា ទាន ដែលឱ្យហើយដល់បុគ្គលនេះ នឹងមានផលច្រើន ឱ្យដល់បុគ្គលនោះមិនមានផលច្រើនឡើយ ពិចារណាដូច្នេះហើយ ទើបឱ្យ ។*

សម្ពុទ្ធិសូត្រ

នៅក្នុងបិដកលេខ ៤១ ទំព័រ ១២១ ព្រះមានព្រះភាគជាម្ចាស់ទ្រង់សម្តែងអំពី ***ហេតុនាំឱ្យប្រសព្វបុណ្យច្រើន ៣ ប្រការ*** *មានសេចក្តីថា ៖*

ម្នាលភិក្ខុទាំងឡាយ ***កុលបុត្រមានសទ្ធា*** *រមែងបានបុណ្យច្រើន ព្រោះមានវបស់ ៣ ក្នុងទីចំពោះមុខ ។* ***វបស់ ៣*** *តើដូចម្តេច ។*

៦. *ម្នាលភិក្ខុទាំងឡាយ* ***កុលបុត្រមានសទ្ធា*** *រមែងបានបុណ្យច្រើន* ***ព្រោះមានសទ្ធាក្នុងទីចំពោះមុខ ១ ។***

៦.*ម្នាលភិក្ខុទាំងឡាយ* ***កុលបុត្រមានសទ្ធា*** *រមែងបាន*

បុណ្យច្រើន **ព្រោះមានទេយ្យធម៌ក្នុងទីចំពោះមុខ ១ ។**

៦. ម្នាលភិក្ខុទាំងឡាយ **កុលបុត្រមានសទ្ធា** រមែងបានបុណ្យច្រើន **ព្រោះមានទក្ខិណាយ្យបុគ្គលក្នុងទីចំពោះមុខ ១ ។** ម្នាលភិក្ខុទាំងឡាយ កុលបុត្រមានសទ្ធា រមែងបានបុណ្យ ច្រើន ព្រោះមានរបស់ ៣ នេះឯងក្នុងទីចំពោះមុខ ។

អដ្ឋកថា

បទថា **សម្មុខីភាវា** សេចក្តីថា ព្រោះភាវៈចំពោះមុខ អធិប្បាយថា ព្រោះសេចក្តីមាន ។ បទថា **បសវតិ** ប្រែថា រមែងត្រឡប់បាន ។ បទថា **សទ្ធាយសម្មុខីភាវោ** សេចក្តីថា ព្រោះបើមិនមានសទ្ធា មិនមានទេយ្យធម៌ និងមិនមានបុគ្គលដែលជាបដិគ្គាហក ពោលគឺព្រះទក្ខិណេយ្យបុគ្គលហើយ សោតនឹងគប្បីធ្វើបុញ្ញកម្មបានយ៉ាងណា, តែព្រោះបច្ចុយ ៣ យ៉ាងនោះមានចំពោះមុខ ទើបអាចធ្វើបុញ្ញកម្មបាន ព្រោះហេតុនោះឯង ទើបព្រះមានព្រះភាគ ត្រាស់ពាក្យមានជាដើមថា **សទ្ធាយ សម្មុខីភាវា** ដូច្នេះ ។ ក៏ក្នុង ៣ យ៉ាងនេះធម៌ ២ យ៉ាងគឺ ទេយ្យធម៌ ១ ទក្ខិណេយ្យបុគ្គល ១ រកបានងាយ, តែសទ្ធារកបានលំបាក ។

ព្រោះបុថុជ្ជនមានសទ្ធាមិនតាំងមាំ ផ្សេងគ្នាទៅតាមបទតាមបាទ ។ ដោយហេតុនោះឯង សូម្បីព្រះអគ្គសាវកដូចជាព្រះមហាមោគ្គល្លានក៏មិនអាចទទួលជានាសទ្ធានោះបាន ទើបពោលថា "**ទ្វិន្នំ ខោ តេ អហំ, អាវុសោ, ធម្មានំ ជិភោគោ ភោគានញ្ច ជីវិតស្ស ច, សទ្ធាយ បន ត្វំយេវ ជិភោគោ** ម្នាលអាវុសោ ខ្ញុំអាត្មាជានាឱ្យអ្នកតែធម៌ ២ យ៉ាង គឺភោគៈ ១ ជីវិត ១ ឯខ្ញុំអ្នកត្រូវតែជានាសទ្ធាខ្លួនឯងចុះ, ដូច្នេះ ។

ខេឡាមសុត្រ

នៅក្នុងបិដកលេខ ៤៩, ទំព័រ ៧៧ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ព្រះសូត្រមួយដែលនិយាយអំពី **(ការឱ្យទានដែលមានផលច្រើន)** មានសេចក្តីថា ៖

សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី ។ គ្រានោះអនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះអនាថបិណ្ឌិកគហបតី អង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏

មានព្រះភាគត្រាស់សួរ ដូច្នេះថា ម្នាលគហបតី ទានក្នុងត្រកូលអ្នកនៅតែឱ្យដែរឬ ។

លោកអនាថបិណ្ឌិកគហបតីទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទានក្នុងត្រកូលខ្ញុំព្រះអង្គនៅតែឱ្យដែរ តែទាននោះ ឯងសៅហ្មង គឺបាយចុងអង្ករនឹងទឹកជ្រក់ជាគម្រប់ពីរ ។

៣. ម្នាលគហបតី បុគ្គលឱ្យទានសៅហ្មងក្តី ឱ្យទានថ្លៃថ្លាក្តី តែឱ្យទានមិនគោរព ធ្វើសេចក្តីមិនកោតក្រែងហើយ ឱ្យមិនឱ្យដោយដៃខ្លួនឯង បោះឱ្យឃ្លាតថា មិនមានផល ហើយឱ្យវិបាករបស់ទាននោះ ៗកើតក្នុងត្រកូលណា ៗ ចិត្តក៏មិនឱនទៅដើម្បីប្រើប្រាស់នូវភត្តដ៏ថ្លៃថ្លា ចិត្តមិនឱនទៅដើម្បីប្រើប្រាស់នូវសម្ពត់ដ៏ថ្លៃថ្លា ចិត្តមិនឱនទៅដើម្បីប្រើប្រាស់នូវយានដ៏ថ្លៃថ្លា ចិត្តមិនឱនទៅដើម្បីប្រើប្រាស់ក្នុងកាមគុណ ៥ ដ៏ថ្លៃថ្លា មួយទៀត ពួកជនណាដែលជាកូនក្តី ប្រពន្ធក្តី ទាសៈក្តី អ្នកបំរើក្តី កម្មករក្តី របស់បុគ្គលនោះ ជនទាំងនោះមិនស្តាប់មិនផ្ទង់ត្រចៀកស្តាប់ រមែងបញ្ឆិនចិត្តទៅកាន់អារម្មណ៍ដទៃ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលគហបតីព្រោះថាវិបាកនៃកម្មទាំងឡាយដែលបុគ្គលធ្វើមិនគោរព

រមែងមានយ៉ាងនេះឯង ។

ម្នាលគហបតី បុគ្គលឱ្យទានសៅហ្មងក្តី ថ្លៃថ្លាក្តី តែឱ្យទាននោះដោយគោរព ធ្វើសេចក្តីកោតក្រែងហើយឱ្យ ឱ្យដោយដៃខ្លួនឯងមិនបោះឱ្យយល់ថា មានផលហើយឱ្យ វិបាករបស់ទាននោះ ។ កើតក្នុងត្រកូលណា ។ ចិត្តរមែងឱនទៅដើម្បីប្រើប្រាស់នូវភត្តដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅដើម្បីប្រើប្រាស់នូវសម្ពត់ដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅដើម្បីប្រើប្រាស់នូវយានដ៏ថ្លៃថ្លា ចិត្តរមែងឱនទៅដើម្បីប្រើប្រាស់ក្នុងកាមគុណ ៥ ដ៏ថ្លៃថ្លា មួយទៀត ពួកជនណាដែលជាកូនក្តី ប្រពន្ធក្តី ទាសៈក្តី អ្នកបំរើក្តី កម្មករក្តី របស់បុគ្គលនោះ ជនទាំងនោះរមែងស្តាប់ផ្តង់ត្រចៀកស្តាប់ មិនបញ្ជូនចិត្តទៅកាន់អារម្មណ៍ដទៃឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលគហបតី ព្រោះថា វិបាករបស់កម្មទាំងឡាយ ដែលបុគ្គលធ្វើដោយគោរព រមែងមានយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ កាលពីព្រេងនាយមានព្រាហ្មណ៍ឈ្មោះ **វេលាម** លោកបានឱ្យទានជាមហាទានមានសភាពយ៉ាងនេះគឺ ៖

-បានឱ្យភាជន៍មាស ៨៤,០០០ ដែលពេញដោយប្រាក់,

-បានឱ្យភាជន៍ប្រាក់ ៨៤,០០០ ដែលពេញដោយមាស,

-បានឱ្យភាជន៍សំរិទ្ធិ ៨៤,០០០ ដែលពេញដោយប្រាក់,

-បានឱ្យដំរី ៨៤,០០០ ដែលមានគ្រឿងអលង្ការមាស មានទង់ជ័យមាសព្រមទាំងបាំងដោយបណ្តាញមាស,

-បានឱ្យរថ ៨៤.០០០ ដែលពាសដោយស្បែកសីហៈ ដែលពាសដោយស្បែកខ្លាធំដែលពាសដែលស្បែកខ្លាដំបង ពាសដោយសម្ពត់កម្ពលមានពណ៌លឿង មានគ្រឿងអលង្ការមាស មានទង់ជ័យមាស បិទបាំងដោយបណ្តាញមាស

-បានឱ្យមេគោ ៨៤,០០០ សម្រាប់រូតបង្ហូរ(ទឹកដោះ) មានភាជន៍សំរិទ្ធិសម្រាប់ត្រង,

-បានឱ្យនាងកញ្ញា ៨៤,០០០ ដែលពាក់កែវមណីនឹងកណ្ឌល,

-បានឱ្យបល្ល័ង្ក ៨៤,០០០ ដែលក្រាលដោយព្រំក្រាលដោយកម្រាលរោមមានពណ៌ស ក្រាលដោយកម្រាល រោមមានផ្កាជាចង្កោម ក្រាលដោយកម្រាលដ៏ប្រសើរធ្វើពីរោមម្រឹគឈ្មស់ មានខ្នើយពណ៌ក្រហមទាំងពីរខាង ព្រមទាំងពិតានមានពណ៌ក្រហម

-បានឱ្យកោដិ[1]នៃសម្ពត់ ៨៤,០០០ គឺសម្ពត់ប្ដី មានសាច់ល្អិត សម្ពត់សូត្រមានពណ៌ល្អិត សម្ពត់អម្បោះ មានសាច់ល្អិត បាច់និយាយថ្វីដល់បាយ ទឹក បង្អែម ភោជនគ្រឿងលាប ទីជេក ដូចជាស្ដីងតែងហូរទៅ ម្នាលគហបតី អ្នកប្រហែលជាមានសេចក្ដីសម្គាល់នូវវេលាម ព្រាហ្មណ៍ទុំះយ៉ាងនេះថា ក្នុងសម័យនោះវេលាមព្រាហ្មណ៍ជាបុគ្គលដទៃដោយពិត (ក្រៅពីតថាគត) លោកបានឱ្យ ទាននោះជាមហាទាន ។ ម្នាលគហបតី ហេតុទុំះអ្នកមិនត្រូវយល់យ៉ាងនេះឡើយ ក្នុងសម័យនោះ វេលាមព្រាហ្មណ៍ក៏គឺតថាគត ទានដែលតថាគតបានឱ្យនោះជាមហាទាន ។ ម្នាលគហបតី មិនមានទក្ខិណេយ្យបុគ្គលណាមួយក្នុងទាននោះ មិនមានបុគ្គលណាមួយសម្រាប់ទក្ខិណាទាននោះទេ ។

ម្នាលគហបតី វេលាមព្រាហ្មណ៍បានឱ្យទានណាដែលឈ្មោះថា មហាទាន ទីងបុគ្គលណាញុំងបុគ្គលដែលមានទិដ្ឋិល្អ ១ រូប (សោតាបន្នបុគ្គល)ឱ្យបរិភោគទាននោះ ជាទានមានផលច្រើនជាងមហាទាន (ដែលឱ្យដល់បុថុជ្ជន)

---

១. កោដិក្នុងទីនេះសំដៅយក សំពត់សាដក ១០ ហៅថា មួយកោដិ ។

- បុគ្គលណាញុំាងបុគ្គលដែលមានទិដ្ឋិស្អ គឺសោតាបន្ន-បុគ្គល ១០០ រូបឱ្យបរិភោគ (ក៏នៅតិចជាងការថ្វាយទានដល់សកទាគាមី ១ រូប)

-បុគ្គលណាញុំាងបុគ្គលជាសកទាគាមី ១០០ រូបឱ្យបរិភោគ(ក៏នៅតិចជាងការថ្វាយទានដល់អនាគាមីបុគ្គល ១រូប)

-បុគ្គលណាញុំាងបុគ្គលជាអនាគាមីបុគ្គល ១០០ រូប ឱ្យបរិភោគ (ក៏នៅមានផលតិចជាងការថ្វាយទានដល់ព្រះអរហន្ត ១ រូប)

-បុគ្គលណាញុំាងបុគ្គលជាព្រះអរហន្ត ១០០ រូប ឱ្យបរិភោគ(ក៏នៅមានផលតិចជាងការថ្វាយទានដល់ព្រះបច្ចេកពុទ្ធ ១ រូប)

-បុគ្គលណាញុំាងបុគ្គលជាព្រះបច្ចេកពុទ្ធ ១០០ រូប ឱ្យបរិភោគ(ក៏នៅមានផលតិចជាង ការថ្វាយទានដល់ព្រះសម្មាសម្ពុទ្ធ ១ អង្គ)

- បុគ្គលណាញុំាងព្រះតថាគតៈអរហន្តសម្មាសម្ពុទ្ធ ឱ្យបរិភោគ (ក៏នៅមានផលតិចជាងការថ្វាយទានដល់ព្រះភិក្ខុសង្ឃ

(សង្ឃទាន) មានព្រះពុទ្ធជាប្រធាន)

- បុគ្គលណាញុំាងសង្ឃមានព្រះពុទ្ធជាប្រធានឱ្យបរិភោគ (ក៏នៅមានផលតិចជាងការសាងវិហារទានឧទ្ទិស ដល់ព្រះភិក្ខុសង្ឃ ដែលនិមន្តមកអំពីទិសទាំង ៤)

-បុគ្គលណា ឱ្យគេធ្វើវិហារឧទ្ទិសចំពោះសង្ឃមកពីទិសទាំង ៤ ក៏នៅមានផលតិចជាងរបស់បុគ្គលដែលមានចិត្តជ្រះថ្លាដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង

-បុគ្គលណាមានចិត្តជ្រះថ្លាដល់ព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផងជាទីពឹង [ក៏នៅមានផលតិចជាងរបស់បុគ្គលដែលមានចិត្តជ្រះថ្លា សមាទាននូវសិក្ខាបទទាំងឡាយ គឺចេតនាវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ដោយការផឹកនូវទឹកស្រវឹង គឺសុរានឹងមេរ័យ (ព្រមទាំងត្រៃសរណាគមន៍)]

-បុគ្គលណាមានចិត្តជ្រះថ្លា សមាទាននូវសិក្ខាបទទាំងឡាយ គឺចេតនាវៀរចាកបាណាតិបាត (វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ

ដោយការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យ (និងការដល់ព្រមដោយសរណាគមន៍) ក៏នៅមានផលតិចជាង របស់បុគ្គលដែលដោយហោចទៅបានចម្រើននូវមេត្តាចិត្ត សូម្បីអស់កាលត្រឹមតែមួយរូតទឹកដោះគោប៉ុណ្ណោះ ការចម្រើនមេត្តាចិត្តនេះរបស់បុគ្គលនោះ មានផលច្រើនជាងទាននោះទៅទៀត ។

ម្នាលគហបតី វេលាមព្រាហ្មណ៍បានឱ្យទានជាមហាទាន និងបុគ្គលណា ញុំាងបុគ្គលមានទិដ្ឋិឫជ្ជុ ១ រូប ឱ្យបរិភោគ, បុគ្គលណាញុំាងបុគ្គលមានទិដ្ឋិឫជ្ជុ ១០០ រូប ឱ្យបរិភោគ, និងបុគ្គលណាញុំាងបុគ្គលជាសកទាគាមី ១ រូបឱ្យបរិភោគ, បុគ្គលណាញុំាងបុគ្គលជាសកទាគាមី ១០០ រូបឱ្យបរិភោគ, និងបុគ្គលណាញុំាងបុគ្គលអនាគាមី ១ រូបឱ្យបរិភោគ, បុគ្គលណាញុំាងបុគ្គលអនាគាមី ១០០ រូបឱ្យបរិភោគ, និងបុគ្គលណាញុំាងព្រះអរហន្ត ១ អង្គ ឱ្យបរិភោគ, បុគ្គលណាញុំាងព្រះអរហន្ត ១០០ អង្គឱ្យបរិភោគ, និងបុគ្គលណាញុំាងព្រះបច្ចេកពុទ្ធ ១ អង្គឱ្យបរិភោគ, បុគ្គលណាញុំាងព្រះបច្ចេកពុទ្ធ ១០០ អង្គឱ្យបរិភោគ, និងបុគ្គលណាញុំាងព្រះតថាគតអរហន្តសម្មាសម្ពុទ្ធឱ្យបរិភោគ, និងបុគ្គលណាញុំាងព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឱ្យបរិភោគ, និងបុគ្គលណាឱ្យគេ

ធ្វើវិហារ ឧទ្ទិសចំពោះសង្ឃមកអំពីទិសទាំង៤, បុគ្គលណាមានចិត្តជ្រះថ្លាដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹង, នឹងបុគ្គលណាមានចិត្តជ្រះថ្លា សមាទាននូវសិក្ខាបទទាំងឡាយ គឺចេតវៀរចាកបាណាតិបាត (វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ ដោយការផឹកនូវទឹកស្រវឹង គឺសុរានិងមេរ័យដោយហោចទៅនឹងបុគ្គលណាចម្រើនមេត្តាចិត្ត សូម្បីអស់កាលត្រឹមតែមួយវារៈទឹកដោះគោប៉ុណ្ណោះ, នឹងបុគ្គលណាចំរើននូវអនិច្ចសញ្ញា សូម្បីអស់កាលគ្រាន់តែផ្ចាត់ម្រាមដៃប៉ុណ្ណោះ ការចម្រើននេះមានផលច្រើនជាងទាននោះទៅទៀត ។

អដ្ឋកថា

បទថា **គហបតីនៅក្នុងត្រកូលរបស់លោកនៅឱ្យទានទៀត** ឬ(អបិ នុ តេ គហបតិ កុលេ ទានំ ទិយ្យតិ) សេចក្តីថានេះ ព្រះមានព្រះភាគ មិនបានត្រាស់សួរដល់ទាន ដែលលោកថ្វាយដល់ភិក្ខុសង្ឃពិតមែនក្នុងផ្ទះរបស់សេដ្ឋីនៅឱ្យទានដែលប្រណិតជាប្រចាំដល់ភិក្ខុសង្ឃ ព្រះសាស្តានឹងទ្រង់មិនដឹងដល់ប្រការនោះ

ក៏មិនមែន ចំណែកទានដែលឱ្យដល់លោកិយមហាជន ទាននោះ សៅហ្មងសេដ្ឋីមិនឆ្អែតស្កប់ស្កល់ចិត្តទើបត្រាស់សួរទាននោះ ។

បទថា កាណាជកំ សេចក្តីថា អង្គរលាយជាមួយកន្ទក់ គឺដាំហើយដោយអង្គរបន្តិចលាយជាមួយកន្ទក់ ។

បទថា ពិឡទុតិយំ គឺមានទឹកបន្លែជ្រក់ជាទីពីរ ។

បទថា អសក្កច្ចំ ទេតិ បានដល់ នឹងឱ្យមិនធ្វើការគោរព ។

បទថា អបចិត្តីកតា ទេតិ សេចក្តីថាឱ្យដោយមិនរាប់អាន គឺដោយមិនគោរពក្នុងទក្ខិណេយ្យបុគ្គល ។

បទថា អសហត្ថា ទេតិ សេចក្តីថា មិនឱ្យដោយដៃរបស់ខ្លួនឱ្យដោយដៃរបស់អ្នកដទៃអធិប្បាយថា រមែងធ្វើត្រឹមតែបង្គាប់ប៉ុណ្ណោះឯង ។

បទថា អបវិដ្ឋំ ទេតិ សេចក្តីថា រមែងមិនឱ្យជាប់តគ្នាគឺឱ្យដូចជាអ្នកប្រាថ្នានឹងចោលចេញដូចអ្នកបណ្តែងចេញនូវសត្វទន្សែងជាក់ក្នុងដំបូកកណ្តៀរ ដូចតិណាទេស ត្រាំស្រាបរបស់អ្នកលេងផឹកស្រាផ្ទាស់ប្តូរប្រចាំឆ្នាំ ដូច្នោះ ។

បទថា **អនាគមនធិដ្ឋិកោ ឥតិ** *សេចក្តីថា* **មិនជឿកម្ម និង**ផលឱ្យទាន ។

បទថា **យត្ថ យត្ថ** *បានដល់* បណ្តាកុលសម្បទាទាំងបី ក្នុងត្រកូលណា ៗ ។ *ក្នុងបទជាដើមថា* **ន ឧឡ្ឃាយ ភត្តកោ**- *គាយមានវិនិច្ឆ័យដូច្នេះកាលគេបង្អោនភោជននៃស្រូវសាលីក្រអូប ដែលមានរសឆ្ងាញ់ផ្សេង ៗចូលទៅហើយគេនឹងមិនបង្អោនចិត្ត ទៅ(ដើម្បីនឹងបរិភោគ) ហើយក៏បានពោលថា លោកចូរនាំ អាហារដែលបង្កឱ្យកើតរោគនេះចេញទៅដូច្នេះ ក៏បានបរិភោគ ជាយលាយនឹងបន្លែជ្រក់ ដោយមានសេចក្តីសំគាល់ថា ដូចជា អាហារទិព្វ កាលគេបង្អោនសំពត់យ៉ាងល្អ មានសំពត់កាសីជា ដើមចូលទៅហើយក៏ពោលថា លោកចូរនាំទៅចុះសំពត់ទាំងនេះ រមែងមិនអាចសូម្បីបិទបាំងបាន រមែងមិនជាប់នៅ សូម្បីដែល ពាងកាយរបស់បុគ្គលដែលស្លៀក ដូច្នេះហើយ ក៏បានស្លៀកសំពត់ សាច់គ្រោតគ្រាតដូចឫសនឹងសំបករបស់ដូងធ្វើជាសំពត់ ដោយ គិតថា អ្នកស្លៀកសំពត់ទាំងនេះ រមែងរលឹកដឹងជាងអ្នកស្លៀក ដណ្តប់ ហើយនូវសំពត់ទាំងនោះ រមែងបិទបាំងសូម្បីវត្តុដែល គួរបិទបាំង ដូច្នេះ កាលគេបង្អោនយានដ៏វិ យានសេះ យានរថ ឬ

ត្រៃស្នែងមាសជាដើមចូលទៅឱ្យក៏ពោលថា លោកចូរនាំទៅចុះ យានទាំងនោះអ្នកណា ៗមិនអាចដើម្បីនឹងអង្គុយជាសុខក្នុងយាន នេះបានទេ ដូច្នេះ កាលគេបង្អោនរថចាស់គ្រាំគ្រាចូលទៅឱ្យក៏ ពោលថា រថនេះជារថមិនញ័រក្នុងរថនេះទើបអង្គុយបានជាសុខ ដូច្នេះ រមែងត្រេកអររថនោះ ។

បទថា ន ឧច្ឆាវេសុ បញ្ចសុ កាមគុណេសុ សេចក្តីថា គេបានឃើញស្រីទាំងឡាយ ជាអ្នកមានរូបដែលប្រដាប់តាក់តែងហើយ បែរជាគិតឃើញថា ដូចជានាងយក្ខិណី នាងយក្ខិណីទាំងនោះជាអ្នកប្រាថ្នានឹងស៊ីយើង ប្រយោជន៍អ្វីដោយស្រីទាំងឡាយទាំងនោះដូច្នេះ រមែងឱ្យវេលាកន្លងទៅតាមសេចក្តីសប្បាយ ។

បទថា ន សុស្សូសន្តិ សេចក្តីថា បរិវារជនទាំងឡាយរមែងមិនប្រាថ្នាដើម្បីនឹងស្តាប់អធិប្បាយថារមែងមិនជឿដូច្នេះក៏មាន ។

បទថា ន សោតំ ឱទហន្តិ សេចក្តីថា រមែងមិនផ្តៀងសោតបសាទចុះដើម្បីស្តាប់ពាក្យដែលគេនិយាយទៅហើយ ។ បទជាដើមថា ដោយគោរព សក្កច្ចំ គប្បីជ្រាបដោយបរិយាយផ្ទុយគ្នានឹងពាក្យពោលហើយ ។

បទថា **វេលាមៈ** (វេលាមោ) សេចក្តីថា ជាអ្នកបានឈ្មោះហើយយ៉ាងនេះ ព្រោះប្រកបដោយគុណទាំងឡាយដ៏ធំក្រៃលែង មានជាតិគោត្រូវបកោគៈ សទ្ធានិងបញ្ញាជាដើម ។ ក្នុងបទថា **សោ ឯវមំ ធានមធាសិ មហាធានំ** នេះ មានអនុបុព្វីកថាដូចតទៅនេះ ៖

បានឮថា ក្នុងអតីត វេលាមព្រាហ្មណ៍នោះ បានចាប់បដិសន្ធិហើយនៅក្នុងផ្ទះរបស់បុរោហិត (ព្រាហ្មណ៍ដែលប្រឹក្សាក្នុងផ្លូវច្បាប់ទំនៀមប្រពៃណី) ក្រុងពារាណសី ពួកញាតិបានតាំងឈ្មោះឱ្យគេថា វេលាមកុមារ ។ ក្នុងវេលាអាយុ ១៦ឆ្នាំ វេលាមកុមារនោះបានទៅកាន់ក្រុងតក្កសិលាដើម្បីសិក្សាសិល្បៈជាមួយរាជកុមារ ក្រុងពារាណសី ។ អ្នកទាំងពីរនោះ ប្រាថ្នាសិក្សាសិល្បៈក្នុងសំណាក់របស់អាចារ្យទិសាបាមោក្ខ ។ ពួកគេប្រាថ្នាហើយយ៉ាងណាចំណែករាជកុមារ ៨ម៉ឺនបួនពាន់នាក់ សូម្បីពួកជនៃក្នុងជម្ពូទ្វីប ក៏ប្រាថ្នាហើយដូច្នោះ ។ ព្រះពោធិសត្វ ក្នុងខណៈដែលខ្លួនរៀនក៏បានជាអាចារ្យ ទើបឱ្យកុមារប្រាំបីម៉ឺនបួនពាន់សិក្សាខ្លួនឯងរៀនសិល្បៈ ៣ឆ្នាំចប់តែបុគ្គលជនៃសិក្សា ១៦ឆ្នាំ ទើបចប់ ។

អាចារ្យដ៏ឆ្លាតថា សិល្បៈរបស់វេលាមកុមាររហ័សរហួនហើយ ទើបពោលថា ម្នាលកូនទាំងឡាយ វេលាមៈ រមែងចេះសិល្បៈទាំងអស់ដែលយើងបានចេះហើយ ពួកអ្នកឯងគ្រប់អ្នកចូលទៅសិក្សាសិល្បៈក្នុងសំណាក់របស់វេលាមៈចុះ ដូច្នេះ ទើបប្រគល់កុមារ ៨ ម៉ឺនបួនពាន់នាក់ ឱ្យដល់ព្រះពោធិសត្វ ។

ព្រះពោធិសត្វថ្វាយបង្គំអាចារ្យហើយ ជាអ្នកមានកុមារច្រាំបីម៉ឺនបួនពាន់បៃហាមចេញទៅហើយ ដល់ក្រុងដែលនៅជិតមួយកន្លែង ទើបឱ្យរាជកុមារអ្នកជាម្ចាស់របស់ក្រុងនោះរៀនកាលគេជំនាញក្នុងសិល្បៈហើយ ទើបឱ្យគេត្រឡប់ទៅនៅក្នុងក្រុងនោះឯង ព្រះពោធិសត្វទៅកាន់ក្រុងច្រាំបីម៉ឺនបួនពាន់ក្រុងដោយឧបាយនោះហើយ ឱ្យរាជកុមារ ៨ ម៉ឺនបួនពាន់នាក់ សិក្សាសិល្បស្ទាត់ជំនាញហើយ ទើបឱ្យរាជកុមារនោះ ។ ត្រឡប់ទៅនៅក្នុងក្រុងនោះ ។ ហើយក៏នាំយករាជកុមារក្រុងពារាណសីត្រឡប់មកកាន់ក្រុងពារាណសី ។ អ្នកទាំងឡាយក្នុងក្រុងពារាណសីនោះ ទើបបានអភិសេករាជកុមារក្រុងពារាណសី អ្នករៀនចប់សិល្បៈហើយទុកក្នុងរាជសម្បត្តិ បានឱ្យតំណែងបុរោហិតដល់វេលាមៈ ។ រាជកុមារច្រាំបីម៉ឺនបួនពាន់សូម្បីទាំងនោះ បានអភិសេកហើយក្នុងរាជ

សម្បត្តិទាំងឡាយរបស់ខ្លួន ហើយក៏នាំគ្នាមកធ្វើការទំនុកបម្រុងព្រះបាទក្រែងពារាណសីគ្រប់ឆ្នាំ ។ ព្រះរាជកុមារទាំងនោះគាល់ព្រះរាជា ហើយបានទៅកាន់សំណាក់របស់វេលាមៈពោលថា បពិត្រលោកអាចារ្យ កាលខ្ញុំទាំងឡាយតាំងនៅហើយក្នុងរាជសម្បត្តិលោកជ្រាបថ្លាដោយវត្តណាគប្បីជ្រាប់ហើយក៏នាំគ្នាទៅកាលរាជកុមារទាំងនោះ នាំយកវរេះរថ មេគោ គោឈ្មោល មាន់និងជ្រូកជាដើម ក្នុងវេលាទៅនិងវេលាមក ជនបទក៏ត្រូវបៀតបៀនយ៉ាងធ្ងន់ ។ មហាជនប្រជុំព្រមគ្នាហើយ ស្រែកយំនៅត្រង់ព្រះរាជវាំង ។ ព្រះរាជាបញ្ជាឱ្យហៅវេលាមៈមកហើយត្រាស់ថា បពិត្រលោកអាចារ្យជនបទត្រូវបៀតបៀន ព្រះរាជាទាំងឡាយ រមែងធ្វើការបន្ទ ធំក្នុងវេលាទៅនិងវេលាមក មនុស្សទាំងឡាយរមែងមិនអាចដើម្បីនឹងតាំងនៅស្ងប់បាន លោកចូរធ្វើឧបាយយ៉ាងណាមួយ ដើម្បីឱ្យជនបទស្ងប់ចាកពីសេចក្តីបៀតបៀន ។ វេលាមៈក្រាបទូលថា បពិត្រមហារាជ ជាការល្អហើយ ខ្ញុំព្រះអង្គនឹងធ្វើឧបាយ ព្រះអង្គមានសេចក្តីត្រូវដោយជនបទមានប្រមាណប៉ុណ្ណា ព្រះអង្គចូរទ្រង់កំណត់នៅជនបទនោះហើយកាន់យកចុះ ។ ព្រះរាជាបានទ្រង់ធ្វើយ៉ាងនោះហើយ ។ វេលាមៈត្រាច់ត្រួតមើលក្នុង

ជនបទរបស់ព្រះរាជា ៨ ម៉ឺនបួនពាន់ហើយ ទើបឱ្យរួមចូលមកនៅក្នុងជនបទរបស់ព្រះរាជា ដូចរូបរួមកាំកង់ទុកត្រង់កុំកង់ដូច្នោះ ។ ចាប់ផ្តើមតាំងពីនោះ ព្រះរាជាទាំងឡាយនោះ ស្តេចមកក្តី ស្តេចទៅក្តី រមែងអន្ទោលទៅតាមជនបទរបស់ព្រះអង្គ ៗប៉ុណ្ណោះ ទ្រង់មិនធ្វើការប្លន់ដោយទ្រង់ត្រិះរិះថា ជនបទរបស់យើងទាំងឡាយដូច្នេះ ទ្រង់មិនបៀតបៀនសូម្បីជនបទរបស់ព្រះរាជាដោយសេចក្តីគោរពចំពោះព្រះរាជា ។ ជនបទទាំងឡាយក៏ស្ងប់ស្ងៀមមិនមានសំឡេងសូមអង្វរ ។ ព្រះរាជាទាំងពួងទ្រង់រីករាយត្រេកអរទ្រង់បវារណាថា បពិត្រលោកអាចារ្យ លោកត្រូវការដោយវត្ថុណា លោកចូរប្រាប់វត្ថុនោះដល់ខ្ញុំទាំងឡាយ ដូច្នេះ ។

វេលាមៈកក់សីសៈហើយ ឱ្យបើកទ្វារបន្ទប់ពេញដោយរតនៈ ៧ ប្រការក្នុងនិវេសន៍របស់ខ្លួន ត្រួតមើលទ្រព្យដែលរក្សាទុកដល់ ៧ ជួរបុរសនៃត្រកូលពិចារណា អំពីសេចក្តីចម្រើននិងសេចក្តីសាបសូន្យហើយគិតថា យើងគួរឱ្យទាន ឱ្យព្រួសសាយទៅទូទាំងជម្ពូទ្វីប ដូច្នេះហើយបានក្រាបទូលចំពោះព្រះរាជាឱ្យសាងចង្រ្កានជួរទុកប្រមាណ ១២ យោជន៍ ជិតត្រើយទន្លេគង្គាឱ្យសាងឃ្លាំងធំទុកហើយដើម្បីត្រូវការរក្សាទឹកដោះថ្លា ទឹកឃ្មុំ ទឹកអំពៅ ប្រេង

ល្ង និងស្រែវជាដើមក្នុងទីនោះ ៗ បានចាត់មនុស្សទាំងឡាយ ទុកថា ក្នុងទីនោះ ៗ ចូរចាត់មនុស្សប្រមាណប៉ុណ្ណេះ ៗ ហើយកាលបើរបស់ណាមួយដែលឈ្មោះថា ពួកមនុស្សនឹងគប្បីបាន សូម្បីត្រឹមតែយមួយមុនខ្វះមិនមាន លោកទាំងឡាយគប្បីជ្រាប់ដល់យើង ដូច្នេះ ទើបឱ្យមនុស្សរៀយស្តារដើរទៅក្នុងក្រុងថា សូមជនទាំងឡាយចូរបរិភោគទានរបស់វេលាមព្រាហ្មណ៍ផ្តើមពីថ្ងៃនោះដូច្នេះ កាលអ្នកចាត់ចែងទានជ្រាប់ថា ភោងទានសម្រេចហើយ ស្លៀកសំពត់តម្លៃមួយពាន់ ពាក់សំពត់ឆៀងស្មាមានតម្លៃ ៥ រយ តែងដោយគ្រឿងប្រដាប់គ្រប់យ៉ាង ដាក់ទឹកដែលមានពណ៌កែវ-ផលឹកឱ្យពេញសុវណ្ណភិង្គារ (កុណ្ឌីទឹកមាស) ហើយដើម្បីសាកល្បងទានបានធ្វើសច្ចកិរិយាថា បើក្នុងលោកនេះ នៅមានទក្ខិ-ណេយ្យបុគ្គលដែលសមគួរទទួលទាននេះ សូមទឹកនេះហូរចេញទៅ ចូរជ្រាបទៅក្នុងផែនដី បើមិនមាន ចូរតាំងនៅជូចដើមយ៉ាងនេះបានផ្ទៀងមាត់សុវណ្ណភិង្គារចុះហើយ ។ ទឹកបានត្រូវធម្មក្រែកឃ្លាំងទុកហើយ ។ ព្រះពោធិសត្វមិនបានក្តៅក្រហាយចិត្តទេថា ឱហ្ន៎ ជម្ពូទ្វីបនេះទទេ រមែងមិនមានសូម្បីបុគ្គលមួយនាក់ដែលសមគួរទទួលទក្ខិណា ដូច្នេះ ហើយគិតថា បើទក្ខិណានឹងបរិសុទ្ធិ

ចំណែកទាយក សូមទឹកហូរចេញហើយ ចូរជ្រាបចូលទៅផែនដីទៅដូច្នេះ ។ ទឹកស្រែដៀងពណ៌កែវផលឹកហូរចេញហើយ ជ្រាបចូលទៅផែនដីអស់ទៅ ។ គ្រានោះគេទៅកាន់រោងទានដោយគិតថា នឹងឱ្យទាន ត្រួតមើលទានហើយ ប្រើឱ្យអ្នកឱ្យបបរក្នុងវេលាបបរឱ្យរបស់ទំពាក្នុងវេលារបស់ទំពាឱ្យអាហារក្នុងវេលាអាហារហើយ ។ ព្រះពោធិសត្វបានឱ្យទានរាល់ ៗថ្ងៃដោយទំនងនេះឯង ។ ក៏ឯក្នុងរោងទាននេះ មិនមានពាក្យដែលនឹងគប្បីនិយាយថាឈ្មោះវត្តនេះមាន ឈ្មោះវត្តនោះមិនមាន ។ ទាននេះនឹងមិនចប់ដោយហេតុត្រឹមតែប៉ុណ្ណេះ ដូចនោះទើបឱ្យនាំមាសក្រហមចេញទៅធ្វើថាសមាសហើយបញ្ជូនដំណឹងទៅដល់ព្រះរាជា ៨៤,០០០ដើម្បីប្រយោជន៍ដល់ថាស ៨៤,០០០ ថាសជាដើម ។ ព្រះរាជាទាំងឡាយទ្រង់ត្រិះរិះថា យើងទាំងឡាយដែលអាចារ្យបានអនុគ្រោះមកយូរហើយដូច្នេះ ទើបទ្រង់ឱ្យចាត់ចែងវត្ថុទាំងពួងបញ្ជូនទៅឱ្យ ។ កាលវេលាមព្រាហ្មណ៍ឱ្យទានបែបនោះ កន្លងទៅហើយអស់ ៧ ឆ្នាំ ៧ខែ ។ គមកព្រាហ្មណ៍គិតថា យើងនឹងបែងចែកប្រាក់ចេញឱ្យទានដូច្នេះហើយទើបឱ្យចាត់ទានត្រៀមទុកក្នុងឱកាសដែលសម្គាល់គ្រាត្រៀមសម្រេចហើយ បានឱ្យថាសមាស

៨៤,០០០ ថាសមាស ពីដើមដល់ចុង ។

ក្នុងបទនោះ បទថា **ពេញដោយរូបិយៈ** (រូបិយបូរានិ) បានដល់ ពេញដោយថាសប្រាក់ ភាជនៈប្រាក់និងមាសកប្រាក់ ក៏ថាសទាំងឡាយអ្នកណា ៗ មិនគួរកំណត់ថាតូច ។ ថាស ៤ ស្លឹក តាំងនៅហើយក្នុងភូមិភាគកំណត់បានមួយកវីស ។ គុម្ព-ថាសជារតនៈ ៩ ។ តាំងពីកណ្តាប់មាត់ជារតនៈ ៨ ។ រថសេះអាជានេយ្យដែលប្រកបទុកព្រមហើយដើម្បីកណ្តាប់មាត់ថារមែងរត់វិលទៅជុំវិញ ។ បានឱ្យថាស ៨៤,០០០ ថាសយ៉ាងនេះគឺបានចាត់បដិគ្គាហកទុកជាពួក ៗ មានចុងបំផុតនៅខាងក្រៅ ជាក់ក្នុងថាសសម្រេចហើយ លើកបញ្ជូនឱ្យចំពោះគ្នាទៅចុងជួរ សូម្បីក្នុងបទជាដើមថា ថាសរូបិយៈ(រូបិយថាតិ)ក៏មាននយនេះដូចគ្នា ក៏សូម្បីក្នុងបទនេះបទថា **ពេញដោយមាស** (សុវណ្ណបូរានិ) បានដល់ ពេញដោយថាសមាសភាជនៈមាសនិងមាសកមាស ។

បទថា ពេញដោយប្រាក់ (ហិរញ្ញបូរានិ) បានដល់ ពេញដោយរតនៈ ៧ យ៉ាង ។

បទថា គ្រឿងប្រដាប់សុទ្ធតែមាស (សោវណ្ណាលង្ការានិ)

បានដល់ គ្រឿងប្រដាប់ជាមាស ។

បទថាមានភាជន:សំរឹតសម្រាប់ទទួលទឹកដោះ (កំសុ-បធារណានិ) បានដល់ ភាជន:ធ្វើដោយប្រាក់ទទួលទឹកដោះ ។ ចំណែកជើងទាំងពីររបស់មេគោទាំងឡាយនោះ បានពាក់ហើយដោយស្រោមមាសត្រង់កបានប្រដាប់ភួងផ្កាម្ទិះត្រង់ជើងទាំង ៤ បានប្រដាប់គ្រឿងប្រដាប់ជើង ត្រង់ខ្នងគ្របដោយសំពត់សាច់ល្អ យ៉ាងប្រសើរ ត្រង់កចងកន្ទឹងមាស ។

បទថា **សំពត់ ៨៤,០០ កោដិ** (វត្ថុកោដិសហស្សានិ) បានដល់សំពត់២០គូដែលគេតែងហៅថា ១ កោដិ តែក្នុងទីនេះ សំពត់ ១០ផ្ទាំង ។ ហៅថា ១ **កោដិ** ។ ក្នុងបទជាដើមថា ជាសំពត់សំបក់ឈើសាច់ល្អិត (**ខោមសុខុមានំ**) គប្បីជ្រាបវិនិច្ឆ័យដូច្នេះបណ្តាសំពត់សំបកឈើជាដើមសំពត់ណា ៗជាសំពត់មានសាច់ល្អិត បានឱ្យហើយទូវសំពត់នោះ ៗប៉ុណ្ណោះ ។ ចំណែកទានពួកណាដែលឃើញហើយថា មិនមែនជាទាន គឺ **ឥត្ថីទាន** (ការឱ្យស្ត្រីជាទាន) **ឧសភទាន** (ការឱ្យគោឧសុភ:ជាទាន) **មជ្ជទាន** (ការឱ្យទឹកស្រវឹងជាទាន) **សមជ្ជទាន** (ការឱ្យការលេងមហោស្រពជាទាន) វិលាមព្រាហ្មណ៍នេះបានឱ្យទានសូម្បីទាំង

នោះ សម្រាប់ជាបរិវារដើម្បីកាត់ពាក្យនិយាយថា ឈ្មោះថា វត្ថុនេះ ក្នុងហេតុនៃទានរបស់វេលាមៈ រមែងមិនមាន ។

បទថា **មជ្ឈេ មញ្ញេ វិសុទ្ធន្តិ** បានដល់ រមែងហូរទៅដូចទន្លេ ។

ព្រះសាស្តា ត្រាស់ទានរបស់វេលាមៈ ដោយហេតុប្រមាណប៉ុណ្ណោះហើយ ត្រាស់ថា ម្នាលគហបតី អ្នកជនៃមិនបានឱ្យហើយនូវមហាទាននោះ តថាគតបានឱ្យហើយ ក៏តថាគតសូម្បីកាលឱ្យទានបែបនោះ មិនបានបុគ្គលដែលសមគួរដើម្បីនឹងទទួលទេ លោកបានឱ្យទានកាលព្រះពុទ្ធ ដូចតថាគតប្រាកដនៅក្នុងលោក ព្រោះហេតុអ្វី ទើបគិតដូច្នេះហ្ន៎ កាលទ្រង់ទេសនាចេញឱ្យទូលាយដល់សេដ្ឋី ទើបបានត្រាស់ពាក្យជាដើមថា **សិយា ខោ បន តោ** ដូច្នេះ ។

សួរថា ក៏រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ពួកណាបានមានហើយក្នុងកាលនោះ រូបជាដើមទាំងនោះ រលត់ហើយ មិនមែន ឬព្រោះហេតុអ្វី ព្រះមានព្រះភាគទើបត្រាស់ថា សមយៃនោះ តថាគតជាព្រាហ្មណ៍ឈ្មោះ **វេលាមៈ** ដូច្នេះ ។

ឆ្លើយថា ព្រោះកាត់ប្រពៃណីមិនដាច់ ។ ដោយថារូបជាដើមទាំងនោះ កាលរលត់ឱ្យបច្ច័យដល់ធម៌ មានវេទនាជាដើមទាំងនេះហើយ ទើបរលត់ ព្រះមានព្រះភាគត្រាស់យ៉ាងនេះ សំដៅដល់ប្រពៃណី (គឺធម៌) ដែលបន្តគ្នាមិនដាច់ ។

បទថា **ន តំ កោចិ ទក្ខិណំ សោធេតិ** សេចក្តីថា មិនមានអ្នកណា ៗ គប្បីពោលថា អ្នកណាជាសមណៈ ឬព្រាហ្មណ៍ ទេវតា ឬមារ ក្រោកឡើងហើយ រមែងជម្រះទក្ខិណាឱ្យបរិសុទ្ធិ ។ ក៏ដោយខ្ពស់បំផុតព្រះពុទ្ធគប្បីជម្រះទក្ខិណានោះឱ្យបរិសុទ្ធិ ។

បទថា **ទិដ្ឋិសម្បន្នំ** បានដល់ លោកជាសោតាបន្ន ដល់ព្រមដោយទស្សនៈ (សោតាបត្តិមគ្គ) ។

បទថា **ឥទំ តតោ មហប្ផលតរំ** សេចក្តីថា ទានដែលឱ្យហើយដល់លោកអ្នកជាសោតាបន្ននេះ មានផលច្រើនជាងទានដែលបុគ្គលបរិច្ចាគច្រាក់និងមាសប្រមាណប៉ុណ្ណេះឱ្យហើយដល់លោកិយមហាជនអស់ ៧ ឆ្នាំ ៧ ខែ ។

ក៏ក្នុងបទនេះថា **យោ ច សតំ ទិដ្ឋិសម្បន្នានំ** សេចក្តីថា គប្បីជ្រោបការវាប់សោតាបន្នដល់លោកអ្នកជា សោតាបន្នលើស

មួយរយនាក់ទៅ ដោយអំណាចលោកអ្នកជាសកទាគាមីម្នាក់ ។ ដោយឱ្យបាយនេះ គប្បីជ្រាបការរាប់បុគ្គលដល់នឹងគុណដោយរយ ដោយលំដាប់ដែលលើសហើយក្នុងកាលក្រោយក្នុងវារៈទាំងពួង ។

ក្នុងបទថា ពុទ្ធប្បមុខំ នេះសង្ឃធ្វើព្រះសម្មាសម្ពុទ្ធជាព្រះសង្ឃត្រេអង្គុយហើយ គប្បីជ្រាបថា សង្ឃមានព្រះពុទ្ធជាប្រធានដូច្នេះ ។ ក្នុងបទនេះថា ចាតុទ្ទិសំ សច្ឆំ ឧទ្ទិស្ស សេចក្តីថា ចេតិយរមែងប្រតិស្ឋាននៅការស្តាប់ ធម៌ពួកគេរមែងធ្វើក្នុងទីដែលមានវិហារដែលបុគ្គលសាងថ្វាយសង្ឃដែលមកពីទិសទាំង ៤ ភិក្ខុទាំងឡាយមកពីទិសទាំង ៤ និងអំពីទិសតូចហើយ មិនត្រូវសាកសួរលាងជើងហើយយកសោរបើកទ្វារធ្វើការជម្រះសេនាសនៈ សម្រេចនៅហើយរមែងបាននូវសេចក្តីសុខវិហារនោះដោយហោចទៅសូម្បីជាបណ្ណសាលា ដែលកើតដល់ខ្នងនៅក្នុង ៤ ទិស គេក៏ហៅថាវិហារដែលបុគ្គលសាងថ្វាយសង្ឃដែលមកពីទិសទាំង ៤ ដូចគ្នា ។

សរណាំគច្ចេយ្យាតិ ឯត្ថមគ្គេនាគតំអនិវត្តនសរណាំ អធិប្បេតំ ។ អបរេ បនាហុ អត្តានំ និយ្យាទេត្វា និច្ចត្តា

សរណាគមនំ តតោ មហប្ផលតរន្តិ វុត្តំ ។

ក្នុងបទនេះថា សរណំ គច្ឆេយ្យ លោកសំដៅដល់សរណៈ ដែលមិនត្រឡប់មកហើយដោយមគ្គ ។ ចំណែកអាចារ្យមួយពួកទៀតពោលថា ឈ្មោះសរណគមន៍ ព្រោះប្រគល់ខ្លួនឱ្យហើយ លោកអធិប្បាយថាមានផលច្រើនជាងទាននោះ ។

សិក្ខាបទានិ សមាទិយេយ្យាតិ បញ្ច សីលានិ គណ្ហេយ្យ ។ សីលម្បិ មគ្គេន អាគតំ អនិវត្តនសីលមេវ កថិតំ ។ អបរេ បនាហុ សព្ពសត្តានំ អភយទានស្ស ទិន្នត្តា សីលំ តតោ មហប្ផលតរន្តិ វុត្តំ ។

បទថា សិក្ខាបទំ សមាទិយេយ្យ បានដល់ គប្បីទទួលបញ្ចសីល ។ សូម្បីសីល លោកពោលសំដៅយកសីលដែលមិនត្រឡប់ប៉ុណ្ណោះ ដែលមកហើយក្នុងមគ្គ ។ ចំណែកអាចារ្យមួយពួកទៀតពោលថា ឈ្មោះថា សីល ព្រោះខ្លួនឱ្យអភ័យទានហើយដល់សត្វទាំងពួង លោកអធិប្បាយថា មានផលច្រើនជាងសរណគមន៍នោះ ។

គន្ធោហនមត្តន្តិ គន្ធូហនមត្តំ, ទ្វីហគ្គុលីហិគណ្ហបិណ្ឌំ

គហេត្វា ឧបសិច្ឆនមត្តំ ។ អបរេ បន "គន្ធោហនមត្ត"ន្តិ បាឡិ វត្វា គាវិយា ឯកវារំ ជនអញ្ជនមត្តន្តិ អត្ថំ វទន្តិ ។

បទថា គន្ធោហនមត្តំ បានដល់ ត្រឹមតែគ្រែរវែកក្នុងរបស់ក្រអូប គឺត្រឹមតែយកម្រាមទាំងពីរចាប់ដុំបាយក្រអូបចូលមក ។ ចំណែកអាចារ្យមួយពួកទៀតពោលព្រះបាលីថា គោធោហន-មត្តំ ហើយទើបបានពោលអត្ថន័យថា ត្រឹមតែទឹកដោះតំណក់តែមួយរបស់មេគោ ។

មេត្តចិត្តន្តិ សព្វសត្តានំ ហិតានុជ្ឈាណចិត្តំ ។ តំ បន អប្បនាវសេនេវ តហិតំ ។អនិច្ចសញ្ញន្តិមគ្គស្ស អនន្តរបច្ចយ-ភាវេន សិខាបត្តពលវិបស្សនំ ។

បទថា មេត្តចិត្តំ បានដល់ ចិត្តដែលផ្សាយតាមទៅប្រយោជន៍ដល់សត្វទាំងពួងទាំងឡាយ ។ តែចិត្តនោះលោកកាន់យកហើយដោយអំណាចអប្បនាប៉ុណ្ណោះ ។

បទថា អនិច្ចសញ្ញំ បានដល់ វិបស្សនាដែលមានកម្លាំងដល់ទីបំផុត ដោយសេចក្តីជាអនន្តរប្បច្ច័យដល់មគ្គ ។

ដីកា មគ្គេនាគតំអនិវត្តនសរណន្តិ ឥមិនា លោកុត្តរ-
សរណាគមនំ ទីបេតិ ។អបរេតិអាទិនា លោកិយសរណាគមនំ
វុត្តំ ។សរណំ នាម តិណ្ណំ រតនានំ ជីវិតបរិច្ចាគមយំ បុញ្ញំ
សព្ភសម្បត្តីនេតិ, តស្មា មហាបួលតរន្តិ អធិប្បាយោ ។ ឥទញ្ច
"សចេ តុំ យថា គហិតំ សរណំ ន ភិន្ទិស្សសិ, ឯវាហំ តំ
មារេមីៈតិ យទិបិ កោចិ តិណ្ហេន សត្ថេន ជីវិតា វោរោបេយ្យ,
តថាបិ "នេវាហំ ពុទ្ធំ ន ពុទ្ធោតិ, ធម្មំ ន ធម្មោតិ, សង្ឃំ ន
សង្ឃោតិ វទាមីៈតិ ឧទ្ធដំ កត្វា គហិតស្ស វសេន វុត្តំ ។

មគ្គេនាគតន្តិ លោកុត្តរសីលំ សន្ធាយ វទតិ ។អបរេ-
តិអាទិនា បន លោកិយសីលំ វុត្តំ ។ សព្ពេសំ សត្តានំ ជីវិត-
ធនាធនិនិហិតធណ្ឌតាយ សកលលោកិយលោកុត្តរគុណា-
ធិដ្ឋានតោ ចស្ស មហាបួលមហានិសំសតាវេទិតព្ពា ។

ឧបសិច្ឆនមត្តន្តិ ឃាយនមត្តំ ។ គន្ធោហនមត្តន្តិ បាថន្តរេ
គោធោហនមត្តំ កាលន្តិ អត្ថោ ។ សោ ច ន សកលោ
គោធោហនក្ខណោ អធិប្បេតោតិ ទស្សេតុំ "គាវិយា ឯកវារំ
ថនអញ្ជនមត្ត"ន្តិ អត្ថោ វុត្តោ ។ អញ្ជនមត្តន្តិ អាកឌ្ឍនមត្តំ ។

គាវិយោ ឯតំ គហេត្វា ឯកខីរពិន្ទុម្បិ ទានកាលមត្តម្បិ គណ្ហន្តមត្តន្តិ វទន្តិ ។ ឯត្តកម្បិ ហិ កាលំ យោ វសន គព្ភបរិវេណវិហារូបចារបរិច្ចេទេន វា អបរិមាណាសុ លោកធាតូសុ សព្វសត្តេ ហិតជវណំ មេត្តចិត្តំ ភាវេតុំ សក្កោតិ ។ ឥទំ តតោ យថាវុត្តទានាធិតោ មហាបលតរំ ។

អដ្ឋកថា

ចំណែកបុណ្យទាំងឡាយ មានទានជាដើមទាំងនេះ គប្បីជ្រាបដោយឧបមាយ៉ាងនេះ ។ ក៏សូម្បីបើថា គេធ្វើជម្ពូទ្វីបឱ្យជាផែនដីស្មើគ្នា ដូចនឹងមុខស្គរ ក្រាលបល្ល័ង្ក តាំងពីដើមហើយ គប្បីឱ្យព្រះអរិយបុគ្គលអង្គុយក្នុងទីនោះ មានសោតាបន្នបុគ្គល ១០ជួរ, សកទាគាមីបុគ្គល ៥ ជួរ,អនាគាមីបុគ្គលពីរជួរកន្លះ, ព្រះខីណាស្រពមួយជួរកន្លះ ព្រះបច្ចេកពុទ្ធគប្បីមានមួយជួរ,ព្រះសម្មាសម្ពុទ្ធព្រះអង្គតែមួយប៉ុណ្ណោះ ទានដែលបុគ្គលថ្វាយចំពោះព្រះសម្មាសម្ពុទ្ធ មានផលច្រើនជាងទានដែលថ្វាយហើយដល់ជនប្រមាណប៉ុណ្ណោះ ។ ចំណែកទានក្រៅនេះ ។

វិហារទានំ បណិធាតោ សិក្ខា មេត្តាយ ភាវនាឲយតោ សម្មសន្តស្ស កលំ ឆាគ្ឃតិ សោឡសឹ ។

គឺវិហារទានបិណ្ឌបាតសិក្ខា ការចម្រើនមេត្តារមែងមិនដល់ចំណែកទី១៦ របស់អ្នកពិចារណាដោយការអស់ទៅ ។

តេនេវភគវាបរិនិព្វានសមយេ"ធម្មានុធម្មប្បដិបត្តិ អនុត្តរា បូជា"តិ អាហ ។ ដោយហេតុនោះឯង ព្រះមានព្រះភាគ ទើបបានត្រាស់ទុកក្នុងសម័យបរិនិព្វានថា ការបដិបត្តិធម៌សមគួរដល់ធម៌ ជាការបូជាខ្ពស់បំផុត ដូច្នេះ ។

សង្ឃទាន

នៅក្នុងព្រះពុទ្ធសាសនាយើងនេះ មានទានមួយឈ្មោះថា សង្ឃទាន គឺជាទានដែលគេធ្វើឧទ្ទិសចំពោះសង្ឃដែលមានព្រះពុទ្ធជាប្រធាន ។ ការធ្វើថ្វាយទានឧទ្ទិសចំពោះសង្ឃមានព្រះពុទ្ធជាប្រមុខនេះ មានផលានិសង្សច្រើនជាងការធ្វើទានជាមួយបុគ្គលឧទ្ទិសចំពោះបុគ្គលម្នាក់ ៗ ដូចជាព្រះអង្គទ្រង់ត្រាស់ថា **ទក្ខិណាទានដែលទាយក ជានកំណត់គុណរបស់សមណព្រាហ្មណ៍ទាំងឡាយ អ្នកមានគុណ ហើយញ៉ាំងចិត្តឱ្យជ្រះថ្លា ញ៉ាំងចេតនាទាំង៣ឱ្យផូរផង់ សង្ឃីមការកើតឡើងនៃផលហើយទើបឱ្យទាន រមែងមានផលមិនតិច គឺរមែងជានសម្រេចនូវមហាសម្បត្តិ(រាជសម្បត្តិ)**

ក្នុងទីដែលកើតហើយ ។ ដូច្នេះសបញ្ជាក់ឱ្យឃើញថា ការធ្វើទានដោយឧទ្ទិសចំពោះសង្ឃនេះ មានអានិសង្សច្រើនណាស់ ដូចមានព្រះសូត្រខាងក្រោម ។

ឧរុកម្ភិកសូត្រ

នៅក្នុងបិដកលេខ ៤៦ ទំព័រ ២២៣ ព្រះមានព្រះភាគជាម្ចាស់ **ទ្រង់សម្តែងសរសើរសង្ឃទាន** ដែលមានសេចក្តីថា ៖

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងប្រាសាទដែលធ្វើអំពីឥដ្ឋក្នុងនាទិកគ្រាម ។ គ្រានោះឯង គហបតីឈ្មោះឧរុកម្ភិក បានចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះឧរុកម្ភិកគហបតីអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា **ម្នាលគហបតី ចុះទានក្នុងត្រកូលអ្នកតែងឱ្យដែរឬ ។** ឧរុកម្ភិកគហបតី ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន **ទានក្នុងត្រកូលខ្ញុំព្រះអង្គតែងឱ្យ** បពិត្រព្រះអង្គដ៏ចម្រើន តែថា **ទាននោះខ្ញុំព្រះអង្គឱ្យចំពោះតែពួកភិក្ខុ ដែលជាអ្នកប្រព្រឹត្តអរញ្ញិកធុតង្គ ប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ប្រព្រឹត្តបំសុកូលិកធុតង្គ**

ជាព្រះអរហន្ត ឬភិក្ខុដែលដល់នូវអរហត្តមគ្គប៉ុណ្ណោះ ។

ម្នាលគហបតី ខ្ញុំអ្នកជាគ្រហស្ថ ជាអ្នកបរិភោគកាម នៅគ្រប់គ្រងដំណែកដ៏ចង្អៀតដោយកូនប្រពន្ធ ប្រើប្រាស់នូវខ្លឹមចន្ទន៍ដ៏ល្អិត ទ្រទ្រង់នូវកម្រងផ្កា គ្រឿងក្រអូបនឹងគ្រឿងលាប ត្រេកអរនូវមាសនឹងប្រាក់ កម្រនឹងដឹងហេតុនេះថា ភិក្ខុទាំងនេះ ជាព្រះអរហន្តឬភិក្ខុទាំងនេះ បានដល់នូវអរហត្តមគ្គដូច្នេះបានឡើយ ។ ម្នាលគហបតី បើទុកណាជាភិក្ខុអ្នកប្រព្រឹត្តអរញ្ញិកធុតង្គ ប៉ុន្តែមានចិត្តរាយមាយ ជាអ្នកលើកំពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានសម្តីផ្តេសផ្តាស ជាអ្នកភ្លេចស្មារតី មិនមានសម្បជញ្ញៈ មិនមានចិត្តតាំងមាំ មានចិត្តវិលវុល មិនមានឥន្ទ្រិយជាប្រក្រតី កាលបើយ៉ាងនេះ ភិក្ខុនោះ គួរគេតិះដៀលដោយហេតុនោះបាន ។

ម្នាលគហបតី បើទុកណាជាភិក្ខុអ្នកប្រព្រឹត្តអរញ្ញិកធុតង្គ ប៉ុន្តែមិនជាអ្នកមានចិត្តរាយមាយ ជាអ្នកមិនលើកំពស់ មិនមានចិត្តឃ្លេងឃ្លោង មិនមានមាត់រឹង មិនមានសម្តីផ្តេសផ្តាស មានស្មារតីខ្ជាប់ខ្ជួន មានសម្បជញ្ញៈ មានចិត្តតាំងមាំ មានចិត្តមូលតែមួយជាអ្នកសង្រួមឥន្ទ្រិយកាលបើយ៉ាងនេះភិក្ខុនោះគួរគេសរសើរ

ដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកក្នុងសេនាសនៈជិតស្រុក ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះគួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកនៅក្នុងសេនាសនៈជិតស្រុក ប៉ុន្តែជាអ្នកមិនមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះគួរសរសើរដោយហេតុនោះបាន ។

ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះគួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាតិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តមិនរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះគួរសរសើរដោយហេតុនោះបាន ។

ម្នាលគហបតី បើទុកជាភិក្ខុអ្នកទទួលនិមន្តគេ ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះគួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកទទួលនិមន្តគេប៉ុន្តែជាអ្នកមិនមានចិត្តរាយមាយ ។បេ។ កាល

បើយ៉ាងនេះ ភិក្ខុនោះគួរសរសើរដោយហេតុនោះបាន ។

ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបំសុកូលិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះគួរតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកប្រព្រឹត្តបំសុកូលិកធុតង្គ ប៉ុន្តែជាអ្នកមានចិត្តមិនរាយមាយ ។បេ។ កាលបើយ៉ាងនេះ ភិក្ខុនោះគួរសរសើរដោយហេតុនោះបាន ។

ម្នាលគហបតីបើទុកជាភិក្ខុទ្រទ្រង់នូវគហបតីចីវរ ប៉ុន្តែជាអ្នកមានចិត្តរាយមាយ ជាអ្នកលើកំពស់ មានចិត្តឃ្លេងឃ្លោង មានមាត់រឹង មានសម្តីផ្តេសផ្តាស ជាអ្នកភ្លេចស្មារតី មិនមានសម្បជញ្ញៈ មិនមានចិត្តតាំងមាំ មានចិត្តវិលវុល មិនមានឥន្ទ្រិយជាប្រក្រតី កាលបើយ៉ាងនេះ ភិក្ខុនោះ គួរគេតិះដៀលដោយហេតុនោះបាន ។ ម្នាលគហបតី បើទុកជាភិក្ខុអ្នកទ្រទ្រង់នូវគហបតីចីវរ ប៉ុន្តែជាអ្នកមិនមានចិត្តរាយមាយ មិនជាអ្នកមិនលើកំពស់ មិនមានចិត្តឃ្លេងឃ្លោង មិនមានមាត់រឹង មិនមានសម្តីផ្តេសផ្តាស មានស្មារតី ខ្ជាប់ខ្ជួន មានសម្បជញ្ញៈ មានចិត្តតាំងមាំ មានចិត្តមូលតែមួយ ជាអ្នក

សង្រ្គមឥន្ទ្រិយ កាលបើយ៉ាងនេះ ភិក្ខុនោះ គួរគេសរសើរដោយហេតុនោះបាន ។

ម្នាលគហបតី **អញ្ចើញអ្នកឱ្យទានចំពោះសង្ឃវិញ កាលបើអ្នកឱ្យទានចំពោះសង្ឃវិញ ចិត្តរមែងជ្រះថ្លា លុះអ្នកនោះមានចិត្តជ្រះថ្លាហើយ គ្រាបែកធ្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ទារុកម្មិកគហបតីក្រាបបង្គំទូលថា** បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមអំពីថ្ងៃនេះទៅ ខ្ញុំព្រះអង្គហ្នឹងឯង នឹងឱ្យទានចំពោះសង្ឃវិញ ។

ទក្ខិណាវិភង្គសូត្រ

នៅក្នុងបិដកលេខ ២៨ ទំព័រ ២១៤ ព្រះមានព្រះភាគជាម្ចាស់ **ទ្រង់សម្តែងអំពីការថ្វាយសំពត់ជល់បុគ្គល ១៤ ប្រភេទ** ដែលមានសេចក្តីថា ៖

ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលព័ស្តុ ក្នុងដែនសក្កៈ ។ គ្រានោះ ព្រះនាងមហាបជាបតិគោតមី នាំយកសំពត់ថ្មី ១គូចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយ

បង្គំព្រះមានព្រះភាគ ហើយគង់នៅក្នុងទីសមគួរ ។ លុះព្រះនាងមហាបជាបតិគោតមី គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ប្ដី ១ គូនេះ ខ្ញុំម្ចាស់វៃខ្លួនឯង ត្បាញខ្លួនឯង ផ្គងចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ អាស្រ័យនូវសេចក្ដីអនុគ្រោះចំពោះខ្ញុំម្ចាស់ទទួលយកសំពត់នោះ ។

[ការអង្វរករនៃនាងមហាបជាបតិគោតមី]

កាលបើព្រះនាងមហាបជាបតិគោតមី ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះមានព្រះភាគក៏មានព្រះបន្ទូលនឹងព្រះនាងមហាបជាបតិគោតមីដូច្នេះថា បពិត្រព្រះនាងគោតមី សូមព្រះនាងប្រគេន(សម្ពត់នេះ)ចំពោះសង្ឃវិញចុះ កាលបើព្រះនាងប្រគេន(សម្ពត់នេះ)ចំពោះសង្ឃហើយ **តថាគតឈ្មោះថា ព្រះនាងបានបូជាហើយផង ទាំងសង្ឃក៏ឈ្មោះថា ព្រះនាងបានបូជាហើយដែរ ។** ព្រះនាងមហាបជាបតិគោតមី ក្រាបបង្គំទូលអង្វរព្រះមានព្រះភាគអស់វារៈពីរដង ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ប្ដី ១ គូនេះ ខ្ញុំម្ចាស់វៃខ្លួនឯង ត្បាញខ្លួនឯង ឧទ្ទិសចំពោះ

ព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ
អាស្រ័យនូវសេចក្តីអនុគ្រោះចំពោះខ្ញុំម្ចាស់ ទទួលយកសំពត់នោះ ។
ព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលនឹងព្រះនាងមហាបជាបតិ-
គោតមីអស់វារៈពីរដូច្នេះថា បពិត្រព្រះនាងគោតមី សូមព្រះនាង
ប្រគេនសង្ឃវិញចុះ កាលបើព្រះនាងប្រគេនសង្ឃហើយ តថាគត
ក៏ឈ្មោះថាព្រះនាងបានបូជាហើយផង ទាំងសង្ឃក៏ឈ្មោះថា ព្រះ
នាងបានបូជាហើយដែរ ។ ព្រះនាងមហាបជាបតិគោតមី ក្រាប
បង្គំទូលព្រះមានព្រះភាគអស់វារៈបីដងដូច្នេះថា បពិត្រព្រះអង្គដ៏
ចម្រើន សំពត់ថ្មី១គូនេះខ្ញុំម្ចាស់វៃខ្លួនឯង តា្បញខ្លួនឯង ឧទ្ទិស
ចំពោះព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះ
ភាគអាស្រ័យនូវសេចក្តីអនុគ្រោះចំពោះខ្ញុំម្ចាស់ ហើយទទួលយក
នូវសំពត់នោះ ។ ព្រះមានព្រះភាគទ្រង់មានព្រះបន្ទូលនឹងព្រះ
នាងមហាបជាបតិគោតមី អស់វារៈបីដងដូច្នេះថា បពិត្រព្រះនាង
គោតមី សូមព្រះនាងប្រគេនសង្ឃហើយ តថាគតក៏ឈ្មោះថា
ព្រះនាងបានបូជា ហើយផងទាំងសង្ឃក៏ឈ្មោះថា ព្រះនាងបាន
បូជាហើយដែរ ។

[កិរិយាអង្វរការនៃព្រះអានន្ទ]

កាលបើព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាយ៉ាងនេះ ហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលអង្វរព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគទ្រង់ទទួល សំពត់ថ្មី ១ គូ របស់ព្រះនាងមហាបជាបតិគោតមី បពិត្រព្រះអង្គ ដ៏ចម្រើន ព្រះនាងមហាបជាបតិគោមី ជាអ្នកឧបការៈច្រើន ជា មាតុច្ឆារបស់ព្រះមានព្រះភាគ ជាអ្នកថែរក្សា អ្នកចិញ្ចឹម អ្នកថ្វាយ ទឹកក្សីរ កាលមាតុច្ឆាបង្កើតព្រះមានព្រះភាគទ្រង់ទិវង្គតទៅ នាង បានបំបៅទឹកដោះ បពិត្រព្រះអង្គដ៏ចម្រើន សូម្បីព្រះមានព្រះភាគ ក៏មានឧបការៈច្រើនដល់ព្រះនាងមហាបជាបតិគោតមីដែរ បពិត្រ ព្រះអង្គដ៏ចម្រើន ព្រោះព្រះនាងមហាបជាបតិគោតមី អាស្រ័យ ព្រះមានព្រះភាគ ទើបបានដល់នូវព្រះពុទ្ធជាទីពឹង បានដល់នូវព្រះ ធម៌ជាទីពឹង បានដល់នូវព្រះសង្ឃជាទីពឹង បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមី អាស្រ័យព្រះមានព្រះភាគ ទើប បានជាអ្នកវៀរចាកការសម្លាប់សត្វ វៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឱ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ

វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមី អាស្រ័យព្រះមានព្រះភាគ ទើបប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃ ប្រកបដោយសីលទាំងឡាយ ដែលជាទីត្រេកអរនៃព្រះអរិយបុគ្គលទាំងឡាយ បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមី អាស្រ័យនូវព្រះមានព្រះភាគ ទើបជាអ្នកអស់សង្ស័យក្នុងទុក្ខ អស់សង្ស័យក្នុងហេតុនាំឱ្យកើតទុក្ខ អស់សង្ស័យក្នុងធម៌រំលត់ទុក្ខ អស់សង្ស័យក្នុងសេចក្តីប្រតិបត្តិទៅកាន់ទីរំលត់ទុក្ខ បពិត្រព្រះអង្គដ៏ចម្រើន សូម្បីព្រះមានព្រះភាគក៏មានឧបការៈច្រើនដល់ព្រះនាងមហាបជាបតិគោតមីដែរ ។

[កិរិយាមិនមែនជាការតបស្នងដោយល្អ]

ព្រះមានព្រះភាគទ្រង់ត្រាស់ថា អើយ៉ាងហ្នឹងហើយ អានន្ទ អើយ៉ាងហ្នឹងហើយ អានន្ទ ម្នាលអានន្ទ បុគ្គលអាស្រ័យបុគ្គលណា ទើបបានដល់ព្រះពុទ្ធជាទីពឹង បានដល់នូវព្រះធម៌ជាទីពឹង

បានដល់នូវព្រះសង្ឃជាទីពឹង ម្នាលអានន្ទ តថាគតមិនសម្តែងនូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម និងការឱ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់អ្នកជម្ងឺថា ជាកម្មដែលបុគ្គលនេះ តបស្នងដល់បុគ្គលនេះបានដោយល្អឡើយ ។

ម្នាលអានន្ទ មួយទៀត បុគ្គលអាស្រ័យនូវបុគ្គលណា ហើយបានវៀរចាកការសម្លាប់សត្វ វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឱ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ វៀរចាកការនិយាយកុហក វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទគឺការផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ម្នាលអានន្ទ តថាគតមិនសម្តែងនូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម និងការឱ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់អ្នកជម្ងឺថា ជាកម្មដែលបុគ្គលនេះតបស្នងដល់បុគ្គលនេះបានដោយល្អឡើយ ។

ម្នាលអានន្ទ មួយទៀត បុគ្គលអាស្រ័យនូវបុគ្គលណា ហើយបានប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះពុទ្ធប្រកប

ដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះធម៌ ប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើកក្នុងព្រះសង្ឃ ប្រកបដោយសីលទាំងឡាយ ដែលជាទីត្រេកអរនៃព្រះអរិយបុគ្គល ម្នាលអានន្ទ តថាគតមិនសម្តែងនូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម និងការឱ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់អ្នកជម្ងឺ ថាជាកម្មដែលបុគ្គលនេះ តបស្នងដល់បុគ្គលនេះបានដោយល្អឡើយ ។

ម្នាលអានន្ទ មួយទៀត បុគ្គលអាស្រ័យនូវបុគ្គលណាហើយ ជាអ្នកអស់សង្ឃឹយក្នុងទុក្ខ អស់សង្ឃឹយក្នុងហេតុនាំឱ្យកើតទុក្ខ អស់សង្ឃឹយក្នុងធម៌រំលត់ទុក្ខ អស់សង្ឃឹយក្នុងសេចក្តីប្រតិបត្តិទៅកាន់ទីរំលត់ទុក្ខ ម្នាលអានន្ទ តថាគតមិនសម្តែងនូវការថ្វាយបង្គំ ការក្រោកទទួល អញ្ជលិកម្ម សាមីចិកម្ម និងការឱ្យនូវចីវរ បិណ្ឌបាត សេនាសនៈ និងភេសជ្ជបរិក្ខារជាបច្ច័យដល់អ្នកជម្ងឺ ថាជាកម្មដែលបុគ្គលនេះ តបស្នងដល់បុគ្គលនេះ បានដោយល្អឡើយ ។

[សេចក្តីផ្សេងគ្នានៃទក្ខិណាទាន]

ម្នាលអានន្ទ ចាជិបុគ្គលិកាទក្ខិណា(ទានដែលឱ្យចំពោះបុគ្គល)នេះមាន ១៤ យ៉ាងគឺ ៖

- បុគ្គលឱ្យទានចំពោះព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ នេះជាចាជិបុគ្គលិកាទក្ខិណាទី ១

- ឱ្យទានចំពោះព្រះបច្ចេកពុទ្ធ នេះជាចាជិបុគ្គលិកាទក្ខិ-ណាទី ២

- ឱ្យទានចំពោះព្រះអរហន្ត ជាសាវ័កបស់ព្រះតថាគត នេះជាចាជិបុគ្គលិកាទក្ខិណាទី ២

- ឱ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវអរហត្តផល នេះជាចាជិបុគ្គលិកាទក្ខិណាទី ៤

- ឱ្យទានចំពោះអនាគាមិបុគ្គល នេះជាចាជិបុគ្គលិកាទក្ខិ-ណាទី ៥

- ឱ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវអនាគាមិផល នេះជាចាជិបុគ្គលិកាទក្ខិណាទី ៦

- ឱ្យទានចំពោះសកទាគាមិបុគ្គល នេះជាចាជិបុគ្គលិកា-ទក្ខិណាទី ៧

- ឱ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសកទាគាមិផល នេះជាបាដិបុគ្គលិកាទក្ខិណាទី ៨

- ឱ្យទានចំពោះសោតាបន្នបុគ្គល នេះជាបាដិបុគ្គលិកាទក្ខិណាទី ៩

- ឱ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល[1] នេះជាបាដិបុគ្គលិកាទក្ខិណាទី ១០

- ឱ្យទានចំពោះអ្នកបួសខាងក្រៅ(ពុទ្ធសាសនា) ដែលបានប្រាសចាកតម្រេកក្នុងកាម[2]ទាំងឡាយ នេះជាបាដិបុគ្គលិកាទក្ខិណាទី ១១

- ឱ្យទានចំពោះបុថុជ្ជនមានសីល នេះជាបាដិបុគ្គលិកាទក្ខិណាទី ១២

---

[1] អដ្ឋកថា: សូម្បីឧបាសកដល់សរណាគមន៍ ៣ក្តី កាន់សីល ៥ ក្តី សីល ១០ ក្តី សាមណេរ ឬភិក្ខុដែលទើបនឹងបួសបាន ១ ថ្ងៃក្តី ភិក្ខុអ្នកមានវត្តប្រតិបត្តិដែលយូរហើយក្តី ភិក្ខុទ្រទ្រង់វិបស្សនាក្តី ទាំងអស់នេះ ឈ្មោះថាប្រតិបត្តិធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល ។

[2] សំដៅយកពួកអ្នកជាកម្មវាទី កិរិយវាទី ដែលបានអភិញ្ញាជាលោកីយ៍ទាំង ៥ ។

- ឱ្យទានចំពោះបុថុជ្ជនទ្រុស្តសីល នេះជាបាដិបុគ្គលិកា-ទក្ខិណាទី ១៣

- ឱ្យទានចំពោះសត្វតិរច្ឆាន នេះជាបាដិបុគ្គលិកាទក្ខិណាទី ១៤ ។

[អានិសង្សរបស់បាដិបុគ្គលិកាទក្ខិណា ១៤ យ៉ាងគឺ]

១- ម្នាលអានន្ទ បណ្តាបុគ្គលអ្នកទទួលទានទាំងនោះ ទក្ខិណាមានគុណមួយរយ[1] ដែលបុគ្គលត្រូវបាន ព្រោះឱ្យទានចំពោះសត្វតិរច្ឆាន ។

២- ទក្ខិណាមានគុណមួយពាន់ ដែលបុគ្គលត្រូវបាន ព្រោះឱ្យចំពោះបុថុជ្ជនទ្រុស្តសីល ។

៣- ទក្ខិណាមានគុណមួយសែន ដែលបុគ្គលត្រូវបាន ព្រោះឱ្យចំពោះបុថុជ្ជនមានសីល ។

---

[1] អដ្ឋកថា ឱ្យនូវអានិសង្ស ១០០ គឺ ១០០ អត្តភាព ក្នុងអត្តភាពមួយ ៗ មានអាយុវែង ១, សម្បុរល្អ ១, សេចក្តីសុខ ១, កម្លាំង ១, ប្រាជ្ញា ១, រួមជាអានិ-សង្ស ៥០០ ។ ទានក្រៅពីសត្វតិរច្ឆានក៏គុណជាច្រាំ ៗតាមនុបាយនេះដែរ ។

៤- ទក្ខិណាមានគុណមួយសែនកោដិ ដែលបុគ្គលត្រូវបាន ព្រោះឱ្យចំពោះអ្នកបួសខាងក្រៅ ដែលប្រាសចាកតម្រេកក្នុងកាមទាំងឡាយ ។

៥-ទក្ខិណាមានគុណរាប់មិនបាន ប្រមាណមិនកើតដែលបុគ្គលត្រូវបាន ព្រោះឱ្យទានចំពោះបុគ្គលដែលធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល ។

៦- នឹងចាំបាច់និយាយទៅថ្វី(ដល់ទក្ខិណាដែលបុគ្គលឱ្យ) ចំពោះសោតាបន្នបុគ្គល ។

៧- នឹងនិយាយទៅថ្វី ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសកទាគាមីផល ។

៨- នឹងនិយាយទៅថ្វី ចំពោះសកទាគាមីផល ។

៩- នឹងនិយាយទៅថ្វី ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវអនាគាមីផល ។

១០- នឹងនិយាយទៅថ្វី ចំពោះអនាគាមិផល ។

១១- នឹងនិយាយទៅថ្វី ចំពោះបុគ្គលអ្នកប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវអរហត្តផល ។

១២- នឹងនិយាយទៅថ្វី ចំពោះអរហន្តសាវ័ក របស់តថាគត ។

១៣- នឹងនិយាយទៅថ្វី ចំពោះព្រះបច្ចេកពុទ្ធ ។

១៤- នឹងនិយាយទៅថ្វី ចំពោះព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ។

[សង្ឃគតាទក្ខិណាទាន ៧ យ៉ាង]

ម្នាលអានន្ទ សង្ឃគតាទក្ខិណា (**ទានដែលតម្កល់ក្នុងសង្ឃ**)នេះមាន ៧ យ៉ាង ។

- បុគ្គលឱ្យទានចំពោះសង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រធាន[1] នេះជាសង្ឃគតាទក្ខិណាទី ១ ។

---

[1] សង្ឃទាំងពីរចំណែក គឺពួកភិក្ខុសង្ឃអង្គុយម្ខាង ពួកភិក្ខុនីសង្ឃ សង្ឃអង្គុយម្ខាង ព្រះសាស្តាជាម្ចាស់គង់ត្រង់កណ្តាល ដូច្នេះហៅថា សង្ឃទាំងពីរចំណែកមានព្រះពុទ្ធជាប្រធាន ។ សង្ឃគតាទក្ខិណាទី ១ នេះ គ្មានទក្ខិណាណាវិសេសស្មើឡើយ ។ ប៉ុន្តែកាលព្រះសាស្តាបរិនិព្វានទៅហើយនោះ គេដម្កល់ព្រះពុទ្ធប្បដិមា ឬព្រះធាតុលើអាសនៈក្នុងទីចំពោះមុខសង្ឃទាំងពីរចំណែក តំកល់ចំណីលើតុ ឬជើងស្រាបហើយធ្វើកិច្ចទក្ខិណាទកជាដើម ថ្វាយវត្ថុទាំងពួងដល់ព្រះសាស្តាជាមុន ទើបថ្វាយសង្ឃទាំងពីរចំណែកជាខាងក្រោយ យ៉ាងនេះក៏ឈ្មោះថា ថ្វាយសង្ឃទាំងពីរចំណែក

- កាលបើព្រះតថាគតបរិនិព្វានទៅ បុគ្គលឱ្យទានចំពោះសង្ឃទាំងពីរចំណែក នេះជាសង្ឃគតាទក្ខិណាទី ២ ។

- ឱ្យទានចំពោះតែភិក្ខុសង្ឃ នេះជាសង្ឃគតាទក្ខិណាទី ៣ ។

- ឱ្យទានចំពោះតែភិក្ខុនីសង្ឃ នេះជាសង្ឃគតាទក្ខិណាទី ៤ ។

- បុគ្គល(ទៅនិមន្តអំពីសំណាក់សង្ឃ)ថា សូមលោកទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណេះ ពួកភិក្ខុនីប៉ុណ្ណេះអំពីសង្ឃដើម្បីខ្ញុំ ហើយទើបឱ្យទាន នេះជាសង្ឃគតាទក្ខិណាទី ៥ ។

- បុគ្គល(ទៅនិមន្តអំពីសំណាក់សង្ឃ)ថា សូមលោកទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណេះអំពីសង្ឃដើម្បីខ្ញុំ ហើយទើបឱ្យទាន នេះជាសង្ឃគតាទក្ខិណាទី ៦ ។

មានព្រះពុទ្ធជាប្រធានដែរ(សម័យឥឡូវនេះ គ្មានភិក្ខុនី មានតែភិក្ខុ ដូច្នេះ ឈ្មោះថាភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន) ។ ភោជនដែលថ្វាយដល់ព្រះសាស្តាយ៉ាងនេះ ត្រូវប្រគេនដល់ភិក្ខុណាដែលប្រតិបត្តិព្រះសាស្តា ដែលបរិបូណ៌ដោយវត្តប្រតិបត្តិ ព្រោះជាវត្តរបស់ព្រះពុទ្ធបិតា ត្រូវបានដល់ភិក្ខុជាកូន ឬទិន្នប្រគេនដល់សង្ឃក៏គួរ ។ បើវត្តនោះជាប្រេត ឬសាដកត្រូវអុជប្រទីប ចងជាទង់ ឬពិតានថ្វាយ ។ អដ្ឋកថា ។

- បុគ្គល(ទៅនិមន្តអំពីសំណាក់សង្ឃ)ថា សូមលោកទាំងឡាយ ចាត់ពួកភិក្ខុនីប៉ុណ្ណោះ អំពីសង្ឃដើម្បីខ្ញុំ ហើយទើបឱ្យទាន នេះជាសង្ឃគតាទក្ខិណាទី ៧ ។

ម្នាលអានន្ទ **ក្នុងកាលជាអនាគត នឹងមានគោត្រភូសង្ឃ (សង្ឃមានតែឈ្មោះ) មានតែសំពត់កាសាវៈចង-ក ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ជនទាំងនោះឧទ្ទិសចំពោះសង្ឃ ហើយនឹងឱ្យទានដល់បុគ្គលទ្រុស្តសីលទាំងនោះ** ម្នាលអានន្ទ **សូម្បីក្នុងកាលនោះ ក៏តថាគតពោលថា សង្ឃគតាទក្ខិណាទាន មានអានិសង្សរាប់មិនបាន ប្រមាណមិនកើតដែរ** ម្នាលអានន្ទ **តថាគត មិនដែលពោលនូវបាដិបុគ្គលិកទានមានផលច្រើនជាងសង្ឃគតាទក្ខិណាទាន ដោយបរិយាយណាមួយឡើយ** ។

[ទក្ខិណាវិសុទ្ធិ]

ម្នាលអានន្ទ **ទក្ខិណាវិសុទ្ធិ** (ការបរិសុទ្ធិនិងមិនបរិសុទ្ធិរបស់ទាន)នេះមាន ៤ យ៉ាង ។

ឯទក្ខិណាវិសុទ្ធិ ៤ ប្រការ តើដូចម្តេចខ្លះ

១- អត្ថានន្ទ ទក្ខិណា ជាយកគោ វិសុជ្ឈតិ នោ

បដិគ្គាហកគោ ម្នាលអានន្ទ **ទក្ខិណាបរិសុទ្ធិខាងអ្នកឱ្យ មិនបរិសុទ្ធិខាងអ្នកទទួល** ។

២- អត្ថានន្ទ ទក្ខិណា បដិគ្គាហកគោ វិសុជ្ឈតិ ដោយកគោ ម្នាលអានន្ទ **ទក្ខិណាបរិសុទ្ធិខាងអ្នកទទួល មិនបរិសុទ្ធិខាងអ្នកឱ្យ** ។

៣-អត្ថានន្ទ ទក្ខិណា នេវ ដោយកគោ វិសុជ្ឈតិ ដោយ បដិគ្គាហកគោ ម្នាលអានន្ទ **ទក្ខិណាមិនបរិសុទ្ធិខាងអ្នកឱ្យផង មិនបរិសុទ្ធិខាងអ្នកទទួលផង** ។

៤- អត្ថានន្ទ ទក្ខិណា ដោយកគោ ចេវ វិសុជ្ឈតិ បដិគ្គាហកគោ ច ម្នាលអានន្ទ **ទក្ខិណាបរិសុទ្ធិខាងអ្នកឱ្យផង បរិសុទ្ធិខាងអ្នកទទួលផង** ។

សេចក្តីអធិប្បាយទក្ខិណាវិសុទ្ធិ ៤ ប្រការ

- ម្នាលអានន្ទ ទក្ខិណាទានបរិសុទ្ធិខាងអ្នកឱ្យ មិនបរិសុទ្ធិខាងអ្នកឱ្យ តើដូចម្តេច ។

ម្នាលអានន្ទ **អ្នកឱ្យក្នុងសាសនានេះ ជាបុគ្គលមានសីល មានធម៌ល្អ ឯពួកទទួលជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក** ។

ម្នាលអានន្ទ យ៉ាងនេះឯងឈ្មោះថា **ទក្ខិណាបរិសុទ្ធិខាងអ្នកឱ្យ មិនបរិសុទ្ធិខាងអ្នកទទួល ។**

- ម្នាលអានន្ទ ទក្ខិណាបរិសុទ្ធិខាងអ្នកទទួល មិនបរិសុទ្ធិខាងអ្នកឱ្យ តើដូចម្តេច ។

ម្នាលអានន្ទ **អ្នកឱ្យក្នុងសាសនានេះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ឯពួកអ្នកទទួលជាបុគ្គលអ្នកមានសីល មានធម៌ល្អ ។** ម្នាលអានន្ទ យ៉ាងនេះឯង ឈ្មោះថា **ទក្ខិណាបរិសុទ្ធិខាងអ្នកទទួល មិនបរិសុទ្ធិខាងអ្នកឱ្យ ។**

- ម្នាលភិក្ខុទាំងឡាយ ទក្ខិណាមិនបរិសុទ្ធិខាងអ្នកឱ្យផង មិនបរិសុទ្ធិខាងអ្នកទទួលផង តើដូចម្តេច ។

ម្នាលអានន្ទ **អ្នកឱ្យក្នុងសាសនានេះ ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ទាំងពួកអ្នកទទួលក៏ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមកដូចគ្នា ។** ម្នាលអានន្ទ យ៉ាងនេះឯងឈ្មោះថា **ទក្ខិណា មិនបរិសុទ្ធិខាងអ្នកឱ្យ មិនបរិសុទ្ធិខាងអ្នកទទួលផង ។**

- ម្នាលភិក្ខុទាំងឡាយ ទក្ខិណាបរិសុទ្ធិខាងអ្នកឱ្យផង បរិសុទ្ធិខាងអ្នកទទួលផង តើដូចម្តេច ។

ម្នាលអានន្ទ **អ្នកឱ្យក្នុងសាសនានេះ ជាបុគ្គលមានសីល**

មានធម៌ស្អ ទាំងពួកអ្នកទទួលក៏ជាបុគ្គលមានសីល មានធម៌ស្អដូចគ្នា ។ ម្នាលអានន្ទ យ៉ាងនេះឯងឈ្មោះថា ទក្ខិណាបរិសុទ្ធិខាងអ្នកឱ្យផង បរិសុទ្ធិខាងអ្នកទទួលផង ។

ម្នាលអានន្ទ នេះឯងជាទក្ខិណាវិសុទ្ធិ ៤ យ៉ាង ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់នៅព្រះសូត្រនេះ លុះព្រះសុគតជាសាស្តាទ្រង់ត្រាស់នូវព្រះសូត្រចហើយ ទើបទ្រង់ត្រាស់នូវព្រះគាថាតទៅទៀតដូច្នេះថា ៖

យោ សីលវា ទុស្សីលេសុ ទទាតិ
ទានំ ធម្មេន លទ្ធំ សុបសន្ទចិត្តោ
អភិសទ្ទហំ កម្មផលំ ឧឡារំ
សា ទក្ខិណា ទាយកតោ វិសុជ្ឈតិ ។

បុគ្គលណា ជាអ្នកមានសីល មានចិត្តជ្រះថ្លាដោយប្រពៃ ជឿស៊ប់នូវកម្មនិងផលរបស់កម្មដ៏សីលល្អបរិបូរ ឱ្យទានដែលខ្លួនបានមកដោយធម៌ ចំពោះពួកអ្នកទ្រុស្តសីល ទក្ខិណានោះបរិសុទ្ធិខាងអ្នកឱ្យ ។

យោ ទុស្សីលោ សីលវន្តេសុ ទទាតិ

ទានំ អធម្មេន លទ្ធំ អប្បសន្នចិត្តោ
អភិសទ្ទហំ កម្មផលំ ឧឡ្ហារំ
សា ទក្ខិណា បដិគ្គាហកតោ វិសុជ្ឈតិ ។

បុគ្គលណា ជាអ្នកទ្រុស្តសីល មានចិត្តមិនបានជ្រះថ្លា មិនជឿស៊ប់ក្នុងកម្មនិងផលរបស់កម្មដ៏លើសលុប ទ្រព្យទានដែលខ្លួនបានមកមិនដោយធម៌ ចំពោះពួកបុគ្គលអ្នកមានសីល ទក្ខិណានោះបរិសុទ្ធិខាងអ្នកទទួល ។

យោ ទុស្សីលោ សីលេសុ ទទាតិ
ទានំ អធម្មេន លទ្ធំ អប្បសន្នចិត្តោ
អនភិសទ្ទហំ កម្មផលំ ឧឡ្ហារំ
ន តំ ទានំ វិបុលផលន្តិ ព្រូមិ ។

បុគ្គលណា ជាអ្នកទ្រុស្តសីល មានចិត្តមិនបានជ្រះថ្លា មិនជឿស៊ប់ក្នុងកម្មនិងផលរបស់កម្មដ៏លើសលុប ទ្រព្យទានដែលខ្លួនបានមកមិនដោយធម៌ចំពោះពួកបុគ្គលទ្រុស្តសីល តថាគតមិនពោលថា ទាននោះមានផលដ៏បរិបូណ៌ទេ ។

យោ សីលវា សីលវន្តេសុ ទទាតិ

ទានំ ទម្មេន លទ្ធំ សុបសន្ថចិត្តោ
អភិសទ្ធហំ កម្មផលំ ឧឡារំ
តំ វេ ទានំ អាមិសទានានមគ្គន្តិ ។

បុគ្គលណា ជាអ្នកមានសីល មានចិត្តជ្រះថ្លាដោយប្រពៃ ជឿស៊ប់នូវកម្មនិងផលរបស់កម្មដ៏លើសលុប ឱ្យទានដែលខ្លួនបានមកដោយធម៌ ចំពោះពួកអ្នកទ្រុស្តសីល តថាគតពោលថា ទាននោះឯង ទើបបានផលដ៏បរិបូណ៌ ។

យោ វីតរាគោ វីតរាគេសុ ទទាតិ
ទានំ ទម្មេន លទ្ធំ សុបសន្ថចិត្តោ
អភិសទ្ធហំ កម្មផលំ ឧឡារំ
តំ វេ ទានំ អាមិសទានានមគ្គន្តិ ។

បុគ្គលណា ជាអ្នកមានសីល មានចិត្តជ្រះថ្លាដោយប្រពៃ ជឿស៊ប់នូវកម្មនិងផលរបស់កម្មដ៏លើសលុប ឱ្យទានដែលខ្លួនបានមកដោយធម៌ចំពោះពួកបុគ្គលប្រាសចាករាគៈ ទាននោះឯង ប្រសើរជាងពួកអាមិសទាន(ទាំងអស់) ។

អដ្ឋកថា

ក្នុងទក្ខិណាវិភង្គសូត្រនោះ បទថា មហាបជាបតីគោតមី បានដល់ព្រះគោត្រថាគោតមី ។ ក៏ក្នុងថ្ងៃថ្វាយព្រះនាមព្រាហ្មណ៍ទាំងឡាយបានទទួលសក្ការៈហើយ ឃើញព្រះលក្ខណសម្បត្តិរបស់ព្រះនាងហើយបានព្យាករណ៍ថា បើព្រះនាងនេះនឹងបានព្រះធីតា ព្រះធីតានឹងជាអគ្គមហេសីរបស់ស្តេចចក្រពត្តិ បើនឹងបានព្រះឱរស ព្រះឱរសនឹងជាស្តេចចក្រពត្តិ ព្រះបជារបស់ព្រះនាងនឹងជាអ្នកធំក្រៃលែង ដោយប្រការសូម្បីទាំងពីរនោះឯងដូច្នេះ ។ ព្រះញាតិទាំងឡាយ ទើបបានថ្វាយព្រះនាមរបស់ព្រះនាងថា បជាបតី ដោយប្រការដូច្នេះ ។ តែក្នុងសូត្រនេះលោកប្រមយកព្រះគោត្រផង ទើបពោលថា មហាបជាបតិគោតមី ។

បទថា ឆវំ បានដល់ ថ្មី ។

បទថាសាមំវាយិតំគឺទ្រង់ត្បាញដោយព្រះហស្តខ្លួនឯង ។ ក៏ក្នុងថ្ងៃនោះព្រះនាងមហាបជាបតិគោតមី ដែលមានពួកបរិវារបែហមហើយ ស្តេចមកកាន់រោងត្បាញសំពត់របស់ជាងហត្ថកម្មទាំងឡាយ ទ្រង់ចាប់ចុងត្រលាត្បាញ បានទ្រង់ធ្វើអាការនៃការ

ត្បាញសំពត់ ។ ពាក្យនោះ លោកពោលសំដៅដល់ការត្បាញសំពត់នោះ ។

សួរថាព្រះនាងគោតមីទ្រង់កើតព្រះទ័យដើម្បីថ្វាយសំពត់មួយគូ ចំពោះព្រះមានព្រះភាគក្នុងកាលណា ។

ឆ្លើយថា ក្នុងកាលដែលព្រះមានព្រះភាគទ្រង់សម្រេចអភិសម្ពោធិញ្ញាណហើយស្តេចមកកាន់ក្រុងកបិលពស្តុ ដោយការស្តេចគ្រាដំបូង ។ ពិតយ៉ាងនោះព្រះបាទសុទ្ធោទនៈមហារាជទ្រង់នាំព្រះសាស្តាដែលស្តេចបិណ្ឌបាត ឱ្យស្តេចទៅកាន់ព្រះរាជនិវេសន៍របស់ព្រះអង្គ ។ គ្រានោះ ព្រះនាងមហាបជាបតិគោតមី ទ្រង់ឃើញព្រះរូបសោភារបស់ព្រះមានព្រះភាគហើយ ទ្រង់ព្រះត្រិះរិះថាព្រះអត្តភាពរបស់បុត្រយើងស្រស់ល្អហ្ន៎ដូច្នេះ ។ លំដាប់នោះព្រះនាងក៏កើតព្រះសោមនស្សជាខ្លាំង ។ អំពីនោះ ទ្រង់ព្រះត្រិះរិះថា កាលបុត្ររបស់យើងនៅត្រង់កណ្តាលវាំង រហូតដល់អស់ ២៩ ឆ្នាំ វត្ថុដែលយើងឱ្យហើយដោយហោចទៅ សូម្បីត្រឹមតែថាផ្លែចេកប៉ុណ្ណោះមិនមានឡើយ សូម្បីឥឡូវនេះយើងនឹងថ្វាយសំពត់ចីវរដល់បុត្រនោះ ។ ទ្រង់ញុំាងព្រះហប្ញទ័យឱ្យកើតឡើង

ថា ក៏ក្នុងក្រុងរាជគ្រឹះនេះមានសំពត់តម្លៃថ្លៃច្រើន សំពត់ទាំងនោះ រមែងមិនញុំាងយើងឱ្យសប្បាយចិត្ត សំពត់ដែលយើងធ្វើដោយខ្លួនឯង រមែងញុំាងយើងឱ្យសប្បាយចិត្តបាន យើងគួរតែធ្វើដោយខ្លួនឯងថ្វាយ ដូច្នេះ ។ គ្រានោះ ព្រះនាងទ្រង់ឱ្យនាំកប្បាសមកពីផ្សារ ទ្រង់ច្របាច់ ទ្រង់ញីដោយព្រះហស្ត ទារអំបោះយ៉ាងល្អិតល្អន់ ទ្រង់ឱ្យសាងរោងការងារត្បាញសំពត់ក្នុងខាងក្នុងព្រះរាជវាំង នោះតែម្តង ទ្រង់ឱ្យហៅជាងសិល្បទាំងឡាយ ព្រះរាជទានគ្រឿងបរិភោគ ខាទនីយៈនិងភោជនីយាហាររបស់ព្រះអង្គនោះឯងឱ្យដល់ ជាងសិល្បទាំងឡាយហើយ ទ្រង់ឱ្យត្បាញសំពត់ ។

ក៏ព្រះនាងដែលពួកកីលៀងនិងមេដោះ បៃហាមហើយ ស្តេចទៅចាប់ចុងត្រល់តាមសមគួរដល់កាលវេលា ។ ក្នុងកាលដែលសំពត់នោះត្បាញសម្រេចហើយ ទ្រង់បានធ្វើសក្ការៈធំដល់ជាងសិល្បទាំងឡាយហើយ ទ្រង់ដាក់សំពត់មួយគូក្នុងហិប ដែលមានក្លិនក្រអូប ទ្រង់ឱ្យកាន់សំពត់ទូលចំពោះព្រះរាជាថា នាងខ្ញុំនឹងកាន់សំពត់ចីវរទៅថ្វាយដល់បុត្រយើង ។ ព្រះរាជាត្រាស់បង្គាប់ឱ្យត្រៀមផ្លូវស្តេច ។ រាជបរិវារទាំងឡាយចោសសំអាតថ្នល់ តាំង

ឆ្នាំងទឹកពេញ លើកទង់សំពត់ទាំងឡាយ តាក់តែងផ្លូវតាំងពីទ្វារព្រះរាជវាំង ដរាបដល់វត្តនិគ្រោធារាម ធ្វើផ្លូវឱ្យពាសពេញដោយផ្កាឈើ ។ ចំណែកព្រះនាងមហាបជាបតីទ្រង់ប្រដាប់គ្រឿងអលង្ការគ្រប់យ៉ាង មានពួកភីលៀងនិងមេដោះហែហមហើយទ្រង់ទូលហិបសំពត់ ស្តេចទៅកាន់សំណាក់របស់ព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់ថ្មីគូនេះជារបស់ខ្ញុំព្រះអង្គ ដូច្នេះជាដើម ។

បទថា ទុតិយម្បិ ខោ សេចក្តីថា កាលព្រះមានព្រះភាគត្រាស់ថា ម្នាលគោតមី ព្រះនាងចូរថ្វាយសង្ឃចុះ ព្រះនាងមហាបជាបតីគោតមីបានក្រាបទូលអង្វរថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គអាចដើម្បីថ្វាយសំពត់ចីវរទាំងឡាយ អំពីឃ្លាំងសំពត់ដល់ភិក្ខុសង្ឃបុប្ផះ ពាន់រូបខ្លះ ក៏សំពត់ថ្មីគូនេះនាងខ្ញុំខាអំបោះដោយខ្លួនឯង ត្បាញខ្លួនឯង តាំងចិត្តឧទ្ទិសព្រះមានព្រះភាគ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគមេត្តាទទួលសំពត់ថ្មីគូនោះរបស់នាងខ្ញុំចុះ ។ ព្រះនាងក្រាបទូលយ៉ាងនេះដល់ ៣ ដង ។ សូម្បីព្រះមានព្រះភាគក៏ត្រាស់ហាមយ៉ាងនោះទៀត ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ឱ្យថ្វាយសំពត់ថ្មីដែលព្រះនាងថ្វាយចំពោះព្រះអង្គដល់ព្រះភិក្ខុសង្ឃហ្ន៎ ។

ឆ្លើយថា ព្រោះដើម្បីទ្រង់អនុគ្រោះព្រះមាតា ។ ក៏បានឮថា ព្រះមានព្រះភាគព្រះអង្គនោះ ទ្រង់មានព្រះត្រិះរិះថា ចេតនា ៣ យ៉ាង គឺបុព្វចេតនា មុញ្ចនចេតនា អបរាបរចេតនា របស់ព្រះនាងមហាបជាបតីនេះ កើតឡើងប្រារព្ធយើងហើយ ចូរកើតឡើងប្រារព្ធព្រះភិក្ខុសង្ឃខ្លះ កាលជាដូច្នេះ ចេតនាទាំង ៦ យ៉ាងក៏ទំនងរួមគ្នាតែមួយ នឹងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខរហូតដល់អស់កាលយូរ ដល់ព្រះនាងមហាបជាបតីគោតមីនោះដូច្នេះ ។ ចំណែកវិតណ្ឌវាទី (អ្នកនិយាយឱ្យវង្វេងជឿ) ពោលថា ទានដែលថ្វាយសង្ឃមានផលច្រើន ។ គប្បីចោទសួរ វិតណ្ឌវាទីនោះថា ព្រោះហេតុអ្វីទើបលោកពោលយ៉ាងនោះ លោករមែងពោលដល់ទានដែលថ្វាយសង្ឃ មានផលច្រើនជាងទានដែលថ្វាយដល់ព្រះសាស្តាឬ ?ឬ ? (វិតណ្ឌវាទីឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំព្រះករុណាពោលយ៉ាងនោះ) លោក យើងពោល ។ លោកចូរអាងព្រះសូត្រមកមើល ។ លោកវិតណ្ឌវាទី

អាងព្រះសូត្រថា ម្នាលគោតមី ព្រះនាងចូរថ្វាយដល់សង្ឃចុះ កាលថ្វាយសង្ឃហើយ នឹងជាការព្រះនាងបានបូជា ទាំងតថាគត និងសង្ឃ ។ ក៏ព្រះសូត្រនេះមានសេចក្តីត្រឹមតែប៉ុណ្ណេះឬ ។ អើ ត្រឹមតែប៉ុណ្ណេះ ។ បើថាជាដូច្នោះ ទានដែលឱ្យដល់អ្នកស៊ីរបស់សល់ទាំងឡាយក៏គប្បីមានផលច្រើន តាមព្រះតម្រាស់ថា ម្នាលអានន្ទ បើយ៉ាងនោះ លោកចូរឱ្យនំដល់អ្នកស៊ីរបស់សល់ទាំងឡាយនិងថាម្នាលកច្ចាន:បើយ៉ាងនោះលោក ចូរឱ្យដុំស្ករអំពៅដល់អ្នកស៊ីរបស់សល់ទាំងឡាយ ដូច្នេះ ។ ក៏កាលជាយ៉ាងនោះ ព្រះសាស្តាទើបទ្រង់ញុាំងសំពត់ដែលនិងថ្វាយ ព្រះអង្គឱ្យដល់សង្ឃហើយ ដូច្នេះ ។ ក៏ជនទាំងឡាយសូម្បីមានព្រះរាជានិងមហាអាមាត្យរបស់ព្រះរាជាជាដើម រមែងបង្គាប់ឱ្យបណ្ណាការដែលនាំមកដើម្បីខ្ជនឱ្យដល់ជនទាំងឡាយ មានអ្នកចិញ្ចឹមជីវជាដើម ជនទាំងនោះក៏គប្បីធំជាងព្រះរាជាជាដើម ។ ពិតមែន ទក្ខិណេយ្យបុគ្គលដ៏កំពូលជាងព្រះសាស្តាមិនមាន តាមព្រះបាលីថា ព្រោះដូច្នោះ លោកកុំកាន់យ៉ាងនោះ ទក្ខិណេយ្យបុគ្គលដែលដល់សេចក្តីជាកំពូល លើសជាងអហុនេយ្យបុគ្គលទាំងឡាយ

អ្នកត្រូវការបុណ្យ ស្វែងរកផលបរិបូណ៌ដែលប្រសើរទីបំផុត ដូចនឹងព្រះពុទ្ធមិនមានក្នុងលោកនេះ ឬក្នុងលោកដទៃ ។ ព្រះចេតនា ៦ ប្រការ របស់ព្រះនាងមហាបជាបតិគោតមីនោះរួមចូលគ្នាហើយនឹងមានដើម្បីប្រយោជន៍ដើម្បីសេចក្តីសុខ រហូតដល់អស់កាលយូរយ៉ាងនេះ ។

ក៏ព្រះមានព្រះភាគទ្រង់ហាមដល់ ៣ ដងហើយ ទ្រង់ឱ្យថ្វាយដល់សង្ឃទ្រង់សំដៅយកអ្វី ។ ត្រាស់យ៉ាងនោះ ដើម្បីជនជំនាន់ក្រោយ និងដើម្បីទ្រង់ឱ្យកើតសេចក្តីកោតក្រែងក្នុងសង្ឃផង ។ នយថា ព្រះមានព្រះភាគទ្រង់មានព្រះតម្រិះយ៉ាងនេះថា តថាគតមិនតាំងនៅយូរទេ តែសាសនារបស់តថាគតនឹងតាំងនៅក្នុងព្រះភិក្ខុសង្ឃ ជនជំនាន់ក្រោយ ចូរញុំាងសេចក្តីកោតក្រែងក្នុងសង្ឃឱ្យកើតឡើង ដូច្នេះ ទើបទ្រង់ហាមដល់ ៣ ដងហើយទ្រង់ឱ្យថ្វាយសង្ឃ ។

ក៏កាលជាដូច្នោះ ព្រះសាស្តាទើបទ្រង់ឱ្យថ្វាយសំពត់ថ្មីមួយគូ សូម្បីដែលព្រះនាងនឹងថ្វាយចំពោះព្រះអង្គឱ្យដល់សង្ឃ ទក្ខិណេយ្យបុគ្គលឈ្មោះថា សង្ឃ ព្រោះដូច្នោះ ជនជំនាន់ក្រោយញុំាងសេចក្តីកោតក្រែងឱ្យកើតឡើងក្នុងសង្ឃនឹងសម្គាល់បច្ចយ

បួន ជាវត្ថុគប្បីថ្វាយសង្ឃកាលមិនលំបាកដោយបច្ច័យបួន នឹងរៀនព្រះពុទ្ធវចនៈធ្វើសមណធម៌ដោយស្រួល កាលជាយ៉ាងនោះ សាសនារបស់យើងនឹងតាំងនៅដល់៥,០០០ឆ្នាំ ដូច្នេះ ។

ក៏ពាក្យថា ធម្មតាទក្ខិណេយ្យបុគ្គលដែលកំពូលជាងព្រះសាស្តាមិនមាននោះ គួរពោលសូម្បីដោយពាក្យថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគមេត្តាទទួលចុះដូច្នេះ ។ ក៏ព្រះអានន្ទត្ថេរៈមិនមានសេចក្តីអាឃាត ឬពៀរវេរក្នុងព្រះនាងមហាបជាបតី ទាំងព្រះថេរៈមិនត្រូវការថា ទក្ខិណារបស់ព្រះនាងកុំបានមានផលច្រើន ។ ពិតមែន ព្រះថេរៈជាបណ្ឌិត ជាពហុស្សូត សម្រេច សេក្ខបដិបទា ។ ព្រះថេរៈនោះ កាលឃើញសំពត់ប្តីមួយគូដែលព្រះនាងថ្វាយព្រះសាស្តានោះមានផលច្រើន ទើបក្រាបទូលសូមដើម្បីទ្រង់ទទួលថា បពិត្រព្រះអង្គដ៏ចម្រើនសូមព្រះមានព្រះភាគមេត្តាទទួលចុះ ដូច្នេះ ។

វិតណ្ឌវាទីពោលទៀតថា ព្រះសាស្តាទ្រង់រាប់បញ្ចូលនឹងសង្ឃ ព្រោះព្រះតម្រាស់ថា កាលថ្វាយសង្ឃហើយ នឹងជាការព្រះនាងបានបូជាទាំងតថាគតនិងសង្ឃ ដូច្នេះ វិតណ្ឌវាទីនោះ គួរត្រូវក្រើនរំលឹកថា ក៏លោកដឹងឬថា សរណៈមានប៉ុនណា សេចក្តី

ជ្រះថ្លាមានប៉ុនណា ។ រីតណ្ហាទីកាលដ៏ធំ ក៏ទីធំពោលថា សរណៈមាន ៣ សេចក្តីជ្រះថ្លាសូម្បីមានត្រឹម ៣ ។ អំពីនោះក៏គួរត្រូវពោលថា តាមលទ្ធិរបស់លោក សរណៈក៏គង់មាន ២ យ៉ាងប៉ុណ្ណោះ ព្រោះសេចក្តីដែលព្រះសាស្តារាប់បញ្ចូលនឹងសង្ឃ ។ កាលជាយ៉ាងនោះ បព្វជ្ជាដែលទ្រង់អនុញ្ញាតយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតបព្វជ្ជាឧបសម្បទាដោយត្រៃសរណាគមន៍ដូច្នេះសូម្បីឧបសម្បទាក៏មិនចម្រើនឡើង ។ អំពីនោះលោកក៏នឹងមិនជាបព្វជិត គង់ជាគ្រហស្ថ ។ គ្រាសូម្បីព្រះសម្មាសម្ពុទ្ធប្រថាប់ក្នុងព្រះគន្ធកុដិ ភិក្ខុទាំងឡាយធ្វើឧបោសថខ្លះ បវារណាខ្លះ សង្ឃកម្មទាំងឡាយខ្លះ កម្មទាំងនោះក៏គប្បីកម្រើកព្រោះសេចក្តីដែលព្រះសាស្តាទ្រង់រាប់បញ្ចូលនឹងសង្ឃនិងមិនមាន ។ ព្រោះដូច្នោះ ទើបមិនគួរពោលពាក្យនេះថា ព្រះសាស្តាទ្រង់រាប់បញ្ចូលនឹងសង្ឃ ។

បទថា អាចាមិតា បានដល់ ទ្រង់ឱ្យចម្រើនព្រមហើយ អធិប្បាយថា គ្រាព្រះហស្តនិងព្រះបាទរបស់ព្រះអង្គមិនញាំងកិច្ចដោយព្រះហស្ត និងព្រះបាទឱ្យសម្រេចព្រះនាងក៏ទ្រង់ឱ្យព្រះហស្ត និងព្រះបាទឱ្យចម្រើនប្រតិបត្តិបាន ។

បទថា ផោសិកា សេចក្តីថា ព្រះនាងទ្រង់ចិញ្ចឹមព្រះអង្គ ដោយឱ្យងូតទឹក ទ្រង់ឱ្យសោយ ទ្រង់ឱ្យផឹក មួយថ្ងៃ ២ ដង ៣ ដង ។

បទថា ឥយំ ផាយេសិ សេចក្តីថា បានឮថា នន្ទកុមារ-ពោធិសត្វ ទ្រង់ជាកម្លោះត្រឹមតែពីរ-បីថ្ងៃប៉ុណ្ណោះ គ្រាកាលនន្ទ-កុមារប្រសូតិហើយ ព្រះនាងមហាបជាបតីទ្រង់ឱ្យព្រះឱរសរបស់ព្រះអង្គ ឱ្យដល់កីលៀងនិងមេដោះចិញ្ចឹម ឯព្រះនាងចិញ្ចឹមបីបាច់ព្រះពោធិសត្វ ព្រះថេរៈសំដៅដល់ការប្រទានព្រះខីរសនោះ ទើបក្រាបទូលយ៉ាងនេះ ។ ព្រះថេរៈ គ្រាសម្តែងសេចក្តីដែលព្រះនាងមហាបជាបតីទ្រង់មានព្រះឧបការៈច្រើន ដោយប្រការដូច្នេះហើយ ឥឡូវនេះកាលនឹងសម្តែងសេចក្តីដែលព្រះតថាគតទ្រង់មានព្រះឧបការៈច្រើន ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូម្បីព្រះមានព្រះភាគ ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា ភគវន្តំ អាគម្ម គឺទ្រង់អាស្រ័យ គឺទ្រង់ពឹងពាក់ ទ្រង់សំដៅយកព្រះមានព្រះភាគ ។

លំដាប់នោះព្រះមានព្រះភាគកាលនឹងទ្រង់អនុមោទនាដល់

ព្រះឧបការៈក្រៃលែង ៗឡើងទៅ ក្នុងព្រះឧបការៈទាំងពីរ ទើបត្រាស់ថា ប្រការនោះជាយ៉ាងនោះជាដើម ។ បណ្តាបទទាំងនោះ បទថា យំ ហានន្តុ បុគ្គលោ បុគ្គលំ អាគម្ម សេចក្តីថា បុគ្គលដែលអន្តេវាសិកអាស្រ័យបុគ្គលដែលជាអាចារ្យណា ។

បទថា ឥស្សានន្តុ បុគ្គលស្ស ឥមិនា បុគ្គលេន សេចក្តីថា បុគ្គលជាអន្តេវាសិកនេះតបស្នងដល់បុគ្គលជាអាចារ្យនេះ ។

បទថា ន សុបដិការំ វេទាមិ សេចក្តីថា តថាគតមិនពោលការតបជំនួសឧបការៈជាការធ្វើដោយល្អ ។ ក្នុងកម្មទាំងឡាយមានការអភិវាទនៈជាដើម ការឃើញអាចារ្យហើយធ្វើការក្រោបថ្វាយបង្គំ ឈ្មោះថា អភិវាទនៈ បានដល់កាលនឹងសម្រេចឥរិយាបថទាំងឡាយ បែរមុខទៅកាន់ទិសដែលអាចារ្យនៅ សំពះហើយជើង សំពះហើយឈរ សំពះហើយអង្គុយ សំពះហើយដេក ។ ចំណែកការឃើញអាចារ្យពីឆ្ងាយហើយ ក្រោកឡើងធ្វើការទទួល ឈ្មោះថា បច្ចុបដ្ឋានៈ ។ ក៏កម្មនេះគឺ ឃើញអាចារ្យហើយផ្គងអញ្ជលីទុកលើសីសៈ នមស្សការអាចារ្យ ឬសូម្បីបែរមុខទៅកាន់ទិសដែលអាចារ្យនោះនៅ នមស្សការយ៉ាងនោះឯង ដើរទៅ

ក្តី ឈរក្តី អង្គុយក្តី ដេកក្តី ផ្ងងអញ្ជលីហើយនមស្សការនោះ ពិត
មែន ឈ្មោះថា អញ្ជលីកម្ម ។ ការធ្វើកម្មដែលសមគួរ ឈ្មោះថា
សាមីចិកម្ម ។ ក្នុងវត្ថុទាំងឡាយមានចីវរជាដើម កាលនឹងថ្វាយ
ចីវរមិនថ្វាយតាមមានតាមបាន ។ ថ្វាយចីវរដែលមានតម្លៃច្រើន
មានមូលតម្លៃ ១០០កហាបណៈ ខ្លះ ៥០០ ខ្លះ ១,០០០ ខ្លះ ។ ក្នុងវត្ថុ
ទាំងឡាយ សូម្បីមានបិណ្ឌបាតជាដើម មានន័យនេះដូចគ្នា ។
ដោយបច្ច័យច្រើនយ៉ាងណា ។ សូម្បីកាលញុំាងចន្លោះចក្រវាឡ
ឱ្យពេញដោយបច្ច័យដ៏ប្រណីត ៤ កាន់យកកំពូលប៉ុនភ្នំសិនេរុ
ថ្វាយរមែងមិនអាចដើម្បីធ្វើកិរិយាដ៏សមគួរដល់អាចារ្យឡើយ ។

ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ប្រារម្ភថា ក៏ទក្ខិ-
ណា ១៤ នេះឯង ។ សូត្រនេះកើតឡើងប្រារព្ធទក្ខិណាជាបាដិ-
បុគ្គលិក ។ ចំណែកព្រះអានន្ទត្ថេរៈកាន់យកទក្ខិណាជាបាដិ-
បុគ្គលិកតែម្យ៉ាងថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះ
ភាគមេត្តាទទួល ដូច្នេះ ។ តែព្រះមានព្រះភាគទ្រង់ប្រារព្ធទេសនា
នេះដើម្បីទ្រង់សម្តែងថា ទានដែលបុគ្គលឱ្យហើយ ក្នុងឋានៈ
១៤ ឈ្មោះថា ជាបាដិបុគ្គលិក ។

បទថា **អយំ បឋមា** សេចក្តីថា ទក្ខិណានេះប្រការទី ១ ដោយអំណាចនៃគុណខ្លះ ដោយអំណាចនៃទក្ខិណាដ៏ចំរើនទីបំផុតខ្លះ ពិតមែនទក្ខិណានេះទី ១ គឺប្រសើរបានដល់ ចំរើនដល់ទីបំផុត ឈ្មោះថា ប្រមាណនៃទក្ខិណានេះមិនមានទក្ខិណាសូម្បីប្រការទី ២-៣ ជាទក្ខិណាយ៉ាងក្រៃលែងដូចគ្នា ។ ទក្ខិណាទាំងឡាយដ៏សេស រមែងមិនដល់សេចក្តីជាទក្ខិណាយ៉ាងក្រៃលែងបាន ។

បទថា **ពាហិរកេ កាមេសុ វីតរាគេ** បានដល់ អ្នកជាកម្មវាទីអ្នកជាកិរិយវាទី អ្នកបានអភិញ្ញា ៥ ដែលជាលោកិយៈ ។

បទថា **បុថុជ្ជនសីលវា** សេចក្តីថា បុថុជ្ជនអ្នកមានសីលដោយឈ្មោះ ជាអ្នកមានសីលជាផែនដី មិនអួតអាង មិនមានមាយា មិនបៀតបៀនអ្នកដទៃ សម្រេចជីវិតដោយកសិកម្ម ឬពាណិជ្ជកម្មដោយធម៌ ដោយប្រពៃ ។

បទថា **បុថុជ្ជនទុស្សីលេ** សេចក្តីថា បុគ្គលទាំងឡាយមាននាយកេវដ្តៈ និងអ្នកចាប់ត្រីជាដើមឈ្មោះថា បុថុជ្ជនអ្នកទ្រុស្តសីល ចិញ្ចឹមជីវិតដោយការបៀតបៀនសត្វដទៃ ។

ឥឡូវនេះព្រះមានព្រះភាគ កាលនឹងទ្រង់កំណត់វិបាករបស់

ទក្ខិណា ជាបាដិបុគ្គលិក ទើបត្រាស់ថា តត្ថរានន្ទ ជាដើម ។ ក្នុងបទទាំងនោះ បទថា តិរច្ឆានគតេ សេចក្តីថា ទានណាដែលបុគ្គលឱ្យហើយ ដើម្បីចិញ្ចឹមដោយអំណាចគុណ ដោយអំណាចឧបការៈទាននេះមិនកាន់យក ។ ទានសូម្បីណាត្រឹមតែថា បាយមួយពំនូត ឬកន្ទុះពំនូតដែលបុគ្គលឱ្យហើយ ទានសូម្បីនោះ ក៏មិនកាន់យកដែរ ។ ចំណែកទានណាដែលបុគ្គលប្រាថ្នាផល ហើយឱ្យតាមសេចក្តីត្រូវការដល់សត្វទាំងឡាយ មានសុនខ ជ្រូក មាន់ និងក្អែកជាដើមណាមួយដែលមកដល់ ទ្រង់សំដៅដល់ទាននេះ ទើបត្រាស់ថា ឱ្យទានក្នុងសត្វតិរច្ឆាន ដូច្នេះ ។

បទថា សតគុណា បានដល់ មានអានិសង្ស ១០០ ។

បទថា បាដិកង្ខិតព្វា គឺគប្បីប្រាថ្នា ។ មានអធិប្បាយថា ទក្ខិណានេះរមែងឱ្យអានិសង្ស ៥០០ គឺអាយុ ១០០ អត្តភាព ឱ្យវណ្ណៈ ១០០ អត្តភាព សុខ ១០០ អត្តភាព ពលៈ ១០០ អត្តភាព បដិភាណ ១០០ អត្តភាព ។ ទក្ខិណាឱ្យអាយុក្នុង ១០០ អត្តភាព ឈ្មោះថា អាយុ ១០០ ឱ្យវណ្ណៈក្នុង ១០០ អត្តភាព ឈ្មោះថា វណ្ណៈ ១០០ ឱ្យសុខក្នុង ១០០ អត្តភាព ឈ្មោះថាសុខ ១០០

អត្តភាព ឱ្យពេលៈក្នុង ១០០ អត្តភាព ឈ្មោះថា ពលៈ ១០០ អត្តភាព ឱ្យបដិភាណ ១០០ អត្តភាព ធ្វើសេចក្តីមិនតក់ស្លុតក្នុង ១០០ អត្តភាព ឈ្មោះថា បដិភាណ ១០០ អត្តភាព ។ សូម្បីក្នុង ភព ១០០ ដែលពោលហើយ ក៏មានសេចក្តីយ៉ាងនេះឯង ។ គប្បីជ្រាបន័យគ្រប់បទ ដោយទំនងនេះ ។

ក្នុងបទនេះថា **អ្នកបដិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល** សូម្បីឧបាសកអ្នកដល់ត្រៃសរណគមន៍ថ្នាក់យ៉ាងទាប ឈ្មោះថា **បដិបត្តិដើម្បីធ្វើឱ្យច្បាស់នូវសោតាបត្តិផល ។** សូម្បីទានដែលឱ្យក្នុងឧបាសកអ្នកបដិបត្តិដើម្បីធ្វើឱ្យច្បាស់នូវសោតាបត្តិផលនោះ រាប់មិនបានប្រមាណមិនកើត ។

ចំណែកទានដែលឱ្យដល់បុគ្គលដែលតាំងនៅក្នុងសីល ៥ មានផលច្រើនជាងនោះ ។

ទាន ដែលឱ្យដល់បុគ្គលដែលតាំងនៅក្នុងសីល១០ មានផលច្រើនជាងនោះទៀត ។

ទានដែលថ្វាយដល់សាមណេរដែលបួស ក្នុងថ្ងៃនោះមានផលច្រើនជាងនោះទៅទៀត ។

ទាន ដែលថ្វាយដល់ភិក្ខុដែលឧបសម្បទ មានផលច្រើនជាងនោះ ។

ទានដែលថ្វាយដល់ភិក្ខុដែលឧបសម្បទនោះឯង អ្នកដល់ព្រមដោយវត្តមានផលច្រើនជាងនោះ ។

ទានឱ្យដល់អ្នកប្រារព្ធវិបស្សនាមានផលច្រើនជាងនោះ ។

ក៏សម្រាប់អ្នកដល់ព្រមដោយមគ្គ អ្នកបដិបត្តិដើម្បីធ្វើឱ្យច្បាស់នូវសោតាបត្តិផល ឈ្មោះថា បដិបត្តិហើយ ។ ទានដែលឱ្យដល់បុគ្គលនោះ មានផលច្រើនជាងនោះទៀត ។

សួរថា ក៏អាចដើម្បីឱ្យទានដល់ភិក្ខុដែលតាំងនៅក្នុងបឋមមគ្គបានឬ ។ ឆ្លើយថា អាចដើម្បីឱ្យបាន ។

ក៏ភិក្ខុអ្នកប្រារព្ធវិបស្សនា កាន់បាត្រនិងចីវរ ចូលស្រុកដើម្បីបិណ្ឌបាត ។ កាលភិក្ខុអ្នកដល់ព្រមដោយមគ្គឈរនៅត្រង់ទ្វារស្រុក ជនទាំងឡាយទទួលបាត្រអំពីដៃក៏ជាក់ខាទនីយៈ និងភោជនីយៈ ។ ការចេញចាកមគ្គរបស់ភិក្ខុ រមែងមានក្នុងខណៈនោះ ។ ទាននេះឈ្មោះថា ជាការឱ្យហើយដល់ភិក្ខុអ្នកដល់ព្រមមគ្គ ។

មួយទៀត ភិក្ខុនោះអង្គុយនៅក្នុងវោងឆាន់ មនុស្សទាំងឡាយទៅហើយដាក់ខាទនីយៈ ភោជនីយៈក្នុងបាត្រ ។ ការចេញចាកមគ្គរបស់ភិក្ខុនោះរមែងមានក្នុងខណៈនោះ ។ ទានសូម្បីនេះឈ្មោះថា ឱ្យហើយដល់ភិក្ខុអ្នកដល់ព្រមដោយមគ្គ ។

ម្យ៉ាងទៀត កាលភិក្ខុនោះអង្គុយក្នុងវិហារ ឬ វោងឆាន់ ឧបាសកទាំងឡាយកាន់បាត្រទៅកាន់ផ្ទះរបស់ខ្លួនហើយ ដាក់ខាទនីយៈនិងភោជនីយៈ ការចេញចាកមគ្គរបស់ភិក្ខុនោះ រមែងមានក្នុងខណៈនោះ ។ ទានសូម្បីនេះ ឈ្មោះថា ឱ្យហើយដល់ភិក្ខុអ្នកដល់ព្រមដោយមគ្គ ។ គប្បីជ្រាបសេចក្តីនូវទានដែលបុគ្គលឱ្យហើយ ដល់អ្នកបដិបត្តិដើម្បីធ្វើឱ្យច្បាស់នូវសោតាបត្តិផលនោះ ដូចទឹកក្នុងប្រឡាយមិនអាចរាប់បានដូច្នោះ ។ គប្បីជ្រាបសេចក្តីនូវទានដែលបុគ្គលឱ្យហើយក្នុងបុគ្គលទាំងឡាយ មានព្រះសោតាបន្នជាដើម ដូចទឹកក្នុងមហាសមុទ្រ ក្នុងបណ្តាមហានទីនោះ ។ ជាការរាប់មិនបាន ។ គប្បីសម្តែងសេចក្តីនេះសូម្បីដោយសេចក្តីដែលធ្វើធូលីក្នុងស្ថានត្រឹមតែថា លានស្រូវនៃផែនដីជាដើម ដរាបដល់ធូលីទាំងផែនដី ដែលប្រមាណមិនបាន ។

ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបទ្រង់ប្រារព្ធថា ក៏ទក្ខិណា ៧ យ៉ាងនេះ ។ ទ្រង់ប្រារព្ធទេសនានេះ ដែលត្រាស់ថា ម្នាលគោតមី ព្រះនាងចូរថ្វាយសង្ឃចុះ កាលថ្វាយសង្ឃហើយ នឹងជាការព្រះនាងបានបូជាទាំងតថាគតនិងសង្ឃ ហើយដើម្បីទ្រង់សម្តែងថា ទានដែលបុគ្គលឱ្យក្នុងហាន:៧ នោះ ជាកាលឈ្មោះថា ថ្វាយសង្ឃហើយ ។

បណ្តាបទទាំងនោះ បទថា **ពុទ្ធុបមុខេ** ឧភតោសង្ឃេ សេចក្តីថា សង្ឃនេះគឺ ភិក្ខុសង្ឃម្ខាង ភិក្ខុនីសង្ឃម្ខាង ព្រះសាស្តាប្រថាប់អង្គុយត្រង់កណ្តាល ឈ្មោះថា សង្ឃ ២ ចំណែក មានព្រះពុទ្ធជាប្រមុខ ។

បទថា **អយំ បឋមា** សេចក្តីថា ឈ្មោះថា ទក្ខិណា មានប្រមាណស្មើដោយទក្ខិណានេះមិនមាន ។ ក៏ទក្ខិណាទាំងឡាយមានទក្ខិណាទីពីរជាដើម រមែងមិនដល់ទក្ខិណាសូម្បីនោះ ។

សួរថា ក៏កាលព្រះតថាគតបរិនិព្វានហើយអាចដើម្បីថ្វាយទានចំពោះព្រះសង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រមុខឬ ។

ឆ្លើយថា អាច ។ ធ្វើដូចម្តេច ។ គឺគប្បីតាំងព្រះពុទ្ធរូបដែល

មានព្រះធាតុ ក្នុងហាន:ជាប្រមុខរបស់សង្ឃទាំងពីរចំណែកក្នុងអាសន: ជាក់តាំងថ្វាយវត្ថុទាំងអស់មានទក្ខិណោទកជាដើមចំពោះព្រះសាស្តាមុនហើយថ្វាយចំពោះព្រះសង្ឃទាំង ២ ចំណែក ។ ទានជាដែលឈ្មោះថា ថ្វាយសង្ឃទាំង ២ ចំណែកមានព្រះពុទ្ធជាប្រមុខ ដោយប្រការដូច្នេះ ។

សួរថា ក្នុងព្រះសង្ឃទាំង ២ ចំណែកនោះ ទានណាថ្វាយព្រះសាស្តា ទាននោះគប្បីធ្វើយ៉ាងណា ។

ឆ្លើយថា គប្បីថ្វាយដល់ភិក្ខុដែលព្រមដោយវត្ត អ្នកបដិបត្តិព្រះសាស្តា ដោយថា ទ្រព្យដែលជារបស់បិតា រមែងដល់បុត្រ ។

សូម្បីការថ្វាយទានដល់ភិក្ខុសង្ឃក៏គួរ ។ ក៏កាន់ទឹកដោះថ្លា និងប្រេងធ្វើជាប្រទីបកាន់យកសំពត់សាដកធ្វើជាទង់បដា ។

បទថា ភិក្ខុសង្ឃេ បានដល់ ភិក្ខុសង្ឃជាច្រើននៅមិនជាច់ ។ សូម្បីក្នុងភិក្ខុនីសង្ឃក៏នំយនេះដូចគ្នា ។

បទថា គោត្រភុនោ បានដល់ សូម្បីត្រឹមតែថា គោត្រប៉ុណ្ណោះ អធិប្បាយថា ជាសមណ:តែឈ្មោះ ។

បទថា កាសាវកណ្ឋា គឺអ្នកមានឈ្មោះថា មានសំពត់កាសាវៈពាន់ក ។ បានឮថា ភិក្ខុទាំងនោះព័ទ្ធសំពត់កាសាវៈផ្ចាំងមួយត្រង់ដៃឬត្រង់ក្រគាច់ទៅ ។ ក៏ទ្វារស្រុក សូម្បីកម្មមានបុត្រ ភរិយា កសិកម្មនិងវណិជ្ជកម្មជាដើមទាំងឡាយ របស់ភិក្ខុដែលទ្រុស្តសីលទាំងនោះក៏នឹងជាប្រក្រតីពិតមែន ។ មិនបានត្រាស់ថា សង្ឃទ្រុស្តសីលក្នុងបទនេះថា អ្នកទាំងឡាយនឹងថ្វាយទានចំពោះសង្ឃបានក្នុងពួកភិក្ខុទ្រុស្តសីលនោះ ពិតមែន សង្ឃឈ្មោះថាទ្រុស្តសីលមិនមាន តែឧបាសកទាំងឡាយឈ្មោះថា ទ្រុស្តសីលនឹងថ្វាយទានដោយគិតថា យើងនឹងថ្វាយចំពោះសង្ឃក្នុងពួកភិក្ខុទ្រុស្តសីលនោះ ។

សូម្បីទក្ខិណាដែលថ្វាយសង្ឃ មានព្រះពុទ្ធជាប្រមុខ ដែលព្រះមានព្រះភាគត្រាស់ថា មានផលរាប់មិនបាន ដោយការរាប់គុណ ដោយប្រការដូច្នេះ ។ សូម្បីទក្ខិណាដែលឱ្យក្នុងសង្ឃដែលមានភិក្ខុមានសំពត់កាសាវៈព័ទ្ធក ត្រាស់ថា មានផលរាប់មិនបានដោយការរាប់គុណដូចគ្នា ។ ក៏ទក្ខិណាដែលដល់សង្ឃ រមែងមានដល់បុគ្គលដែលអាចដើម្បីធ្វើសេចក្តីកោតក្រែងក្នុងសង្ឃ ។ តែ

សេចក្តីកោតក្រែងក្នុងសង្ឃធ្វើបានលំបាក ។ ក៏បុគ្គលណាត្រៀមទេយ្យធម៌ដោយគិតថា យើងនឹងឱ្យទក្ខិណាដល់សង្ឃ ទៅវិហារ ហើយឆ្លើយប្រាប់ថា បពិត្រលោកដ៏ចម្រើន សូមលោកចូរឱ្យព្រះថេរៈមួយរូបចំពោះសង្ឃចុះ ។ លំដាប់នោះ បានសាមណេរអំពីសង្ឃ រមែងដល់សេចក្តីជាប្រការដទៃថា យើងបានសាមណេរហើយដូច្នេះ ។ ទក្ខិណារបស់បុគ្គលនោះរមែងមិនដល់សង្ឃ ។ កាលបានព្រះមហាថេរៈ ក៏កើតសេចក្តីសោមនស្សថា យើងបានមហាថេរៈហើយ ដូច្នេះ ទក្ខិណាក៏មិនដល់សង្ឃដូចគ្នា ។ ចំណែកបុគ្គលណាបានសាមណេរ អ្នកឧបដ្ឋាកសម្បទាហើយ ភិក្ខុកម្លោះ ឬថេរៈជាពាលឬបណ្ឌិតរូបណាមួយអំពីសង្ឃហើយមិនសង្ស័យ រមែងអាចដើម្បីធ្វើសេចក្តីកោតក្រែងក្នុងសង្ឃថា យើងនឹងថ្វាយសង្ឃ ។ ទក្ខិណារបស់បុគ្គលនោះឈ្មោះថា ដល់សង្ឃហើយ ។ បានឮថា ពួកឧបាសកអ្នកសមុទ្រឯណោះធ្វើយ៉ាងនេះ ។ ក៏ក្នុងឧបាសកទាំងនោះ ម្នាក់ជាម្ចាស់របស់វត្ត ជាកុដុម្ពី បាននិមន្តចំពោះអំពីសង្ឃថា យើងនឹងថ្វាយទក្ខិណាដល់សង្ឃ ទើបឆ្លើយប្រាប់ថា សូមលោកចូរឱ្យភិក្ខុមួយរូប ។ ឧបាសកនោះបានភិក្ខុទ្រុស្តសីល

មួយរូប នាំទៅកាន់ស្ថានទីអង្គុយក្រោលអាសនៈចង្ហិតានខាងលើ បូជាដោយរបស់ក្រអូបធូប និងផ្កាឈើ លាងជើង លាបដោយប្រេង បានថ្វាយទេយ្យធម៌ដោយសេចក្តីកោតក្រែងក្នុងសង្ឃ ដូចធ្វើសេចក្តីនមស្ការចំពោះព្រះពុទ្ធ ។ ភិក្ខុរូបនោះមកកាន់ទ្វារផ្ទះថា លោកចូរឱ្យចប ដើម្បីប្រយោជន៍ដល់ការបដិបត្តិវត្តក្នុងខាងក្រោយភត្ត ។ ឧបាសកអង្គុយយកជើងឆ្ពិះចបឱ្យហើយនិយាយថា ចូរទទួលទៅ ។ មនុស្សទាំងឡាយបានឃើញហេតុនោះហើយ បាននិយាយនិងគេនោះថា លោកបានធ្វើសក្ការៈដល់ភិក្ខុនេះពីព្រឹកល្អណាស់មិនអាចនិងពោលបាន ឥឡូវនេះ សូម្បីត្រឹមតែថា ឧបចារៈ (មារយាទ) ក៏មិនមាន នេះឈ្មោះថា អ្វីហ្ន៎ ។ ឧបាសកពោលថា នែ៎នាយ សេចក្តីកោតក្រែងនោះមានចំពោះសង្ឃ មិនមានដល់ភិក្ខុនោះ ។

សួរថា ក៏អ្នកណា រមែងញុំាងទក្ខិណាដែលថ្វាយសង្ឃ ដែលភិក្ខុមានតែសំពត់កាសាវៈព័ទ្ធ-កឱ្យហ្មត់ចត់ ។

ឆ្លើយថា ព្រះមហាថេរៈ ៨០ រូបមានព្រះសារីបុត្រនិងព្រះមោគ្គល្លានជាដើម រមែងឱ្យហ្មត់ចត់បាន ។ មួយទៀត ព្រះថេរៈ

ទាំងឡាយបរិនិព្វានយូរហើយ ព្រះខីណាស្រពទាំងឡាយដែលនៅមានជីវិតតាំងពីព្រះថេរៈជាដើម ដរាបដល់ថ្ងៃនេះ រមែងឱ្យហ្មត់ចត់ដូចគ្នា ។

ក្នុងបទនេះថា ម្នាលអានន្ទ ប៉ុន្តែថា តថាគតមិនពោលថាជាបុគ្គលិកទានថា មានផលច្រើនជាងទក្ខិណាដែលដល់ហើយក្នុងសង្ឃដោយបរិយាយណា ។ ឮយ សង្ឃមានព្រះពុទ្ធជាប្រមុខមាននៅ សង្ឃបច្ចុប្បន្ននេះមាននៅ សង្ឃដែលមានភិក្ខុមានតែសំពត់កាសាវៈព័ទ្ធក្នុងអនាគតក៏មាននៅ ។ សង្ឃដែលមានព្រះពុទ្ធជាប្រមុខ មិនគប្បីនាំចូលទៅនឹងសង្ឃក្នុងបច្ចុប្បន្ននេះទេ សង្ឃក្នុងបច្ចុប្បន្ននេះ ក៏មិនគប្បីនាំចូលទៅនឹងសង្ឃដែលមានតែសំពត់កាសាវៈព័ទ្ធក្នុងអនាគត មិនគប្បីពោលតាមសម័យនោះទេ ។ ក៏សមណបុថុជ្ជនដែលនាំទៅចំពោះអំពីសង្ឃ ជាបាដិបុគ្គលិកសោតាបន្ន កាលបុគ្គលអាចដើម្បីធ្វើសេចក្តីកោតក្រែងក្នុងសង្ឃទានដែលឱ្យក្នុងសមណៈបុថុជ្ជន មានផលច្រើនជាង ។

ក្នុងពាក្យសូម្បីមានជាដើមថាសោតាបន្នដែលទាយកកាន់យកដោយចំពោះ ជាបាដិបុគ្គលិកសទាគាមី ក៏មានន័យនេះដូច

គ្នា ។ ពិតមែន កាលបុគ្គលអាចដើម្បីធ្វើសេចក្តីកោតក្រែងក្នុងសង្ឃ ឱ្យទានសូម្បីក្នុងភិក្ខុទុស្តសីលដែលចោះចំពោះ ហើយកាន់យក មានផលច្រើនជាងទានដែលបុគ្គលថ្វាយក្នុងព្រះខីណាស្រពនោះឯង ។ ក៏ពាក្យណាដែលពោលថា ម្នាលមហាបពិត្រ ទានដែលឱ្យដល់អ្នកមានសីល មានផលច្រើន ទានដែលឱ្យក្នុងអ្នកទុស្តសីលមិនមានផលច្រើនយ៉ាងនោះទេ ពាក្យនោះគប្បីលះនូយនេះហើយ គប្បីឃើញក្នុងចតុក្កៈនេះថា ម្នាលអានន្ទ ក៏សេចក្តីបរិសុទ្ធិនៃទក្ខិណានេះមាន ៤ យ៉ាង ។

បទថា **ទាយកតោ វិសុជ្ឈតិ** សេចក្តីថា ទក្ខិណាខ្លះបរិសុទ្ធិ ដោយសេចក្តីមានផលច្រើន អធិប្បាយថា ជាទានមានផលច្រើន ។

បទថា **កល្យាណធម្មោ** បានដល់ មានសុចរិតធម៌ ។

បទថា **បាបធម្មោ** គឺមានធម៌អាក្រក់ ។ ក៏គប្បីសម្តែងព្រះវេស្សន្តរមហារាជក្នុងបទនេះថាទក្ខិណាខ្លះបរិសុទ្ធិខាងអ្នកឱ្យ ។ ក៏ព្រះវេស្សន្តរមហារាជនោះទ្រង់ឱ្យព្រះឱរសព្រះធីតាដល់ព្រាហ្មណ៍ជូជកហើយ ញុាំងផែនដីឱ្យញាប់ញ័រ ។

គប្បីសម្តែងនាយកេវដ្ដៈ អ្នកអាស្រ័យនៅត្រង់ឆ្នេរស្ទឹង កល្យាណទីក្នុងពាក្យនេះថា ទក្ខិណាខ្លះបរិសុទ្ធិខាងអ្នកទទួល ។ បានឮថាកេវដ្ដៈនោះ បានថ្វាយបិណ្ឌបាតដល់ព្រះទីឃសោមត្ថេរៈ ដល់ ៣ ដង ដេកលើគ្រែជាទីស្ងាប់បានពោលថា បិណ្ឌបាតដែលថ្វាយដល់លោកម្ចាស់ទីឃសោមត្ថេរៈ រមែងលើកខ្ញុំឡើង ។

គប្បីសម្តែងដល់ព្រានអ្នកនៅក្នុងវឌ្ឍមានៈក្នុងបទថា នេវ ទាយកតោ នេវ ទាយកតោ នេះ ។ បានឮថា នាយព្រាននោះ កាលឱ្យទក្ខិណាឧទ្ទិសដល់អ្នកស្ងាប់ បានឱ្យដល់ភិក្ខុដែលទ្រុស្ត-សីលមួយរូបនោះឯងដល់ ៣ គ្រា ។ ក្នុងគ្រាទី ៣ អមនុស្សស្រែកឡើងថា មនុស្សទ្រុស្តសីលបន្ទន់ឆាន់ ដូច្នេះ ។ ក្នុងវេលាដែលព្រាននោះថ្វាយដល់ភិក្ខុដែលមានសីលមួយរូបមកដល់ផលរបស់ទក្ខិណាក៏ដល់គេ ។

គប្បីសម្តែងអសទិសទានក្នុងពាក្យនេះថា ទាយកតោ ចេវ វិសុជ្ឈតិ ទក្ខិណាខ្លះបរិសុទ្ធិខាងអ្នកឱ្យប៉ុណ្ណោះ ។

ក្នុងពាក្យថា សា ទក្ខិណា ទាយកតោ វិសុជ្ឈតិ ទក្ខិណានោះបរិសុទ្ធិខាងទាយកនេះ គប្បីជ្រាបសេចក្តីបរិសុទ្ធិនៃទានក្នុងបទទាំងពួងដោយទំនងនេះថា អ្នកស្រែ អ្នកឆ្ការតបានស្រែ

សូម្បីមិនល្អ នង្គ័លក្នុងសម័យកម្ចាត់ធូលី ជាំពូជដែលមានសារៈថែរក្សារហូតដល់អស់មួយយប់ កាលមិនដល់សេចក្តីប្រមាទ រមែងបានស្រូវល្អជាងស្រែដែលមិនថែរក្សារបស់អ្នកជនៃ ឈ្មោះយ៉ាងណា អ្នកមានសីលសូម្បីឱ្យទានដល់បុគ្គលអ្នកទ្រុស្តសីល រមែងបានផលច្រើនដូច្នោះ ។

ក្នុងបទថា **វីតរាគោ វីតរាគេសុ** នេះ ព្រះអនាគាមី ឈ្មោះថា ច្រាសចាករាគៈ ចំណែកព្រះអរហន្តជាអ្នកច្រាសចាករាគៈដោយមិនមានសេសសល់ ព្រោះដូច្នោះ ទានដែលព្រះអរហន្តឱ្យដល់ព្រះអរហន្តនោះឯង ជាទានដ៏ប្រសើរ ។ ព្រោះហេតុអ្វី ។ ព្រោះមិនមានសេចក្តីច្រាច្នាកពរបស់អ្នកអាល័យក្នុងកព ។

សួរថាព្រះខីណាស្រពរមែងមិនជឿផលទានមែនឬ ។

ឆ្លើយថា បុគ្គលទាំងឡាយដូចជាព្រះខីណាស្រព ដែលថាមិនជឿនូវផលទាននោះ មិនមានឡើយ ក៏កម្មដែលព្រះខីណាស្រពធ្វើហើយ មិនជាកុសល ឬអកុសលព្រោះជាអ្នកច្រាសចាកឆន្ទៈរាគៈហើយ រមែងតាំងនៅក្នុងហានកិរិយា ដោយហេតុនោះ បណ្ឌិតទាំងឡាយទើបពោលថា ទានសូមក្នុងព្រះខីណាស្រពនោះមានផល

ច្រើន ដូច្នេះ ។

សួរថា ក៏ទានដែលព្រះសម្មាសម្ពុទ្ធទ្រង់ឱ្យដល់ព្រះសារីបុត្តត្ថេរៈមានផលច្រើន ឬថា ទានដែលព្រះសារីបុត្តត្ថេរៈថ្វាយចំពោះព្រះសម្មាសម្ពុទ្ធមានផលច្រើន ។

ឆ្លើយថា បណ្ឌិតទាំងឡាយពោលថា ទានដែលព្រះអង្គទ្រង់ឱ្យដល់ព្រះសារីបុត្រមានផលច្រើន ។ ព្រោះហេតុអ្វី ។ ព្រោះបុគ្គលដទៃវៀរព្រះសម្មាសម្ពុទ្ធឈ្មោះថាអាចឱ្យញុំាងផលទានឱ្យកើតឡើងមិនមាន ។ ពិតយ៉ាងនោះ ទាន រមែងឱ្យផលដល់អ្នកអាចដើម្បីធ្វើដោយសម្បទា៤ក្នុងអត្តភាពនោះឯង ។

សម្បទាក្នុងសូត្រនេះមានដូច្នេះគឺ ៖

- ទេយ្យធម៌បានមកដោយមិនបៀតបៀនអ្នកដទៃ ប្រកបដោយធម៌ដ៏ប្រពៃ

- ប្រកបដោយចេតនា ដោយមានបុព្វចេតនាជាដើម ជាធម៌ធំ ។

- អ្នកទទួលមានគុណធម៌ដ៏ប្រសើរក្រៃលែង បានដល់ព្រះខីណាស្រព ។

- សេចក្តីដល់ព្រមដោយវត្តៈ គឺ ជាអ្នកចេញអំពីនិរោធសមាបត្តិ ក្នុងថ្ងៃនោះ ដូច្នេះ ។

ការសរុបសេចក្តីរឿងទានក្នុងសូត្រនេះ

ក៏ក្នុងទក្ខិណាវិភង្គសូត្រ ក្នុងចតុត្ថវគ្គ ឧបរិបណ្ណាសក ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទាន ២១ យ៉ាង ។

ចាដិបុគ្គលិកទានមាន ១៤

១-តថាគតេ អរហន្តេ សម្មាសម្ពុទ្ធេ ទានំ ទេតិ ឱ្យទានចំពោះព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។

២-បច្ចេកសម្ពុទ្ធេ ទានំ ទេតិ ឱ្យទានចំពោះព្រះបច្ចេកសម្ពុទ្ធ ។

៣-តថាគតសាវកេ អរហន្តេ ទានំ ទេតិ ឱ្យទានចំពោះព្រះអរហន្ត ជាសាវ័កបស់តថាគត ។

៤-អរហត្តផលសច្ឆិកិរិយាយ បដិបន្នេ ទានំ ទេតិ ឱ្យទានចំពោះបុគ្គល ដែលប្រតិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវអរហត្តផល ។

៥-អនាគាមិស្ស ទានំ ទេតិ ឱ្យទានចំពោះអនាគាមិ-បុគ្គល ។

៦-អនាគាមិផលសច្ឆិកិរិយាយ បដិបន្នេ ទានំ ទេតិ ឱ្យទានចំពោះបុគ្គលដែលប្រតិបត្តិ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវអនាគាមិផល ។

៧-សកទាគាមិស្ស ទានំ ទេតិ ឱ្យទានចំពោះសកទា-គាមិបុគ្គល ។

៨-សកទាគាមិផល សច្ឆិកិរិយាយ បដិបន្នេ ទានំ ទេតិ ឱ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវសកទាគាមិផល ។

៩-សោតាបន្នេ ទានំ ទេតិ ឱ្យទានចំពោះសោតាបន្ន-បុគ្គល ។

១០-សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នេ ទានំ ទេតិ ឱ្យទានចំពោះបុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល ។

១១-ពាហិរកេ កាមេសុ វីតរាគេ ទានំ ទេតិ ឱ្យទាន *ចំពោះអ្នកបួសខាងក្រៅ (ពុទ្ធសាសនា) ដែលប្រាសចាក តម្រេកក្នុងកាមទាំងឡាយ ។*

១២-បុថុជ្ជនសីលវន្តេ ទានំ ទេតិ ឱ្យទានចំពោះ *បុថុជ្ជនមានសីល*

១៣-បុថុជ្ជនទុស្សីលេ ទានំ ទេតិ ឱ្យទានចំពោះ *បុថុជ្ជនទ្រុស្តសីល*

១៤-តិរច្ឆានគតេ ទានំ ទេតិ ឱ្យទានចំពោះសត្វ *តិរច្ឆាន ។*

សច្ឆគតាទក្ខិណាទានមាន ៧

១-ពុទ្ធប្បមុខេ ឧភតោសង្ឃេ ទានំ ទេតិ *បុគ្គលឱ្យ ទានចំពោះសង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រធាន ។*

២-តថាគតេ បរិនិព្វុតេ ឧភតោសង្ឃេ ទានំ ទេតិ *កាលបើព្រះតថាគតបរិនិព្វានទៅ បុគ្គលឱ្យទានចំពោះសង្ឃទាំង ពីរចំណែក ។*

៣-ភិក្ខុសង្ឃេ ទានំ ទេតិ ឱ្យទានចំពោះតែភិក្ខុសង្ឃ ។

៤-ភិក្ខុនីសច្ឆេ ទានំ ទេតិ ឱ្យទានចំពោះតែភិក្ខុនីសង្ឃ ។

៥-ឯត្តកេ មេ ភិក្ខូ ច ភិក្ខុនិយោ ច សច្ឆាតោ ឧទ្ទិស្សថាតិ ទានំ ទេតិ បុគ្គល(ទៅនិមន្តអំពីភិក្ខុសង្ឃ)ថា សូមលោកម្ចាស់ទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណោះ ពួកភិក្ខុនីប៉ុណ្ណោះ អំពីសង្ឃដើម្បីខ្ញុំ ហើយទើបឱ្យទាន ។

៦-ឯត្តកេ មេ ភិក្ខុ សច្ឆាតោឧទ្ទិស្សថាតិទានំ ទេតិ បុគ្គល(ទៅនិមន្តអំពីសំណាក់សង្ឃ)ថា សូមលោកម្ចាស់ទាំងឡាយ ចាត់ពួកភិក្ខុប៉ុណ្ណោះអំពីសង្ឃដើម្បីខ្ញុំហើយទើបឱ្យទាន ។

៧-ឯត្តកា មេភិក្ខុនិយោ សច្ឆាតោ ឧទ្ទិស្សថាតិ ទានំ ទេតិ បុគ្គល(ទៅនិមន្តអំពីសំណាក់សង្ឃ)ថា សូមលោកម្ចាស់ទាំងឡាយ ចាត់ពួកភិក្ខុនីប៉ុណ្ណោះអំពីសង្ឃដើម្បីខ្ញុំ ហើយទើបឱ្យទាន ។

(សុត្តន្តបិដកភាគ ២៨, ទំព័រ ២២០-២២៦)

អធិប្បាយបាដិបុគ្គលិកទាន

ក៏បណ្តាទាន ២១ យ៉ាងនោះ ទានណាដែលបុគ្គលឱ្យហើយដល់សត្វតិរច្ឆាន ដើម្បីនឹងចិញ្ចឹមដោយអំណាចនៃគុណមានការដល់ព្រមដោយលក្ខណៈជាដើមនិងដោយអំណាចឱ្យបការៈមានការបានទឹកដោះនិងការចាំថែរក្សាជាដើម, ទាននោះ ព្រះអង្គទ្រង់មិនកំណត់យកទេ ព្រោះមិនប្រកបដោយលក្ខណៈនៃទាន ។ មែនពិត ការបរិច្ចាគដោយវត្ថុដែលគប្បីឱ្យរបស់ខ្លួន ដោយអំណាចសេចក្តីប្រាថ្នាដើម្បីសេចក្តីអនុគ្រោះ និងការបូជាឈ្មោះថា ទាន ។ ការបរិច្ចាគវត្ថុដែលគប្បីឱ្យ ដោយអំណាចការភ័យខ្លាចសេចក្តីស្រឡាញ់ និងប្រាថ្នាការសូកបាន់ជាដើម មិនឈ្មោះថា ទាន ទេ ព្រោះជាទានដែលមានទោស ។ វត្ថុសូម្បីត្រឹមតែពំនូតបាយ កន្ទុះពំនូតឯណាដែលបុគ្គលឱ្យហើយ សូម្បីវត្ថុនោះ ព្រះអង្គក៏មិនបានកំណត់យកដែរ ព្រោះមិនអាចក្នុងការឱ្យផលបានតាមដែលប្រាថ្នាចង់បាន ព្រោះការៈនៃទានដែលលួមដល់សេចក្តីត្រូវការនូវមិនទាន់បានបរិបូរណ៍ ។ ក៏ទានណាដែលបុគ្គលប្រាថ្នាចំពោះផលដោយនយជាដើមថា បុណ្យដែលសម្រេចដោយទាននេះឯង ចូរមាន

ដើម្បីសេចក្តីចម្រើននៃប្រយោជន៍សុខតទៅ ដូច្នេះ បានឱ្យដល់បណ្តាសត្វតិរច្ឆាន មានសុនខ ជ្រូក មាន់ និងក្អែកជាដើម សត្វឯណាមួយដែលខ្លួនបានជួបប្រទះហើយ ល្មមដល់សេចក្តីត្រូវការទាននោះព្រះអង្គទ្រង់កំណត់យកហើយថា ទានក្នុងសត្វតិរច្ឆាន ។

ឧរាន ក្នុងសត្វតិរច្ឆាននោះឈ្មោះថា មានអានិសង្ស ១០០ ដង ព្រោះឱ្យអានិសង្ស ៥០០ គឺឱ្យអាយុក្នុង ១០០ អត្តភាព ឱ្យពណ៌សម្បុរ ឱ្យសេចក្តីសុខ ឱ្យកម្លាំង ឱ្យបដិភាណក្នុង ១០០ អត្តភាព ។ គប្បីជ្រាបន័យ សូម្បីក្នុងទានដែលខ្ពស់ឡើងទៅយ៉ាងដូច្នេះដែរ ។

មួយទៀត ជនទាំងឡាយ មានព្រានសំណាញ់ និងអ្នកចាប់ត្រីជាដើម ដែលចិញ្ចឹមជីវិតដោយការបៀតបៀនសត្វជនៃ ឈ្មោះថា បុថុជ្ជនទ្រុស្តសីល **ឧរាន** ដែលគេឱ្យហើយដល់បុថុជ្ជនទ្រុស្តសីលនោះ មានអានិសង្ស ១០០០ ដង ។

ម្យ៉ាងទៀត បុគ្គលអ្នកមានសីល ដូចជាអ្នកមានសីល ជាអ្នកមិនអួតអាង មិនមានមាយា មិនបៀតបៀនសត្វជនៃ ចិញ្ចឹមជីវិតដោយកសិកម្ម ឬពាណិជ្ជកម្ម ដោយធម៌ស្មើ ឈ្មោះថា បុថុ-

ជួនមានសីល ។ **ទាន** ដែលគេឱ្យហើយដល់បុថុជ្ជនមានសីលនោះ មានអានិសង្ស ១ សែនជង ។

មួយទៀត អ្នកមានអភិញ្ញា ៥ ដែលជាលោកីយ៍ មានប្រក្រតីពោលកម្ម ជាអ្នកបួសខាងក្រៅ(ពុទ្ធសាសនា)ឈ្មោះថាជាអ្នកគ្មានសេចក្តីត្រេកអរក្នុងកាមទាំងឡាយ **ទាន** ដែលគេឱ្យហើយដល់តាបស អ្នកមិនមានសេចក្តីត្រេកអរក្នុងកាមទាំងឡាយនោះ មានអានិសង្ស ១ សែនកោដិ ។

ទាន ដែលគេឱ្យហើយដល់អ្នកទទួលទាំងឡាយ ១០ នេះ គឺដល់បុគ្គលដែលប្រតិបត្តិដើម្បីសោតាបត្តិផល ដល់ព្រះសោតាបន្ន ដល់បុគ្គលដែលប្រតិបត្តិដើម្បីសកទាគាមិផល ដល់ព្រះសកទាគាមី ដល់បុគ្គលដែលប្រតិបត្តិដើម្បីអនាគាមិផល ដល់ព្រះអនាគាមី ដល់បុគ្គលដែលប្រតិបត្តិដើម្បីអរហត្តផល ដល់ព្រះអរហន្ត ដល់ព្រះបច្ចេកពុទ្ធ ដល់ព្រះសម្មាសម្ពុទ្ធ ជាទានដែលវាប់មិនបានដោយផល ។

សួរថា សេចក្តីប្លែកផ្សេងគ្នានៃទានដែលគេឱ្យហើយដល់បដិគ្គាហក:ទាំង ១០ ពួកនោះ តើដូចម្តេចខ្លះ ?

ឆ្លើយថា ភាវៈនៃទានដែលគេឱ្យហើយ ចំពោះបុគ្គលដែលប្រតិបត្តិដើម្បីប្រយោជន៍ដល់សោតាបត្តិផល មានផលរាប់មិនបាន គប្បីជ្រាបដូចជាទឹកក្នុងចង្អូរជារបស់ដែលរាប់មិនបាន ដូច្នោះ ។ ភាវៈនៃទានដែលបុគ្គលថ្វាយហើយ ចំពោះព្រះអរិយបុគ្គលទាំងឡាយ មានព្រះសោតាបន្នជាដើម ជាទានមានផលរាប់មិនបាន ដោយអំណាចគុណខ្ពស់ក្រៃលែងជាងគ្នាន គប្បីជ្រាបដូចជាទឹកក្នុងមហានទី និងក្នុងមហាសមុទ្រនោះ ។ ជារបស់ដែលរាប់មិនបានដូច្នោះ ។ សេចក្តីនេះគប្បីជ្រាបសូម្បីក្នុងភាវៈនៃអាចម៍ដីចាប់ដើមអំពីអាចម៍ដីក្នុងប្រទេសដែលមានទំហំស្មើនឹងមណ្ឌលាននៃផែនដី រហូតដល់អាចម៍ដីពេញទាំងផែនដីប្រមាណមិនបាន ។ មែនពិត សូម្បីកាលបើមានភាវៈនៃទានទាំងនោះ ជាទានស្មើគ្នាដោយភាវៈជាទានមានផលរាប់មិនបាន, ភាវៈនៃទានជារបស់តិចនិងច្រើន រមែងមានដូចគ្នា គប្បីជ្រាបដូចជាសំវដ្តកប្បជាដើម ជារបស់រាប់មិនបាន និងជាភាវៈនៃមហាកប្ប ក៏ជារបស់ដែលរាប់មិនបានដូច្នោះ ។

បណ្តាអ្នកទទួលទាំងនោះ អ្នកទទួលទាំង៨នេះ គឺឧបាសក

អ្នកដល់នូវព្រះត្រៃសរណៈ, ឧបាសកអ្នកតាំងនៅក្នុងសីល ៥, ឧបាសកអ្នកតាំងនៅក្នុងសីល១០, សាមណេរដែលបួសក្នុងថ្ងៃនោះ,ភិក្ខុអ្នកគ្រាន់តែបួសហើយភ្លាម,ភិក្ខុអ្នកដល់ព្រមដោយវត្ត, ភិក្ខុអ្នកប្រារព្ធវិបស្សនា, ភិក្ខុអ្នកតាំងនៅក្នុងបឋមមគ្គ ឈ្មោះថាជាអ្នកប្រតិបត្តិដើម្បីប្រយោជន៍ដល់សោបត្តិផល ។ មែនពិត ការចុះកាន់ព្រះសាសនា ក៏ត្រឹមតែដើម្បីរលាស់ចេញនូវទុក្ខក្នុងវដ្ត-សង្សារនិងត្រឹមតែដើម្បីចាក់ឫសនូវមគ្គតែប៉ុណ្ណោះ, ព្រោះហេតុនោះ កិរិយាដល់នូវសរណៈ ការសមាទានសិក្ខាបទបព្វជ្ជាឧបសម្បទ ការញុំាងសីលឱ្យបរិបូរណ៍ ការប្រកបរឿយ ៗ នូវអធិចិត្តសិក្ខាវិបស្សនាដែលជាចំណែកនៃការត្រាស់ដឹង សរុបទៅបដិបទ ទាំងនេះ ជាការបដិបត្តិដើម្បីធ្វើឱ្យជាក់ច្បាស់នូវសោតាបត្តិផល ដោយពិត ។

ប្រៀបដូចជាសមាធិភាវនា ដែលជាចំណែកនៃកិរិយាត្រាស់ដឹង រមែងជាឧបនិស្សយដោយភាវៈជាបច្ច័យនៃការសម្រេចនូវអរិយមគ្គ ជាបន្តបន្ទាប់គ្នាទៅយ៉ាងណាមិញ ការធ្វើសីលឱ្យបរិបូរណ៍ ឧបសម្បទ បព្វជ្ជាកិរិយាតាំងនៅក្នុងសីល ១០ ឬសីល

៥ របស់ឧបាសកដែលជាចំណែកនៃការត្រាស់ដឹង ដោយហោច
ទៅ សូម្បីការដល់នូវសរណៈដែលជាចំណែកនៃការត្រាស់ដឹង
រមែងជាឧបនិស្សយនៃការបាននូវអរិយមគ្គ ក៏យ៉ាងដូច្នោះដែរ
ព្រោះហេតុនោះ បដិបទាទាំងអស់នេះ ព្រះមានព្រះភាគជាម្ចាស់
ទ្រង់ត្រាស់ថា ជាសេចក្តីបដិបត្តិដើម្បីប្រយោជន៍ដល់សោតាបត្តិ-
ផលដូច្នេះ ។

បណ្តាបដិគ្គាហក:ទាំង ៨ ពួកនោះ សូម្បីទានដែលបុគ្គល
ឱ្យហើយ ដល់ឧបាសកអ្នកដល់នូវត្រៃសរណៈក៏រមែងមានផល
រាប់មិនបាន សេចក្តីជ្រះថ្លាដែលញាណជម្រះហើយ ដែលសង្រ្គោះ
ដោយសេចក្តីរាប់អាននិងសេចក្តីគោរពដ៏ច្រើន ក្នុងព្រះមានព្រះ
ភាគជាម្ចាស់ ក្នុងព្រះធម៌ ក្នុងព្រះសង្ឃ ដោយអាការៈយ៉ាង
ប្រសើរក្រៃលែង ដែលប្រព្រឹត្តទៅហើយដោយអាការៈថា ភាវៈ
ជាអ្នកមានព្រះវតនត្រ័យនោះជាខាងដើម ជាអាទិថា ព្រះមានព្រះ
ភាគជាម្ចាស់ ទ្រង់បានត្រាស់ដឹងដោយប្រពៃចំពោះព្រះអង្គឯង ព្រះ
ធម៌ គឺព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្តែងហើយដោយ
ល្អ ព្រះសង្ឃជាអ្នកប្រដិបត្តិហើយដោយល្អ ដូច្នេះ ឈ្មោះថា

សរណាគមន៍ ។ បុណ្យដែលបុគ្គលធ្វើហើយក្នុងសន្តាន ដែលខ្ជនអប់រំហើយដោយសេចក្តីជ្រះថ្លា ដែលប្រព្រឹត្តទៅក្នុងវត្តព្រះរតនត្រ័យនោះ រមែងជាទានមានផលច្រើន ព្រោះកិរិយាជល់ព្រមនៃខេត្ត ដោយប្រការដូច្នេះឯង ។

ឆាន ដែលបុគ្គលឱ្យហើយ ជល់ឧបាសកអ្នកមានសីល ៥ ជាទានមានផលច្រើនជាងទាននោះ ។ ព្រោះថា សរណាគមន៍ គឺកិរិយាជល់ព្រមនៃអធ្យាស្រ័យ ព្រោះមានសេចក្តីជ្រះថ្លាក្នុងវត្ថុ ៣ យ៉ាង, ព្រះរតនត្រ័យ សរុបសេចក្តីទៅ សីល ៥ របស់ឧបាសកអ្នកប្រាកជដូច្នោះនោះ ក៏គឺសេចក្តីសង្រួមកាយ វាចា ដែលកិរិយាជល់ព្រមនៃអធ្យាស្រ័យឧបត្ថម្ភហើយ ។ ព្រោះហេតុនោះ ទានដែលបុគ្គលឱ្យហើយចំពោះឧបាសកអ្នកមានសីល ៥ នោះ ទើបឈ្មោះថា មានផលច្រើនយ៉ាងដូច្នេះ ។

ឆាន ដែលបុគ្គលឱ្យហើយ ចំពោះឧបាសកអ្នកមានសីល ១០ នោះ ជាទានមានផលច្រើនជាងទានដែលគេ ឱ្យជល់ឧបាសកអ្នកមានសីល ៥ នោះ ។ មែនពិត សីល ១០ ឈ្មោះថា សីលរបស់ឧបាសកយ៉ាងបរិបូរណ៌ ព្រោះហេតុនោះ ទានដែលបុគ្គល

ឱ្យហើយ ចំពោះឧបាសកអ្នកមានសីល ១០នោះ ទើបមានផលច្រើនដូច្នេះ ។

ឆាន ដែលបុគ្គលប្រគេនហើយ ដល់សាមណេរមានផលច្រើនជាងទាននោះ ។

ឆាន ដែលបុគ្គលប្រគេនហើយ ដល់ភិក្ខុអ្នកគ្រាន់តែបួសស្រេចហើយភ្លាម មានផលច្រើនជាងទាននោះ ។

ឆាន ដែលបុគ្គលប្រគេនហើយ ដល់ភិក្ខុអ្នកដល់ព្រមដោយវត្ត មានផលច្រើនជាងទាននោះ ។

ឆាន ដែលបុគ្គលប្រគេនហើយ ដល់ភិក្ខុអ្នកប្រារព្ធវិបស្សនា មានផលច្រើនជាងទាននោះ ។

ក៏ភាវៈនៃទាន ដែលបុគ្គលឱ្យហើយចំពោះបដិគ្គាហកៈនោះជាទានមានផលច្រើនប្លែកផ្សេង ៗគ្នា ។ ព្រោះភាវៈនៃគុណមានសីលរបស់សាមណេរជាដើម ប្រសើរជាងគ្នាជាដើម ព្រោះគុណដែលប្រសើរខ្ពង់ខ្ពស់ជាងគ្នាដូច្នេះ ។ ក៏ភាវៈនៃលោកអ្នកដែលដល់ព្រមដោយមគ្គ ឈ្មោះថា ជាអ្នកមានគុណមិនទាន់ពេញបរិបូរណ៍ ព្រោះលោកជាអ្នកមិនទាន់បានសម្រេចកិច្ច ព្រោះសង្កិ-

លេសធម៌ទាំងឡាយលោក កំពុងតែលះបង់និងព្រោះរៀងទានធម៌ទាំងឡាយ គឺលោកកំពុងតែចម្រើនដោយចំណែកនោះ ៗ ក៏ភាវៈនៃលោកអ្នក ដែលដល់ព្រមដោយផលទាំងឡាយ ឈ្មោះថា ជាអ្នកមានគុណបរិបូណ៌ហើយ ព្រោះលោកជាអ្នកមានកិច្ចសម្រេចហើយ ព្រោះហេតុនោះ គប្បីជ្រាបភាវៈនៃលោកអ្នកដែលតាំងនៅក្នុងផលជាខេត្តដ៏ខ្ពង់ខ្ពស់ជាងអ្នកដែលតាំងនៅក្នុងមគ្គនោះ ៗ ។

មួយទៀត ភាវៈនៃលោកអ្នកដែលតាំងនៅក្នុងមគ្គខាងលើ ជាអ្នកមានគុណខ្ពង់ខ្ពស់ ជាងលោកអ្នកដែលតាំងនៅក្នុងមគ្គខាងក្រោមនិងភាវៈនៃលោកអ្នកដែលតាំងនៅក្នុងផលខាងលើ ជាអ្នកមានគុណខ្ពង់ខ្ពស់ ជាងលោកអ្នកដែលតាំងនៅក្នុងផលខាងក្រោម, ប្រាកដហើយមែនពិត ។ មែនពិតដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ភាវៈនៃទានដែលបុគ្គលប្រគេនហើយ ដល់ព្រះអរិយបុគ្គលអ្នកមានគុណខ្ពង់ខ្ពស់ទាំងឡាយជាទានមានផលច្រើន ។

សួរថា ឈ្មោះថា ភាវៈនៃលោកអ្នកដែលព្រមព្រៀង ដោយមគ្គ ដែលធម្មតាកំណត់ហើយ ដោយលក្ខណៈនៃមគ្គចិត្ត, ក៏ក្នុងខណៈនោះ ការប្រគេនទានក្តី ការទទួលទានក្តី នឹងមានព្រមយ៉ាងដូចម្តេច ?

ឆ្លើយថា ភិក្ខុអ្នកប្រារព្ធវិបស្សនាជាអ្នកឈរនៅត្រង់មាត់ទ្វារផ្ទះ ឬអង្គុយនៅក្នុងវិហារនិងសាលាឆាន់ ទាយកទទួលបាត្រវបស់លោកហើយ ក៏ដាក់នូវបស់ដែលគួរឆាន់គួរបរិភោគចូលទៅ,ក្នុងខណៈនោះ ការចេញចាកកិលេសដោយមគ្គ រមែងមានដល់ភិក្ខុ ទាននេះឈ្មោះថា ជាទានដែលប្រគេនហើយ ដល់លោកអ្នកដែលព្រមព្រៀងដោយមគ្គ ។

ទាន ១៤ យ៉ាងនេះ ឈ្មោះថា បាដិបុគ្គលិកទាន ព្រោះធ្វើវិគ្រោះថា ចំពោះបុគ្គលគឺចំពោះបុគ្គលម្នាក់ ឈ្មោះថា ចំពោះបុគ្គល, ទានដែលឈ្មោះថា បាដិបុគ្គលិកទាន ព្រោះអត្ថថា គឺគេឱ្យដល់បុគ្គលចំពោះនោះ ។

អធិប្បាយសង្ឃគតាទក្ខិណាទាន

ក៏ទានដែលបុគ្គលប្រគេនហើយ ដល់បុគ្គលទាំង ៧ ពួកនេះ គឺបុគ្គលឱ្យទានចំពោះសង្ឃទាំងពីរចំណែក មានព្រះពុទ្ធជាប្រធាន ។ល។ បុគ្គលទៅនិមន្តអំពីសំណាក់សង្ឃថា សូមលោកទាំងឡាយ ចាត់ពួកភិក្ខុនីប៉ុណ្ណោះអំពីសង្ឃដើម្បីខ្ញុំហើយទើបឱ្យទាន ឈ្មោះថា ទានដែលប្រព្រឹត្តទៅក្នុងសង្ឃ ។ ទានដែលប្រព្រឹត្តទៅ

ក្នុងសង្ឃទាំងអស់នោះមានផលវាប់មិនបាន ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ចំពោះព្រះអានន្ទដូច្នេះថា ម្នាលអានន្ទ ក្នុងកាលអនាគតនឹងមានគោត្រភូសង្ឃ(សង្ឃមានតែឈ្មោះ) មានតែសំពត់កាសាវៈចង-ក ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក ជនទាំងនោះឧទ្ទិសចំពោះសង្ឃ ហើយនឹងឱ្យទានដល់បុគ្គលទ្រុស្តសីលទាំងនោះ ម្នាលអានន្ទ សូម្បីក្នុងកាលនោះ ក៏តថាគតពោលថា សង្ឃគតាទក្ខិណាទានមានអានិសង្សវាប់មិនបាន ប្រមាណមិនកើតដែរ ម្នាលអានន្ទ តថាគតមិនដែលពោលនូវបាដិបុគ្គលិកទានថាមានអានិសង្សច្រើនជាងសង្ឃគតាទក្ខិណាទាន ដោយបរិយាយណាមួយឡើយ ។

ដោយហេតុនោះ ក្នុងអដ្ឋកថា ទក្ខិណាវិភង្គសូត្រ ទើបលោកពោលថា សូម្បីទក្ខិណាដែលបុគ្គលប្រគេនហើយចំពោះព្រះសង្ឃមានព្រះពុទ្ធជាប្រធានព្រះមានព្រះភាគទ្រង់ត្រាស់ថា ឈ្មោះថា ទានមានផលវាប់មិនបាន ព្រោះការវាប់ដោយគុណដូច្នេះ ។ មែនពិត ទក្ខិណាដែលប្រព្រឹត្តទៅក្នុងព្រះសង្ឃ រមែងមានដល់បុគ្គលដែលអាចដើម្បីនឹងធ្វើនូវសេចក្តីគោរពកោតក្រែង ចំពោះ

ព្រះសង្ឃ ។ តែក៏រីឯធ្វើនូវសេចក្តីគោរពកោតក្រែងចំពោះព្រះសង្ឃជាកិច្ចដែលធ្វើបានដោយកម្រ ។ ក៏បុគ្គលណាចាត់ចែងនូវទេយ្យធម៌ដោយគិតថា អាត្មាអញនឹងប្រគេននូវទានដែលប្រព្រឹត្តទៅក្នុងព្រះសង្ឃ ដូច្នេះ ទៅកាន់វត្តពោលថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន សូមព្រះគុណម្ចាស់ឱនូវព្រះថេរៈ ១ រូប ចាកអំពីព្រះសង្ឃដូច្នេះ,លុះដល់បានសាមណេរអំពីព្រះសង្ឃហើយក៏រមែងដល់នូវភាពជាដទៃ អន់ចិត្តថា អាត្មាអញបានសាមណេរៈ ដូច្នេះ, ទក្ខិណារបស់បុគ្គលនោះរមែងមិនឈ្មោះថា ប្រព្រឹត្តទៅក្នុងព្រះសង្ឃទេ ។ សូម្បីកាលបើបានព្រះមហាថេរៈហើយ ទោះជាធ្វើសេចក្តីសោមនស្សឱ្យកើតឡើងថា អាត្មាអញបានព្រះមហាថេរៈដូច្នេះ, ទក្ខិណានោះក៏មិនឈ្មោះថា ប្រព្រឹត្តទៅក្នុងព្រះសង្ឃដូចគ្នាដែរ ។ ចំណែកបុគ្គលណា បានបដិគ្គាហកៈជាសាមណេរ ឬឧបសម្បន្នជាកំលោះ ឬព្រះថេរៈជាពាល ឬបណ្ឌិតរូបណាមួយចាកពីព្រះសង្ឃ ជាអ្នកមិនមានសេចក្តីសង្ស័យ រមែងអាចដើម្បីនឹងធ្វើនូវសេចក្តីគោរពកោតក្រែងក្នុងព្រះសង្ឃថា អាត្មាអញប្រគេនដល់ព្រះសង្ឃ ដូច្នេះ, ទក្ខិណារបស់បុគ្គលនោះរមែងឈ្មោះថា

ជាទានដែលប្រព្រឹត្តទៅក្នុងព្រះសង្ឃ ។ សមណៈដែលទាយកនិមន្តចំពោះចាកព្រះសង្ឃជាបុថុជ្ជន, ជាជិបុគ្គលិកជាព្រះសោតាបន្ន, កាលបើបុគ្គលអាចធ្វើសេចក្តីគោរពកោតក្រែងក្នុងព្រះសង្ឃទានដែលបុគ្គលប្រគេនហើយចំពោះសមណៈដែលជាបុថុជ្ជន ក៏ជាទានមានផលច្រើនជាង ។ សូម្បីក្នុងពាក្យជាដើមថា សមណៈដែលទាយកនិមន្តចំពោះចាកសង្ឃ ជាព្រះសង្ឃបដិគ្គាហកៈ ជាព្រះសកទាគាមីក៏នំយនេះដូចគ្នាដែរ ។ មែនពិត កាលបើបុគ្គលអាចដើម្បីនឹងធ្វើនូវសេចក្តីគោរពកោតក្រែង ចំពោះព្រះសង្ឃទានដែលបុគ្គលប្រគេនហើយ សូម្បីចំពោះសមណៈទុស្តសីលដែលគេនិមន្តចំពោះចាកសង្ឃ ក៏ជាទានមានផលច្រើនជាងទានដែលប្រគេនចំពោះព្រះខីណាស្រពដោយពិត ។ ក៏ព្រះតម្រាស់ណាដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា បពិត្រមហារាជ ទានដែលបុគ្គលប្រគេនហើយដល់សមណៈអ្នកមានសីល ជាទានមានផលច្រើន, ដែលប្រគេនហើយ ដល់សមណៈដែលទុស្តសីលមិនមានផលច្រើនយ៉ាងដូច្នោះទេ ដូច្នេះ, ព្រះតម្រាស់នោះព្រះអង្គទ្រង់ត្រាស់លះនំយនេះចោល ។

ដីកាទក្ខិណាវិភង្គសូត្រនោះថា

បទថា គុណាសច្ចាយ សេចក្តីថា ព្រោះការគណនារាប់ដោយផលអានិសង្ស គឺព្រោះភាវៈនៃទានមានផលច្រើន ។ ទក្ខិ-ណាព្រះមានព្រះភាគទ្រង់ត្រាស់ថាមានផលរាប់មិនបាន ក៏ព្រោះភាវៈនៃទក្ខិណានោះ គឺបុគ្គលប្រគេនហើយចំពោះសង្ឃ ។ ក៏ការប្រគេនចំពោះព្រះសង្ឃ រមែងមានដោយវិធីណា,ដើម្បីនឹងសម្តែងនូវវិធីនោះ ព្រះអដ្ឋកថាចារ្យ ទើបពោលពាក្យជាដើមថា សច្ឆគៈ-តា ទក្ខិណា ហិ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា ចិតិការំ បានដល់ សេចក្តីគោរព ។ ចាកពីព្រះសង្ឃមិនមែនចាកបុគ្គល ។ បទថា អញ្ញថត្តំ មានសេចក្តីថា មិនញ៉ាំងចិត្តឱ្យកើតឡើងយ៉ាងនេះថា ទាន ជាទាន គឺអាត្មាអញឱ្យហើយដល់បុគ្គលនេះ, ដូច្នេះ ហើយចាត់ចែងនូវទេយ្យធម៌ដោយគិតថា អាត្មាអញនឹងប្រគេនដល់ព្រះសង្ឃ ដូច្នេះ រមែងដល់នូវភាវៈជាអ្នកមានចិត្តផ្សេង អន់ចិត្តថា ទាន ឈ្មោះថាជាទានដែលអាត្មាអញគប្បីប្រគេនដល់សាមណេរ ដូច្នេះ, ព្រោះហេតុនោះ ទក្ខិណារបស់បុគ្គលនោះ រមែងមិនឈ្មោះថា ជាទាន

ដែលប្រព្រឹត្តទៅក្នុងព្រះសង្ឃទ្បើយ ទក្ខិណាវមែងមិនឈ្មោះថា ប្រព្រឹត្តទៅក្នុងព្រះសង្ឃបាន ក៏ព្រោះធ្វើចិត្តឱ្យប្រែប្រួលទៅដោយ អំណាចនៃបុគ្គល ។

ពីរបទថា **និព្ពេមតិកោ ហុត្វា** មានសេចក្តីថា មិនញុំាងសេចក្តីសង្ស័យឱ្យកើតទ្បើងថា ទាន ជាទានដែលអាត្មាអញឱ្យហើយដល់បុគ្គលនេះ ឬក៏មិនបានឱ្យហើយឬទេហ្ន៎ ។

ពីរបទថា **សទ្ធេ ចិត្តីការំ** មានសេចក្តីថា កាលបើបុគ្គលនឹករលឹកដល់គុណនៃព្រះសង្ឃ មានភាវៈជាអ្នកប្រតិបត្តិប្រពៃជាដើមប្រកេនដោយអំណាចសេចក្តីគោរព ដែលកើតទ្បើងហើយក្នុងបុគ្គលនោះប្រៀបដូចជាប្រកេនទូវចំពោះមុខនៃព្រះសង្ឃ ដោយសេចក្តីគោរពក្នុងសង្ឃគុណ ទានដែលបុគ្គលប្រកេនហើយចំពោះគណៈជាបុថុជ្ជន ក៏វមែងមានផលច្រើនជាង ។ ទានដែលបុគ្គលប្រកេនហើយចំពោះគណៈអ្នកទ្រុស្តសីល ក៏វមែងមានផលច្រើនជាងទាន ដែលគេប្រកេនចំពោះព្រះខីណាស្រព ដោយពិត ព្រោះសមណៈនោះ គេនិមន្តចំពោះអំពីព្រះសង្ឃ និងព្រោះគេប្រកេនហើយ ដោយគិតយ៉ាងនេះថា អាត្មាអញនឹងប្រកេនដល់ព្រះសង្ឃដូច្នេះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាល

អានន្ទ តថាគតមិនដែលពោលនូវបាដិបុគ្គលិកទានថា មានអានិ-
សង្សច្រើនជាងសង្ឃគតាទក្ខិណាទាន ដោយបរិយាយណាមួយ
ឡើយដូច្នេះ ។ ព្រះអដ្ឋកថាចារ្យចោទសួរថា ប្រសិនបើទានដែល
គេប្រគេនហើយ សូម្បីចំពោះសមណៈអ្នកទ្រុស្តសីលដែលគេ
និមន្តចំពោះអំពីព្រះសង្ឃ រមែងជាទានមានផលច្រើនជាង(ទាន
ដែលបុគ្គលប្រគេនហើយចំពោះព្រះខីណាស្រព) កាលបើមាន
យ៉ាងដូច្នេះ, ពាក្យថា បពិត្រមហារាជ ទានដែលបុគ្គលប្រគេន
ហើយដល់បុគ្គលអ្នកមានសីលនុ៎ះឯង ជាទានមានផលច្រើន, ដែល
ប្រគេនដល់បុគ្គលទ្រុស្តសីល មិនមានផលច្រើនយ៉ាងដូច្នោះទេ
ដូច្នេះនេះ តើយ៉ាងដូចម្តេចហ្ន៎ ! ដូច្នេះហើយ ទើបពោលថា ពាក្យ
នោះ ព្រះមានព្រះភាគត្រាស់ហើយ លះបង់នូវនិយាយនេះចោល
ដូច្នេះ ។

ឆ្លើយថា ពាក្យនោះ ព្រះអង្គទ្រង់លះចោលនូវវិធីនិមន្ត
ចំពោះអំពីព្រះសង្ឃ ហើយត្រាស់ដោយអំណាចការនិមន្តសមណៈ
អ្នកទ្រុស្តសីលតែម្យ៉ាង ដូច្នេះ ។

(មង្គលត្ថទីបនី)

អានិសង្សនៃការធ្វើទាន

ការលះបង់ទ្រព្យសម្បត្តិធ្វើទាន ពិតជាមិនឥតប្រយោជន៍ឡើយ ។ ការឱ្យទាននេះមានប្រយោជន៍យ៉ាងធំធេងណាស់ដល់ប្រទេសជាតិ បើជាច់ឫមិនមានការឱ្យទាននេះហើយ នៅក្នុងសង្គមជាតិទាំងមូល ក៏មិនមានទូវសេចក្តីសុខដែរ ដូចជា ៖

- **មាតាបិតា** បើមិនបានឱ្យទាន គឺមិនចិញ្ចឹមយើងមកទេ យើងប្រាជកជាត្រូវស្លាប់តាំងអំពីកើតមកម្ល៉ះ ។

- **ស្វាមីភរិយា** រកទ្រព្យសម្បត្តិបានមក បើមិនប្រើប្រាស់ចាយវាយ ឬចិញ្ចឹមគ្នានិងគ្នា ចិញ្ចឹមគ្រួសារទេ វាប្រាកដជាបែកបាក់គ្នាជាមិនខាន ។

- **គ្រូអាចារ្យ** បើមិនឱ្យទាន គឺមិនលះបង់នូវមន្តវិជ្ជាដល់កូនសិស្សទេ កូនសិស្សនឹងល្ងិតល្ងង់រកទីពឹងគ្មាន ។

សរុបមក ជីវិតរបស់មនុស្សយើង ដែលរស់នៅបាន ក៏ព្រោះទាន,យើងមានវ័យធំមកបានក៏ព្រោះទាន,យើងមានសេចក្តីចេះដឹងក្នុងកិច្ចការផ្សេង ៗបានក៏ព្រោះទាន, លោកនេះនឹងមានសេចក្តីសុខទៅបានក៏ព្រោះទាន,ហេតុនេះ ទាន ទើបជាកិច្ចសំខាន់បំផុត និងមានប្រយោជន៍ដ៏យ៉ាងធំធេងដល់សង្គមលោក ។

ម្យ៉ាងទៀត ចំពោះការធ្វើទាននេះមានអានិសង្សច្រើនទៀត ដូចដែលព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ព្រះសូត្រជាបន្តបន្ទាប់ខាងក្រោម ៖

សីហសូត្រ

នៅក្នុងបិដកលេខ ៤៤, ទំព័រ ៧៤ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់នូវ(**ផលនៃការឱ្យទាន ៥ប្រការ**)មានសេចក្តីថា ៖

សម័យមួយ ព្រះដ៏មានព្រះភាគគង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះសីហៈសេនាបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះសីហៈសេនាបតីអង្គុយក្នុងទីសមគួរហើយ បានក្រាបទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គអាចបញ្ញត្តផលទាន ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯងបានឬទេ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលសីហៈ អាចបញ្ញត្តបាន ម្នាលសីហៈ ៖

- ទាយកអ្នកម្ចាស់ទាន ជាទីស្រឡាញ់ ជាទីគាប់ចិត្ត របស់ជន

ច្រើនដោយហេតុណា ហេតុនេះឯង ជាផលទានរបស់បុគ្គលដែលគប្បីឃើញច្បាស់ដោយខ្លួនឯង ។

- *ម្នាលសីហៈ* មួយទៀត **ពួកសប្បុរសរួកមានចិត្តស្ងប់រម្ងាប់រមែងរាប់រកទាយករួកម្ចាស់ទាន ម្នាលសីហៈ បើពួកសប្បុរស មានចិត្តស្ងប់រម្ងាប់ តែងរាប់រកទាយកអ្នកម្ចាស់ទាន** ដោយហេតុណា ហេតុនេះឯង ជាផលទានរបស់បុគ្គលដែលគប្បីឃើញច្បាស់ដោយខ្លួនឯង ។

- *ម្នាលសីហៈ* មួយទៀត **កិត្តិសំឡេងដ៏ពីរោះរបស់ទាយករួកម្ចាស់ទាន រមែងខ្ចរខ្ចាយទៅម្នាលសីហៈឯកិត្តិសព្ទដ៏ពីរោះរបស់ទាយកម្ចាស់ទាន រមែងខ្ចរខ្ចាយទៅ** ដោយហេតុណា ហេតុនេះឯងជាផលទានដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ។

- *ម្នាលសីហៈ* មួយទៀត **ទាយកម្ចាស់ទានចូលទៅកាន់បរិសំទណាមោះជាខត្តិយបរិសទំក្តីព្រាហ្មណបរិសទំក្តីគហបតីបរិសំទក្តីសមណបរិសំទក្តីក៏ក្លៀវក្លាមិនមានសេចក្តីរឿនខ្មាសដោយហេតុណា** ហេតុនេះឯង ជាផលទាន ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ។

- *ម្នាលសីហៈ* មួយទៀត **ទាយកម្ចាស់ទាន លុះបែកធ្លាយ**

រាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ម្នាលសីហៈ បើទាយកម្ចាស់ទានបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ដោយហេតុណា ហេតុនេះឯង ជាផលទានដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ។

កាលព្រះដ៏មានព្រះភាគ ត្រាស់យ៉ាងនេះហើយ សីហសេនាបតីបានក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ផលទានទាំង ៤ ប្រការ ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ដែលព្រះដ៏មានព្រះភាគសម្តែងប្រាប់ហើយនេះ ខ្ញុំព្រះអង្គមិនបាច់ជឿព្រះដ៏មានព្រះភាគ ត្រង់ផលទានទាំងនោះទេ ខ្ញុំព្រះអង្គបានដឹងនុ៎ះដែរ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយក ម្ចាស់ទាន រមែងជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ជនច្រើន ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយកម្ចាស់ទាន ពួកសប្បុរសអ្នកមានចិត្តស្ងប់រម្ងាប់តែងវាប់រកខ្ញុំព្រះអង្គ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយកម្ចាស់ទាន កិត្តិសព្ទដ៏ពីរោះរបស់ខ្ញុំក៏លាន់ឮថា សីហសេនាបតីជាអ្នកឱ្យទាន ជាអ្នកធ្វើបុណ្យ អ្នកឧបដ្ឋានសង្ឃ ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាទាយកម្ចាស់ទានចូលទៅកាន់បរិស័ទណា ទោះជាខត្តិយបរិស័ទក្តី ព្រាហ្មណបរិស័ទក្តី គហបតីបរិស័ទក្តី សមណបរិស័ទក្តី ក៏ក្លៀវក្លា មិនមានសេចក្តីអៀនខ្មាស ។

បពិត្រព្រះអង្គដ៏ចម្រើន ផលទានទាំង ៤ ប្រការ ដែលបុគ្គលគប្បីឃើញច្បាស់ដោយខ្លួនឯង ដែលព្រះដ៏មានព្រះភាគសម្តែងហើយ ខ្ញុំព្រះអង្គមិនជាប់ជឿព្រះដ៏មានព្រះភាគ ត្រង់ផលទានទាំងនោះទេ ដ្បិតខ្ញុំព្រះអង្គដឹងនូវផលទានទាំងនោះដែរ ។

បពិត្រព្រះអង្គដ៏ចម្រើន ត្រង់ដែលព្រះដ៏មានព្រះភាគបានត្រាស់ទីនឹងខ្ញុំព្រះអង្គយ៉ាងនេះរួចហើយថា ម្នាលសីហៈ ទាយកម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិសួគ៌ ទេវលោក ។ ខ្ញុំព្រះអង្គមិនដឹងហេតុនុ៎ះមែន ក៏ប៉ុន្តែថា ខ្ញុំព្រះអង្គចេះតែជឿព្រះដ៏មានព្រះភាគក្នុងផលទាននោះ ។ ម្នាលសីហៈ រឿងនុ៎ះពិតមែន ម្នាលសីហៈ រឿងនុ៎ះពិតមែន ម្នាលសីហៈ ទាយកម្ចាស់ទាន លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ។

ធនំ បិយោ ហោតិ ភជន្តិ នំ ពហូ
កិត្តឹ ច បប្បោតិ យសស្ស វឌ្ឍតិ
អមច្ចភូតោ បរិសំ វិគាហតិ
វិសារទោ ហោតិ ឆរោ អមច្ចរី
តស្មា ហិ ធានានិ ធនន្តិ បណ្ឌិតា
វិនេយ្យ អមច្ឆេរមលំ សុខេសិនោ
តេ ឆឡង្គំ តិធិវេ បតិដ្ឋិតោ
ឆេវានំ សហព្យាគតា រមន្តិ តេ
កតាវកាសា កតកុសលា ឥតោ ចុតា
សយម្បភា អនុវិចរន្តិ នន្ទនេ
តេ តត្ថ នន្ទន្តិ រមន្តិ មោទរេ
សមម្បិតា កាមគុណេហិ បញ្ចហិ ។
កត្វាន វាក្យំ អសិតស្ស តាទិនោ
រមន្តិ សព្ពេ សុគតស្ស សាវកាតិ ។

នរជនមិនមានសេចក្តីកំណាញ់ ជាអ្នកឱ្យទានជាទីស្រឡាញ់ (របស់ជនដ៏ច្រើន)ផង ពួកសប្បុរសជាច្រើនតែងរាប់រកទាយកនោះផង (ទាយកនោះ)ដល់នូវកិត្តិសព្ទផងយសរមែងចំរើនដល់ទាយកនោះផង ទាយកនោះចូលទៅកាន់បរិស័ទ មិនមានសេចក្តីអៀនខ្មាស មានតែសេចក្តីក្លៀវក្លាផង ហេតុដូច្នោះ បណ្ឌិតទាំងឡាយអ្នកស្វែងរកសេចក្តីសុខត្រូវលះបង់នូវមន្ទិល គឺសេចក្តីកំណាញ់ហើយឱ្យនូវទានទាំងឡាយបណ្ឌិតទាំងនោះស្ថិតនៅក្នុងស្ថានត្រៃត្រឹង្សអស់កាលយូរអង្វែង បណ្ឌិតទាំងនោះ ទៅកើតក្នុងសហភាពនៃពួកទេវតារីករាយសប្បាយ បណ្ឌិតទាំងនោះមានឱកាសធ្វើហើយ មានកុសលធ្វើហើយ ច្យុតអំពីលោកនេះមានរស្មីខ្លួនឯង អន្ទោលទៅក្នុងទីជាទីត្រេកអរ បណ្ឌិតទាំងនោះស្កប់ស្កល់ដោយកាមគុណទាំង ៥ រីករាយសប្បាយក្នុងទីនោះ ។ ពួកសាវ័កទាំងអស់របស់ព្រះសុគត ធ្វើតាមពាក្យរបស់ព្រះតថាគត ព្រះអង្គមិនជាប់ដោយអកុសលធម៌ ប្រកបដោយតាទិគុណហើយរមែងរីករាយ ។

អដ្ឋកថា

បទថា សន្និដ្ឋិកំ បានដល់ ទីពឹងយើញដោយខ្លួនឯង ។

បទថា ទាយកោ គឺជាអ្នកខ្ជាប់ខ្ជួនក្នុងការឱ្យ ។ អធិប្បាយថា មិនមែនឈប់នៅដោយហេតុត្រឹមតែឈ្មោះថា ទានជារបស់ល្អប៉ុណ្ណោះទេ ថែមទាំងនៅអាចដើម្បីបរិច្ចាគបានផង ។

បទថា ទានបតិ បានដល់ ឱ្យទានយ៉ាងណា ទើបបានឈ្មោះថា ជាម្ចាស់នៃទាន ។ មិនមែនជាទាសៈ និងមិនមែនជាសហាយទាន ។

ក៏អ្នកណាខ្លួនឯងបរិភោគរបស់ឆ្ងាញ់របស់ល្អ តែឱ្យរបស់មិនឆ្ងាញ់ដល់បុគ្គលដទៃ អ្នកនោះជាទាសៈនៃទេយ្យធម៌ ពោលគឺទាសៈនៃទាន ។

អ្នកណាខ្លួនឯងបរិភោគរបស់ណា តែងឱ្យរបស់នោះ អ្នកនោះ ជាសហាយទាន(សម្លាញ់) ។

ចំណែកអ្នកណា ខ្លួនញុំាងអត្តភាពឱ្យប្រព្រឹត្តទៅដោយរបស់ធម្មតា ។ តែឱ្យរបស់ឆ្ងាញ់ ។ដល់បុគ្គលដទៃ អ្នកនោះឈ្មោះថា

ជាម្ចាស់ ជាធំ ជាម្ចាស់នៃទាន ។ ព្រះមានព្រះភាគទ្រង់ត្រាស់សំដៅយកទាយកអ្នកជាយ៉ាងនោះថាជាទានបតីដូច្នេះ ។

បទថា អមច្ចភូតោ បានដល់ មិនមែនជាអ្នកគ្មានអំណាច ។ បទថា វិសារទោ គឺបានសោមនស្សប្រកបដោយញាណ ។ បទថា សហព្យគតា គឺដល់សេចក្តីរួមគ្នាជាមួយគ្នា ។ បទថា កតាវកាសា សេចក្តីថា ឈ្មោះថាមានឱកាសដែលធ្វើហើយ ព្រោះខ្លួនធ្វើកម្មដែលមានឱកាសក្នុងត្រៃទិព្វនោះ តែហេតុកម្មនោះ ជាកុសលតែម្យ៉ាង ព្រោះដូច្នោះ ទើបត្រាស់ថា **កតកុសលា** (សាងកុសលទុក) ។ បទថា **មោឌរេ** គឺ រីករាយសប្បាយជានិច្ច ។ បទថា **អសិតស្ស** បានដល់ ព្រះតថាគតអ្នកដែលកិលេសអាស្រ័យមិនបាន ។ បទថា **តាទិនោ** គឺជាអ្នកដល់លក្ខណៈមាំមួន ។

ប្រវត្តិសង្ខេបរបស់សីហសេនាបតី

នៅនគរវេសាលី ពួកស្តេចលិច្ឆវីបានតែងតាំងសីហរាជកុមារជាសេនាបតី ។ សីហសេនាបតីជាឧបដ្ឋាកទំនុកបម្រុងដល់

និគន្ថនាដបុត្រ ។ នៅក្នុងជម្ពូទ្វីបមានជន ៣ រូប ជាបុគ្គលកំពូលក្នុងការឧបត្ថម្ភពួកនិគ្រន្ថ គឺឧបាលីគហបតីនៅស្រុកនាលន្ទា វប្ប-សក្យៈនៅនគរកបិលពស្តុ និងសីហសេនាបតីនៅនគរវេសាលី នេះឯង ។

សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងកូដាគារ-សាលានាមហាវនៃ ជិតក្រុងវេសាលី ។ សម័យនោះឯង ពួកស្តេចលិច្ឆវីជាច្រើនអង្គ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញអង្គុយប្រជុំគ្នាក្នុងសណ្ឋាគារសាលាកណ្តាលក្រុង ពោលសរសើរគុណព្រះពុទ្ធ សរសើរគុណព្រះធម៌ សរសើរគុណព្រះសង្ឃ ដោយអនេក-បរិយាយ ។

អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសន្តិ ដោយសេចក្តីថា ពួកស្តេចលិច្ឆវីទាំងនោះ ជាបណ្ឌិតមានសទ្ធាជ្រះថ្លា ជាព្រះអរិយសាវ័កថ្នាក់សោតាបន្ន ខ្លះថ្នាក់សកទាគាមី ខ្លះថ្នាក់អនាគាមី ខ្លះ បានសរសើរគុណព្រះរតនត្រៃមានព្រះពុទ្ធរតនៈជាដើម ។ គុណនៃព្រះពុទ្ធរតនៈមាន ៣យ៉ាង គឺចរិយាគុណ ១ សរីរគុណ ១ និងគុណគុណ ១ (ពុទ្ធគុណមានអរហំជាដើម) ។ បណ្តាគុណ

ទាំងបីនោះ ពួកស្តេចលិច្ឆវីប្រារព្ធព្រះចរិយាគុណគឺ ពោលគុណរបស់ព្រះសម្មាសម្ពុទ្ធដោយជាតក ៥៥០ មានសេចក្តីថា ព្រះសម្មាសម្ពុទ្ធទ្រង់បំពេញនូវបារមី ១០, ឧបបារមី ១០, បរមត្ថបារមី ១០ អស់ ៤ អសង្ខ្យៃយកប្បៃ ១ សែនកប្ប ព្រះអង្គធ្វើនូវ ញាតត្ថចរិយា លោកត្ថចរិយា និងពុទ្ធត្ថចរិយាឱ្យដល់ទីបំផុតហើយ ធ្វើនូវមហាបរិច្ចាគ ៥ ប្រការ គឺព្រះអង្គទ្រង់ធ្វើនូវកម្មដែលគេធ្វើបានដោយកម្រយ៉ាងនេះហ្ន៎ ។ ពួកស្តេចលិច្ឆវីពណ៌នាចរិយា-គុណរបស់ព្រះពុទ្ធអង្គ រហូតដល់ភពតុសិត ហើយទើបឈប់ ។

ធម្មស្ស វណ្ណំ ភាសន្តិ កាលដែលពោលគុណនៃព្រះធម៌ បានពោលព្រះធម្មគុណជាចំណែក ៧ថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយនោះ ពោលដោយនិកាយមាន ៥ និកាយ ពោលដោយបិដកមាន ៣ ពោលដោយអង្គមាន ៩ ពោលដោយខន្ធមាន ៨៤ ពាន់ព្រះធម្មក្ខន្ធ ។

សង្ឃស្ស វណ្ណំ ភាសន្តិ កាលដែលពោលគុណរបស់ព្រះសង្ឃ ក៏ពោលដោយសង្ខេបនៃបព្វជ្ជាថា កុលបុត្រទាំងឡាយបានស្តាប់ព្រះធម៌ទេសនារបស់ព្រះដ៏មានព្រះភាគហើយ បាននូវ

សទ្ធាជ្រះថ្លា លះបង់នូវគំនរទ្រព្យសម្បត្តិ ព្រមទាំងពពួកញាតិ
សេ្វតច្ឆត្រ តំណែងឧបរាជ តំណែងសេនាបតី សេដ្ឋីនិងនាយឃ្លាំង
ជាដើមចូលកាន់ផ្នួស ក្នុងព្រះសាសនាដ៏ប្រសើរបស់ព្រះបរម
សាស្តា ។ ក្នុងសម័យពុទ្ធកាលចំពោះរាជបព្វជិត ដូចជាព្រះភទ្ទិយៈ
ព្រះមហាកប្បិន និង ព្រះបាទបុក្កុសាតិជាដើម បានលះបង់នូវ
សេ្វតច្ឆត្រចេញបួសមានចំនួនដល់ទៅ ៨ ម៉ឺនព្រះអង្គ ។ ចំណែក
កុលបុត្រទាំងឡាយ មានយសកុលបុត្រសោណសេដ្ឋីបុត្រ និង
រដ្ឋបាលកុលបុត្រជាដើម សុទ្ធតែបានលះបង់នូវទ្រព្យសម្បត្តិជា
ច្រើនកោដិ ហើយចេញមកបួសក្នុងព្រះសាសនារបស់ព្រះដ៏មាន
ព្រះភាគ រហូតដល់កំណត់ចំនួនមិនបាន ។

វេលាដែលស្តេចលិច្ឆវីទាំងឡាយប្រជុំគ្នា ពោលសរសើរ
គុណព្រះរតនត្រៃនោះ សីហសេនាបតីជាសាវ័កបស់និគន្ឋនាដបុត្រ
ក៏អង្គុយក្នុងបរិស័ទនោះដែរ ។ គ្រានោះសីហសេនាបតីមានសេចក្តី
ត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគអង្គនោះ ជាក់ជាព្រះអរហន្ត-
សម្មាសម្ពុទ្ធពិតប្រាកដ បានជាពួកស្តេចលិច្ឆវីដែលមានកេរ្តិ៍ឈ្មោះ
ល្បីល្បាញទាំងនេះ ពោលសរសើរដល់ដោយអនេកបរិយាយ បើ
ដូច្នោះ គួរតែអាត្មាអញចូលទៅដើម្បីជួបនឹងព្រះដ៏មានព្រះភាគជា

ព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ លំដាប់នោះ សីហសេនាបតី បានចូលទៅលំនៅនិគន្ថនាដបុត្រហើយ ស្នើរសូមដូច្នេះថា បពិត្រលោកដ៏ចម្រើន ខ្ញុំចង់ចូលទៅដើម្បីជួបនឹងព្រះសមណគោតម ។

បានជាសីហសេនាបតី ចាំបាច់សូមដល់និគន្ថនាដបុត្រ ដូច្នេះ ពីព្រោះនិគន្ថនាដបុត្របានគិតរួចហើយថា សីហសេនាបតីនេះ កាលបើនរណា ៗ ពោលគុណរបស់ព្រះសមណគោតម គេបានស្តាប់ហើយគេនឹងចូលទៅគាល់ព្រះសមណគោតម ដូច្នេះយើងនឹងសាបសូន្យ ទើបបានពោលផ្តាំទុកនឹងសីហសេនាបតីថា ក្នុងលោកនេះ មនុស្សជាច្រើននាក់តែងដើរនិយាយថា យើងជាព្រះពុទ្ធ យើងជាព្រះពុទ្ធ បើលោកមានបំណងនឹងចូលទៅជួបអ្នកណា ៗ គួរសួរយើងជាមុនសិន បើសមគួរយើងនឹងឱ្យលោកទៅ បើមិនសមគួរទេ យើងនឹងហាមលោក ។ គ្រានោះឯងនិគន្ថនាដបុត្របានស្តាប់ពាក្យរបស់សីហសេនាបតីដូច្នោះ មានសេចក្តីសោកយ៉ាងខ្លាំងដូចត្រូវភ្លុំសង្កត់ ទោមនស្សខូចចិត្តដូច្នេះថា យើងមិនប្រាថ្នាឱ្យគេទៅទីណា គេក៏មានបំណងនឹងទៅទីនោះ យើងនេះត្រូវគេហ្នឹងឯងសម្លាប់ហើយ ។ រួចហើយនិគន្ថនាដបុត្រទើបគិតថា យើងនឹងធ្វើឧបាយហាមគេក៏បានពោលដូច្នេះថា ម្នាលសីហៈ លោក

ឯងជាកិរិយវាទ នឹងចូលទៅជួបព្រះសមណគោតមជាអកិរិយវាទ ដូចម្តេចកើត ម្នាលសីហៈ ព្រោះថា ព្រះសមណគោតមជាអកិរិយវាទ ទើបតែងសម្តែងធម៌ដើម្បីឃាត់កិច្ចការថា មិនត្រូវធ្វើទាំងទ្ធន្នានពួកសាវ័កដោយធម៌នោះដែរ ។ លំដាប់នោះការប្រុងប្រៀបដំណើរដើម្បីទៅជួបព្រះដ៏មានព្រះភាគរបស់សីហសេនាបតី ក៏ត្រឡប់ទៅជាអាក់ខានវិញ ។ ពាក្យហាមឃាត់របស់និគន្ថនាដបុត្រធ្វើបីតិរបស់សីហសេនាបតី ដែលកើតឡើងហើយឱ្យវិនាសទៅវិញ ដូចធ្វើប្រទីបដែលឆេះឆ្លោ ហើយឱ្យរលត់ទៅវិញ ពុំនោះសោត ដូចផ្តាច់បាត្រដែលពេញ ទៅដោយភត្តាហារដូច្នោះឯង ។ ការត្រៀមរៀបចំដំណើរដោយសេះ ដោយជើរ ព្រមទាំងផ្លាកម្រងគ្រឿងក្រអូបជាដើម ត្រូវបានរំសាយទៅវិញ ។

ទុតិយម្បិ ខោ គឺសូម្បីក្នុងលើកទី ២ កាលដែលពួកស្តេចលិច្ឆវីសរសើរគុណព្រះពុទ្ធអង្គ បានសរសើរអំពីសីរគុណដោយអំណាចមហាបុរិសលក្ខណៈ៣២ ប្រការ ព្រះអនុព្យញ្ជនៈ ៨០ និងព្រះរស្មីម្ខាងមួយព្យាមនៃព្រះទសពល ។ សរសើរគុណព្រះធម៌ គឺសរសើរព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ទុក

ល្អហើយដោយមិនមានការភ្លាំងភ្លាត់ក្នុងបទណាមួយ ឬក្នុងព្យញ្ជនៈណាមួយឡើយ ។ សរសើរគុណព្រះសង្ឃដោយគុណក្នុងបដិបទាថា កុលបុត្រជាអ្នកបានលះបង់នូវយសសិរីនិងទ្រព្យសម្បត្តិមានសភាពបែបនេះ បួសក្នុងព្រះសាសនានៃព្រះពុទ្ធបរមគ្រូ ជាបុគ្គលមានប្រក្រតីមិនខ្វិលច្រអូស ជាអ្នកធ្វើឱ្យបរិបូណ៌ក្នុងធុតង្គគុណទាំង ១៣ ប្រការ និងបដិបត្តិអប់រំសមថវិបស្សនា ។

តតិយម្បិ ពោ ក្នុងវារៈទី ៣ កាលដែលសរសើរ ព្រះពុទ្ធអង្គ ក៏បានពោលនូវពុទ្ធគុណទាំងឡាយ ដោយបរិយាយនៃព្រះសូត្រនោះថា **ឥតិបិ សោ ភគវា** ដូច្នេះជាដើម ។ ពោលសរសើរព្រះធម៌ ដោយធម្មគុណទាំងឡាយ តាមបរិយាយនៃព្រះសូត្រនោះថា **স্বাক্খাতো ভគវតা ধম্মো** ដូច្នេះជាដើម ។ ពោលសរសើរព្រះសង្ឃដោយសង្ឃគុណទាំងឡាយ តាមបរិយាយនៃព្រះសូត្រនោះថា **សុប្បដិបន្នោ ភគវតោ សាវកសង្ឃោ** ដូច្នេះជាដើម ។

សីហាសេនាបតីបានស្តាប់អំពីគុណនៃព្រះរតនត្រៃជាលើកទី ៣ ក៏មានសេចក្តីត្រិះរិះដូច្នេះថា ចំពោះពួកនិគ្រន្ថទាំងឡាយនេះ

ទោះបីយើងលាក្តី មិនលាក្តី នឹងធ្វើអ្វីដល់យើង បើដូច្នោះ យើងមិនចាំបាច់លា មិនចាំបាច់សូមការអនុញ្ញាតអ្វីទាំងអស់ យើងនឹងចូលទៅដើម្បីគាល់ព្រះដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធនោះ តែលាភមែន ឥឡូវយើងបានមកជួបហើយ ។ សីហសេនាបតីកើតបីតិបាមោជ្ជ ដូចបុរសក្រខ្សត់បានជួបនូវកំណប់ធំដូច្នោះឯង ទើបចូលទៅគាល់ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ ។ សីហសេនាបតីបានក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយនៅក្នុងទីសមគួរទូលសួរបញ្ហាតាមដែលបានស្តាប់ពួមក ។ ព្រះដ៏មានព្រះភាគបានវិសជ្ជនាព្រមទាំងត្រាស់សម្តែងធម៌ ៨ យ៉ាងដល់សីហសេនាបតី ។ សីហសេនាបតីបានស្តាប់ហើយ ក៏មានឧទានសរសើរព្រះធម៌ថា ភ្លឺច្បាស់ពេកណាស់ ទើបក្រាបទូលសូមព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមតាំងអំពីថ្ងៃនេះទៅសូមព្រះដ៏មានព្រះភាគចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកដល់សរណៈស្មើដោយជីវិត ។ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ម្នាលសីហៈ អ្នកចូរធ្វើនូវការពិចារណារួចហើយសឹមធ្វើ ព្រោះការពិចារណារួចហើយសឹមធ្វើ រមែងជាគុណគាប់ប្រសើរនៃពួកមនុស្សអ្នកចេះដឹងប្រហែលនឹងអ្នក ។ សីហសេនាបតីក្រាបបង្គំទូលថា

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីពេញចិត្តត្រេកអរ លើសលប់ហួសប្រមាណចំពោះភាសិតរបស់ព្រះអង្គ ដោយហេតុដែលព្រះអង្គសម្តែងនិច្ចខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលសីហៈ អ្នកចូរធ្វើនូវការពិចារណារួចហើយសឹមធ្វើ ព្រោះការពិចារណារួចហើយសឹមធ្វើ រមែងជាគុណគាប់ប្រសើរនៃពួកមនុស្សអ្នកចេះដឹងប្រហែលនឹងអ្នក ។ បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតពួកអន្យតិរ្ថិយបានខ្ញុំព្រះអង្គជាសាវកហើយ ក៏ដង្ហែទង់ចូលទៅកាន់ក្រុងវេសាលីទាំងមូល ហើយប្រកាសសេចក្តីថា សីហសេនាបតីបានចុះចូលមកជាសាវករបស់ពួកយើងហើយ ចម្លែកតែព្រះដ៏មានព្រះភាគ ត្រឡប់ជាទ្រង់ត្រាស់ចំពោះខ្ញុំព្រះអង្គយ៉ាងនេះវិញថា ម្នាលសីហៈអ្នកចូរធ្វើនូវការពិចារណារួចហើយសឹមធ្វើ ព្រោះថាការពិចារណារួចហើយសឹមធ្វើ រមែងជាគុណគាប់ប្រសើរនៃមនុស្សអ្នកចេះដឹងប្រហែលនឹងអ្នក ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់ព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងទីរលឹក ចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះដ៏មានព្រះភាគចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់នូវសរណៈស្មើដោយជីវិតជាគម្រប់ ២ ដងផង ។ ព្រះដ៏មានព្រះភាគទ្រង់

ត្រាស់ថា ម្នាលសីហៈ ត្រកូលរបស់អ្នកដូចជាអណ្តូងទឹករបស់ពួកនិគ្រន្ថ អស់កាលយូរណាស់មកហើយ អ្នកគប្បីសម្អាល់នូវបិណ្ឌបាតដែលអ្នកគួរឱ្យដល់ពួកនិគ្រន្ថ ដែលចូលមករកនោះផង ។ សីហសេនាបតីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីពេញចិត្តត្រេកអរលើសលប់ហួសប្រមាណ ចំពោះភាសិតរបស់ព្រះអង្គ ដោយហេតុដែលព្រះអង្គបានសម្តែងនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលសីហៈ ត្រកូលរបស់អ្នកដូចជាអណ្តូងទឹករបស់ពួកនិគ្រន្ថអស់កាលយូរណាស់មកហើយ អ្នកគប្បីសម្អាល់នូវបិណ្ឌបាត ដែលអ្នកគួរឱ្យដល់ពួកនិគ្រន្ថដែលចូលមករកនោះផង ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គធ្លាប់ឮពាក្យនេះថា ព្រះសមណគោតមទ្រង់ត្រាស់យ៉ាងនេះថា បុគ្គលត្រូវឱ្យទានដល់តថាគតតែម្យ៉ាង មិនត្រូវឱ្យទានដល់ពួកសាស្តាដទៃឡើយ បុគ្គលត្រូវឱ្យទានដល់ពួកសាវ័ករបស់តថាគតតែម្យ៉ាង មិនត្រូវឱ្យទានដល់ពួកសាវ័កពួកសាស្តាដទៃឡើយ បុគ្គលឱ្យទានដល់តថាគតតែម្យ៉ាង ទើបមានផលច្រើន ឱ្យដល់ពួកសាស្តាដទៃមិនមានផលច្រើនឡើយ បុគ្គលឱ្យទានដល់ពួកសាវ័ករបស់តថាគតតែម្យ៉ាង ទើបមានផលច្រើន ឱ្យទានដល់ពួកសាវ័ករបស់ពួកសាស្តា

ដទៃ មិនមានផលច្រើនឡើយ តែឥឡូវនេះព្រះដ៏មានព្រះភាគ ត្រឡប់ជាបបួលខ្ញុំព្រះអង្គឱ្យធ្វើទានសូម្បីក្នុងពួកនិគ្រន្ថផង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងដឹងក្នុងកាលគួរចំពោះទាននោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះសូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមតាំងអំពីថ្ងៃនេះទៅ សូមព្រះដ៏មានព្រះភាគទ្រង់ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់នូវសរណៈស្មើដោយជីវិតជាគម្រប់ ៣ ដងផង ។

គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងនូវអនុបុព្វីកថា ចំពោះសីហសេនាបតី គឺ **ទ្រង់ប្រកាសនូវទានកថា សីលកថា សគ្គកថា នូវទោសរបស់កាមទាំងឡាយដ៏លាមកសៅហ្មង** និងអានិសង្សក្នុងការចេញចាកកាម ។

ដែលថា **អនុបុព្វីកថា** គឺពាក្យពោលតាមលំដាប់យ៉ាងនេះថា សីលក្នុងលំដាប់នៃទាន សួគ៌ទេវលោកក្នុងលំដាប់នៃសីល មគ្គក្នុងលំដាប់នៃសួគ៌ទេវលោក ។

ដែលថា **ទានកថា** គឺពាក្យពោលដែលទាក់ទងនឹងគុណរបស់ទាន មានជាអាទិ៍យ៉ាងនេះថា ៖

- ទាន ជាហេតុនៃសេចក្តីសុខ ។
- ទាន ជាមូលនៃសម្បត្តិ ។
- ទាន ជាទីតាំងនៃភោគៈទាំងឡាយ ។
- ទាន ជាគ្រឿងការពារក្នុងវដ្តសង្សារ ។
- ទាន ជាទីគេចពួនពីការក្រលំបាក ។
- ទាន ជាផ្លូវដែលអ្នកប្រាជ្ញបានដើរហើយ ។
- ទាន ដូចជាស្បៀងក្នុងដំណើរផ្លូវឆ្ងាយ ។
- ទាន ដូចជាខ្សែសម្រាប់តោងយោងខ្លួន ។
- ទាន ដូចជាអាសនៈមាសប្រដាប់ទៅដោយរតនៈផ្សេង ៗ ដោយអត្ថថា ជាទីពឹងអាស្រ័យ ។
- ទាន ដូចជាមហាប្រឹថពី ដោយអត្ថថា ជាទីតាំងអាស្រ័យ ។
- ទាន ដូចជានាវា ដោយអត្ថថា ជាគ្រឿងចម្លងឱ្យរួចផុតចាកទុក្ខ ។
- ទាន ដូចជាអ្នកចម្បាំងដ៏ក្លាហាន នៅក្នុងសង្គ្រាម ដោយអត្ថថា មានចិត្តបូជា លះបង់ជាប់ស្រឡះ ។
- ទាន ដូចជាព្រះនគរដែលរៀបចំល្អហើយ ដោយអត្ថ

ថា ជាគ្រឿងការពារភ័យ ។

- **ទាន ដូចជាផ្កាឈូក** ដោយអត្ថថា មិនត្រូវមន្ទិល គឺ សេចក្តីកំណាញ់ជាដើម ប្រឡាក់ឡើយ ។

- **ទាន ដូចជាភ្លើង** ដោយអត្ថថា ដុតនូវមន្ទិលគឺសេចក្តី កំណាញ់ជាដើម ។

- **ទាន ដូចជាពស់មានពិស** ដោយអត្ថថា ចូលជិតបាន ដោយលំបាក ។

- **ទាន ដូចជារាជសីហ៍** ដោយអត្ថថា មិនភ័យតក់ស្លុត ។

- **ទាន ដូចជាស្តេចដំរី** ដោយអត្ថថា មានកម្លាំងខ្លាំងក្លា ។

- **ទាន ដូចជាគោឧសភរាជ** ដោយអត្ថថា ជាមង្គលដ៏ក្រៃលែង ។

- **ទាន ដូចជាស្តេចសេះវលាហក** ដោយអត្ថថា ធ្វើបុគ្គលឱ្យដល់ទីក្សេមយ៉ាងឆាប់រហ័ស ។

- **ទាន ជាផ្លូវដែលព្រះតថាគតស្តេចយាង ។**

- **ទាន ជាវង្សនៃព្រះពុទ្ធគ្រប់ព្រះអង្គ ។**

កាលដែលព្រះតថាគតបំពេញនូវទានបារមី បានបដិបត្តិមហាយញ្ញជាអនេក គឺ មហាយញ្ញក្នុងគ្រាជា**វេលាមព្រាហ្មណ៍**

មហាយញ្ញក្នុងគ្រាជា**មហាគោវិន្ទព្រាហ្មណ៍** មហាយញ្ញក្នុងគ្រាជាស្តេចចក្រពត្តិ ព្រះនាម**មហាសុទស្សនៈ** មហាយញ្ញក្នុងគ្រាជា**ព្រះវេស្សន្តរ** ។ កាលដែលព្រះតថាគតជាសត្វទន្យាយ បានលះបង់ខ្លួនដោយលោតចូលគំនរភ្លើង កំពុងឆេះដើម្បីឱ្យទានដល់ស្ទឹមដែលបានមកដល់ហើយ ។

ធម្មតាទានក្នុងលោក រមែងឱ្យសក្តសម្បត្តិ(សម្បត្តិព្រះឥន្ទ) មារសម្បត្តិ ព្រហ្មសម្បត្តិ ចក្រពត្តិសម្បត្តិ សាវកបារមីញ្ញាណ បច្ចេកពោធិញ្ញាណ និងឱ្យទៅអភិសម្ពោធិញ្ញាណ គឺបានត្រាស់ជាព្រះសម្មាសម្ពុទ្ធ ។

ព្រោះហេតុដែលអ្នកឱ្យទាន អាចសមាទានសីលបាន ទើបទ្រង់ត្រាស់ **សីលកថា** ក្នុងលំដាប់នៃទាន ។ សីលជាទីពឹងអាស្រ័យ សីលជាវាហាណៈ សីលជាគ្រឿងយឺតយោង ។ល។ សីលនេះជាវង្សរបស់ព្រះតថាគត ព្រះអង្គបានបំពេញសីលក្នុងអត្តភាពទាំងឡាយ រកទីបំផុតមិនបាន ដូចកាលដែលព្រះអង្គជាស្តេចនាគឈ្មោះ **សង្ខបាល** ស្តេចនាគឈ្មោះ **ចម្បេយ្យៈ** ស្តេចនាគឈ្មោះ **សីលវៈ** ក្នុងកាលដែលព្រះអង្គជាស្តេចដំរីចិញ្ចឹមមាតានិងស្តេចដំរីឆទ្ទន្តជាដើម ។ ទីពឹងពំនាក់នៃសម្បត្តិក្នុងលោក

នេះ និងលោកដទៃដូចជាសីលពុំមានឡើយ ។ គ្រឿងប្រដាប់ដូច ជាគ្រឿងប្រដាប់ គឺសីលក៏មិនមានដែរ ។ មនុស្សលោកព្រមទាំង ទេវលោក កាលដែលពិចារណាមើលមនុស្សដែលប្រដាប់ដោយ សីល លាបគ្រឿងក្រអូបគឺសីល រមែងមានចិត្តរីករាយជានិច្ច មិនចេះធុញទ្រាន់ ។ ព្រោះបុគ្គលអាស្រ័យនូវសីលនេះហើយ រមែងបានទៅកាន់សុគតិភពទើបទ្រង់ត្រាស់នូវសគ្គកថាក្នុងលំដាប់ នៃសីល ។

ដែលថា **សគ្គកថា** គឺពាក្យពោលអំពីឋានទេវតាមាន ជា អាទិ៍យ៉ាងនេះថា ស្ថានសួគ៌នេះគួរប្រាថ្នា គួរត្រេកអរ គួរពេញ ចិត្ត ។ ក្នុងស្ថានសួគ៌នេះ មានការលេងជានិច្ច បានសម្បត្តិជានិច្ច ក្នុងឋានចាតុម្មហារាជិកា សោយសុខសម្បត្តិ ទិព្វសម្បត្តិ ៩ លាន ឆ្នាំមនុស្ស ទេវតាជាន់តាវត្តិង្ស សោយសុខសម្បត្តិ ទិព្វសម្បត្តិ ៣៦ លានឆ្នាំមនុស្ស ។ល ។ ពិតណាស់ ព្រះឱស្ឋនៃព្រះសម្មា-សម្ពុទ្ធទាំងឡាយ មិនល្មមដែលនឹងត្រាស់ពណ៌នានូវសម្បត្តិក្នុង ទេវលោកឡើយ សមដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតគប្បីពោលនូវសគ្គកថា ដោយអនេ-កបរិយាយ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងអំពីសម្បត្តិទិព្វ ក្នុងទេវលោក ដែលជាអានិសង្សរបស់ទាន សីល គឺម្យ៉ាង ជាប្រយោជន៍ឱ្យមនុស្សជ្រកចិត្តចេញពីកាមគុណ ជារបស់មនុស្សម្យ៉ាងទៀត ឱ្យឃើញធម៌ជាអនត្តា អ្វី ៗប្រព្រឹត្តទៅតាមបច្ចយមានកម្មប្បច្ចយជាដើម ។ ព្រះអង្គត្រាស់សម្តែងធម៌ ប្រៀបដូចជាយកបន្ទាជោះបន្ទា ព្រោះថា កាមគុណជារបស់មនុស្សជោតជាប់ក្នុងចិត្តនៃមនុស្ស ទើបព្រះអង្គត្រាស់នូវសគ្គកថា ។ កាលដែលមនុស្សអ្នកស្តាប់បង្អោនចិត្តទៅកាន់ទេវលោក ដែលជាផលរបស់ទាន សីលហើយ ដើម្បីនឹងសម្តែងថា សូម្បីទេវលោកនោះក៏មិនទៀងមិនឋិតថេរ មិនគួរធ្វើនូវសេចក្តីត្រេកអរដោយអំណាចរាគៈឡើយ ទើបព្រះអង្គទ្រង់ត្រាស់សម្តែងនូវទោសរបស់កាមទាំងឡាយជាបន្ត ។

ការមាទីនវកថា ដោយសេចក្តីថា ព្រះអង្គទ្រង់ត្រាស់អំពីកាមទាំងឡាយ មានសេចក្តីសុខតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមនេះមានច្រើនក្រៃពេក ។ ឧកញ្ញារំ គឺអាប់ឱន លាមក ថោកទាប ។ **សង្កិលេសំ** ដោយសេចក្តីថា សត្វទាំងឡាយរមែងសៅហ្មងនៅក្នុងសង្សារវដ្ត ក៏ដោយអាស្រ័យ

កាមទាំងអស់នោះ ។

ព្រះដ៏មានព្រះភាគទ្រង់ប្រកាសសម្តែងនូវទោស របស់កាមទាំងឡាយរួចហើយ ទើបព្រះអង្គទ្រង់ត្រាស់សម្តែងនូវ **នេក្ខម្មានិសង្សកថា** គឺទ្រង់ត្រាស់អំពីអានិសង្សនៃការចេញចាកកាម ។

កាលដែលព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា សីហសេនាបតី មានចិត្តស្រួលមានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តខ្ពស់ មានចិត្តជ្រះថ្លាហើយ ទើបទ្រង់ប្រកាសនូវធម្មទេសនាដែលព្រះពុទ្ធទាំងឡាយតែងលើក ឡើងសម្តែងដោយព្រះអង្គឯង គឺ ទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ។

សាមុក្កំសិកា បានដល់ព្រះធម៌ទេសនា ដែលព្រះអង្គទ្រង់លើកឡើងដោយព្រះអង្គឯង ។ ចំពោះធម៌ដែលព្រះអង្គទ្រង់ចាប់លើកឡើងសម្តែងដោយព្រះអង្គឯងអធិប្បាយថាព្រះធម៌ទេសនាដែលទ្រង់ឃើញដោយព្រះសយម្ភូញាណ មិនសាធារណៈដល់អ្នកដទៃ ។ សួរថា ព្រះធម៌ទេសនា ដែលទ្រង់លើកឡើងដោយព្រះអង្គឯងនោះគឺអ្វី ? ឆ្លើយថា គឺអរិយសច្ចទេសនា ។

ធម្មតាសំពត់សស្អាត មិនជ្រលក់ប្រឡាក់ដោយវត្ថុមានពណ៌ខ្មៅ គួរទទួលនូវទឹកជ្រលក់បានដោយល្អ មានឧបមាដូចម្តេចមិញ

ធម្មចក្ខុ គឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលីប្រាសចាកមន្ទិលក៏កើតឡើងដល់សីហសេនាបតីក្នុងទីនោះថា **ធម្មជាតិណាមួយដែលកើតឡើង ធម្មជាតិទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា** មានឧបមេយ្យដូច្នោះឯង ។

គ្រានោះ សីហសេនាបតីបានឃើញច្បាស់នូវអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យហើយដល់នូវភាពជាអ្នកក្លាហាន ប្រព្រឹត្តទៅក្នុងសាសនានៃព្រះបរមសាស្តាដោយមិនចេះតែជឿបុគ្គលដទៃហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទ្រង់ទទួលនូវភត្តរបស់ខ្ញុំព្រះអង្គជាមួយនឹងភិក្ខុសង្ឃដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ លំដាប់នោះសីហសេនាបតីដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទទួលនិមន្តហើយ ទើបក្រោកចាកទីអង្គុយថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណ ហើយដើរចេញទៅ ។

ដល់ផ្ទះហើយ សីហសេនាបតី បានហៅបុរសម្នាក់មកថា ម្នាលបុរសដ៏ចម្រើន អ្នកចូរទៅ ចូរដឹងនូវសាច់ដែលប្រព្រឹត្តទៅតាម

ប្រក្រតី ។ **បវត្ត មំសំ** បានដល់សាច់ដែលជាកប្បិយៈ ដែលប្រព្រឹត្តទៅហើយតាមប្រក្រតី អធិប្បាយថា អ្នកចូរវេកទិញអំពីវានផ្សារ ។ សីហាសេនាបតីបានចាត់ចែងខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ក្នុងផ្ទះរបស់ខ្លួន ។ លុះរាត្រីកាលនោះកន្លងទៅសីហាសេនាបតី ទើបប្រើបុរសនោះឱ្យទៅក្រាបទូលភត្តកាលដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលគួរហើយភត្តក្នុងផ្ទះរបស់សីហាសេនាបតីសម្រេចហើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ស្តេចយាងចូលទៅកាន់លំនៅរបស់សីហាសេនាបតី លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលសីហាសេនាបតីក្រាលបម្រុងទុកជាមួយនឹងព្រះភិក្ខុសង្ឃ ។

ក្នុងសម័យនោះ ពួកនិគ្រន្ថជាច្រើននាក់ ផ្គងនូវដើមដៃស្រែកកន្ទក់កន្ទេញសព្វច្រក សព្វផ្លូវត្រឡែងកែងក្នុងក្រុងវេសាលីថា ថ្ងៃនេះសីហាសេនាបតីសម្លាប់សត្វមានសរីរៈធាត់ ធំ ធ្វើភត្តដើម្បីសមណគោតម ចំណែកសមណគោតមទុកជាដឹង ក៏នៅតែឆាន់សាច់ដែលគេសម្លាប់ចំពោះខ្លួនដែរ ព្រះសមណគោតមនេះឈ្មោះថា ត្រូវបដិច្ចកម្ម ។

បដិច្ចកម្ម គឺជាឈ្មោះនៃអំពើរបស់អ្នកដែលគ្រាន់តែបរិភោគសាច់ ក៏បានឈ្មោះថា សម្លាប់សត្វដែរ ឬជាឈ្មោះអំពើដែលគេសម្លាប់ព្រោះអាស្រ័យខ្លួន ពុំនោះសោត ពាក្យថា **បដិច្ចកម្ម** នេះជាឈ្មោះរបស់និមិត្តកម្ម ។ លទ្ធិពួកនិគ្រន្ថប្រកាន់ថា **បដិច្ចកម្ម** គឺជាអកុសលត្រូវបានដល់អ្នក ឱ្យពាក់កណ្តាល អ្នកទទួលពាក់កណ្តាល ។

អំពើបង្អាប់បង្កិចរបស់ពួកនិគ្រន្ថនេះ ត្រូវបានបុរសម្នាក់ចូលទៅខ្សឹបប្រាប់សីហសេនាបតី ។ សីហសេនាបតីពោលថា ពួកលោកទាំងអស់នោះ ប្រាថ្នារកទោសព្រះពុទ្ធ ប្រាថ្នារកទោសព្រះធម៌ ប្រាថ្នារកទោសព្រះសង្ឃអស់កាល ជាយូរណាស់មកហើយ រហូតមកដល់ឥឡូវនៅតែមិនចេះអៀនខ្មាសសោះ ពួកលោកទាំងនោះ ពោលបង្អាប់ព្រះដ៏មានព្រះភាគដោយពាក្យមិនពិត ពាក្យទទេ ជាពាក្យកុហកភូតភរ បោកប្រាស់ទាំងដែលពួកយើងមិនបានក្លែងផ្តាច់បង់ជីវិត សត្វព្រោះហេតុតែជីវិតរបស់ខ្លួនឯងឡើយ ។ លំដាប់នោះ សីហសេនាបតីបានញុំាងព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឱ្យបានឆាន់ ឆ្អែតស្កប់ស្កល់ដោយខាទនីយភោជនីយាហារដ៏ឧត្តមដោយដៃខ្លួនឯង ។

កាលដែលព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់សោយរួចហើយ ឈប់ដាក់ព្រះហស្តទៅក្នុងបាត្រទៀតហើយ សីហសេនាបតី ក៏អង្គុយក្នុងទីដ៏សមគួរ ។ កាលដែលសីហសេនាបតី អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ពន្យល់ឱ្យឃើញច្បាស់ ឱ្យកាន់យក ឱ្យអាចហ៊ាន ឱ្យរីករាយដោយធម្មីកថាហើយ ព្រះអង្គទ្រង់ក្រោកចាកអាសនៈយាងចេញទៅ ។

ទានានិសង្សសូត្រ

នៅក្នុងបិដកលេខ ៤៤, ទំព័រ ៨០ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី **[អានិសង្សនៃការឱ្យទាន ៥ ប្រការ]** មានសេចក្តីថា ៖

បញ្ចិមេ ភិក្ខវេ ទានេ អានិសំសា ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សក្នុងទាននេះ**មាន ៥ យ៉ាង** ។ កតមេ បញ្ច ។

៥ យ៉ាង តើដូចម្តេចខ្លះ

១- ពហុនោ ជនស្ស បិយោ ហោតិ គឺជាទីស្រឡាញ់ជាទីគាប់ចិត្តនៃជនច្រើន

២- មនាបោ សប្បុរិសោ ភជន្តិ ពួកសប្បុរស

អ្នកស្ងប់រមែងគប់រក

៣- កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ មានកិត្តិសព្ទ ដ៏ពីរោះខ្ចរខ្ចាយទៅ

៤- គិហិធម្មោ អនបគតោ ហោតិ មិនបានប្រាសចាកធម៌របស់គ្រហស្ថ

៥-កាយស្សភេទា បរម្មរណា សុគតឺ សគ្គំ លោកំ ឧបបជ្ជតិ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងកើតក្នុងសុគតិសួគ៌ ទេវលោក ។

ម្នាលភិក្ខុទាំងឡាយនេះអានិសង្សក្នុងទានទាំង៥យ៉ាង ។

ទទមានោ បិយោ ហោតិ សតំ ធម្មំ អនុក្កមំ
សន្តោ នំ សធា ភជន្តិ សញ្ញតា ព្រហ្មចារយោ
តេ តស្ស ធម្មំ ទេសេន្តិ សព្វទុក្ខាបនំទនំ
យំ សោ ធម្មំ ឥធញ្ញាយ បរិនិព្វាតនាសវោតិ ។

បុគ្គលកាលឱ្យទាន រមែងជាទីស្រឡាញ់ ជាអ្នកអនុកូលទៅតាមធម៌របស់ពួកសប្បុរស ពួកសព្រហ្មចារីអ្នកសង្រួមមានចិត្តស្ងប់រម្ងាប់ រមែងរាប់រកបុគ្គលនោះសព្វកាល ពួកសព្រហ្មចារី

នោះ រមែងសម្តែងធម៌ ជាគ្រឿងបន្ទោបង់នូវទុក្ខទាំងអស់ដល់បុគ្គលនោះទាំងបុគ្គលនោះដឹងនូវធម៌ហើយ ជាអ្នកមិនមានអាសវៈ រមែងបរិនិព្វានក្នុងលោកនេះ ។

អដ្ឋកថា

បទថា តិហិធម្មោ អនបគតោ ហោតិ គឺជាអ្នកមានសីល ៥ មិនដាច់ ។

បទថា សតំ ធម្មំ អនុក្កមំ បានដល់ ជាអ្នកធ្វើដំណើរទៅតាមធម៌របស់សប្បុរស គឺមហាបុរស ។

បទថា សន្តោ នំ សទា ភជន្តិ បានដល់ សប្បុរសទាំងឡាយ គឺព្រះសម្មាសម្ពុទ្ធ ព្រះបច្ចេកពុទ្ធ និង សាវករបស់ព្រះតថាគត រមែងគប់រកអ្នកឱ្យទានសព្វកាល ។

បុគ្គលសូត្រ

នៅក្នុងបិដកលេខ ៤៤, ទំព័រ ៨៥ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់អំពី **[មាតាបិតាត្រូវការហាន: ៥ ប្រការអំពីបុត្រ]** មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយមាតាបិតា ពិចារណាឃើញហេតុ ៥

យ៉ាងនេះ រមែងចង់បានបុត្រដែលកើតក្នុងត្រកូល ។ **ហេតុ ៥ យ៉ាង ដូចម្តេចខ្លះ?**

១- ភតោ វា នោ ភវិស្សតិ គឺបុត្រដែលយើងចិញ្ចឹមហើយ នឹងចិញ្ចឹមយើងវិញ,

២-កិច្ចំ វា នោ ករិស្សតិ បុត្រនឹងជួយធ្វើកិច្ចការយើង,

៣- កុលវំសោ ចរំ តិដ្ឋេ វង្សត្រកូលនឹងស្ថិតនៅយូរ,

៤- ទាយជ្ជំ បដិបជ្ជតិ បុត្រប្រតិបត្តិទទួលយកមត៌ក,

៥- អថ វា បន បេតានំ ទក្ខិណានុប្បទស្សតិ មួយទៀត បុត្រនឹងឧទ្ទិសទក្ខិណាទានឱ្យដល់យើងដែលធ្វើមរណកាលទៅកាន់លោកខាងមុខ ។

ម្នាលភិក្ខុទាំងឡាយមាតាបិតាកាលពិចារណាឃើញហេតុ ៥ យ៉ាងនេះ រមែងចង់បានបុត្រដែលកើតក្នុងត្រកូល ។

បញ្ចដ្ឋានានិ សម្បស្សំ បុត្តំ ឥច្ឆន្តិ បណ្ឌិតា
ភតោ វា នោ ភវិស្សតិ កិច្ចំ វា នោ ករិស្សតិ
កុលវំសោ ចរំ តិដ្ឋេ ទាយជ្ជំ បដិបជ្ជតិ
អថ វា បន បេតានំ ទក្ខិណានុប្បទស្សតិ

ឋានានេតានិ សម្បស្សំ បុត្តំ ឥច្ឆន្តិ បណ្ឌិតា
តស្មា សន្តោ សប្បុរិសា កតញ្ញូ កតវេទិនោ
ភរន្តិ មាតាបិតរោ បុព្ពេ កតមនុស្សរំ
កយិរន្តិ នេសំ កិច្ចានិ យថាតំ បុព្ពការិនំ
ឱវាទការី ភតធោសី កុលវំសំ អថាបយំ
សទ្ធោ សីលេនសម្បន្នោបុត្តោ ហោតិ បសំសិយោតិ ។

អ្នកប្រាជ្ញទាំងឡាយ កាលបើពិចារណាឃើញហេតុទាំង ៥ យ៉ាង រមែងចង់បានបុត្រ គឺបុត្រដែលយើងចិញ្ចឹម ហើយនឹងចិញ្ចឹមយើងវិញ នឹងធ្វើកិច្ចការដល់យើង រង្វត្រកូលនឹងស្ថិតនៅយូរ ប្រតិបត្តិគួរដើម្បីទទួលយកមត៌ក មួយទៀត នឹងឧទ្ទិសទក្ខិណាទានឱ្យដល់យើងដែលទៅកាន់លោកខាងមុខ អ្នកប្រាជ្ញទាំងឡាយ កាលបើពិចារណាឃើញហេតុទាំង ៥ យ៉ាងនេះហើយ រមែងចង់បានបុត្រ ហេតុដូច្នោះ ពួកសប្បុរសអ្នកស្ងប់រំងាប់ជាកតញ្ញូកតវេទិបុគ្គលកាលរលឹកឃើញនូវឧបការគុណដែលលោកធ្វើហើយ ក្នុងកាលមុនក៏រមែងចិញ្ចឹមមាតាបិតារមែងជួយធ្វើកិច្ចការរបស់បុព្វការីទាំងនោះតាមសមគួរ ។ បុត្រអ្នកធ្វើតាមឱវាទ

ចិញ្ចឹម មាតាបិតាដែលលោកបានចិញ្ចឹមខ្លួនមកហើយ មិនញាំង
វង្សត្រកូលឱ្យសាបសូន្យ ជាអ្នកមានសទ្ធា បរិបូណ៌ដោយសីល
រមែងជាទីសរសើរនៃអ្នកផងទាំងពួង ។

អដ្ឋកថា

បទថា ភតោ វា នោ ភរិស្សតិ ដោយសេចក្តីថា បុត្រដែល
យើងចិញ្ចឹមមកហើយ ថ្នាក់ថ្នមមកហើយដោយឱ្យបៅដោះនិង
ញាំងដៃជើងឱ្យចម្រើនធំធាត់ជាដើម ក្នុងពេលដែលយើងចាស់
គេនឹងចិញ្ចឹមយើងដោយការលាងដៃ លាងជើង ឱ្យទូតទឹកនិងឱ្យ
បបរបាយជាដើម ។

បទថា កិច្ចំ វា នោ ករិស្សតិ ដោយសេចក្តីថា គេសម្រាក
ការងារបស់ខ្លួនហើយ នឹងមកជួយធ្វើកិច្ចការរបស់យើង ដែល
កើតឡើងក្នុងរាជត្រកូលជាដើម ។

បទថា កុលវំសោ ចរំ តិដ្ឋេ ដោយសេចក្តីថា មិនធ្វើសម្បត្តិ
របស់យើង មានស្រែចម្ការ មាសប្រាក់ជាដើម ឱ្យវិនាសអន្តរាយ
ឡើយ ម្យ៉ាងទៀត គេមិនធ្វើនូវសលាកភត្តទានជាដើម ដែលយើង
ប្រព្រឹត្តមកហើយឱ្យដាច់បាត់ទៅនោះឡើយ គឺឱ្យនៅតែប្រព្រឹត្តទៅ

ដូច្នេះវង្សត្រកូលរបស់យើងនឹងតាំងនៅបានយូរ ។

បទថា **ធាយន្តំ បដិបជ្ជតិ** ដោយសេចក្តីថា បុត្រកាលប្រព្រឹត្តឱ្យសមគួរដល់មត៌ក ដោយការបដិបត្តិដ៏សម គួរដល់វង្សត្រកូល ក៏នឹងគ្រប់គ្រងនូវមត៌កដែលជាសម្បត្តិរបស់យើងបាន ។

បទថា **ឧក្កិណ្ណំនុប្បឧស្សតិ (ឧក្កិណ្ណំ អនុប្បឧស្សតិ)** ដោយសេចក្តីថា បុត្រនឹងបំពេញទានឧទ្ទិសចំណែកបុណ្យឱ្យចាប់អំពីថ្ងៃទី ៣ រាប់ពីថ្ងៃស្លាប់ទៅ ។

បទថា **សន្តោ សប្បុរិសា** ដោយសេចក្តីថា គឺជាសប្បុរសជាមនុស្សល្អ ដោយការបដិបត្តិប្រពៃក្នុងមាតាបិតា ។

បទថា **បុព្វេ កតមនុស្សរំ** ដោយសេចក្តីថា កាលរលឹកដល់គុណ ដែលមាតាបិតាធ្វើទុកក្នុងកាលមុនហើយ ។

បទថា **ឱវាទការី** គឺជាអ្នកធ្វើតាមឱវាទដែលមាតាបិតាទូន្មានហើយ ។

បទថា **ភតធោសី** បានដល់ បុត្រនឹងចិញ្ចឹមមើលថែមាតាបិតា តាមដែលមាតាបិតាបានចិញ្ចឹមមើលថែខ្លួនមក ។

បទថា **បសំសិយោ** ដោយសេចក្តីថា ជាបុគ្គលដែលមហាជនគប្បីសរសើរក្នុងបច្ចុប្បន្ននេះឯង ។

ខុទ្ទកសូត្រ

នៅក្នុងបិដកលេខ ៤៤, ទំព័រ ៧១ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់អំពី **[តួនាទីរបស់ភរិយាដែលល្អ]** មានសេចក្តីថា ៖

សម័យមួយ ព្រះដ៏មានព្រះភាគគង់នៅក្នុងជាតិយាវនទៀបក្រុងភទ្ទិយៈ ។ គ្រានោះឧគ្គហមេណ្ឌកនត្តា (ជាចៅមេណ្ឌកសេដ្ឋី) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះឧគ្គហមេណ្ឌកនត្តាអង្គុយក្នុងទីសមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ មានភិក្ខុជាគម្រប់ ៤ នឹងព្រះអង្គ ទទួលភត្តខ្ញុំព្រះអង្គក្នុងថ្ងៃស្អែក ។ ព្រះដ៏មានព្រះភាគទទួលដោយតុណ្ហីភាព ។ (គ្រានោះឧគ្គហមេណ្ឌកនត្តាជីបច្ឆាស់ថា ព្រះដ៏មានព្រះភាគទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ

ចេញទៅ ។ ដល់វេលារាត្រីកន្លងហើយ ព្រះដ៏មានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រ និងចីវរក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅឯលំនៅរបស់ឧគ្គហមេណ្ឌកនត្តា លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លំដាប់នោះ ឧគ្គហមេណ្ឌកនត្តា អង្គាសព្រះដ៏មានព្រះភាគឱ្យឆ្អែតស្កប់ស្កល់ដោយខាទនីយភោជនីយាហារដ៏ថ្លៃថ្លាដោយដៃខ្លួនឯង គ្រាតែព្រះដ៏មានព្រះភាគទ្រង់ឃាត់ ។ លុះឧគ្គហមេណ្ឌកនត្តា (ឃើញ) ព្រះដ៏មានព្រះភាគឆាន់រួចលែងលូកព្រះហស្តក្នុងបាត្រហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះឧគ្គហមេណ្ឌកនត្តា អង្គុយក្នុងទីសមគួរហើយ ទើបក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកកុមារីរបស់ខ្ញុំព្រះអង្គទាំងអម្បាលនេះ មុខជានឹងទៅកាន់ត្រកូលប្តី បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគទូន្មានពួកកុមារីទាំងនោះឱ្យទាន បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគប្រៀនប្រដៅពួកកុមារីទាំងនោះ ដោយតុណ្ហីភាព ។ គ្រានោះ ឧគ្គហមេណ្ឌកនត្តា ដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណចេញឱវាទានុសាសនៈណា ដែលនាំឱ្យបានប្រយោជន៍

និងសេចក្តីសុខអស់កាលដ៏វែងដល់កុមារីទាំងនោះ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងពួកកុមារីទាំងនោះយ៉ាងនេះថា ម្នាលកុមារីទាំងឡាយ ហេតុដូច្នោះ ពួកកុមារីក្នុងលោកនេះ ត្រូវសិក្សាយ៉ាងនេះថា មាតានិងបិតាជាអ្នកប្រាថ្នាសេចក្តីចម្រើន ជាអ្នកស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះអាស្រ័យសេចក្តីអនុគ្រោះហើយ ឱ្យដល់បុរសជាស្វាមីណា **យើងទាំងឡាយជាស្រីភ្ញាក់ឡើងមុនគេ, ដេកក្រោយគេ, ប្រុងខ្នន់នឹងទទួលកិច្ចការអ្វី ៗ,ប្រព្រឹត្តផ្កាប់ផ្កួន,និយាយពាក្យផ្អែមល្ហែមដល់ស្វាមីនោះ,** ម្នាលកុមារីទាំងឡាយ ពួកនាងត្រូវសិក្សាយ៉ាងនេះចុះ ។ ម្នាលកុមារីទាំងឡាយ ហេតុដូច្នោះ ពួកកុមារីក្នុងលោកនេះ ត្រូវសិក្សាយ៉ាងនេះថាបុគ្គលណាជាទីគោរពនៃស្វាមីទោះជាមាតាក្តី បិតាក្តី សមណព្រាហ្មណក្តី យើងទាំងឡាយនឹងធ្វើសក្ការៈគោរពរាប់អានបូជាដល់បុគ្គលទាំងនោះ ទាំងទទួលគួរសម រៀបចំដោយអាសនៈ និងទឹកលាងជើងចំពោះជនទាំងឡាយ ដែលមកដល់ហើយ ម្នាលកុមារីទាំងឡាយ ពួកនាងត្រូវសិក្សាយ៉ាងនេះ ។ ម្នាលកុមារីទាំងឡាយ ហេតុដូច្នោះ ពួកកុមារីក្នុងលោកនេះត្រូវសិក្សាយ៉ាងនេះថា ការងារទាំងឡាយណាខាងក្នុងផ្ទះរបស់ប្តី ទោះរោម

ចៀមក្តី កប្បាសក្តី ពួកយើងនឹងជាស្រីឈ្លាសវៃក្នុងការងារទាំងនោះ មិនខ្វិលច្រអូស បរិបូណ៌ដោយឧបាយ និងការត្រិះរិះក្នុងកិច្ចការទាំងនោះថា គួរធ្វើគួរចាត់ចែង ម្នាលកុមារីទាំងឡាយ ពួកនាងត្រូវសិក្សាយ៉ាងនេះ ។ ម្នាលកុមារីទាំងឡាយ ហេតុដូច្នោះ ពួកកុមារីក្នុងលោកនេះ ត្រូវសិក្សាយ៉ាងនេះថា ជនណាជាជនខាងក្នុងផ្ទះរបស់ស្វាមី ទោះខ្ញុំក្តី អ្នកបម្រើក្តី អ្នកធ្វើការងារក្តី ពួកយើងដឹងការងារដែលជនទាំងនោះធ្វើហើយ ព្រោះការងារដែលជនទាំងនោះធ្វើហើយផង ដឹងការងារដែលជនទាំងនោះមិនបានធ្វើ ព្រោះការងារដែលជនទាំងនោះ មិនបានធ្វើផង ដឹងថា ឈឺធ្ងន់ ឈឺស្រាលផង ហើយចែករំលែកខាទនីយភោជនីយាហារជាចំណែក ៗ ដល់ជនទាំងនោះផងម្នាលកុមារីទាំងឡាយ ពួកនាងត្រូវសិក្សាយ៉ាងនេះ ។ ម្នាលកុមារីទាំងឡាយ ហេតុដូច្នោះ ពួកកុមារីក្នុងលោកនេះ ត្រូវសិក្សាយ៉ាងនេះថា ស្វាមីនាំរបស់ណាមក ទោះទ្រព្យក្តី ស្រូវក្តី ប្រាក់ក្តី មាសក្តី យើងទាំងឡាយនឹងធ្វើរបស់នោះ ឱ្យសម្រេចដោយការរក្សា និងការគ្រប់គ្រង មិនជាស្រីអ្នកលេង មិនជាស្រីអ្នកលួច មិនជាស្រីអ្នកផឹកសុរា មិនមែនជាស្រីអ្នកបំផ្លាញរបស់ទ្រព្យដែលខ្លួនគ្រប់គ្រងនោះ ម្នាលកុមារីទាំងឡាយ ពួកនាងត្រូវ

សិក្សាយ៉ាងនេះ ។ ម្នាលនាងកុមារីទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ទាំង ៥ យ៉ាងនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងពួកទេវតាមានកាយជាទីគាប់ចិត្ត ។

យោ នំ ភរតិ សព្ទធា និច្ចំ អាតាបិ ឧស្សុកោ
សព្ទកាមហរំ ភោសំ ភត្តារំ ឆាតិមញ្ញតិ ។

ស្វាមីណាចិញ្ចឹមភរិយានោះសព្ទកាល មានព្យាយាមទ្រល់ទ្វាយជានិច្ច ភរិយាមិនត្រូវមើលងាយស្វាមីអ្នកចិញ្ចឹម អ្នកបំពេញសេចក្តីប្រាថ្នាទាំងពួង(នោះ)ឡើយ ។

ន ចាបិ សោត្ថិ ភត្តារំ ឥស្សាចារេនភោសយេ
ភត្តុ ច ភរុនោ សព្ទេ បជិបូជេតិ បណ្ឌិតា ។

ស្ត្រីល្អមិនត្រូវក្រោធខឹងនឹងស្វាមី ដោយកិរិយាប្រព្រឹត្តឫស្យាផង ស្ត្រីអ្នកចេះដឹង រមែងបូជាចំពោះពួកជនទាំងពួង ដែលជាទីគោរពរបស់ស្វាមីផង ។

ឧដ្ឋាយិកា អនលសា សច្ចហិតបរិជ្ជនា
ភត្តុ មនាបំ ចរតិ សំភតំ អនុរក្ខតិ ។

ភរិយាគប្បីជាស្ត្រីមានព្យាយាម មិនខ្ជិលច្រអូស សង្គ្រោះ

ជនជាខាងក្នុងផ្ទះស្វាមី ប្រព្រឹត្តកិច្ចការជាទីគាប់ចិត្តរបស់ស្វាមី រក្សាទុកនូវសម្បត្តិដែលស្វាមីបានមកហើយ ដោយប្រពៃ ។

យា ឯវំ វត្តតី នារី ភត្តុ ឆន្ទវសានុគា

មនាបា នាម តេ ទេវា យត្ត សា ឧបបជ្ជតីតិ ។

នារីណា បានប្រព្រឹត្តយ៉ាងនេះ លុះតាមអំណាចសេចក្តីប្រាថ្នារបស់ស្វាមី នារីនោះ រមែងទៅកើតក្នុងពួកទេវតាទាំងនោះ ដែលមានកាយជាទីពេញចិត្ត ។

អដ្ឋកថា

សួរថា ព្រោះហេតុអ្វី ទើបឧគ្គហាសេដ្ឋីដែលជាចៅប្រុសរបស់មេណ្ឌកសេដ្ឋីនោះ យាងព្រះដ៏មានព្រះភាគ មានព្រះអង្គជាគម្រប់ ៤ ពោលគឺភិក្ខុ ៣ អង្គ មានព្រះដ៏មានព្រះភាគជាគម្រប់ ៤ អង្គ ?

ឆ្លើយថា ក្នុងគ្រឹះស្ថានរបស់លោកសេដ្ឋីនោះ មានរៀបចំការងារមង្គលមួយដ៏ធំ ម្ល៉ោះហើយ ត្រូវមានមនុស្សដ៏ច្រើនមកប្រជុំគ្នានាគ្រឹះស្ថាននោះ ។ លោកសេដ្ឋីគាត់គិតថា អ្នកថ្វាយចង្ហាន់ព្រះភិក្ខុសង្ឃមុខតែលំបាកនឹងយកចិត្តភ្ញៀវ កាលណាបើព្រះភិក្ខុ

សង្ឃច្រើនអង្គពេកនោះដូច្នោះ ទើបអារាធនាព្រះដ៏មានព្រះភាគ ដោយមានព្រះអង្គជាគម្រប់ ៤ អង្គតែប៉ុណ្ណោះ ។ ម្យ៉ាងទៀត លោកសេដ្ឋីគាត់មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលបើព្រះបរមសាស្តាទ្រង់ប្រទានឱវាទ នៅកណ្តាលជំនុំព្រះភិក្ខុសង្ឃច្រើនអង្គក្នុង ៗស្រី ៗទាំងឡាយនោះរវល់តែសម្លឹងមើលលោកអង្គនេះ អង្គនោះម្ល៉ោះហើយ មិនអាចនឹងទទួលយកនូវព្រះបរមពុទ្ធឱវាទបាន ទើបនិមន្តព្រះសង្ឃតែ ៣ អង្គ មានព្រះដ៏មានព្រះភាគជាគម្រប់ ៤ ។ ព្រះដ៏មានព្រះភាគ លុះសម្តែងព្រះសូត្រជាឱវាទចប់ហើយ កាលដែលព្រះអង្គទ្រង់សរុបដោយព្រះគាថាទាំងឡាយ ទើបត្រាស់ពាក្យជាដើមថា **យោ នំ ភរតិ សត្ថា** ។

បណ្តាបទទាំងនោះបទថា **ភរតិ** បានដល់ រក្សា ចិញ្ចឹម ទំនុកបម្រុង ។

បទថា **សត្ថុកាមហារំ** គឺឱ្យវត្ថុដែលគួរប្រាថ្នាទាំងពួង ។

បទថា **សោត្ថិ** ប្រែថា ជាស្ត្រីដែលល្អ ។

បទថា **ឯវំ វត្តតិ** បានដល់ ប្រព្រឹត្តវត្តប្រមាណប៉ុណ្ណោះ ឱ្យបរិបូណ៌ ។

បទថា **មនាបា នាម តេ ទេវា** បានដល់ ទេវតាជាន់និម្មានរតី ។ ពិតណាស់ ទេវតាទាំងនោះមានឈ្មោះថា និម្មានរតី ព្រោះនិម្មិតរូបដែលខ្លួនប្រាថ្នាហើយអភិរម្យ ។

ចុន្ទីសូត្រ

នៅក្នុងបិដកលេខ ៤៤, ទំព័រ ៦៧ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់អំពី **[វត្ថុដែលមានផលដ៏ប្រសើរ]** មានសេចក្តីថា ៖

សម័យមួយ ព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តវេឡុវន ជាកលន្ទកនិវាបដ្ឋាន ទៀបក្រុងរាជគ្រឹះ ។ គ្រានោះនាងចុន្ទីរាជកុមារី មានរថ ៥០០ និងកុមារី ៥០០ បៃហាមចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគហើយប្រថាប់ក្នុងទីសមគួរ ។

លុះនាងចុន្ទីរាជកុមារីប្រថាប់ក្នុងទីសមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន រាជកុមារឈ្មោះ **ចុន្ទៈ** ជាបងខ្ញុំព្រះអង្គនោះនិយាយយ៉ាងនេះថា តាមតែបុគ្គលណាក៏ដោយ ទោះស្ត្រីក្តី បុរសក្តី ដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ហើយវៀរចាក

ចាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន បុគ្គលនោះលុះបែកធ្លាយរាងកាយស្លាប់ទៅ ទៅកើតក្នុងសុគតិ មិនទៅកើតក្នុងទុគ្គតិទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមសួរព្រះដ៏មានព្រះភាគថា បុគ្គលជ្រះថ្លាក្នុងព្រះសាស្តា មានសភាពដូចម្តេច លុះបែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតក្នុងសុគតិ មិនទៅកើតក្នុងទុគ្គតិជ្រះថ្លាក្នុងព្រះធម៌មានសភាពដូចម្តេច លុះបែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតសុគតិ មិនទៅកើតក្នុងទុគ្គតិ ជ្រះថ្លាក្នុងព្រះសង្ឃមានសភាពដូចម្តេច លុះបែកធ្លាយរាងកាយស្លាប់ទៅបានទៅកើតសុគតិ មិនទៅកើតក្នុងទុគ្គតិបំពេញក្នុងសីល មានសភាពដូចម្តេច លុះបែកធ្លាយរាងកាយស្លាប់ទៅបានទៅកើតសុគតិ មិនទៅកើតក្នុងទុគ្គតិទេ ។

ម្នាលនាងចុន្ទី រាប់តាំងពីពួកសត្វឥតជើងក្តី មានជើង ២ ក្តី ជើង ៤ ក្តី ជើងច្រើនក្តី មានរូបក្តី ឥតរូបក្តី មានសញ្ញាក្តី ឥតសញ្ញាក្តី នេវសញ្ញានាសញ្ញាក្តី ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធប្រាកដជាប្រសើរជាងពួកសត្វទាំងនោះ ។ ម្នាលនាងចុន្ទី ពួកបុគ្គលណាជ្រះថ្លាក្នុងព្រះពុទ្ធ ពួកបុគ្គលនោះឈ្មោះថា ជ្រះថ្លាក្នុងបុគ្គលដ៏ប្រសើរ

ផលដ៏ប្រសើរ រមែងមានដល់ពួកបុគ្គលអ្នកជ្រះថ្លាក្នុងបុគ្គលដ៏ប្រសើរ ។ ម្នាលនាងចុន្ទី ពួកសង្ខតធម៌ក្តី អសង្ខតធម៌ក្តី ទាំងប៉ុន្មាន វិរាគធម៌ គឺធម៌ញុំាងសេចក្តីស្រើងឱ្យទ្រុឌទ្រោម នាំចេញនូវសេចក្តីស្រេកឃ្លាន គាស់រំលើងនូវសេចក្តីអាល័យ ផ្តាច់បង់នូវវដ្តៈអស់តណ្ហាប្រាសចាកតម្រេករលត់ ទុក្ខមិនមានគ្រឿងចាក់ជោត ប្រាកដជាប្រសើរជាងពួកធម៌ទាំងនោះ ។ ម្នាលនាងចុន្ទី ពួកបុគ្គលណាជ្រះថ្លាក្នុងវិរាគធម៌ ពួកបុគ្គលនោះឈ្មោះថា ជ្រះថ្លាក្នុងធម៌ដ៏ប្រសើរ ផលដ៏ប្រសើរ រមែងមានដល់ពួកបុគ្គលអ្នកជ្រះថ្លាក្នុងធម៌ដ៏ប្រសើរ ។ ម្នាលនាងចុន្ទី សង្ឃក្តី គណៈក្តី ទាំងប៉ុន្មាន សង្ឃសាវ័ករបស់តថាគត បើរាប់ជាគូបុរសមាន ៤ គូ បើរាប់រៀងជាបុគ្គលមាន ៨ សង្ឃទាំងនោះជាសង្ឃសាវ័កនៃព្រះដ៏មានព្រះភាគ ជាអ្នកគួរទទួលចតុប្បច្ច័យ ដែលបុគ្គលខុទ្ទិសចំពោះហើយនាំមកបូជា គួរទទួលអាគន្តុកទាន គួរទទួលទូវទានដែលបុគ្គលជឿនូវកម្មនិងផលនៃកម្មហើយបូជា គួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើជាបុញ្ញក្ខេត្តដ៏ប្រសើរ របស់សត្វលោកប្រាកដជាប្រសើរជាងសង្ឃ ឬគណៈទាំងនោះ ។ ម្នាលនាងចុន្ទី ពួកបុគ្គលណាជ្រះ

ថ្វាក្នុងព្រះសង្ឃ ពួកបុគ្គលនោះ ឈ្មោះថាជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ផលដ៏ប្រសើរ រមែងមានដល់ពួកបុគ្គលអ្នកជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរ ។ ម្នាលនាងចុន្ទី សីលដែលព្រះអរិយៈសរសើរទាំងអម្បាលម៉ាន ជាសីលមិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុស ជាសីលដែលវិញ្ញូជនសរសើរ ហើយមិនប៉ះពាល់ដោយតណ្ហា និងទិដ្ឋិប្រព្រឹត្តទៅដើម្បីសមាធិនេះ ប្រាកដជាប្រសើរជាងសីលទាំងនោះ ។ ម្នាលនាងចុន្ទី ពួកបុគ្គលណាជាអ្នកបំពេញក្នុងពួកសីលដែលព្រះអរិយៈសរសើរហើយ ពួកបុគ្គលទាំងនោះ ឈ្មោះថា បានបំពេញក្នុងសីលដ៏ប្រសើរ ។

អគ្គតោ វេ បសន្នានំ អគ្គំ ធម្មំ វិជានតំ
អគ្គេ ពុទ្ធេ បសន្នានំ ទក្ខិណេយ្យេ អនុត្តរេ
អគ្គេ ធម្មេ បសន្នានំ វិរាគូបសមេ សុខេ
អគ្គេ សង្ឃេ បសន្នានំ បុញ្ញក្ខេត្តេ អនុត្តរេ
អគ្គស្មឹ ទានំ ទទតំ អគ្គំ បុញ្ញំ បវឌ្ឍតិ
អគ្គំ អាយុ ច វណ្ណោ ច យសោ កិត្តិ សុខំ ពលំ ។

បុណ្យដ៏ប្រសើរផង អាយុដ៏ប្រសើរផង សម្បុរកាយដ៏

ប្រសើរផង យសស័ក្តិដ៏ប្រសើរផង កេរ្តិ៍ឈ្មោះដ៏ប្រសើរផង សុខដ៏ប្រសើរផង កម្ចាត់ដ៏ប្រសើរផង រមែងចម្រើនដល់ពួកបុគ្គលអ្នកដឹងច្បាស់នូវធម៌ដ៏ប្រសើរជ្រះថ្លានឹងវត្ថុដ៏ប្រសើរគឺជ្រះថ្លាក្នុងព្រះពុទ្ធដ៏ប្រសើរដែលជាទក្ខិណេយ្យ បុគ្គលរកបុគ្គលដទៃក្រៃលែងជាងគ្មានជ្រះថ្លាក្នុងព្រះធម៌ដ៏ប្រសើរ ជាធម៌ប្រាសចាកភាគៈ ជាធម៌ស្ងប់រំងាប់នាំមកនូវសុខជ្រះថ្លាក្នុងព្រះសង្ឃដ៏ប្រសើរជាបុញ្ញក្ខេត្តរកខេត្តដទៃ ក្រៃលែងជាងគ្មានជាអ្នកឱ្យនូវទានចំពោះបុគ្គលដ៏ប្រសើរ ។

អគ្គស្ស ទាតា មេធាវី អគ្គធម្ម សមាហិតោ

ទេវភូតោ មនុស្សេ វា អគ្គប្បត្តោ បមោទតីតិ ។

បុគ្គលអ្នកមានប្រាជ្ញា មានចិត្តតម្កល់ក្នុងធម៌ដ៏ប្រសើរ ជាអ្នកឱ្យនូវទានចំពោះបុគ្គលដ៏ប្រសើរតែងបានទៅកើតជាទេវតា ឬមនុស្សជ្រះនូវសេចក្តីប្រសើរ រមែងរីករាយ ។

អដ្ឋកថា

បទថា បញ្ចហិ រថសតេហិ ដោយសេចក្តីថា ព្រះនាងចុន្ទី (ព្រះរាជធីតានៃព្រះបាទពិម្ពិសារ) សោយព្រះក្រយាព្រឹកហើយ

បានចូលគាល់ព្រះជនក សូមឱ្យចាត់ចែងនូវរថ ៥០០ គ្រឿង ដើម្បីរថទាំងនោះហែហម ចូលគាល់ព្រះបរមសាស្តា ។ ព្រះរាជធីតាមាននូវព្រះតម្រិះថា យើងនឹងទូលសួរចំណុចដែលបានសន្ទនានូវបញ្ហាដែលយើងឱ្យប្រព្រឹត្តទៅជាមួយនឹងព្រះជេដ្ឋភាតា ។ ដូច្នេះហើយក៏បានកាន់យកផ្ការម្រង និងគ្រឿងក្រអូបជាដើម ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ ។

បទថា **អរិយកន្តានិ សីលានិ** បានដល់ សីលដែលសម្បយុត្តដោយមគ្គនិងផល ។ ក៏សីលទាំងនោះជាសីលដែលគួរប្រាថ្នា គួរត្រេកអររបស់ព្រះអរិយៈទាំងឡាយ ព្រោះហេតុនោះទើបមិនលះបង់សូម្បីក្នុងភពជាទៃ ។

បុញ្ញាភិសន្ទសូត្រ

នៅក្នុងបិដកលេខ ១៤២, ទំព័រ ១៤៦ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី(**គំនរបុណ្យកុលស**)មានសេចក្តីថា ៖

មហោឧធឺ អបរិមិតំ មហាសរំ
ពហុភេរវំ រតនគណានមាលយំ
នជ្ជោ យថា មច្ចគណាសច្ឆសេវិតា

បុថ្ថ សវន្តិ ឧបយន្តិ សាគរំ
ឯវំ នរំ អន្នធបានវត្ថនំ
សេយ្យានិសជ្ជត្ថរណាសយ្ច ធាយកំ
បុញ្ញស្ស ធារា ឧបយន្តិ បណ្ឌិតំ
នជ្ជោ យថា វារិវហាវ សាគរន្តិ ។

ទន្លេទាំងឡាយដ៏ច្រើនជាទីនៅអាស្រ័យនៃពួកត្រីរមែងហូរចុះទៅកាន់សាគរ ។ សាគរជាអន្លង់ទឹកធំដែលបុគ្គលប្រមាណមិនបាន ជាស្រះធំប្រកបដោយអារម្មណ៍គួរឱ្យស្ងប់ស្ងែងដ៏ក្រៃលែង ជាទីកើតនៃរតនវត្ថុទាំងឡាយយ៉ាងណាមិញ ធារានៃបុណ្យ រមែងប្រព្រឹត្តហូរទៅកាន់ជនដែលជាបណ្ឌិតអ្នកឱ្យនូវបាយ ទឹក សំពត់ ទីដេក ទីអង្គុយ និងគ្រឿងកម្រាល ដូចជាស្ទឹង ទន្លេទាំងឡាយដែលហូរទៅកាន់សាគរយ៉ាងនោះឯង ។

សាធុសូត្រ

*នៅក្នុងបិដកលេខ ២៩, ទំព័រ ៥១ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់អំពី (**អានិសង្សនៃការឱ្យទាន**) មានសេចក្តីថា ៖*

លំដាប់នោះឯង កាលរាត្រីបឋមយាមកន្លងទៅហើយ ពួក

សតុល្លបកាយិកាទេវតាជាច្រើន មានវស្ស៊ីដ៏រុងរឿងញុំាងវត្តជេត-ពនទាំងមូលឱ្យភ្លឺស្វាង ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះមានព្រះភាគ ហើយរនៅក្នុងទីដ៏សមគួរ ។

ទេវតាមួយអង្គ ឈរនៅក្នុងទីដ៏សមគួរ បន្ទឹនូវឧទាននេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

សាធុ ខោ មារិស ទានំ មច្ចេរា ច បមាទា ច

ឯវំ ទានំ ន ទីយតិ បុញ្ញមាកង្ខមានេន

ទេយ្យំ ហោតិ វិជានតាតិ ។

បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ***ទាន*** *ជាការប្រពៃណាស់ បុគ្គលឱ្យទានមិនបានយ៉ាងនេះ* ***ព្រោះសេចក្តីកំណាញ់ផង ព្រោះសេចក្តីប្រហែសផង ទាន*** *កាលបើបុគ្គលដឹងច្បាស់ ជាអ្នកប្រាថ្នានូវបុណ្យគួរតែឱ្យ ។*

លំដាប់នោះ ទេវតាមួយអង្គទៀត បន្ទឹនូវឧទាននេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

សាធុ ខោ មារិស ទានំ

អបិច អប្បកស្មីបិ សាហុ ទានំ

អប្បស្មេកេ បវេច្ចន្តិ ពហុនេកេ ន ទិច្ចរេ
អប្បស្មា ទក្ខិណា ទិន្នា
សហស្សេន សមំ មិតាតិ ។

បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ***ទាន*** *ជាការប្រពៃណាស់ កាលដែលទ្រព្យមានតិចនៅតែឱ្យបានជាការប្រពៃជនពួកខ្លះសូម្បីមានទ្រព្យបន្តិចបន្តួចក៏ឱ្យបានជនពួកខ្លះមានទ្រព្យច្រើនតែឱ្យមិនកើតទក្ខិណាទានដែលគេចែករំលែកអំពីទ្រព្យតិច ហើយឱ្យមានផលស្មើគ្នានឹងទានដទៃរាប់ពាន់ ។*

លំដាប់នោះ ទេវតាដទៃទៀត បានបន្ទឺនូវគុណទាននេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

សាធុ ខោ មារិស ទានំ
អប្បកស្មីបិ សាហុ ទានំ
ទានញ្ហេ យុទ្ធញ្ហេ សមានមាហុ
អប្បាបិ សន្តា ពហុកេ ជិនន្តិ
អប្បម្បិ ចេ សទ្ធហានោ ទទាតិ

តេនេវ សោ ហោតិ សុខី បរត្ថាតិ ។

បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ***ទាន*** *ជាការប្រពៃណាស់ កាលដែលទ្រព្យមានតិច នៅតែឱ្យបាន ជាការប្រពៃ មួយទៀត ការឱ្យដោយសទ្ធា ជាការប្រពៃ ពួកអ្នកប្រាជ្ញពោលថា ទានឥតចម្បាំងមានកម្លាំងស្មើគ្នា ពួកសប្បុរសសូម្បីមានគ្នាតិច រមែងឈ្នះពួកអសប្បុរសដែលមានគ្នាច្រើនបាន កាលបើបុគ្គលណាជឿ(កម្មផល)ហើយឱ្យទាន សូម្បីបន្តិចបន្តួចបុគ្គលនោះរមែងបានសេចក្តីសុខក្នុងលោកខាងមុខ ព្រោះតែទាននោះឯង ។*

លំដាប់នោះ ទេវតាជនៃទៀត បានបន្លឺនូវឧទាននេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

សាធុ ខោ មារិស ទានំ
អប្បកស្មីបិ សាហុ ទានំ
សទ្ធាយបិ សាហុ ទានំ
អបិច ធម្មលទ្ធស្សបិ សាហុ ទានំ
យោ ធម្មលទ្ធស្សបិ ទទាតិ ទានំ
ឧដ្ឋានវីរិយាធិគតស្ស ភគ្គុ

អតិកម វេតរណី យមស្ស
និព្ភាន ឋានានិ ឧបេតិ មច្ចោតិ ។

បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ ***ទាន*** *ជាការប្រពៃណាស់ កាលដែលទ្រព្យមានតិច នៅតែឱ្យបាន ជាការប្រពៃ ការឱ្យដោយសទ្ធា ជាការប្រពៃ មួយទៀត ការឱ្យនូវរបស់ដែលបានមកដោយធម៌ ជាការប្រពៃ ជនណាឱ្យទានដល់បុគ្គលអ្នកបានធម៌ អ្នកត្រាស់ដឹង ដោយសេចក្តីសង្វាតនិងសេចក្តីព្យាយាម ជននោះកន្លងបង់នូវវេតរណីនរករបស់ស្តេចយម: ហើយដល់នូវឋានទាំងឡាយ ជាទិព្វបាន ។*

លំដាប់នោះ ទេវតាជនៃទៀត បានបន្ថែមនូវឧទាននេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា :

សាធុ ខោ មារិស ទានំ
អប្បកស្មីបិ សាហុ ទានំ
សទ្ធាយបិ សាហុ ទានំ
ធម្មលទ្ធស្សបិ សាហុ ទានំ
អបិច វិច្ឆេយទានំបិ សាធុ

វិច្ឆេយ្យទានំ សុគតប្បសត្ថំ
យេ ទក្ខិណេយ្យា ឥធ ជីវលោកេ
ឯតេសុ ទិន្នានិ មហប្ផលានិ
វិជានិ វុត្តានិ យថា សុខេត្តេតិ ។

បពិត្រព្រះអង្គអ្នកនិទ៌ុក្ខ ***ទាន*** *ជាការប្រពៃណាស់ កាលដែលទ្រព្យមានតិចនៅតែឱ្យបានជាការប្រពៃ មួយទៀត ការឱ្យដោយសទ្ធាជាការប្រពៃ ទាំងឱ្យរបស់ដែលបាន មកដោយធម៌ជាការប្រពៃប៉ុន្តែការពិចារណាហើយឱ្យ ទើបជាការប្រពៃ ព្រោះទានដែលបុគ្គលពិចារណាហើយឱ្យ ព្រះសុគតទ្រង់សរសើរ ពួកទក្ខិណេយ្យបុគ្គលណាមានក្នុងជីវលោកនេះ ទានដែលបុគ្គលឱ្យចំពោះពួកទក្ខិណេយ្យបុគ្គលនុ៎ះ មានផលច្រើនដូចជាពូជដែលបុគ្គលសាបព្រោះក្នុងស្រែល្អ ។*

លំដាប់នោះ ទេវតាជនៃទៀត បានបន្ថែមនូវឧទាននេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

សាធុ ខោ មារិស ទានំ
អប្បកស្មីបិ សាហុ ទានំ

សទ្ធាយបិ សាហុ ទានំ
ធម្មលទ្ធសប្បិ សាហុ ទានំ
វិច្ឆេយទានំបិ សាធុ
អបិច ចាណោសុបិ សាធុ សំយមោ
យោ ចាណភូតានិ អហេឋយំ ចរំ
បរូបឃាឆា ន ភវោតិ ចាបំ
ភីរុំ បសំសន្តិ ន ហិ តត្ត សូរំ
ភយា ហិ សន្តោ ន ភវោន្តិ ចាបន្តិ ។

បពិត្រព្រះអង្គអ្នកនិទ្ទុក្ខ **ទាន** *ជាការប្រពៃណាស់ កាលដែលទ្រព្យមានតិច នៅតែឱ្យបាន ជាការប្រពៃ ការឱ្យដោយសទ្ធា ជាការប្រពៃ ការឱ្យរបស់ដែលបានមកដោយធម៌ ជាការប្រពៃ ការពិចារណាហើយឱ្យ ក៏ជាការប្រពៃហើយ ប៉ុន្តែការសង្រួម គឺការមិនបៀតបៀនក្នុងសត្វទាំងឡាយ ក៏វិតតែជាការប្រពៃណាស់ បុគ្គលណាមិនប្រព្រឹត្តបៀតបៀនដូវសត្វទាំងឡាយ មិនធ្វើបាបព្រោះខ្លាចការតិះដៀលអំពីអ្នកដទៃ ជនទាំងឡាយតែងសរសើរបុគ្គលខ្លាចបាប មិនសរសើរបុគ្គលក្លៀវក្លាក្នុងបាបនោះទេ ឯពួក

សប្បុរសមិនធ្វើបាប ព្រោះខ្លាចបាប ។

លំដាប់នោះ ទេវតាដទៃទៀត បានក្រាបបង្គំទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះមានព្រះភាគភាសិតរបស់អ្នកណាហ្ន៎ ជាសុភាសិត ។

ព្រះដ៏មានព្រះភាគត្រាស់ថា ភាសិតរបស់អ្នកទាំងឡាយគ្រប់គ្នាជាសុភាសិតដោយបរិយាយដែរហើយ តែអ្នកទាំងឡាយចូរស្តាប់របស់តថាគតវិញថា ៖

ទានា ច ខោ ធម្មបទំវ សេយ្យោ

បុព្វេវ ហិ បុព្វតរេវ សន្តោ

និព្វានមេវជ្ឈគមុំ សបញ្ញាតិ ។

ការឱ្យទាន ពិតជាអ្នកប្រាជ្ញសរសើរ ដោយចំណែកច្រើនក៏មែនហើយ តែថា ចំណែកធម៌ប៉ុណ្ណោះប្រសើរជាងទាន ព្រោះពួកសប្បុរសអ្នកមានប្រាជ្ញាក្នុងកាលមុនទើងកាលមុនទៅទៀត បានត្រាស់ដឹងនូវនិព្វានធម៌ ។

អដ្ឋកថា

*បទថា ឧទានំ ឧទានេសិ **បន្ទឺនូវឧទាន** បានដល់ ថ្លែងវាចាពោលចេញមក ។ ដូចប្រែងដែលលើសពីជួសបាន (ហៀរដោយ*

ដួស) ក៏ហូរចេញមក គេហៅប្រេងនោះថា ប្រេងហៀរ ឬទឹកប្រេងដែលមិនអាចទប់នៅក្នុងស្រះបាន រមែងហូរជោរជន់លិចគេហៅទឹកនោះថា "ឱឃៈអន្ធង់ទឹក"យ៉ាងណា ពាក្យដែលពោរពេញដោយបីតិមិនអាចនឹងរក្សាទុកក្នុងចិត្តបានបីតិកើនឡើងទប់ស្កាត់មិនជាប់ ទើបថ្លែងចេញមកខាងក្រៅ វាចានោះ ហៅថា **ឧទាន** ដូច្នោះដែរ ទេវតានោះថ្លែងឧទានដែលកើតពីបីតិបែបនេះ ។

បទថា សទ្ធាយបិ សាហុ ឋានំ **ការឱ្យដោយសទ្ធា ជាការប្រពៃ** បានដល់ ទានដែលបុគ្គលសូម្បីជឿនូវកម្មនិងផលរបស់កម្មហើយឱ្យជាការប្រពៃ គឺមានផល បានដល់ ជាវត្ថុចម្រើននោះឯង ។

បទថា **អហុ ពោល** គឺរមែងពោល ។

សួរថា ទាននិងការចម្បាំងទាំងពីរនោះ ទើបឈ្មោះថា ស្មើគ្នា តើដូចម្តេច ។

ឆ្លើយថា ព្រោះថា បុគ្គលដែលខ្ជិលច្រអូសក្នុងជីវិត រមែងមិនអាច ដើម្បីនឹងច្បាំងបុគ្គលដែលខ្ជិលច្រអូសការអស់ហិនហោចទ្រព្យក៏រមែងមិនអាចដើម្បីនឹងឱ្យទាន ។

ពិតមែនកាលបុគ្គលពោលថា ខ្ញុំនឹងរក្សាជីវិតផងនឹងច្បាំងផងដូច្នេះ រមែងច្បាំងមិនបាន តែបុគ្គលលះបង់សេចក្តីអាល័យក្នុងជីវិតហើយ ឱ្យខុសប្បាហ៍កើតឡើងថា យើងត្រូវកាត់អវយវៈឬជល់ស្លាប់ក៏ដោយ យើងនឹងត្រូវជាធំឱ្យបានដូច្នេះ ទើបច្បាំងបាន ។ បុគ្គលកាលពោលថា យើងនឹងរក្សាភោគៈទាំងឡាយនិងឱ្យទានដូច្នេះ ឈ្មោះថា រមែងធ្វើទានមិនបាន តែបុគ្គលលះបង់សេចក្តីអាល័យក្នុងភោគៈទាំងឡាយ និងមានខុសប្បាហៈថា យើងនឹងឱ្យមហាទានដូច្នេះ ឈ្មោះថា រមែងឱ្យទានបាន ។ ទាននិងការច្បាំង រមែងស្មើគ្នា សូម្បីដោយអាការយ៉ាងនេះ ។ ពាក្យអ្វី ៗ ដែលនឹងគប្បីពោលឱ្យក្រៃលែងជាងនេះមិនមាន ។

បទថា អប្បាបិ សន្តា ពហុកេ ជិនំ **ពួកសប្បុរសសូម្បីមានគ្នាតិច រមែងឈ្នះពួកអសប្បុរសដែលមានគ្នាច្រើនបាន** អធិប្បាយថា ពួកវីរបុរសទោះជាមានតិច ក៏អាចច្បាំងឈ្នះអ្នកខ្លាចដែលមានគ្នាច្រើនបានយ៉ាងណា បុគ្គលដែលជល់ព្រមដោយសទ្ធាក៏យ៉ាងនោះ ។

កាលឱ្យទានតិច រមែងញាំញីសេចក្តីកំណាញ់ច្រើន ទាំង

បានផលរបស់ទានជាច្រើន ។

ទានន៏ងការច្បាំងទើបស្មើគ្នាសូម្បីដោយអាការយ៉ាងនេះ ។ ព្រោះហេតុនេះឯង ទេវតាទើបពោលថា កាលបើបុគ្គលជឿហើយឱ្យទានសូម្បីបន្តិច ដូច្នេះ ។ ក៏ដើម្បីប្រកាសសេចក្តីនេះថា ព្រោះដូច្នោះឯង ទាយកនោះរមែងជាអ្នកមានសេចក្តីសុខក្នុងលោកមុខ ដូច្នេះ គប្បីញុំាងរឿងព្រាហ្មណ៍ឯកសាដកឱ្យពិស្តារ ។

បទថា ធម្មលទ្ធស្ស **ដែលបានមកដោយធម៌** បានដល់បុគ្គលមានភោគៈដែលបានហើយដោយធម៌ដ៏ស្ងប់ និងបុគ្គលមានធម៌ដែលបានហើយ ។ ក្នុងសេចក្តីនេះ បុគ្គលមានធម៌ដែលសម្រេចហើយ ជាព្រះអរិយបុគ្គលឈ្មោះថា អ្នកមានធម៌ដែលបានហើយ ។ ព្រោះដូច្នោះទានដែលបុគ្គលមានភោគៈដែលបានហើយដោយធម៌ រមែងឱ្យដល់ព្រះអរិយបុគ្គលដែលមានធម៌បានហើយ លោកពោលថា សូម្បីនោះក៏ជាការល្អ ។ សេចក្តីក្នុងបទគាថាថា "ជនណាឱ្យទានដល់បុគ្គលអ្នកបានធម៌" សូម្បីនេះក៏ន័យនេះឯង ។

បទថា ឧដ្ឋានវីរិយាធិគតស្ស **អ្នកត្រាស់ដឹងដោយសេចក្តីសង្វាត និងសេចក្តីព្យាយាម** បានដល់ អ្នកមានភោគៈ

ដែលសម្រេចហើយ ដោយការសង្វាតនិងសេចក្តីព្យាយាម ។

បទថា **វេតរណិ (នរកដែលមានទន្លេ)** នេះ ជាត្រឹមតែគោលទេសនាប៉ុណ្ណោះ ។ អធិប្បាយថា ក៏បុគ្គលនោះ រួចផុតទៅបានដោយប្រការទាំងពួង គឺក្នុងនរកបស់ស្តេចយម ឈ្មោះថាវេតរណីខ្លះក្នុងមហានរក៣១ មានសញ្ជីវនរកនិងកាឡសុត្តនរកជាដើមខ្លះ ។

បទថា **វិចេយ្យទានំ ទានដែលបុគ្គលពិចារណាហើយឱ្យ** គឺទានដែលបុគ្គលជ្រើសរើសហើយ ទើបឱ្យ ។ ក្នុងសេចក្តីនេះបានដល់ ទានដែលបុគ្គលជ្រើសរើសហើយឱ្យនោះមាន ២ យ៉ាង គឺជ្រើសរើសទក្ខិណា (ទេយ្យធម៌សម្រាប់ធ្វើបុណ្យ)មួយយ៉ាង ជ្រើសរើសព្រះទក្ខិណេយ្យបុគ្គល (បុគ្គលដែលគួរទទួលទេយ្យធម៌)មួយយ៉ាង ។

ក្នុងពីរយ៉ាងនោះ ការនាំបច្ច័យទាំងឡាយ ដែលអាក្រក់ចេញទៅហើយជ្រើសរើសយកបស់ដ៏ប្រណីត ៗថ្វាយដល់ព្រះទក្ខិណេយ្យបុគ្គលទាំងនោះ ឈ្មោះថា ការជ្រើសរើសទក្ខិណា ។ ការលះវៀរបុគ្គលទាំងឡាយក្រៅអំពីសាសនានេះអ្នកមានសីល

វិបត្តិហើយ និងបុគ្គលដែលនៅតាមជង្រៃ ៩៥ ប្រភេទ ហើយថ្វាយទានដល់បព្វជិតក្នុងព្រះសាសនា អ្នកដល់ព្រមដោយសីលាទិគុណ ឈ្មោះថាការជ្រើសរើសព្រះទក្ខិណេយ្យបុគ្គល ។ ដោយអាការទាំងពីរយ៉ាង យ៉ាងនេះ ឈ្មោះថា ទានដែលបុគ្គលជ្រើសរើសឱ្យ ។

បទថា **សុគតប្បសដ្ឋំ** គឺ **សុគតេន វណ្ណិតំ ព្រះសុគតទ្រង់សរសើរហើយ** ។ ក៏ទេវតាពោលដល់ការជ្រើសរើសទក្ខិណា (របស់ធ្វើបុណ្យ) ដោយពាក្យថា **ពីជានិ វុត្តានិ យថា ដូចជាពូជដែលសាបព្រោះហើយ** នេះអធិប្បាយថា ទេយ្យធម៌ គឺរបស់ធ្វើបុណ្យដែលប្រណីត ។ ដូចនឹងការជ្រើសរើសពូជដែលសាបព្រោះហើយ ។

បទថា **ថាណោសុបិ សាធុ សំយមោ ការសង្រួម គឺការមិនបៀតបៀនក្នុងសត្វទាំងឡាយ ក៏រឹងរឹតតែជាការប្រពៃណាស់** បានដល់ សូម្បីការសង្រួមក្នុងសត្វទាំងឡាយ ក៏រមែងជាកម្មដែលចម្រើន ។

ទេវតានេះកាលនឹងឈានកន្លងអានិសង្សរបស់ទានដែល

ពួកទេវតាពួកជដៃពោលហើយបានផ្តើមដល់អានិសង្សនៃសីល ។

ពាក្យថា អហេឋយំ ចរំ **មិនប្រព្រឹត្តបៀតបៀន** បានដល់ មិនត្រាច់ទៅបៀតបៀន ។

បទថា បរូបវាទា **ការតិះដៀលអំពីអ្នកជដៃ** គឺព្រោះខ្លាចសេចក្តីតិះដៀលនៃបុគ្គលជដៃ ។

បទថា ភយា **ខ្លាច** បានដល់ ឧបវាទភ័យ (ភ័យគឺ សេចក្តីតិះដៀល) ។

បទថា ធានា ច ខោ ធម្មបទំវ សេយ្យោ **បទនៃធម៌ត្រឹមតែមួយ ក៏ប្រសើរជាងទាន** សេចក្តីថា បទនៃធម៌ ពោលគឺព្រះនិព្វានន៎ុះឯង ប្រសើរជាងទាន ។

បទថា បុព្វេវ ហិ បុព្វតរេវ សន្តោ **ព្រោះថា សប្បុរសទាំងឡាយជាន់ដើមឬជាន់ដើមទៅទៀត** អធិប្បាយថា ក្នុងកាលមុន គឺកាលនៃព្រះពុទ្ធព្រះនាមថា កស្សបៈជាដើម និងក្នុងកាលមុន ទៅទៀត គឺក្នុងកាលនៃព្រះពុទ្ធព្រះនាមថា កោនាគមនៈជាដើមក្តី បណ្ឌិតទាំងនោះសូម្បីទាំងអស់ឈ្មោះថាជាសប្បុរសក្នុងកាល មុន ឬក្នុងកាលមុនទៅទៀតនោះឯង ដូច្នេះឯង ។

តតិយវគ្គ ទានសូត្រ

នៅក្នុងបិដកលេខ ៥៣,ទំព័រ ២៤ ព្រះអង្គទ្រង់ត្រាស់នូវ **[ការឱ្យទានដែលមានផលច្រើន]** ដោយមានសេចក្តីថា ៖

ខ្ញុំបានស្តាប់មកថា ព្រះមានព្រះភាគទ្រង់ត្រាស់ហើយ ព្រះអរហន្តសម្តែងហើយ ។ ម្នាលភិក្ខុទាំងឡាយ **បើពួកសត្វដឹងផលនៃការចែកទាន ដូចជាតថាគតដឹងដូច្នោះ បើមិនទាន់ឱ្យទានទេ ក៏មិនហ៊ានបរិភោគឡើយ** ម្យ៉ាងទៀត **មន្ទិលគឺសេចក្តីកំណាញ់របស់សត្វទាំងនោះ ក៏មិនគ្របសង្កត់ចិត្តបានឡើយ** ។ ទោះបីពំនូតបាយជាដំបូង ដុំបាយជាដំបូងឯណារបស់សត្វទាំងនោះ សត្វទាំងឡាយមិនបាន រំលែកអំពីពំនូតបាយនោះ ក៏មិនបរិភោគឡើយ បើសត្វទាំងនោះមានបដិគ្គាហកបុគ្គល ។ ម្នាលភិក្ខុទាំងឡាយ តថាគតដឹងផលនៃការឱ្យ និងការចែករំលែកយ៉ាងណា សត្វទាំងឡាយមិនដឹងយ៉ាងនោះទេ ព្រោះហេតុណា ហេតុនោះ សត្វទាំងឡាយមិនបានឱ្យទានហើយ ទើបហ៊ានបរិភោគ មួយទៀត មន្ទិលគឺសេចក្តីកំណាញ់ ក៏មិនគ្របសង្កត់ចិត្តសត្វទាំងឡាយនោះ ។

លុះព្រះមានព្រះភាគ ទ្រង់សម្តែងសេចក្តីនុ៎ះហើយ ។ ទ្រង់

ត្រាស់គាថាព័ន្ធនេះ ក្នុងសូត្រនោះថា ៖

ឯវញ្ចេ សត្តា ជានេយ្យុំ យថាវុត្តំ មហេសិនា
វិបាកំ សវិភាគស្ស យថា ហោតិ មហប្ផលំ
វិនេយ្យ មច្ឆេរមលំ វិប្បសន្នេន ចេតសា
ទជ្ជុំ កាលេន អរិយេសុ យត្ត ទិន្នំ មហប្ផលំ
អន្នញ្ច ទត្វាន ពហុំនោ ទក្ខិណេយ្យេសុ ទក្ខិណំ
ឥតោ ចុតា មនុស្សត្តា សគ្គំ គច្ឆន្តិ ទាយកា
តេ ច សគ្គគតា តត្ថ មោទន្តិ កាមកាមិនោ
វិបាកំ សវិភាគស្ស អនុភោន្តិ អមច្ឆរាតិ ។

បើសត្វទាំងឡាយ គប្បីដឹងផលនៃការចែករំលែកថា មានផលច្រើនដូចព្រះពុទ្ធទ្រង់សែ្វងរកគុណដ៏ធំត្រាស់ទុកហើយយ៉ាងនេះ សត្វទាំងឡាយមានចិត្តជ្រះថ្លា គប្បីបន្ទោបង់មន្ទិល គឺសេចក្តីកំណាញ់ចេញ ទានដែលគេឱ្យហើយ ដល់ព្រះអរិយៈទាំងឡាយណា រមែងមានផលច្រើន បុគ្គលទាំងឡាយ គួរឱ្យទានដល់ព្រះអរិយៈទាំងនោះក្នុងកាលដ៏គួរមួយទៀត ជនច្រើននាក់ឱ្យបាយជា

ទក្ខិណាទានដល់ទក្ខិណេយ្យបុគ្គលទាំង២ឡាយ ទាយកទាំង២ឡាយ លុះច្យុតអំពីអត្តភាពជាមនុស្សនេះហើយ រមែងទៅកាន់ឋានសួគ៌ ទាយកទាំងនោះ លុះទៅកាន់ឋានសួគ៌ ជាអ្នកមានចំណង់ក្នុងកាម រមែងរីករាយក្នុងស្ថានសួគ៌នោះ សត្វទាំង២ឡាយមិនកំណាញ់ រមែងសោយផលនៃការចែករំលែក ។

ខ្ញុំបានស្តាប់មកយ៉ាងនេះថា សេចក្តីនេះឯង ព្រះមានព្រះភាគបានត្រាស់ទុកហើយ ។

អដ្ឋកថា

បទថា **ឯវំ** ក្នុងបទថា **ឯវញ្ចេ** នេះប្រព្រឹត្តទៅក្នុងសេចក្តីឧបមា ។ បទថា ចេ ជានិបាតចុះក្នុងបរិកប្ប ។ បទថា សត្តា បានដល់ អ្នកប្រជាប់ គឺអ្នកជ្រួតជ្រាបទៅក្នុងអារម្មណ៍មានរូបជាដើម ។ បទថា ជានេយ្យំ ប្រែថា គប្បីដឹង ។ បទថា **ទានសំវិភាគសទ្ធេ** បានដល់ចេតនាដែលរួបរួមទេយ្យធម៌ មានបាយជាដើម ឱ្យដល់បុគ្គលដទៃដោយសេចក្តីអនុគ្រោះ និងការបូជាយ៉ាងណាមួយ ឈ្មោះថា **ទាន** (ការឱ្យ) ចំណែកចេតនាដែលចែកចំណែកមួយរបស់វត្ថុ ដែលកាន់យកទុកបរិភោគហើយ ឱ្យឈ្មោះថា

សវិភាគ(ការចែករំលែក) ។ បទថា**វិបាកំ** គឺផល ។ បទថា **យថាហំ ជានាមិ** បានដល់ ដូចជាតថាគតដឹង ។ សេចក្តីនេះ ព្រះដ៏មានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ បើថា សត្វទាំងឡាយពួកនេះគប្បីដឹងផលនៃការចែករំលែកទាន ដូចជាតថាគតដឹង ដោយកម្លាំងញ្ញាណដែលជាផលនៃកម្ម ដោយប្រចក្សក្នុងពេលឥឡូវនេះ មានអត្ថថា ផលទានរមែងមានដល់ ១០០ ដង ដោយការឱ្យទាន សូម្បីដល់សត្វតិរច្ឆាន ហើយសោយសុខប្រព្រឹត្តទៅក្នុង ១០០ អត្តភាពដូច្នេះ ។ បទថា **ន អឌ្ឍា កុញ្ជេយ្យុំ** សេចក្តីថា សត្វទាំងឡាយ បើមិនទាន់ឱ្យរបស់ដែលគួរបរិភោគដល់បុគ្គលដទៃមុនទេ ក៏មិនហ៊ានបរិភោគ តែកាលឱ្យហើយទើបហ៊ានបរិភោគ ។ បទថា **ន ច នេសំ មច្ឆេរមលំ ចិត្តំ បរិយាទាយ តិដ្ឋេយ្យ** ម្យ៉ាងសេចក្តីកំណាញ់ដែលជាមន្ទិលនឹងមិនគ្របសង្កត់ចិត្តរបស់សត្វទាំងនោះសេចក្តីថា សេចក្តីកំណាញ់ដែលជាមន្ទិលយ៉ាងណាមួយរបស់ធម៌ខ្មៅ ដែលជាឧបក្កិលេស ទម្លាយភាពផូរផង់របស់ចិត្ត មានលក្ខណៈមិនព្រមឱ្យសម្បត្តិរបស់ខ្លួនដល់បុគ្គលដទៃ ។ ម្យ៉ាងទៀតសេចក្តីកំណាញ់នឹងមន្ទិលមានឥស្សាលោភៈ

ទីងទោសៈជាដើម ដែលធ្វើអន្តរាយដល់ទានសូម្បីដទៃ និងមិនគ្របសង្កត់ចិត្តរបស់សត្វទាំងនោះ ដោយអាការៈដែលមិនមានចេតនាទីងឱ្យឬមានចេតនាមិនបរិសុទ្ធិ ។ ក៏អ្នកណាសោតកាលដឹងផលរបស់ទានដោយពេញចិត្ត ទីងគប្បីឱ្យឱកាសដល់សេចក្តីកំណាញ់ ដែលជាមន្ទិលក្នុងចិត្តរបស់ខ្លួនបាន ។ បទថា **យោបិ នេសំ អស្ស ចរិមោ អាលោបោ** បានដល់គប្បីមានដុំបាយ ដុំក្រោយរបស់សត្វពួកនោះ ។ បទថា **ចរិមំ** កពឡំជាវេវចនៈនៃពាក្យថា **អាលោបោ** នោះឯង ។ សេចក្តីនេះ លោកអធិប្បាយថា តាមប្រក្រតីសត្វទាំងនេះមានជីវិតរស់នៅបានដោយខ្លួនឯង ដោយដុំបាយត្រឹមណា ជួសដុំបាយ ទុកមួយដុំក្នុងដុំបាយទាំងនោះសម្រាប់ខ្លួន ហើយឱ្យដុំបាយទាំងអស់ក្រៅពីនោះដល់បុគ្គលដែលត្រូវការ ហើយមករកដុំបាយដែលសល់ទុកនោះ ឈ្មោះថា ដុំបាយក្រោយក្នុងទីនេះ ។ បទថា **តតោបិ ន អសិវិគជិគ្ឃា ភុញ្ជេយ្យុំ សវេ នេសំ បដិគ្គាហកា អស្សុ** សត្វទាំងនោះមិនគប្បីចែករំលែកដុំបាយ ដុំខាងក្រោយពីដុំបាយនោះ ហើយក៏មិនគប្បីបរិភោគ បើបដិគ្គាហករបស់សត្វទាំងឡាយមាន សេចក្តីថា បើបដិគ្គាហកៈ

របស់សត្វទាំងនោះមាន សត្វទាំងឡាយគប្បីចែករំលែកសូម្បីពីដុំបាយមានប្រមាណតាមដែលពោលហើយគប្បីឱ្យមួយចំណែកហើយទើបបរិភោគ សត្វទាំងឡាយ គប្បីដឹងដូចយ៉ាងតថាគតដឹងផលរបស់ការចែករំលែកទានដោយជាក់ច្បាស់ដូច្នេះ ។ ដោយបទថា **យស្មា ច ខោ** ជាដើម ព្រះមានព្រះភាគជាម្ចាស់ទ្រង់ញុំាងសេចក្តីតាមព្រះពុទ្ធបំណងឱ្យសម្រេចដោយហេតុថា សត្វទាំងនេះមិនដឹងផលក្នុងការចែករំលែកទានយ៉ាងនេះ ព្រោះផលរបស់កម្មនៅមិនទាន់ឃើញប្រចក្ស ដោយបទនេះគប្បីឃើញថា ព្រះអង្គទ្រង់សម្តែងដល់ហេតុនៃការមិនបដិបត្តិក្នុងបុណ្យដទៃ និងការបដិបត្តិក្នុងវត្តុដែលមិនមែនបុណ្យ ។ ក្នុងគាថាទាំងឡាយ មានអធិប្បាយដូចតទៅនេះ បទថា **យថាវុត្តំ** ជានេយ្យំ**មហោសិនា** សេចក្តីថា ដូចយ៉ាងដែលព្រះមានព្រះភាគអ្នកស្វែងរកគុណដ៏ធំ ត្រាស់ហើយដោយនយជាដើមថា អ្នកឱ្យទានដល់សត្វតិរច្ឆានមានផល ១០០ ដូច្នេះឬដោយនយជាដើមក្នុងសូត្រនេះថា **ឯវញ្ចេ** អធិប្បាយថា ដូចយ៉ាងដែលព្រះមានព្រះភាគត្រាស់ហើយ ដោយព្រះញ្ញាណ គឺទ្រង់ជ្រាបផ្លូវចិត្ត ។ បទថា **វិបាកំ សំវិភាគស្ស** បានដល់ ផល

នៃការចែកវិលែក ។ ក៏និងនិយាយថ្វីដល់ទានដែលថា គ្មានផលនោះ ។ បទថា **យថាហោតិ មហប្ផលំ** គួរកើតចិត្តថា បើសត្វទាំងឡាយពួកនេះ គប្បីដឹងដោយវិធីត្រង់ផលនោះ ជាផលធំសោត ។ បទថា **វិនេយ្យ មច្ឆេរមលំ** សេចក្តីថា សត្វទាំងឡាយគប្បីកម្ចាត់បង់នូវសេចក្តីកំណាញ់ដែលជាមន្ទិល មានចិត្តផូរផង់ថ្លាដោយចំពោះយ៉ាងក្រៃលែងផង សេចក្តីជឿផលនៃកម្មនិងដោយសេចក្តីជឿក្នុងព្រះរតនត្រ័យ គប្បីឱ្យទានដែលឱ្យហើយ សូម្បីតិចក៏មានផលច្រើនក្នុងព្រះអរិយបុគ្គលអ្នកសម្បូរដោយគុណ មានសីលជាដើមព្រោះជាអ្នកឆ្ងាយចាកកិលេសទាំងឡាយតាមកាលដែលគួរ ។ លោកអ្នកគួរដល់ទក្ខិណាទាន ព្រោះធ្វើឱ្យមានផលច្រើន ឈ្មោះថា ទក្ខិណេយ្យបុគ្គល គឺជាអ្នកបដិបត្តិប្រពៃ ។ ឱ្យទក្ខិណាគឺ ទេយ្យធម៌ដែលអ្នកឱ្យជឿលោកខាងមុខក្នុងទក្ខិណេយ្យបុគ្គលទាំងនោះដោយទាននោះជាទានធំ ។ ម្យ៉ាងទៀត សួរថាគួរនឹងឱ្យទានយ៉ាងណា ។ ឆ្លើយថាគួរឱ្យទក្ខិណាទានក្នុងទក្ខិណេយ្យបុគ្គល ។ ម្យ៉ាង អ្នកឱ្យកាលច្យុតចាកកំណើតជាមនុស្សនេះហើយរមែងទៅកាន់ស្ថានសួគ៌ដោយការបដិសន្ធិ ។ បទថា **កាមកា-**

មិនោសេចក្តីថា ទាយកអ្នកប្រាថ្នាកាម គឺ មានសេចក្តីពេញចិត្ត ក្នុងកាមទាំងឡាយ ព្រោះជាអ្នកធ្វើសេចក្តីល្អដោយបានទទួលកម្ម ដែលជាសម្បត្តិនៃទេពសម្បត្តិដ៏ឧឡារដែលគួរប្រាថ្នា រមែងរីករាយ គឺបានទទួលសេចក្តីទំនុកបម្រុងតាមពេញចិត្ត ។

តោទេយ្យទានសូត្រ

នៅក្នុងបិដកលេខ ៤៤, ទំព័រ ៨២ ព្រះអង្គទ្រង់ត្រាស់នូវ **(ទាយកអ្នកឱ្យភោជនឈ្មោះថា ឱ្យហាន: ៥ យ៉ាង ដល់ បដិគ្គាហក:)** មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ទាយកកាលឱ្យភោជនាហារ ឈ្មោះថា **ឱ្យស្ថាន៥** យ៉ាងដល់បដិគ្គាហក:ទាំងឡាយ ។ **ស្ថាន ៥ យ៉ាង ដូចម្តេចខ្លះ?**

១- អាយុំ ទេតិ **គឺឱ្យអាយុ**

២- វណ្ណំ ទេតិ **ឱ្យពណ៌សម្បុរ**

៣- សុខំ ទេតិ **ឱ្យសុខ**

៤- ពលំ ទេតិ **ឱ្យកម្លាំង**

៥- បដិភាណំ ទេតិ **ឱ្យបដិភាណ:គឺប្រាជ្ញាវាងវៃ** ។

-**បុគ្គលដែលបានឱ្យអាយុហើយ** រមែងបានចំណែកអាយុទិព្វ ឬ អាយុជារបស់មនុស្ស ។

-**ឱ្យពណ៌សម្បុរ** រមែងបានចំណែកពណ៌សម្បុរទិព្វ ឬពណ៌សម្បុរជារបស់មនុស្ស ។

-**ឱ្យសុខ**រមែងបានចំណែកសុខទិព្វឬសុខជារបស់មនុស្ស ។

-**ឱ្យកម្លាំង** រមែងបានចំណែកកម្លាំងទិព្វ ឬកម្លាំងជារបស់មនុស្ស ។

-**ឱ្យបដិភាណ** រមែងបានចំណែកបដិភាណជាទិព្វ ឬបដិភាណជារបស់មនុស្ស ។

ម្នាលភិក្ខុទាំងឡាយ ពាយកកាលឱ្យភោជនាហារ ឈ្មោះថា ឱ្យស្ថាន ៥ យ៉ាងនេះ ដល់បដិគ្គាហក:ទាំងឡាយ ។

អាយុទោ ពលទោ ធីរោ វណ្ណទោ បដិភាណទោ

សុខស្ស ទាតា មេធាវី សុខំ សោ អធិគច្ឆតិ ។

ធីរជនអ្នកមានប្រាជ្ញា ជាអ្នកឱ្យអាយុ ឱ្យកម្លាំង ឱ្យពណ៌ សម្បុរ ឱ្យបដិភាណ ឱ្យសុខ(ដល់គេ) ហើយធីរជននោះរមែងបានសុខ ។

អាយុំ ទត្វា ពលំ វណ្ណំ សុខញ្ច បដិភាណទោ
ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតិ ។

អ្នកប្រាជ្ញឱ្យអាយុ ពណ៌សម្បុរ សេចក្តីសុខ ទាំងបដិភាណ ទៅកើតក្នុងទីណា ៗ រមែងមានអាយុវែង មានយសបរិវារ ។

អដ្ឋកថា

*បទថា អាយុំ ទេតិ បានដល់ ឈ្មោះថា **រមែងឱ្យអាយុ គឺឱ្យជីវិតរស់នៅ** ។*

*បទថា វណ្ណំ **គឺឱ្យពណ៌សម្បុរកាយ** ។*

*បទថា សុខំ **គឺឱ្យសុខផ្លូវកាយនិងសុខផ្លូវចិត្ត** ។*

*បទថា ពលំ **គឺឱ្យកម្លាំងកាយ** ។*

*បទថា បដិភាណំ **គឺឱ្យបញ្ញាឈ្លាសក្នុងការចងបញ្ហាសួរ និងឈ្លាសក្នុងការដោះស្រាយបញ្ហា** ។*

អាឝិត្តសូត្រ

*នៅក្នុងបិដកលេខ ២៥, ទំព័រ ៧ ព្រះអង្គទ្រង់ត្រាស់នូវ (**ផលនៃការឱ្យទាន**) ដោយមានសេចក្តីថា ៖*

ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ លំដាប់នោះឯង កាលដែលវេលាវត្រីបឋមយាមកន្លងទៅហើយ ទេវតាមួយអង្គមានរស្មីដ៏ល្អ ញុំាងវត្តជេតពនឱ្យភ្លឺ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏អភិវាទព្រះមានព្រះភាគ ហើយស្ថិតនៅក្នុងទីដ៏សមគួរ ។

លុះទេវតានោះ ឋិតនៅក្នុងទីសមគួរហើយបានពោលនូវគាថាទាំងនេះ ក្នុងសំណាក់នៃព្រះមានព្រះភាគថា ៖

អាទិត្តស្មឹ អគារស្មឹ យំ នីហរតិ ភាជនំ

តំ តស្ស ហោតិ អត្ថាយ នោ ច យំ តត្ថ ឌយ្ហតិ ។

បុគ្គលជញ្ជូននូវភាជន៍ណា អំពីផ្ទះដែលភ្លើងកំពុងឆេះ ពុំនោះសោត ភ្លើងមិនទាន់ឆេះនូវវត្ថុណាក្នុងផ្ទះនោះ ភាជន៍និងវត្ថុនោះ ជាប្រយោជន៍នៃបុគ្គលនោះឯង ។

ឯវមាទិត្តកោ លោកោ ជរាយ មរណេន ច

នីហរេថេវ ទានេន និន្នំ ហោតិ សុនិព្ភតំ ។

(យ៉ាងណា) សត្វលោកដែលជរា និងមរណៈឆេះយ៉ាង

នេះ ត្រូវនាំទ្រព្យចេញដោយទានកុំខាន ទានដែលបុគ្គលឱ្យហើយ ឈ្មោះថា នាំចេញដោយល្អ ។

ទិន្នំ សុខផលំ ហោតិ ទានិន្នំ ហោតិ តំ តថា

ចោរា ហរន្តិ រាជានោ អគ្គិ ឌយ្ហតិ ឧទ្ធតិ ។

វត្ថុដែលបុគ្គលឱ្យហើយ ជាវត្ថុមានសុខជាផល វត្ថុដែលបុគ្គលមិនឱ្យហើយ ជាវត្ថុមិនមានសុខជាផលទេ ពួកចោរតែងនាំទៅ ពួកព្រះរាជការតែងរឹបយក ភ្លើងតែងឆេះវិនាសទៅ ។

អថ អន្តេន ជហតិ សរីរំ សបរិគ្គហំ

ឯតទញ្ញាយ មេធាវី ភុត្វា ច យថានុភាវំ អនិន្ទិតោ សគ្គមុបេតិ ឋានន្តិ ។

ពុំនោះសោត វេលាស្លាប់ទៅក៏រមែងលះបង់នូវសរីរៈ និងរបស់ដែលបុគ្គលធ្លាប់ហួងហែង អ្នកប្រាជ្ញដឹងនូវសេចក្តីនេះហើយ គប្បីបរិភោគផង ឱ្យទានផង បុគ្គលឱ្យទាំងបរិភោគឱ្យសមគួរតាមសភាពហើយ គេមិនដែលនិន្ទាទេ តែងបានទៅកើតក្នុងឋានសួគ៌ ។

អដ្ឋកថា

បទថា ជរាយ មរណេន ច **ជរានិងមរណៈ** នេះ **ជាគោល**នៃទេសនា អធិប្បាយថា លោកគឺ ពួកសត្វត្រូវភ្លើងទាំង ទ្បាយ ១១ កង[1] មានរាគៈជាដើម ដុតពោលហើយ ។

បទថា ទានេន **ដោយទាន** បានដល់ ដោយចេតនាក្នុងការ ឱ្យទាន ។

បទថា និន្នំ ហោតិ សុនីភតំ **ទានដែលបុគ្គលឱ្យហើយ** ឈ្មោះថា នាំចេញដោយល្អ សេចក្តីថា ចេតនាដែលជាបុណ្យ ក្នុងការឱ្យ រមែងមានដល់ទាយកនុ៎ះឯង ដូចវត្ថុដែលម្ចាស់របស់ ផ្ទះនាំចេញហើយ ព្រោះហេតុនោះ ទើបលោកពោលថា **ចោរ** ហរន្តិ **ពួកចោរតែងនាំទៅ** អធិប្បាយថា កាលភោគៈដែលខ្លួន មិនបានឱ្យហើយ សូម្បីចោរទាំងឡាយក៏ប្លន់បាន សូម្បីព្រះរាជា ទាំងឡាយក៏នឹងរឹបយកបាន សូម្បីភ្លើងក៏អាចឆេះបាន ឬអន្តរធាន ទៅ សូម្បីក្នុងទីដែលខ្លួនរក្សាទុកហើយ ។

---

១. ភ្លើង ១១ កង គឺ រាគៈ, ទោសៈ, មោហៈ, ជាតិ, ជរា, មរណៈ, សោកៈ, បរិទេវៈ, ទុក្ខ, ទោមនស្ស, ឧបាយាស ។

បទថា អន្តេន **ដោយទំបំផុត** គឺដោយការស្លាប់ ។

បទថា សរីរំ សបរិគ្គហំ **រមែងលះបង់នូវសរីរៈ** អធិប្បាយថា រាងកាយនិងភោគៈមិនវិនាសទៅដោយអំណាចនៃអន្តរាយទាំងឡាយ មានចោរជាដើម ។

បទថា សគ្គមុបេតិ **តែងបានទៅកើតក្នុងឋានសួគ៌** អធិប្បាយថា រមែងកើតក្នុងឋានសួគ៌ ដូចស្តេចមហារាជវេស្សន្តរជាដើម ។

សុទ្ធត្តសូត្រ

នៅក្នុងបិដកលេខ ៤២, ទំព័រ ១៥៦ ព្រះអង្គទ្រង់ត្រាស់ពី [**អានិសង្សនៃការឱ្យទាន**] ដោយមានសេចក្តីថា ៖

គ្រានោះ អនាថបិណ្ឌិកគហបតី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះអនាថបិណ្ឌិកគហបតីអង្គុយក្នុងទីដ៏សមគួរហើយ ព្រះមានព្រះភាគត្រាស់ថា ម្នាលគហបតី អរិយសាវ័កកាលឱ្យនូវភោជនាហារ ឈ្មោះថា **ឱ្យនូវឋាន ៤ យ៉ាង ដល់បជិគ្គាហកទាំងឡាយ ។ ឋាន ៤ យ៉ាង តើដូចម្តេចខ្លះ។**

១- អាយុំ ទេតិ គឺឱ្យអាយុ

២- វណ្ណំ ទេតិ ឱ្យពណ៌សម្បុរ

៣- សុខំ ទេតិ ឱ្យសុខ

៤- ពលំ ទេតិ ឱ្យកម្លាំង ។

លុះឱ្យអាយុហើយ រមែងជាអ្នកមានចំណែក គឺបានទទួលយកនូវអាយុជារបស់ទិព្វ ឬ ជាអាយុរបស់មនុស្ស ។ លុះឱ្យវណ្ណៈហើយ... លុះឱ្យសុខហើយ... លុះឱ្យពលៈហើយ... រមែងជាអ្នកមានចំណែក គឺបានទទួលយកនូវពលៈជារបស់ទិព្វ ឬជារបស់មនុស្ស ។

ម្នាលគហបតីអរិយសាវ័កកាលឱ្យភោជនាហារឈ្មោះថាឱ្យនូវឋាន: ៤ យ៉ាងនេះ ដល់បដិគ្គាហកទាំងឡាយ ។

យោ សញ្ញំ បរេតត្តភោជិនំ កាលេន សក្កច្ច ទទាតិ ភោជនំ

ចត្តារិ ឋានានិ អនុប្បវេច្ឆតិ អាយុញ្ច វណ្ណញ្ច សុខំ ពលញ្ច ។

បុគ្គលណា ឱ្យនូវភោជនាហារដល់ពួកភិក្ខុដែលសង្រួម (ក្នុងសីល) ជាអ្នកបរិភោគភោជនដែលបុគ្គលដទៃឱ្យដោយគោរពតាមកាល បុគ្គលនោះ រមែងបានទទួលនូវឋាន:ទាំង ៤ យ៉ាង គឺអាយុ ១ វណ្ណ: ១ សុខ: ១ ពល: ១ ។

អាយុទាយី ពលទាយី សុខំ វណ្ណំ ទទោ នរោ

ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតិ ។

ជនអ្នកឱ្យអាយុ ឱ្យពល: ឱ្យសុខ: ឱ្យវណ្ណ: កើតក្នុងភពណា ៗ រមែងជាអ្នកមានអាយុវែង មានយសបរិវារក្នុងភពនោះ ៗ ។

អដ្ឋកថា

បទថា សញ្ញំ បានដល់ បដិគ្គាហក:អ្នកសង្រួមតាមផ្លូវកាយនិងវាចា ។ បទថា **បរទត្តភោជិនំ** សេចក្តីថា អ្នកបរិភោគរបស់ដែលបុគ្គលដទៃឱ្យហើយ ទើបញុំាងអត្តភាព ឱ្យប្រព្រឹត្តទៅ ។ បទថា កាលេន បានដល់ តាមកាលសមគួរ ។ បទថា **សក្កច្ច ទទាតិ** សេចក្តីថា ធ្វើសក្ការ:ដោយដៃរបស់ខ្លួន ។ បទថា **ចត្តារិ ឋានានិ អនុប្បវេច្ឆតិ** សេចក្តីថា រមែងបង្អរ គឺឱ្យនូវហេតុ

៤ ។ បទថា យសវា ហោតិ បានដល់ មានបរិវារច្រើន ។

កិន្នុឥសូត្រ

នៅក្នុងបិដកលេខ ២៩, ទំព័រ ៨២ ព្រះអង្គទ្រង់ត្រាស់ [**អំពីទេវតាបញ្ហា ៥ខ**] មានសេចក្តីថា ៖

ទេវតាទូលសួរថា ៖

កិន្នុធោ ពលធោ ហោតិ

កិន្នុធោ ហោតិ វណ្ណធោ

កិន្នុធោ សុខធោ ហោតិ

កិន្នុធោ ហោតិ ចក្ខុធោ

យោ ច សព្ពធនោ ហោតិ

តំ មេ អក្ខាហិ បុច្ឆិតោតិ ។

បុគ្គលឈ្មោះអ្វី ឈ្មោះថា ***ឈ្មោះកម្ចាត់***

ឈ្មោះអ្វី *ឈ្មោះថា* ***ឈ្មោះពណ៌សម្បុរ***

ឈ្មោះអ្វី *ឈ្មោះថា* ***ឈ្មោះសេចក្តីសុខ***

ឈ្មោះអ្វី *ឈ្មោះថា* ***ឈ្មោះចក្ខុ***

មួយទៀត ***បុគ្គលណាឈ្មោះរបស់អ្វី*** *ឈ្មោះថា* ***ឈ្មោះគ្រប់យ៉ាង***

សូមព្រះអង្គសម្តែងប្រាប់សេចក្តីនោះដល់ខ្ញុំព្រះអង្គជាអ្នកសួរ ។

ព្រះមានព្រះភាគត្រាស់តបថា ៖

អន្ធទោ ពលទោ ហោតិ

វត្តទោ ហោតិ វណ្ណទោ

យានទោ សុខទោ ហោតិ

ទីបទោ ហោតិ ចក្ខុទោ

សោ ច សព្វទទោ ហោតិ

អមតន្ទទោ ច សោ ហោតិ

យោ ធម្មមនុសាសតិ ។

បុគ្គលឱ្យបាយ ឈ្មោះថា **ឱ្យកម្លាំង**

ឱ្យសម្ផត់ *ឈ្មោះថា* **ឱ្យពណ៌សម្បុរ**

ឱ្យយានជិនៈ *ឈ្មោះថា* **ឱ្យសេចក្តីសុខ**

ឱ្យប្រទីប *ឈ្មោះថា* **ឱ្យចក្ខុ**

មួយទៀត **បុគ្គលណា ឱ្យទីនៅអាស្រ័យបុគ្គលនោះ** *ឈ្មោះថា* **ឱ្យវត្ថុគ្រប់យ៉ាង បុគ្គលណាប្រៀនប្រដៅធម៌ បុគ្គលនោះ** *ឈ្មោះថា* **ឱ្យព្រះនិព្វាន** ។

អដ្ឋកថា

បទថា អន្នទោ **ខ្សិបាយ** អធិប្បាយថា បុគ្គលសូម្បីមានកម្លាំងច្រើន តែមិនបានបរិភោគអាហារច្រើន ៗថ្ងៃ (ពីរ-បីថ្ងៃ) ក៏មិនអាចដើម្បីនឹងក្រោកឡើង ចំណែកបុគ្គលដែលមានកម្លាំងខ្សោយ បានបរិភោគអាហារហើយ ក៏រមែងដល់ព្រមដោយកម្លាំងបាន ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា បុគ្គលខ្សិបាយ ឈ្មោះថា **ខ្សិកម្លាំង** ដូច្នេះ ។

បទថា វត្ថទោ **ខ្សិសំពត់** អធិប្បាយថា បុគ្គលសូម្បីមានរូបល្អ តែមានសំពត់ស្មោកគ្រោក ដូចសំពត់ជូតឬមិនមានសំពត់ឡើយ រមែងជាអ្នកគួរស្អប់ ត្រូវប្រមាថមើលងាយមិនគួរមើល បុគ្គលមានសំពត់បិទបាំងល្អហើយ រមែងល្អដូចទេវបុត្រ ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ថា ខ្សិសំពត់ឈ្មោះថា **ខ្សិពណ៌សម្បុរ** ដូច្នេះ ។

បទថា យានទោ **ខ្សិយាន** បានដល់ យានទាំង ៦ ប្រាយមានហត្ថិយានជាដើម ក៏ប៉ុន្តែក្នុងបណ្តាយានទាំងនោះ យាន ដំរី យានសេះ រមែងមិនសមគួរដល់សមណៈ ការខ្សិទៅដោយរថក៏មិន

សមគួរដែរ យានដែលសមគួរដល់សមណៈ ក៏គឺស្បែកជើង សម្រាប់សមណៈអ្នករក្សានូវសីលខន្ធ ព្រោះដូច្នោះបុគ្គលឱ្យឆត្រ ស្បែកជើង ឈើច្រត់ គ្រែ តាំង ធ្វើផ្លូវ សាងជណ្តើរ សាងស្ពាន ចម្លងទូក សូម្បីទាំងអស់ ក៏ឈ្មោះថា **ឱ្យយានជូចគ្នា** ។

បទថា **សុខោ ហោតិ ឈ្មោះថា ឱ្យសេចក្តីសុខ** គឺឈ្មោះថា ឱ្យសេចក្តីសុខ ក៏ព្រោះនាំសេចក្តីសុខក្នុង**យានមកឱ្យ** ។

បទថា **ចក្ខុទោ ហោតិ ឈ្មោះថា ឱ្យចក្ខុ** អធិប្បាយថា ឱ្យប្រទីបគោមភ្លើង ឈ្មោះថា **ឱ្យចក្ខុ** ព្រោះបុគ្គលទាំងឡាយ សូម្បីមានភ្នែកក៏មិនអាចមើលឃើញក្នុងទីងងឹតបាន អ្នកឱ្យប្រទីបគោមភ្លើងនោះ រមែងបានសូម្បីនូវសេចក្តីដល់ ព្រមនៃទិព្វចក្ខុដូចព្រះអនុរុទ្ធត្ថេរ ។

បទថា **សព្វទោ ហោតិ ឈ្មោះថា ឱ្យវត្ថុគ្រប់យ៉ាង** អធិប្បាយថា អ្នកឱ្យទីនៅអាស្រ័យ ឈ្មោះថា វត្ថុគ្រប់យ៉ាង អធិប្បាយថា កាលភិក្ខុត្រាច់បិណ្ឌបាត ២-៣ ភូមិ សូម្បីមិនបានអ្វី ៗ ត្រឡប់មកងូតទឹកក្នុងស្រះបោក្ខរណីដ៏ត្រជាក់ចូលទៅកាន់ទីសម្រាក អាស្រ័យដេកលើគ្រែមួយភ្លែត ហើយក្រោកឡើងមក

អង្គុយក្តី ក្នុងកាយរមែងបានកម្លាំង ដូចទីសម្រាកនាំយកមកជាក់បំពេញ ។ ក៏បុគ្គលត្រាច់ទៅក្នុងខាងក្រៅ ពណ៌សម្បុរក្នុងកាយរមែងភ្លៅអាប់ទៅដោយឆ្ងល់ និងកំដៅថ្ងៃ កាលចូលទៅកាន់ទីសម្រាកអាស្រ័យបិទទ្វារហើយដេក ត្រឹមតែមួយរយៈសេចក្តីបន្តនៃវិសភាគៈ(ក្តៅ)រមែងចូលទៅស្ងប់រម្ងាប់សេចក្តីបន្តនៃសភាគៈ(ម្ជុប់) រមែងប្រព្រឹត្តទៅ រមែងបានពណ៌សម្បុរវណ្ណៈ ដូចទីសម្រាកនាំដាក់បំពេញ ។ ក៏កាលបុគ្គលត្រាច់ទៅខាងក្រៅ ជើងរមែងមុតបន្ទា ជំពប់នឹងដង្កត់ឈើ អន្តរាយទាំងឡាយមានពស់ជាដើមនិងចោរភ័យរមែងកើតឡើងកាលចូលទៅកាន់ទីសម្រាកអាស្រ័យបិទទ្វារដេកហើយ អន្តរាយទាំងអស់ទាំងនោះ រមែងមិនមានកាលស្ងាធ្យាយបីតិនិងសេចក្តីសុខក្នុងធម៌ រមែងកើតឡើងកាលធ្វើកម្មដ្ឋានទុកក្នុងចិត្ត សេចក្តីសុខដ៏ស្ងប់ រមែងកើតឡើងកាលបុគ្គលត្រាច់ទៅខាងក្រៅញើសទាំងឡាយ រមែងហូរចេញភ្នែកទាំងពីរ រមែងស្រវាំងក្នុងវេលាដែលចូលទៅកាន់សេនាសនៈ រមែងដូចជាធ្លាក់ចុះទៅក្នុងរណ្តៅ គ្រែនិងតាំង រមែងមិនប្រាកដ ក៏កាលបុគ្គលដេកសម្រាកត្រឹមតែមួយរយៈ សេចក្តីថ្លាផូរផង់នៃភ្នែកក៏នឹងមាន ហាក់ដូចជាទីសម្រាកនាំប្រាសាទភ្នែកមកជាក់

បំពេញ ។ ទ្វារបង្អួច គ្រែ តាំង រមែងប្រាកដ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា សោ ច សព្ពទទោ ហោតិ យោ ធម្មាតិ ឧបសគ្គយំ មួយទៀត **បុគ្គលណាឱ្យទីនៅអាស្រ័យបុគ្គលនោះ ឈ្មោះថា ឱ្យវត្ថុគ្រប់យ៉ាង** ដូច្នេះ ។

បទថា អមតំ ទទោ ច សោ ហោតិ **បុគ្គលនោះឈ្មោះថាឱ្យព្រះនិព្វាន** សេចក្តីថា អ្នកបង្រៀនធម៌ឈ្មោះថា ឱ្យទានដែលមិនស្លាប់ ដូចធ្វើបាតឱ្យពេញដោយភោជនដ៏ប្រណីត ។

បទថា យោ ធម្មមនុសាសតិ **បុគ្គលណាប្រៀនប្រដៅធម៌** អធិប្បាយថា បុគ្គលណារមែងទូន្មានធម៌ រមែងប្រាប់អដ្ឋកថា រមែងបង្រៀនបាលី(បិដក) រមែងដោះស្រាយបញ្ហាដែលសួរហើយ រមែងប្រាប់កម្មដ្ឋាន រមែងធ្វើធម្មសវនៈ សូម្បីទាំងអស់នេះឈ្មោះថា រមែងប្រៀនប្រដៅធម៌ ។ គប្បីជ្រាបថា ការឱ្យធម៌នេះឯងប្រសើរជាងការឱ្យទាំងពួង ។ សមដូចដែលត្រាស់ទុកថា ៖

សព្ពទានំ ធម្មទានំ ជិនាតិ សព្ពរតឹ ធម្មរតឹ ជិនាតិ សព្ពរសំ ធម្មរសោ ជិនាតិ តណ្ហក្ខយោ សព្ពទុក្ខំ ជិនាតិ ។

ការឱ្យធម៌រមែងឈ្នះអស់ការឱ្យទាំងពួង សេចក្តីត្រេកអរក្នុងធម៌ រមែងឈ្នះអស់សេចក្តីត្រេកអរទាំងពួង រសនៃធម៌ឈ្នះអស់រសទាំងពួង, ការអស់ទៅនៃតណ្ហាឈ្នះអស់ទុក្ខទាំងពួង ។

ខទយសូត្រ

នៅក្នុងបិដកលេខ ៣០, ទំព័រ ១១៨ ព្រះអង្គទ្រង់ត្រាស់ពី **[ការមិនជាប់នៅក្នុងវស]** មានសេចក្តីថា ៖

សាវត្ថីនិទាន គ្រានោះឯង ព្រះមានព្រះភាគទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់លំនៅរបស់ខទយព្រាហ្មណ៍អស់វារៈពីរដង ។ លំដាប់ឯង ខទយព្រាហ្មណ៍យកបាយដាក់ពេញបាត្រព្រះមានព្រះភាគ ។

ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់លំដៅរបស់ខទយព្រាហ្មណ៍អស់វារៈបីដង ។ ខទយព្រាហ្មណ៍ក៏យកបាយដាក់ពេញបាត្រព្រះមានព្រះភាគជាគម្រប់ពីរដង ។

ព្រះមានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់លំនៅរបស់ខទយព្រាហ្មណ៍ ជា

គម្រប់បីដង ។ ខុទយព្រាហ្មណ៍ ក៏យកថាយដាក់ពេញបាត្រព្រះមានព្រះភាគជាគម្រប់បីដង ។ ហើយពោលពាក្យនេះ និងព្រះមានព្រះភាគថា ព្រះសមណាគោតមនេះជាអ្នកជាប់ចិត្តក្នុងវេទបនិមន្តមកហើយ ៗ ។

បុនប្បុនំ ចេវ វបន្តិ ពីជំ
បុនប្បុនំ វស្សតិ ទេវរាជា
បុនប្បុនំ ខេត្តំ កសន្តិ កស្សកា
បុនប្បុនំ អញ្ញមុបេតិ រដ្ឋំ ។

ភ្លៀងបង្អុរចុះហើយ ៗ ជនទាំងឡាយ ក៏ព្រោះពូជហើយ ៗ អ្នកភូវរាស់ទាំងឡាយ ភូវរាស់ស្រែហើយ ៗតែងនាំស្រូវទៅកាន់ដែនក៏ហើយ ៗ ។

បុនប្បុនំ យាចកា យាចយន្តិ
បុនប្បុនំ ទានបតី ទទន្តិ
បុនប្បុនំ ទានបតី ទទិត្វា
បុនប្បុនំ សគ្គមុបេន្តិ ឋានំ ។

ស្ងួមទាំងឡាយសូមហើយ ៗ ម្ចាស់ទានទាំងឡាយ ក៏ឱ្យ

រឿយ ។ លុះម្ចាស់ទានទាំងឡាយឱ្យរឿយ ។ហើយ រមែងទៅកាន់ឋានសួគ៌ក៏រឿយ ។ ។

បុនប្បនំ ខីរណិកា ទុហន្តិ
បុនប្បនំ វច្ឆោ ឧបេតិ មាតរំ
បុនប្បនំ កិលមតិ ជន្តុ ច
បុនប្បនំ គព្ភមុបេតិ មត្តោ
បុនប្បនំ ជាយតិ មិយ្យតិ ច
បុនប្បនំ សីវថិកំ ហរន្តិ ។

អ្នកវួតទឹកដោះគោទាំងឡាយ រួតរឿយ ។ កូនគោក៏ចូលទៅរកមេគោរឿយ ។អ្នកល្ងង់ខ្លៅលំបាកផង ញាប់ញ័រផងរឿយ ។ តែងចូលទៅកាន់គភ៌ក៏រឿយ ។ ទាំងកើតទាំងស្លាប់ក៏រឿយ ។ ។

មគ្គញ្ច លទ្ធា អបុនព្ភវាយ
បុនប្បនំ ជាយតិ ភូរិបញ្ញោតិ ។

គេនាំទៅកាន់ទីស្មសានក៏រឿយ ។ ចំណែកអ្នកមានបញ្ញាដូចជាផែនដី លុះបាននូវមគ្គហើយ មិនកើតក្នុងភពថ្មីទៀតរឿយ ។ ឡើយ ។

កាលព្រះមានព្រះភាគត្រាស់យ៉ាងនេះហើយ ខុទយព្រាហ្មណ៍បានពោលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។បេ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់នូវព្រះរតនត្រ័យជាទីពឹង ស្មើដោយជីវិតតាំងពីថ្ងៃនេះជាដើមរៀងទៅ ។

អដ្ឋកថា

បទថា ខីឌេនេន បូរេសិ មានសេចក្តីថា ព្រាហ្មណ៍យកបាយនិងសម្ល ព្រមទាំងរបស់ដែលគេរៀបចំទុកដើម្បីខ្លួនទៅជាក់បាត្រហូតពេញហើយប្រគេន ។ បានឮថា ព្រះមានព្រះភាគទ្រង់ត្រួតមើលឧបសង្ឃយសត្វលោកនៅវេលាជិតភ្លឺ ទ្រង់ក៏បានឃើញព្រាហ្មណ៍នោះ ចូលក្នុងសំណាញ់ញាណរបស់ព្រះអង្គ (លុះទ្រង់ឃើញហើយ) ព្រះអង្គទ្រង់បដិបត្តិព្រះសរីរៈនៅព្រឹកព្រលឹម ស្តេចយាងចូលព្រះគន្ធកុដិ ទ្រង់បិទទ្វារហើយគង់ប្រថាប់ ព្រះអង្គទ្រង់ទតឃើញកោជន ដែលគេលើកចូលទៅទុកជិតព្រាហ្មណ៍ ។ គ្រានោះព្រះអង្គ ទ្រង់ស្តាយបាត្រនឹងព្រះអង្សរកូដ ស្តេចយាងអំពីព្រះគន្ធកុដិដល់ខ្លោងទ្វារព្រះនគរ ទ្រង់នាំបាត្រចេញហើយ ស្តេចយាង

ចូលព្រះនគរ ព្រះអង្គទ្រង់ព្រះដំណើរទៅតាមលំដាប់ ទ្រង់ឈរប្រថាប់នៅត្រង់ស៊ុមទ្វារផ្ទះរបស់ព្រាហ្មណ៍ ។ គ្រានោះព្រាហ្មណ៍បានឃើញព្រះដ៏មានព្រះភាគហើយ បានថ្វាយភោជន ដែលគេចាត់ចែងមក ដើម្បីខ្លួនដាក់ពេញបាត្រនៃព្រះដ៏មានព្រះភាគ ។ ពាក្យថា ឥធនេន បុរេសិ នេះ លោកពោលសំដៅយកភោជននោះ ។

បទថា ទុតិយម្បិ បានដល់ សូម្បីក្នុងថ្ងៃទី ២ ។

បទថា តតិយម្បិ បានដល់ សូម្បីក្នុងថ្ងៃទី ៣ ។

បានឮថា ក្នុងវេលាដែលព្រះដ៏មានព្រះភាគស្តេចយាងទៅកាន់ទ្វារផ្ទះរបស់ព្រាហ្មណ៍ជាប់ត ៗគ្នារហូត ៣ ថ្ងៃមិនមានអ្នកណា ៗដែលនឹងអាចក្រោកឡើងទទួលបាត្របានឡើយ មហាជនបានត្រឹមតែឈរមើលប៉ុណ្ណោះ ។

បទថា ឯតទវោ ច មានសេចក្តីថា ព្រាហ្មណ៍សូម្បីបានថ្វាយចង្ហាន់រហូតអស់វារៈ ៣ ថ្ងៃ ក៏មិនបានថ្វាយដោយសទ្ធាឡើយ ។ ព្រាហ្មណ៍បរិភោគដោយមិនបានថ្វាយ សូម្បីតែកិក្ខាដល់បព្វជិតដែលបានមកឈរនៅទៀបនឹងទ្វារផ្ទះ តែបានថ្វាយ

ព្រោះខ្លាចគេគរហានិន្ទាថា បព្វជិតមកឈរដល់ទ្វារផ្ទះហើយ សូម្បីត្រឹមតែភិក្ខា ក៏មិនថ្វាយ ស៊ីតែឯង ដូច្នេះ ។ កាលដែលថ្វាយ ២ ថ្ងៃដំបូងថ្វាយហើយមិនបាននិយាយអ្វី ។ឡើយ ត្រឡប់ចូលផ្ទះទាំងព្រះដ៏មានព្រះភាគ ក៏មិនបានត្រាស់អ្វី ។ដូចគ្នា ទ្រង់យាងចេញមក ប៉ុន្តែក្នុងថ្ងៃទី ៣ ព្រាហ្មណ៍មិនអាចអត់ទ្រាំបាន ទើបបានពោលពាក្យនេះថា **បកដ្ឋកោ** បានដល់ជាប់ជំពាក់ក្នុងរស ។ សូម្បីព្រះដ៏មានព្រះភាគ ព្រះអង្គយាងទៅរហូតដល់ទៅ ៣ ដង ក៏ដើម្បីឱ្យព្រាហ្មណ៍បន្ទឹរាចានោះ ។ឯង ។

ព្រះបរមសាស្តា ទ្រង់ព្រះសណ្តាប់ពាក្យរបស់ព្រាហ្មណ៍ហើយ ទើបព្រះអង្គបានត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកថ្វាយបិណ្ឌបាតរហូត ៣ ថ្ងៃ នៅតិចជង់នៅឡើយ ក្នុងលោកនេះមានធម៌ ១៦ ប្រការ ដែលគួរធ្វើរឿយ ។ ។ ដូច្នេះ ដើម្បីនឹងទ្រង់សម្តែងធម៌ទាំងនោះទើបទ្រង់ផ្តើមព្រះធម្មទេសនានេះថា **បុនប្បុនំ ចេវ វបន្តិ ពីជំ** ដូច្នេះ ។

បណ្តាបទទាំងនោះបទថា **បុនប្បុនំ ចេវ វបន្តិ** លោកពោលទុកក្នុងសស្សវារៈរួចហើយ សូម្បីក្នុងសស្សវារៈដទៃ ។ទៀត

ក៏ដូចគ្នា ។ អ្នកស្រែរមែងសាបព្រោះដោយមិនស្មាក់ស្ទើរចិត្តថា ប៉ុណ្ណោះល្មមហើយ ដូច្នេះឡើយ ។

បទថា **បុនប្បុនំ** វុត្តតិ សេចក្តីថា មិនមែនថ្វាយ តែមួយថ្ងៃឈប់ ។ ត្រូវថ្វាយរាល់ ៗថ្ងៃ រាល់ ៗ ឆ្នាំ ជនបទរមែងមានទ្រព្យច្រើន ដោយអាការយ៉ាងនេះ ។

បទថា **យាចកោ** នេះ ព្រះអង្គទ្រង់សម្តែងដោយភាវៈជាអ្នកឆ្លាតក្នុងទេសនា ។

បទថា **ខីរណិកោ** បានដល់ អ្នករូតទឹកដោះគោ ព្រោះទឹកជាហេតុ ។ ពិតមែន ជនទាំងនោះមិនមែនប្រាថ្នាចង់បានទឹកដោះនោះតែម្តងឡើយ អធិប្បាយថា រមែងប្រាថ្នារូតទឹកដោះឡើងវឿយ ៗ ។

បទថា **កិលមតិ ជន្តុ** ច មានសេចក្តីថា សត្វនេះរមែងលំបាកនឹងរើបម្រះដោយឥរិយាបទនោះ ៗ ។

បទថា **គព្ភំ** បានដល់ ពោះសត្វតិរច្ឆាន មានឆ្កែស្រុកនឹងឆ្កែព្រៃជាដើម ។

បទថា **មគ្គញ្ចុ លទ្ធា អបុនព្ភវាយ** មានសេចក្តីថា ព្រះនិព្វាន ឈ្មោះថា មគ្គ ព្រោះមិនកើតទៀត អធិប្បាយថា បានព្រះនិព្វាននោះ ។

បទថា **ឯវំ វុត្តេ** មានសេចក្តីថា កាលព្រះដ៏មានព្រះភាគ ទ្រង់ឈរនៅចន្លោះថ្នល់នោះឯង ទ្រង់បានសម្តែងនូវបុនប្បុនធម៌ ១៦ ប្រការ បានត្រាស់យ៉ាងនេះ ។

បទថា **ឯតទវោ ច** មានសេចក្តីថា ក្នុងទីបំផុតនៃទេសនា ព្រាហ្មណ៍ព្រមទាំងបុត្រភរិយា ពួកមិត្តនិងញាតិ ជ្រះថ្លាបានថ្វាយបង្គំទៀបព្រះឃុគលបាទនៃព្រះដ៏មានព្រះភាគ ហើយបានពោលពាក្យនេះថា អភិក្កន្តំ ភោ (បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ សូមព្រះគោតមដ៏ចម្រើន ចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់នូវព្រះរតនត្រ័យជាទីពឹង ស្មើដោយជីវិតតាំងពីថ្ងៃនេះជាដើមរៀងទៅ) ។

រឿយៗ ១៦ យ៉ាង

១- ភ្លៀងបង្អុរចុះរឿយ ៗ
២- ជនទាំងឡាយព្រោះពូជរឿយ ៗ
៣- អ្នកភ្ជួរវាស់ទាំងឡាយ ភ្ជួរវាស់ស្រែរឿយ ៗ
៤- តែនាំស្រូវទៅកាន់ដែនរឿយ ៗ
៥- សួមទាំងឡាយសូមរឿយ ៗ
៦- ម្ចាស់ទានទាំងឡាយឱ្យរឿយ ៗ
៧- ម្ចាស់ទានទាំងឡាយឱ្យហើយរឿយ ៗ
៨- រមែងទៅកាន់ឋានសួគ៌រឿយ ៗ
៩- អ្នកវឹតទឹកដោះគោទាំងឡាយ វឹតរឿយ ៗ
១០- កូនគោចូលទៅរកមេគោរឿយ ៗ
១១- អ្នកល្ងង់ខ្លៅលំបាករឿយ ៗ
១២- អ្នកល្ងង់ខ្លៅញាប់ញ័ររឿយ ៗ
១៣- អ្នកល្ងង់ខ្លៅតែងចូលទៅកាន់គភ៌រឿយ ៗ
១៤- អ្នកល្ងង់ខ្លៅកើតរឿយ ៗ
១៥- អ្នកល្ងង់ខ្លៅស្លាប់រឿយ ៗ
១៦- គេនាំទៅកាន់ទីស្មសានរឿយ ៗ ។

អន្ធសូត្រ

នៅក្នុងបិដកលេខ ២៩, ទំព័រ ៨១ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងអំពី [**អានិសង្សនៃការឱ្យទាន**] មានសេចក្តីថា ៖

ទេវតាក្រាបទូលសួរថា ៖

អន្ធមេវាភិនន្ទន្តិ ឧភយេ ទេវមានុសា
អថវោ នាម សោ យក្ខោ យំ អន្ធំ នាភិនន្ទតិ ។

ជនទាំងពីរពួក គឺទេវតានិងមនុស្ស រមែងប្រាថ្នានូវបាយតែម្យ៉ាង អ្នកណាមិនប្រាថ្នាបាយ ឈ្មោះថា យក្ខ ដោយពិត ។

ព្រះមានព្រះភាគត្រាស់ថា ៖

យេ នំ ទទន្តិ សទ្ធាយ វិប្បសន្នេន ចេតសា
តមេវ អន្ធំ ភជតិ អស្មីលោកេ បរម្ហិ ច
តស្មា វិនេយ្យ មច្ឆេរំ ទជ្ជា ទានំ មលាភិភូ
បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិនំ ។

ជនទាំងឡាយណា មានចិត្តជ្រះថ្លាឱ្យបាយនោះដោយសទ្ធា

ជាយនោះ រមែងចូលទៅរកជនទាំងនោះវិញក្នុងលោកនេះ និង
លោកខាងមុខ ព្រោះហេតុនោះ សាធុជនគប្បីកម្ចាត់បង់នូវសេចក្តី
កំណាញ់ គ្របសង្កត់នូវមន្ទិលហើយឱ្យទានចុះ (ព្រោះថា)
បុណ្យទាំងឡាយជាទីពឹងនៃពួកសត្វក្នុងបរលោក ។

អដ្ឋកថា

បទថា អភិនន្ទតិ ប្រែថា រមែងប្រាថ្នា ។

បទថា ភជតិ ប្រែថា រមែងមកដល់គេ គឺថា អានិសង្ស
នោះ រមែងជាប់តាមទៅខាងក្រោយ ប្រៀបដូចជាអានិសង្សដែល
ជាប់តាមចិត្តរបស់គហបតី និងព្រះសីវលីត្ថេរៈជាដើម ។

បទថា តស្មា អធិប្បាយថា ព្រោះការឱ្យអាហារ នោះឯង
រមែងជាប់តាមទៅទាំងក្នុងលោកនេះនឹងលោកខាងមុខ ព្រោះហេតុ
នោះ ព្រះមានព្រះភាគទើបត្រាស់ថា បុគ្គលគប្បីនាំនូវសេចក្តី
កំណាញ់ចេញ គប្បីគ្របសង្កត់នូវសេចក្តីកំណាញ់ ដែលជាមន្ទិល
ចេញហើយឱ្យទាន ។

សុមនសុត្រ

នៅក្នុងបិដកលេខ ៤៤, ទំព័រ ៦៣ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់សម្តែងអំពី **[ទេវតាមានសេចក្តីវិសេសជាងគ្នាដោយហេតុ ៥ ប្រការ]** មានសេចក្តីថា ៖

គ្រានោះ នាងសុមនាវាជកុមារី មានរថ ៥០០ និងវាជកុមារី ៥០០ អង្គ ហែហមចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយប្រថាប់ក្នុងទីសមគួរ ។ លុះនាងសុមនាវាជកុមារី ប្រថាប់នៅក្នុងទីសមគួរហើយ បានទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន **សាវ័កពីររូបរបស់ព្រះដ៏មានព្រះភាគក្នុងលោកនេះមានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានបញ្ញាស្មើគ្នា** ប៉ុន្តែ មួយអង្គជាទាយក មួយអង្គ មិនមែនជាទាយក សាវ័កទាំងនោះដល់បែកធ្លាយរាងកាយស្លាប់ទៅ ក៏ទៅកើតក្នុងសុគតិ សួគ៌ ទេវលោក បពិត្រព្រះអង្គដ៏ចម្រើន សាវ័កទាំងពីរដែលកើតជាទេវតានោះ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាងសុមនា មានដែរ ម្នាលនាងសុមនា សាវ័កណាជាទាយក សាវ័កនោះ ដល់កើតជា

ទេវតា រមែងគ្របសង្កត់ទេវតាឯណោះ ដែលមិនមែនជាទាយក ដោយហេតុ ៥ គឺ ៖

១- ឱភ្ញេន អាយុនា **អាយុទិព្វ**

២- ឱភ្ញេន វណ្ណេន **សម្បត្តិព្វ**

៣- ឱភ្ញេន សុខេន **សុខទិព្វ**

៤- ឱភ្ញេន យសេន **យសទិព្វ**

៥- ឱភ្ញេន អាធិបតេយ្យេន **អធិបតេយ្យទិព្វ** ។

ម្នាលនាងសុមនា សាវ័កណាជាទាយក សាវ័កនោះ ដល់នៅកើតជាទេវតា រមែងគ្របសង្កត់ទេវតាឯណោះដែលមិនមែនជាទាយកដោយហេតុ ៥ យ៉ាងនេះ ។

ស. បពិត្រព្រះអង្គដ៏ចម្រើន ចុះបើទេវតាទាំងពីរនោះ ច្យុតអំពីទេវលោកនោះមកកើតក្នុងមនុស្សលោកនេះ បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលទាំងពីរនោះ ដែលកើតជាមនុស្ស ហើយតើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ។

ព. ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាងសុមនា មានដែរ ម្នាលនាងសុមនា បុគ្គលណាជាទាយក បុគ្គលនោះដល់មកកើត

ជាមនុស្ស រមែងគ្របសង្កត់បុគ្គលឯណោះ ដែលមិនមែនជាទាយកដោយហេតុ ៥ យ៉ាងគឺ ៖

១-មានុសកេន អាយុនា ***អាយុជារបស់មនុស្ស***

២-មានុសកេន វណ្ណេន ***សម្បុរជារបស់មនុស្ស***

៣-មានុសកេន សុខេន ***សុខជារបស់មនុស្ស***

៤-មានុសកេន យសេន ***យសជារបស់មនុស្ស***

៥-មានុសកេន អាធិបតេយ្យេន ***អធិបតេយ្យជារបស់មនុស្ស*** ។

ម្នាលនាងសុមនា សាវ័កណាជាទាយក សាវ័កនោះ ដល់ទៅកើតជាទេវតា រមែងគ្របសង្កត់ទេវតាឯណោះ ដែលមិនមែនជាទាយកដោយហេតុ ៥ យ៉ាងនេះ ។

ស. បពិត្រព្រះអង្គដ៏ចម្រើន ចុះបើអ្នកទាំងពីរនោះ ចេញចាកផ្ទះបួស បពិត្រព្រះអង្គដ៏ចម្រើន បព្វជិតទាំងនោះ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ។

៣. ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលនាងសុមនាមានដែរ ម្នាលនាងសុមនា បុគ្គលណាជាទាយក បុគ្គលនោះលុះបួសហើយ

រមែងគ្រប់សង្កត់បព្វជិតឯណោះ ដែលជាមិនមែនជាទាយកដោយ
ហេតុ ៥ យ៉ាងគឺ ៖

១- បើគេអង្វរ រមែងប្រើប្រាស់ចីវរច្រើន បើគេមិនអង្វរ
ប្រើប្រាស់ចីវរតិច,

២- បើគេអង្វរ រមែងបរិភោគបិណ្ឌបាតច្រើន បើគេមិន
អង្វរ ក៏បរិភោគបិណ្ឌបាតតិច,

៣- បើគេអង្វរ រមែងប្រើប្រាស់សេនាសនៈច្រើន បើគេ
មិនអង្វរ ក៏រមែងប្រើប្រាស់សេនាសនៈតិច,

៤- បើគេអង្វរ រមែងប្រើប្រាស់គិលានប្បច្ចយភេសជ្ជ-
បរិក្ខារច្រើន បើគេមិនអង្វរ រមែងប្រើប្រាស់តិច,

៥- បើប្រសិនជានៅជាមួយពួកសព្រហ្មចារីណាពួក ស-
ព្រហ្មចារីនោះ រមែងរាប់អានភិក្ខុនោះ ដោយកាយកម្មជាទីគាប់
ចិត្តច្រើន មិនជាទីគាប់ចិត្តតិច រាប់អានដោយវចីកម្ម ជាទីគាប់
ចិត្តច្រើន មិនជាទីគាប់ចិត្តតិច រាប់អានដោយមនោកម្មជាទីគាប់
ចិត្តច្រើន មិនជាទីគាប់ចិត្តតិច ខ្ញុំឃើញបម្រើជាទីគាប់ចិត្តច្រើន
មិនជាទីគាប់ចិត្តតិច ។

ម្នាលនាងសុមនា បុគ្គលណាជាទាយក បុគ្គលនោះដល់បានបួសហើយ រមែងគ្រប់សង្កត់បព្វជិតឯណោះដែលមិនមែនជាទាយកដោយហេតុ ៥ យ៉ាងនេះ ។

សុ. បពិត្រព្រះអង្គដ៏ចម្រើន ចុះបើបព្វជិតទាំងពីរបុគ្គលនោះបានសម្រេចព្រះអរហត្ត បពិត្រព្រះអង្គដ៏ចម្រើន បណ្តាបព្វជិតទាំងពីរបុ ដែលបាសម្រេចព្រះអរហត្តហើយ នុ៎ះ តើមានសេចក្តីវិសេស មានហេតុផ្សេងគ្នាដែរឬទេ ។

ព. ម្នាលនាងសុមនា ត្រង់រឿងនុ៎ះ តថាគតមិនសម្តែងហេតុផ្សេងគ្នា ត្រង់ចិត្តដែលរួចស្រឡះដោយវិមុត្តិនេះទេ ។ បពិត្រព្រះអង្គដ៏ចម្រើន អស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន ចំឡែកណាស់ បពិត្រព្រះអង្គដ៏ចម្រើន **បុគ្គលគួរឱ្យទានទាំងឡាយមែន គួរធ្វើធ្វើបុណ្យទាំងឡាយ មែន ព្រោះថា បុណ្យទាំងឡាយ ជាឧបការៈដល់អ្នកដែលកើតជាទេវតាផង បុណ្យទាំងឡាយជាឧបការៈដល់អ្នកដែលកើតជាមនុស្សផង បុណ្យទាំងឡាយជាឧបការៈដល់អ្នកបួស(បាននៅយូរ)ផង ។**

ព. ម្នាលនាងសុមនា ហេតុនុ៎ះ យ៉ាងនេះហើយ ម្នាលនាងសុមនា ហេតុនុ៎ះ យ៉ាងនេះហើយ ម្នាលនាងសុមនាបុគ្គលគួរឱ្យ

ទានទាំងឡាយគួរធ្វើបុណ្យទាំងឡាយ (ព្រោះ)បុណ្យទាំងឡាយ ជាឧបការៈដល់អ្នកដែលកើតជាទេវតាផង បុណ្យទាំងឡាយជា ឧបការៈដល់អ្នកដែលកើតជាមនុស្សផង បុណ្យទាំងឡាយជា ឧបការៈដល់អ្នកបួសផង ។

ព្រះដ៏មានព្រះភាគ បានត្រាស់ពាក្យនេះ លុះព្រះសុគត បានត្រាស់ពាក្យនេះហើយ ព្រះសាស្តាបានត្រាស់ជាគាថានេះត ទៅទៀតថា ៖

យថាបិ ចន្ទោ វិមលោ គច្ឆំ អាកាសធាតុយា
សព្ពេ តារគណេ លោកេ អាភាយ អតិរោចតិ
តថេវ សីលសម្បន្នោ សទ្ធោ បុរិសបុគ្គលោ
សព្ពេ មច្ឆរិនោ លោកេ ចាគេន អតិរោចតិ ។

ព្រះចន្ទ្រមិនមានមន្ទិលកាលចរទៅតាមអាកាសរមែងរុងរឿងលើសជាងពួកផ្កាយទាំងអស់លើអាកាស ដោយពន្លឺ(របស់ខ្លួន) យ៉ាងណាមិញ បុរសបុគ្គលមានសទ្ធាបរិបូណ៌ដោយសីលរមែងរុងរឿងជាពួកបុគ្គលកំណាញ់ទាំងអស់ក្នុងលោក ដោយចាគៈក៏យ៉ាងនោះដែរ ។

យថាបិ មេឃោ ជនយំ វិជ្ជុមាលី សត្តុក្ករុ
ថលំ និន្នញ្ច បូរេតិ អភិវស្សំ វសុន្ធរំ
ឯវំ ទស្សនសម្បន្នោ សម្មាសម្ពុទ្ធសាវកោ
មច្ចរី អធិគ្គណ្ហាតិ បញ្ញាដ្ឋានេហិ បណ្ឌិតោ
អាយុនា យសសា ចេវ វណ្ណេន ច សុខេន ច
ស វេ ភោគបរិព្យុឡ្ហោ បេច្ច សគ្គេ មមោទតិ ។

កាលភ្លៀងប្រកបដោយផ្គេកបន្ទោរ ដ៏ឆ្អៀលឆ្ងាត់បរិបូណ៌ដោយភ្នំទឹកដ៏ច្រើន បង្អុរចុះមកបំពេញផែនដីដែលខ្ពស់ទាបឱ្យពោរពេញ យ៉ាងណាមិញ សាវ័ករបស់ព្រះសម្មាសម្ពុទ្ធដែលបរិបូណ៌ដោយទស្សនៈជាបណ្ឌិត រមែងគ្របសង្កត់បុគ្គលអ្នកមានសេចក្តីកំណាញ់ ដោយហេតុ ៥ យ៉ាងគឺ ***អាយុ យស សម្បុរ សុខ និងអធិបតី*** *បណ្ឌិតនោះឯង បរិបូណ៌ដោយភោគៈដល់ទៅ លោកខាងមុខរមែងរីករាយក្នុងឋានសួគ៌ ក៏យ៉ាងនោះដែរ ។*

អដ្ឋកថា

បទថា សុមនា រាជកុមារី គឺជាព្រះរាជធីតានៃព្រះបាទបសេនទិកោសល មានព្រះនាមថា ***សុមនា ។*** *ដែលបាននាមដូច្នោះ*

ព្រោះព្រះរាជធីតាទ្រង់បានធ្វើនូវមហាសក្ការៈ ហើយទ្រង់តាំងសេចក្តីប្រាថ្នាទុកមក ។

សេចក្តីពិស្តារ មានតាំងអំពីសាសនានៃព្រះសម្មាសម្ពុទ្ធវិបស្សី គឺពួកអ្នកនគរគិតគ្នាថា ពួកយើងបញ្ចប់សង្គ្រាម ហើយពួកយើងគប្បីថ្វាយទានដល់សង្ឃមានព្រះពុទ្ធជាប្រមុខ ។ ដោយអ្នកនគរអាស្រ័យសេនាបតី ហើយធ្វើបុណ្យតាមលំដាប់ ដូច្នេះក្នុងថ្ងៃមុនដំបូងជាវារៈរបស់សេនាបតី ។ ក្នុងថ្ងៃនោះ សេនាបតីត្រៀមមហាទាន ជាក់មនុស្សយោមការពារជុំវិញដោយបញ្ជាថា ថ្ងៃនេះ ពួកអ្នកចូរយោមដោយប្រុងប្រយ័ត្ន គឺកុំឱ្យអ្នកណា ៗមកថ្វាយភិក្ខាឡើយ ។

ក្នុងថ្ងៃនោះ មានភរិយាលោកសេដ្ឋីម្នាក់អង្គុយយំផងនិយាយទៅរកធីតារបស់ខ្លួនផងថា កូនស្រីម្តាយអើយ ប្រសិនបើបិតារបស់កូននៅរស់វានមានជីវិតនោះ គឺក្នុងថ្ងៃនេះ ម្តាយនឹងនិមន្តព្រះទសពលឆាន់ជាគ្រាដំបូង ។ កូនស្រីនិយាយនឹងមាតាថា បពិត្រម៉ែ សូមអ្នកម៉ែកុំភ័យព្រួយអ្វីឡើយ កូននឹងធ្វើដោយឧបាយវិធីដែលអាចឱ្យព្រះសង្ឃ មានព្រះពុទ្ធបរមគ្រូជាប្រមុខ ឆាន់នូវភិក្ខារបស់យើងជាគ្រាដំបូង ។ ភ្លាមនោះធីតានៃលោកសេដ្ឋីបាន

ចាត់ចែងចង្ក្រានដែលមិនមានទឹក គឺនិរុទកបាយាសដាក់ចុះនៅក្នុងថាសមាស ដែលថាសមាសនោះមានតម្លៃ ១ សែន រហូតពេញថាស ហើយទើបដាក់ទឹកដោះគោ ទឹកឃ្មុំ និងស្ករក្រួសជាដើម លាយចូលទើបយកថាសមួយទៀតមកគ្រប រួចហើយយកភួងផ្កាម្ទិះមករៀបចំដាក់គ្របពីលើភាជន:នោះ ឱ្យដូចជាភាជន:ផ្កាម្ទិះដូច្នោះឯង ។

លុះដល់ភត្តកាល ព្រះដ៏មានព្រះភាគស្តេចយាង ព្រមដោយព្រះភិក្ខុសង្ឃ ចូលទៅកាន់ភូមិសំដៅទៅផ្ទះសេនាបតី ។ សេដ្ឋីធីតា នាងនាំយកភាជន:មាសដាក់ភិក្ខា គ្របដោយផ្កាម្ទិះ មានពួកនាងទាសីហែហមចេញអំពីផ្ទះស្អាត់ ផ្លូវព្រះដ៏មានព្រះភាគ ។ នៅក្នុងរវាងផ្លូវពួកអ្នកយាមរបស់សេនាបតីពោលថា នែនាង ! កុំទៅផ្លូវនេះ ។ **ធម្មតាអ្នកមានបុណ្យច្រើន រមែងមានពាក្យសម្តីត្រូវចិត្តអ្នកស្តាប់** នាងពោលទៅកអ្នកយាមទាំងឡាយ ដែលចេះតែហាមហើយ ហាមទៀតថា **លោកបង លោកពូ លោកអ៊ំ** ព្រោះហេតុអ្វី បានជាមិនឱ្យពួកនាងខ្ញុំចូលទៅ ? ពួកអ្នកយាមពោលថា អើនាង! លោកសេនាបតីចាត់ពួកយើងឱ្យយាមរក្សាការណ៍ដោយបង្គាប់ថា កុំឱ្យអ្នកណា ៗនាំយកអាហារភោជនចូល

ទៅជាជាច់ខាត ។ នាងពោលថា ក៏ពួកលោកឃើញភោជន ក្នុងដៃរបស់ខ្ញុំឬ ? ពួកអ្នកយាមពោលថា ឃើញតែភួងផ្កា ។ នាងសួរថា លោកសេនាបតី មិនឱ្យធ្វើសូម្បីតែការបូជាដោយភួងផ្កាឬ ? ពួកអ្នកយាមពោលថា លោកសេនាបតីអត់ហាមទេ ។ នាងពោលថា បើអ៊ីចឹង សូមពួកលោកបើកផ្លូវទៅ ។

បានឱកាសហើយ នាងក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ទទួលនូវភួងផ្កាម៉ិះនេះ ព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ទតព្រះនេត្រទៅរកអ្នកបម្រើសេនាបតីម្នាក់ហើយ ត្រាស់ឱ្យទទួលភួងផ្កាម៉ិះទុកតាមព្រះអង្គទៅ ។ នាងថ្វាយបង្គំព្រះបរមសាស្តាហើយ នាងតាំងសេចក្តីប្រាថ្នាថា កាលដែលខ្ញុំម្ចាស់កើតក្នុងភពតូចភពធំតទៅ សូមកុំឱ្យខ្ញុំម្ចាស់មានជីវិតរស់នៅដោយសេចក្តីតក់ស្លុតឡើយ សូមឱ្យបានជាទីស្រឡាញ់ដូចភួងផ្កាម៉ិះនេះ និងសូមឱ្យមានឈ្មោះថា **សុមនា** រហូត ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា នាងចូរមានសេចក្តីសុខចុះ ។ សេដ្ឋីធីតាថ្វាយបង្គំហើយធ្វើប្រទក្សិណព្រះដ៏មានព្រះភាគ ក្រាបទូលលាត្រឡប់ទៅផ្ទះវិញ ។

ព្រះដ៏មានព្រះភាគ ស្តេចយាងដល់ផ្ទះសេនាបតីទ្រង់គង់

ប្រថាប់លើអាសនៈដែលគេក្រាលថ្វាយ សេនាបតីកាន់យកបបរ
យាគូបង្អែនចូលទៅថ្វាយព្រះបរមសាស្តាទ្រង់យកព្រះហស្តបិទ
បាត្រ ។ សេនាបតីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំង
ឡាយ គង់រៀបរយហើយ ព្រះអង្គ ។ ព្រះដ៏មានព្រះភាគត្រាស់
ថា តថាគតបានបិណ្ឌបាតក្នុងវាងផ្លូវហើយ ។ សេនាបតីលើកួង
ផ្ទាម្ខិះចេញបានឃើញបិណ្ឌបាត មធុបាយាសគ្រប់ល្មមដល់ភិក្ខុ
ទាំងឡាយ ដួសថ្វាយតាំងពីព្រះដ៏មានព្រះភាគទៅ រីឯសេនាបតី
បានថ្វាយនូវទេយ្យធម៌របស់ខ្លួន ។ ព្រះបរមសាស្តាសោយស្រេច
ហើយទ្រង់ត្រាស់សម្តែងនូវមង្គលកថា រួចស្តេចយាងត្រឡប់
ទៅវិញ ។

សេនាបតីសួរថា ស្រីដែលថ្វាយបិណ្ឌបាត ជាអ្នកណា ?
កូនស្រីលោកសេដ្ឋីធនញ្ជោស ។ សេនាបតីគិតថា ស្ត្រីដែល
មានបញ្ញា កាលដែលមកនៅក្នុងផ្ទះរបស់យើងគឺថា សគ្គសម្បត្តិ
របស់បុរសមិនមែនរកបានដោយក្រទេ គិតហើយ ទើបចាត់ចែង
នាំនាងបានមកតាំងទុកក្នុងតំណែងជាប្រមុខ ។

សេដ្ឋីធីតា បានមកនៅផ្ទះសេនាបតីហើយ ក៏ចាប់ផ្តើម
ចំណាយទ្រព្យក្នុងផ្ទះរបស់មាតា និង ក្នុងផ្ទះរបស់សេនាបតីថ្វាយ

ទានដល់ព្រះសម្មាសម្ពុទ្ធបំពេញបុណ្យរហូតអស់អាយុ ។ កាលដែលនាងចុតិអំពីមនុស្សបានទៅ បដិសន្ធិក្នុងទេវលោកកាមាវចរសួគ៌ ។ ក្នុងខណៈដែលនាងកើតនោះឯង មានភ្លៀងផ្កាម្ទិះទូទៅពេញទេវលោកត្រឹមក្បាលជង្គង់ ។ ពួកទេវតាទាំងឡាយគិតគ្នាថា ទេពធីតានេះកាន់យកឈ្មោះរបស់ខ្លួនដោយខ្លួនឯងមកទើបតាំងនាមទេពធីតាថា សុមនា ។ សុមនាទេពធីតាចុតិបដិសន្ធិក្នុងទេវលោកនិងមនុស្សលោករហូត ៨៩ កប្ប ក្នុងទីដែលនាងកើតហើយនោះ ។ ភ្លៀងផ្កាម្ទិះក៏ធ្លាក់មកជានិច្ច ទើបមានឈ្មោះថា **សុមនា**ដូចដើម ។ កាលដែលនាងមកបដិសន្ធិក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីនៃព្រះបាទកោសលក្នុងថ្ងៃនោះឯង កុមារិកា ៥០០ នាក់ក៏បដិសន្ធិក្នុងត្រកូលនោះ ។ ហើយប្រសូតចាកគភ៌ក្នុងថ្ងៃតែមួយជាមួយគ្នាទាំងអស់ ។ ក្នុងខណៈព្រះរាជធីតាប្រសូតនោះឯង ភ្លៀងផ្កាម្ទិះធ្លាក់ចុះប្រមាណត្រឹមជង្គង់ ។

ព្រះរាជា ទតព្រះនេត្រឃើញព្រះធីតាទ្រង់សប្បាយ ព្រះហឫទ័យយ៉ាងក្រៃលែង ដោយព្រះរាជាទ្រង់ជ្រាបថាព្រះរាជធីតានេះ ជាអ្នកមានបុណ្យបានសាងទុកមកហើយ ធីតារបស់យើង

កាន់យកឈ្មោះរបស់ខ្លួនមកដោយខ្លួនឯង ទើបទ្រង់ព្រះរាជទានព្រះនាមថា **សុមនា** ដល់ព្រះរាជធីតារបស់ព្រះអង្គ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា ធីតារបស់យើងប្រាកដជាមិនកើតមកម្នាក់ឯងនោះឡើយ ទ្រង់ឱ្យស្វែងរកឃើញមានទារិកា ៥០០ នាក់កើតក្នុងព្រះនគរ ទើបទ្រង់គ្រាស់ឱ្យចិញ្ចឹមទុកទាំងអស់ ហើយត្រូវនាំមកបង្ហាញដល់ធីតារបស់យើងមួយខែម្តង ។ ។

នៅពេលដែលព្រះរាជធីតា មានទួវព្រះជន្មវស្សាបាន ៧ ខួប លោកសេដ្ឋីអនាថបិណ្ឌិក បានសាងព្រះជេតពន មហាវិហារហើយស្រេច ។ កាលដែលបានបញ្ជូនទូតទៅ ក្រាបទូលដល់ព្រះបរមសាស្តាហើយ ព្រះលោកនាថជាព្រះសុគតសាស្តា មានព្រះភិក្ខុសង្ឃជាបរិវារស្តេចយាងចូលកាន់ក្រុងសាវត្ថី ។

អនាថបិណ្ឌិកសេដ្ឋី បានចូលទៅក្រាបទូលដល់ព្រះរាជាថា បពិត្រព្រះមហារាជដ៏ចម្រើន ព្រះពុទ្ធដំណើរស្តេចយាងមកកាន់ទីនេះ ជាមង្គលទាំងដល់ខ្ញុំព្រះអង្គ ទាំងដល់ព្រះអង្គជាព្រះរាជា សូមព្រះអង្គទ្រង់ប្រោសឱ្យព្រះនាងសុមនារាជកុមារី ព្រមដោយកុមារដទៃជាបរិវារ ៥០០ នាក់ កាន់កូមទីកនិងផ្កាកម្រង គ្រឿងក្រអូបជាដើម ទទួលដំណើរព្រះទសពល ព្រះអង្គ ។ ព្រះរាជា

ទ្រង់ត្រាស់ថា ល្អហើយ លោកសេដ្ឋី ហើយព្រះអង្គក៏ទ្រង់ចាត់ចែងដូច្នោះ ។ ព្រះរាជធីតា ក៏បានចូលគាល់ព្រះបរមសាស្តា សម្មាសម្ពុទ្ធ តាមពាក្យដែលព្រះបិតា ទ្រង់ណែនាំបានប្រថាប់នៅក្នុងទីដ៏សមគួរមួយ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងព្រះធម៌ទេសនា ញុំាងព្រះធីតានិងកុមារីទាំង ៥០០ នាក់ ឱ្យតាំងនៅក្នុងសោតាបត្តិផល ។ ក្នុងវារៈនោះមានគ្រហស្ថ បានសម្រេចសោតាបត្តិផល ២ ពាន់នាក់ ។

ព្រះនាងសុមនារាជកុមារី ចូលគាល់ព្រះដ៏មានព្រះភាគ ព្រោះហេតុអ្វី ? ព្រោះមានបំណងទូលសួរបញ្ហា ។ បានស្តាប់មកថា ក្នុងសាសនានៃព្រះសម្មាសម្ពុទ្ធកស្សបទសពល មានភិក្ខុពីរអង្គជាសម្លាញ់នឹងគ្នា មួយអង្គបំពេញសារាណីយធម៌ (មានការចែកចាយនូវបច្ច័យ ៤ ដែលខ្លួនបានមកដល់បុគ្គលដែលគួរឱ្យជាដើម) ។ ភិក្ខុដែលបំពេញនូវសារាណីយធម៌ ពោលរំលឹកភិក្ខុជាសម្លាញ់ថា អ្នកដ៏មានអាយុ ឈ្មោះថា ទាន ដែលមិនឱ្យផលរមែងមិនមានឡើយ កាលឱ្យរបស់ខ្លួនដល់អ្នកដទៃហើយសឹមបរិភោគទើបគួរ ។ ភិក្ខុដែលបំពេញនូវភត្តគ្គវត្តតបថា អ្នកដ៏មានអាយុ អ្នកមិនដឹងទេ ឬការឱ្យទេយ្យធម៌ធ្លាក់ចុះ រមែងមិនគួរ

បុគ្គលដែលកាន់យកត្រឹមតែអាហារញ៉ាំងជីវិតរបស់ខ្លួន ឱ្យប្រព្រឹត្តទៅបានប៉ុណ្ណោះទើបគួរ ។ ទាំងពីរអង្គមិនអាចញ៉ាំងគ្នាឱ្យនៅក្នុងឱវាទរបស់ខ្លួនបានក៏បំពេញវត្តតែរៀង ខ្លួនរហូតដល់ចុតិចាកភពនោះបដិសន្ធិក្នុងទេវលោក ។ ភិក្ខុដែលបំពេញនូវសាវណីយធម៌ គ្របសង្កត់នូវភិក្ខុដែលមិនបានឱ្យទានដោយធម៌ ៥ យ៉ាង ក្នុងទេវលោកវិលវល់ក្នុងទេវតា និងមនុស្សអស់មួយចន្លោះព្រះពុទ្ធ ទើបកើតក្នុងក្រុងសាវត្ថី ។

អង្គដែលបពេញនូវសាវណីយធម៌បដិសន្ធិក្នុងគភ៌ ព្រះអគ្គមហេសីនៃព្រះបាទកោសល មួយអង្គទៀត បដិសន្ធិក្នុងផ្ទៃនៃស្រីបម្រើរបស់ព្រះអគ្គមហេសីនោះ ហើយប្រសូត ក្នុងថ្ងៃជាមួយគ្នា ។ ក្នុងថ្ងៃដាក់ឈ្មោះ ពោលគឺថ្វាយព្រះនាមដល់ព្រះរាជបុត្រ ព្រះមាតាស្រង់ទឹកឱ្យបុត្រហើយដាក់បុត្រឱ្យផ្ទំក្នុងបន្ទប់ប្រកបដោយសិរី ជាមួយនឹងបុត្ររបស់ស្ត្រីអ្នកបម្រើព្រះអគ្គមហេសីនោះឯង ។ ដោយវល់នាំគ្នាចាត់ចែងកិច្ចការខាងក្រៅបន្ទប់ ព្រះរាជបុត្របើកព្រះនេត្រឡើង បានឃើញស្នូតឆ្នូតដ៏ធំផង ទីកន្លែងផ្ទំប្រកបដោយសិរីដែលគេចាត់ចែងយ៉ាងល្អផង ព្រមទាំងព្រះរាជនិវេសន៍ ប្រដាប់ដោយគ្រឿងអលង្ការផង ទើបដឹងខ្លួនព្រះអង្គថា

យើងកើតក្នុងព្រះរាជត្រកូល ។ ព្រះរាជបុត្រនឹកថា យើងធ្វើកម្ម
អ្វីហ្ន៎ ទើបបានកើតនៅក្នុងទីនេះដូច្នេះ ក៏រលឹកបានដោយផលនៃ
ការបំពេញនូវសារាណីយធម៌ ។ ព្រះរាជបុត្រគិតទៀតថា សម្លាញ់
របស់យើងកើតក្នុងទីណាហ្ន៎ ក៏បានឃើញនៅក្នុងទីដែលទាបជាង
ខ្លួននោះឯង ទាំងដែលបានជ្រាបថា នេះព្រោះមកអំពីមិនជឿពាក្យ
របស់យើង ទើបពោលថា សម្លាញ់អ្នកមិនជឿពាក្យរបស់យើង ។
ពេលនោះទាវកជាសម្លាញ់ ក៏តបមកវិញភ្លាមថា បើអ៊ីចឹង តើវា
យ៉ាងម៉េច ? ព្រះរាជបុត្រក៏បានឆ្លើយបញ្ជាក់ប្រាប់ទៅថា អ្នក
មើលសម្បត្តិរបស់យើងមើល៍ យើងដេកនៅលើទីដ៏មានសិរីនៅ
ក្រោមស្វេតឆត្រ ចំណែកអ្នកវិញដេកនៅនឹងត្រែទាបលើកម្រាល
រឹង ៗ ។ ទាវកជាសម្លាញ់ពោលថា អ្នកឯងកើតមាននូវមានះ
ព្រោះអាស្រ័យរបស់ហ្នឹង ឬរបស់ហ្នឹង គឺគេយកសំពត់មកពុំព័ទ្ធ
នឹងបន្ទះឫស្សី គ្រាន់តែជាបបរីធាតុប៉ុណ្ណោះ មិនមែនទេឬ ។

ព្រះរាជធីតាសុមនា បានស្តាប់ពាក្យរបស់អ្នកទាំងពីរនោះ
ហើយ ទើបគិតថា នៅជិត ៗប្អូនប្រុសទាំងពីររបស់យើងមិនមាន
អ្នកណាទ្បើយ ក៏បានដើរចូលទៅអែបនឹងមាត់ទ្វារ បានឮពាក្យ
ថា ធាតុ ដូច្នេះ ក៏គិតថា ពាក្យថា ធាតុ នេះ មិនមាននៅខាង

ក្រៅអំពីព្រះពុទ្ធសាសនាឡើយ ឬនប្រុសរបស់យើងប្រាកដជាសមណាទេវបុត្រ ។ ព្រះរាជធីតាបានគិតតទៅទៀតថា បើយើងនឹងក្រាបទូលដល់ព្រះមាតាបិតាថា ទារកទាំងពីរនិយាយគ្នាយ៉ាងនេះព្រះបិតាជាដើម មុខតែនឹងឱ្យគេនាំយកទៅចោល ឬ យ៉ាងម៉េច ៗមិនខាន ដោយយល់ថា អ្នកទាំងពីរគឺជាអមនុស្សដូច្នេះ យើងមិនប្រាប់ហេតុការណ៍នេះដល់អ្នកណាឡើយ យើងនឹងទូលសួរ ចំពោះព្រះទសពល ដែលទ្រង់ជាព្រះបិតាវិដ្ឋរបស់យើង ព្រះអង្គនឹងត្រាស់ប្រាប់សេចក្តីនេះឱ្យយើងបានដឹងច្បាស់ ។

សោយព្រះក្រយាពេលព្រឹកស្រេចហើយ ព្រះរាជធីតាក៏ចូលទៅគាល់ព្រះរាជាជាព្រះបិតា ហើយទូលសូមការអនុញ្ញាតដើម្បីទៅគាល់ព្រះដ៏មានព្រះភាគ ។ ព្រះរាជាត្រាស់បង្គាប់ឱ្យចាត់រថ ៥០០ គ្រឿង ។ សូមបញ្ជាក់ថា នៅក្នុងជម្ពូទ្វីបនេះ មានតែកុមារី ៣ នាក់ប៉ុណ្ណោះ ដែលបានរថ ៥០០ គ្រឿងអំពីសម្លាក់បិតារបស់ខ្លួន គឺព្រះនាងចន្ទី ជាព្រះរាជធីតារបស់ព្រះបាទពិម្ពិសារ ១ នាងវិសាខា ជាធីតារបស់ធនញ្ជ័យសេដ្ឋី ១ និងព្រះនាងសុមនាកាន់យកគ្រឿងក្រអូប និងផ្កាឈើ ហើយបានឈរនៅក្នុងរថរបស់ខ្លួនដែលមានរថ ៥០០ ទៀត ជាបរិវារធ្វើដំណើរចូលគាល់ព្រះ

បរមសាស្តាដោយគិតថា យើងនឹងទូលសួរព្រះអង្គនូវបញ្ហានេះ ។

(សេចក្តីតទៅ មាននៅក្នុងព្រះសូត្រនេះខាងដើម ស្រាប់ហើយ) ។

ក្នុងបទជាដើមថា **មានុស្សកេនគប្បីជ្រាបវិនិច្ឆ័យដូចនេះ** អ្នកជាប្រធានដោយហេតុ ៥ យ៉ាងគឺ ៖

ដោយអាយុ ដូចជាព្រះមហាកស្សបត្ថេរៈ ព្រះពាកុលត្ថេរៈ និងព្រះអានន្ទត្ថេរៈ ។

ដោយវណ្ណៈ ដូចជាព្រះមហាគតិម្ពអភយត្ថេរៈ និងអាមាត្យអ្នកជាភណ្ឌាគារិកអ្នករក្សាឃ្លាំង ។

ដោយសុខ ដូចជាព្រះរដ្ឋបាលកុលបុត្រ សោភណសេដ្ឋីបុត្រ ។

ដោយយស ទាំងសេចក្តីជាធំ ដូចជាព្រះបាទធម្មាសោកៈ ភជ ។

បទថា **យាចិតោវ ពហុំ** សេចក្តីថា ជាប្រធានដោយហេតុនេះថា ជាអ្នកដែលគេអង្វរ ទើបប្រើប្រាស់ចីវរជាដើម ជាចំណែកច្រើនដូចព្រះពាក្កុលត្ថេរៈ ព្រះសីវលីត្ថេរៈ និងព្រះអានន្ទត្ថេរៈជាដើម ។

បទថា យថិនំ វិមុត្តិយា វិមុត្តំ សេចក្តីថា ដោយហេតុផ្សេង ៗគ្នាយ៉ាងណា ដែលនឹងគប្បីពោលប្រារព្ធវិមុត្តិរបស់បុគ្គលមួយនាក់និងវិមុត្តិរបស់បុគ្គលមួយនាក់ តថាគតមិនពោលហេតុដែលផ្សេង ៗគ្នាទេ ។ ពិតមែន ក្មេងអាយុ ៧ ខួបក្តី ព្រះថេរៈអាយុ ១០០ ក្តី មិនថា និងជាភិក្ខុ ឬភិក្ខុនី ឧបាសក ឧបាសិកា ទេវតា មារ ព្រហ្ម ក៏សម្រេចវិមុត្តិក្នុងលោកុត្តរមគ្គមកហូតហើយ ឈ្មោះថា សេចក្តីផ្សេងគ្នាមិនមានឡើយ ។

ចំពោះពាក្យថា ឧស្សុនសម្បន្នោ នៅក្នុងព្រះគាថាខាងចុង ព្រះអដ្ឋកថាប្រាប់ថា គឺព្រះសោតាបន្ន ។

រឿងទេពធីតា ២៥ រូប

(អន្លក់ ១ ក្តាប់របស់ស្ត្រីមានសទ្ធាអាចជូរយកសម្បត្តិសួគ៌បាន)

សម័យមួយ ព្រះមហាមោគ្គល្លាន បាននិមន្តទៅឋានត្រៃត្រឹង្សទេវតាលោក បានឃើញវិមានប្រាសាទនិងរូបឆោមពន្លឺរស្មីរបស់ទេពធីតា ២៥ រូប ដែលមានទីលំនៅជិត ៗគ្នា ក៏ចូលទៅក្នុងទេវសង្កាត់នោះ ពួកទេពធីតាទាំង ២៥ រូបបានឃើញព្រះមហា-

មោគ្គល្លានហើយ ក៏នាំគ្នាទៅថ្វាយបង្គំ រួចស្ថិតនៅក្នុងទីសមគួរ ទើបព្រះមហាមោគ្គល្លានសួរថា ម្នាលទេពធីតាទាំងឡាយ នាងបរិបូណ៌ដោយភោគៈគឺវត្ថុទិព្វទាំង ១០ យ៉ាង តើនាងបានធ្វើបុណ្យអ្វីក្នុងជាតិមុន ?

-ទេពធីតាទី ១ ឆ្លើយថា យើងខ្ញុំទាំងអស់គ្នា បានឃើញភិក្ខុនិមន្តទៅបិណ្ឌបាតក្នុងភូមិ មានសេចក្តីជ្រះថ្លាបានប្រគេនស្ករអំពៅបន្តិច ។

-ទេពធីតាទី ២ មានចិត្តជ្រះថ្លា ប្រគេនផ្លែទម្លាប់មួយ ។

-ទេពធីតាទី៣មានចិត្តជ្រះថ្លាប្រគេនអំពៅ ១ កំណាត់ ។

-ទេពធីតាទី៤មានចិត្តជ្រះថ្លា ប្រគេនផ្លែត្រសក់ ១ ។

-ទេពធីតាទី៥មានចិត្តជ្រះថ្លា ប្រគេនផ្លែល្មៅ ១ ។

-ទេពធីតាទី៦មានចិត្តជ្រះថ្លាប្រគេនផ្លែត្រសក់ស្រេ ១ ។

-ទេពធីតាទី៧ មានចិត្តជ្រះថ្លា ប្រគេនផ្លែមាក់ប្រាំង ១ ។

-ទេពធីតាទី៨មានចិត្តជ្រះថ្លាប្រគេនចង្រ្កានកំដៅដៃ ១ ។

-ទេពធីតាទី ៩ មានចិត្តជ្រះថ្លាប្រគេនអន្ទក់ ១ក្តាប់ ។

-ទេពធីតាទី ១០ មានចិត្តជ្រះថ្លាបានប្រគេនផ្កា ១ក្តាប់ ។

-ទេពធីតាទី១១ មានចិត្តជ្រះថ្លា បានប្រគេនមើមដំឡូង ១ ដុំ ។

-ទេពធីតាទី ១២ មានចិត្តជ្រះថ្លាប្រគេនស្លឹកស្ពៅ ១ កាប់ ។

-ទេពធីតាទី ១៣ មានចិត្តជ្រះថ្លា ប្រគេនជ្រក់ស្វាយបន្ថិច ។

-ទេពធីតាទី១៤មានចិត្តជ្រះថ្លា ប្រគេនល្ងបុកបន្ថិច ។

-ទេពធីតាទី១៥មានចិត្តជ្រះថ្លាប្រគេនវត្តពន្ធចង្កេះ ១ ។

-ទេពធីតាទី១៦មានចិត្តជ្រះថ្លាប្រគេនយោគបាត្រ ១ ។

-ទេពធីតាទី១៧មានចិត្តជ្រះថ្លាប្រគេនស្លាកបាត្រ ១ ។

-ទេពធីតាទី១៨មានចិត្តជ្រះថ្លា ប្រគេនផ្ទៃតស្លឹក ១ ។

-ទេពធីតាទី១៩មានចិត្តជ្រះថ្លាប្រគេនផ្ទៃកស្លឹកគ្នោត១ ។

-ទេពធីតាទី២០មានចិត្តជ្រះថ្លាប្រគេនផ្ទៃតកន្ទុយក្ងោក ១ ។

-ទេពធីតាទី ២១ មានចិត្តជ្រះថ្លា ប្រគេនឆត្រ១ ។

-ទេពធីតាទី២២ មានចិត្តជ្រះថ្លា ប្រគេនស្បែកជើង ១ សម្រាប់ ។

-ទេពធីតាទី២៣មានសេចក្តីជ្រះថ្លា ប្រគេនទំ ១ ។

-ទេពធីតាទី២៤មានសេចក្តីជ្រះថ្លាប្រគេនត្រប៉ែកបន្តិច ។

-ទេពធីតាទី២៥មានសេចក្តីជ្រះថ្លាប្រគេនក្រៀមមួយ ។

ឯ.ទេពធីតាទាំង ២៥ រូប បានប្រាប់បុព្វកម្មរបស់ខ្លួន ៗ ដូច្នេះហើយ បាននិយាយចំពោះមហាមោគ្គល្លានថា សូមលោកម្ចាស់មើលនូវវិមានរបស់យើងខ្ញុំចុះ យើងខ្ញុំជាស្រីទេពអប្សរមានសម្បុរជាទីប្រាថ្នា មានបរិវារម្នាក់ ១ ពាន់រូប ចោមរោមបម្រើ នេះជាផលបុញ្ញកម្មនោះឯង ។

ព្រះមហាមោគ្គល្លានបានជ្រាបសេចក្តីនេះសព្វគ្រប់ហើយ ក៏និមន្តបាត់អំពីទីនោះទៅ ។

ឥណិដ្ឋសូត្រ

នៅក្នុងបិដកលេខ ៤២, ទំព័រ ២០០ ព្រះអង្គទ្រង់ត្រាស់ពី **[ការធ្វើជំនួញ]** ដោយមានសេចក្តីថា ៖

គ្រានោះ ព្រះសារីបុត្រដ៏មានអាយុ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយគង់ក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្រដ៏មានអាយុគង់នៅក្នុងទីសម

គួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដោយពាក្យដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុបច្ច័យដូចម្តេច ដែលនាំឱ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះក្នុងលោកនេះ ដែលខ្ជិនប្រកបទៅហើយ ខាតទុនជាប្រក្រតី, បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឱ្យជំនួញបែបនោះរបស់បុគ្គលពួកខ្លះក្នុងលោកនេះ ដែលខ្ជិនប្រកបទៅហើយ មិនបានចំណេញដូចបំណង, បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឱ្យជំនួញបែបនោះរបស់បុគ្គលពួកខ្លះក្នុងលោកនេះដែលខ្ជិនប្រកបទៅហើយ មានចំណេញដូចបំណង បពិត្រព្រះអង្គដ៏ចម្រើន ចុះហេតុដូចម្តេច បច្ច័យដូចម្តេច ដែលនាំឱ្យជំនួញបែបនោះរបស់បុគ្គលពួកខ្លះក្នុងលោកនេះ ដែលខ្ជិនប្រកបទៅហើយ បានចំណេញលើសបំណង ។

ព្រះដ៏មានព្រះភាគត្រាស់តបថា ម្នាលសារីបុត្រ បុគ្គលពួកខ្លះក្នុងលោកនេះ ចូលទៅរកសមណ ឬព្រាហ្មណ៍ ហើយបវារណាថា បពិត្រលោកដ៏ចម្រើន លោកចូរប្រាប់(សុំ)ដោយបច្ច័យចុះបុគ្គលនោះ បវារណាដោយបច្ច័យណាមែន តែមិនឱ្យបច្ច័យនោះទេ

បុគ្គលនោះបើច្យុតអំពីលោកនេះទៅមកកើតក្នុងលោកនេះបុគ្គលនោះប្រកបការជំនួញណា ជំនួញរបស់បុគ្គលនោះ រមែងខាតទុនទៅជាប្រក្រតី ។

-ម្នាលសារីបុត្រ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះចូលទៅរកសមណៈឬព្រាហ្មណ៍ហើយបវារណាថា បពិត្រលោកដ៏ម្រើន លោកចូរប្រាប់ដោយបច្ចយចុះ បុគ្គលនោះ បវារណាដោយបច្ចយណាមែន តែឱ្យបច្ចយនោះមិនតាមបំណងទេ បុគ្គលនោះបើច្យុតអំពីលោកនេះទៅ បានមកកើតក្នុងលោកនេះ បុគ្គលនោះប្រកបការជំនួញណា ជំនួញរបស់បុគ្គលនោះ មិនមានចំណេញដូចបំណង ។

-ម្នាលសារីបុត្រ មួយទៀត បុគ្គលពួកខ្លះក្នុងលោកនេះចូលទៅរកសមណៈឬព្រាហ្មណ៍ហើយបវារណាថា បពិត្រលោកដ៏ម្រើន លោកចូរប្រាប់ដោយបច្ចយចុះ បុគ្គលនោះបវារណាដោយបច្ចយណា ក៏ឱ្យបច្ចយនោះតាមបំណងមែន បុគ្គលនោះបើច្យុតអំពីលោកនេះទៅ បានមកកើតក្នុងលោកនេះ បុគ្គលនោះប្រកបការជំនួញណាជំនួញរបស់បុគ្គលនោះ រមែងមានចំណេ-

ញដូចបំណង ។

- ម្នាលសារីបុត្រ មួយទៀតបុគ្គលពួកខ្លះក្នុងលោកនេះ ចូលទៅរកសមណ ឬព្រាហ្មណ៍ ហើយបវារណាថា បពិត្រលោកដ៏ម្រើន លោកចូរជ្រាប់ដោយបច្ច័យចុះ បុគ្គលនោះបវារណាដោយបច្ច័យណា ក៏ឱ្យបច្ច័យនោះលើសបវារណា បុគ្គលនោះបើច្យុតអំពីលោកនេះទៅ បានមកកើតក្នុងលោកនេះ បុគ្គលនោះប្រកបការជំនួញណា ជំនួញរបស់បុគ្គលនោះ រមែងមានចំណេញលើសបំណង ។

ម្នាលសារីបុត្រ នេះជាហេតុ នេះជាបច្ច័យដែលនាំឱ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ មានតែខាតទុនជាប្រក្រតី ១,

ម្នាលសារីបុត្រ មួយទៀត នេះជាហេតុ នេះជាបច្ច័យដែលនាំឱ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ មិនមានចំណេញដូចបំណង ១,

ម្នាលសារីបុត្រ មួយទៀត នេះជាហេតុ នេះជាបច្ច័យដែលនាំឱ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះក្នុងលោកនេះ ដែលខ្លួន

ប្រកបទៅហើយ បានចំណេញដូចបំណង ១,

ម្នាលសារីបុត្រ មួយទៀត នេះជាហេតុ នេះជាបច្ច័យដែលនាំឱ្យជំនួញបែបនោះ របស់បុគ្គលពួកខ្លះក្នុងលោកនេះ ដែលខ្លួនប្រកបទៅហើយ មានចំណេញលើសបំណង ១ ។

អដ្ឋកថា

បទថា តាទិសាវ សេចក្តីថា ការធ្វើជំនួញដូចគ្នានោះគឺស្រដៀងគ្នានោះ ។

បទថា ឆេកតាមិនី ហោតិ គឺខាតទុន ។ អធិប្បាយថា ផលកំរៃដែលខ្លួនប្រាថ្នាត្រូវសាបសូន្យអស់ ។

បទថា ន យថាធិប្បាយា ហោតិ សេចក្តីថា បានផលកំរៃដែលខ្លួនប្រាថ្នា មិនបានតាមបំណងរបស់ខ្លួន ។

បទថា បរាធិប្បាយា ហោតិ សេចក្តីថា បានផលលើសគឺលើសជាងដែលខ្លួនប្រាថ្នា ។ ក្នុងបទថា សមណំ វា ព្រាហ្មណំ វា នេះគប្បីជ្រាបថា ជាសមណៈ ឬព្រាហ្មណ៍ ព្រោះមានបាបស្ងប់ហើយ មានបាបដែលអណ្តែតចោលហើយ ។

បទថា វត្ថ ភន្តេ បច្ចយេន សេចក្តីថា វមែង៥បវារណា គឺនិមន្តយ៉ាង៥នេះថា បពិត្រលោកដ៏ចម្រើន លោកគប្បីសូមបច្ច័យ ៤ យ៉ាង៥ មានចីវរជាដើមបាន ។

បទថា យេនបកាវេតិ សេចក្តីថា គេវមែង៥បវារណា កំណត់ទុកដោយបច្ច័យណា ។

បទថា តំ ន ទេតិ សេចក្តីថា គេមិនថ្វាយបច្ច័យនោះ គ្រប់ប្រការ ។

បទថា តំនយថាធិប្បាយំ ទេតិ សេចក្តីថា គេវមែង៥មិនអាចនិង៥ថ្វាយបច្ច័យនោះ តាមដែលសមណៈ ឬព្រាហ្មណ៍នោះប្រាថ្នា គឺថ្វាយតិចចុះ ។

បទថា យថាធិប្បាយំ ទេតិ សេចក្តីថា សមណៈឬព្រាហ្មណ៍នោះវមែង៥ប្រាថ្នាបច្ច័យប៉ុនណា គេក៏ថ្វាយបច្ច័យប៉ុណ្ណោះ ។

បទថា បរាធិប្បាយំ ទេតិ សេចក្តីថា គេបវារណាបច្ច័យទុកតិច តែថ្វាយច្រើនជាង ។

រឿងសេដ្ឋីឈ្មោះពិឡាលបទកៈ

ព្រះសាស្តាកាលគង់ប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះ **ពិឡាលបទកៈ** (សេដ្ឋីជើងឆ្មា) ត្រាស់ព្រះធម្មទេសនានេះថា មាវមញ្ញេថ បុញ្ញស្ស ជាដើម ។

[ឱ្យទានខ្លួនឯងនិងបបួលអ្នកដទៃបានសម្បត្តិ ២ យ៉ាង]

សេចក្តីពិស្តារថា សម័យមួយ អ្នកក្រុងសាវត្ថីនាំគ្នាថ្វាយទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយរួបរួមជាមួយគ្នា ។ នៅថ្ងៃមួយ ព្រះសាស្តា កាលនឹងទ្រង់ធ្វើនូវអានុមោទនា ទើបត្រាស់យ៉ាងនេះថា ៖

- ឧបាសកឧបាសិកាទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ឱ្យទានដោយខ្លួនឯង, តែមិនបបួលអ្នកដទៃ, គេរមែងបានភោគសម្បត្តិ, តែមិនបានបរិវារសម្បត្តិនៅក្នុងទីកន្លែងដែលខ្លួនកើតហើយ ៗទេ,

- បុគ្គលខ្លះទៀត មិនឱ្យទានដោយខ្លួនឯង, បបួលតែអ្នកដទៃ, គេរមែងបានបរិវារសម្បត្តិ, តែមិនបានបរិវារសម្បត្តិនៅក្នុងទីដែលខ្លួនកើតហើយ ៗទេ,

- បុគ្គលខ្លះទៀត មិនឱ្យទានដោយខ្លួនឯងផង បែមទាំងមិន

បបួលអ្នកដទៃទៀត, គេរមែងមិនបានភោគសម្បត្តិមិនបានបរិវារសម្បត្តិក្នុងទីកន្លែងដែលខ្លួនកើតហើយ ។ទេ ហើយជាមនុស្សដើរវើសកាកសំណល់បរិភោគ,

- បុគ្គលខ្លះទៀត ឱ្យទានដោយខ្លួនឯងផង បបួលអ្នកដទៃផង, គេរមែងបានទាំងភោគសម្បត្តិ និងបរិវារសម្បត្តិនៅក្នុងទីកន្លែងដែលខ្លួនកើតហើយ ។ផង ។

[បណ្ឌិតរាយអង្គាសរបស់ធ្វើបុណ្យ]

គ្រានោះ មានបណ្ឌិតបុរសម្នាក់ ស្តាប់ធម៌ទេសនានោះហើយ គិតថា ឱ ! ហេតុនេះអស្ចារ្យណាស់, ឥឡូវនេះយើងនឹងធ្វើកម្មដែលប្រព្រឹត្តទៅដើម្បីបានសម្បត្តិទាំងពីរ, ទើបក្រាបទូលព្រះសាស្តាក្នុងវេលាដែលក្រោកទៅថា បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃស្អែកនេះ សូមព្រះអង្គទទួកនូវភិក្ខាបរស់ពួកខ្ញុំព្រះអង្គ ។

ព្រះសាស្តា. ក៏លោកមានសេចក្តីត្រូវការដោយភិក្ខុប៉ុន្មានអង្គ ?

បុរស. ភិក្ខុទាំងអស់ ព្រះអង្គ ។

ព្រះសាស្តាទ្រង់ទទួលហើយ ។ សូម្បីគេក៏បានទៅកាន់

ស្រុក ដើរស្រែកប្រកាសថា បពិត្រពុកម៉ែទាំងឡាយ ខ្ញុំបាននិមន្ត
ព្រះភិក្ខុសង្ឃដែលមានព្រះពុទ្ធជាប្រធាន ដើម្បីឆាន់ភត្តាហារនៅ
ក្នុងថ្ងៃស្អែកនេះ, អ្នកណាអាចថ្វាយទានដល់ភិក្ខុទាំងឡាយ មាន
ប្រមាណប៉ុណ្ណា,អ្នកនោះចូរឱ្យវត្ថុផ្សេង ៗមានអង្ករជាដើមដើម្បី
ប្រយោជន៍ដល់អាហារមានយាគូជាដើម ដើម្បីភិក្ខុទាំងឡាយមាន
ប្រមានប៉ុណ្ណោះ, ពួកយើងនឹងដាំនៅក្នុងទីកន្លែងតែមួយ ហើយ
ថ្វាយទានជាមួយ ។

[ហេតុដែលសេដ្ឋីមានឈ្មោះថាពិឡាលបទកៈ]

ភ្លាមនោះ មានសេដ្ឋីម្នាក់ ឃើញបុរសនោះមកដល់ទ្វារផ្ទះ
របស់ខ្លួនហើយក៏មានសេចក្តីក្រោធឡើងថា អ្នកនេះមិននិមន្តព្រះ
ភិក្ខុសង្ឃឱ្យល្មមកម្លាំង(ទ្រព្យ)របស់ខ្លួនទេ បែរជាត្រូវមកដើរ
បបួលអ្នកស្រុកទាំងអស់ថែមទៀត, ទើបប្រាប់ថា ឯងចូរនាំយក
ភាជនៈដែលកាន់មក ដូច្នេះហើយ យកម្រាមដៃ ៣ ម្រាមចាប់
បានឱ្យអង្ករបន្តិច, សណ្តែកខៀវ សណ្តែកពាជមាសកដូចគ្នា ។
តាំងពីនោះមកសេដ្ឋីនោះទើបមានឈ្មោះថា **ពិឡាលបទកសេដ្ឋី** ។
សូម្បីកាលនឹងឱ្យភេសជ្ជៈមានទឹកដោះនិងទឹកអំពៅជាដើមក៏ផ្សៀង

មាត់ចាក់ចូរមិនបន្តិចធ្វើឱ្យមាត់ដបនោះជាប់ជាមួយ ឱ្យកេសជ្ជៈមានទឹកដោះថ្លា និងទឹកអំពៅជាដើមហូរចុះមួយដំណក់ ៗ បានឱ្យបន្តិចបន្តួចប៉ុណ្ណោះ ។

ឧបាសកធ្វើវត្ថុទានដែលបុគ្គលឱ្យដោយរួមគាតែបានកាន់យកវត្ថុរបស់ដែលសេដ្ឋីនេះឱ្យទុកមួយចំណែក ។

(សេដ្ឋីឱ្យមនុស្សទៅមើលការធ្វើរបស់បុរសអ្នកវាយអង្ក្រោស)

សេដ្ឋីនោះ ឃើញកិរិយារបស់ឧបាសកនោះហើយគិតថា ហេតុអ្វីហ្ន៎បុរសនេះទើបទទួលយករបស់យើង ហើយទុកផ្សេងអ៊ីចឹង ? ទើបបញ្ជូនចូពុបដ្ឋាកម្នាក់ទៅខាងក្រោយគេ ដោយបញ្ជាថា ឯងចូរទៅ, ចូរដឹងនូវកម្មដែលបុរសនេះធ្វើ ។ ឧបាសកទៅហើយពោលថា សូមផលធំ ចូរមានដល់លោកសេដ្ឋី ។ ដូច្នេះហើយបានដាក់អង្ករ ១-២ គ្រាប់ ដើម្បីប្រយោជន៍ដល់យាគូ ភត្តនិងនំ,ដាក់សណ្តែកខៀវ សណ្តែកពាជមាសខ្លះបន្តត់ដំណក់ប្រេងនិងទឹកអំពៅបន្តិចខ្លះ ចុះក្នុងភាជនៈគ្រប់ ៗភាជនៈ ។ ឧបដ្ឋាកទៅប្រាប់ដល់លោកសេដ្ឋីហើយ ។ សេដ្ឋីស្តាប់ពាក្យនោះហើយទើបគិតថា ប្រសិនបើបុរសនោះនឹងពោលទោស យើងនៅក្នុង

កណ្តាលបរិស័ទសោត, ឈ្មួញលើកឈ្មោះ របស់យើងឡើង ប៉ុណ្ណោះ យើងនឹងប្រហារវាឱ្យស្លាប់ ។ ក្នុងថ្ងៃស្អែកឡើង ទើប សៀតកាំបិតទុកនៅក្នុងចន្លោះសំពត់ហើយ បានទៅឈរនៅក្នុង រោងទាន ។

[ឆ្លាតនិយាយធ្វើឱ្យអ្នកគិតអាក្រក់ត្រឡប់ជាទន់ខោរ]

បុរសនោះ ទំនុកបម្រុងព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ហើយក្រាបទូលព្រះមានព្រះភាគជាម្ចាស់ថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបបួលមហាជនថ្វាយទាននេះ ពួកមនុស្សដែល ខ្ញុំព្រះអង្គបបួលហើយក្នុងទីនោះ បានឱ្យអង្ករជាដើមច្រើនខ្លះ តិច ខ្លះតាមកម្លាំងរបស់ខ្លួន, សូមផលដ៏បរិបូណ៌ ចូរមានដល់មហា- ជនពួកនោះទាំងអស់ ។

សេដ្ឋីបានឮពាក្យនោះហើយគិតថា យើងមកតាំងចិត្តថា ឈ្មួញលើកឈ្មោះរបស់យើងថា សេដ្ឋីឈ្មោះនោះកាន់យកអង្ករ ជាដើមដោយចាប់ម្រាមឱ្យ, យើងនឹងសម្លាប់បុរសនេះឱ្យស្លាប់, តែបុរសនេះ ធ្វើទានឱ្យរួមគ្នាទាំងអស់ ហើយពោលថា ទានដែល ជនពួកណាជួសឱ្យដោយនាឡិជាដើមឱ្យក្តី, ទានដែលជនពួកណា កាន់យកដោយចាប់ម្រាមហើយឱ្យក្តី, សូមផលដ៏បរិបូណ៌ចូរមាន

ដល់ជនពួកនោះទាំងអស់, សេដ្ឋីគិតថា បើយើងនឹងមិនឱ្យបុរសសភាពនេះ អត់ទោសឱ្យសោត, អាជ្ញារបស់ទេពជាម្ចាស់នឹងធ្លាក់ចុះលើសីសៈរបស់យើង ។ សេដ្ឋីនោះបានក្រាបចុះទៀប ជើងរបស់ឧបាសកនោះហើយពោលថា នាយ សូមនាយចូរអត់ទោសឱ្យខ្ញុំផង, និងត្រូវឧបាសកនោះសួរថា នេះអ្វី ? ទើបប្រាប់រឿងនោះទាំងអស់ ។

ព្រះសាស្តាទ្រង់ឃើញកិរិយានោះហើយ ត្រាស់សួរ អ្នកខ្វយខ្វាយក្នុងទានថា នេះអ្វីហ៎ ? គេក្រាបទូលរឿងនោះ ទាំងអស់តាំងពីថ្ងៃដំបូងមក ។

[កុំមើលបុណ្យថាតិចតួច]

ភ្លាមនោះព្រះសាស្តា ទ្រង់ត្រាស់សួរសេដ្ឋីនោះថានយថាជាយ៉ាងនោះឬ ?សេដ្ឋី,កាលគេក្រាបទូលថាយ៉ាងនោះព្រះអង្គ, ទ្រង់ត្រាស់ថា ឧបាសកដែលឈ្មោះថា បុណ្យដែលអ្នកណា ៗ មិនគួរមើលថា តិចតួច ដែលបុគ្គលថ្វាយទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធដួចជាតថាគតជាប្រធាន ហើយមិនគួរមើលងាយថា ជារបស់តិចតួច, ដោយថា បុរសអ្នកជាបណ្ឌិត ធ្វើបុណ្យរឿយ ៗ រមែងពេញទៅដោយបុណ្យជាលំដាប់ពិត ប្រៀបដូចភាជនៈដែល

បើកមាត់រមែងពេញទៅដោយទឹក ដូច្នោះ ។ ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

មាវមញ្ញេថ បុញ្ញស្ស ន មត្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
អាបូរតិ ធីរោ បុញ្ញស្ស ថោកំ ថោកំបិ អាចិនំ ។

បុគ្គលមិនគួរមើលបុណ្យថា បុណ្យមានប្រមាណតិច និងមិនឱ្យផលដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយដំណក់ទឹកដែលធ្លាក់ចុះ យ៉ាងណា អ្នកមានប្រាជ្ញា កាលសន្សំបុណ្យបន្តិចម្តង ៗ គង់ពេញបានដោយបុណ្យយ៉ាងនោះដែរ ។

អធិប្បាយគាថា

សេចក្តីនៃព្រះគាថានោះថា បុរសជាបណ្ឌិត កាលបើធ្វើបុណ្យហើយកុំមើលងាយគឺមិនគួរមើលងាយបុណ្យយ៉ាងនេះថា យើងធ្វើបុណ្យមានប្រមាណតិច បុណ្យមានប្រមាណតិចនោះនឹងមិនមកដោយអំណាចនៃវិបាកក៏ទេ កាលបើដូច្នេះ កម្មបន្តិចបន្តួចនឹងឃើញយើងទីណា ?ឬថា យើងនឹងឃើញកម្មនោះទីណា ?

កាលណាបុណ្យនោះនឹងមកឱ្យផល ?ដូចយ៉ាងថាភាជន:ដីដែលគេបើកគ្របចំហមាត់ទុកកណ្តាវាល រមែងពេញដោយតំណក់ទឹកដែលធ្លាក់ចុះមក (ម្តងមួយតំណក់ ៗ) មិនជាច់ខ្សែយ៉ាងណា, ធីវជន គឺអ្នកជាបណ្ឌិត កាលសន្សំបុណ្យបន្តិចម្តង ៗរមែងពេញដោយបុណ្យបាន ដូច្នោះដែរ ។

បណ្ឌិតធ្វើទានដោយខ្លួនឯង រមែងបានទ្រព្យយ៉ាងនេះគឺ

១- បានកើតក្នុងត្រកូលអភិជន ដែលមានទ្រព្យសម្បត្តិអាចបរិភោគប្រើប្រាស់តាំងតែនៅក្នុងផ្ទៃមាតា ។

២- កាលប្រកបការងារចិញ្ចឹមជីវិត រមែងរកទ្រព្យបានដោយងាយ ។

៣- ទ្រព្យសម្បត្តិដែលកើតឡើងជាទ្រព្យត្រជាក់ បានជាប្រយោជន៍ដល់ខ្លួនឯង និងអ្នកដទៃមិននាំមកនូវការក្តៅក្រហាយចិត្តឡើយ ។

៤- ទ្រព្យសម្បត្តិដែលកើតឡើង មិនមានវិបត្តិដោយភ័យណានីមួយឡើយ ។

បណ្ឌិតបបួលអ្នកដទៃឱ្យធ្វើទាន

រមែងបានបរិវារសម្បត្តិទាំងនេះ ៖

១- មានមនុស្សល្អ ស្មោះត្រង់សុចរិតជាបរិវារយ៉ាងច្រើន,

២- រមែងមានមិត្តល្អ អាចទីពឹងអាស្រ័យបាន,

៣-រមែងបានជួបតែបណ្ឌិតជាកល្យាណមិត្តមនុស្សពោលប្រ កាយអន្តរាយផ្សេង ៗ រមែងទៅឆ្ងាយដោយអំណាចបុណ្យដែលបបួលអ្នកដទៃឱ្យធ្វើសេចក្តីល្អដូច្នេះ ។

រឿងអបុត្តកសេដ្ឋីធ្វើទានស្តាយក្រោយ

សេចក្តីតំណាលថា អបុត្តកសេដ្ឋីនោះក្នុងអតីតកាលកើតជាសេដ្ឋីក្នុងក្រុងពារាណសី ថ្ងៃមួយក្រោកអំពីព្រលឹម បរិភោគរួចហើយ ទៅគាល់មប្រើស្តេចឃើញព្រះបច្ចេកពុទ្ធ ព្រះនាម **គតរសិទ្ធី** ញុំាងបុគ្គលឱ្យយកចង្ហាន់បិណ្ឌបាត ប្រគេនដល់ព្រះបច្ចេកពុទ្ធអង្គនោះ ហើយជៀសចេញទៅ ។ សេដ្ឋីនោះទៅកើតក្នុងសុគតិភពអស់វារៈ ១៤ ជាតិ ដោយផលជាតិនោះឯង គឺកើតជាសេដ្ឋីក្រុងសាវត្ថីអស់វារៈ ៧ ជាតិ ទៅកើតឋានសួគ៌ ៧ ជាតិទៀត ដោយផលទាននោះឯង ដែលបានប្រគេនដល់ព្រះបច្ចេកពុទ្ធ ។

ព្រោះថា ចេតនាតែមួយពិតក្នុងបិណ្ឌបាតទានតែមួយដែរ

គឺមិនឱ្យបដិសន្ធិ ២ ទេ សម្រេចនូវប្រយោជន៍ ជវនចិត្តតែមួយ កាលពោលថា អ្នកចូរឱ្យបិណ្ឌបាតដល់សមណៈ នេះត្រង់ជវនចិត្តកណ្តាលក៏គ្មាន នីឯងចុងក៏គ្មាន ជវនចិត្តមិនស្ទុះទៅកាន់គ្រប់ទាំង ៣ កាល គឺចេតនា ៣ មិនគ្រប់គ្រាន់ ។

(មង្គលត្ថទីបនីភាគ ៣, ទំព័រ ១៣)

លក្ខណសូត្រ

នៅក្នុងបិដកលេខ ១៩, ទំព័រ ១៧ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ព្រះសូត្រមួយដែលនិយាយអំពី **[អានិសង្សនៃការធ្វើទានដោយវេបស់បរិភោគ]** មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ កាលតថាគតអាស្រ័យនូវជាតិពីមុន លំនៅពីមុន កើតជាមនុស្សក្នុងកាលមុន ជាអ្នកឱ្យនូវខាទនីយ-ភោជនីយាហារ មានរសជាតិដ៏ថ្លៃថ្លា ព្រមទាំងទឹក ៨ ប្រការ ដែលគួរភ្លក្ស គួរលិទ្ធ ។ ព្រះតថាគតនោះ ព្រោះបានសន្សំកុសលកម្មនោះ ឱ្យធំទូលាយហើយនោះ ព្រះតថាគតនោះ លុះបែកធ្លាយរាងកាយបន្ទាប់អំពីសេចក្តីស្លាប់ ក៏បានទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ព្រោះកុសលកម្ម ដែលព្រះតថាគតបានធ្វើ សន្សំ បណ្តុះ

បណ្តាលឱ្យជំទូលាយនោះឯង ។ លុះព្រះតថាគតច្យុតចាកហាន
សួគ៌នោះ មកកាន់អត្តភាពជាមនុស្សនេះ ក៏បាននូវមហាបុរិស-
លក្ខណៈទាំងនេះគឺ ជាអ្នកមានសាច់ដ៏ពេញក្នុងទីទាំង ៧ អន្លើ គឺ
**សាច់ពេញត្រង់ខ្នងជើងទាំងពីរ, សាច់ពេញត្រង់ចង្កួយស្មាទាំងពីរ,
សាច់ពេញត្រង់-ក** ។ ព្រះតថាគតនោះ ប្រកបដោយលក្ខណៈ
នោះ បើនៅគ្រប់គ្រងគេហដ្ឋានទីឯងបានជាស្តេចចក្រពត្តិ (ប្រកប
ដោយធម៌ ជាស្តេចទ្រង់ធម៌ មានជ័យជំនះ ផ្សាយអំណាចរហូត
ដល់ផែនដី ដែលមានមហាសមុទ្រទាំង ៤ ព័ទ្ធជុំវិញទីឯដល់នូវភាព
ជាអ្នកមានជនបទដ៏មាំមួន ប្រកបដោយរតនៈទាំង ៧ ប្រការ ។
រតនៈ ៧ ប្រការរបស់ស្តេចចក្រពត្តិនោះគឺ ចក្ករតនៈ ១ ហត្ថិរតនៈ ១
អស្សរតនៈ ១ មណិរតនៈ ១ ឥត្ថីរតនៈ ១ គហបតីរតនៈ ១ បរិនាយក-
រតនៈ ១ រួមត្រូវជា ៧ ប្រការ ។ ព្រះរាជបុត្ររបស់ស្តេចចក្រពត្តិ
នោះ ក៏មានចំនួនច្រើនពាន់ ច្រើនតែជាអ្នកក្លៀវក្លា មានរូបស-
ណ្ឋានជាអ្នកអង់អាច អាចញាំញីនូវសេនារបស់ស្តេចឯទៀត
បាន ។ ស្តេចចក្រពត្តិនោះប្រោបប្រាមគ្រប់គ្រងផែនដីនេះ ដែល
មានសាគរជាទីបំផុត ឱ្យជាផែនដីឥតមានគោល ឥតមាននិមិត្ត ឥត
មានបន្ទា គឺចោរឡើយ ជាផែនដីស្តុកស្តម្ភ មាំមួន ក្សេមក្សាន្ត ឥត

មានឧបទ្រព ឥតមានទីពួនរបស់ចោរដោយធម៌ស្មើគឺ សីល ៥ មិនបាច់ពឹងអាជ្ញា មិនបាច់ពឹងគ្រឿងសស្ត្រាវុធឡើយ) ។ កាលបើបានជាស្តេចហើយ តើនឹងបានរបស់អ្វី គឺនឹងបានខាទនីយភោជនីយាហារ មានរសជាតិដ៏ថ្លៃថ្លា ព្រមទាំងទឹក ៨ ប្រការ ដែលគួរភ្លក្សគួរលិទ្ធ ។ កាលបើបានជាស្តេចនឹងបានរបស់នេះឯង ។ (បើចេញចាកគេហដ្ឋានទៅបួស នឹងបានត្រាស់ជាអរហន្តសម្មាសម្ពុទ្ធក្នុងលោក មានដម្បូល គឺកិលេសបើកចេញហើយ ។) កាលបើព្រះតថាគតបាន ត្រាស់ជាព្រះពុទ្ធនឹងបានរបស់អ្វី គឺនឹងបានខាទនីយភោជនីយាហារ មានរសជាតិដ៏ថ្លៃថ្លា ព្រមទាំងទឹក ៨ ប្រការដែលគួរភ្លក្សគួរលិទ្ធ ។ កាលបើបានត្រាស់ដឹងជាព្រះពុទ្ធនឹងបានរបស់នេះឯង ។ លុះព្រះមានព្រះភាគត្រាស់សេចក្តីនេះរួចហើយ ។ ទើបទ្រង់ត្រាស់គាថាព័ន្ធនេះក្នុងលក្ខណៈនោះថា ៖

ខជ្ជភោជនំ អថលេហសាយិតំ ឧត្តមគ្គរសធាយគោអហុ
តេនសោសុចរិតេន កម្មានន្ទវនេ ចិរមកិ ប្បមោទតិ ។

ព្រះតថាគត ជាអ្នកឱ្យខាទនីយភោជនីយាហារ និងទឹកដែលគួរលិទ្ធគួរភក្សដែលមានរសជាតិដ៏ឧត្តមថ្លៃថ្លា ព្រោះកម្មជាសុចរិតនោះ ព្រះតថាគតនោះ ទើបរីករាយក្នុងនន្ទវន(ឧទ្យាន)

អស់កាលយូរ ។

សត្ត ចុស្សទេ ឥថាធិគច្ឆតិ ហាត្ថបាទមុទុតលញ្ច វិន្ទតិ អាហុ ព្យញ្ជនមិត្តកោវិទា ខជ្ជភោជនរសលាភីតាយ ។

លុះច្យុតមកកើតក្នុងមនុស្សលោកនេះ ក៏បាននូវសាច់ដ៏ពេញក្នុងទីទាំង ៧ អន្លើផង បាននូវផ្ទៃដៃ និងផ្ទៃជើងដ៏ទន់ល្អន់ ជនទាំងឡាយដែលជាអ្នកឈ្លាសក្នុងការទាយនូវព្យញ្ជនទីងនិមិត្តនាំគ្នាទាយព្រះតថាគត ព្រោះហេតុតែព្រះតថាគតបានឱ្យនូវខាទនីយៈ-ភោជនីយាហារ ទើបបាននូវខាទនីយភោជនីយាហារមានរសជាតិដ៏ថ្លៃថ្លា ។

ន តំ គិហិស្សបិ តនត្តជោតកំបញ្ចដ្ឋំបិ ច តថាធិគចតិ ខជ្ជភោជនសប្បលាភិរុត្តមំ អាហុ សព្ពគិហិពន្ធនច្ឆិទន្តិ ។

លក្ខណៈនោះ មិនមែនជាគ្រឿងឆ្លុះបំភ្លឺសេចក្តីដល់ព្រះតថាគត ដែលនៅជាគ្រហស្ថប៉ុណ្ណោះទេ ទោះបីតថាគតចេញទៅបួស ក៏គង់បានទទួលផលនោះដែរ អ្នកដែលបាននូវខាទនីយភោ-ជនីយាហារ មានរសជាតិដ៏ឧត្តម ហៅថា អ្នកកាត់បង់នូវចំណង់របស់គ្រហស្ថទាំងអស់បាន ។

អដ្ឋកថា

បទថា រសិតានំ គឺសម្បរិវណ៌ដោយរស ។ ក្នុងបទថា ខាទនីយានំ បានដល់របស់ទំពាមានមេម្បៅជាដើម ឈ្មោះថា របស់គួរទំពា ។

បទថា ភោជនីយានិ បានដល់ ភោជន ៥ យ៉ាង ។ បទថា សាយនីយានិ បានដល់ ទឹកដោះថ្លា ទឹកដោះខាប់ជាដើម ដែលគួរលិទ្ធរស ។ បទថា លេហនីយានិ បានដល់ ថាយថាយាស ធ្វើដោយមេម្បៅជាដើម ដែលគួរភ្លក្ស ។

បទថា ផាណានិ បានដល់ ទឹកផ្លែឈើ ៨ ។ ការឱ្យភោជនដែលប្រណីតនេះ ព្រះតថាគតបានឱ្យហើយ រហូតដល់អស់ ៤ អសង្ខ្យៃយ្យកៃ្រលែងដោយសែនកប្ប ឈ្មោះថា កម្មក្នុងទីនេះ ។ កាលភោជនសៅហ្មងធ្លាក់ដល់ពោះ លោហិតស្អេកស្លាំង សាច់ស្ងួត ឈ្មោះថា ស្រជៀងកម្ម ព្រោះដូច្នោះ សត្វទាំងឡាយអ្នកឱ្យរបស់សៅហ្មងគិតថា ជនចូរដឹងការៈនៃរបស់សៅហ្មង ដែលសត្វទាំងនោះឱ្យហើយ ដោយហេតុនេះជាអ្នកមានសាច់តិចមានលោហិត មានថាយនិងទឹកបានលំបាក ដូចមនុស្សប្រេត ។ តែកាល

ភោជនប្រណីតជាក់ដល់ពោះសាច់និងឈាម រមែងចម្រើន សត្វទាំងឡាយមានកាយសម្បុរណ៌ គួរជ្រះថ្លា គួរស្រឡាញ់ គួរក្រឡេកមើល ព្រោះដូច្នោះ លោកព្រមទាំងទេវលោកចូរដឹងភាពដែលព្រះតថាគត ជាបុគ្គលឱ្យភោជនដ៏ប្រណីត រហូតដល់អស់កាលយូរដោយហេតុនេះ ព្រោះដូច្នោះ មហាបុរិសលក្ខណៈ គឺមានមំសៈពេញឡើងក្នុងទី ៧ កន្លែង រមែងកើតឡើង ព្រះលក្ខណៈពេញឡើងទី ៧ កន្លែងនេះឯង ឈ្មោះថាលក្ខណៈ, ភាពជាអ្នកបានរបស់ប្រណីត ឈ្មោះថា អានិសង្ស ។

បទថា **ខជ្ជភោជនំ អថ លេហសាយិតំ** បានដល់ របស់ទំពា របស់បរិភោគ របស់លិទ្ធនិងរបស់ភក្សរស ។

បទថា **ឧត្តមរសទាយកោ** ប្រែថា អ្នកឱ្យរសប្រណីតជាអ្នកឱ្យឆ្ងាស់ឬអ្នកឱ្យរសដ៏ឧត្តមប្រសើរ ។ បទថា **សត្ថុ ចុស្ស-ទេ** គឺព្រះលក្ខណៈពេញក្នុងទី៧កន្លែង ។ បទថា **តទត្ថជោតកំ** គឺសម្តែងអាហារមានរបស់ទំពារបស់បរិភោគជាដើមអធិប្បាយថា ញុំាងលាភឱ្យប្រព្រឹត្តទៅដល់បរិព្វាជកទាំងនោះ ។ បទថា **បព្ភដ្ឋបិ ច** ប្រែថា សូម្បីបួសហើយ ។ បទថា **តទាធិគច្ឆតិ** កាត់បទជា តំអធិគច្ឆតិ ។ **លាភិរុត្តមំ** កាត់បទជា លាភិឧត្តមំ ។

សាឡសូត្រ

នៅក្នុងបិដកលេខ ៤៤, ទំព័រ ៨៦ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់អំពី(**សេចក្តីចម្រើន៥យ៉ាង**)មានសេចក្តីថា ៖

ម្នាលភិក្ខុទាំងឡាយ ដើមឈើ ចម្រើនឡើងដោយសេចក្តីចម្រើន ៥ យ៉ាង ព្រោះអាស្រ័យស្តេចភ្នំឈ្មោះ ហិមវន្ត ។ **៥ យ៉ាង ដូចម្តេចខ្លះ?**

១- សាខាបត្តបលាសេន វឌ្ឍន្តិ គឺចម្រើនដោយមែក ស្លឹក ត្រួយ

២- តចេន វឌ្ឍន្តិ ចម្រើនដោយសម្បក

៣- បប្បដិកាយ វឌ្ឍន្តិ ចម្រើនដោយក្រមរ

៤- ផេគ្គុនា វឌ្ឍន្តិ ចម្រើនដោយស្រាយ

៥- សារេន វឌ្ឍន្តិ ចម្រើនដោយខ្លឹម ។

ម្នាលភិក្ខុទាំងឡាយ ដើមឈើធំ ចម្រើនឡើងដោយសេចក្តីចម្រើន ៥ យ៉ាងនេះ ព្រោះអាស្រ័យស្តេចភ្នំឈ្មោះ ហិមវន្ត ។ ម្នាលភិក្ខុទាំងឡាយ ជននៅខាងក្នុង រមែងចម្រើនដោយសេចក្តីចម្រើន ៥ យ៉ាង ព្រោះអាស្រ័យជនជាម្ចាស់ត្រកូលមានសទ្ធា

ដូច្នោះដែរ ។ **៥ យ៉ាងដូចម្តេចខ្លះ**ៗ

១- សទ្ធា វឌ្ឍន្តិ គឺចម្រើនដោយសទ្ធា

២- សីលេន វឌ្ឍន្តិ ចម្រើនដោយសីល

៣- សុតេន វឌ្ឍន្តិ ចម្រើនដោយសុតៈ

៤- ចាគេន វឌ្ឍន្តិ ចម្រើនដោយចាគៈ

៥- បញ្ញា វឌ្ឍន្តិ ចម្រើនដោយបញ្ញា ។

ម្នាលភិក្ខុទាំងឡាយ ជននៅខាងក្នុង រមែងចម្រើនដោយសេចក្តីចម្រើន៥ យ៉ាងនេះ ព្រោះអាស្រ័យជនជាម្ចាស់ត្រកូលមានសទ្ធា ។

យថា ហិ បព្ភគោ សេលោ អរញ្ញស្មឹ ព្រហាវនេ
តំ រុក្ខា ឧបនិស្សាយ វឌ្ឍន្តេតេ វនប្បតី
តថេវ សីលសម្បន្នំ សទ្ធំ កុលបុត្តំ ឥធ
ឧបនិស្សាយ វឌ្ឍន្តិ បុត្តធាតា ច ពន្ធវា
អមច្ចា ញាតិសង្ឃា ច យេ ចស្ស អនុជីវិនោ
តស្ស សីលវតោ សីលំ ចាគំ សុចរិតានិ ច
បសង្សមានានុកុព្វន្តិ យេ ភវន្តិ វិចក្ខណា

ឥធ ធម្មំ ចរិត្វាន សគ្គំ សុគតិគាមិនំ

នន្ទិនោ ទេវលោកស្មឹ មោទន្តិ កាមកាមិនោតិ ។

ភ្នំថ្មក្នុងជង្ហែព្រៃធំ ដើមឈើធំ ៗទាំងនោះរមែងចម្រើនឡើង ព្រោះអាស្រ័យភ្នំថ្មនោះ យ៉ាងណាមិញ កូនប្រពន្ធទាំងឡាយ ជៀតង្ស្រទាំងឡាយ អាមាត្យទាំងឡាយ ពួកញាតិទាំងឡាយ ពួកជនអ្នកចិញ្ចឹមជីវិតដោយសារបុគ្គលនោះ រមែងចម្រើនឡើង ព្រោះអាស្រ័យនឹងកុលបុត្រអ្នក មានសទ្ធា បរិបូណ៌ដោយសីលក្នុងលោកនេះ ក៏យ៉ាងនោះដែរ ។ ពួកជនមានកូននិងប្រពន្ធជាដើមនោះ ឃើញសីលផង ចាគៈផង និងសុចរិតទាំងឡាយផង របស់កុលបុត្រអ្នកមានសីលនោះហើយ រមែងធ្វើតាម ។ ក្នុងលោកនេះ ពួកអ្នកប្រាជ្ញណាជាអ្នកប្រព្រឹត្តធម៌ ជាអ្នកមានដំណើរទៅកាន់សុគតិសួគ៌ ពួកអ្នកប្រាជ្ញនោះ ជាអ្នកត្រេកអរក្នុងឋានសួគ៌ សម្រេចដូចសេចក្តីប្រាថ្នានៅក្នុងទេវលោក ។

អដ្ឋកថា

បទថា អរញ្ញេស្មឹ គឺក្នុងទីដែលមិនមែនភូមិស្រុក ។

បទថា ព្រហាវនេ បានដល់ ក្នុងព្រៃស្រោង ។

មហាសារលសូត្រនិទានអដ្ឋកថា

នៅក្នុងបិដកលេខ ៣០, ទំព័រ ១២៤ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ព្រះសូត្រមួយដែលនិយាយអំពី **(បុត្តបណ្ដេញបិតាឱ្យចេញពីផ្ទះ)** មានសេចក្ដីថា ៖

សាវត្ថីនិទាន ។ គ្រានោះ ព្រាហ្មណ៍មហាសាលម្នាក់ មានខ្លួនសៅហ្មង មានសំពត់ដណ្ដប់ក៏សៅហ្មង បានចូលទៅរកព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយក៏ធ្វើសេចក្ដីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួរវីរករាយ និងពាក្យដែលគួរវលីកហើយ ក៏អង្គុយក្នុងទីសមគួរ ។

បទថា **លូនោ លូខបាបុរណោ** បានដល់ ជាមនុស្សចាស់ មានខ្លួនសៅហ្មង មានសំពត់ដណ្ដប់ក៏សៅហ្មង ។

បទថា **ឧបសង្កមិ** ប្រែថា ចូលទៅរក ។ ព្រោះហេតុអ្វី ព្រាហ្មណ៍ទើបចូលទៅរកព្រះដ៏មានព្រះភាគ ? ព្រោះមានរឿងបានពោលមកថា ក្នុងផ្ទះរបស់ព្រាហ្មណ៍នោះ មានប្រាក់ដល់ទៅ ៨ សែន ។ ព្រាហ្មណ៍នោះបានធ្វើអាវាហមង្គលដល់បុត្រ ៤ នាក់ ចាយប្រាក់អស់ដល់ទៅ ៤ សែន ។ លំដាប់នោះ កាលដែលនាង

ព្រាហ្មណីជាភរិយារបស់ព្រាហ្មណ៍ បានធ្វើកាលកិរិយាហើយ បុត្រទាំង៤ឃ្លាយបានប្រឹក្សាគ្នាថា បើបិតានឹងនាំយកនាងព្រាហ្មណីដទៃមក ត្រកូលយើងនឹងបែកដោយអំណាចបុត្រដែលកើតក្នុងផ្ទៃរបស់នាងទៅយើង យើងនឹងសង្គ្រោះបិតារបស់យើង ។ បុត្រទាំង ៤ នាក់នោះ ទំនុកបម្រុងដោយអាហារបរិភោគ និងគ្រឿងស្លៀកដណ្តប់ជាដើម សុទ្ធតែប្រណីត ។ ព្រមទាំងធ្វើការគក់ច្របាច់ដៃជើងទៀតផង ។ ថ្ងៃមួយកាលដែលព្រាហ្មណ៍នោះឯង សម្រាកពេលថ្ងៃហើយក្រោកឡើង ទើបនាំគ្នាគក់ច្របាច់ខ្យាគាត់ ហើយពោលទោសក្នុងការនៅគ្រប់គ្រងផ្ទះ ម្នាក់ពោលយ៉ាងនេះ ម្នាក់ពោលយ៉ាងនោះ ទើបអង្វរបិតាថា ពួកកូននឹងទំនុកបម្រុងបិតារបៀបនេះរហូតអស់ជីវិតសូមបិតាកុំព្រួយ ខ្យាតែប្រាក់ដែលនៅសល់ទាំងប៉ុន្មានដល់ពួកកូនមក ។ ព្រាហ្មណាបានខ្យាប្រាក់ដល់បុត្រម្នាក់ ៗមួយសែន ហើយបែងចែកគ្រឿងឧបភោគបរិភោគទាំងអស់ ជាបួនចំណែកខ្យាដល់កូន ទុកតែសំពត់ស្លៀកដណ្តប់របស់ខ្លួនតែប៉ុណ្ណោះ ។ បន្ទាប់ពីចែកទ្រព្យសម្បត្តិហើយ បុត្រច្បងបានទំនុកបម្រុងព្រាហ្មណ៍ជាបិតាបាន ២ ៣ ថ្ងៃ ពេលដែល

ព្រាហ្មណ៍ឆ្លងទឹកហើយដើរចូលផ្ទះ កូនប្រសាស្រីឈរនៅនឹងស៊ុមទ្វារ ក៏បាននិយាយជាមួយព្រាហ្មណ៍យ៉ាងនេះថា ម៉េចបានជាឪឯងឱ្យប្រាក់កូនច្បងតែប៉ុណ្ណឹង បើចែកឱ្យដូចតែគ្នាអីចឹង ម៉េចបាននៅតែជាមួយនឹងកូនច្បង ឬមកអំពីអត់ស្គាល់ផ្លូវទៅផ្ទះកូនផ្សេងទៀត ? ព្រាហ្មណ៍ក្រោធខឹង ពោលថា ឃើ ! ស្រីថោកច ចង្រៃយក៍ហើយ ក៏បានទៅផ្ទះកូនដទៃ ។ ទៅបានត្រឹមតែ ២ ៣ ថ្ងៃ ក៏វត់ទៅផ្ទះកូនដទៃទៀតដោយទំនងដូច ៗគ្នា ។ កាលដែលមិនអាចចូលទៅផ្ទះកូនណាមួយបាន ក៏បួសជាអ្នកស្លៀកដណ្តប់សំពត់ពណ៌សត្រាច់ភិក្ខាចារ ។ ដោយកាលកន្លងទៅ ក៏ចាស់ជរា មានរាងកាយទ្រុឌទ្រោម ស្លេកស្លាំងព្រោះការបរិភោគមិនល្អ ខ្វះខាតទាំងដំណេកក៏លំបាក ។ ពេលមួយ ត្រឡប់មកពីភិក្ខាចារដេកកន្លែងមួយ លក់ទៅភ្ញាក់ឡើង ក្រោកអង្គុយពិចារណាខ្លួនឯងឃើញថាមិនបានទីពឹងក្នុងបុត្រ ទើបគិតថា យើងបានស្តាប់មកថា ព្រះសមណគោតម មានព្រះភក្ត្រមិនចង់ចិញ្ចើម មានតែព្រះភក្ត្រស្រស់ចរចាគួរ ឱ្យសប្បាយចិត្តឆ្ងាតក្នុងបដិសណ្ឋារៈ ដូច្នេះយើងអាចចូលទៅគាល់ព្រះសមណគោតមបាន ។ ព្រោះហេតុនោះ ទើប

ព្រាហ្មណ៍រៀបរយសំពត់ស្បៀកដណ្តប់ កាន់ភិក្ខាភាជនៈចូលទៅគាល់ព្រះដ៏មានព្រះភាគដល់ទីប្រថាប់ ។

លុះព្រាហ្មណ៍មហាសាលនោះ អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះដ៏មានព្រះភាគ ត្រាស់យ៉ាងនេះថា ម្នាលព្រាហ្មណ៍ អ្នកមានខ្ជនសៅហ្មងមានសំពត់ដណ្តប់ក៏សៅហ្មង តើព្រោះហេតុអ្វី ? ព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គមានកូន ៤ នាក់ ក្នុងក្រុងនេះឯង កូនទាំងនោះកាន់យកទ្រព្យដែលជារបស់ខ្ញុំព្រះអង្គទាំងអស់រួចហើយជីងថា ខ្ញុំព្រះអង្គអស់ទ្រព្យសម្បត្តិហើយ ទើបប្រឹក្សាសមគំនិតគ្នាជាមួយនឹងភរិយារបស់គេវៀង ៗខ្ជនបណ្តេញខ្ញុំព្រះអង្គចេញអំពីផ្ទះ សូមព្រះអង្គទ្រង់ជ្រាប ។

ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ អ្នកចូររៀននូវគាថាទាំងឡាយនេះ ហើយសូត្រក្នុងវេលាជាទីប្រជុំនៅពេលដែលពួកមហាជនកំពុងប្រជុំគ្នាផង ទាំងដែលកូនទាំងឡាយរបស់អ្នកអង្គុយប្រជុំក្នុងទីនោះផងដែរថា ៖

យេហិ ជាតេហិ ឧទ្ទិស្សុំ យេសញ្ច ភវមិច្ឆិសំ
តេ មំ ធារេហិ សំបុច្ច សាវ វាចេន្តិ សូករំ ។

ខ្ញុំត្រេកអរដោយកូនទាំង៦ឡាយណា ដែលកើតហើយផង ប្រាថ្នានូវសេចក្តីចម្រើន ដល់កូនទាំង៦ឡាយណាផង កូនទាំង៦នោះ ក៏សមគំនិតគ្នាជាមួយនឹង៦ប្រពន្ធទាំង៦ឡាយ ហើយបណ្តាញខ្ញុំដូចជាឆ្កែបណ្តាញជ្រូក ។

បទថា ឧទ្ទិស្សុ៎ ដោយសេចក្តីថា ខ្ញុំមានការភ្ញើតភ្ញើនត្រេកអរជាមោក្ខ ។

បទថា ភវមិច្ឆិសំ ដោយសេចក្តីថា ខ្ញុំប្រាថ្នាសេចក្តីចម្រើន ។

បទថា សារ វាទេន្តិ សូករំ ដោយសេចក្តីថា ពួកឆ្កែទាំង៦ ហ្វូង ព្រុសជេញជ្រូក ព្រុសស្រែកឡើង៣ដង ។ រឿយ ។យ៉ាងណា បុត្រទាំង៦ឡាយក៏យ៉ាង៦នោះដែរ ព្រមជាមួយនឹង៦ភរិយា បណ្តាញខ្ញុំ ដោយសំឡេង៣ដង ។ ឱ្យចេញទៅ ។

អសន្តា កិរ មំ ៨ម្មា តាត តាតាតិ ភាសរេ
រក្ខសា បុត្តរូបេន តេ ៨ហន្តិ វយោគតំ ។

កូនទាំង៦ឡាយ ជាអសប្បុរស លាមក គ្រាន់តែហៅខ្ញុំថា បិតា បិតាប៉ុណ្ណោះទេ ប៉ុន្តែកូនទាំង៦នោះ ដូចអារក្សទឹកដែលមក ដោយរូបជាកូន លះបង់នូវខ្ញុំដែលមានអាយុចូលដល់បច្ឆិមវ័យ ហើយ ។

បទថា អសន្តា បានដល់ អសប្បុរសទាំងឡាយ ។

បទថា ជម្មា ប្រែថា បុគ្គលលាមក ។

បទថា ភាសរេ ប្រែថា រមែងពោល ។

បទថា បុត្តរូបេន បានដល់ ដោយភេទរបស់បុត្រ ។

បទថា វយោគតំបានដល់ ខ្ចុំដែលមានវ័យទាំងបីកន្លង ហើយតាំងនៅក្នុងបច្ឆិមវ័យ ។

អសេ្សវ ជិណ្ណោ និព្ភោគោ ទានធ អបនីយតិ

ពាលកានំ បិតា ថេវោ បរាគារេសុ ភិក្ខតិ ។

បិតាចាស់របស់បុគ្គលពាលទាំងឡាយមិនមានអ្វីបរិភោគ តែងសូមទានប្របផ្ទះនៃជនដទៃ ដូចជាសេះចាស់ប្រើប្រាស់មិនបាន គេនាំចេញចាកចំណី ។

បទថា និព្ភោគោ ប្រែថា មិនមានគ្រឿងបរិភោគ ។

បទថា ទានធ អបនីយតិ ដោយសេចក្តីថា មនុស្សទាំងឡាយ រមែងឱ្យចំណីដែលមានរសផ្សេង ៗដល់សេះ ក្នុងវេលាដែលសេះនៅពេញកម្លាំងរហ័សរហួន លុះដល់ចាស់អស់កម្លាំង ក៏លះបង់ចោល មិនបានទទួលការមើលថែ ត្រូវដើរទៅរក

ស្មៅស្ងួតក្នុងព្រៃជាមួយនឹងមេគោទាំងឡាយ ។ បិតាដែលមិនមានទ្រព្យសម្បត្តិ ព្រោះទ្រព្យទាំងពួងត្រូវប្លន់ទៅអស់ ដល់ពេលចាស់ក៏ដូចសេះនោះឯង បិតាចាស់នៃបុគ្គលពាលទាំងឡាយ ដូចជាខ្ញុំនេះត្រូវដើរសូមអាហារពីផ្ទះអ្នកដទៃ ។

ឧណ្ហា វ កិរ មេ សេយ្យោ យញ្ញេ បុត្តា អនស្សវា
ចណ្ឌម្បិ គោណំ វារេតិ អថោ ចណ្ឌម្បិ កុក្កុរំ
អន្ធការេ បុរេ ហោតិ គម្ភីរេ គាធមេធតិ
ឧណ្ហស្ស អានុភាវេន ខលិត្វា បដិតិដ្ឋតីតិ ។

ឈើច្រត់របស់ខ្ញុំប្រសើរ កូនទាំងឡាយដែលមិនស្តាប់បង្គាប់ មិនប្រសើរដូចជាឈើច្រត់ឡើយ ព្រោះឈើច្រត់ រមែងការពារគោកាចក៏បាន ការពារឆ្កែកាចក៏បាន ច្រត់ទៅមុខក្នុងទីងងឹតក៏បាន ស្ទង់ក្នុងទឹកជ្រៅក៏បាន បុគ្គលភ្លាត់រអិលគង់ទប់ទល់បាន ដោយអានុភាពនៃឈើច្រត់ ។

សព្ទថា យញ្ញេ ជានិបាត លោកពោលអធិប្បាយទុកថា គេថាឈើច្រត់នៅប្រសើរជាង ល្អជាងបុត្ររបស់យើង ដែលមិនជឿស្តាប់ មិនគោតក្រែង មិននៅក្នុងការគ្រប់គ្រង ។ ដើម្បីបញ្ជាក់

អំពីឈើច្រត់នោះថា ជារបស់ប្រសើរ ទើបព្រះដ៏មានព្រះភាគទ្រង់
ត្រាស់ថា **ចណ្ឌម្ប៊ិ គោណំ** ដូច្នេះជាដើម ។

បទថា **បុរេ ហោតិ** បានដល់ ប្រើនាំមុខអធិប្បាយថា យក
ឈើច្រត់នោះច្រត់ទៅខាងមុខ រមែងស្រួល ។

បទថា **គាធមេធតិ** ដោយសេចក្តីថា ពេលចុះទឹក ប្រើ
ឈើច្រត់ជាទីពឹងក្នុងទឹកជ្រៅ ។

លំដាប់នោះឯង ព្រាហ្មណមហាសាលនោះបានរៀននូវ
ព្រះគាថាទាំងឡាយនេះ ក្នុងសម្នាក់ព្រះដ៏មានព្រះភាគ **បរិយោ-
បុណិត្វា** គឺរៀនសូត្រទាល់តែរត់មាត់ ។ **សន្និសិន្នេសុ** ក្នុងថ្ងៃ
ដែលពួកព្រាហ្មណ៍ប្រជុំគ្នា ទាំងដែលពួកបុត្រប្រដាប់ដោយគ្រឿង
អលង្ការទាំងពួង ចូលកាន់ទីប្រជុំនោះហើយ អង្គុយលើអាសនៈ
យ៉ាងធំ កណ្តាលពួកព្រាហ្មណ៍ ។ **អភាសិ** ព្រាហ្មណ៍ចាស់ជាបិតា
គិតថានេះ ជាពេលរបស់យើងហើយ ទើបចូលទៅកណ្តាលទីប្រជុំ
លើកដៃឡើងពោលថា អស់លោកដ៏ចម្រើនទាំងឡាយ ខ្ញុំមានបំណង
នឹងពោលគាថាដល់លោកទាំងឡាយ កាលដែលខ្ញុំពោលដល់
លោកទាំងឡាយ តើលោកទាំងឡាយស្តាប់ខ្ញុំទេ ? កាលដែលពួក

ព្រាហ្មណ៍ពោលថា ពោលចុះព្រាហ្មណ៍ ពួកយើងនឹងស្តាប់ដូច្នេះ ទើប
បានឈរពោលពេលនោះតែម្តងនូវព្រះគាថាដែលមានសេចក្តីថា ៖

ខ្ញុំត្រេកអរដោយកូនទាំងឡាយណា ដែលកើតហើយផង
ប្រាថ្នានូវសេចក្តីចម្រើន ដល់កូនទាំងឡាយណាផងកូនទាំងនោះ
ក៏សមគំនិតគ្នាជាមួយនឹងប្រពន្ធទាំងឡាយ ហើយបណ្តេញខ្ញុំ
ដូចជាឆ្កែបណ្តេញក្រួក ។

កូនទាំងឡាយជាអសប្បុរស លាមកគ្រាន់តែហៅខ្ញុំថា
បិតា បិតាប៉ុណ្ណោះទេ ប៉ុន្តែកូនទាំងនោះ ដូចអាវក្សទឹកដែលមក
ដោយរូបជាកូន លះបង់នូវខ្ញុំដែលមានអាយុចូលដល់បច្ឆិមវ័យ
ហើយ ។

បិតាចាស់របស់បុគ្គលពាលទាំងឡាយ មិនមានអ្វីបរិភោគ
តែងសូមទានប្របផ្ទះនៃជនដទៃ ដូចជាសេះចាស់ប្រើប្រាស់មិន
បាន គេនាំចេញចាកចំណី ។

ឈើច្រត់របស់ខ្ញុំប្រសើរ កូនទាំងឡាយដែលមិនស្តាប់
បង្គាប់ មិនប្រសើរដូចជាឈើច្រត់ឡើយ ព្រោះឈើច្រត់ រមែង
ការពារគោកាចក៏បាន ការពារឆ្កែកាចក៏បាន ច្រត់ទៅមុខក្នុងទីងងឹត

ក៏បាន សុងក្នុងទឹកជ្រៅក៏បាន បុគ្គលភ្លាត់រអិលគង់ទប់វិញបាន ដោយអានុភាពនៃឈើច្រត់ ។

ដោយសម័យនោះឯង ពួកមនុស្សមានប្រពៃណីដូច្នេះថា បុគ្គលណាបរិភោគសម្បត្តិនៃមាតាបិតាហើយ មិនចិញ្ចឹមមាតាបិតា បុគ្គលនោះត្រូវសម្លាប់ចោល ព្រោះហេតុដូច្នោះហើយ បុត្រទាំងអស់របស់ព្រាហ្មណ៍ទើបក្រាប ចុះក្បែរជើងទាំងពីររបស់បិតា ហើយអង្វរថា លោកឪពុក អើយ សូមលោកឪពុកឱ្យជីវិតដល់ពួកកូនផង ព្រោះទឹកចិត្តរបស់បិតាទន់ភ្លន់ដល់កូន ៗ ព្រាហ្មណ៍ជាបិតាទើបពោលថា បពិត្រលោកដ៏ចម្រើនទាំងឡាយ សូមលោកទាំងឡាយ កុំឱ្យកូន ៗដ៏ល្ងង់ខ្លៅរបស់ខ្ញុំនេះវិនាសឡើយ ពួកគេនឹងចិញ្ចឹម មើលថែដល់ខ្ញុំតទៅ ។

លំដាប់នោះ មនុស្សទាំងឡាយបានពោលទៅរកកូន ៗ ទាំងនោះដូច្នេះថា នែ ! ពួកអ្នកឯងប្រុងចាំស្តាប់ណា៎ ចាប់តាំងពីថ្ងៃនេះទៅ បើពួកអ្នកមិនប្រណិបត្តន៍បិតារបស់អ្នកឯងឱ្យល្អទេ ពួកយើងនឹងសម្លាប់ពួកអ្នកឯងចោលជាមិនខាន ។ កូន ៗ ទាំងនោះមានការភ័យខ្លាច ទើបនាំបិតាទៅកាន់ផ្ទះដើម្បីប្រណិបត្តន៍ ។

នេត្វា ឱ្យបិតាអង្គុយលើតាំងហើយលើក ទ្បើងនាំទៅដោយខ្លួនឯង ។ នហាបេត្វា យកប្រេងលាបខ្លួន ហើយគក់ច្របាច់ដល់ពេលងូតទឹកឱ្យងូត ទឹកដែលអប់ដោយគ្រឿងក្រអូបនិងជូនគ្រឿងស្លៀកដណ្តប់ដោយគូសំពត់មួយគូម្នាក់ ៗ ។ កូនទាំងអស់បានហៅប្រពន្ធរបស់ខ្លួនមកប្រាប់ថា ចាប់តាំងពីថ្ងៃនេះទៅ ពួកនាងចូរប្រណិប័តន៍បិតារបស់យើងឱ្យល្អ បើពួកនាងប្រមាទពួកយើងនឹងបណ្តេញពួកនាងឱ្យចេញពីផ្ទះរួចហើយកូន ៗបានជូនអាហារភោជនយ៉ាងប្រណីតអញ្ជើញបិតាបរិភោគ ។

ព្រាហ្មណ៍បានអាហារល្អ មានដំណេកយ៉ាងសប្បាយ ត្រឹមតែ ២ ៣ ថ្ងៃប៉ុណ្ណោះ ក៏មានកម្លាំងមានរាងកាយស្រស់បស់ ។ ព្រាហ្មណាសម្លឹងមើលអត្តភាពហើយគិតថា យើងបានសម្បត្តិនេះព្រោះអាស្រ័យព្រះសមណគោតម ទើបកាន់គ្រឿងបណ្ណាការធ្វើដំណើរទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ធ្វើសេចក្តីរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ ហើយក៏អង្គុយក្នុងទីដ៏សមគួរ ។ ឯតទវោច ព្រាហ្មណ៍បានជាក់ថ្វាយសំពត់មួយគូទៀបបាទមូលនៃព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ទទួលដោយសេចក្តី

អនុគ្រោះ រួចហើយព្រាហ្មណ៍បានពោលពាក្យនេះ គឺក្រាបទូលព្រះដ៏មានព្រះភាគ ក្នុងពេលទទួលសរណាគមនរួចហើយនោះឯង យ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ពួកកូន ៗបានឱ្យភត្តាហារប្រចាំដល់ខ្ញុំព្រះអង្គ ៤ ចំណែកខ្ញុំព្រះអង្គសូមថ្វាយដល់ព្រះអង្គ ២ ចំណែកក្នុង ៤ ចំណែកនោះ ឯខ្ញុំព្រះអង្គនឹងបរិភោគខ្លួនឯង ២ ចំណែក ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកកុំបូជាដល់តថាគត ចំពោះចំណែកដែលល្អឡើយ តថាគតនឹងទៅដល់កន្លែងតាមដែលតថាគតត្រូវទៅ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងដូច្នោះឯង ហើយបានថ្វាយបង្គំព្រះដ៏មានព្រះភាគត្រឡប់ទៅផ្ទះ ។ ទៅដល់ផ្ទះហើយបានហៅ ពួកកូនមកប្រាប់ថា កូន ៗទាំងឡាយ ព្រះសមណគោតម ជាសម្លាញ់របស់ឪនៅពេលព្រះអង្គយាងមកដល់ចូរកូន ៗ កុំភ្លេចថ្វាយភត្តាហារជាប្រចាំរបស់ឪ ២ ចំណែកដល់ព្រះអង្គណ៎ា ។ ពួកកូនទាំងគ្នាទទួលថា ល្អហើយឪ ។

ព្រឹកស្អែកឡើង ព្រះដ៏មានព្រះភាគទ្រង់ប្រដាប់បាត្រ និងចីវរ ទ្រង់យាងទៅកាន់គេហដ្ឋានរបស់កូនប្រុសច្បង ។

កូនប្រុសច្បងបានទទួលបាត្រចាកព្រះហស្ត រួចយាងព្រះ

អង្គចូលកាន់គេហដ្ឋាន ថ្វាយទីគង់ប្រថាប់ដ៏ប្រណីតហើយ ទើបបានថ្វាយនូវភោជនដ៏ប្រណីតឧត្តម ។ ថ្ងៃបន្ទាប់មកទៀត ព្រះបរមសាស្តាស្តេចយាងទៅកាន់គេហដ្ឋាននៃកូន ម្នាក់ទៀត ជាបន្តបន្ទាប់ព្រះអង្គស្តេចយាងទៅកាន់គេហដ្ឋាន នៃបុត្រៃបស់ព្រាហ្មណ៍គ្រប់គ្នាតាមលំដាប់ដោយប្រការដូច្នេះឯង ។ ពួកកូន ៗទាំងនោះ គ្រប់គ្នាបានធ្វើសក្ការៈដូច ៗគ្នា ។

ក្រោយមក ថ្ងៃមួយ នៅឯគេហដ្ឋានរបស់កូនប្រុស ច្បង មានពិធីមង្គល ។ កូនបាននិយាយនឹងបិតាថា បពិត្របិតា ពួកយើងនឹងថ្វាយមង្គលដល់អ្នកណា ? ព្រាហ្មណ៍ជាបិតាពោលថា ពួកយើងអត់ស្គាល់អ្នកដទៃណាឡើយ ព្រះសមណគោតមជាសម្លាញ់របស់ឪមិនមែនទេឬ ។ កូនច្បងបានពោលថា បើដូច្នោះ បិតាចូរយាងព្រះសមណគោតម មកដើម្បីសោយភត្តាហារក្នុងថ្ងៃស្អែក ព្រមដោយភិក្ខុសង្ឃ ៥០០ អង្គ ។ ព្រាហ្មណ៍ក៏បានធ្វើដូច្នោះ តាមពាក្យរបស់កូន ។

ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនូវការអារាធនាហើយហែហមទៅដោយព្រះភិក្ខុសង្ឃស្តេចយាងទៅតាមកាលកំណត់ចូល

កាន់គ្រឹះស្ថានរបស់បុត្រច្បងដែលប្រជាប់តាក់ តែងដោយគ្រឿងប្រជាប់ផ្សេង ៗ ។ បុត្រច្បងបានទិមន្តព្រះសង្ឃដែលមានព្រះពុទ្ធអង្គជាប្រមុខ គង់លើអាសនៈដែលបានក្រាលទុកហើយ បានថ្វាយនូវបាយាសដែលមានទឹកតិច ព្រមទាំងខាទនីយាហារផ្សេង ៗ ទៀត ។ កូនទាំងអស់បានមកជួបជុំគ្នា សមគួរតាមវេលាបានក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះគោតមដ៏ចម្រើន ពួកខ្ញុំព្រះអង្គបានប្រណិបត័ន្ធបិតារបស់ពួកខ្ញុំព្រះអង្គ ដោយមិនបានប្រមាទឡើយ សូមព្រះអង្គទ្រង់ទតមើលនូវអត្តភាព ។ ព្រះបរមសាស្តាទ្រង់ត្រាស់ថា ការចិញ្ចឹមបីបាច់ថែរក្សាមាតាបិតា ដែលពួកអ្នកបានធ្វើហើយ គឺជាការល្អ ពួកបុរាណបណ្ឌិត បានធ្លាប់ប្រព្រឹត្តមកហើយយ៉ាងស្មោះស្មើ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នូវនាគរាជជាតកប្រកាសអរិយសច្ច ៤ ក្នុងពេលចប់ព្រះធម៌ទេសនាព្រាហ្មណ៍ព្រមទាំងកូន ៤ នាក់ ទាំងកូនប្រសាស្រី ៤ នាក់ទៀតនោះ បានបញ្ចូនញាណ ទៅតាមក្រសែព្រះធម៌ តាំងនៅក្នុងសោតាបត្តិផល ។ ចាប់តាំងពីពេលនោះមក ព្រះបរមសាស្តា ស្តេចពុំបានយាងទៅកាន់ផ្ទះនៃជនទាំងនោះទៀតឡើយ ក្នុងកាលទាំងពួង ។

សេរីសូត្រ

សេរីទេវបុត្តឋិតនៅក្នុងទីសមគួរហើយ ក្រាបទូលព្រះមានព្រះភាគដោយគាថាថា ៖

អន្ធមេវាភិនន្ទន្តិ ឧភយោ ទេវមានុសា
អថខោ ឆាម សោ យក្ខោ យំ អន្ធំ ឆាភិនន្ទតីតិ ។

យក្សនោះឯង មិនត្រេកអរចំពោះបាយណាឯទេវតា និងមនុស្សទាំងពីរពួក រមែងត្រេកអរចំពោះបាយនោះ ។

ព្រះមានព្រះភាគត្រាស់ថា ៖

យេ នំ ឧទន្តិ សទ្ធាយ វិប្បសន្នេន ចេតសា
តមេវ អន្ធំ ភជតិ អស្មឹ លោកេ បរម្ហិ ច
តស្មា វិនេយ្យ មច្ឆេរំ ឧជ្ឈា ឆានំ មលាភិភូ
បុញ្ញានិ បរលោកស្មឹ បតិដ្ឋា ហោន្តិ បាណិ នន្តិ ។

ពួកជនណា មានចិត្តជ្រះថ្លា ឱនូវបាយនោះដោយសទ្ធា បាយនោះឯង រមែងទៅតាមនូវពួកជននោះវិញ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង ព្រោះហេតុនោះ បុគ្គលគប្បីបន្ទោបង់នូវសេចក្តីកំណាញ់គ្រប សង្កត់នូវមន្ទិល គឺ សេចក្តីកំណាញ់ហើយ

ឱ្យនូវទាន ព្រោះបុណ្យទាំងឡាយ រមែងជាទីពឹងរបស់សត្វក្នុងលោកខាងមុខ ។

មនាបទាយីសូត្រ

នៅក្នុងបិដកលេខ ៤៤, ទំព័រ ៩៨ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ត្រាស់ព្រះសូត្រមួយដែលនិយាយអំពី **[អ្នកឱ្យរបស់ជាទីពេញចិត្តរមែងបានរបស់ជាទីពេញចិត្ត]** មានសេចក្តីថា ៖

សម័យមួយ ព្រះដ៏មានព្រះភាគ ស្តេចគង់នៅក្នុងកូដាគារសាលា នាមហាវ័ន ទៀបក្រុងវេសាលី ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់បាត្រចីវរក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់លំនៅនៃឧគ្គគហបតី អ្នកក្រុងវេសាលី លុះចូលទៅដល់ហើយក៏គង់លើអាសនៈដែលគេក្រាលថ្វាយ ។ លំដាប់នោះ ឧគ្គគហបតីអ្នកក្រុងវេសាលី ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះឧគ្គគហបតី អ្នកក្រុងវេសាលី អង្គុយក្នុងទីសមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះ

ភក្ត្រព្រះដ៏មានព្រះភាគថា អ្នកឱ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចំរើន ខាទនីយាហារប្រាកដស្មើដោយផ្ការាសាព្រឹក្សជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គ សូមព្រះដ៏មានព្រះភាគ ទទួលនូវខាទនីយាហារនោះ ដើម្បីសេចក្តីអនុគ្រោះដល់ខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដោយសេចក្តីអនុគ្រោះ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា បុគ្គលឱ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចំរើន សូករមំសៈដ៏ប្រសើរ ស្អាតជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គមាន សូមព្រះដ៏មានព្រះភាគទ្រង់ទទួលសូករមំសៈនោះ ដើម្បីអនុគ្រោះខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដើម្បីអនុគ្រោះ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះដ៏មានព្រះភាគថា បុគ្គលឱ្យរបស់ជាទីគាប់ចិត្តរមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចំរើន នាលិយសាក[1]ដែលច្រឡំដោយប្រេងជាទីគាប់ចិត្ត

១- នាលិយសាកនេះ សំដៅយកភោជនីយាហារដែលគេច្របាច់ជាមួយនឹងម្សៅស្រូវសាលី

របស់ខ្ញុំព្រះអង្គ សូមព្រះដ៏មានព្រះភាគ ទ្រង់ទទួលនាលិយសាក
នោះដើម្បីអនុគ្រោះខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួល
ដើម្បីអនុគ្រោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ពាក្យនេះខ្ញុំព្រះអង្គ
បានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រព្រះដ៏មានព្រះ
ភាគថា បុគ្គលឱ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្ត
វិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ជាយស្រូវសាលីឥតមានរនុក
មានសំឡច្រើនមុខ មានម្ហូបក្រៀមច្រើនមុខជាទីគាប់ចិត្តខ្ញុំព្រះអង្គ
សូមព្រះដ៏មានព្រះភាគ ទ្រង់ទទួលនូវភោជននោះ ដើម្បីអនុគ្រោះ
ខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដើម្បីអនុគ្រោះ ។
បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ
បានទទួលចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា បុគ្គលឱ្យរបស់ជា
ទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏
ចំរើន សម្ពត់ទាំងឡាយនៅក្នុងដែនកាសីជាទីគាប់ចិត្តរបស់ខ្ញុំព្រះ
អង្គ សូមព្រះដ៏មានព្រះភាគទទួលសម្ពត់ទាំងនោះ ដើម្បីអនុគ្រោះ

ហើយចំអិនក្នុងសប្បិដែលលាយដោយជីរជាដើម ។

ខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលដើម្បីសេចក្តីអនុគ្រោះ ។ បពិត្រព្រះអង្គដ៏ចំរើន ពាក្យនេះខ្ញុំព្រះអង្គបានស្តាប់ចំពោះព្រះភក្ត្រ បានទទួលចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគថា បុគ្គលឱ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។ បពិត្រព្រះអង្គដ៏ចំរើន បល្ល័ង្កដែលក្រាលដោយព្រំ មានរោមវែង (ជាង ៤ ធ្នាប់) កម្រាលពណ៌សដែលធ្វើដោយរោមសត្វ កម្រាលដែលធ្វើដោយរោមសត្វ ជាផ្កាចង្កោម កម្រាលដ៏ឧត្តមដែលធ្វើដោយស្បែកសត្វឈ្មស់ មានខ្នើយពណ៌ក្រហមទាំងសងខាង ព្រមទាំងពិតានមានពណ៌ក្រហមជាទីគាប់ចិត្តរបស់ខ្ញុំព្រះអង្គ ។ បពិត្រព្រះអង្គដ៏ចំរើន មួយទៀត យើងខ្ញុំដឹងរបស់នុ៎ះថា របស់នុ៎ះ មិនគួរដល់ព្រះដ៏មានព្រះភាគ បពិត្រព្រះអង្គដ៏ចំរើន ផែនក្តារខ្លឹមចន្ទន៍របស់ខ្ញុំព្រះអង្គនេះថ្លៃជាងមួយសែន សូមព្រះដ៏មានព្រះភាគទទួលផែនក្តារនោះ ដើម្បីអនុគ្រោះខ្ញុំព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដើម្បីអនុគ្រោះ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគអនុមោទនា ដោយអនុមោទនីយគាថានេះ ចំពោះឧគ្គគហបតីអ្នកក្រុងវេសាលីថា ៖

មនាបធាយី លភតេ មនាបំ
យោ ឧជុភូតេសុ ទធាតិ ជន្តុសា
អច្ឆាទនំ សយនមថន្នបានំ
ឆានប្បការានិ ច បច្ចយានិ
ចត្តញ្ច មុត្តញ្ច អនុគ្គហីតំ
ខេត្តូបមេ អរហន្តេ វិទិត្វា
សោ ធុច្ចំ សប្បុរិសោ ចជិត្វា
មនាបធាយី លភតេ មនាបន្តិ ។

បុគ្គលឱ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ សប្បុរសណាដឹងនូវពួកព្រះអរហន្ត ឧបមាដូចជាស្រែហើយប្រគេនសម្ពត់ស្បៀកដណ្តប់ ដំណេក បាយ ទឹក នឹងបច្ច័យទាំងឡាយ មានប្រការផ្សេង ៗ ដែលខ្ជនបរិច្ចាគហើយផង លះបង់ហើយផង មិនមានស្តាយផង ចំពោះលោកអ្នកមានកាយ វាចា ចិត្តត្រង់សប្បុរសនោះឈ្មោះថាលះបង់ហើយនូវវត្ថុដែលគេលះបង់បានដោយកម្រ បុគ្គលអ្នកឱ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគ អនុមោទនាដោយអនុមោទនីយគាថានេះ ចំពោះឧគ្គគហបតីអ្នកក្រុងវេសាលី ហើយទ្រង់ក្រោកចាកអាសនៈចៀសចេញទៅ ។ លំដាប់នោះ ឧគ្គគហបតីអ្នកក្រុងវេសាលី ក៏ធ្វើមរណកាលក្នុងសម័យ ក្រោយមក លុះឧគ្គគហបតីអ្នកក្រុងវេសាលីធ្វើមរណកាលហើយក៏ទៅកើតក្នុងពួកទេវតាដែលសម្រេចដោយចិត្តណាមួយ ១ ។ សម័យនោះ សោត ព្រះដ៏មានព្រះភាគគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋីទៀបក្រុងសាវត្ថី ។ គ្រានោះឧគ្គទេវបុត្រ កាលរាត្រីកន្លងទៅហើយ មានរស្មីដ៏រុងរឿង បំភ្លឺវត្តជេតពនទាំងអស់ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឈរក្នុងទីសមគួរ ។ លុះឧគ្គទេវបុត្រឈរនៅក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគត្រាស់សួរយ៉ាងនេះថា ម្នាលឧគ្គៈ សេចក្តីសមតាមបំណងរបស់អ្នកមានដែរឬទេ ។ បពិត្រព្រះដ៏មានព្រះភាគ សូមទ្រង់ជ្រាបសេចក្តីសមប្រកបតាម

១.តាមអដ្ឋកថាថាទៅកើតក្នុងពួកទេវតាដែលកើតក្នុងសុទ្ធាវាសទាំងឡាយដោយឯកជ្ឈានចិត្ត ។

បំណងរបស់ខ្ញុំព្រះអង្គមានដែរ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ បានត្រាស់ទឹងឧគ្គទេវបុត្រដោយគាថាទាំងឡាយថា ៖

មនាបធាយី លភតេ មនាបំ
អគ្គស្ស ធាតា លភតេ បុនគ្គំ
វរស្ស ធាតា វរលាភី ច ហោតិ
សេដ្ឋន្តុនោ សេដ្ឋមុបេតិ ឋានំ
អគ្គធាយី វរធាយី សេដ្ឋធាយី ច យោ នរោ
ទីឃាយុ យសវា ហោតិ យត្ថ យត្ថូបបជ្ជតិ ។

បុគ្គលអ្នកឱ្យរបស់ជាទីគាប់ចិត្ត រមែងបានរបស់ជាទីគាប់ចិត្តវិញ បុគ្គលអ្នកឱ្យរបស់ខ្ពង់ខ្ពស់ រមែងបានរបស់ខ្ពង់ខ្ពស់វិញ បុគ្គលអ្នកឱ្យរបស់ប្រសើរ រមែងបានរបស់ដ៏ប្រសើរវិញ បុគ្គលអ្នកឱ្យរបស់ដ៏ថ្លៃថ្លា រមែងបានទូវហាន:ដ៏ថ្លៃថ្លាវិញ នរៈណា អ្នកឱ្យរបស់ខ្ពង់ខ្ពស់ផង អ្នកឱ្យរបស់ប្រសើរផង អ្នកឱ្យរបស់ថ្លៃថ្លាផង នរៈនោះ កើតក្នុងទីណា ៗជាអ្នកមានអាយុវែង មានយសសក្តិក្នុងទីនោះ ៗ ។

ប្រវត្តិសង្ខេបរបស់ខុគ្គគហបតី

ខុគ្គគហបតី[1] មានពីរនាក់ផ្សេងគ្នា គឺ ម្នាក់ជាសេដ្ឋីក្រុងវេសាលី ឯតទគ្គៈលើឧបាសកទាំងឡាយ ផ្នែកខាងថ្វាយភោជនជាទីគាប់ចិត្តរបស់ខ្លួនដល់ព្រះសង្ឃមានព្រះពុទ្ធជាប្រមុខ ។ ម្នាក់ទៀតជាសេដ្ឋីនៅហត្ថិគ្រាមជាឯតទគ្គៈ ផ្នែកខាងឧបដ្ឋាកព្រះសង្ឃ ។

ខុគ្គគហបតី មានបុណ្យបានធ្វើមកហើយក្នុងកាលមុនវិលវល់ក្នុងមនុស្សនិងទេវតាអស់ ១ សែនកប្បក្នុងពុទ្ធុប្បាទនេះ គាត់បានកើតក្នុងត្រកូលសេដ្ឋីក្រុងវេសាលី ។ ក្រោយមកដោយរូបរាងរបស់គាត់ខ្ពស់ស្អាត ព្រមទាំងគុណទាំងឡាយ របស់គាត់ប្រសើរខ្ពង់ខ្ពស់ទៀត ទើបមាននាមប្រាកដថា ខុគ្គៈ ។

ខុគ្គគហបតី ជាសេដ្ឋីក្រុងវេសាលីនេះ មានធម៌អស្ចារ្យចម្លែក ៨ ប្រការគឺ ៖

១- បានឃើញព្រះដ៏មានព្រះភាគអំពីចម្ងាយ ជាដំបូងបង្អស់អត់មានសង្ស័យថា ព្រះពុទ្ធមែន ឬមិនមែនឡើយ មានតែចិត្តជ្រះថ្លាចំពោះព្រះដ៏មានព្រះភាគដោយគ្រាន់តែបានឃើញប៉ុណ្ណោះ ។

---

១. បិដកលេខ ៤៨, ទំព័រ ១០៨ គហបតិវគ្គ

២- មានចិត្តជ្រះថ្លាហើយ ក៏ចូលទៅអង្គុយជិតព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់សម្តែងនូវអនុបុព្វីកថា ហើយទ្រង់ប្រកាសសច្ចធម៌ ក៏បានធម្មចក្ខុ គឺ សោតាបត្តិផលទាំងបាននូវសិក្ខាបទទាំងឡាយ មានព្រហ្មចរិយៈជាគម្រប់ ៥ (ក្រោយមកទៀត ក៏បានសម្រេចនូវអនាគាមិផល) ។

៣- បានលះបង់ភរិយាឱ្យទៅបុរសដទៃ តាមដែលភរិយានោះឯង ត្រូវការបុរសនោះជាស្វាមីចំពោះចិត្តរបស់ឧគ្គគហបតីមិនប្រែប្រួលឡើយ ។

៤- មិនមានចិត្តគិតថា យើងនឹងឱ្យទ្រព្យសម្បត្តិប៉ុណ្ណោះ មិនឱ្យប៉ុណ្ណោះ យើងនឹងឱ្យរបស់នេះ មិនឱ្យរបស់នោះ ដូច្នេះឡើយ គឺទ្រព្យសម្បត្តិទាំងអស់ក្នុងត្រកូលជាសាធារណៈដល់អ្នកមានសីល មានកល្យាណធម៌ទាំងឡាយ ដូចជារបស់សង្ឃ និងដូចជារបស់ពួកគណៈ ។

៥- ចូលទៅអង្គុយជិតភិក្ខុណា តែងចូលទៅអង្គុយ ជិតដោយគោរព មិនមែនដោយមិនគោរពនោះទេ ។

៦- បើភិក្ខុអង្គនោះសម្តែងធម៌ឱ្យគាត់ស្តាប់ គាត់ស្តាប់ដោយ

គោរពមិនមែនស្តាប់ដោយមិនគោរពនោះទេ តែបើភិក្ខុមិនសម្តែងធម៌ទេ គាត់តែងសម្តែងធម៌ដល់ភិក្ខុអង្គនោះវិញ ។

៧- ពួកទេវតាតែងចូលមករក ហើយប្រាប់ថា ម្នាលគហបតី ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយដោយប្រពៃ ។ គាត់បាននិយាយទៅរកពួកទេវតាវិញយ៉ាងនេះថា ម្នាលទេវតាទាំងឡាយ អ្នកទាំងឡាយគប្បីពោលយ៉ាងនេះក្តី មិនគប្បីពោលយ៉ាងនេះក្តី ឯធម៌ពិតព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយដោយប្រពៃមែន ។ សេចក្តីអស្ចារ្យគឺនៅត្រង់ចិត្តរបស់គហបតីមិនបានប៉ោងឡើង ព្រោះហេតុបានចរចាជាមួយនឹងទេវតានោះឡើយ ។

៨- ពិចារណារកសញ្ញោជនធម៌ជាចំណែកខាងក្រោម ៥ ដែលមិនទាន់លះបង់ក្នុងខ្លួនមិនឃើញឡើយ ។

នៅក្នុងអដ្ឋកថា **មនាបទាយីសូត្រ** បានសម្តែងថា ឧគ្គគហបតី ជាសេដ្ឋីក្រុងវេសាលី មានអធ្យាស្រ័យសំដៅដល់ព្រះអរហន្ត កាលដែលនៅជាមនុស្ស ព្រោះហេតុដូច្នោះ ទើបព្រះដ៏មានព្រះភាគ ត្រាស់សួរនៅក្នុងព្រះសូត្រថា ម្នាលឧគ្គៈ បំណងរបស់អ្នកបានសម្រេចហើយឬ ? ឧគ្គសុទ្ធាវាសព្រហ្ម បានសម្រេច

នូវព្រះអរហន្តហើយ ទើបបានក្រាបទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះដ៏មានព្រះភាគ សូមទ្រង់ជ្រាបបំណងរបស់ខ្ញុំព្រះអង្គ បានសម្រេចហើយ ។

ឧគ្គគហបតី[1] អ្នកស្រុកហត្ថិគ្រាម មានធម៌ចម្លែកអស្ចារ្យ ៨ ប្រការគឺ ៖

១- គាត់កំពុងតែសប្បាយរីករាយជាមួយនឹងបរិវារ ស្រីឯស្រាក្នុងនាគវន ដែលជាសួនឧទ្យានរបស់គាត់ពេលនោះ គាត់យើញព្រះដ៏មានព្រះភាគជាដំបូងអំពីចម្ងាយ គាត់ក៏មានសេចក្តីជ្រះថ្លាចំពោះព្រះដ៏មានព្រះភាគ ដោយគ្រាន់តែយើញប៉ុណ្ណោះ ទាំងការស្រីឯស្រាក៏ស្វាងទៅ ។

២- មានចិត្តជ្រះថ្លាហើយ បានចូលទៅគាល់ព្រះអង្គបានស្តាប់អនុបុព្វីកថា និងអរិយសច្ចធម៌ក៏បានសម្រេចដល់អនាគាមិផល ក្នុងគ្រានោះតែម្តង ។

៣- ចិត្តមិនប្រែប្រួលឡើយ នៅពេលប្រគល់ភរិយារបស់គាត់ឱ្យទៅបុរសដទៃ ។

---

១. ឯតទគ្គបាលី បិដកលេខ ៤០, ទំព័រ ៥៧ ឈ្មោះ ឧគ្គតគហបតី ។

៤-គាត់ទុកទ្រព្យសម្បត្តិដ៏ច្រើនក្នុងត្រកូលរបស់គាត់ ឱ្យជាសាធារណៈដល់អ្នកមានសីល មានកល្យាណធម៌ទាំងឡាយ ។

៥- ចូលទៅអង្គុយជិតភិក្ខុណា តែងចូលទៅអង្គុយជិតដោយគោរព បើភិក្ខុអង្គនោះសម្តែងធម៌ឱ្យស្តាប់ក៏ស្តាប់ ដោយគោរពបើមិនសម្តែងធម៌ទេគាត់ក៏សម្តែងដល់ភិក្ខុអង្គនោះវិញ ។

៦- កាលដែលគាត់និមន្តព្រះសង្ឃមកហើយ ពួកទេវតាបានមកប្រាប់គាត់ថា ម្នាលគហបតី ភិក្ខុឯណោះជាឧភតោភាគវិមុត្ត ភិក្ខុឯណោះជាបញ្ញាវិមុត្ត ភិក្ខុឯណោះជាកាយសក្ខី ភិក្ខុឯណោះជាទិដ្ឋិប្បត្តៈ ភិក្ខុឯណោះជាសទ្ធាវិមុត្ត ភិក្ខុឯណោះជាធម្មានុសារី ភិក្ខុឯណោះជាសទ្ធានុសារី ភិក្ខុឯណោះជាអ្នកមានសីលមានកល្យាណធម៌ ចំណែកភិក្ខុឯណោះជាបុគ្គលទ្រុស្តសីលមានធម៌ដ៏លាមក ។ ត្រង់ដែលទេវតាទាំងឡាយមកប្រាប់នេះមិនជាអស្ចារ្យទេ ដែលអស្ចារ្យនៅត្រង់ថ្វាយចង្ហាន់សង្ឃដោយមិនមានចិត្តកើតឡើងយ៉ាងនេះថា ប្រគេនវត្ថុតិចដល់អង្គនេះ ប្រគេនវត្ថុច្រើនដល់អង្គនោះ ដូច្នេះឡើយ គឺថ្វាយទានមានស្មើរ ដោយពិត ។

៧- មានពួកទេវតាចូលមកចរចា ក្នុងប្រធានបទដែលថា ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយដោយប្រពៃ ។ សេចក្តីអស្ចារ្យនៅត្រង់ចិត្តរបស់គហបតី មិនបានប៉ោងឡើងព្រោះហេតុការចរចាជាមួយ នឹងទេវតាទាំងឡាយនោះ ។

៨- ពិចារណាសញ្ញោជនធម៌ខាងក្រោម ៥ គឺពួកសញ្ញោជន:ដែលលះដោយមគ្គ ៣ ខាងក្រោម បានដល់សក្កាទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វតបរាមាស:១ កាមរាគ:១ បដិឃៈ ១ ដែលមិនទាន់លះបង់ក្នុងខ្លួន មិនឃើញឡើយ ។

ក្នុងអដ្ឋកថា អង្គុត្តរនិកាយ ឯកនិបាត បានសម្តែងថា ឧគ្គគហបតីនេះ ជាអ្នកត្រេកអរដ៏ក្រៃលែងក្នុងការថ្វាយទាន ដល់ភិក្ខុសង្ឃ ។ ទេវតាមកក្នុងពេលរាត្រីហើយជ្រាបដល់លោកសេដ្ឋីថា ភិក្ខុអង្គនេះមានវិជ្ជា ៣ អង្គនោះមានអភិញ្ញា ៦ អង្គនោះមានសីល អង្គនោះទ្រស្តសីល ។ លោកសេដ្ឋីជ្រាបហើយតាមដែលទេវតាបានប្រាប់ ក៏នៅតែថ្វាយទេយ្យធម៌ដោយចិត្តស្មើដដែល សូម្បីអង្គុយក្នុងសម្នាក់ព្រះបរម សាស្តាក៏ពោលតែគុណនោះ ៗ ឯង ។ ក្រោយមកព្រះដ៏មានព្រះភាគ កាលដែលប្រថាប់នៅព្រះជេតពនមហាវិហារ ព្រះអង្គទ្រង់ស្ថាបនាឧគ្គគហបតី អ្នកស្រុក

ហត្ថគ្រាមក្នុងតំណែងឯតទគ្គៈលើឧបាសកទាំងឡាយ ផ្នែកខាងឧបដ្ឋាកសង្ឃ ។

ប្រភេទនៃការធ្វើទានផ្សេងៗ

១- អាមិសទាន ការឱ្យវត្ថុបច្ច័យរបស់ផ្សេង ។

២- ធម្មទាន ការឱ្យធម៌ជាទានគឺការសម្តែងធម៌ទេសនា ការបង្រៀនធម៌ និងការកសាងសៀវភៅផ្សេង ។ ចែកជាធម្មទាន ។

➥ ក្នុងទានទាំងពីរយ៉ាងនេះ ធម្មទានជាទានប្រណីតជាងអាមិសទាន ដូចជាព្រះបាលីថា ៖

សព្ពទានំ ធម្មទានំ ជិនាតិ ធម្មទានឈ្នះអស់ទានទាំងពួង ។

➥ ចំពោះអានិសង្សវិញគឺ **អាមិសទាន** ឱ្យផលធ្វើឱ្យមានទ្រព្យសម្បត្តិ វត្ថុរបស់របរបរិបូណ៌មិនចេះខ្វះ ចំណែក **ធម្មទាន** ឱ្យផលគឺមានបញ្ញាច្រើន ។

នយមួយទៀតថា ៖

១- សាហត្ថិកទាន ការឱ្យទានដោយដៃខ្លួនឯង

២- អាណាត្តិកទាន ការឱ្យទានដោយប្រើអ្នកដទៃឱ្យធ្វើជំនួស ។

➥ ក្នុងទានទាំងពីរយ៉ាងនេះ **សាហត្ថិកទាន** ប្រណីតជាង **អាណត្តិកទាន** ។

➥ ចំពោះអានិសង្សវិញគឺ **សាហត្ថិកទាន** កាលបញ្ចេញផល ក៏រមែងជាអ្នកមានទ្រព្យសម្បត្តិច្រើន នឹងបរិវារ, ចំណែក **អាណត្តិកទាន** សូម្បីកាលបញ្ចេញផល ឱ្យជាអ្នកបរិបូណ៌ដោយភោគៈសម្បត្តិកពិត តែបរិវារមិនសូវមានទេ ។

នៃយមួយទៀតថា ៖

១- សម្បជានទាន ការធ្វើបុណ្យដែលប្រកបដោយសេចក្តីចេះដឹង គឺដឹងនូវផលនៃការឱ្យទាននោះជាដើម

២- អសម្បជានទាន ការធ្វើបុណ្យដោយមិនមានសេចក្តីចេះដឹងសេចក្តីចូលចិត្តក្នុងរឿងកម្មនិងផលរបស់កម្មជាដើម ។

➥ ចំពោះអានិសង្សវិញគឺ **សម្បជានទាន** កាលបញ្ចេញផល ក៏រមែងជាអ្នកមានទ្រព្យសម្បត្តិ និងព្រមដោយបញ្ញា, ចំណែក **អសម្បជានទាន** កាលបញ្ចេញផល ឱ្យត្រឹមតែជាអ្នក

មានទ្រព្យសម្បត្តិ តែខ្វះសតិបញ្ញា ។

នយមួយទៀតថា ៖

១- វដ្តនិស្សិតទាន ការធ្វើបុណ្យដោយការប្រាថ្នាភោគៈសម្បត្តិ គឺប្រាថ្នាឱ្យមានទ្រព្យជាសេដ្ឋី មហាសេដ្ឋីនិងប្រាថ្នានូវភវសម្បត្តិ គឺត្រូវការឱ្យកើតជាមនុស្ស ជាទេវតា ជាព្រហ្ម,

២- វិវដ្តនិស្សិតទាន ការធ្វើបុណ្យដោយមិនមាន សេចក្តីប្រាថ្នាក្នុងភោគៈសម្បត្តិ និងភវសម្បត្តិទេ ប្រាថ្នាតែសម្មាសម្ពោធិញ្ញាណ បច្ចេកពោធិញ្ញាណ អគ្គសាវកពោធិញ្ញាណ មហាសាវក ពោធិញ្ញាណ នឹងប្រកតិសាវក ពោធិញ្ញាណយ៉ាងណាមួយប៉ុណ្ណោះ ។

➥ ចំពោះអានិសង្សវិញ គឺ **វដ្តនិស្សិតទាន** មិនហៅថាទានបារមីទេ ជាទានកុសលសាមញ្ញ កាលបញ្ចេញផល ក៏ឱ្យមានសេចក្តីសុខត្រឹមតែមនុស្ស នឹងទេវតាប៉ុណ្ណោះ មិនអាចនឹងឱ្យដល់មគ្គផលដោយឆាប់រហ័សបានទេ ចំណែក **អវដ្តនិស្សិតទាន** ហៅថា **ទានបារមី** កាលបញ្ចេញផល ឱ្យមានសេចក្តីសុខក្នុងមនុស្ស និងទេវតា នឹងអាចឱ្យដល់មគ្គផល បានដោយឆាប់រហ័ស ។

ទានទានពួកជនែទៀតគឺ

១~ ហីនទាន
២~ មជ្ឈិមទាន — **មានន័យ ៣ គឺ ៖**
៣~ បណីតទាន

ន័យទី ១ **ហីនទាន** *ការធ្វើបុណ្យថ្នាក់ទាប បានដល់ ការធ្វើបុណ្យដែលមានសេចក្តីប្រាថ្នា លាភ យស ការ លើកសរសើរ ។*

~ **មជ្ឈិមទាន** *ការធ្វើបុណ្យថ្នាក់កណ្តាល បានដល់ ការធ្វើបុណ្យដែលមានសេចក្តីប្រាថ្នាមនុស្សសម្បត្តិទេវតាសម្បតិ ។*

~ **បណីតទាន** *ការធ្វើបុណ្យថ្នាក់ខ្ពស់ បានដល់ ការធ្វើបុណ្យតាមដំណើរផ្លូវបស់ព្រះអរិយជាម្ចាស់ និងព្រះពោធិសត្វទាំងឡាយ គឺសេចក្តីប្រាថ្នាព្រះនិព្វាន ។*

ន័យទី ២ **ហីនទាន** *ការធ្វើបុណ្យថ្នាក់ទាប បានដល់ការធ្វើបុណ្យដែលមានសេចក្តីប្រាថ្នាមនុស្សសម្បត្តិ ទេវតាសម្បត្តិ ។*

~ **មជ្ឈិមទាន** *ការធ្វើបុណ្យថ្នាក់កណ្តាល បានដល់ ការធ្វើបុណ្យដែលមានសេចក្តីប្រាថ្នា ជាសាវ័កពោធិញ្ញាណ បច្ចេក-

ពោធិញ្ញាណ ។

~ **បណីតទារេ** ការធ្វើបុណ្យថ្នាក់ខ្ពស់ បានដល់ ការធ្វើបុណ្យប្រថ្នាសម្មាសម្ពោធិញ្ញាណ ។

នយទី ៣ **ហីនទារេ** ការធ្វើបុណ្យថ្នាក់ទាប បានដល់ការធ្វើបុណ្យដែលប្រកបដោយឆន្ទៈវីរិយៈ ចិត្តៈ បញ្ញាតិចតួច ពោលគឺមានការពេញចិត្ត ព្យាយាម ចាប់ចិត្ត យល់ដឹងក្នុងការធ្វើបុណ្យនោះ ត្រឹមតែបន្តិចបន្តួច ។

~ **មជ្ឈិមទារេ** ការធ្វើបុណ្យថ្នាក់កណ្តាល បានដល់ ការធ្វើបុណ្យដែលប្រកបដោយឆន្ទៈវីរិយៈចិត្តៈបញ្ញា ល្មមប្រមាណ ពោលគឺមានការពេញចិត្ត ព្យាយាម ចាប់ចិត្ត យល់ដឹងក្នុងការធ្វើបុណ្យនោះយ៉ាងល្អ ធម្មតាសាមញ្ញទូទៅ ។

~ **បណីតទារេ** ការធ្វើបុណ្យថ្នាក់ខ្ពស់ បានដល់ ការធ្វើបុណ្យដែលប្រកបដោយឆន្ទៈ វីរិយៈ ចិត្តៈ បញ្ញាយ៉ាងក្រៃលែង ពោលគឺមានការពេញចិត្ត ព្យាយាម ចាប់ចិត្ត យល់ដឹងក្នុងការធ្វើបុណ្យនោះយ៉ាងល្អក្រៃលែង តាមដំណើរផ្លូវរបស់សប្បុរសទាំងឡាយ ។

ទានទានពួកជនែទៀត

១.ទាសទាន ការធ្វើបុណ្យដោយគ្រឿងឧបភោគបរិភោគ ដែលអាក្រក់ជាងវត្ថុបច្ចុយដែលខ្លួនប្រើខ្លួនបរិភោគ ។

២. សហាយទាន ការធ្វើបុណ្យដោយគ្រឿងឧបភោគ បរិភោគ ដែលស្មើគ្នានិងវត្ថុបច្ចុយដែលខ្លួនប្រើខ្លួនបរិភោគ ។

៣. សាមិសទាន ការធ្វើបុណ្យដោយគ្រឿងឧបភោគ បរិភោគ ដែលល្អជាងវត្ថុបច្ចុយដែលខ្លួនប្រើខ្លួនបរិភោគ ។

➥ ចំពោះបុគ្គលដែលធ្វើទាន ៣ ប្រភេទនេះ នៅក្នុងមង្គលត្ថទីបនីមានសម្តែងថា ៖

ទាសោ ហុត្វា ទេតិ តណ្ហាទាសព្យស្ស ឧបគតត្តា បុគ្គលអ្នកឱ្យទាន មានសភាពជាខ្ញុំនៃទាន ព្រោះភាវៈនៃបុគ្គលនោះចូលទៅជិតកាន់យកជាខ្ញុំនៃតណ្ហា ។ គឺឱ្យវត្ថុថោកទាប បរិភោគខ្លួនឯងដ៏ថ្លៃថ្លា,ទាសោ វិយ ហោតិ ទុកដូចជាបុគ្គលជាខ្ញុំទាន, មនុស្សខ្ញុំគេជាមនុស្សថោកទាប(បើបានសោយរាជ្យជាស្តេច ៗ អង្គនោះ និងនៅក្រោមបង្គាប់គេ) ។

សហាយោ ហុត្វា ទេតិ តស្ស អប្បិយការវិសជ្ជនតោ

បុគ្គលឱ្យទាន មានសភាពជាសម្លាញ់(នោះ) ព្រោះភាពនៃខ្លួនបានលះបង់នូវទេយ្យធម៌មិនជាទីស្រឡាញ់របស់ខ្លួន (បើបានសោយរាជ្យជាស្តេច ៗអង្គនោះ ឯករាជ្យ) ។

សាមិ ហុត្វា ទេតិ តត្ថ តណ្ហាទាសព្យតោ អត្តានំ មោចេត្វា អភិភុយ្យ បវត្តនតោ បុគ្គលអ្នកឱ្យទានមានសភាពជាម្ចាស់ ព្រោះបានដោះខ្លួនចេញអំពីខ្ទុំនៃតណ្ហាក្នុងទេយ្យវត្ថុនោះ ព្រោះបានគ្របសង្កត់លើតណ្ហា ព្រោះជាម្ចាស់នៃទេយ្យវត្ថុ គឺបរិភោគខ្លួនឯងចោកទាប ដល់ឱ្យទានមានវត្ថុដ៏ថ្លៃថ្លា ឬមានចិត្តគ្របសង្កត់លើលោក មិនឱ្យតណ្ហាជិះជាន់បាន លះបង់មច្ឆរិយមិនមានមន្ទិល ។ (បើបានសោយរាជ្យជាស្តេច គឺ បានត្រួតលើនគរដទៃ) ។

មានទានពួកជនៃទៀត ៖

១- លោកាធិបតេយ្យទាន ការធ្វើបុណ្យដែលប្រារព្ធមនុស្សចំណែកច្រើនជាធំ គឺខ្លួនឯងមិនមានសេចក្តីពេញចិត្ត និងធ្វើទេ តែខ្លាចអ្នកជនៃមើលងាយ និងតិះដៀលទើបបានធ្វើ ។

២- អត្តាធិបតេយ្យទាន ការធ្វើបុណ្យប្រារព្ធខ្លួនឯង ជា

ធំគឺគិតថា យើងជាមនុស្ស ជាអ្នកមានទ្រព្យសម្បត្តិច្រើន បើមិនបរិច្ចាគទ្រព្យជួយសង្គ្រោះក្នុងកិច្ចការនោះ ៗទេ ក៏ជាការឱ្យស្អប់មិនសមគួរដូច្នោះ ទើបធ្វើ ។

៣- ធម្មាធិបតេយ្យទាន ការធ្វើបុណ្យដែលប្រារព្ធធម៌ជាធំ គឺពិចារណាថា ការបរិច្ចាគទាននេះ ជាធម៌ គឺសប្បុរសទាំងឡាយនិមយធ្វើសូម្បីព្រះពោធិសត្វទាំងឡាយ កាលនៅបំពេញបារមីនោះ ក៏បានបំពេញទានបារមីជាដើម មុនរហូតដល់សាវ័កផ្សេង ៗ របស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំងឡាយ ក៏ពេញចិត្តក្នុងការសាងទាននោះដូចគ្នា ការពិចារណាយើញជាប្រយោជន៍ដូច្នេះហើយក៏ធ្វើឱកាសតាមពេលវេលា ។

(ចាក.គម្ពីបរមត្ថជោតិក បរិច្ឆេទទី ៥ ក្បាលទី ២ ទំព័រ ១៨៣)

សរុបទាន

កាលសរុបមក ទាននេះមាន ៤ យ៉ាងគឺ ៖

១-ចេតនាទាន បានដល់ ចេតនាចេតសិកដែលប្រកបជាមួយមហាកុសល ដែលជាហេតុនៃការឱ្យទាន

២.ឥត្តុទ្ទានៈ បានដល់ បច្ចុប្បន្ន ៤ ដែលជាទេយ្យធម៌

៣. អលោភទ្ទានៈ បានដល់ អលោភចេតសិកដែលប្រកបជាមួយចេតនាចេតសិក ដែលជាហេតុនៃការឱ្យទាន

៤.អទោសទ្ទានៈ បានដល់ វិតិចេតសិក ៣ ដែលមានការវៀរចាកអកុសលទុច្ចរិត ដែលជាហេតុឱ្យសត្វទាំងឡាយមិនត្រូវទុក្ខព្រួយចិត្ត ក្នុងការដែលនឹងមានភ័យកើតឡើងជាអភ័យទានទាំងខាងក្នុងនិងខាងក្រៅ ។

ព្រះគាថាសម្តែងសរសើរអំពីទាន

ទានំ នាម សុខានីនំ និទានំ បរមំ មតំ
និព្វានំ បន សោត្ថានំ បតិដ្ឋាតិ បវុច្ចតិ ។

ធម្មតា **ទាន** លោកពោលថា ជាហេតុដ៏សំខាន់នៃសេចក្តីសុខជាដើម, នៅពោលទៀតថា ជាទីតាំងនៃជណ្តើរទាំងឡាយដែលទៅកាន់ព្រះនិព្វាន ។

ទានំ តាណំ មនុស្សានំ ទានំ ពន្ធុ បរាយនំ
ទានំ ទុក្ខាធិបន្នានំ សត្តានំ បរមា គតិ ។

ទាន ជាគ្រឿងការពារ(ភ័យ) របស់មនុស្សទាំងឡាយ,

ទាន ជាផៅពង្ស ជាគ្រឿងនាំមុខ, ទានជាគតិដ៏សំខាន់របស់សត្វទាំងឡាយ ដែលដល់នូវ(ការរួចចាក)សេចក្តីទុក្ខ ។

ទុក្ខនិត្ថរណាដ្ឋេន ទានំ នាវាតិ ទីបិតំ
ភយរក្ខណាតោ ទានំ នគរន្តិ ច វណ្ណិតំ ។

ទាន លោកពោលថា ជានាវា ព្រោះអត្ថថា ជាគ្រឿងឆ្លងចាកសេចក្តីទុក្ខ, និងលោកនៅពោលសរសើរថា ជានគរ ព្រោះអាចការពារភ័យបាន ។

ទានំ ទុរាសទដ្ឋេន វុត្តមាសិវិសោតិ ច
ទានំ លោភមលាទីហិ បទុមំ អនុបលិត្តត្តោ ។

ទាន លោកពោលថា ជាអសិវិពិស ព្រោះអត្ថថា ចូលទៅជិតបានដោយលំបាក, ទាន ជាផ្កាបទុម(ឈូក) ព្រោះមន្ទិលគឺលោភៈជាដើមប្រឡាក់មិនបាន ។

នត្ថិ ទានសមោ លោកេ បុរិសស្ស អវស្សយោ
បដិបជ្ជថ តស្មា តំ កិរិយាជ្ឈាសយេន ច ។

ទីពំនាក់អាស្រ័យរបស់បុរសក្នុងលោក ស្មើដោយទានមិនមាន, ព្រោះហេតុនោះ អ្នកទាំងឡាយចូរបំពេញទាន ដោយការ

ធ្វើតាមអធ្យាស្រ័យ ។

សគ្គលោកនិធានានិ ធានានិ មតិមា ឥធ
កោ ហិ នាម លោកេ ន ធនេយ្យ ហិតេរតោ ។

នរជនណាសោត ដែលជាអ្នកមានបញ្ញាក្នុងលោកនេះ តែងត្រេកអរចំពោះប្រយោជន៍ក្នុងលោក និងមិនឱ្យទានទាំងឡាយ ដែលជាហេតុនាំមកនូវឋានសួគ៌នោះសោត ។

សុត្វា ទេវេសុ សម្បត្តិ កោ នរោ ឋានសម្ភវំ
ន ទជ្ជា សុខប្បទំ ធានំ ធានំ ចិត្តប្បមោទនំ ។

នរជនណាសោតបានឮថា ទានជាដែនកើតឡើងនៃសម្បត្តិក្នុងទេវលោក និង មិនគប្បីឱ្យទានដែលឱ្យដល់នូវសេចក្តីសុខ ទានជាគ្រឿងញុំាងចិត្តឱ្យរីករាយ ។

ធានេន បដិបន្នេន អច្ឆរាបរិវារិតោ
រមតេ សុចិរំ កាលំ នន្ទនេ សុរនន្ទនេ ។

នរជនដែលបានបំពេញទានហើយ គឺជាបុគ្គលដែលពួកនាងស្រីទេពអប្សរហែហម សប្បាយអភិរមក្នុងឧទ្យានឈ្មោះនន្ទវន ជាទីកន្លែងគួររីករាយរបស់ទេវតានោះរហូតអស់កាលជានិច្ច ។

បីតិមុទ្ធារំ វិន្ទតិ ទាតាគារវមស្មឹ គច្ឆតិ លោកេ កិត្តិមនន្តំ យាតិ ច ទាតា វិស្សនីយោ ហោតិ ច ទាតា ។

អ្នកឱ្យ(ទាន) រមែងបាននូវបីតិដ៏លើសលុប រមែងជួបប្រសព្វនូវសេចក្តីគោរពក្នុងលោកនេះ អ្នកឱ្យ(ទាន)រមែងជួបប្រសព្វនូវកិត្តិសព្ទ(ល្អ)ជាច្រើនអ្នកឱ្យ(ទាន)រមែងជាអ្នកដែលមហាជនទុកចិត្ត ។

ឧត្វា ទានំ យាតិនរោ សោ ភោឆ្ឈសមិទ្ធឹ ទីឃញ្ចាយុ សុស្សរ តម្បិ ចវិន្ទតិរូបំសគ្គេ សទ្ធឹ កីឆ្ឈតិ ទេវេហិ វិមានេសុ ឋត្វា នានា មត្តមយូរាភិរុតេសុ ។

នរជននោះ ឱ្យទានរួចហើយ រមែងដល់នូវសេចក្តីតាំងមាំនៃភោគៈ និងមានអាយុយឺនយូរ តែងមានសូរសៀងពីរោះ និងមានរូបសម្បត្តិស្អាតអាស្រ័យនៅក្នុងវិមានទាំងឡាយ ដែលមានហ្វូងសត្វក្ងោកគួរឱ្យពេញចិត្តច្រើនប្រភេទ បន្ទឹសម្លេងលាន់ព្រមទាំងយកនោះតែងលេងកម្សាន្តជាមួយ ពួកទេវតាក្នុងឋានសួគ៌ ។

ចោរាវិរាជោឧកណាវកានំ ធនំ អសាធារណាមេវ ទានំ ឧទាតិ តំ

សាវកញ្ញាណភូមិ បច្ចេកភូមិ បន ពុទ្ធភូមិ ។

ទាននោះ មិនជាទ្រព្យទូទៅដល់សាធារណៈដល់ភ័យទាំង ឡាយ មានចោរភ័យ អរិយភ័យ (ភ័យពីសត្រូវ) រាជភ័យ ឧទកភ័យ និងអគ្គីភ័យទេ ទាននោះ គឺតែងឱ្យសម្រេចសាវក-ញ្ញាណភូមិ បច្ចេកភូមិ រហូតដល់ពុទ្ធភូមិ ។

(ចាក អដ្ឋកថា មធុរត្ថវិលាសនី)

អនុមោទនាវិសាខាគាថា

នៅក្នុងបិដកលេខ ៨, ទំព័រ ១៣៦ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់អំពី ***[អានិសង្សនៃការឱ្យទាន]*** *មានសេចក្តីថា ៖*

កាលឧបាសិកាវិសាខា បានថ្វាយទានដល់ព្រះភិក្ខុសង្ឃ ដែលមានព្រះសម្មាសម្ពុទ្ធជាប្រធានរួចហើយ ព្រះអង្គក៏ទ្រង់ធ្វើអនុមោទនាចំពោះនាងវិសាខា ដោយគាថាទាំងឡាយនេះថា ៖

យា អន្នបានំ ឧឧតី បមោទិតា សីលូប បន្នា សុគតស្សសាវិកា

ឧឆាតិ ឆានំ អភិភុយ្យ មច្ចរំ សោវគ្គិកំ សោកនុទំ សុខាវហំ

ឥតុំ ពលំ សាលភតេ ច អាយុំ អាគម្ម មគ្គំ វិរដំ អនន្តណាំ

សា បុញ្ញកាមា សុខីនី អនាមយា សគ្គម្ហិ កាយម្ហិ ចរំ បមោទតិ ។

ស្រីណាជាអ្នកឱ្យបាយ និងទឹក មានចិត្តរីករាយ មានសីលបរិបូណ៌ ជាសាវិការបស់ព្រះសុគត គ្របសង្កត់នូវសេចក្តីកំណាញ់ បានហើយឱ្យនូវទាន ស្រីនោះឯងតែងបាននូវផល គឺអាយុណ៍ដ៏ប្រសើរដោយប្រពៃ មានរូបជាដើម បានបន្ទោបង់នូវសេចក្តីសោក នាំមកនូវសេចក្តីសុខ មានកម្លាំងនឹងអាយុជាទិព្វ ស្រីនោះ ជាស្រីមានសេចក្តីប្រាថ្នានូវបុណ្យ មានសេចក្តីសុខ ឥតមានទុក្ខ តែងរីករាយក្នុងស្ថានសួគ៌ អស់កាលជាអង្វែង ព្រោះអាស្រ័យមគ្គចិត្តដ៏ប្រាសចាកធូលី មិនមានកិលេស(នោះឯង) ។

អានិសង្សរបស់ទាន ១៨ យ៉ាងគឺ

១- ទានំ សគ្គស្ស សោបាណាំ *ទានជាជណ្តើរឡើងកាន់ឋានសួគ៌*

២- ទានំ នេតិ ច សព្ពិយ *ទានរមែងធ្វើឱ្យបាន*

ឥស្សរិយយស

៣- ទានំ បវេសនំ សគ្គំ អ្នកឱ្យទានរមែងចូលទៅកាន់ឋានសួគ៌

៤- ទានំ ទ្វារំ វិវិតំ ទានចាត់ទុកដូចជាបើកទ្វារឋានសួគ៌

៥- ទានំឧលិទ្ធហារតំ ទានជាទីកំចាត់បង់នូវសេចក្តីទាល់ក្រ

៦- ទានំនាថំមនុស្សានំ ទានជាទីពឹងរបស់មនុស្សទាំងឡាយ

៥- ទានំ និរយំ មោចតិ ទានធ្វើឱ្យរួចចាកអំពីនរក

៦- ទានំ បវត្តតិ ភោគំ ទានជាទីហូរមកនៃភោគសម្បត្តិ

៧- ទានំ រក្ខតិជីវិតំ ទានធ្វើឱ្យអាចរក្សាជីវិតទុកបាន

៨- ទានំ ភោគំ ឧប្បដ្ឋតិ អ្នកឱ្យទានមានភោគសម្បត្តិកើតឡើងឯង

៩- ទានំ សហាយ សម្ភូត ទានអាចញុំាងមិត្តសម្ភាញ់ឱ្យកើតឡើងបាន

១០- សព្វកាមទទំ ទានំ ទានអាចឱ្យសម្រេចសេចក្តី

ប្រាថ្នាគ្រប់យ៉ាង

១១- កប្បរុក្ខូបមំ យថា ទានមានឧបមាដូចដើមកប្បព្រឹក្ស (ព្រោះអាចឱ្យសម្រេចនូវសេចក្តីប្រាថ្នាបាន)

១២- ធានំ សម្បត្តិ ភាជនំ ទានជាភាជន:សម្រាប់ទ្រទ្រង់ទុកនូវសម្បត្តិទាំងពួង

១៤- ធានំ អនុយាយី ច លោហជ្ជំ អ្នកឱ្យទានរមែងជួបប្រទះនូវបុគ្គលអ្នកមានចិត្តល្អ

១៦- ធានំ មោក្ខូបថវរំ ទានអាចឱ្យសម្រេចនូវព្រះនិព្វានបាន

១៧- ធានំ អបាយ សញ្ញនំ ទានអាចឱ្យបិទបាំងនូវអបាយបាន

១៨- ធានំ ពុទ្ធូគោចរំ ទានជាទីគោចរនៃព្រះពុទ្ធទាំងឡាយ ។ (ចាក.នានាធម្មសង្គហ:ទំព័រ៣០)

អានិសង្សរបស់ទានមួយទៀតគឺ

- សុខានំ និធានំ ទានជាដើមហេតុនៃសេចក្តីសុខទាំងពួង

- សម្បត្តីនំ មូលំ ទានជាឫសគល់នៃសម្បត្តិ
- ភោគានំ បតិដ្ឋា ទានជាទីតាំងនៃភោគៈ
- តាណំ ទានជាទីគេចពួនពីការក្រលំបាក
- លេណំ ទានជាគ្រឿងការពារភ័យក្នុងវដ្តៈ
- បរាយនំ ទានជាផ្លូវទៅកាន់សុគតិ
- អាវស្សយោ ទានជាទីពំនាក់អាស្រ័យ
- បតិដ្ឋា ទានជាទីពឹងរបស់សត្វលោក
- អារម្មណំ ទានជាទីតោងសម្រាប់យោងខ្លួន
- គតមគ្គោ ទានជាផ្លូវនៃព្រះពុទ្ធទាំងឡាយ
- ពុទ្ធវំសោ ទានជាវង្សនៃព្រះពុទ្ធទាំងឡាយ
- សគ្គសម្បត្តី ទានធ្វើឱ្យសម្រេចនូវសម្បត្តិព្រះឥន្ទ
- មារសម្បត្តី ទានធ្វើឱ្យបានសម្រេចនូវសម្បត្តិស្តេចមារ
- ព្រហ្មសម្បត្តី ទានធ្វើឱ្យសម្រេចសម្បត្តិព្រហ្ម
- ចក្កវត្តិសម្បត្តី ទានធ្វើឱ្យសម្រេចស្តេចចក្រពត្តិ

- សាវកបារមីញ្ញាណំ ទានធ្វើឱ្យសម្រេចជាសាវក-បារមីញ្ញាណ

- បច្ចេកពោធិញ្ញាណំ ទានធ្វើឱ្យសម្រេចជាបច្ចេក-ពោធិញ្ញាណ

- អភិសម្ពោធិញ្ញាណំ ទានធ្វើឱ្យសម្រេចនូវអភិ-សម្ពោធិញ្ញាណ ។

អានិសង្សថ្វាយបាយជាទាន

១- មានអាយុវែង ២- មានកម្លាំង
៣- មានប្រាជ្ញា ៤- មានពណ៌សម្បុរល្អ
៥- មានយស ៦- មានសេចក្តីសុខ
៧- ជាអ្នកបានបាយ ៨- ជាអ្នកបានទឹក
៩- ជាអ្នកក្លៀវក្លា ១០- ជាអ្នកប្រាជ្ញ ។

អានិសង្សថ្វាយបាយដ៏ប្រសើរ

១- បានទៅកើតឋានតាវត្តឹង្ស
២- បានជាមហេសីនៃស្តេចទេវតា ៣០ ដង

៣- ប្រាថ្នាអ្វីក្នុងចិត្តក៏កើតឡើងដូចសេចក្តីប្រាថ្នា

៤- បានជាមហេសីនៃស្តេចចក្រពត្តិ ២០ ដង

៥- មិនដែលស្គាល់ទុគ្គតិ

៦- បាននូវវិជ្ជា ៣បដិសម្ភិទា៤វិមោក្ខ៨អភិញ្ញា ៦ ។

(សុត្តន្តបិដកលេខ ៧៦, ទំព័រ ១០)

អានិសង្សថ្វាយចាយមួយវែក

១- បានទៅកើតក្នុងឋានតាវត្តឹង្ស

២- បានជាមហេសីនៃស្តេចទេវតា ៣៦ ដង

៣- បានជាមហេសីនៃស្តេចចក្រពត្តិ ៥០ ដង

៤- បានសម្បត្តិទាំងពួងតាមប្រាថ្នា

៥- មិនដែលស្គាល់ទុគ្គតិ

៦- បាននូវវិជ្ជា៣ បដិសម្ភិទា៤វិមោក្ខ ៨អភិញ្ញា ៦ ។

សុត្តន្តបិដកលេខ ៧៦, ទំព័រ ១២

អានិសង្សថ្វាយទឹកដោះគោជាទានមាន ៥ ប្រការ

១- មានកម្លាំង

២- បរិបូណ៌ដោយរូប(រូបស្អាត)

៣- ជាអ្នកមានចិត្តរីករាយ

៤- ជាអ្នកមានកូនសព្វគាល

៥- ជាអ្នកមិនមានជម្ងឺគ្រប់កាលទាំងពួង

➥ ទឹកដោះគោនេះ លោកកសង្រ្គោះចូលក្នុងភោជនដែរ ព្រោះជារបស់បរិភោគដូចគ្នា ។

អានិសង្សថ្វាយទឹកជាទាន

បានទៅកើតក្នុងឋានតាវត្តឹង្ស មានវិមានដ៏ល្អប្រសើរ ជាងពួកស្រីទេពអប្សរ ១០០០ នាក់ គ្រប់សង្កត់ពួកស្រីទាំងនោះ ដោយហេតុទាំងនេះគឺ

១- បានជាមហេសីនៃស្តេចទេវរាជ ៥០ ដង

២- បានជាមហេសីនៃស្តេចចក្រពត្តិ ២០ ដង

៣- កាលណាចង់បានទឹកលើកំពូលភ្នំក្តី លើចុងឈើក្តី ឰដ៏អាកាសក្តី លើផែនដីក្តី ក៏បាននូវទឹកយ៉ាងឆាប់

៤- ចង់បានទឹកកាលណា មហាមេឃក៏ញុំាងភ្លៀង ឱ្យកើតក្នុងកាលនោះ កម្ដៅក្តី សេចក្តីក្រហល់ក្រហាយក្តី មិនមានក្នុងសរីរៈកាយឡើយ

៥- មិនទៅកាន់ទុគ្គតិអស់ ៩១ កប្ប

៦- បាននូវវិជ្ជា៣បដិសម្ភិទា៤វិមោក្ខ ៨ អភិញ្ញា៦ ។

(សុត្តន្តបិដកលេខ ៧៦, ទំព័រ ២១)

អានិសង្សថ្វាយតែសម្តេចជាឧទាន

១- ជាអ្នកមានអាយុវែង

២- ជាអ្នកមានកម្លាំង

៣- ជាអ្នកមានប្រាជ្ញា

៤- ជាអ្នកមានពណ៌សម្បុរល្អ

៥- ជាអ្នកមានយស

៦- ជាអ្នកមានសេចក្តីសុខ

៧- ជាអ្នកមិនមានឧបទ្រព

៨- ជាអ្នកមិនមានចង្រៃ

៩- តែងមានគេគោរពកោតក្រែងគ្រប់កាល

១០- មិនដែលមានការព្រាត់ប្រាសចាកសត្វ នឹងសង្ខារជាទីស្រឡាញ់ ។

(សុត្តន្តបិដកលេខ ៧៤, ទំព័រ ១៥១)

អានិសង្សថ្វាយទឹកឃ្មុំជាទាន

១- បានរីករាយក្នុងទេវលោកអស់ ៣ ម៉ឺនកប្ប ភ្លៀងទឹកឃ្មុំបង្អុរចុះមក

២- ជាអ្នកបានបាយជាប្រក្រតី នឹងទឹក

៣- កើតក្នុងមនុស្សលោកនឹងទេវលោក

៤- ជាអ្នកបានសម្រេចនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង

៥- មិនទៅកាន់ទុគ្គតិអស់ ៣ ម៉ឺនកប្ប

៦- បាននូវវិជ្ជា ៣បដិសម្ភិទា៤វិមោក្ខ ៨អភិញ្ញា៦ ។

(សុត្តន្តបិដកលេខ ៧៤, ទំព័រ ១៨៣)

អានិសង្សថ្វាយសប្បិជាទាន

[ទឹកដោះរាវ ទឹកដោះថ្លា]

១- កើតជាទេវតា ឬជាមនុស្សតែងបានសេចក្តីសុខ

២- បានដល់នូវអចលបទ គឺព្រះនិព្វាន

៣- បានជាស្តេចទេវតាអស់ ៥៤ ដង

៤- បានជាស្តេចចក្រពត្តិអស់ ៥១ ដង

៥- បាននូវភោគៈប្រមាណមិនបាន

៦- មិនទៅកាន់ទុគ្គតិអស់ ៣០ ពាន់កប្ប

៧- មិនដែលសូមសប្បិអ្នកដទៃ

៨- សប្បិកើតឡើងតាមសេចក្តីប្រាថ្នា

៩- បាននូវសម្ផត់ គ្រឿងក្រអូប សប្បិ និងវត្ថុដទៃប្រព្រឹត្ត ទៅក្នុងបច្ចុប្បន្ន

១០- បាននូវសប្បិរាប់មិនអស់

១០-មានសតិបដ្ឋានជាទីដេកមានសមាធិជ្ឈានជាគោចរ ។

(សុត្តន្តបិដកលេខ ៧៤, ទំព័រ ២២៥)

រឿងព្រះបាទនន្ទរាជ

ក្នុងអតីតកាល កុដុម្ពីក៍ម្នាក់ ជាអ្នកនៅក្នុងទីក្រុងពារាណសី ត្រាច់ទៅក្នុងព្រៃ បានឃើញសំពត់អនុវាតរបស់ព្រះបច្ចេកពុទ្ធ លោកកំពុងធ្វើចីពរមិនគ្រប់គ្រាន់ ទើបបានប្រគេនសំពត់ដណ្តប់ របស់ខ្លួន ។ កុដុម្ពីក៍នោះបានទៅកើតក្នុងភពតាវត្តិង្ស ព្រោះកម្មនោះ សោយទូវទិព្វសម្បត្តិច្យុតចាកភពតាវត្តិង្សនោះហើយ ក៏បានមក កើតក្នុងត្រកូលនៃអមាត្យ ក្នុងទីប្រមាណមួយយោជន៍អំពីក្រុង ពារាណសី បានចម្រើនពេញវ័យហើយ ក្នុងថ្ងៃនក្ខត្តឫក្សបានពោល ថា បពិត្រអ្នកម្តាយ សូមអ្នកម្តាយឱ្យសំពត់សាដកដល់ខ្ញុំ ខ្ញុំនឹង លេងនក្ខត្តឫក្ស ។ មាតានោះបានឱ្យសំពត់ស (ប៉ុន្តែ)កាលកូន

នោះពោលថា សំពត់នេះសាច់មិនល្អទេ ដូច្នេះ, ទើបបានឱ្យសំពត់ផ្សេងទៀត ។ កូននោះហាមនូវសំពត់នោះទៀត ។ ម្តាយនោះពោលថា ក្នុងផ្ទះរបស់យើងគ្មានសំពត់ល្អជាងនេះទេ ។ កូននោះពោលថា បពិត្រអ្នកម្តាយ ខ្ញុំនឹងទៅកន្លែងដែលបាន ។ ម្តាយនោះបានពោលថា នែ៎កូន ម្តាយប្រាថ្នាចង់ឱ្យកូនឯង បាននូវរាជសម្បត្តិក្នុងក្រុងពារាណសី ក្នុងថ្ងៃនេះទៀតផង ។ កូននោះពោលថា បពិត្រអ្នកម្តាយ ប្រពៃហើយ ដូច្នេះ ថ្វាយបង្គំមាតាត្រូវនិយាមនៃបុណ្យជាស់តឿន ហើយក៏ទៅកាន់ក្រុងពារាណសីដេកដណ្តប់គ្រប់នូវអវយវៈព្រមទាំងក្បាលលើផ្ទាំងសិលាដែលជាមង្គលក្នុងឧទ្យាន ក៏ថ្ងៃនោះ ជាថ្ងៃទី ៧ នៃព្រះរាជាក្រុងពារាណសី ទ្រង់បានទីវង្គតទៅ ។ ជនទាំងឡាយមានអាមាត្យជាដើម បានបូជានូវព្រះសរីរៈកិច្ចរបស់ព្រះរាជាហើយ ទើបប្រឹក្សាគ្នាថា ព្រះរាជាទ្រង់មានព្រះរាជធីតាតែមួយព្រះអង្គប៉ុណ្ណោះ គ្មានព្រះរាជឱរសទេ រាជសម្បត្តិដែលប្រាសចាកព្រះរាជានឹងតាំងនៅពុំបានឡើយ ដូច្នេះហើយ កាលនឹងលែងបុស្សរថ (រថ មានពណ៌ស) ទៅបានទឹមសេះសិន្ធ ៤ ដែលមានសម្បុរ ដូចជាផ្កាកុមុទ ហើយបានតាំងរាជកុក្កុធភ័ណ្ឌ ៥ ប្រការ លើរថស្រេចហើយ ក៏លែងរថទៅ

រថបានចេញទៅតាមមាត់ទ្វារទិសខាងកើត ចូលកាន់ឧទ្យានធ្វើប្រទក្សិណកុមារនោះ មិនទៅណា ។ បុរោហិតបានបើកជាយសំពត់ដែលដណ្តប់ ហើយត្រួតពិនិត្យមើលផ្ទៃនៃបាទជើង ពោលថា កុមារនេះសមគួរហើយ ដើម្បីគ្រប់គ្រងរាជសម្បត្តិ ដូច្នេះហើយឱ្យគេប្រគំនូវដូរតន្ត្រីអស់វារៈ ៣ ដង ។ គ្រានោះកុមារបានបើកមុខឡើងហើយពោលថា បពិត្រលោកឪពុក តើមានហេតុអ្វី ។ បុរោហិតពោលថា បពិត្រលោកម្ចាស់ រាជសម្បត្តិរមែងសម្រេចដល់លោកម្ចាស់ ។ កុមារសួរថាចុះព្រះរាជារបស់អ្នកទាំងឡាយស្តេចយាងទៅណា ។ បុរោហិតពោលថា បពិត្រលោកម្ចាស់ ព្រះអង្គទ្រង់ស្តេចទីវង្គតទៅហើយ ។ កន្លងទៅបានប៉ុន្មានថ្ងៃហើយ ? ។ បុរោហិតពោលថា ថ្ងៃនេះជាថ្ងៃទី ៧ ។ កុមារសួរថា ព្រះរាជឪរសក្តី ព្រះរាជធីតាក្តី មិនមានទេ ។ បុរោហិតពោលថា បពិត្រលោកម្ចាស់ មានតែព្រះរាជធីតា តែព្រះរាជឪរសមិនមានទេ ។ កុមារពោលថា បើដូច្នោះខ្ញុំនឹងគ្រប់គ្រងនូវរាជសម្បត្តិ ពួកអាមាត្យទាំងនោះ នាំគ្នាធ្វើមណ្ឌបសម្រាប់អភិសេកក្នុងពេលនោះភ្លាម ហើយក៏បានអភិសេកក្នុងមណ្ឌបនោះ រួចហើយបានបង្អោនសំពត់ដែលមានតម្លៃ ១ ពាន់ ចូលទៅថ្វាយ ។ ព្រះរាជា

អង្គនោះ មានព្រះរាជឱង្ការថា សំពត់នេះមានសាច់មិនល្អ អ្នកទាំងឡាយចូរនាំយកកុន្ទីទឹកមាសមក ខ្ញុំនឹងបាននូវសំពត់ ដូច្នេះហើយ ស្តេចក្រោកឡើងទ្រង់យកព្រះហស្តក្បង់ទឹកហើយទ្រង់សាច់ទៅទិសខាងកើត ។ ដើមកប្បព្រឹក្ស ៨ ដើមបានទំលាយផែនដីដ៏ក្រាស ផុសឡើង ហើយក្នុងពេលនោះភ្លាម ។ ដើមកប្បព្រឹក្ស ៨ ដើម ផុសឡើងហើយត្រង់ទិសទក្សិណ ៨ ដើម ផុសឡើងហើយត្រង់ទិសបស្ចឹម ៨ ដើម ផុសឡើងហើយត្រង់ទិសឧត្តរដោយឧបាយនេះ ។ ដើមកប្បព្រឹក្សទាំងអស់មាន ៣២ ដើម ដុះឡើងហើយដោយប្រការដូច្នេះ ។ ព្រះរាជាអង្គនោះ ទ្រង់ស្លៀកសំពត់ទិព្វ ១ ទ្រង់បានដណ្តប់សំពត់ទិព្វ ១ ទ្រង់ត្រាស់បញ្ជាឱ្យពួកអាមាត្យវាយស្គរជ័យឃោសនាក្នុងរាជធានីរបស់ព្រះបាទនន្ទរាជថា ស្រីទាំងឡាយកុំគ្បាញសូត្រឡើយ ហើយទ្រង់ត្រាស់បញ្ជាឱ្យលើកឆត្រឡើង ។ ឱ្យស្តេចឡើងលើកដ៏រីដ៏ប្រសើរ ទ្រង់យាងចូលទៅព្រះនគរ ស្តេចឡើងលើប្រាសាទទ្រង់សោយនូវមហាសម្បត្តិ គ្រប់គ្រងរដ្ឋធានីរបស់ព្រះអង្គទាំងអស់ ប្រៀបដូចជាឧត្តរកុរុទ្វីប ទ្រង់បានព្រះរាជទានសំពត់ទិព្វទាំងឡាយ ដល់មនុស្សទាំងឡាយដែលបានមកហើយ ក្រោយមកទ្រង់បានសាងព្រះផ្នួស ព្រមទាំងព្រះទេវី

នៅក្នុងព្រះឧទ្យាន ញុំាងឈានឱ្យកើតឡើង ហើយមានឈានមិនសាបសូន្យ ហើយបានទៅកើតក្នុងព្រហ្មលោក ។ ក្នុងពេលនេះ ពុទ្ធកាលព្រះរាជាអង្គនោះបានកើតជាព្រះមហាកស្សបត្ថេរៈព្រះទេវីបានមកកើតជានាងភទ្ទកាបិលានី ដូច្នេះឯង ។

រឿងព្រះធេវីព្រះនាមគោបាលមាតា

ក្នុងចន្លោះផ្លូវទៅកាន់នគរឧជ្ជេនី មានទិគមមួយឈ្មោះតេលនាឡី ។ ក្នុងទិគមនោះ មានធីតារបស់សេដ្ឋីពីរនាក់ ធីតាម្នាក់ជាអ្នកក្រីក្រ ដោយកាលកន្លងទៅនៃមាតាបិតា អាស្រ័យនូវស្រីមេនំចិញ្ចឹមជីវិត ជាអ្នកមានខ្លួនស្អាតស្រស់ មានសក់វែងជាងពួកស្រីឯទៀត ធីតាម្នាក់ជាអ្នកស្តុកស្តម្ភ តែមិនមានសក់ ។ ក្នុងគ្រានោះ ព្រះមហាកច្ចាយនត្ថេរៈ ព្រមទាំងភិក្ខុ ៧ រូប មានប្រាថ្នានឹងក្រាបទូលនូវការកើតឡើងនៃព្រះពុទ្ធ ដល់ព្រះរាជាព្រះនាមចណ្ឌបជ្ជោត ទើបនិមន្តទៅកាន់ក្រុងឧជ្ជេនី ដល់ទិគមនោះហើយក៏ចូលទៅបិណ្ឌបាតក្នុងទិគមនោះ (តែ)ឥតបានវត្ថុអ្វីឡើយ ។ សេដ្ឋីធីតាដែលមានសក់វែងដ៏ងរឿងនោះហើយក៏បញ្ជូនស្រីមេនំទៅដោយប្រាប់ថា ចូរនាងនិមន្តព្រះថេរៈទាំងឡាយ ហើយឱ្យគង់

ក្នុងផ្ទះ ។ ស្រីនោះបានធ្វើយ៉ាងដូច្នោះ ។ សេដ្ឋីធីតាបានចូលទៅកាន់បន្ទប់ ហើយឱ្យស្រីមេនំកាត់សក់របស់ខ្លួន បញ្ជូនទៅហើយដោយប្រាប់ថា នែនាង ចូរនាងឱ្យសក់ទាំងនេះ ដល់សេដ្ឋីធីតាដែលមិនមានសក់ ឈ្មោះនុ៎ះ ធីតារបស់សេដ្ឋីនោះ ឱ្យនូវវត្ថុអ្វី ចូរនាំយកវត្ថុនោះមក ពួកយើងនឹងប្រគេនបិណ្ឌបាតដល់ព្រះគុណម្ចាស់ទាំងឡាយដោយវត្ថុនោះ ។ នាងបានធ្វើយ៉ាងដូច្នោះហើយ បានទទួលយកទ្រព្យ ៨ កហាបណៈមកឱ្យហើយ ដល់សេដ្ឋីធីតាដែលមានសក់ ។ សេដ្ឋីធីតានោះបានធ្វើបិណ្ឌបាតមួយ ឱ្យទៅជាមួយកហាបណៈ ហើយញុំាងបុគ្គលឱ្យប្រគេនហើយដល់ព្រះថេរៈទាំងឡាយ ខ្លួនឯងនៅក្នុងបន្ទប់ ។ ព្រះមហាកច្ចាយនត្ថេរៈ ដ៏ងហេតុការណ៍នោះហើយ បានឱ្យបុគ្គលទៅហៅសេដ្ឋីធីតានោះមក ។ សេដ្ឋីធីតានោះ បានមកហើយ ព្រោះសេចក្តីគោរពចំពោះព្រះថេរៈ ថ្វាយបង្គំព្រះថេរៈហើយ ក៏បានញុំាងសទ្ធាជ្រះថ្លាដ៏មានកម្លាំងឱ្យកើតឡើងហើយ ។ ឈ្មោះថា ទាន ដែលនាងប្រគេនហើយក្នុងខេត្តដ៏ល្អ រមែងឱ្យនូវវិបាកក្នុងបច្ចុប្បន្នទាន់ភ្នែក ព្រោះហេតុនោះ សក់ទាំងឡាយរបស់នាងបានដុះឡើងវិញ ហើយក្នុងភាវៈតាម

ប្រក្រតីភ្លាមជាមួយគ្នានឹងការថ្វាយបង្គំព្រះថេរៈ ។ ព្រះថេរៈទាំងឡាយ ទទួលបិណ្ឌបាតហើយ កាលសេដ្ឋីធីតានោះ ឃើញទុំ៉ះឯង ក៏ហោះទៅឋិតនៅកាន់អាកាសវេហាស៍បានចុះក្នុងឧទ្យាន ឈ្មោះកាញ្ចនវែន ហើយធ្វើនូវភត្តកិច្ច ។ បុគ្គលអ្នករក្សាឧទ្យាន ឃើញព្រះថេរទាំងឡាយហើយ ក៏បានក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាស្តេចយាងទៅកាន់ព្រះរាជឧទ្យាន ទ្រង់ទតព្រះនេត្រឃើញព្រះថេរៈទាំងឡាយ ហើយទ្រង់បានត្រាស់សួរថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន ក្នុងថ្ងៃនេះ ព្រះគុណម្ចាស់ទាំងឡាយបានហើយនូវភិក្ខាក្នុងទីឯណា ? ដូច្នេះ ទ្រង់ព្រះសណ្តាប់រឿងនោះហើយ ទ្រង់ស្តេចយាងទៅដំណាក់ ត្រាស់ឱ្យនាំសេដ្ឋីធីតានោះមកក្នុងថ្ងៃនោះឯង ហើយទ្រង់បានអភិសេកនាងជាអគ្គមហេសី ។

ក្នុងកាលក្រោយមក ព្រះនាងទ្រង់បានប្រសូតព្រះរាជបុត្រ បានយកឈ្មោះរបស់សេដ្ឋី ដែលជាអយ្យការរបស់ព្រះរាជឪរសថ្វាយព្រះនាមថា គោបាល ចំណែកព្រះនាងប្រាកដនាមថា គោបាលមាតាទេវី ដោយអំណាចព្រះនាមរបស់ព្រះរាជឪរស ទ្រង់ជ្រះថ្លាហើយយ៉ាងក្រៃលែងចំពោះព្រះថេរៈ ទ្រង់បានឱ្យបុគ្គល

កសាងព្រះវិហារថ្វាយព្រះថេរៈហើយ ក្នុងព្រះរាជឧទ្យានឈ្មោះកាញ្ចនវែន ដូច្នេះឯង ។

(អដ្ឋកថា ឯកនិបាត អង្គុត្តរនិកាយ)

អានិសង្សបុណ្យទាន

- វីការធ្វើទាន ធ្វើបានជាស្ពាន ឈានទៅសួគ៌សុខ
ធ្វើបានជាទុន ទុកទៅជាតិមុខ កើតក្នុងសំបុក
សម្បត្តិភោគទ្រព្យ ។
- ទានមានអង្គបី ឱ្យផលក្រាស់ក្រៃ ប្រសើរគួរគាប់
ទីមួយទេយ្យធម៌ សមគួរដល់ទ្រព្យ ទីពីរនោះភ្ជាប់
នឹងចិត្តជ្រះថ្លា ។
- រីឯទីបី អ្នកទទួលទេ- យ្យធម៌នោះណា
បរិបូណ៌ដោយគុណ ទើបមានផលា អានិសង្សា
ថ្លៃថ្លាកន្ធង ។
- ទោះបីមានទ្រព្យ តែមិនបានភ្ជាប់ អង្គបីនេះផង
ធ្វើច្រើនយ៉ាងណា តែខុសគន្ធង ច្រើនតែសៅហ្មង
ផលបានពុំគាប់ ។
- អ្នកសោយបុណ្យចាស់ កើតមកប្រទះ លើគំនរទ្រព្យ

តែមិនចេះប្រើ ដោយផ្លូវគួរគាប់ មុខតែអភ័ព្វ
ក្នុងជាតិខាងមុខ ។
- អ្នកសាងបុណ្យថ្មី មានពីរអត្ថន័យ ផ្សេងទាំងក្តីសុខ
អ្នកមួយសាងកម្ម ជាទ្រព្យកប់ទុក កប់តស៊ីចុក
ទុកចាយជាតិក្រោយ ។
- អ្នកសាងមា៉ងទៀតព្រោះលះបង់ជាតិចេញចាកភពបី
ប្រាថ្នានិព្វាន ស្ថានសុខសិរី ឥតមានសុខអ្វី
អាចប្រៀបផ្ទឹមបាន ។

ពួជដែលបុគ្គលព្រោះហើយ សូម្បីតិចក្នុងស្រែដ៏ល្អ កាលភ្លៀងធ្លាក់ស្រួល ផលរមែងញុំាងអ្នកស្រែឱ្យត្រេកអរបានជួចម្តេចមិញ សក្ការៈដែលបុគ្គលជំកល់ទុកហើយ សូម្បីតិចក្នុងតាទិបុគ្គលទាំងឡាយ មានសីលមានគុណ បុណ្យរមែងមានផលច្រើន ក៏ដូច្នោះឯង ។

ការឱ្យទានជារឿងរបស់សេចក្តីត្រជាក់នៃចិត្ត អ្នកដែលមិនឱ្យនូវទានរឿយ ៗ រមែងមានចិត្តផួរផង់ បុគ្គលដែលមានការឱ្យទានមិនជាច់ រមែងមានចិត្តមិនក្តៅក្រហាយក្នុងរឿងរបស់អ្នកដទៃ មានតែចិត្តយោគយល់អធ្យាស្រ័យ មេត្រីភាពដល់មនុស្សសត្វ

ផងគ្នា ។ ម្យ៉ាងទៀតចិត្តរបស់មនុស្សយើងនេះមានអំណាចមានសមត្ថភាពអាចរកទ្រព្យបាន បើអ្នកណាសន្សំការឱ្យនិងការលះបង់មកច្រើន កើតជាតិណា ៗ រមែងជាអ្នកមានទ្រព្យសម្បត្តិច្រើន ។ បើអ្នកណាមានទូវសេចក្តីកំណាញ់មានលោភៈច្រើន និងមានទ្រព្យតិចនៅពេលដែលខ្ជនកើត ដូចពាក្យដែលព្រះអង្គទ្រង់ត្រាស់ទុកថា ៖

អ្នកមានទ្រព្យសម្បត្តិច្រើន ព្រោះជាអ្នកធ្លាប់ឱ្យទានមកច្រើន ។

សូម្បីព្រះសម្មាសម្ពុទ្ធជាម្ចាស់ ក៏ទ្រង់ត្រាស់សរសើរទានមកច្រើនលក្ខណៈ ដូចតទៅនេះ ៖

- **បុគ្គលគួរឱ្យក្នុងវត្ថុដែលគួរឱ្យ**
- **ការជ្រើរើសហើយឱ្យ ព្រះសុគតទ្រង់សរសើរ**
- **បុគ្គលពាលប៉ុណ្ណោះ ដែលមិនសរសើរការឱ្យទាន**
- **កាលមានចិត្តជ្រះថ្លាហើយ ទក្ខិណាទានឈ្មោះថាមានផលតិចមិនមាន**
- **បុណ្យរបស់អ្នកឱ្យរមែងចំរើនទៅមុខ**
- **អ្នកឱ្យរមែងចងមិត្តទុកបាន**

- អ្នកឱ្យរមែងជាទីស្រឡាញ់របស់ពួកជនច្រើន

- អ្នកមានបញ្ញា កាលឱ្យសេចក្តីសុខដល់អ្នកដទៃ រមែងបានទទួលសេចក្តីសុខមកវិញ ។

- អ្នកឱ្យបាយ ឈ្មោះថា ឱ្យកម្លាំង

- អ្នកឱ្យសម្ពត់ ឈ្មោះថា ឱ្យពណ៌សម្បុរ

- អ្នកឱ្យយាន ឈ្មោះថា ឱ្យសេចក្តីសុខ

- អ្នកឱ្យប្រទីប ឈ្មោះថា ឱ្យចក្ខុគឺភ្នែក

- អ្នកឱ្យទីសំណាក់អាស្រ័យ ឈ្មោះថា ឱ្យវត្ថុគ្រប់យ៉ាង ។

- អ្នកឱ្យធម្មទាន ឈ្មោះថា ឱ្យព្រះនិព្វាន

- អ្នកឱ្យរបស់ជាទីពេញចិត្ត រមែងបានរបស់ជាទីពេញចិត្តវិញ

- អ្នកឱ្យវត្ថុដ៏លើស រមែងបានវត្ថុដ៏លើសវិញ

- អ្នកឱ្យរបស់ល្អ រមែងបានរបស់ល្អវិញ

- អ្នកឱ្យទីហានដ៏ប្រសើរ រមែងចូលទៅកាន់ទីហានដ៏ប្រសើរវិញ ។

៨. នរជនប្រុសស្រីឯណា ឱ្យរបស់ដែលលើស ឱ្យ

របស់ដែលល្អនិងទីហានដ៏ប្រសើរ, នរជននោះកើតនៅក្នុងទី រមែងជាអ្នកមានអាយុយឺនយូរ មានយសក្នុងទីនោះ ៗ ។

៣. កាលបើផ្ទះត្រូវភ្លើងឆេះហើយ បុគ្គលនាំចេញនូវ ភាជន៍ណាទាន់ ភាជន៍នោះ រមែងបានជាប្រយោជន៍នៃបុគ្គលនោះ ភាជន៍ណា ដែលភ្លើងឆេះក្នុងផ្ទះនោះ ភាជន៍នោះ មិនបានជា ប្រយោជន៍នៃបុគ្គលនោះឡើយ ។

៤. សត្វលោកកាលបើត្រូវជរា និងមរណៈឆេះយ៉ាង នេះហើយ បុគ្គលគួរតែនាំចេញនូវទ្រព្យដោយការឱ្យទាន ព្រោះ ទ្រព្យដែលបុគ្គលឱ្យហើយ ឈ្មោះថា នាំចេញហើយដោយ ប្រពៃ ។

៥. ពួជដែលបុគ្គលព្រោះហើយ សូម្បីមានប្រមាណច្រើន ក្នុងស្រែទួលផល រមែងមិនបរិបូណ៌ទាំងមិនញុំាងអ្នកស្រែឱ្យ ត្រេកអរបាន ជួចម្តេចមិញ ទានដែលបុគ្គលជំកល់ទុកហើយ មាន ប្រមាណច្រើន ក្នុងបុគ្គលទ្រុស្តសីលទាំងឡាយ ផលរមែងមិន បរិបូណ៌ទាំងមិនបានញុំាងទាយកឱ្យត្រេកអរបានក៏ដូច្នោះឯង ។

នៅក្នុងទីនេះ ដើម្បីឱ្យសម្រេចទៅជាអាមិសទានបាននោះ

ត្រូវអាស្រ័យចេតនានិងទេយ្យធម៌ជាប្រមាណ ទើបអាចសម្រេចជាអាមិសទានបាន សមដូចពាក្យដែលព្រះដ៏មានព្រះភាគព្រះអង្គទ្រង់ត្រាស់ថា ចេតនាហំ ភិក្ខវេ បុញ្ញំ វទាមិ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា **ចេតនាជាតួបុណ្យ** ។

បន្ទាប់អំពីយើងបានយល់ពាក្យថា **ទាន** នេះហើយ តទៅខ្ញុំព្រះករុណាសូមលើកយកអានិសង្សនៃការធ្វើទាន ដែលមានសម្តែងនៅក្នុងគម្ពីរព្រះត្រៃបិដក និងនៅក្នុងព្រះអដ្ឋកថា ដែលមានសេចក្តីដូចតទៅនេះ ៖

ទានញ្ហេ ឯតម្មង្គលមុត្តមំ

☝.ភិរិយោយបំពេញទាន នេះជាមង្គលដ៏ឧត្តម ។

មង្គលកថា មង្គលទី ១៥ ចប់

គម្ពីរជាឧបករណ៍ក្នុងការរៀបរៀងសៀវភៅនេះ

-គម្ពីរព្រះត្រៃបិដករបស់ពុទ្ធសាសនបណ្ឌិត ព.ស.២៥៥៧
-អដ្ឋកថាពន្យល់សេចក្តីនៃគម្ពីរព្រះត្រៃបិដក.ស.២៥២២
-មង្គលត្ថទីបនីភាគ ១ របស់ព្រះមហាយិន នឿន ព.ស.២៥៣៨
-គម្ពីរឃ្លាំងបរិយត្តិភាគ ១-២ ព.ស. ២៥៥៧
-គម្ពីរធម្មាវលី របស់ភិក្ខុធម្មវាចារ្យ
-មង្គលជីវិត របស់ព្រះភិក្ខុ វជិប្បញ្ញោ គូ សុភាព ព.ស.២៥៥៥
-វចនានុក្រម សម្តេចព្រះសង្ឃរាជ ជួន ណាត ព.ស. ២៥១១
-ព្រមទាំងឯកសារមួយចំនួនទៀត។

ថ្ងៃល្អនៃជីវិត

នៅក្នុងបិដកលេខ ៤១ ទំព័រ ៤៧៩ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ទ្រង់ត្រាស់ជាមួយនឹងភិក្ខុថាម្នាលភិក្ខុទាំងឡាយសត្វទាំងឡាយណាប្រព្រឹត្តសុចរិតដោយកាយប្រព្រឹត្តសុចរិតដោយវាចាប្រព្រឹត្តសុចរិតដោយចិត្តក្នុងវេលាព្រឹកវេលាថ្ងៃវេលាល្ងាចសត្វទាំងនោះឈ្មោះថាមានវេលាព្រឹត្តដ៏ល្អវេលាថ្ងៃដ៏ល្អវេលាល្ងាចដ៏ល្អ។ សមដូចព្រះគាថាថា៖

សុនក្ខត្តំ សុមង្គលំ សុបភាតំ សុហុដ្ឋិតំ
សុខណោ សុមុហុត្តោ ច សុយិដ្ឋំ ព្រហ្មចារិសុ។

ថ្ងៃណាដែលសត្វទាំងឡាយប្រព្រឹត្តល្អដោយកាយវាចាចិត្តថ្ងៃនោះឈ្មោះថា នក្ខត្តបឫក្សល្អ មង្គលល្អ ថ្ងៃក្លឹស្វាងល្អ ថ្ងៃនៃអរុណរះឡើងល្អ ខណៈល្អ យាមល្អ (ទានដែលបុគ្គលបូជាហើយ)ដល់ព្រហ្មចារីបុគ្គលទាំងឡាយ (ក្នុងពេលនោះឈ្មោះថាជាគ្រឿងបូជាល្អ។